CAO COMPLIANCE ADVISOR OMBUDSMAN

*The Independent Accountability Mechanism for IFC & MIGA*

ខែតុលា ឆ្នាំ២០២៥

# របាយការណ៍ស៊ើបអង្កេតភាពអនុលោម ស្ដីពីការពាក់ព័ន្ធរបស់ IFC ទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា (អេស៊ីលីដា អម្រិត ធនាគារហត្ថា អិលអូអិលស៊ី ប្រាសាក់ និងស្ថាបនា)

គម្រោង IFC លេខ #២១៨៥៦, #២៧៨២៧, #៣១៤៦៧, #៣៤៧៤៨, #៣៨៦០៩, #៣៩១៦៧, #៤១២៩៤, #៤២៤៨០, #៤៤២១១, #៤៤២៣១, #៤៤៧៤២, #៤៤៨៨២, #៤៥៥៣៥

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥

## អំពីស៊ីអេអូ

ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) គឺជាយន្តការគណនេយ្យភាពឯករាជ្យរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសមាជិកក្រុមធនាគារពិភពលោក។ យើងធ្វើការសម្របសម្រួលដោះស្រាយបណ្តឹងពីប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីគម្រោងរបស់ IFC និង MIGA ដោយយុត្តិធម៌ ឥតលម្អៀង និងប្រកបដោយភាពស្ថាបនា លើកកម្ពស់លទ្ធផលផ្នែកបរិស្ថាន និងសង្គមនៃគម្រោងទាំងនោះ និងបង្កើនគណនេយ្យភាពសាធារណៈ និង ការរៀនសូត្រនៅ IFC និង MIGA។

ស៊ីអេអូ គឺជាការិយាល័យឯករាជ្យ ដែលរាយការណ៍ទៅកាន់ក្រុមប្រឹក្សានាយកប្រតិបត្តិការរបស់ IFC និង MIGA ដោយផ្ទាល់។ សម្រាប់ព័ត៌មានបន្ថែម សូមមើល www.cao-ombudsman.org។

## អំពីមុខងារត្រួតពិនិត្យភាពអនុលោម

មុខងារត្រួតពិនិត្យភាពអនុលោមរបស់ស៊ីអេអូ ត្រួតពិនិត្យឡើងវិញលើភាពអនុលោមរបស់ IFC និង MIGA ចំពោះគោលនយោបាយបរិស្ថាន និងសង្គម វាយតម្លៃលើការខូចខាតដែលពាក់ព័ន្ធ និងផ្តល់អនុសាសន៍អំពីវិធានការដោះស្រាយដែលសមស្រប។

មុខងារត្រួតពិនិត្យភាពអនុលោមរបស់ ស៊ីអេអូ អនុវត្តតាមអភិក្រម បីជំហាន៖

**ការវាយតម្លៃ**

ត្រួតពិនិត្យជាបឋម ដើម្បីកំណត់ថាតើពាក្យបណ្តឹង ឬសំណើផ្ទៃក្នុងចាំបាច់ត្រូវធ្វើការស៊ើបអង្កេតភាពអនុលោមដែរឬទេ។

**ការស៊ើបអង្កេត**

ការកំណត់ជាប្រព័ន្ធ និងប្រកបដោយសត្យានុម័ត ថាតើ IFC/MIGA បានអនុលោមតាមគោលនយោបាយបរិស្ថាន និងសង្គមរបស់ខ្លួនដែរឬទេ និងថាតើមានការខូចខាត ពាក់ព័ន្ធនឹងបដិលោមភាពណាមួយដែរឬទេ។

**ការពិនិត្យតាមដាន**

ការផ្ទៀងផ្ទាត់អំពីការអនុវត្តវិធានការគ្រប់គ្រង ដែលត្រូវបានបង្កើតឡើងឆ្លើយតបនឹងរបកគំហើញ និងអនុសាសន៍ពីការស៊ើបអង្កេតអំពីភាពអនុលោមប្រកបដោយប្រសិទ្ធភាព។

# តារាងមាតិកា

១. សាវតា ........ 1

១.១ ការវិវត្តនៃវិស័យបរិយាប័ន្នហិរញ្ញវត្ថុនៅលើពិភពលោក ........ 1

១.២ មីក្រូហិរញ្ញវត្ថុ និងបំណុលវ័ណ្ឌកនៅកម្ពុជា ........ 5

២. ការវិនិយោគរបស់ IFC នៅក្នុងស្ថាប័នហិរញ្ញវត្ថុចំនួនប្រាំមួយ ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងរបស់ស៊ីអេអូ ........ 11

២.១.១ អេស៊ីលីដា និង ក្រុមហ៊ុន North Haven Thai ........ 12

២.១.២ អម្រឹត និង Advans ........ 14

២.១.៣ ធនាគារហត្ថា ........ 16

២.១.៤ MEF ........ 17

២.១.៥ MIFA ........ 21

៣. ការស៊ើបអង្កេតអំពីភាពអនុលោម ........ 22

៣.១ ពាក្យបណ្តឹង ........ 22

៣.២ ការវាយតម្លៃរបស់ស៊ីអេអូ ........ 25

៣.៣ ការឆ្លើយតបរបស់ IFC ........ 26

៣.៤ ការវាយតម្លៃរបស់ស៊ីអេអូ ........ 28

៣.៥ វិសាលភាពនៃការស៊ើបអង្កេត ........ 28

៣.៦ វិធីសាស្ត្រស៊ើបអង្កេត ........ 30

៣.៧ គោលនយោបាយ IFC ស្តង់ដារ និងការអនុវត្តការវិនិយោគមីក្រូហិរញ្ញវត្ថុ ដែលពាក់ព័ន្ធ ........ 32

៣.៧.១ គោលនយោបាយរបស់ IFC ដែលពាក់ព័ន្ធ ........ 32

៣.៧.២ ខ្សែបន្ទាត់ពេលវេលាសម្រាប់ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) ដែលពាក់ព័ន្ធ បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា និងការវិនិយោគរបស់ IFC ........ 39

៣.៧.៣ ការគូសបញ្ជាក់អំពី GIIP នៅក្នុងការវិនិយោគមីក្រូហិរញ្ញវត្ថុ ........ 43

៤. ការវិភាគ និងគំហើញ ........ 44

៤.១ អភិក្រមទូទៅរបស់ IFC ចំពោះការត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគ (ESDD) និងការត្រួត

**ពិនិត្យការវិនិយោគមីក្រូហិរញ្ញវត្ថុ ...... 45**

**៤.២ ការពិចារណាលើសមិទ្ធកម្ម E&S នៃគម្រោង និងអនុគម្រោងរបស់ IFC ទាក់ទងនឹងបញ្ហានៃពាក្យបណ្តឹង ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យរបស់ IFC ...... 51**

៤.២.១ ការពិចារណាអំពីសមិទ្ធកម្មបរិស្ថាន និងសង្គមរបស់ IFC ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃ PS1 ពាក់ព័ន្ធនឹងប្រជាជនដែលងាយរងគ្រោះ ...... 52

៤.២.២ ការពិចារណាអំពីសមិទ្ធកម្មបរិស្ថាន និងសង្គមរបស់ IFC ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃ PS7 ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ...... 72

៤.២.៣ ការពិចារណាអំពីសមិទ្ធកម្ម E&S របស់អតិថិជន និងអតិថិជនបន្តរបស់ IFC ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃ PS1 ពាក់ព័ន្ធនឹងយន្តការបណ្តឹងសារទុក្ខ ...... 80

**៤.៣ ភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចនៃក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ទាក់ទងនឹងប្រជាជនដែលងាយរងគ្រោះ ...... 86**

៤.៣.១ ការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែក E&S របស់ IFC នៃការវិនិយោគរបស់ខ្លួន នៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា, North Haven Thai, Advans, MEF និង MIFA ...... 86

៤.៣.២ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA ...... 103

៤.៣.៣ សេចក្តីសន្និដ្ឋានអំពីភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគរបស់ខ្លួន ...... 108

**៤.៤ អនុលោមភាពរបស់ IFC ចំពោះកាតព្វកិច្ចនៃក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ...... 109**

៤.៤.១ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវលើការវិនិយោគរបស់ខ្លួន នៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA ...... 110

៤.៤.២ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យការវិនិយោគរបស់ខ្លួន នៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA ...... 115

**៤.៥ ភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចនៃក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ទាក់ទងនឹងលទ្ធភាពទទួលបានដំណោះស្រាយបណ្តឹងសារទុក្ខ ...... 121**

៤.៥.១ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវនៃការវិនិយោគរបស់ខ្លួន នៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA ...... 122

៤.៥.២ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA ...... 123

៤.៥.៣ សេចក្តីសន្និដ្ឋានអំពីភាពអនុលោមរបស់ IFC ចំពោះគោលនយោបាយនិរន្តរភាពរបស់ខ្លួនទាក់ទងនឹងលទ្ធភាពទទួលបានឧបាស្រ័យ ....128
៥. ការវាយតម្លៃរបស់ស៊ីអេអូទៅលើគ្រោះថ្នាក់ដែលពាក់ព័ន្ធ .... 129
៥.១ ការបាត់បង់មុខរបរចិញ្ចឹមជីវិត និងទ្រព្យសម្បត្តិដែលមានផលិតភាព ....131
៥.២ អសន្តិសុខស្បៀង និងផលប៉ះពាល់លើសុខភាព ការអប់រំ និងទំនាក់ទំនងគ្រួសារ ....136
៥.៣ ផលប៉ះពាល់លើជនជាតិដើមភាគតិច ....144
៥.៤ ភាពភ័យខ្លាច និងហេតុការណ៍នៃការគំរាមកំហែង និងការសងសឹក....147
៦. មូលហេតុឫសគល់នៃបដិលោមភាព .... 151
៧. អនុសាសន៍សម្រាប់ផែនការសកម្មភាពរបស់គណៈគ្រប់គ្រង IFC.... 153
ឧបសម្ព័ន្ធ ក. គំនិតផ្តួចផ្តើមបន្តបន្ទាប់នៅកម្ពុជា .... 161
ឧបសម្ព័ន្ធ ខ. ខ្សែបន្ទាត់ពេលវេលាលម្អិតនៃ GIIP ដែលពាក់ព័ន្ធនៅក្នុងបរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា និងការវិនិយោគរបស់ IFC.... 164
ឧបសម្ព័ន្ធ គ. ទិដ្ឋភាពទូទៅនៃដំណើរការស៊ើបអង្កេតរបស់ស៊ីអេអូ.... 170
ឧបសម្ព័ន្ធ ឃ៖ គំហើញរបស់ស៊ីអេអូអំពីបដិលោមភាព គ្រោះថ្នាក់ដែលពាក់ព័ន្ធ និងអនុសាសន៍ .... 174

# អក្សរកាត់

| **អក្សរកាត់** | **និយមន័យ** |
|---|---|
| អេស៊ីលីដា | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| Advans | Advans S.A. SICAR |
| AIP | គោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន |
| អម្រឹត | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត |
| BFI | ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ |
| ស៊ីអេអូ | ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (IFC និង MIGA) |
| CBC | ការិយាល័យឥណទានកម្ពុជា |
| CMA | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា |
| E&S | បរិស្ថាន និងសង្គម |
| ESAP | ផែនការសកម្មភាពបរិស្ថាន និងសង្គម |
| ESMS | ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESRS | សេចក្តីសង្ខេបអំពីការត្រួតពិនិត្យបរិស្ថាន និងសង្គម |
| ESRP | នីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គម |
| FCP | ការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ |
| FI | អន្តរការីហិរញ្ញវត្ថុ |
| GIIP | ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ |
| ធនាគារហត្ថា | ធនាគារ ហត្ថា ភីអិលស៊ី |
| ICLT | ប័ណ្ណកម្មសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| អិលអូអិលស៊ី | អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| MEF | ឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ S.A., SICAV-SIF |
| MIFA | មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី SA, SICAV-SIF |
| MIGA | ទីភ្នាក់ងារធានាការវិនិយោគពហុភាគី |
| MSME | សហគ្រាសធុនមីក្រូ តូច និងមធ្យម |
| NBC | ធនាគារជាតិកម្ពុជា |
| North Haven Thai | ក្រុមហ៊ុន North Haven Thai Private Equity L.P. |

| **អក្សរកាត់** | **និយមន័យ** |
|---|---|
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| PS | ស្តង់ដារសមិទ្ធកម្មរបស់ IFC |
| ប្រាសាក់ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក |
| ស្ថាបនា | ធនាគារ ស្ថាបនា ភីអិលស៊ី |
| SME | សហគ្រាសធុនតូច និងមធ្យម |
| SPI | សេចក្ដីសង្ខេបស្ដីពីការវិនិយោគដែលបានស្នើ |
| TOR | លក្ខខណ្ឌយោង |

## សេចក្ដីសង្ខេប

*របាយការណ៍នេះពិនិត្យភាពអនុលោមរបស់ IFC តាមគោលនយោបាយបរិស្ថាន និងសង្គម (E&S) របស់ខ្លួន ទាក់ទងនឹងការវិនិយោគដោយផ្ទាល់ និងដោយប្រយោលចំនួន ១៣ នៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាចំនួនប្រាំមួយ ដែលផ្តល់សេវាមីក្រូហិរញ្ញវត្ថុ រួមមាន អេស៊ីលីដា អម្រឹត ធនាគារហត្ថា អិលអូអិលស៊ី ប្រាសាក់ និង ស្ថាបនា។ ការស៊ើបអង្កេតរបស់ស៊ីអេអូបានឆ្លើយតបទៅនឹងពាក្យបណ្តឹងដែលបានដាក់ តាងនាមឲ្យអ្នកខ្ចីមីក្រូហិរញ្ញវត្ថុចំនួន ១៨ នាក់[1] ដែលចោទប្រកាន់ថា ការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់បំណុលរបស់គ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះ បណ្តាលឱ្យមានផលប៉ះពាល់សង្គមអវិជ្ជមានលើពួកគេ គ្រួសារ និងសហគមន៍របស់ពួកគេ ដែលរួមមាន ការបាត់បង់ដីធ្លី និងមុខរបរចិញ្ចឹមជីវិត ផលប៉ះពាល់លើជនជាតិដើមភាគតិច និងកង្វះខាតដំណោះស្រាយបណ្តឹងសារទុក្ខប្រកបដោយប្រសិទ្ធភាព។*

*ស៊ីអេអូរកឃើញថា ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងត្រួតពិនិត្យហិរញ្ញវត្ថុរបស់អតិថិជនមុនពេលវិនិយោគ[2] IFC មិនបានអនុលោមតាមកាតព្វកិច្ចនៃគោលនយោបាយនិរន្តរភាពក្នុងការវិនិយោគរបស់ខ្លួន ក្នុងគោលបំណង "មិនបង្កគ្រោះថ្នាក់" ដើម្បីធានាថា សោហ៊ុយនៃការអភិវឌ្ឍសេដ្ឋកិច្ចមិនធ្លាក់ទៅលើជនក្រីក្រ ឬជនងាយរងគ្រោះ ដោយមិនសមាមាត្រនោះទេ និងព្យាយាមធានាថា តាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន កិច្ចខិតខំប្រឹងប្រែងពិនិត្យតាមដាន និងការត្រួតពិនិត្យរបស់ខ្លួន សកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ហិរញ្ញប្បទាន ត្រូវបានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម (គោលនយោបាយនិរន្តរភាព ឆ្នាំ ២០១២ កថាខណ្ឌទី៧ និង ៩។[3]*

*IFC បានដឹងពីហានិភ័យអវិជ្ជមាននៅក្នុងវិស័យនេះ ប៉ុន្តែបានចាត់ទុកថាផលប៉ះពាល់លើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុស្ថិតនៅខាងក្រៅវិសាលភាពនៃគោលនយោបាយ និងកាតព្វកិច្ចផ្នែកបរិស្ថាន និងសង្គមរបស់ខ្លួន។ ជាលទ្ធផល IFC មិនបានចាត់ទុកអ្នកខ្ចី និងគ្រួសារពួកគេ ជាក្រុមងាយរងគ្រោះនៅក្រោមគោលនយោបាយនិរន្តរភាពរបស់ IFC នោះទេ។ IFC មិនបានតម្រូវឱ្យអតិថិជនរបស់ខ្លួនអនុវត្តលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធ នៅក្នុងស្តង់ដារសមិទ្ធកម្មទី១ (PS1) ដើម្បីប្រើប្រាស់ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) ស្តង់ដារសមិទ្ធកម្មទី៧ និងបញ្ជីផាត់ចេញរបស់ IFC នៅក្នុងសកម្មភាពមីក្រូហិរញ្ញវត្ថុរបស់ពួកគេនោះទេ។ ស៊ីអេអូចាត់ទុកការមិនអនុវត្ត*

---

[1] ពាក្យបណ្តឹងដែលបានប្តឹងទៅស៊ីអេអូនេះ ត្រូវបានដាក់ជូនតាងនាមឲ្យអ្នកខ្ចីចំនួន ១៨ នាក់។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងដំណើរការនៃការស៊ើបអង្កេតរបស់ខ្លួន ស៊ីអេអូបាននិយាយជាមួយសមាជិកគ្រួសាររបស់ដើមបណ្តឹងដទៃទៀត ដែលពួកគេមួយចំនួនជាអ្នកខ្ចីរួមគ្នា។ ស៊ីអេអូកត់សម្គាល់ថា ផលប៉ះពាល់អវិជ្ជមានដែលបានពិពណ៌នានៅក្នុងរបាយការណ៍នេះតែងតែជួបប្រទះនៅកម្រិតគ្រួសារ។ ក្នុងករណីសមស្រប របាយការណ៍នេះសំដៅដល់គ្រួសារដែលរងផលប៉ះពាល់ ជំនួសឱ្យបុគ្គលដែលរងផលប៉ះពាល់។

[2] ដើម្បីធានាថាការវាយតម្លៃរបស់ស៊ីអេអូលើភាពអនុលោមរបស់ IFC ចំពោះក្របខណ្ឌនិរន្តរភាពរបស់ខ្លួនគឺ ផ្អែកលើការយល់ដឹងយ៉ាងពេញលេញអំពីកិច្ចខិតខំប្រឹងប្រែងរបស់ IFC នោះ ស៊ីអេអូក៏បានពិចារណាអំពីកិច្ចខិតខំប្រឹងប្រែងរបស់ IFC ក្នុងការលើកកម្ពស់មីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ នៅក្រោម *បរិយាប័ន្នហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រការពារអ្នកប្រើប្រាស់*របស់ខ្លួនផងដែរ។

[3] សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី ៥ និង ៨។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។ ការវិនិយោគនៅក្នុងសំណុំរឿងនេះមានរយៈពេល ២០ឆ្នាំ។ សម្រាប់ការវិនិយោគនៅ Advans (ត្រូវបានអនុម័តនៅឆ្នាំ២០០៤) និង MEF (ត្រូវបានអនុម័តនៅឆ្នាំ២០០៩) គោលនយោបាយបរិស្ថាន និងសង្គម (E&S) ដទៃទៀត គឺអាចអនុវត្តបាន នៅក្នុងផ្នែកមួយចំនួននៃវដ្តការវិនិយោគ។ ស៊ីអេអូនឹងកត់សម្គាល់បទប្បញ្ញត្តិសមមូលនៅក្នុងគោលនយោបាយដាច់ដោយឡែកពីគ្នា តាមភាពពាក់ព័ន្ធ។

*ទាំងនេះជាបដិលោមភាព ទាក់ទងនឹងការខូចខាតដែលទទួលរងដោយដើមបណ្តឹង ហើយបានផ្តល់អនុសាសន៍អំពីវិធានការដោះស្រាយទាំងនៅកម្រិតគម្រោង និងកម្រិតប្រព័ន្ធ ដល់ IFC។*

*ស៊ីអេអូទទួលស្គាល់ថា មីក្រូហិរញ្ញវត្ថុបានដើរតួនាទីដ៏មានតម្លៃក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ធ្វើឱ្យសហគ្រាសធុនតូចមានភាពរីកចម្រើន និងលើកកម្ពស់ជីវភាពរស់នៅរបស់គ្រួសារដែលមានប្រាក់ចំណូលទាបជាច្រើនគ្រួសារ។ ការស៊ើបអង្កេតនេះផ្តល់ការយល់ដឹងអំពីរបៀបដែល IFC អាចពង្រឹងការអនុវត្តរបស់ខ្លួនដើម្បីផ្តល់អត្ថប្រយោជន៍ទាំងនេះឲ្យកាន់តែមានសង្គតិភាព និងសមធម៌ ជាពិសេសសម្រាប់ជនងាយរងគ្រោះ។*

*សេចក្តីសម្រេចនៅក្នុងរបាយការណ៍ស៊ើបអង្កេតនេះត្រូវបានដាក់កម្រិតចំពោះការវាយតម្លៃលើភាពអនុលោមរបស់ IFC តាមលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងសង្គម (E&S) ទាក់ទងនឹងការវិនិយោគរបស់ IFC ចំនួន ១៣ ដែលគ្របដណ្តប់ដោយសំណុំរឿងនេះ និងការខូចខាតដែលពាក់ព័ន្ធ ដែលបានទទួលរងដោយដើមបណ្តឹងចំនួន ១៨ នាក់ ដែលបានដាក់ពាក្យបណ្តឹងទៅកាន់ស៊ីអេអូ។ ក្នុងការបង្កើតគំហើញពាក់ព័ន្ធនឹងការខូចខាតដែលទាក់ទងនឹងបដិលោមភាពរបស់ IFC តាមលក្ខខណ្ឌតម្រូវ E&S របស់ខ្លួននោះ ស៊ីអេអូបានពិចារណាលើសមិទ្ធកម្ម E&S របស់គម្រោង និងអនុគម្រោងទាំងនោះ។[4] ការពិចារណានេះមិនបង្កើតបានជាការវាយតម្លៃលើវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាទាំងមូលនោះទេ។*

## បរិបទមីក្រូហិរញ្ញវត្ថុជាតិ និងជាសកល

ស៊ីអេអូកត់សម្គាល់ថា បញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ ទាមទារឱ្យមានការយល់ដឹងកាន់តែទូលំទូលាយអំពីសារៈសំខាន់នៃវិស័យមីក្រូហិរញ្ញវត្ថុ រួមទាំងនិន្នាការ ហានិភ័យ និងការការពារផងដែរ។ IFC គឺជាវិនិយោគិនឈានមុខគេលើពិភពលោកនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដោយផ្តល់ប្រាក់កម្ចីសរុបចំនួន ៦,២ ពាន់លានដុល្លារដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) និងគ្រឹះស្ថានហិរញ្ញវត្ថុ ប្រហែល ៣៣០ កន្លែង ដែលផ្តោតលើសហគ្រាសធុនតូច និងមធ្យម (SMEs) ក្នុងរយៈពេលជាង ២០ ឆ្នាំកន្លងមកនេះ។ អតិថិជន និងអតិថិជនបន្តទាំងនេះផ្តល់សេវាហិរញ្ញវត្ថុនៅ ៩៥ ប្រទេស រួមទាំងប្រទេសកម្ពុជាផងដែរ។[5] ស៊ីអេអូចាត់ទុកថា ការចូលរួមជាយូរអង្វែង និងយ៉ាងទូលំទូលាយរបស់ IFC នៅក្នុងវិស័យនេះ ពាក់ព័ន្ធនឹងការស៊ើបអង្កេតអនុលោមភាពនេះ និងទទួលស្គាល់ពីគុណតម្លៃ និងអត្ថប្រយោជន៍នៃការអភិវឌ្ឍ ដែលមីក្រូហិរញ្ញវត្ថុបាននាំមកកាន់ប្រទេសកម្ពុជា ទន្ទឹមនឹងនោះ គូសបញ្ជាក់អំពីតម្រូវការការការពារសុវត្ថិភាព ដែលនឹងត្រូវរួមបញ្ចូលនៅគ្រប់គម្រោងអភិវឌ្ឍន៍ទាំងអស់ដែលផ្តល់ហិរញ្ញប្បទានដោយ IFC ជាពិសេសគម្រោងដែលពាក់ព័ន្ធនឹងប្រជាជនងាយរងគ្រោះ។

មីក្រូហិរញ្ញវត្ថុបានលេចឡើងនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ជាឧបករណ៍ដែលធ្វើឲ្យក្រុមដែលមានប្រាក់ចំណូលទាប និងជនក្រីក្រដែលងាយរងគ្រោះ ដែលជាធម្មតាត្រូវបានផាត់ចេញពីធនាគារបែបប្រពៃណី[6] អាចបង្កើន

[4] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៧៧

[5] គេហទំព័រវិស័យមីក្រូហិរញ្ញវត្ថុរបស់ IFC៖ https://bit.ly/4iQqJeQ

[6] អវត្តមាននៃសេវាហិរញ្ញវត្ថុ*ផ្លូវការ* អមមកជាមួយនឹងការរីកដុះដាលនៃសេវា*ក្រៅផ្លូវការ* ជាចម្បង នៅក្នុងទម្រង់សមាគមសន្សំប្រាក់និងឥណទានបង្វិល (ROSCAs) ដែលមានឈ្មោះដូចជា *tanda* នៅអាមេរិកឡាទីន *susu* នៅអាហ្វ្រិកខាងលិច និងខារីបៀន *មូលនិធិ chit* នៅឥណ្ឌា *តុងទីន*នៅកម្ពុជា *arisan* នៅឥណ្ឌូណេស៊ី និងឧទាហរណ៍ដទៃទៀតរាប់មិនអស់ នៅស្ទើរតែគ្រប់ប្រទេសដែលមានប្រាក់ចំណូលកម្រិតទាប និងមធ្យម នៅក្នុងពិភពលោក និងនៅក្នុងសហគមន៍ជនអន្តោប្រវេសន៍ នៅគ្រប់ទីកន្លែងដទៃទៀត។ David Roodman *ការត្រួតពិនិត្យដ៏ត្រឹមត្រូវ៖ ការសួរសំណួរដែលមិនពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ* សារព័ត៌មាននៃស្ថាប័ន Brookings ឆ្នាំ២០១២ ទំព័រទី៣៩-៤០។

ប្រាក់ចំណូលនៅក្នុងគ្រួសារ បង្កើតទ្រព្យសកម្ម និងកាត់បន្ថយភាពងាយរងគ្រោះដោយសារវិបត្តិសេដ្ឋកិច្ច។ ការពង្រីកមីក្រូហិរញ្ញវត្ថុជាបន្តបន្ទាប់ក៏បានគាំទ្រដល់ការបង្កើតការងារ ជម្រុញទីផ្សារក្នុងស្រុក និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចទាំងមូល តាមរយៈការកៀរគរប្រាក់សន្សំ និងបង្កើនចរាចរមូលធននៅក្នុងសហគមន៍។ នៅប្រទេសជាច្រើន រួមទាំងប្រទេសកម្ពុជាផងដែរ អត្ថប្រយោជន៍ទាំងនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញបរិយាប័ន្នហិរញ្ញវត្ថុ និងគាំទ្រដល់គោលដៅអភិវឌ្ឍន៍ជាតិ។[7]

ស្របពេលជាមួយគ្នានេះ ភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃមីក្រូហិរញ្ញវត្ថុ ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៩០ បានអមមកជាមួយការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ដែលមានការគ្រប់គ្រងមិនល្អនៅក្នុងប្រទេសមួយចំនួន ដែលនៅក្នុងបរិបទមួយចំនួន បណ្តាលឱ្យមានផលប៉ះពាល់សង្គមអវិជ្ជមានលើអ្នកខ្ចី និងគ្រួសាររបស់ពួកគេ។[8] បទពិសោធន៍ទាំងនេះបាននាំឲ្យមានការអភិវឌ្ឍស្តង់ដារ និងគោលការណ៍ផ្តល់ប្រាក់កម្ចី ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានលើអ្នកខ្ចី ដែលគាំទ្រដោយឧស្សាហកម្ម និងវិនិយោគិនទាំងឡាយ រួមទាំងស្ថាប័នហិរញ្ញវត្ថុនៃការអភិវឌ្ឍ (DFIs) ផងដែរ។[9]

បទពិសោធន៍របស់ប្រទេសកម្ពុជាឆ្លុះបញ្ចាំងពីបញ្ហាប្រឈមដែលបានពិពណ៌នាខាងលើ។ ប្រទេសកម្ពុជាមានអ្នកខ្ចីមីក្រូហិរញ្ញវត្ថុច្រើនជាងប្រទេសដទៃទៀត។ នៅឆ្នាំ២០២២ នៅពេលដែលពាក្យបណ្តឹងនេះត្រូវបានប្តឹងនោះ ប្រទេសកម្ពុជាគឺជាប្រទេសដែលសម្បូរឥណទានច្រើនជាងគេលំដាប់ទី៣ នៅលើពិភពលោក។ ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុជាមធ្យម បានកើនឡើងពី ៤០៩ ដុល្លារអាមេរិក ក្នុងឆ្នាំ២០០៦ ដល់ ៤.៥៧៨ ដុល្លារ ក្នុងឆ្នាំ២០២៣ ស្មើនឹង ៦៧% នៃផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ (៦១២ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០០៦ និង ១៨៨% នៃផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ (២.៤២៩ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០២៣។ របាយការណ៍ជាច្រើន ចាប់តាំងពីឆ្នាំ២០០៩ មក បានគូសបញ្ជាក់ពីវិបត្តិនៃភាពជំពាក់បំណុលច្រើនលើសលុបរបស់ប្រទេសកម្ពុជា និងផលប៉ះពាល់ដែលពាក់ព័ន្ធ ចំពោះប្រជាជនដែលងាយរងគ្រោះ រួមទាំង ការបាត់បង់មុខរបរចិញ្ចឹមជីវិត និងភាពគ្មានដីធ្លីផងដែរ។

ការឆ្លើយតបទៅនឹងកង្វល់ទាំងនេះ រួមមាន គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី ដែលបង្កើតឡើងដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) ដែលគាំទ្រដោយវិនិយោគិនសង្គម និង DFIs រួមទាំង IFC ផងដែរ។

---

[7] ក្រុមធនាគារពិភពលោក កំណត់សម្គាល់គោលនយោយកម្ពុជាស្តីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ ឆ្នាំ២០១៩ https://bit.ly/4nukijN; Akotey, Joseph Oscar និង Adjasi, Charles K.D., ឆ្នាំ២០១៦ "តើមីក្រូឥណទានបង្កើនសុខុមាលភាពគ្រួសារនៅពេលអវត្តមានធានារ៉ាប់រងខ្នាតមីក្រូបានដែរឬទេ?" ការអភិវឌ្ឍពិភពលោក, Elsevier, ច្បាប់ទី ៧៧(C), ទំព័រ ២៨០-៣៩៤។ Crépon, Bruno, Florencia Devoto, Esther Duflo និង William Parienté ឆ្នាំ២០១៥ "ការប៉ាន់ស្មានផលប៉ះពាល់នៃមីក្រូឥណទានលើអ្នកដែលប្រើប្រាស់វា៖ ភស្តុតាងពីការពិសោធន៍ដែលត្រូវបានជ្រើសរើសដោយចៃដន្យនៅប្រទេសម៉ារ៉ុក" *ទិនានុប្បវត្តិសេដ្ឋកិច្ចអាមេរិក៖ សេដ្ឋកិច្ចអនុវត្ត* ៧ (១)៖ ១២៣–៥០។

[8] Sam Mendelson និង Daniel Rozas, វិបត្តិមីក្រូហិរញ្ញវត្ថុដែលត្រូវបានជ្រើសរើស៖ អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល *ការត្រួតពិនិត្យគោលនយោបាយសេដ្ឋកិច្ចរបស់ Oxford* ច្បាប់ទី ៤០ លេខ ១ និទាឃរដូវ ឆ្នាំ២០២៤ ទំព័រទី ៣០-៤៣ https://bit.ly/3FomyI4 និង CGAP, Greg Chen, Stephen Rasmussen និង Xavier Reille, កំណើន និងភាពងាយរងគ្រោះនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ, កំណត់សម្គាល់ចំណុចផ្តោត ខែកុម្ភៈ ឆ្នាំ២០១០ ទំ. ១៤-១៥ https://bit.ly/4iKaYFC។

[9] សូមមើល CGAP គោលការណ៍ណែនាំស្តីពីការយល់ព្រមជាឯកច្ឆន្ទលើមីក្រូហិរញ្ញវត្ថុ៖ គោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិ និងការត្រួតពិនិត្យមីក្រូហិរញ្ញវត្ថុ https://bit.ly/3DrIzFy យុទ្ធនាការឆ្លាតវៃ SPTF CERISE គោលការណ៍ការពារអតិថិជន https://bit.ly/3Fqg2AR និងមជ្ឈមណ្ឌលបរិយាប័ន្នហិរញ្ញវត្ថុ Accion ការដាក់គោលការណ៍ឱ្យដំណើរការ៖ ការណែនាំលម្អិតអំពីគោលការណ៍ការពារអតិថិជន ការការពារ និងការផ្តល់ភាពអង់អាចដល់អ្នកប្រើប្រាស់ហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ https://bit.ly/4nAkyO7។

រដ្ឋាភិបាលកម្ពុជាក៏បានអនុវត្តវិធានការនិយ័តកម្មមួយចំនួនផងដែរ ដូចជា ការកំណត់ពិដានអត្រាការប្រាក់ និងតម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុរៀបចំយន្តការទទួលពាក្យបណ្ដឹងអ្នកប្រើប្រាស់។ (សូមមើលប្រអប់ខាងក្រោម សម្រាប់ព័ត៌មានបន្ថែមអំពីរបាយការណ៍សំខាន់ៗ ដែលចងក្រងឯកសារពីផលប៉ះពាល់សង្គមអវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងព្រឹត្តិការណ៍សំខាន់ៗក្នុងការអភិវឌ្ឍការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់ទាំងនោះ)។

ស៊ីអេអូទទួលស្គាល់ពីគុណតម្លៃ និងអត្ថប្រយោជន៍នៃការអភិវឌ្ឍ ដែលមីក្រូហិរញ្ញវត្ថុបាននាំមកកាន់ប្រទេសកម្ពុជា។ ស្របពេលជាមួយគ្នានេះ ដូចដែលរបាយការណ៍នេះបង្ហាញ វាមានសារៈសំខាន់សម្រាប់ IFC ក្នុងការអនុវត្តគោលនយោបាយនិរន្តរភាពរបស់ខ្លួនចំពោះគ្រប់គម្រោងទាំងអស់ដែលផ្ដល់ហិរញ្ញប្បទានដោយ IFC រួមទាំងការវិនិយោគមីក្រូហិរញ្ញវត្ថុផងដែរ ដើម្បីជៀសវាង និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងហានិភ័យលើក្រុមដែលងាយរងគ្រោះ។

| របាយការណ៍ស្ដីពីផលប៉ះពាល់អវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និង សមិទ្ធផលនៃ GIIP | | |
|---|---|---|
| **ឆ្នាំ** | **របាយការណ៍គន្លឹះ** | **សមិទ្ធផលនៃ GIIP** |
| **២០០២-២០០៨** | | **គោលការណ៍ណែនាំស្ដីពីមីក្រូហិរញ្ញវត្ថុ និងគោលការណ៍ស្វ័យនិយ័តកម្ម** ដោយក្រុមប្រឹក្សាយោបល់ដើម្បីជួយជនក្រីក្រ (CGAP) បណ្ដាញគម្រោងវាយតម្លៃសហគ្រាសធុនតូច (SEEP) អង្គការ Accion អន្តរជាតិ ធនាគារ Deutsche និង FMO |
| **២០០៩-២០១០** | **ការវាយតម្លៃដែលផ្ដល់មូលនិធិដោយធនាគារពិភពលោក**បានពិពណ៌នាអំពីអសមត្ថភាពក្នុងការសងប្រាក់កម្ចីថាជា "កង្វល់ដ៏ខ្លាំងក្លាមួយសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ" នៅកម្ពុជា។ | គោលការណ៍ការពារអតិថិជននៃយុទ្ធនាការឆ្លាតវៃ វេទិកាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវរបស់ IFC<br>**មគ្គុទ្ទេសក៍ណែនាំផ្នែកបច្ចេកទេសរបស់ CGAP សម្រាប់វិនិយោគក្នុងការអនុវត្តគោលការណ៍ការពារ**អតិថិជន |
| **២០១១-២០១២** | CGAP កំណត់ថាឧស្សាហកម្ម MFI មានហានិភ័យខ្ពស់នៃភាពជំពាក់បំណុលច្រើនលើសលុប | **គោលការណ៍សម្រាប់វិនិយោគិននៅក្នុងហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន** (PIIF)<br>SPTF **ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម** |
| **២០១៣** | ការសិក្សារបស់**វិទ្យាស្ថានអភិវឌ្ឍន៍កម្ពុជា**បានលើកឡើងអំពីហានិភ័យខ្ពស់នៃភាពជំពាក់បំណុលច្រើនលើសលុប | **កម្មវិធីវិញ្ញាបនប័ត្រនៃយុទ្ធនាការឆ្លាតវៃ** |
| **ឆ្នាំ** | **របាយការណ៍គន្លឹះ** | **សមិទ្ធផលនៃ** GIIP |
| **២០១៥-២០១៦** | **ឯកសារគោលនយោបាយ** IFC នៅកម្ពុជាជូនដំណឹងពីភាពជំពាក់បំណុលច្រើនលើសលុប និងការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុទន់ខ្សោយ | **ឧបករណ៍** ALINUS ចេញដោយក្រុមការងារវិនិយោគិននៃ SPTF |
| **២០១៩** | **កំណត់សម្គាល់អំពីគោលនយោបាយរបស់ធនាគារពិភពលោកជូន** | **កំណត់សម្គាល់ផ្នែកបច្ចេកទេសរបស់ធនាគារពិភព** |

| **របាយការណ៍ស្តីពីផលប៉ះពាល់អវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និង សមិទ្ធផលនៃ GIIP** | | |
|---|---|---|
| **ឆ្នាំ** | **របាយការណ៍គន្លឹះ** | **សមិទ្ធផលនៃ GIIP** |
| | ដំណឹងអំពី "ការកើនឡើងនៃផលជៀបបំណុលនឹងការប្រើប្រាស់" អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និង សមាគមធាងត្នោត (STT) រាយការណ៍ពីការបាត់បង់ដីធ្លី និងការ រំលោភបំពាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ | **លោក**ស្តីពីការដោះស្រាយពាក្យបណ្តឹងក្នុងចំណោម អ្នកផ្តល់សេវាហិរញ្ញវត្ថុ |
| **២០២០** | របាយការណ៍ **MIMOSA ដែលរៀបចំដោយ IFC** បានមើលឃើញ តិត្ថិភាពទីផ្សារ និងកង្វះខាតការការពារអ្នកប្រើប្រាស់នៅកម្ពុជា | |
| **២០២១** | **អង្គការសមធម៌កម្ពុជា និង អង្គការលីកាដូ បានរាយការណ៍**ពី សហគមន៍ដីធ្លីជាប់បំណុល<br>**ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអ្នកជំនាញឯករាជ្យនៃអង្គ ការសហប្រជាជាតិ**បង្ហាញពីកង្វល់នៃផលប៉ះពាល់សង្គមអវិជ្ជមាន នៃភាពជាប់បំណុលច្រើនលើសលុបនៅកម្ពុជា | **មាគារសម្រាប់កិច្ចការពារអតិថិជនរបស់** CERISE+SPTF |
| **២០២២-២០២៤** | **ការសិក្សាដែលរៀបចំដោយរដ្ឋាភិបាលអាល្លឺម៉ង់**រកឃើញ ការ កាត់បន្ថយអាហារ ការលក់ដីធ្លី និងការបោះបង់ការសិក្សាដែល ទាក់ទងនឹងបំណុល<br>**អង្គការសមធម៌កម្ពុជា និង អង្គការលីកាដូ** បោះពុម្ពផ្សាយការសិក្សា បែបបរិមាណវិស័យស្តីពីអ្នកខ្ចីប្រាក់កម្ចីខ្នាតមីក្រូ<br>ការអង្កេត **៦០ ដេស៊ីបែល** រកឃើញថា មានភាពតានតឹងខ្ពស់ក្នុង ការសងប្រាក់ និងផលប៉ះពាល់សង្គមអវិជ្ជមានលើអតិថិជន MFI | |

## ការវិនិយោគរបស់ IFC

IFC បានធ្វើការវិនិយោគនៅក្នុងអន្តរការីហិរញ្ញវត្ថុ (FIs) ដែលផ្តល់មីក្រូហិរញ្ញវត្ថុនៅកម្ពុជាយ៉ាងហោចណាស់ ចាប់តាំងពីឆ្នាំ២០០០ មក ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមធនាគារពិភពលោក ដើម្បីគាំទ្រ ដល់បរិយាប័ន្នហិរញ្ញវត្ថុ។ ទាក់ទងនឹងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ (BFIs) ទាំងប្រាំមួយនៅកម្ពុជា នៅក្នុង សំណុំរឿងនេះ IFC មានការវិនិយោគដោយផ្ទាល់នៅអេស៊ីលីដា អម្រឹត និងធនាគារហត្ថា។ នៅពេលស៊ីអេអូ បានទទួលពាក្យបណ្តឹង IFC ក៏មានទំនាក់ទំនងហិរញ្ញវត្ថុដោយប្រយោលជាមួយប្រាសាក់ អិលអូអិលស៊ី និង ស្ថាបនាផងដែរ ដោយទំនាក់ទំនងជាមួយអិលអូអិលស៊ី និងស្ថាបនា នៅមានភាពសកម្ម។ ទំនាក់ទំនងនេះ បានកើតឡើងតាមរយៈការវិនិយោគនៅក្នុងតណទានពង្រឹងមីក្រូហិរញ្ញវត្ថុ (MEF ដែលក្រោយមកប្តូរឈ្មោះ ទៅជាមូលនិធិសកលសម្រាប់យេនឌ័រឆ្លាតវៃ ឬ GGSF) មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុល អាស៊ី (MIFA) ក្រុមហ៊ុន North Haven Thai (ក្រុមហ៊ុនភាគហ៊ុនឯកជន) និង Advans S.A. (ក្រុមហ៊ុន ហូលឌីងមីក្រូហិរញ្ញវត្ថុ)។[10] សរុបមក សំណុំរឿងនេះពាក់ព័ន្ធនឹងគម្រោងរបស់ IFC ចំនួន ១៣ គម្រោង ដែល គាំទ្រការផ្តល់ប្រាក់កម្ចីរបស់អតិថិជនដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs)។

[10] BFIs ទាំងប្រាំមួយ នៅកម្ពុជា ដែលការអនុវត្តរបស់ពួកគេជាកម្មវត្ថុនៃពាក្យបណ្តឹង រួមមាន អេស៊ីលីដា អម្រឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា។ អតិថិជនផ្ទាល់របស់ IFC ចំនួនប្រាំពីរ ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ រួមមាន អេស៊ីលីដា, អម្រឹត, ធនាគារហត្ថា, MEF, MIFA, ក្រុមហ៊ុន North Haven Thai និង Advans។

## ពាក្យបណ្តឹង

ស៊ីអេអូបានទទួលពាក្យបណ្តឹងមួយ នៅខែកុម្ភៈ ឆ្នាំ២០២២ ពីអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរគឺ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និងអង្គការសមធម៌កម្ពុជា (EC) តាងនាមឲ្យអ្នកខ្ចីប្រាក់ចំនួន ១៨ នាក់ ដែលបានខ្ចីប្រាក់ពីអតិថិជន/អតិថិជនបន្តរបស់ IFC មួយ ឬច្រើន។ ពាក្យបណ្តឹងនេះបានចោទប្រកាន់ថា ការវិនិយោគរបស់ IFC បានបណ្តាលឱ្យពួកគេបាត់បង់មុខរបរចិញ្ចឹមជីវិត និងដីធ្លី រួមទាំងទឹកដីសហគមន៍ជនជាតិដើមភាគតិច និងផលប៉ះពាល់សង្គមអវិជ្ជមានដទៃទៀត។ ដើមបណ្តឹងផ្តល់ទឡ្ហីករណ៍ថា IFC មិនបានអនុវត្តការត្រួតពិនិត្យបរិស្ថាន និងសង្គមយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យអតិថិជនរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ដើម្បីជៀសវាង ឬកាត់បន្ថយផលប៉ះពាល់ និងហានិភ័យសង្គមនោះទេ។ ពួកគេអះអាងថា អតិថិជន/អតិថិជនបន្ត តែងតែប្រើកលយុទ្ធប្រមូលប្រាក់ក្រៅប្រព័ន្ធតុលាការដោយបង្ខំ ដូចជា ការបៀតបៀនអ្នកខ្ចីនៅផ្ទះ ការគំរាមកំហែងនាំពួកគេនៅជួបអាជ្ញាធរមូលដ្ឋាន និងដាក់សម្ពាធឱ្យពួកគេខ្ចីប្រាក់បន្ថែម បញ្ឈប់ការសិក្សារបស់កូនដើម្បីឲ្យពួកគេទៅធ្វើការ ឬលក់ដីធ្លីរបស់ពួកគេដើម្បីសងប្រាក់កម្ចី។

ពាក្យបណ្តឹងនេះអះអាងថា ដោយសារព័ត៌មានដែលមានជាសាធារណៈអំពីហានិភ័យខ្ពស់នៃគ្រោះថ្នាក់សង្គមរបស់វិស័យនេះ IFC គួរតែតម្រូវឱ្យអ្នកផ្តល់ប្រាក់កម្ចីទាំងនេះត្រួតពិនិត្យសកម្មភាពរបស់ពួកគេ សម្រាប់ហានិភ័យ និងផលប៉ះពាល់សង្គម រួមទាំងផលប៉ះពាល់ចំពោះអ្នកខ្ចីផងដែរ។ វាចង្អុលបង្ហាញថា អ្នកខ្ចីមីក្រូហិរញ្ញវត្ថុទំនងជាជនងាយរងគ្រោះ ដូច្នេះហើយទាមទារឲ្យមានការការពារ និងការពិនិត្យតាមដានបន្ថែម ដើម្បីធានាថា គម្រោង IFC មិនមានផលប៉ះពាល់ដល់សង្គម។ ដោយសារភាពភ័យខ្លាចការសងសឹកចំពោះការនិយាយប្រឆាំងនឹងឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ អ្នកខ្ចីដែលជាដើមបណ្តឹងបានស្នើសុំឱ្យស៊ីអេអូរក្សាការសម្ងាត់នៃអត្តសញ្ញាណរបស់ពួកគេ។

## ការឆ្លើយតបរបស់ IFC

ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ទទួលស្គាល់ថា ការខូចខាតដែលបានចោទប្រកាន់មានភាពធ្ងន់ធ្ងរ ប៉ុន្តែពួកគេនៅតែអះអាងថា ផលប៉ះពាល់លើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ស្ថិតនៅខាងក្រៅវិសាលភាពនៃគោលនយោបាយបរិស្ថាន និងសង្គមរបស់ IFC ដោយលើកហេតុផលថា៖[11]

- អ្នកប្រើប្រាស់ផលិតផលរបស់អតិថិជនមិនត្រូវបានយោងដល់ នៅក្នុងគោលការណ៍និរន្តរភាព ឬស្តង់ដារសមិទ្ធកម្ម ថាជាប្រភេទភាគីពាក់ព័ន្ធដែលវិធានការកាត់បន្ថយហានិភ័យបរិស្ថាន និងសង្គមត្រូវអនុវត្តចំពោះពួកគេនោះទេ
- ក្របខណ្ឌនិរន្តរភាពរបស់ IFC អនុវត្តចំពោះហានិភ័យបរិស្ថាន និងសង្គមដែលអាចកើតឡើង និង

[11] នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ គណៈគ្រប់គ្រង IFC បានដាក់សំណើសុំឱ្យក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការសម្រេចចិត្តរបស់ស៊ីអេអូ ក្នុងការស៊ើបអង្កេត ដោយបានបង្ហាញគោលជំហររបស់ខ្លួនថា ផលប៉ះពាល់អវិជ្ជមានលើអ្នកខ្ចី និងស្តង់ដារការការពារអ្នកប្រើប្រាស់ស្ថិតនៅខាងក្រៅវិសាលភាពនៃគោលនយោបាយ E&S របស់ IFC ដូច្នេះ IFC បានចាត់ទុកថា វានៅខាងក្រៅវិសាលភាពនៃអាណត្តិរបស់ស៊ីអេអូ។ IFC បានចង្អុលបង្ហាញថា ពួកគេដោះស្រាយបញ្ហាដែលទាក់ទងនឹងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងកិច្ចការពារអ្នកប្រើប្រាស់ដាច់ដោយឡែកពីគោលនយោបាយ E&S តាមរយៈការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ និងការពិនិត្យតាមដាន និងសេវាទីប្រឹក្សា ដែលពួកគេជឿជាក់ថានៅខាងក្រៅអាណត្តិរបស់ស៊ីអេអូ។ IFC បានដកសំណើរសុំការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ហើយការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូបានបន្តដំណើរការទៅមុខ។

ផលប៉ះពាល់នៃ "សកម្មភាពអាជីវកម្ម" ដែលត្រូវបានគាំទ្រ លើ "សហគមន៍ជុំវិញ និងកម្មករ" ប៉ុន្តែមិនមែនចំពោះផលប៉ះពាល់បរិស្ថាន និងសង្គមលើអតិថិជនបន្ត (ក្នុងសំណុំរឿងនេះ ជាអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ) នោះទេ

- សកម្មភាពអាជីវកម្មដែល IFC ផ្តល់ការគាំទ្រតាមរយៈអតិថិជន FI មិនមែនជាការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុដោយផ្ទាល់នោះទេ ប៉ុន្តែជាសកម្មភាពប្រើប្រាស់ចុងក្រោយ ដែលកើតចេញពីការប្រើប្រាស់ប្រាក់កម្ចីទាំងនោះដោយអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ (ឧទាហរណ៍ កសិកម្មខ្នាតតូច ឬសកម្មភាពជំនួញនានា ដូចជា ហាងលក់ទំនិញចម្រុះ ជាដើម)
- IFC ដោះស្រាយការផ្តល់ប្រាក់កម្ចីរបស់អតិថិជន និងការអនុវត្តការប្រមូលប្រាក់តាមរយៈក្របខណ្ឌហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងដំណើរការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុដ៏ទូលំទូលាយ មិនមែននៅក្នុងក្របខណ្ឌនិរន្តរភាពនោះទេ ជាអភិក្រមមួយដែលមានសង្គតិភាពនឹងធនាគារអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគីដទៃទៀត ដែលដោះស្រាយហានិភ័យទាំងនេះតាមរយៈយុទ្ធសាស្រ្តកិច្ចគាំពារសង្គមដ៏ទូលំទូលាយ។

IFC ក៏ពន្យល់ផងដែរថា ក្រៅពីលក្ខខណ្ឌតម្រូវនៃក្របខណ្ឌនិរន្តរភាពទៀតនោះ IFC ក៏បានធ្វើការនៅកម្រិតស្ថាប័ន និងកម្រិតវិស័យអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវនៅក្នុងប្រទេសកម្ពុជាផងដែរ។[12]

## លក្ខខណ្ឌតម្រូវនៃគោលនយោបាយ

បញ្ញត្តិជាក់លាក់នៅក្នុងគោលនយោបាយនិរន្តរភាព និងស្តង់ដារសមិទ្ធកម្ម (រួមគ្នាបង្កើតបានជាក្របខណ្ឌនិរន្តរភាពរបស់ IFC) អនុវត្តចំពោះសំណុំរឿងនេះ។[13] ទោះបីជាមានគោលជំហររបស់ IFC ដូចខាងលើក៏ដោយ ក៏ស៊ីអេអូរកមិនឃើញការលើកលែង ឬដែនកំណត់ក្នុងការអនុវត្តក្របខណ្ឌនិរន្តរភាពរបស់ IFC ចំពោះអ្នកប្រើប្រាស់ហិរញ្ញវត្ថុ អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ឬអ្នកប្រើប្រាស់សេវាហិរញ្ញប្បទានរបស់ IFC ជាទូទៅដែរ។[14] ផ្ទុយទៅវិញ មានបញ្ញត្តិជាច្រើនបញ្ជាក់យ៉ាងច្បាស់ថា វាបានគ្របដណ្តប់លើសកម្មភាពមីក្រូហិរញ្ញវត្ថុ។

គោលនយោបាយនិរន្តរភាព៖

- ធ្វើឲ្យ IFC ប្តេជ្ញាចិត្តធានាថា សោហ៊ុយលើការអភិវឌ្ឍសេដ្ឋកិច្ចមិនធ្លាក់លើជនក្រីក្រ ឬជនងាយរងគ្រោះដោយមិនសមាមាត្រគ្នានោះទេ ជាប្រភេទអ្នកប្រើប្រាស់ដែលរួមបញ្ចូលអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ

---

[12] ស៊ីអេអូទទួលស្គាល់ និងពិចារណាលើអភិក្រមដាច់ដោយឡែករបស់ IFC នៅពេលត្រួតពិនិត្យភាពអនុលោមរបស់ IFC តាមគោលនយោបាយ E&S របស់ខ្លួន នៅក្នុងផ្នែកទី៤ នៃរបាយការណ៍នេះ។

[13] សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។ ការវិនិយោគនៅក្នុងសំណុំរឿងនេះមានរយៈពេល ២០ឆ្នាំ។ សម្រាប់ការវិនិយោគនៅ Advans (ត្រូវបានអនុម័តនៅឆ្នាំ២០០៤) និង MEF (ឆ្នាំ២០០៩) គោលនយោបាយបរិស្ថាន និងសង្គម (E&S) ដទៃទៀត គឺអាចអនុវត្តបាន នៅក្នុងផ្នែកមួយចំនួននៃវដ្តការវិនិយោគ។ ស៊ីអេអូនឹងកត់សម្គាល់បទប្បញ្ញត្តិសមមូលនៅក្នុងគោលនយោបាយដាច់ដោយឡែកពីគ្នា តាមភាពពាក់ព័ន្ធ។

[14] ក្របខណ្ឌនិរន្តរភាពអនុវត្តចំពោះគ្រប់គម្រោងរបស់ IFC និងវិសាលភាពពេញលេញនៃហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងទាំងនោះ រួមទាំង "ផលប៉ះពាល់ពិសេសៗ" ដែលមិនបានលើកឡើងយ៉ាងជាក់លាក់នៅក្នុងគោលនយោបាយទាំងនេះផងដែរ "លើកលែងតែត្រូវបានផាត់ចេញជាពិសេស"។ គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌទី១ ៣ ២០ និង ២២ និងកំណត់សម្គាល់ការណែនាំរបស់ IFC ចំពោះ PS១ កថាខណ្ឌទី១៦ និង ១៧។

ជាច្រើន (កថាខណ្ឌទី៩)[15]

- បញ្ជាក់ថា និរន្តរភាព E&S នៃសកម្មភាពដែល IFC ផ្តល់ហិរញ្ញប្បទាន មានសារៈសំខាន់ចំពោះការសម្រេចបាននូវផលសម្រេចនៃការអភិវឌ្ឍជាវិជ្ជមាន (កថាខណ្ឌទី១) [16]
- ធ្វើឲ្យ IFC មានកាតព្វកិច្ចព្យាយាមធានាថា តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ ការពិនិត្យតាមដាន និងការត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួន សកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ហិរញ្ញប្បទានជូន បានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម (PS) (កថាខណ្ឌទី៧)[17] – នៅក្នុងសំណុំរឿងនេះ ស្តង់ដារសមិទ្ធកម្មទី១ *(ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម)* ស្តង់ដារសមិទ្ធកម្មទី៧ *(ជនជាតិដើមភាគតិច)*
- តម្រូវឲ្យអតិថិជនដែលជាអន្តរការីហិរញ្ញវត្ថុ (FI) ទាំងអស់ រួមទាំង MFIs ផងដែរ ធ្វើប្រតិបត្តិការប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ E&S នៃផលប័ត្ររបស់ពួកគេឲ្យមានសង្គតិភាពនឹង PS1 បញ្ជីផាត់ចេញរបស់ IFC[18] និងច្បាប់ជាតិ ព្រមទាំងស្តង់ដារសមិទ្ធកម្មដទៃទៀត អាស្រ័យលើហានិភ័យ E&S នៃសកម្មភាពរបស់ FI (កថាខណ្ឌ ៣៣ និង ៣៥)។[19]

បទប្បញ្ញត្តិស្តង់ដារសមិទ្ធកម្មស្រដៀងគ្នានេះក៏អនុវត្តចំពោះការវិនិយោគមីក្រូហិរញ្ញវត្ថុផងដែរ។ PS១ តម្រូវឱ្យអតិថិជនកំណត់អត្តសញ្ញាណក្រុមងាយរងគ្រោះ ឬក្រុមមានការលំបាក និងអនុវត្តវិធានការផ្សេងៗ ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានមិនសមាមាត្រ ព្រមទាំងបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងបរិស្ថាន (ESMS) ដើម្បីកំណត់ និងអនុវត្តវិធានការកាត់បន្ថយទាំងនោះសម្រាប់ជនងាយរងគ្រោះ ស្របតាមការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP)។ PS៧ តម្រូវឱ្យអតិថិជនវាយតម្លៃ ទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះជនជាតិដើមភាគតិច (IP) ដែលរងផលប៉ះពាល់ដោយសារគម្រោង។ លើសពីនេះទៀត បញ្ជីផាត់ចេញរបស់ IFC លើកឡើងពីមីក្រូហិរញ្ញវត្ថុជាពិសេស ដោយតម្រូវឱ្យអ្នកផ្តល់សេវាមិនបន្ត "សកម្មភាពដែលប៉ះពាល់ដីធ្លីដែលកាន់កាប់ ឬត្រូវបានទាមទារក្រោមការវិនិច្ឆ័យដោយជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះទេ"។[20]

ជារួម បញ្ញត្តិទាំងនេះបញ្ជាក់ថា ហានិភ័យសង្គម និងផលប៉ះពាល់នៃការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ ដែលបណ្តាលមកពីការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់មួយចំនួន សុទ្ធតែស្ថិតនៅក្នុងវិសាលភាពនៃ

---

15 សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ៥ និង ៨។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

16 សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី១។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

17 សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ៥។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

18 បញ្ជីផាត់ចេញរបស់ IFC កំណត់ប្រភេទគម្រោង ដែល IFC និងអតិថិជនជាអន្តរការីហិរញ្ញវត្ថុរបស់ខ្លួន នឹងមិនផ្តល់ហិរញ្ញប្បទានជូន។

19 សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៩។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

20 គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌទី៣៣ និង ៣៥, ទិដ្ឋភាពទូទៅអំពីស្តង់ដារសមិទ្ធកម្ម ឆ្នាំ២០១២ កថាខណ្ឌទី៥, PS១ ឆ្នាំ២០១២ កថាខណ្ឌទី៧ និង ១២, PS៧ ឆ្នាំ២០១២ កថាខណ្ឌទី១ ៨ និង ៩, និងបញ្ជីផាត់ចេញរបស់ IFC។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៩, PS១ ឆ្នាំ២០០៦ កថាខណ្ឌទី៣ ៤ ៨ និង ១២, PS៧ ឆ្នាំ២០០៦ កថាខណ្ឌទី១ ៣ ៧ និង ៨ និងបញ្ជីផាត់ចេញរបស់ IFC ឆ្នាំ២០០៧។

លក្ខខណ្ឌតម្រូវ E&S របស់ IFC។ ដូច្នេះ ការស៊ើបអង្កេតរបស់ស៊ីអេអូបានត្រួតពិនិត្យភាពអនុលោមរបស់ IFC តាមបញ្ញត្តិនៃក្របខណ្ឌនិរន្តរភាពទាំងនេះ។

## ការវិភាគអំពីភាពអនុលោម និង គំហើញរបស់ស៊ីអេអូ

សម្រាប់ការស៊ើបអង្កេតនេះ ស៊ីអេអូបានវិភាគភាពអនុលោមរបស់ IFC តាមគោលនយោបាយ E&S របស់ខ្លួនទាក់ទងនឹងបញ្ហានៃពាក្យបណ្តឹង ដូចបានសង្ខេបនៅខាងក្រោម។ ការវាយតម្លៃនេះបានពិចារណាលើការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន និងអតិថិជនបន្តដែលពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យសកម្មភាព និងភាពអនុលោមរបស់ IFC ពាក់ព័ន្ធនឹងជនងាយរងគ្រោះ ជនជាតិដើមភាគតិច និងយន្តការបណ្តឹងសារទុក្ខ និងដើម្បីវាយតម្លៃការខូចខាតដែលពាក់ព័ន្ធ។

ដើម្បីធានាថាការវាយតម្លៃភាពអនុលោមរបស់ IFC ចំពោះក្របខណ្ឌនិរន្តរភាពរបស់ខ្លួនគឺ ផ្អែកលើការយល់ដឹងយ៉ាងពេញលេញអំពីសកម្មភាពរបស់ IFC នោះ ស៊ីអេអូក៏បានពិចារណាអំពីកិច្ចខិតខំប្រឹងប្រែងរបស់ IFC ក្នុងការលើកកម្ពស់មីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ នៅក្រោម *បរិយាប័ន្នហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រការពារអ្នកប្រើប្រាស់*របស់ខ្លួនផងដែរ។ នៅខណៈពេលដែលបច្ចុប្បន្ន IFC មិនបានអនុវត្តគោលនយោបាយ E&S របស់ខ្លួនចំពោះអ្នកខ្ចីប្រាក់មីក្រូហិរញ្ញវត្ថុនោះទេ វាអនុវត្ត *យុទ្ធសាស្ត្រ*ដាច់ដោយឡែកនេះ ដោយផ្អែកតាមទស្សនវិស័យផ្នែកហិរញ្ញវត្ថុជាចម្បង ដើម្បីត្រួតពិនិត្យការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជនមីក្រូហិរញ្ញវត្ថុ ធៀបនឹងស្តង់ដារការពារអតិថិជន និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ដែលត្រូវបានបង្កើតឡើង (សូមមើលប្រអប់ខាងក្រោម)។ ស៊ីអេអូកត់សម្គាល់ថា ស្តង់ដារ GIIP មួយចំនួន ដែលពាក់ព័ន្ធនឹងការទប់ស្កាត់ផលប៉ះពាល់សង្គមអវិជ្ជមានលើអ្នកខ្ចីប្រាក់ មួយផ្នែកត្រូវបានអនុវត្តដោយ IFC តាមរយៈក្របខណ្ឌដាច់ដោយឡែកនេះ។

នៅទីបំផុត សំណួរដ៏សំខាន់សម្រាប់ការត្រួតពិនិត្យភាពអនុលោមរបស់ស៊ីអេអូគឺ ថាតើ IFC បានអនុវត្តតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាព ដោយមិនគិតពីក្របខណ្ឌ ឬកម្មវិធីផ្លូវការ ដែលខ្លួនត្រូវធ្វើសកម្មភាពស្របតាមនោះដែរឬទេ។

**យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់របស់ IFC**

**សេចក្តីសង្ខេបអំពីការអនុវត្តដែលពាក់ព័ន្ធ[21]**

នៅកម្រិតគម្រោង៖

- ការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ៖ ជាធម្មតា IFC បានរួមបញ្ចូលអ្នកឯកទេសមីក្រូហិរញ្ញវត្ថុ ជាផ្នែកមួយនៃក្រុមការងារផ្នែកហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធ្វើការត្រួតពិនិត្យគោលនយោបាយ និងនីតិវិធីហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជន FI រួមទាំងថាតើអតិថិជនបានអនុវត្តតាមស្តង់ដារ GIIP ស្តីពីការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុដែរឬទេ។ ដំណើរការនេះមិនរួមបញ្ចូលការផ្ទៀងផ្ទាត់ការអនុវត្តគោលការណ៍ និងនីតិវិធីទាំងនេះនោះទេ និងកម្រពាក់ព័ន្ធនឹងការចុះត្រួតពិនិត្យទីតាំង និងការសម្ភាសអ្នកខ្ចី ឬភាគីពាក់ព័ន្ធដទៃទៀតណាស់។
- ការព្រមព្រៀងមានការបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងតាមផ្លូវច្បាប់៖ កិច្ចព្រមព្រៀងវិនិយោគមួយចំនួនរួមបញ្ចូល

[21] យ៉ាងហោចណាស់ចាប់តាំងពីឆ្នាំ២០១១ មក IFC បានចាត់វិធានការដើម្បីរួមបញ្ចូលការពិចារណាផ្នែកហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវទៅក្នុងដំណើរការវិនិយោគរបស់ខ្លួន ជាពិសេសនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ តាមរយៈយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់។

ការព្រមព្រៀងមានការបញ្ជាក់ ដែលតម្រូវឱ្យមានការអនុលោមតាមគោលការណ៍ស្តីពីការការពារអតិថិជន និង គោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ IFC។ គោលការណ៍ទាំងនេះ ជាញឹកញាប់ ត្រូវបានរាយ នៅក្នុងឧបសម្ព័ន្ធ ប៉ុន្តែមិនមានកាតព្វកិច្ចរាយការណ៍របស់អតិថិជន ឬការផ្ទៀងផ្ទាត់ភាពអនុលោមរបស់ IFC ជាប់ មកជាមួយនោះទេ។

ភាពអនុលោមតាមគោលការណ៍ទាំងនេះរបស់អតិថិជន ឬគោលនយោបាយ និងការអនុវត្តរបស់អតិថិជនដែលត្រូវ បានត្រួតពិនិត្យក្នុងអំឡុងពេលនៃការត្រួតពិនិត្យភាពត្រឹមត្រូវ មិនត្រូវបានពិនិត្យតាមដានដោយ IFC ក្នុងអំឡុងពេល នៃដំណាក់កាលត្រួតពិនិត្យការវិនិយោគនោះទេ។ ដូច្នេះ មិនមានការត្រួតពិនិត្យឯកទេសលើការអនុវត្តការការពារអ្នក ប្រើប្រាស់ហិរញ្ញវត្ថុ នៅពេលដែលគម្រោងមួយត្រូវបានអនុម័តដោយ IFC នោះទេ។

នៅកម្រិតគោលនយោបាយតាមវិស័យ៖

- IFC បានធ្វើការជាមួយ និងគាំទ្ររដ្ឋាភិបាល សមាគមឧស្សាហកម្ម និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីបង្កើនសមត្ថភាព នៅក្នុងប្រទេស ពង្រឹងក្របខណ្ឌនិយ័តកម្ម និងផ្តល់សេវាទីប្រឹក្សាអំពីគោលនយោបាយ និងការអនុវត្តហិរញ្ញវត្ថុ ប្រកបដោយការទទួលខុសត្រូវ។
- នៅប្រទេសកម្ពុជាជាពិសេស IFC បានគាំទ្រដល់ការបង្កើតក្រុមហ៊ុនក្រេឌីតប៊្យូរកម្ពុជា (CBC) ដើម្បីពង្រឹងការវាយ តម្លៃបំណុលនៅកម្ពុជា នៅថ្នាក់ជាតិ និងបានផ្តល់ការប្រឹក្សាដល់រដ្ឋាភិបាលអំពីលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ និងបានផ្តល់ការប្រឹក្សា និងជាតុចូលដល់សមាគមឧស្សាហកម្មនានា ដូចជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងសមាគមធនាគារកម្ពុជា (ABC) ស្តីពីការអនុវត្តហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ។ (សូមមើលព័ត៌មាន លម្អិតបន្ថែមស្តីពីអភិក្រមរបស់ IFC នៅផ្នែក ៤.១)។

ចំពោះការវិភាគដែលបានបង្ហាញខាងក្រោម និងនៅក្នុងផ្នែកទី ៤ នៃរបាយការណ៍នេះ ស៊ីអេអូបានវាយតម្លៃ សកម្មភាពរបស់មន្ត្រីផ្នែកបរិស្ថាន និងសង្គមរបស់ IFC និងសមាជិកក្រុមវិនិយោគ ដូចជា អ្នកឯកទេសផ្នែក មីក្រូហិរញ្ញវត្ថុ ឬផ្នែកឧស្សាហកម្ម ជាដើម ដែលជាអ្នកត្រួតពិនិត្យការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូល ប្រាក់របស់អតិថិជន តាមទស្សនវិស័យផ្នែកហិរញ្ញវត្ថុ ដែលពាក់ព័ន្ធ។ ការវិភាគនេះវាយតម្លៃពីសង្គតិភាពនៃ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យជាមួយគោលនយោបាយ និរន្តរភាពរបស់ IFC រួមទាំងការព្យាយាមធានាថា ការវិនិយោគទាំងនោះបានប្រកាន់ខ្ជាប់នូវស្តង់ដារសមិទ្ធកម្ម របស់ IFC ដោយមិនគិតថាអ្នកណាបានអនុវត្តសកម្មភាពទាំងនោះឡើយ។

## ១. សង្គតិភាពនៃការវិនិយោគរបស់ IFC នឹងស្តង់ដារសមិទ្ធកម្មរបស់ IFC

ដូចបានពន្យល់ខាងលើ គោលនយោបាយនិរន្តរភាពរបស់ IFC តម្រូវឱ្យសកម្មភាពដែល IFC ផ្តល់ហិរញ្ញប្បទាន រួមទាំង ការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន និងអតិថិជនបន្តរបស់ IFC គួរតែស្រប នឹងស្តង់ដារសមិទ្ធកម្មរបស់ IFC[22] រួមទាំង GIIP និងច្បាប់ជាតិ ដែលពាក់ព័ន្ធផងដែរ ដើម្បីបញ្ចៀស និងកាត់ បន្ថយផលប៉ះពាល់សង្គមអវិជ្ជមានលើជនងាយរងគ្រោះ និងជនជាតិដើមភាគតិច។ កម្រិតដែលការអនុវត្ត ការផ្តល់ប្រាក់កម្ចីរបស់អតិថិជន និងអតិថិជនបន្តរបស់ IFC មានសង្គតិភាពនឹងលក្ខខណ្ឌតម្រូវទាំងនេះ គឺជា ចំណុចពិចារណាដ៏សំខាន់មួយក្នុងការកំណត់ថាតើ IFC បានអនុលោមតាមកាតព្វកិច្ចរបស់ខ្លួន នៅក្រោម ក្របខណ្ឌនិរន្តរភាពក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគទាំងនេះដែរឬទេ។

[22] កថាខណ្ឌទី៧ នៃគោលនយោបាយនិរន្តរភាពឆ្នាំ២០១២ ចែងថា "IFC ព្យាយាមធានា [...] ថា សកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ ហិរញ្ញប្បទានជូន បានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម"។

ក្នុងការពិចារណាលើភាពអនុលោមរបស់ IFC ស៊ីអេអូបានត្រួតពិនិត្យសកម្មភាពរបស់ IFC ដែលរួមមានជាអាទិ៍ សកម្មភាពដែលស្ថិតនៅក្រោម *យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់* ដែលអាចនាំឱ្យសម្រេចបាននូវសង្គតិភាពជាមួយបទប្បញ្ញត្តិនៃ PS១ ស្ដីពីការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ។

នៅខណៈពេលដែលការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូ មិនធ្វើឲ្យគំហើញនៃបដិលោមទាក់ទងនឹងគម្រោង ឬអនុគម្រោងជាក់លាក់ណាមួយនោះទេ ស៊ីអេអូពិចារណាលើសមិទ្ធកម្ម E&S នៅកម្រិតគម្រោង ឬអនុគម្រោង នៅពេលកំណត់ភាពអនុលោមរបស់ IFC ជាមួយនឹងលក្ខខណ្ឌតម្រូវ E&S របស់ខ្លួន និងនៅពេលវាយតម្លៃការខូចខាត។[23] ការសង្កេតរបស់ស៊ីអេអូ ទាក់ទងនឹងសកម្មភាពរបស់ IFC ដើម្បីធានាថា គម្រោងមីក្រូហិរញ្ញវត្ថុដែលខ្លួនបានផ្តល់ហិរញ្ញប្បទានស្របនឹង PS ដែលពាក់ព័ន្ធ មានបង្ហាញនៅខាងក្រោម។

**ក) ESMS គ្រប់គ្រាន់សម្រាប់ជនងាយរងគ្រោះ ស្របតាម PS១៖** អតិថិជន FI របស់ IFC ត្រូវបានតម្រូវឱ្យអនុវត្ត ESMS នៃគម្រោង អនុលោមតាម PS១ ដែលកំណត់ និងអនុវត្តវិធានការកាត់បន្ថយពិសេសសម្រាប់ជនងាយរងគ្រោះ ដោយអនុវត្តតាមស្តង់ដារ GIIP។ ទាក់ទងនឹងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ (BFIs) នៅក្នុងសំណុំរឿងនេះ GIIP តម្រូវឱ្យអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ៖

- ធ្វើការវាយតម្លៃសមត្ថភាពសងប្រាក់របស់អ្នកខ្ចីឱ្យបានត្រឹមត្រូវ
- រចនាផលិតផលដើម្បីការពារអតិថិជនពីគ្រោះថ្នាក់ រួមទាំងតាមរយៈការមិនទទួលយកវត្ថុបញ្ចាំដែលនឹងបង្កើតការលំបាកធ្ងន់ធ្ងរ ឬការបាត់បង់សមត្ថភាពស្វែងរកប្រាក់ចំណូលយ៉ាងខ្លាំងក្លាចំពោះអតិថិជន
- ផ្តល់ព័ត៌មានច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលា ដើម្បីអនុញ្ញាតឱ្យប្រជាជនដែលអាចរងផលប៉ះពាល់ ធ្វើការសម្រេចចិត្តដោយមានព័ត៌មានពេញលេញ
- អនុវត្តការការពារដ៏រឹងមាំ ដើម្បីរកឱ្យឃើញ និងកែតម្រូវការអនុវត្តបែបឈ្លានពាន ឬរំលោភបំពានក្នុងអំឡុងពេលផ្តល់ប្រាក់កម្ចី និងប្រមូលបំណុល ដែលត្រូវបានហាមឃាត់ដោយច្បាប់កម្ពុជា។

ក្នុងដំណើរការនៃការស៊ើបអង្កេតនេះ ស៊ីអេអបានពិចារណាលើគោលនយោបាយរបស់អតិថិជន និងអតិថិជនបន្ត ការសិក្សាទូទាំងវិស័យ និងឯកសារសិក្សា និងបានសម្ភាសអ្នកខ្ចីប្រាក់មីក្រូហិរញ្ញវត្ថុ បុគ្គលិក BFI អ្នកឯកទេសផ្នែកឧស្សាហកម្ម ស្ថាប័នសិក្សា សង្គមស៊ីវិល និងបុគ្គលិក IFC។ ស៊ីអេអូបានសង្កេតឃើញចន្លោះប្រហោងរវាងការអនុវត្តរបស់ BFI និងស្តង់ដារ GIIP ដូចបានរៀបរាប់ខាងលើ ដែលត្រូវតម្រូវដោយ PS១ ដូចខាងក្រោម៖

- *ការអនុម័តការអនុម័តប្រាក់កម្ចី* ស៊ីអេអូបានសង្កេតឃើញថា គោលនយោបាយ និងការអនុវត្តរបស់ BFIs មិនចាំបាច់ធានាបាននូវការវាយតម្លៃយ៉ាងគ្រប់គ្រាន់លើសមត្ថភាពសងបំណុលរបស់អ្នកខ្ចីដែលងាយរងគ្រោះនោះទេ។ ចំណុចខ្សោយ រួមមាន ការពឹងផ្អែកលើដីធ្លីបញ្ចាំខ្លាំងពេក និងកង្វះខាតការការពារយ៉ាងគ្រប់គ្រាន់ ដើម្បីទប់ស្កាត់បុនហិរញ្ញប្បទានដែលមានហានិភ័យខ្ពស់ ដោយអ្នកខ្ចីត្រូវបានលើកទឹកចិត្តឲ្យទទួលយកប្រាក់កម្ចីថ្មីដែលមានទំហំកាន់តែធំដើម្បីសងកម្ចីដែលមានស្រាប់។
- *ការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់បែបឈ្លានពាន* អ្នកខ្ចី ជាញឹកញាប់ បានរាយការណ៍ពីការអនុវត្ត ដែលតាមគំនិតរបស់ពួកគេ ដាក់សម្ពាធពួកគេឲ្យទទួលយកប្រាក់កម្ចីដែលមានទំហំធំជាងអ្វី

[23] គោលនយោបាយស៊ីអេអូ ឆ្នាំ២០១២ កថាខណ្ឌទី ១១៤

ដែលពួកគេត្រូវការ ឬអាចសងវិញបាន ហើយងាកទៅរកយន្តការដោះស្រាយដែលមានគ្រោះថ្នាក់ ដើម្បីបំពេញកាតព្វកិច្ចសងប្រាក់កម្ចី។ ការអនុវត្តដែលឈ្លានពាន រួមមាន ការទៅមើលផ្ទះ និងកន្លែងធ្វើការរបស់អ្នកខ្ចីជាបន្តបន្ទាប់ ការបញ្ចុះបញ្ចូលឱ្យទទួលយកប្រាក់កម្ចីក្នុងទំហំកាន់តែធំ ដោយផ្អែកលើតម្លៃវត្ថុបញ្ចាំ និងការចូលរួមពីមេភូមិ និងមេឃុំនៅក្នុងមូលដ្ឋាន ក្នុងការផ្សាយពាណិជ្ជកម្ម និងផ្សព្វផ្សាយផលិតផលកម្ចីដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ។

លើសពីនេះទៀត អ្នកខ្ចីបានរាយការណ៍យ៉ាងខ្ជាប់ខ្ជួនអំពីកលយុទ្ធប្រមូលបំណុល ដែលមិនមែនតែងតែបានរួមបញ្ចូលនៅក្នុងឯកសារគោលនយោបាយរបស់ BFIs ទាំងប្រាំមួយជាផ្លូវការនោះទេ ប៉ុន្តែត្រូវបានប្រើប្រាស់ដោយបុគ្គលិក BFI មួយចំនួន។ ការអនុវត្តទាំងនេះត្រូវបានរាយការណ៍ថា រួមមាន ការចូលរួមពីមេភូមិ និងមេឃុំនៅក្នុងមូលដ្ឋានក្នុងការប្រមូលបំណុល តាមរយៈមធ្យោបាយនានា ដូចជា ការកោះហៅអ្នកខ្ចីទៅសួរចម្លើយអំពីការសងបំណុលយឺតយ៉ាវរបស់ពួកគេ[24] ការធ្វើឲ្យអ្នកខ្ចីមានភាពខ្មាស់អៀនជាសាធារណៈ ការគំរាមរឹបអូសដីធ្លី ឬផ្ទះសម្បែង និងការផ្តល់យោបល់ឲ្យគ្រួសារខ្ចីប្រាក់ពីអ្នកផ្តល់ប្រាក់កម្ចីក្រៅប្រព័ន្ធ ដែលមានការប្រាក់លើសពីអត្រាដែលច្បាប់បានកំណត់ និងគ្មានការការពារតាមផ្លូវច្បាប់ ឬបញ្ឈប់កូនពីសាលារៀន ដើម្បីឲ្យពួកគេទៅធ្វើការសងប្រាក់កម្ចី។។

ស៊ីអេអូសង្កេតឃើញថា IFC ខ្វះខាតការត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គម លើការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន ដើម្បីធានាថាពួកគេបានអនុវត្តស្របតាម GIIP និងបានដោះស្រាយហានិភ័យ និងផលប៉ះពាល់លើអ្នកខ្ចីប្រាក់ដែលងាយរងគ្រោះ ស្របតាមស្តង់ដារសមិទ្ធិកម្មទី១ (PS1)។

**ខ. ការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច៖** PS7 និងបញ្ជីផាត់ចេញរបស់ IFC តម្រូវឱ្យអតិថិជនរបស់ IFC ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច និងជៀសវាងការប៉ះពាល់ដីធ្លីរបស់ពួកគេដោយមិនមានការយល់ព្រមពីពួកគេ។ លើសពីនេះទៀត ច្បាប់ជាតិកម្ពុជា ក៏បានហាមឃាត់យ៉ាងច្បាស់លាស់ មិនឲ្យអ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុទទួលយកប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច (ICLTs) ជាវត្ថុបញ្ចាំនោះទេ។ ទាក់ទងនឹងពាក្យបណ្តឹងនេះ GIIP ទាមទារឱ្យមានការរចនាផលិតផលមីក្រូហិរញ្ញវត្ថុដែលផ្តល់អត្ថប្រយោជន៍ដល់អតិថិជន និង BFIs ដើម្បីធានាបាននូវការប្រាស្រ័យទាក់ទងយ៉ាងច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលាជាមួយអ្នកខ្ចី ក្នុងលក្ខណៈ និងភាសាដែលពួកគេអាចយល់បាន។ ស៊ីអេអូបានសម្គាល់ឃើញចន្លោះប្រហោងខាងក្រោម រវាងការអនុវត្តរបស់អតិថិជន និងអតិថិជនបន្ត និងលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងសង្គមរបស់ IFC៖

---

[24] IFC និង BFI មួយ ដែលបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះ បានផ្តល់ទឡ្ហីករណ៍ថា ការអនុវត្តមួយចំនួនដែលរួមបញ្ចូលអាជ្ញាធរមូលដ្ឋាន គឺជាផ្នែកមួយនៃតួនាទីរបស់អាជ្ញាធរទាំងនេះនៅក្នុងប្រទេសកម្ពុជា ក្នុងការសម្របសម្រួលវិវាទនានា។ ទោះបីជាអាជ្ញាធរមូលដ្ឋានកំពុងដើរតួជាអ្នកសម្របសម្រួល ឬក្នុងឋានៈផ្សេងទៀតក៏ដោយ ក៏ស៊ីអេអូបានស្តាប់ឮជាបន្តបន្ទាប់ ពីដើមបណ្តឹង សង្គមស៊ីវិល និងអ្នកសិក្សា ដែលមានចំណេះដឹងអំពីបរិបទសង្គមនៅកម្ពុជាថា ការអនុវត្តទាំងនេះបង្កើតការភ័យខ្លាច និងការភ័ន្តច្រឡំក្នុងចំណោមអ្នកខ្ចីដែលងាយរងគ្រោះ។ អ្នកខ្ចីទាំងនេះច្រើនតែមិនដឹងច្បាស់អំពីភាពខុសគ្នារវាងតួអង្គនៃរដ្ឋាភិបាល និងតួអង្គឯកជននោះទេ ដែលនេះជាការភ័ន្តច្រឡំដែលលិខិតបទដ្ឋានគតិយុត្តិរបស់រដ្ឋាភិបាល ដែលពាក់ព័ន្ធ ព្យាយាមទប់ស្កាត់។ យោងតាមអ្នកសិក្សាសង្គម ការរួមបញ្ចូលគ្នានៃអំណាចក្នុងមូលដ្ឋាន ភាពអាម៉ាស់ និងការទទួលខុសត្រូវផ្នែកសីលធម៌ ជាញឹកញាប់ ជម្រុញឱ្យអ្នកខ្ចីដែលងាយរងគ្រោះទទួលយកយុទ្ធសាស្ត្រទប់ទល់ដែលមានគ្រោះថ្នាក់ ដើម្បីសងបំណុលរបស់ពួកគេ ទោះបីជាវានឹងបង្កើតការលំបាកយ៉ាងខ្លាំងក្លាក៏ដោយ។ ព័ត៌មានលម្អិតបន្ថែមទៀត មាននៅក្នុងផ្នែក ៤.២។

- *ការបញ្ចាំដីជនជាតិដើមភាគតិច* នៅក្នុងករណីជាច្រើន BFIs បានទទួលយកវត្ថុបញ្ចាំជាដីធ្លី ដែលស្ថិតនៅក្នុងទឹកដីរបស់ជនជាតិដើមភាគតិច [25] ដែលមានហានិភ័យនៃការបាត់បង់បំណែកដីសហគមន៍ ដោយមិនមានការយល់ព្រមពីសហគមន៍ និងបង្កហានិភ័យជាបន្តបន្ទាប់ដល់បូរណភាពដីធ្លី វប្បធម៌ និងលទ្ធភាពទទួលបានធនធានធម្មជាតិរបស់សហគមន៍ជនជាតិដើមភាគតិច ជាហានិភ័យដែល PS7 តម្រូវឲ្យអតិថិជនជៀសវាង
- *កង្វះខាតផលិតផលដែលមានសមស្របផ្នែកវប្បធម៌* ស៊ីអេអូបានរកឃើញថា មិនមានការចង្អុលបង្ហាញថា BFIs នៅក្នុងសំណុំរឿងនេះ ដែលធ្វើការនៅតំបន់ជនជាតិដើមភាគតិចភាគច្រើន បានបង្កើតផលិតផលដែលគិតគូរពីវប្បធម៌ និងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចនោះទេ ដូចជា ការផ្តល់ផលិតផលជំនួសឲ្យវត្ថុបញ្ចាំជាដីធ្លី ជាពិសេសសម្រាប់អ្នកខ្ចីជាជនជាតិដើមភាគតិច។ ដោយសារតួនាទីដ៏សំខាន់របស់ដីធ្លី ពាក់ព័ន្ធនឹងអត្តសញ្ញាណ មុខរបរចិញ្ចឹមជីវិត ប្រវត្តិសាស្ត្រ និងបេតិកភណ្ឌវប្បធម៌របស់ជនជាតិដើមភាគតិចនោះ ការបាត់បង់ដីធ្លីទាំងនោះអាចបង្កការខូចខាតយ៉ាងខ្លាំង
- *កង្វះខាតការប្រាស្រ័យទាក់ទងដែលសមស្រប* ស៊ីអេអូបានរកឃើញថា ពុំមានការចង្អុលបង្ហាញថា BFIs បានបកប្រែព័ត៌មាន ឬឯកសារនានា ជាភាសាជនជាតិដើមភាគតិច នៅក្នុងតំបន់ដែលប្រជាជនភាគច្រើនជាជនជាតិដើមភាគតិចនោះទេ ដែលរារាំងដល់ការប្រាស្រ័យទាក់ទងជាមួយជនជាតិដើមភាគតិច ដែលជាញឹកញាប់ ជាអតិថិជនគោលដៅនៅក្នុងតំបន់ទាំងនេះ។

**គ) ការបង្កើតយន្តការបណ្តឹងសារទុក្ខអំពីគម្រោង ស្របតាម PS1៖** PS1 (កថាខណ្ឌទី២២ ទី៣៥)[26] GIIP និងលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិទាំងអស់ តម្រូវឲ្យអតិថិជនរបស់ IFC/គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បង្កើតយន្តការបណ្តឹងសារទុក្ខ ដើម្បីទទួល វាយតម្លៃ និងធ្វើសកម្មភាពលើការតវ៉ាពីប្រជាជនដែលរងផលប៉ះពាល់ពីគម្រោង។ នៅខណៈពេលដែល BFIs ទាំងប្រាំមួយមានគោលនយោបាយគ្រប់គ្រងពាក្យបណ្តឹងរួចហើយនោះ អ្នកខ្ចីបានរាយការណ៍ថា យន្តការបណ្តឹងសារទុក្ខទាំងនេះមិនគ្រប់គ្រាន់សម្រាប់ដោះស្រាយការតវ៉ានោះទេ ហើយជាញឹកញាប់ វាត្រូវបានប្រើជាឧបករណ៍សម្រាប់ដាក់សម្ពាធលើអ្នកខ្ចីបន្ថែមទៀត។ ស៊ីអេអូបានរកឃើញថា IFC មិនបានធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃ PS1 នោះទេ។

- នៅក្នុងសំណុំរឿងជាច្រើន អ្នកខ្ចីបានអះអាងថា ដំណើរការដោះស្រាយពាក្យបណ្តឹង ជាញឹកញាប់បានក្លាយជា "ដំណើរការស្វែងរកការពិត" ដើម្បីបំភិតបំភ័យ និងបង្ខូចកេរ្តិ៍ឈ្មោះដើមបណ្តឹង ជាជាងការដោះស្រាយបញ្ហាបុគ្គល ដែលបានលើកឡើង
- ដើមបណ្តឹងក៏បានរាយការណ៍ផងដែរថា សកម្មភាពរបស់អតិថិជន និងអតិថិជនបន្តរបស់ IFC មួយចំនួនអាចរួមចំណែកដល់បរិបទកាន់តែទូលំទូលាយនៃការសងសឹកអ្នករិះគន់អំពីការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

[25] ដើមបណ្តឹងដែលជាជនជាតិដើមភាគតិចទាំងប្រាំពីរនាក់នៅក្នុងសំណុំរឿងនេះបានរាយការណ៍ថា អតិថិជន/អតិថិជនបន្តរបស់ IFC ចំនួនបួន បានទទួលយកប្លង់ដីទន់ ដែលត្រួតស៊ីគ្នាជាមួយប័ណ្ណ ICLT របស់ពួកគេ។

[26] សម្រាប់ការវិនិយោគរបស់ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី១៧ និងទី២៩។ សម្រាប់ការវិនិយោគរបស់ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

## ២. អនុលោមភាពរបស់ IFC ចំពោះលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាពដែលថា សកម្មភាពមីក្រូហិរញ្ញវត្ថុដែលខ្លួនផ្តល់ហិរញ្ញប្បទានបំពេញតាមស្តង់ដារសមិទ្ធកម្មដែលពាក់ព័ន្ធ

**ក) ការកំណត់ ការវាយតម្លៃ និងការគ្រប់គ្រងផលប៉ះពាល់ផ្សេងៗលើក្រុមងាយរងគ្រោះ៖** ស្របតាមលក្ខខណ្ឌតម្រូវរបស់ PS1 ដែលបានរៀបរាប់ខាងលើ អតិថិជន FI និងអតិថិជនបន្តរបស់ IFC គួរតែបានកំណត់អត្តសញ្ញាណអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ដែលភាគច្រើនជាជនក្រីក្រ មានអក្ខរកម្មទាប និងស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចមិនស្ថិតស្ថេរ ថាងាយរងគ្រោះ និងបានអនុវត្តការការពារដែលសមស្រប តាមរយៈប្រព័ន្ធគ្រប់គ្រង E&S របស់ពួកគេ។ ស៊ីអេអូរកឃើញថា ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគ និងត្រួតពិនិត្យការវិនិយោគ IFC មិនបានតម្រូវឱ្យអតិថិជនរបស់ខ្លួនចាត់វិធានការទាំងនេះទេ។[27] ស្របតាមគោលជំហររបស់ខ្លួនដែលថា អ្នកខ្ចីមីក្រូហិរញ្ញវត្ថុមិនមែនជាជនដែលរងផលប៉ះពាល់ ដែលវិធានការកាត់បន្ថយហានិភ័យផ្នែកបរិស្ថាន និងសង្គម ត្រូវអនុវត្តចំពោះពួកគេនោះទេ IFC មិនបានតម្រូវឱ្យអតិថិជនរបស់ខ្លួនកំណត់ និងវាយតម្លៃភាពងាយរងគ្រោះរបស់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ និងគ្រួសាររបស់ពួកគេ ឬអនុវត្តវិធានការកាត់បន្ថយយ៉ាងសមស្របសម្រាប់ការវិនិយោគទាំងនេះទេ។

ស៊ីអេអូកត់សម្គាល់ថា ផលិតផលមីក្រូហិរញ្ញវត្ថុត្រូវបានរចនាសម្រាប់ប្រជាជនមួយផ្នែកបានទទួលសេវាមិនគ្រប់គ្រាន់ និងថា អ្នកខ្ចី និងគ្រួសាររបស់ពួកគេភាគច្រើនមានអក្ខរកម្មក្នុងការអាន ការសរសេរ ផ្នែកហិរញ្ញវត្ថុ និងច្បាប់នៅកម្រិតទាប ជាកត្តាដែលជះឥទ្ធិពលលើភាពងាយរងគ្រោះរបស់ប្រជាជន ឬគ្រួសារ។[28] ទោះបីជាយ៉ាងណាក៏ដោយ IFC បានចាត់ថ្នាក់គម្រោងទាំង ១៣ ថាមានហានិភ័យផ្នែកបរិស្ថាន និងសង្គមពីកម្រិតមធ្យមទៅទាប ដោយមិនគិតពីហានិភ័យ និងផលប៉ះពាល់សង្គមដែលបានចងក្រងជាឯកសារ លើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុដែលងាយរងគ្រោះនៅកម្ពុជា រួមទាំងការបាត់បង់ដីធ្លី ការធ្លាក់ចុះនៃជីវភាពរស់នៅ និងការបាត់បង់លទ្ធភាពទទួលបានការអប់រំនោះទេ។[29] ហានិភ័យ និងផលប៉ះពាល់ទាំងនេះត្រូវបានចងក្រងឯកសារយ៉ាងទូលំទូលាយ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០ មក និងត្រូវបានទទួលស្គាល់ដោយក្រុមធនាគារពិភពលោក

[27] IFC ត្រូវបានតម្រូវឲ្យអនុវត្តការត្រួតពិនិត្យភាពត្រឹមត្រូវលើហានិភ័យ និងផលប៉ះពាល់នានា ស្របតាមលក្ខណៈ វិសាលភាព និងភាពជាក់លាក់នៃគម្រោង គោលនយោបាយនិរន្តរភាព (កថាខណ្ឌទី ១៩ ២១ ៣២-៣៣)។ សម្រាប់ការវិនិយោគរបស់ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី១៣ ២៧-២៩។ សម្រាប់ការវិនិយោគរបស់ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

[28] ជនទាំងនេះ ជាញឹកញាប់ រួមមាន បុគ្គល និងគ្រួសារក្រីក្រ និងមានប្រាក់ចំណូលទាប ដែលខ្វះលទ្ធភាពទទួលបានសេវាធនាគារបែបប្រពៃណី ដោយសារពួកគេមិនបំពេញតាមលក្ខខណ្ឌតម្រូវនៃទ្រព្យបញ្ចាំធម្មតា ប្រាក់ចំណូល ឬប្រវត្តិឥណទាន។

[29] គោលនយោបាយនិរន្តរភាពតម្រូវឱ្យ IFC (i) កំណត់ហានិភ័យផ្នែកបរិស្ថាន និងសង្គមនៃការវិនិយោគ FI របស់ខ្លួន ដោយគិតគូរពីហានិភ័យនៃសកម្មភាពអាជីវកម្មជាក់លាក់របស់ FI និងព័ត៌មានអំពីហានិភ័យដោយផ្ទាល់ (ii) កំណត់លក្ខខណ្ឌតម្រូវដើម្បីគ្រប់គ្រងហានិភ័យទាំងនោះ និង (iii) ចាត់ថ្នាក់ការវិនិយោគរបស់ខ្លួន ដោយគិតគូរពីទំហំពេញលេញនៃហានិភ័យផ្នែកបរិស្ថាន និងសង្គម និងផលប៉ះពាល់នៃការវិនិយោគទាំងនោះ ដោយពិចារណាលើហានិភ័យផ្នែកបរិស្ថាន និងសង្គមដែលមានមកជាមួយ ទាក់ទងនឹងវិស័យជាក់លាក់ណាមួយ ព្រមទាំងបរិបទនៃសកម្មភាពអាជីវកម្មផងដែរ។ គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌទី៣២ ៣៤ ៤០ និង ៤២។ សម្រាប់ការវិនិយោគរបស់ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី១៣ ១៨ និង ២៧-២៩។ សម្រាប់ការវិនិយោគរបស់ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

រួមទាំង IFC ផងដែរ។[30]

ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC មិនបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់គោលនយោបាយនិរន្តរភាពនោះទេ (កថាខណ្ឌទី២២ ៣១-៣៥) ពីព្រោះវាមិនបានរួមបញ្ចូលការត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គម[31] នៃសមត្ថភាពរបស់អតិថិជនក្នុងការគ្រប់គ្រងហានិភ័យសង្គមនៃមីក្រូហិរញ្ញវត្ថុលើជនងាយរងគ្រោះឲ្យបានគ្រប់គ្រាន់ ឬសមត្ថភាពរបស់ពួកគេក្នុងការធានាថា អនុគម្រោងរបស់ពួកគេមិនមានហានិភ័យសង្គមនៃមីក្រូហិរញ្ញវត្ថុលើជនងាយរងគ្រោះតាមដែលអាចធ្វើបាននោះទេ។[32] ស៊ីអេអូយល់ឃើញថា កិច្ចខិតខំប្រឹងប្រែងរបស់ IFC នៅក្រោម *យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់*របស់ខ្លួន ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគគឺមិនគ្រប់គ្រាន់ ដើម្បីធានាថា អតិថិជន និងអតិថិជនបន្តរបស់ខ្លួនបានបង្កើត និងអនុវត្តប្រព័ន្ធគ្រប់គ្រង ស្របតាម GIIP និងលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែលពាក់ព័ន្ធនោះទេ។ ជាពិសេស IFC មិនបានធានាថា អ្នកផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ បានបង្កើត និងអនុវត្ត ESMS ដែលមានសមត្ថភាពកំណត់អត្តសញ្ញាណបុគ្គល និងក្រុមដែលជួបការលំបាក ឬងាយរងគ្រោះ និងបានអនុវត្តវិធានការផ្សេងៗ ដើម្បីកុំឱ្យផលប៉ះពាល់អវិជ្ជមានធ្លាក់ទៅលើពួកគេដោយមិនសមាមាត្រនោះទេ។[33] លើសពីនេះទៀត IFC មិនបានធានាថាអតិថិជនរបស់ខ្លួនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃ PS1 ដែលត្រូវអនុវត្តតាម និងធានាថា អតិថិជនបន្តបានអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែលហាមឃាត់អាជ្ញាធរមូលដ្ឋានមិនឲ្យផ្សព្វផ្សាយផលិតផលប្រាក់កម្ចី ការផ្តល់សេវាជាភ្នាក់ងារលក់ ឬការទាមទារឲ្យអ្នកខ្ចីសងប្រាក់នោះទេ។[34]

ដោយផ្អែកលើចំណុចខាងលើ ស៊ីអេអូយល់ឃើញថា IFC មិនបានបំពេញកាតព្វកិច្ចនៃគោលនយោបាយនិរន្តរភាពរបស់ខ្លួន ក្នុងការរៀបចំ និងអនុវត្តការវិនិយោគរបស់ខ្លួន ក្នុងគោលបំណង "មិនបង្កគ្រោះថ្នាក់" និងធានាថាសកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ហិរញ្ញប្បទានបំពេញតាមលក្ខខណ្ឌតម្រូវនៃ PS1 ជាពិសេស ការការពារក្រុមងាយរងគ្រោះ (កថាខណ្ឌទី៧ ៩ និង ២២) នោះទេ។

[30] នៅឆ្នាំ២០០៩ ការវាយតម្លៃដែលផ្តល់មូលនិធិដោយធនាគារពិភពលោកបានពិពណ៌នាអំពីអសមត្ថភាពក្នុងការសងប្រាក់កម្ចីថាជា "កង្វល់ដ៏ខ្លាំងក្លាមួយសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ" នៅកម្ពុជា។ នៅឆ្នាំ២០១៥ ឯកសារគោលនយោបាយរបស់ IFC បានគូសបញ្ជាក់ពីហានិភ័យសង្គមដែលអាចកើតឡើងនៃបំណុលវ័ណ្ឌករបស់អ្នកប្រើប្រាស់ម្នាក់ៗ។ ចាប់ពីឆ្នាំ២០១៩ មក អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអង្គការសហប្រជាជាតិបានរាយការណ៍ជាបន្តបន្ទាប់អំពីផលប៉ះពាល់ផ្នែកសង្គមសំខាន់ៗចំពោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា (សូមមើលព័ត៌មានលម្អិតបន្ថែមនៅក្នុងផ្នែក ១.១.២ និង ៤.២ នៃរបាយការណ៍នេះ)។

[31] ការវិភាគរបស់ស៊ីអេអូបានពិចារណាទាំងដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែក E&S របស់ IFC និងដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកមីក្រូហិរញ្ញវត្ថុជាពិសេស ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់របស់ IFC។ វាបានរកឃើញថា ដំណើរការទាំងពីរមិនបានវាយតម្លៃហានិភ័យ E&S ដែលទាក់ទងនឹងមីក្រូហិរញ្ញវត្ថុសម្រាប់ជនងាយរងគ្រោះឱ្យបានគ្រប់គ្រាន់នោះទេ។

[32] សម្រាប់ការវិនិយោគរបស់ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី១៧ និង ២៧-២៩។

[33] ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌទី៣៣ និង ៣៥ និង PS1 កថាខណ្ឌទី៧ និង ១២។ សម្រាប់ការវិនិយោគរបស់ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី២៧-២៩ និង PS1 ឆ្នាំ២០០៦ កថាខណ្ឌទី៤ ៨ និង ១២។ សម្រាប់ការវិនិយោគរបស់ Advans សូមមើល ESRP ឆ្នាំ១៩៩៨ កថាខណ្ឌទី២២ ជើងទំព័រទី៧។

[34] ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌទី៣៥ និងទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌទី៥។ សម្រាប់ការវិនិយោគរបស់ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី២៨ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌទី៣ និងសម្រាប់ការវិនិយោគរបស់ Advans IFC OP ៤.០១ កថាខណ្ឌទី៩។

**ខ) ការកំណត់ ការវាយតម្លៃ និងការគ្រប់គ្រងផលប៉ះពាល់លើជនជាតិដើមភាគតិច៖** មុនពេលវិនិយោគ IFC មិនបានអនុវត្តក្របខណ្ឌនិរន្តរភាព ដើម្បីត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតឡើងលើជនជាតិដើមភាគតិច ឬកំណត់វិធានការកាត់បន្ថយដែលពាក់ព័ន្ធ នៅក្នុងការវិនិយោគដែលគ្របដណ្ដប់ដោយសំណុំរឿងនេះទេ ដែលរួមទាំងអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការនៅក្នុងតំបន់ IP ភាគច្រើនផងដែរ។ ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ IFC បានពឹងផ្អែកលើការរាយការណ៍របស់អតិថិជនដោយផ្ទាល់ ដោយមិនមានចងក្រង ឯកសារអំពីការផ្ទៀងផ្ទាត់ថា គម្រោងរបស់ពួកគេនឹងមិននាំមកនូវហានិភ័យនៃផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច ឬដីធ្លី និងបេតិកភណ្ឌវប្បធម៌របស់ពួកគេនោះទេ។

នៅខណៈពេលដែលគម្រោងទាំង ១៣ បានតម្រូវឱ្យមានការអនុវត្តបញ្ជីផាត់ចេញរបស់ IFC ដែលបញ្ជាក់ពីប្រភេទគម្រោងដែលស្ថាប័ននឹងមិនផ្តល់ហិរញ្ញប្បទាននោះ IFC បានធ្វើការត្រួតពិនិត្យមុនពេលវិនិយោគតិចតួចចំពោះអតិថិជនដែលមានស្រាប់។ នៅគ្រប់ករណីដែលស៊ីអេអូបានត្រួតពិនិត្យ IFC បានអនុវត្តបញ្ជីផាត់ចេញចំពោះផលប៉ះពាល់ដែលអាចកើតឡើងនៃអនុគម្រោង ប៉ុន្តែមិនមែនចំពោះសកម្មភាពរបស់អតិថិជន FI ដោយផ្ទាល់នោះទេ និងមិនមានភស្តុតាងណាមួយដែលថា IFC បានផ្តល់ព័ត៌មានដល់អតិថិជនអំពីរបៀបដោះស្រាយដីធ្លី IP ដែលមិនមានការទទួលស្គាល់ជាផ្លូវការ ឬថាអតិថិជនយល់ពីរបៀបដោះស្រាយវានោះទេ។ ក្នុងអំឡុងពេលត្រួតពិនិត្យទីតាំង និងសម្ភាសជាមួយបុគ្គលិកសាខាងក្នុងមូលដ្ឋាន ជាពិសេសក្នុងតំបន់ដែលប្រជាជនភាគច្រើនជា IP នោះ ស៊ីអេអូបានសង្កេតឃើញថា បុគ្គលិក BFIs ដែលបានសម្ភាស ភាគច្រើន មានការយល់ដឹងស្រពិចស្រពិលអំពីលក្ខខណ្ឌតម្រូវនៃបញ្ជីផាត់ចេញ ដែលហាមឃាត់ពួកគេមិនឲ្យធ្វើសកម្មភាពដែលប៉ះពាល់ដល់ដីធ្លីរបស់ IP។

ក្នុងអំឡុងពេលត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គម IFC បានពិនិត្យតាមដានរបៀបដែលអតិថិជនរបស់ខ្លួនបានអនុវត្តលក្ខខណ្ឌតម្រូវនៃបញ្ជីផាត់ចេញ ប៉ុន្តែបានផ្តល់ការប្រឹក្សា ឬការណែនាំជាឯកសារតិចតួចណាស់ អំពីបទប្បញ្ញត្តិនៃបញ្ជីនោះ ទាក់ទងនឹងជនជាតិដើមភាគតិច ដែលហាមឃាត់សកម្មភាពមីក្រូហិរញ្ញវត្ថុដែលប៉ះពាល់ដល់ដីសហគមន៍ជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីពួកគេនោះទេ។ ទោះបីជាក្នុងករណីដែលអតិថិជនបានរាយការណ៍ថា ចំណុចផាត់ចេញនៃ IP ជាមូលហេតុទូទៅមួយនៃការបដិសេធប្រាក់កម្ចីក៏ដោយ ក៏ IFC មិនបានស្នើសុំធ្វើការផ្ទៀងផ្ទាត់ពីរបៀបអនុវត្តបទប្បញ្ញត្តិទាំងនោះដែរ។ ការត្រួតពិនិត្យរបស់ស៊ីអេអូ លើគោលនយោបាយ និងការអនុវត្តរបស់អតិថិជន និងអតិថិជនបន្ត ក៏បានបង្ហាញពីករណីដែលប្លង់ដីទន់ជាវត្ថុបញ្ចាំពីអ្នកខ្ចីជាជនជាតិដើមភាគតិច ដែលត្រួតលើដីសហគមន៍ IP ត្រូវបានទទួលយកជាវត្ថុបញ្ចាំដោយមិនមានការយល់ព្រមពីសហគមន៍នោះទេ។ ការពឹងផ្អែកលើដីជាវត្ថុបញ្ចាំនេះបានបង្កើតហានិភ័យដែលអ្នកខ្ចីជាជនជាតិដើមភាគតិចនឹងប្រើប្រាស់ចំណែកផ្ទាល់ខ្លួននៃដីសហគមន៍ជាវត្ថុបញ្ចាំ ដើម្បីថែរក្សាលទ្ធភាពទទួលបានឥណទាន ដែលប៉ះពាល់ដល់ការការពារ ដែលបទប្បញ្ញត្តិនៃបញ្ជីផាត់ចេញមានបំណងផ្តល់ជូន។

ស៊ីអេអូយល់ឃើញថា IFC មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច និងធានាថា សកម្មភាពមីក្រូហិរញ្ញវត្ថុដែលខ្លួនផ្តល់ហិរញ្ញប្បទានមិនប៉ះពាល់ដល់ដីរបស់

ពួកគេ ដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីពួកគេ ស្របតាម PS7 (កថាខណ្ឌទី៨ និង ៩)[35] និងបញ្ជីផាត់ចេញរបស់ IFC នោះទេ។ ស៊ីអេអូក៏យល់ឃើញផងដែរថា IFC មិនបានធានាថា អតិថិជន និងអតិថិជនបន្តរបស់ខ្លួន បានអនុវត្តតាមច្បាប់ជាតិដែលពាក់ព័ន្ធស្តីពីការការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច (គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌទី ៣៥ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌទី ៥) នោះទេ។[36]

**គ) លទ្ធភាពទទួលបានឧបាស្រ័យក្នុងការដោះស្រាយបណ្តឹងសារទុក្ខ៖** ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្នុងសំណុំរឿងនេះ ដំណើរការយន្តការបណ្តឹងសារទុក្ខ ដែលមានបំណងផ្តល់លទ្ធភាពទទួលបានសំណងដល់អ្នកខ្ចី និងរាយការណ៍ទៅកាន់ IFC អំពីយន្តការទាំងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកលើកំណត់ត្រាការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកបរិស្ថាន និងសង្គម និងការគ្រប់គ្រងរបស់ IFC ស៊ីអេអូយល់ឃើញថា ជាទូទៅ IFC បានបញ្ជាក់យល់ព្រមលើអត្ថិភាពនៃយន្តការទាំងនេះដោយមិនមានការត្រួតពិនិត្យមុខងារ ឬភាពគ្រប់គ្រាន់របស់យន្តការទាំងនេះទេ។ ជាពិសេស ស៊ីអេអូយល់ថា មិនមានភស្តុតាងដែលថា IFC បានវាយតម្លៃថា តើបណ្តាញពាក្យបណ្តឹងរបស់ BFIs បានបំពេញតាមលក្ខខណ្ឌតម្រូវនៃ PS1 ដែរឬទេ រួមទាំងថាតើវាបានដំណើរការយ៉ាងឆាប់រហ័ស អាចប្រើប្រាស់បាន សមស្របតាមវប្បធម៌ មានតម្លាភាព និងមានសុវត្ថិភាព ក្នុងការទប់ស្កាត់ការសងសឹកដែរឬទេ។[37] ចាប់ពីឆ្នាំ២០២២ មក IFC បានផ្តល់ប្រឹក្សា និងការបណ្តុះបណ្តាលដល់អតិថិជនមួយចំនួនអំពីការទប់ស្កាត់ការគំរាមកំហែង និងការសងសឹកចំពោះអ្នកខ្ចី ដែលបានលើកឡើងនូវកង្វល់នានាតាមរយៈយន្តការទាំងនេះ។ នៅខណៈពេលដែលមានការអភិវឌ្ឍជាវិជ្ជមាននោះ ភាពស៊ីជម្រៅនៃយន្តការទាំងនេះនៅមានកម្រិត និងមិនត្រូវបានតាមដានដោយការគ្រប់គ្រងរបស់ IFC នោះទេ។

ដោយផ្អែកលើចំណុចខាងលើ ស៊ីអេអូយល់ឃើញថា IFC មិនបានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាថា អតិថិជន និងអតិថិជនបន្តបានបង្កើតយន្តការបណ្តឹងសារទុក្ខបានគ្រប់គ្រាន់ ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ (កថាខណ្ឌទី៣៥) និងមិនស្របតាម PS1 (កថាខណ្ឌទី៣៤ និង ៣៥) នោះទេ។[38] IFC ក៏មិនបានព្យាយាមធានាថា អតិថិជនរបស់ខ្លួនបានអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិទាក់ទងនឹងការដោះស្រាយពាក្យបណ្តឹងនៅស្ថាប័នហិរញ្ញវត្ថុ ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ (កថាខណ្ឌទី៣៥) PS (ទិដ្ឋភាពទូទៅ កថាខណ្ឌទី៥) នោះដែរ។[39]

## គ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងបដិលោមភាពរបស់ IFC

ដោយផ្អែកលើភស្តុតាងដែលបានត្រួតពិនិត្យក្នុងអំឡុងពេលស៊ើបអង្កេតរបស់ខ្លួន រួមទាំងសកម្មភាពរបស់ IFC

[35] សម្រាប់ការវិនិយោគរបស់ MEF, PS7 ឆ្នាំ២០០៦ កថាខណ្ឌទី៧ និង ៨។

[36] សម្រាប់ការវិនិយោគរបស់ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី២៨ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌទី៣ និងសម្រាប់ការវិនិយោគរបស់ Advans IFC OP ៤.០១ កថាខណ្ឌទី៩។ ច្បាប់ជាតិដែលពាក់ព័ន្ធ រួមមាន មាត្រា៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា (ឆ្នាំ២០០៦) បទបញ្ជាក្រសួង (ប្រកាស) លេខ ៥៥៦ សជណ. ស្តីពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ (ឆ្នាំ២០១៧) មាត្រា ១៩ នៃច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ (ឆ្នាំ២០១៩)។ ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ (នស/រកម /១១១៩/០១៦) និងអនុក្រឹត្យ (ប្រកាស) លេខ ធ៧-០១៧-២៩៩ ស្តីពីដំណោះស្រាយពាក្យបណ្តឹងរបស់អតិថិជន។

[37] PS1 ឆ្នាំ២០១២ កថាខណ្ឌទី២៥, PS1 ឆ្នាំ២០០៦ កថាខណ្ឌទី២៣។

[38] សម្រាប់ការវិនិយោគរបស់ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី២៨ និង ២៩, PS1 កថាខណ្ឌទី២៣។

[39] សម្រាប់ការវិនិយោគរបស់ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី២៨ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌទី៣ និងសម្រាប់ការវិនិយោគរបស់ Advans IFC OP ៤.០១ កថាខណ្ឌទី៩។

នៅក្រោម *យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់*ផងដែរ ស៊ីអេអូយល់ឃើញថា ដើមបណ្ដឹងទាំង ១៨ នាក់បានទទួលរងការខូចខាត ទាក់ទងនឹងបដិអនុលោមភាពរបស់ IFC ចំពោះកាតព្វកិច្ចនៃគោលនយោបាយនិរន្តរភាព ក្នុងការកំណត់ និងកាត់បន្ថយផលប៉ះពាល់សង្គម ដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា ធនាគារ North Haven Thai, Advans, MEF និង MIFA។[40] ស៊ីអេអូយល់ថា IFC មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៅក្រោមគោលនយោបាយនិរន្តរភាព ក្នុងការធ្វើការដើម្បីធានាថា តាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវ ការពិនិត្យតាមដាន និងការគ្រប់គ្រងរបស់ខ្លួន សកម្មភាពដែលខ្លួនផ្ដល់ហិរញ្ញប្បទានត្រូវបានអនុវត្តស្របតាមស្ដង់ដារសមិទ្ធកម្មនោះទេ។[41]

ស៊ីអេអូបានរកឃើញការខូចខាតដូចខាងក្រោម៖

1. **ការបាត់បង់មុខរបរចិញ្ចឹមជីវិត និងទ្រព្យសកម្មដែលមានផលិតភាព** ដើមបណ្ដឹងចំនួនដប់ប្រាំនាក់ ដែលពួកគេភាគច្រើនមានភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចរួចហើយនោះ បានរាយការណ៍ពីការថយចុះនៃមុខរបរចិញ្ចឹមជីវិត បន្ទាប់ពីលក់ដីកសិកម្ម ឬទ្រព្យសកម្មសម្រាប់បង្កើតប្រាក់ចំណូលដទៃទៀត ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ។ ពួកគេបានរៀបរាប់ថា ពួកគេលក់ទ្រព្យសកម្មទាំងនេះដើម្បីឆ្លើយតបនឹងសម្ពាធនៃការប្រមូលប្រាក់ ឬដោយភ័យខ្លាចថាអ្នកផ្ដល់ប្រាក់កម្ចីនឹងលក់ឡៃឡុងវត្ថុបញ្ចាំដែលជាដីធ្លីរបស់ពួកគេក្រោមតម្លៃទីផ្សារ។ ដើមបណ្ដឹង ១១ នាក់បានទាញអាគតដ្ឋានពីការពឹងផ្អែកលើការធ្វើកសិកម្មជាប្រភពចំណូលចម្បងរបស់ពួកគេ ហើយដើមបណ្ដឹង ៤ នាក់ ក្នុងចំណោម ១១ នាក់នេះ បានលក់ដីកសិកម្មរបស់ពួកគេទាំងអស់ ឬស្ទើរតែទាំងអស់ ដែលបង្ខំឱ្យពួកគេបោះបង់ចោលការធ្វើស្រែចំការជាការងារប្រចាំថ្ងៃ ឬងាកទៅរកយន្តការទប់ទល់ដែលមានគ្រោះថ្នាក់។[42] ដើមបណ្ដឹងបានរាយការណ៍ថា ការបាត់បង់ដីធ្លី ឬទ្រព្យសកម្មដែលមានផលិតភាព បានកាត់បន្ថយសមត្ថភាពរបស់ពួកគេក្នុងការបង្កើតប្រាក់ចំណូលយ៉ាងខ្លាំង ដែលបង្កើនហានិភ័យនៃការធ្លាក់ចូលទៅក្នុង ឬធ្លាក់កាន់តែជ្រៅទៅក្នុងភាពក្រីក្រ។
2. **ការថយចុះនៃសន្តិសុខស្បៀង ផលប៉ះពាល់ដល់សុខភាព និងការរំខានដល់គ្រួសារ** ក្នុងចំណោមដើមបណ្ដឹងទាំង ១៨ នាក់ មានប្រាំមួយនាក់បានរាយការណ៍ពីការកាត់បន្ថយគុណភាព ឬបរិមាណអាហារនៅក្នុងគ្រួសារ ដើម្បីសងបំណុល។ នៅក្នុងសំណុំរឿងចំនួន ១២ ដើមបណ្ដឹងបានរាយការណ៍ពីការពន្យារពេលទទួលការព្យាបាល ឬការទទួលរងផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត រួមទាំងការគេងមិនលក់ ការថប់បារម្ភ ការធ្លាក់ទឹកចិត្ត ការបាត់បង់ចំណង់អាហារ ហើយក្នុងករណីមួយចំនួន ការមានគំនិត ឬការប៉ុនប៉ងធ្វើអត្តឃាត។ ដើមបណ្ដឹងដប់នាក់បានបញ្ឈប់ការសិក្សារបស់កូនពួកគេ ដើម្បីជួយសង

[40] គោលនយោបាយនិរន្តរភាព ធ្វើឲ្យ IFC ព្យាយាម "...ធានាថា តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ ការពិនិត្យតាមដាន និងការគ្រប់គ្រងរបស់ខ្លួន សកម្មភាពអាជីវកម្មដែលខ្លួនផ្ដល់ហិរញ្ញប្បទានជូន អនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃស្ដង់ដារសមិទ្ធកម្ម" (កថាខណ្ឌទី៧)។

[41] គោលនយោបាយនិរន្តរភាព ធ្វើឲ្យ IFC ព្យាយាម "...ធានាថា តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ ការពិនិត្យតាមដាន និងការគ្រប់គ្រងរបស់ខ្លួន សកម្មភាពអាជីវកម្មដែលខ្លួនផ្ដល់ហិរញ្ញប្បទានជូន អនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃស្ដង់ដារសមិទ្ធកម្ម" (កថាខណ្ឌទី៧)។

[42] យន្តការទប់ទល់ត្រូវបានពិពណ៌នានៅខាងក្រោម និងរួមមាន ការកាត់បន្ថយគុណភាព និងបរិមាណអាហារ ការពន្យារពេលទទួលការព្យាបាល ការបញ្ឈប់ការសិក្សារបស់កុមារដើម្បីជួយសងបំណុល ឬសមាជិកគ្រួសារធ្វើចំណាកស្រុក នៅពេលខ្លះ នៅក្នុងបរិបទដែលលក្ខខណ្ឌការងារមិនមានសុវត្ថិភាព ដើម្បីស្វែងរកការងារធ្វើដើម្បីសងបំណុល។

បំណុល ដោយកុមារបានចូលធ្វើការនៅគ្រប់ករណីទាំងអស់។[43] នៅក្នុងសំណុំរឿងចំនួនប្រាំពីរ ដើមបណ្តឹង ឬសមាជិកគ្រួសាររបស់ពួកគេបានធ្វើទេសន្តរប្រវេសន៍ទៅប្រទេសដទៃទៀត ឬតំបន់ដទៃទៀតនៅក្នុងប្រទេសកម្ពុជា ដើម្បីទៅស្វែងរកការងារធ្វើ ដើម្បីសងប្រាក់កម្ចី ដែលដើមបណ្តឹងបាននិយាយថា វានាំឲ្យមានការបែកបាក់គ្រួសារ ការរំខានដល់ការអប់រំកុមារ ការពើបប្រទះនឹងលក្ខខណ្ឌការងារមិនល្អ និងភាពរងគ្រោះតាមយេនឌ័រជាក់លាក់។ ក្នុងករណីមួយចំនួន វាក៏បានបង្កើតភាពតានតឹងផ្នែកហិរញ្ញវត្ថុបន្ថែមទៀតដែរ។

3. **ផលប៉ះពាល់លើជនជាតិដើមភាគតិច** ដើមបណ្តឹងដែលជាជនជាតិដើមភាគតិចបានរាយការណ៍ពីផលប៉ះពាល់អវិជ្ជមានបន្ថែមទៀត។ ដើមបណ្តឹងប្រាំពីរនាក់ មកពីសហគមន៍ជនជាតិដើមភាគតិចដែលទទួលស្គាល់ដោយរដ្ឋាភិបាល បានរាយការណ៍ពីការលក់ចំណែកដីដែលត្រូវតស៊ូគ្នានឹងដីសហគមន៍ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ដែលបានកាត់បន្ថយមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ហើយក្នុងករណីមួយចំនួន បានប៉ះពាល់អត្តសញ្ញាណរបស់ពួកគេក្នុងនាមជាជនជាតិដើមភាគតិច។ ដីពីរចំណែក ក្នុងចំណោមដីដែលបានលក់ទាំងនេះ ត្រូវបានលក់ទៅឲ្យអ្នកដែលមិនមែនជាសមាជិកសហគមន៍ជនជាតិដើមភាគតិច។ ដោយហេតុថា ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច (ICLTs) ត្រូវបានបង្កើតឡើងដើម្បី "ការពារកម្មសិទ្ធិសមូហភាព" និង "ថែរក្សាអត្តសញ្ញាណ វប្បធម៌ [...] ទំនៀមទម្លាប់ និងប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗនោះ" ស៊ីអេអូចាត់ទុកថា ការលក់ដីសហគមន៍ទៅឱ្យអ្នកដែលមិនមែនជាសមាជិកសហគមន៍ប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិចកាន់តែទូលំទូលាយ។[44] ស៊ីអេអូ សន្និដ្ឋានថា ចំណុចខ្វះខាតរបស់ IFC ទាក់ទងនឹងការពឹងផ្អែករបស់អ្នកផ្តល់ខ្ចីប្រាក់លើការប្រើប្រាស់ដីធ្លីជាទ្រព្យបញ្ចាំ និងការទទួលយកទ្រព្យបញ្ចាំដែលត្រូវតស៊ូគ្នានឹងដីរបស់ជនជាតិដើមភាគតិច ដែលស្ថិតក្រោមការការពារ បានធ្វើឱ្យខូចដំណើរការ ICLT ប៉ះពាល់ដល់សុចរិតភាពនៃដីសហគមន៍ជនជាតិដើមភាគតិច បានរួមចំណែកដល់ជម្លោះក្នុងសហគមន៍ និងមានផលប៉ះពាល់អវិជ្ជមានដល់អត្តសញ្ញាណ និងវប្បធម៌របស់ជនជាតិដើមភាគតិច។

[43] កុមារគ្រប់រូបដែលមានអាយុចាប់ពី ១៣ ដល់ ១៧ ឆ្នាំ បានចូលធ្វើការងារអចិន្ត្រៃយ៍ ឬការងារបណ្តោះអាសន្ន ដើម្បីជួយផ្គត់ផ្គង់ហិរញ្ញវត្ថុគ្រួសាររបស់ពួកគេ។ កុមារមួយចំនួនក្នុងចំណោមពួកគេ បានប្រឈមមុខនឹងហានិភ័យនៃលក្ខខណ្ឌការងារដែលមានគ្រោះថ្នាក់ ឬមានការកេងប្រវ័ញ្ច។

[44] អនុក្រឹត្យស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច លេខ ៨៣ អនក្រ.បក. ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ https://bit.ly/3IrHZK9 មាត្រា ២។ នៅឆ្នាំ២០១៨ UN OHCHR បានគូសបញ្ជាក់ថា ការការពារសិទ្ធិទទួលបានដី និងធនធាន គឺជាមូលដ្ឋានគ្រឹះនៃសុខុមាលភាពរយៈពេលវែងរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា និងចាំបាច់ចំពោះការមានវត្តមានរបស់ពួកគេក្នុងនាមជាប្រជាជនដែលមានអត្តសញ្ញាណដោយឡែក។ សូមមើល៖ UN OHCHR, ការវាយតម្លៃលើឱកាសទទួលបានឥណទានសម្រាប់សហគមន៍ជនជាតិដើមនៅកម្ពុជា ដែលកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ, ខែតុលា ឆ្នាំ២០១៨, ទំ. https://bit.ly/4bShl1P។ ស្របជាមួយគោលការណ៍ទាំងនេះ ក្រុមធនាគារពិភពលោកគាំទ្រដល់គម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច (LASED) ដែលមានបំណងពង្រឹងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន តាមរយៈ ICLT សម្រាប់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ជនបទនៅកម្ពុជា។ សូមមើល៖ ក្រុមធនាគារពិភពលោក, គម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច III, គម្រោងលេខ P១៧១៣៣១ https://bit.ly/43CGnoC។

4. **ការគំរាមកំហែង និងការបំភិតបំភ័យ** ដើមបណ្តឹងគ្រប់រូប លើកលែងតែដើមបណ្តឹងម្នាក់ បានរាយការណ៍ថា មន្ត្រីដែលមកពីអតិថិជន និងអតិថិជនបន្តរបស់ IFC បានគំរាមកំហែងពួកគេដោយសកម្មភាពសងសឹកនានា ដូចជា ការនាំទៅជួបអាជ្ញាធរមូលដ្ឋាន នគរបាល ឬតុលាការ ឬមានការរឹបអូសយកដីធ្លី ឬផ្ទះសម្បែងរបស់ពួកគេ ហើយលក់ក្នុងតម្លៃទាបជាងទីផ្សារ។ កលយុទ្ធទាំងនេះត្រូវបានរាយការណ៍ថា បានបង្កឱ្យមានបរិយាកាសនៃភាពភ័យខ្លាច ធ្វើឲ្យអ្នកខ្ចីស្ទាក់ស្ទើរក្នុងការចូលទៅជួបអ្នកផ្តល់ប្រាក់កម្ចីដើម្បីស្វែងរកជម្រើសដំណោះស្រាយ និងនាំឲ្យពួកគេប្រើយន្តការទប់ទល់ដែលមានគ្រោះថ្នាក់។ លើសពីនេះទៀត ដើមបណ្តឹងដែលបានព្យាយាមប្រើយន្តការបណ្តឹងសារទុក្ខ បានរាយការណ៍ថា ដំណើរការនៃយន្តការនេះបានក្លាយជាប្រភពនៃការគំរាមកំហែង និងការបៀតបៀន។ ស៊ីអេអូក៏បានកត់សម្គាល់ផងដែរថា ស្ត្រីជាដើមបណ្តឹងបីនាក់បានរាយការណ៍ពីវត្តមានរបស់បុរសជាមន្ត្រី BFI នៅក្នុងផ្ទះរបស់ពួកគេយ៉ាងយូរ នៅខណៈពេលដែលពួកគេនៅម្នាក់ឯង ដែលពួកគេយល់ឃើញថា វាជាទម្រង់មួយនៃការបំភិតបំភ័យបន្ថែមទៀត។

### *គំហើញទូទៅនៃគ្រោះថ្នាក់*

ប្រភេទគ្រោះថ្នាក់ដែលបានពិពណ៌នាខាងលើ ត្រូវបានរាយការណ៍ទៅស៊ីអេអូដោយដើមបណ្តឹងដោយផ្ទាល់។ ពួកវាស្របនឹងហានិភ័យសង្គម និងផលប៉ះពាល់អវិជ្ជមានដែលបានចងក្រងជាឯកសារយ៉ាងទូលំទូលាយនៅក្នុងការសិក្សាដោយអង្គការជាតិ និងអន្តរជាតិ ដែលរួមមាន ទីភ្នាក់ងារអង្គការសហប្រជាជាតិ ក្រុមសង្គមស៊ីវិល និងអ្នកសិក្សាអំពីបំណុលវ័ណ្ឌក និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។[45] ការតម្រឹមរវាងសក្ខីកម្មរបស់ដើមបណ្តឹង និងភស្តុតាងដែលបានចងក្រងជាឯកសារយ៉ាងទូលំទូលាយនេះ បង្កើនភាពជឿជាក់លើការខូចខាតដែលពួកគេបានពិពណ៌នា និងធ្វើឲ្យពួកគេស្ថិតនៅក្នុងលំនាំនៃផលប៉ះពាល់សង្គមដែលត្រូវបានទទួលស្គាល់យ៉ាងច្បាស់នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។

ស៊ីអេអូយល់ឃើញថា ការខូចខាតទាំងនេះឆ្លុះបញ្ចាំងពីភាពងាយរងគ្រោះយ៉ាងជាក់លាក់របស់ដើមបណ្តឹងទាំង ១៨ នាក់ និងគ្រួសាររបស់ពួកគេ ដែលពឹងផ្អែកលើកសិកម្មខ្នាតតូច មានអក្ខរកម្មផ្នែកច្បាប់ និងហិរញ្ញវត្ថុមានកម្រិត មានឧបសគ្គផ្នែកភាសា ហើយការយល់ដឹងតិចតួចអំពីសិទ្ធិរបស់កូនបំណុលបានបង្កើនការពើបប្រទះរបស់ពួកគេទៅនឹងផលប៉ះពាល់អវិជ្ជមាននៃការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលបំណុលដែលមានគ្រោះថ្នាក់។

[45] សូមមើលឧទាហរណ៍៖ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) (ឆ្នាំ២០១៩) *មីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ ទស្សនៈវិស័យស្តីពីសិទ្ធិមនុស្ស* ភ្នំពេញ; អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ឆ្នាំ២០២៣) *ចុងបញ្ចប់នៃសេចក្តីថ្លែងការណ៍អំពីបេសកកម្ម* ភ្នំពេញ ប្រទេសកម្ពុជា; អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និង អង្គការសមធម៌កម្ពុជា (ឆ្នាំ២០១៩), ការខូចខាតទ្រព្យបញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា; ធនាគារពិភពលោក (ឆ្នាំ២០១៩) *បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា៖ ការថែរក្សាកំណើនប្រកបដោយចីរភាព* វ៉ាស៊ីងតោន ឌីស៊ី; ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) (ឆ្នាំ២០២២), *ការសិក្សាពីការជំពាក់បំណុលវ័ណ្ឌកនៅកម្ពុជា*; ៦០ ដេស៊ីបែល (ឆ្នាំ២០២៤) *របាយការណ៍សមិទ្ធកម្មផ្នែកសង្គមនៃមីក្រូហិរញ្ញវត្ថុកម្ពុជា*; និង Green, W., និង Bylander, M. (ឆ្នាំ២០២៣) "អំណាចនៃការបង្ខិតបង្ខំដោយបំណុល៖ មីក្រូហិរញ្ញវត្ថុ និងការបាត់បង់កម្មសិទ្ធិដីធ្លីនៅកម្ពុជា" *ការអភិវឌ្ឍពិភពលោក* ច្បាប់ទី១៦១។

ដោយផ្អែកលើភស្តុតាង ស៊ីអេអូសន្និដ្ឋានថា ការខូចខាតទាំងនេះទាក់ទងនឹងបដិលោមភាពរបស់ IFC តាមគោលនយោបាយនិរន្តរភាពរបស់ខ្លួន ជាពិសេសកាតព្វកិច្ចរបស់ខ្លួននៅក្រោមក្របខណ្ឌនិរន្តរភាព ក្នុងការធានាថាអតិថិជនកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យ E&S ស្របតាមការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) ផ្តល់ការពិចារណាជាពិសេសចំពោះកាលៈទេសៈ និងតម្រូវការរបស់ជនងាយរងគ្រោះ ធានាថាក្រុមទាំងនោះមិនរងផលប៉ះពាល់ដោយសារគម្រោងដោយមិនសមាមាត្រឡើយ និងបន្តអនុវត្តយន្តការបណ្តឹងសារទុក្ខប្រកបដោយប្រសិទ្ធភាព ភាពអាចចូលប្រើប្រាស់បាន និងទំនុកចិត្ត ដោយគ្មានហានិភ័យនៃការសងសឹកនោះទេ។ ផលវិបាកនៃការខូចខាតដែលដើមបណ្តឹងទាំងនេះបានជួបប្រទះ លាតសន្ធឹងហួសពីអ្នកខ្ចីម្នាក់ៗ ទៅដល់គ្រួសារ និងសហគមន៍របស់ពួកគេ ហើយក្នុងករណីជនជាតិដើមភាគតិច ដល់បេតិកភណ្ឌវប្បធម៌ និងអត្តសញ្ញាណរបស់ពួកគេផងដែរ។

## មូលហេតុឫសគល់នៃបដិលោមភាព

ស៊ីអេអូកំណត់មូលហេតុឫសគល់នៃបដិលោមភាពរបស់ IFC នៅក្នុងសំណុំរឿងនេះ ដូចខាងក្រោម៖

1. ***ការប្រើអភិក្រមដែលមិនបានពិចារណាពីហានិភ័យសង្គម និងផលប៉ះពាល់លើអ្នកទទួលផលគម្រោង៖*** គោលនយោបាយនិរន្តរភាពរបស់ IFC ធ្វើឲ្យស្ថាប័ននេះប្តេជ្ញាចិត្តសម្រេចឲ្យបាននូវផលសម្រេចនៃការអភិវឌ្ឍជាវិជ្ជមាន ដោយតាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវ ការពិនិត្យតាមដាន និងការគ្រប់គ្រង ធានាថា សកម្មភាពដែលខ្លួនគាំទ្រមាននិរន្តរភាពបរិស្ថាន និងសង្គម និងអនុលោមតាម PS។ គោលនយោបាយនេះក៏តម្រូវផងដែរថា សោហ៊ុយលើការអភិវឌ្ឍសេដ្ឋកិច្ចមិនធ្លាក់លើជនក្រីក្រ ឬជនងាយរងគ្រោះដោយមិនសមាមាត្រគ្នានោះទេ និងអនុវត្តស្តង់ដារសមិទ្ធកម្ម ដើម្បីធានាថាអតិថិជនអនុវត្តតាមការប្តេជ្ញាចិត្តនេះ។[46] នៅក្នុងសំណុំរឿងនេះ បដិលោមភាពរបស់ IFC កើតចេញពីការមិនទទួលស្គាល់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ គ្រួសារ និងសហគមន៍របស់ពួកគេ — ដែលរួមមាន កសិករ ជនជាតិដើមភាគតិច និងអ្នកដទៃទៀត ដែលភាពងាយរងគ្រោះរបស់ពួកគេត្រូវបានផ្សារភ្ជាប់ទៅនឹងអក្ខរកម្មកម្រិតទាប (រួមទាំង អក្ខរកម្មហិរញ្ញវត្ថុ ផងដែរ) ប្រាក់ចំណូលទាប និងការពឹងផ្អែកលើមុខរបរចិញ្ចឹមជីវិតនៅលើដីធ្លី — ជាជនងាយរងគ្រោះ។

2. **ការដាច់ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំនៅកម្រិតវិស័យ និងការអនុវត្តនៅកម្រិតគម្រោង៖** សំណុំរឿងនេះបានគូសបញ្ជាក់ពីចន្លោះប្រហោងនៃអភិក្រម រវាងការចូលរួមយ៉ាងទូលំទូលាយរបស់ IFC នៅកម្រិតវិស័យ ដើម្បីលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅកម្ពុជា និងការប្រើចំណេះដឹង ស្តង់ដារ និងការអនុវត្តដូចគ្នា ចំពោះការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ខ្លួនផ្ទាល់។ IFC បានដើរតួនាទីយ៉ាងសកម្មនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា អស់រយៈពេលជាងពីរទសវត្សរ៍មកហើយ ដោយគាំទ្រគំនិតផ្តួចផ្តើមដោះស្រាយហានិភ័យនៃបំណុលវ័ណ្ឌក និងពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ។ ឧទាហរណ៍ រួមមាន កិច្ចសហការ

---

[46] ស្តង់ដារសមិទ្ធកម្មទី១ រួមជាមួយស្តង់ដារដែលពាក់ព័ន្ធ (PS5 PS7 PS2) តម្រូវឲ្យអតិថិជនកំណត់អត្តសញ្ញាណក្រុមងាយរងគ្រោះ ឬមានការលំបាក វាយតម្លៃហានិភ័យដែលមិនសមាមាត្រ និងអនុវត្តការវាស់ស្ទង់ ដើម្បីបញ្ចៀសការខូចខាត និងធានាថា ពួកគេទាំងអស់គ្នាទទួលបានអត្ថប្រយោជន៍នៃគម្រោង។

ជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើតក្រុមហ៊ុនក្រេឌីតប៊្យូរូកម្ពុជា (CBC) និងជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និង CBC ដើម្បីបង្កើតគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី ព្រមទាំងសេវាទីប្រឹក្សា ដើម្បីពង្រឹងក្របខណ្ឌការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុផងដែរ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះឆ្លុះបញ្ចាំងពីការទទួលស្គាល់យ៉ាងច្បាស់អំពីផលប៉ះពាល់អវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុដែលអាចកើតឡើង និងការប្តេជ្ញាចិត្តលើកកម្ពស់ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) នៅកម្រិតវិស័យ។ ប៉ុន្តែ IFC មិនបានអនុវត្តការយល់ដឹង និងស្តង់ដារ GIIP ដូចគ្នាជាប្រព័ន្ធ ទៅលើការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ខ្លួនផ្ទាល់នោះទេ។ ជាលទ្ធផល ហានិភ័យដែល IFC កំពុងខិតខំកាត់បន្ថយនៅក្នុងវិស័យនេះ ដូចជាបំណុលវ័ណ្ឌក ការបាត់បង់ទ្រព្យសកម្មដែលមានផលិតភាព និងការអនុវត្តការប្រមូលបំណុលដែលមានគ្រោះថ្នាក់ មិនត្រូវបានកំណត់ វាយតម្លៃ ឬដោះស្រាយយ៉ាងជាប់លាប់ នៅក្នុងគម្រោងដែលខ្លួនបានផ្តល់ហិរញ្ញប្បទាននោះទេ។ ចន្លោះប្រហោងរវាងភាពជាអ្នកដឹកនាំនៅកម្រិតវិស័យរបស់ IFC និងការអនុវត្តនៅកម្រិតគម្រោងរបស់ខ្លួន បានរួមចំណែកដល់ការកើតឡើងជាបន្តបន្ទាប់នៃការខូចខាតផ្នែកសង្គមក្នុងចំណោមអ្នកខ្ចីប្រាក់នៅក្នុងការវិនិយោគដែលគ្របដណ្តប់ដោយសំណុំរឿងនេះ។

### អនុសាសន៍របស់ស៊ីអេអូ ទៅកាន់ IFC

ដោយគិតគូរពីគំហើញខាងលើ ស៊ីអេអូផ្តល់អនុសាសន៍ថា IFC គួរតែចាត់វិធានការដូចខាងក្រោម។

*អនុសាសន៍កម្រិតគម្រោង*

1. **IFC គួរតែធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីរៀបចំ និងអនុវត្តកម្មវិធីដែលមានប្រសិទ្ធភាពមួយ ដើម្បីវាយតម្លៃ ពង្រឹង និងដោះស្រាយអសាធនភាព និងការជំពាក់បំណុលរបស់ដើមបណ្តឹងម្នាក់ៗ រួមទាំងដើមបណ្តឹងទាំង ១៨ នាក់ ដែលដាក់ពាក្យបណ្តឹងនេះផងដែរ។** ជម្រើសក្នុងការដោះស្រាយគួរតែរួមមាន ការផ្អាកសងប្រាក់ ការលើកលែងការប្រាក់ ឬបំណុលដែលជំពាក់ ការរៀបចំឥណទានឡើងវិញ បុនហិរញ្ញប្បទានដោយមិនបង្កើនបំណុល ការគាំទ្រចំពោះមុខរបរចិញ្ចឹមជីវិត ឬការងារ ឬវិធានការសមស្របដទៃទៀត អាស្រ័យលើស្ថានភាពរបស់អ្នកខ្ចីម្នាក់ៗ។ កម្មវិធីទាំងនេះក៏គួរតែពិចារណាលើ៖
    a. **ការប្រមូលទិន្នន័យមូលដ្ឋាន និងបណ្តុំព័ត៌មានសេដ្ឋកិច្ចសង្គមរបស់អ្នកខ្ចីបន្ត** រួមទាំងការប្រឈមនឹងប្រាក់កម្ចី អត្រាការប្រាក់ សមត្ថភាពសងប្រាក់ និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គម តាមរយៈទីភ្នាក់ងារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីធានាបាននូវទំនុកចិត្ត និងការចូលរួមរបស់សហគមន៍។
    b. ការស្វែងយល់ពីរាល់**ជម្រើសក្នុងការរៀបចំឥណទានឡើងវិញ បុនហិរញ្ញប្បទាន ឬការលើកលែង** សម្រាប់អ្នកខ្ចីដែលរងផលប៉ះពាល់ ដែលមានការលំបាកផ្នែកហិរញ្ញវត្ថុដែលអាចផ្ទៀងផ្ទាត់បាន និងការ**ពិចារណាលើផ្លូវចេញសម្រាប់អ្នកជំពាក់បំណុល**។ ផ្លូវចេញសម្រាប់អ្នកជំពាក់បំណុលអាចរួមមាន ការធ្វើផែនការគ្រប់គ្រងបំណុលបុគ្គល ការសំដៅលើគំនិតផ្តួចផ្តើមបង្កើតប្រាក់ចំណូល ការប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុ និងការជួយអ្នកខ្ចីដោយយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីកាត់បន្ថយការពឹងផ្អែកលើឥណទាន។

c. **ចាប់ដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលនៅតាមសហគមន៍**ដើម្បីបង្កើតបណ្តាញទំនាក់ទំនងជាមួយអ្នកខ្ចី ពិនិត្យតាមដានការអនុវត្តការផ្តល់ប្រាក់កម្ចី និងលើកកម្ពស់ការចូលរួមដ៏មានអត្ថន័យរបស់ភាគីពាក់ព័ន្ធនៅគ្រប់ពេលនៃការវិនិយោគរបស់ IFC។ ភាពជាដៃគូក៏អាចផ្តល់នូវ**ការគាំទ្រដល់មុខរបរចិញ្ចឹមជីវិត និងការងារ** និងភ្ជាប់ទំនាក់ទំនងរវាងអ្នកខ្ចី និងទីផ្សារការងារដែលពាក់ព័ន្ធបានដែរ (ឧទាហរណ៍ តាមរយៈការរៀបចំពិព័រណ៍ការងារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសកម្មភាពចូលរួមរបស់និយោជក ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន)។

IFC អាចទាញយកអត្ថប្រយោជន៍ពីការព្រមព្រៀងនៃកិច្ចសន្យា និងឥទ្ធិពលនៃកេរ្តិ៍ឈ្មោះរបស់ខ្លួន ដើម្បីធានាថាមានការចូលរួមពីអតិថិជន និងការសហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលគួរឱ្យទុកចិត្ត ដើម្បីធ្វើការវាយតម្លៃអ្នកខ្ចី និងផ្តល់ការគាំទ្រដល់មុខរបរចិញ្ចឹមជីវិត។ IFC ក៏អាចប្រមូលផ្តុំបរធនរបស់ម្ចាស់ជំនួយ ឬធនធាននៃសេវាទីប្រឹក្សារបស់ខ្លួន ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការប្រឹក្សាអំពីបំណុល ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការពិនិត្យតាមដាន។

2. IFC **គួរតែបន្តកិច្ចខិតខំប្រឹងប្រែងផ្តល់ការគាំទ្រដល់ការបង្កើតយន្តការពាក្យបណ្តឹងឯករាជ្យ**[47]**សម្រាប់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជា** ដែលអនុវត្តតាមការអនុវត្តឧស្សាហកម្មអន្តរជាតិល្អស្របតាមលក្ខខណ្ឌតម្រូវនៃ PS1។ យន្តការគួរតែឯករាជ្យពីគ្រឹះស្ថានហិរញ្ញវត្ថុ និងបុគ្គលសម្ព័ន្ធរបស់ពួកគេ ក្នុងការធ្វើអភិបាលកិច្ច និងការធ្វើប្រតិបត្តិការ ហើយ FIs គួរតែប្តេជ្ញាចិត្តអនុលោមតាម និងអនុវត្តដំណោះស្រាយរបស់ខ្លួន។ IFC បានចាប់ផ្តើមធ្វើការជាមួយសមាគមធនាគារកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងដៃគូអភិវឌ្ឍន៍ដទៃទៀតនៅឆ្នាំ២០២៤ ដើម្បីបង្កើតយន្តការសម្រាប់វិស័យនេះ។ IFC អាចកោះប្រជុំដៃគូទាំងនេះរួមជាមួយធនាគារជាតិនៃកម្ពុជា (NBC) DFIs ដទៃទៀត និងសង្គមស៊ីវិល ដើម្បីរួមគ្នារចនាគំរូដែលមានប្រសិទ្ធភាព។[48]

3. IFC **គួរតែធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយលើគោលនយោបាយ និងការអនុវត្តរបស់គ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ** ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ ដើម្បី៖
   a. កំណត់ និងដោះស្រាយចន្លោះប្រហោងនៃ PS1 និង PS7 រួមទាំង GIIP ដែលពាក់ព័ន្ធ និងពង្រឹងសមត្ថភាពរបស់អតិថិជន និងអតិថិជនបន្តផងដែរ
   b. តម្រូវឱ្យអតិថិជនរួមបញ្ចូលលក្ខណៈវិនិច្ឆ័យនៃសមិទ្ធកម្មសង្គម លើសពីប្រាក់កម្ចីដែលបានអនុម័ត ឬបំណុលដែលបានប្រមូល នៅក្នុងគម្រោងលើកទឹកចិត្តសម្រាប់មន្ត្រីឥណទាន/មន្ត្រីប្រមូលប្រាក់ និងអ្នកគ្រប់គ្រង។

4. IFC **គួរតែបង្កើតកម្មវិធីបណ្តុះបណ្តាលអតិថិជន** ដើម្បីពង្រឹងយន្តការបណ្តឹងសារទុក្ខជាប្រព័ន្ធ នៅកម្រិតអតិថិជន និងអតិថិជនបន្ត ដោយផ្តោតលើការបង្កើតឧបករណ៍ និងអភិវឌ្ឍសមត្ថភាពក្នុងការ

[47] យន្តការបណ្តឹងដែលដំណើរការដោយឯករាជ្យ គួរតែដំណើរការដោយគ្មានការជះឥទ្ធិពល ឬការគ្រប់គ្រងពីភាគីដែលមានសក្តានុពលចំពោះពាក្យបណ្តឹងដែលវាអាចទទួលបាន។

[48] ជម្រើសនៃការផ្តល់មូលនិធិអាចរួមមាន គំរូចម្រុះនៃការរួមចំណែករបស់ម្ចាស់ជំនួយ ពន្ធ MFI និងការគាំទ្រពីដៃគូអភិវឌ្ឍន៍។

ដោះស្រាយវិវាទ ដោយទប់ស្កាត់ការគំរាមកំហែង ការបៀតបៀន ឬការសងសឹកចំពោះអ្នកខ្ចី។ ស្របពេលជាមួយគ្នានេះ ផ្តល់ការបណ្តុះបណ្តាលឯកទេស ស្របតាម GIIP ដល់មន្ត្រីឥណទាន និងមន្ត្រីប្រមូលប្រាក់ ដោយគ្របដណ្តប់ការវាយតម្លៃយ៉ាងត្រឹមត្រូវលើសមត្ថភាពសងប្រាក់ និងការយល់ដឹងអំពីលក្ខខណ្ឌតម្រូវរបស់ IFC ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច និងរបៀបបញ្ចៀសការខូចខាត ក្នុងការអនុវត្តការផ្តល់កម្ចី និងការប្រមូលប្រាក់របស់ពួកគេ។ IFC គួរតែតម្រូវឲ្យរបាយការណ៍តាមដានការអនុវត្ត។

5. **IFC គួរតែធ្វើការជាមួយអតិថិជនដើម្បីបង្កើត និងអនុវត្តកម្មវិធីផ្តល់ភាពអង់អាចផ្នែកហិរញ្ញវត្ថុ** សំដៅលើ (i) កសាងការយល់ដឹង និងសមត្ថភាពរបស់អ្នកខ្ចីដែលងាយរងគ្រោះ ក្នុងការចូលរួមជាមួយ BFIs និង (ii) អភិវឌ្ឍការប្រាស្រ័យទាក់ទង និងឯកសារព័ត៌មានអំពីប្រាក់កម្ចីដែលអាចប្រើប្រាស់បាន សម្រាប់អ្នកខ្ចី។ ការបណ្តុះបណ្តាលគួរតែត្រូវបានកែសម្រួលតាមកម្រិតភាសា និងអក្ខរកម្មនៅក្នុងមូលដ្ឋាន និងផ្តល់ជូនដោយទីភ្នាក់ងារ ឬអង្គការមិនមែនរដ្ឋាភិបាល ដោយមានវត្តមានសហគមន៍ ដែលត្រូវបានបង្កើតឡើង។ ខ្លឹមសារគួរតែរួមបញ្ចូលការខ្ចីប្រាក់ដោយមានព័ត៌មានគ្រប់គ្រាន់ ហានិភ័យនៃបំណុលវ័ណ្ឌក លក្ខខណ្ឌនៃប្រាក់កម្ចី យន្តការបណ្តឹងសារទុក្ខ និងសិទ្ធិរបស់អ្នកខ្ចី ក្នុងគោលបំណងធ្វើឲ្យអ្នកខ្ចីអាចធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ និងចូលរួមប្រកបដោយការស្ថាបនា ជាមួយ BFIs។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ IFC គួរតែគាំទ្រឲ្យអតិថិជន និងអតិថិជនបន្តបង្កើតសំណុំឯកសារប្រាក់កម្ចី និងការប្រាស្រ័យទាក់ទងរបស់អ្នកខ្ចី ដែលអាចប្រើប្រាស់បាន មានភាពសមស្របផ្នែកវប្បធម៌ និងត្រូវបានបង្ហាញជាភាសាក្នុងស្រុក ដើម្បីធានាបាននូវការយល់ព្រមដោយមានព័ត៌មានគ្រប់គ្រាន់ និងការយល់ដឹងរបស់អ្នកខ្ចីអំពីសិទ្ធិ និងកាតព្វកិច្ច។

### *អនុសាសន៍កម្រិតស្ថាប័ន*

ដើម្បីដោះស្រាយមូលហេតុឫសគល់នៃគំហើញអំពីបដិលោមភាព នៅក្នុងសំណុំរឿងនេះ ស៊ីអេអូផ្តល់អនុសាសន៍ថា IFC គួរតែពង្រឹងការធ្វើសមាហរណកម្មកាតព្វកិច្ចនៃគោលនយោបាយនិរន្តរភាពរបស់ខ្លួន រួមមាន កាតព្វកិច្ចដែលទាក់ទងនឹងការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការការពារក្រុមងាយរងគ្រោះ និងជនជាតិដើមភាគតិច ទៅក្នុងការរៀបចំរចនាសម្ព័ន្ធ ការត្រួតពិនិត្យភាពត្រឹមត្រូវ និងការគ្រប់គ្រងសកម្មភាពមីក្រូហិរញ្ញវត្ថុរបស់ខ្លួន។

IFC គួរតែអភិវឌ្ឍការងាររបស់ខ្លួនដែលមានស្រាប់នៅក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងកំណែទម្រង់វិស័យនេះ នៅក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុពិភពលោក និងកម្ពុជា ដើម្បី៖

1. **អភិវឌ្ឍសមត្ថភាព និងឧបករណ៍ ព្រមទាំងបង្កើនជំនាញផ្ទៃក្នុង ដើម្បីរៀបចំ និងអនុវត្តដំណើរការសម្រាប់ប្រើប្រាស់ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងគ្រប់គ្រងគម្រោង ដើម្បីកំណត់ក្រុមងាយរងគ្រោះ និងវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនៃការវិនិយោគពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុ។** ដំណើរការនេះគួរតែវាយតម្លៃសមត្ថភាព និងបទពិសោធន៍របស់អតិថិជនក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនៃ GIIP ទាក់ទងនឹងអ្នកខ្ចីដែលងាយរងគ្រោះ និងជនជាតិដើមភាគតិចផងដែរ។ ក្នុងអំឡុងពេលគ្រប់គ្រង IFC គួរតែតម្រូវឲ្យ FIs រួមបញ្ចូលបណ្តុំព័ត៌មានអំពីសំណាកតំណាងឲ្យអ្នកខ្ចីឥណទានខ្នាត

តូច (ឧ. រួមជាមួយចំនួនប្រាក់កម្ចី និងរយៈពេល អត្រាការប្រាក់ ការទូទាត់សង ភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុ និងកម្រិតទុក្ខព្រួយ និងរបៀបដែលបុគ្គលិក FI ធ្វើអន្តរកម្មជាមួយសហគមន៍) នៅក្នុងរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំរបស់ពួកគេ។ ការរួមបញ្ចូលបែបនេះនឹងជួយ IFC តាមដានលទ្ធផលរបស់អ្នកខ្ចី និងធានាថាអតិថិជនអនុវត្តស្របតាមស្តង់ដារសមិទ្ធកម្ម GIIP និងច្បាប់ជាតិដែលពាក់ព័ន្ធ។

2. **រួមបញ្ចូលកិច្ចព្រមព្រៀងស្តង់ដារ រួមជាមួយលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ លើការបំពេញតាម GIIP ទាក់ទងនឹងអ្នកខ្ចីដែលងាយរងគ្រោះ នៅក្នុងកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ សម្រាប់ការវិនិយោគលើបរិយាប័ន្នហិរញ្ញវត្ថុ។** ស្តង់ដារ GIIP ទាំងនេះគួរតែចងកាតព្វកិច្ចលើលក្ខខណ្ឌតម្រូវ ដែលអតិថិជនត្រូវបំពេញ និងរាយការណ៍នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ពួកគេ ហើយ IFC នឹងពិនិត្យតាមដានដើម្បីផ្ទៀងផ្ទាត់ការអនុវត្តរបស់ពួកគេ។

## ជំហានបន្ទាប់

របាយការណ៍នេះ តាមកាលបរិច្ឆេទ ត្រូវបានបញ្ចប់ដោយស៊ីអេអូ និងផ្ញើទៅកាន់គណៈគ្រប់គ្រងរបស់ IFC និងក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ IFC។ ស្របតាមគោលនយោបាយរបស់ស៊ីអេអូ IFC នឹងត្រូវដាក់ជូននូវរបាយការណ៍របស់គណៈគ្រប់គ្រងទៅកាន់ក្រុមប្រឹក្សាភិបាលសម្រាប់ពិចារណា ដែលនឹងរួមបញ្ចូលផែនការសកម្មភាពគ្រប់គ្រង (MAP) ក្នុងគោលបំណងដោះស្រាយគំហើញរបស់ស៊ីអេអូ អំពីបដិលោមភាព និងការខូចខាតដែលពាក់ព័ន្ធ។ MAP រួមមាន សកម្មភាពដោះស្រាយដែលមានពេលវេលាកំណត់ ដែលបានស្នើដោយគណៈគ្រប់គ្រង។ របាយការណ៍របស់គណៈគ្រប់គ្រងគួរតែរួមបញ្ចូលការឆ្លើយតបយ៉ាងសមហេតុផលទៅនឹងគំហើញ ឬអនុសាសន៍របស់ស៊ីអេអូ ដែល IFC/MIGA មិនអាចដោះស្រាយបាន នៅក្នុង MAP។ បន្ទាប់ពីក្រុមប្រឹក្សាភិបាលរបស់ IFC អនុម័តលើ MAP នោះហើយ ស៊ីអេអូនឹងបោះពុម្ពផ្សាយរបាយការណ៍ស៊ើបអង្កេតនេះ និងរបាយការណ៍របស់គណៈគ្រប់គ្រង IFC។ បន្ទាប់មក ស៊ីអេអូមានតួនាទីផ្ទៀងផ្ទាត់ការអនុវត្តសកម្មភាព MAP ប្រកបដោយប្រសិទ្ធភាព តាមរយៈការត្រួតពិនិត្យភាពអនុលោម។

# ១. សាវតា

ក្នុងរយៈពេល ៤៥ ឆ្នាំមកនេះ មីក្រូហិរញ្ញវត្ថុ[49] ត្រូវបានចាត់ទុកថាជាឧបករណ៍ដ៏ជោគជ័យមួយក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនដែលមានការលំបាកខ្លាំងបំផុត តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុដល់ជន ឬក្រុមជនក្រីក្រ និងមានប្រាក់ចំណូលទាប ដែលជាធម្មតា ត្រូវបានផាត់ចេញពីប្រព័ន្ធធនាគារតាមបែបប្រពៃណី។ IFC គឺជាវិនិយោគិនដ៏ចម្បងរបស់ក្រុមធនាគារពិភពលោក លើវិស័យមីក្រូហិរញ្ញវត្ថុ និងជាវិនិយោគិនឈានមុខគេនៅលើពិភពលោក ដែលធ្វើការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) និងគ្រឹះស្ថានហិរញ្ញវត្ថុផ្តោតលើសហគ្រាសធុនតូច និងមធ្យម (SME) ប្រហែល ៣៣០ កន្លែង ដែលផ្តល់សេវាកម្មហិរញ្ញវត្ថុនៅ ៩៥ ប្រទេស។[50] មីក្រូហិរញ្ញវត្ថុបានដើរតួជាខ្សែបន្ទាត់ជីវិតសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាបជាច្រើនគ្រួសារ ដោយមានផលជះផ្នែកហិរញ្ញវត្ថុ និងសុខុមាលភាពជាវិជ្ជមាន តាមរយៈការពង្រីកលទ្ធភាពទទួលបានហិរញ្ញវត្ថុ កាត់បន្ថយការពឹងផ្អែកលើអ្នកផ្តល់ប្រាក់កម្ចីដោយគ្មាននិយ័តកម្ម និងផ្តល់រយៈពេលកម្ចីវែងជាង រួមជាមួយអត្រាការប្រាក់ទាបជាង។[51]

## ១.១ ការវិវត្តនៃវិស័យបរិយាប័ន្នហិរញ្ញវត្ថុនៅលើពិភពលោក

គម្រោងមីក្រូហិរញ្ញវត្ថុបានលេចឡើងនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ នៅពេលដែលគ្រួសារជនបទ និងមានប្រាក់ចំណូលទាបភាគច្រើន នៅលោកខាងត្បូង ខ្វះខាតលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការប្រកបដោយអត្ថន័យ សំដៅផ្តល់ឥណទានដល់គ្រួសារក្រីក្រដែលមិនមានវត្ថុបញ្ចាំ និងមិនអាចទទួលបានឥណទានធនាគារ។[52] នៅទសវត្សរ៍ឆ្នាំ១៩៩០ អង្គការមិនមែនរដ្ឋាភិបាល (NGOs) មួយចំនួន បានរំលេចនូវគោលដៅជាក់លាក់ក្នុងការ

---

[49] មីក្រូហិរញ្ញវត្ថុ សំដៅយ៉ាងទូលំទូលាយលើ សេវាធនាគារសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប ជាពិសេសជនក្រីក្រ និងក្រីក្រខ្លាំង។ និយមន័យនៃសេវាទាំងនេះមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ និយមន័យកាន់តែចង្អៀតគឺ ជាញឹកញាប់ វាសំដៅលើមីក្រូឥណទានសម្រាប់សហគ្រិនធុនមីក្រូ។ ចំនួនទឹកប្រាក់ដែលចាត់ទុកថាជាមីក្រូ ក៏មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតដែរ។ CGAP គោលការណ៍ណែនាំស្តីពីការយល់ព្រមជាឯកច្ឆន្ទលើមីក្រូហិរញ្ញវត្ថុ៖ គោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិ និងការត្រួតពិនិត្យមីក្រូហិរញ្ញវត្ថុ https://bit.ly/3DrIzFy។ បច្ចុប្បន្ន គេយល់ថា មីក្រូហិរញ្ញវត្ថុគឺលើសពីឥណទានសម្រាប់ការវិនិយោគនៅក្នុងសហគ្រាសធុនមីក្រូ ប៉ុន្តែវាគ្របដណ្តប់លើតម្រូវការសេវាហិរញ្ញវត្ថុជាច្រើន និងចម្រុះរបស់ជនក្រីក្រ។ សៀវភៅណែនាំអំពីមីក្រូហិរញ្ញវត្ថុថ្មី (ឆ្នាំ២០១៣)

[50] វេបសាយត៍វិស័យមីក្រូហិរញ្ញវត្ថុរបស់ IFC៖ https://bit.ly/4iQqJeQ

[51] ក្រុមធនាគារពិភពលោក កំណត់សម្គាល់គោលនយោបាយនៃប្រទេសកម្ពុជាស្តីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ ឆ្នាំ២០១៩ ទំ.៦ មាននៅ https://bit.ly/3NITywL។

[52] អវត្តមាននៃសេវាហិរញ្ញវត្ថុ*ផ្លូវការ* អមមកជាមួយនឹងការរីកដុះដាលនៃសេវា*ក្រៅផ្លូវការ* ភាគច្រើននៅក្នុងទម្រង់សមាគមសន្សំប្រាក់ និងឥណទានបង្វិល (ROSCAs) ដែលមានឈ្មោះដូចជា *tanda* នៅអាមេរិកឡាទីន *susu* នៅអាហ្វ្រិកខាងជើង និងការីបៀន *មូលនិធិ chit* នៅឥណ្ឌា *តុងទីន*នៅកម្ពុជា *arisan* នៅឥណ្ឌូណេស៊ី និងឧទាហរណ៍ដទៃទៀតរាប់មិនអស់ នៅស្ទើរតែគ្រប់ប្រទេសដែលមានប្រាក់ចំណូលកម្រិតទាប និងមធ្យម នៅក្នុងពិភពលោក និងនៅក្នុងសហគមន៍ជនអន្តោប្រវេសន៍ នៅគ្រប់ទីកន្លែងដទៃទៀត។ David Roodman *ការត្រួតពិនិត្យភាពត្រឹមត្រូវ៖ ការសួរសំណួរដែលមិនពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ* សារព័ត៌មាននៃស្ថាប័ន Brookings ឆ្នាំ២០១២ ទំព័រទី៣៩-៤០។

បង្កើតប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនៅជុំវិញពិភពលោក។[53] នៅឆ្នាំ១៩៩៩ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) ចំនួន ១៥៦ នៅ ៥៨ ប្រទេស ដែលបានរាយការណ៍ទៅកាន់មូលដ្ឋានទិន្នន័យជាសកលសម្រាប់មីក្រូហិរញ្ញវត្ថុទីផ្សារ MIX[54] និងមានគ្រឹះស្ថានចំនួន ២.៥១៥ កន្លែង បានរាយការណ៍យ៉ាងតិចម្តង ទៅកាន់ទីផ្សារ MIX នៅឆ្នាំ២០១១។[55]

ចំនួនអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ និងផលបត្រប្រាក់កម្ចីបានកើនឡើងយ៉ាងឆាប់រហ័ស។ នៅចន្លោះឆ្នាំ១៩៩៩ និង ឆ្នាំ ២០១០ ទិន្នន័យ MIX បានរាយការណ៍ពីការកើនឡើងនៃអ្នកខ្ចីមីក្រូហិរញ្ញវត្ថុពីជាង ៩ លាននាក់ ទៅ ជាង ១០០ លាននាក់ នៅទូទាំងពិភពលោក។ ទន្ទឹមនឹងនេះ ផលបត្រប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុបានកើនឡើងពី ១,៨ ពាន់លានដុល្លារ នៅឆ្នាំ១៩៩៩ ទៅ ៩០ ពាន់លានដុល្លារនៅឆ្នាំ ២០១០។

ដោយសារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការកើនឡើង អង្គការមិនមែនរដ្ឋាភិបាលដែលកំពុងដំណើរការគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានជួបប្រទះបញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធ និងនិយ័តកម្មក្នុងការកៀរគរមូលនិធិ។ ជាលទ្ធផលក្នុងអំឡុងទសវត្សរ៍ឆ្នាំ២០០០ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលផ្តល់មីក្រូហិរញ្ញវត្ថុ បានផ្លាស់ប្តូរទៅជាស្ថាប័នពាណិជ្ជកម្មស្វែងរកប្រាក់ចំណេញ។[56]

---

[53] អ្នកចាប់ផ្តើមដំបូងៗ Accion (ដែលមានពិសោធន៍ជាមួយមីក្រូឥណទាននៅទសវត្សរ៍ ឆ្នាំ១៩៧០) និង FINCA (បង្កើតឡើងក្នុងឆ្នាំ ១៩៨៤) បានដំណើរការនៅជាច្រើនប្រទេសរួចហើយ។ អង្គការមិនមែនរដ្ឋាភិបាលសប្បុរសធម៌ ដូចជា Opportunity International, អង្គការទស្សនៈពិភពលោក, Freedom from Hunger និងអង្គការដទៃទៀតកំពុងបង្កើត NGOs មីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសដែលពួកគេធ្វើប្រតិបត្តិការ។

[54] ទិន្នន័យទីផ្សារ MIX៖ https://bit.ly/41KUNAZ។ ទីផ្សារ MIX គឺជាប្រភពចម្បងនៃព័ត៌មានសាធារណៈស្តីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) និងការអនុវត្តហិរញ្ញវត្ថុ និងសង្គមរបស់ពួកគេ ដែលផ្តល់របាយការណ៍វិភាគនៅកម្រិតសកល តំបន់ និងប្រទេស។ CGAP, Patrick Spaven និង Karina Broens Nielsen ការវាស់ស្ទង់ការអភិវឌ្ឍទីផ្សារ៖ សៀវភៅណែនាំសម្រាប់អ្នកផ្តល់មូលនិធិ និងអ្នកអនុវត្តកម្មវិធីបរិយាប័ន្នហិរញ្ញវត្ថុ ខែតុលា ឆ្នាំ២០១៧ ទំ. ៦១ https://bit.ly/4414MDy។

[55] ទិន្នន័យទីផ្សារ MIX៖ https://bit.ly/41KUNAZ។ ទីផ្សារ MIX បានកែប្រែយុទ្ធសាស្ត្រប្រមូលទិន្នន័យរបស់ខ្លួន នៅក្រោយឆ្នាំ ២០១១ ដោយផ្តោតលើស្ថាប័នដែលមានការរាយការណ៍យ៉ាងជាប់លាប់ ដោយចំនួនស្ថាប័នជារួមបានថយចុះនៅក្រោយឆ្នាំ២០១១ នៅខណៈពេលដែលចំនួនអតិថិជន និងផលបត្រប្រាក់កម្ចីបន្តកើនឡើង។

[56] Deborah Drake, Elisabeth Rhyne. *ការធ្វើពាណិជ្ជកម្មមីក្រូហិរញ្ញវត្ថុ៖ ការរក្សាតុល្យភាពរវាងពាណិជ្ជកម្ម និងការអភិវឌ្ឍ* សារព័ត៌មាន Kumerian ឆ្នាំ២០០២; Ira W. Lieberman *កំណើន និងការវិវត្តផ្នែកពាណិជ្ជកម្មនៃមីក្រូហិរញ្ញវត្ថុ* នៅក្នុង The Future of Microfinance ១២ ៩-៣៥ (Ira W. Lieberman, Paul Dileo, Todd A. Watkins និង Anna Kanze eds. ឆ្នាំ២០២០) https://bit.ly/4kPwJWn។ សូមមើល Conger, L., Inga, P. និង Webb, R. (ឆ្នាំ២០០៩) The Mustard Tree៖ ប្រវត្តិមីក្រូហិរញ្ញវត្ថុនៅប៉េរូ, San Isidro, Universidad de San Martin de Porres។

ទន្ទឹមនឹងនេះ មូលនិធិអន្តរជាតិបានគាំទ្រដល់ការពង្រីកឧស្សាហកម្មមីក្រូហិរញ្ញវត្ថុយ៉ាងឆាប់រហ័ស។ នៅឆ្នាំ២០០៤ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបានបែងចែកប្រាក់ចំនួន ១ ពាន់លានដុល្លារដល់មីក្រូហិរញ្ញវត្ថុ ដោយមានទឹកប្រាក់ចំនួន ៦០០ លានដុល្លារផ្សេងទៀត ត្រូវបានបែងចែកដោយមូលនិធិដែលគ្រប់គ្រងដោយឯកជន។[57] មូលធនអន្តរជាតិដែលហូរចូលទៅក្នុងមីក្រូហិរញ្ញវត្ថុបានឈានដល់ ៤៧ ពាន់លានដុល្លារ នៅឆ្នាំ២០១៨ (សូមមើលរូបភាពទី ១)។

**រូបភាពទី១៖ និន្នាការផ្តល់មូលនិធិជាអន្តរជាតិសម្រាប់បរិយាប័ន្នហិរញ្ញវត្ថុ (ឆ្នាំ២០១១-២០១៨)**




Source: CGAP Cross-Border Funder Survey 2008-2018; Trendable Set N=21; Symbiotics MIV Survey 2009 - 2019

កំណើនដ៏ឆាប់រហ័សនេះបានអមជាមួយនឹងបញ្ហាប្រឈម។[58] ឧទាហរណ៍ នៅចន្លោះឆ្នាំ១៩៩៩ និងឆ្នាំ២០០១ វិបត្តិឥណទាននៅប្រទេសបូលីវី ដែលមានទំនាក់ទំនងនឹងការផ្តល់ប្រាក់កម្ចីច្រើនពេកដល់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ បានបណ្តាលឱ្យមានការមិនបំពេញកាតព្វកិច្ចជាច្រើន ការតវ៉ារបស់អ្នកខ្ចី និងការកើនឡើងនៃសមាគមកូនបំណុល។[59] នៅចន្លោះឆ្នាំ២០០៨ និង ឆ្នាំ២០០៩ វិបត្តិការសងប្រាក់ស្រដៀងគ្នាបានកើតឡើងនៅប្រទេសម៉ារ៉ុក នីការ៉ាហ្គា និងបូស្នៀ បន្ទាប់ពីមានកំណើនយ៉ាងឆាប់រហ័ស ដែលជំរុញឱ្យមានការកែលម្អនិយ័តកម្ម និងអភិបាលកិច្ច។[60] នៅឆ្នាំ២០១០ កំណើនយ៉ាងខ្លាំងនៃការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុនៅ Andhra Pradesh

---

[57] Xavier Reille និង Ousa Sananikone. *យានវិនិយោគមីក្រូហិរញ្ញវត្ថុ* CGAP ខែមេសា ឆ្នាំ២០០៧។ IFIs នៅទីនេះត្រូវបានកំណត់និយមន័យថាជា "ផ្នែកវិនិយោគឯកជនរបស់ទីភ្នាក់ងារអភិវឌ្ឍន៍សាធារណៈ" ដែលរួមមាន ស្ថាប័នអភិវឌ្ឍន៍ពហុភាគី ដូចជា IFC និង IADB ព្រមទាំងស្ថាប័នទ្វេភាគី ដូចជា KfW FMO។ល។

[58] Sam Mendelson និង Daniel Rozas វិបត្តិមីក្រូហិរញ្ញវត្ថុដែលត្រូវបានជ្រើសរើស៖ អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល *ការត្រួតពិនិត្យគោលនយោបាយសេដ្ឋកិច្ចរបស់ Oxford* លេខ ៤០ ច្បាប់ទី១ រដូវផ្ការីក ឆ្នាំ២០២៤ ទំព័រ ៣០-៤៣ https://bit.ly/3FomyI4 និង CGAP, Greg Chen, Stephen Rasmussen និង Xavier Reille កំណើន និងភាពងាយរងគ្រោះនៃមីក្រូហិរញ្ញវត្ថុ កំណត់សម្គាល់ចំណុចផ្តោត ខែកុម្ភៈ ឆ្នាំ២០១០ ទំ. ១៤-១៥ https://bit.ly/4iKaYFC។

[59] នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០១ សមាគមអ្នកលក់ផ្លែឈើ អ្នកកាប់គោ និងកសិករក្រីក្រ បានចាប់អ្នកគ្រប់គ្រងធនាគារ Bolivia ជាចំណាប់ខ្មាំង។ ដោយមានភាពភ្ញាក់ផ្អើលយ៉ាងខ្លាំង ពួកគេទាមទារឲ្យមានការលើកលែង ឬកាត់បន្ថយបំណុលរបស់ពួកគេ ដែលកើតឡើងតាមរយៈអ្នកផ្តល់ប្រាក់កម្ចីខ្នាតមីក្រូ និងអ្នកផ្តល់ប្រាក់កម្ចីអតិថិជន។ ស្ថានភាពនេះត្រូវបានដោះស្រាយ ប៉ុន្តែនៅតែមានអតិថិជនមីក្រូហិរញ្ញវត្ថុដែលជំពាក់បំណុលវ័ណ្ឌក។ Elisabeth Rhyne វិបត្តិមីក្រូហិរញ្ញវត្ថុបូលីវី នៅក្នុង Monday Developments, https://bit.ly/3XRmAyx, Elisabeth Rhyne ការធ្វើពាណិជ្ជកម្ម និងវិបត្តិមីក្រូហិរញ្ញវត្ថុបូលីវី DAI ខែវិច្ឆិកា ឆ្នាំ២០០១។

[60] CGAP, Greg Chen, Stephen Rasmussen, and Xavier Reille កំណើន និងភាពងាយរងគ្រោះនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ កំណត់សម្គាល់ចំណុចផ្តោត ខែកុម្ភៈ ឆ្នាំ២០១០ https://bit.ly/4iKaYFC។ នៅបូស្នៀ កត្តាមួយនៃការជំពាក់បំណុលវ័ណ្ឌក គឺកង្វះខាតស្តង់ដារឧស្សាហកម្មសម្រាប់ក្រមសីលធម៌ ដែលធ្វើឲ្យអតិថិជនមិនទទួលបានការការពារពីការប្រព្រឹត្តិដោយអយុត្តិធម៌ និងការអនុវត្តមិនត្រឹមត្រូវ។ សូមមើល Klaus Maurer និង Justyna Pytkowska បំណុលរបស់អតិថិជនមីក្រូឥណទាននៅបូស្នៀ និង ហឺហ្សេហ្គោវីណា មូលនិធិសហភាពអឺរ៉ុបសម្រាប់ការអភិវឌ្ឍន៍អឺរ៉ុប https://bit.ly/4iGIuME។ នៅប្រទេសម៉ារ៉ុក ការសិក្សាមួយដែលធ្វើឡើងដោយ IFC បានបណ្តាលឱ្យមានវេទិកាចែករំលែកព័ត៌មានរវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ការកែលម្អអភិបាលកិច្ច និងការអនុវត្តការផ្តល់ប្រាក់កម្ចី និងការបង្កើនការត្រួតពិនិត្យរបស់រដ្ឋាភិបាល។ IFC ការបញ្ចប់វិបត្តិមីក្រូហិរញ្ញវត្ថុនៅប្រទេសម៉ារ៉ុក៖ ធ្វើសកម្មភាពឲ្យឆាប់រហ័ស ធ្វើសកម្មភាពឲ្យត្រឹមត្រូវ ឆ្នាំ២០១៤ https://bit.ly/426coEM។ នៅប្រទេសនីការ៉ាហ្គា ធនាគារពិភពលោកបានគាំទ្រដល់ការពង្រឹងក្របខណ្ឌនិយ័តកម្ម និងការត្រួតពិនិត្យមីក្រូហិរញ្ញវត្ថុ រួមទាំងការការពារអ្នកប្រើប្រាស់ផងដែរ។ WB Nicaragua ការទទួលបានសេវាហិរញ្ញវត្ថុយ៉ាងទូលំទូលាយ ខែតុលា ឆ្នាំ២០១៣ https://bit.ly/3XODkqa។

ប្រទេសឥណ្ឌា បានបណ្ដាលឱ្យមានការរីករាលដាលនៃការខ្ចីប្រាក់ និងបំណុលវ័ណ្ឌក ការកើនឡើងនៃអត្រាការមិនបំពេញកាតព្វកិច្ច និងរបាយការណ៍ជាច្រើនអំពីការធ្វើអត្តឃាតរបស់កូនបំណុល ដែលជម្រុញឱ្យរដ្ឋាភិបាលក្នុងមូលដ្ឋានធ្វើអន្តរាគមន៍ ដោយហាមឃាត់សកម្មភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើន។[61]

ចាប់តាំងពីមានវិបត្តិនៅប្រទេសបូលីវីមក វិស័យនេះបានចាប់ផ្ដើមខិតខំប្រឹងប្រែងដោះស្រាយ និងបញ្ចៀសផលប៉ះពាល់អវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុ។ នៅខែកញ្ញា ឆ្នាំ២០០២ ក្រុមប្រឹក្សាយោបល់ដើម្បីជួយជនក្រីក្រ (CGAP) ដែល IFC និង WB ជាសមាជិក បានអនុម័តគោលការណ៍ណែនាំរួមស្ដីពីបទប្បញ្ញត្តិ និងការត្រួតពិនិត្យឧស្សាហកម្មនេះ។[62] Accion អន្តរជាតិ ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនស្វែងរកប្រាក់ចំណេញឈានមុខគេ បានអនុម័តបណ្ដុំគោលការណ៍នៃឧស្សាហកម្មនេះដំបូងគេ ក្នុងឆ្នាំ២០០៤[63] ដែលត្រូវបានផ្សព្វផ្សាយជាបន្តបន្ទាប់ដោយយុទ្ធនាការឆ្លាតវៃ ដែលជាគំនិតផ្ដួចផ្ដើមជាសាកល ដឹកនាំដោយមជ្ឈមណ្ឌលបរិយាប័ន្នហិរញ្ញវត្ថុ (CFI) និងបានតម្កល់នៅ Accion អន្តរជាតិ នៅចន្លោះឆ្នាំ២០០៩ និង ឆ្នាំ២០២០។ យុទ្ធនាការឆ្លាតវៃក៏បានបង្កើតគោលការណ៍ការពារអតិថិជន ដែលជាស្តង់ដារការពារអតិថិជនហិរញ្ញវត្ថុជាសកលដំបូងគេ និងបានបង្កើតកម្មវិធីវិញ្ញាបនប័ត្រ ដើម្បីធ្វើសុពលកម្មការអនុវត្តប្រកបដោយទំនួលខុសត្រូវដោយអ្នកផ្ដល់សេវាហិរញ្ញវត្ថុ។[64] ចាប់តាំងពីពេលបិទយុទ្ធនាការឆ្លាតវៃ ក្នុងឆ្នាំ២០២០ មក ក្រុមការងារអនុវត្តការងារសង្គម (SPTF)+Cerise បានបន្តគ្រប់គ្រងគោលការណ៍ការពារអតិថិជន។[65] ការអភិវឌ្ឍទាំងនេះឆ្លុះបញ្ចាំងពីការ

[61] នៅខែតុលា ឆ្នាំ២០១០ រដ្ឋមន្ត្រីអភិវឌ្ឍន៍ជនបទរដ្ឋ នៃរដ្ឋ Andhra Pradesh បានប្រកាសបទបញ្ញត្តិមួយដើម្បីការពារអ្នកខ្ចីពី "ការបៀតបៀន" ដោយភ្នាក់ងារ MFI បន្ទាប់ពីមានការតវ៉ា និងការរាយការណ៍អំពីការកើនឡើងនៃអំពើហិង្សា។ ការចោទប្រកាន់ រួមមានករណីចាប់ពង្រត់កុមារ ធ្វើពេស្យាចារក្មេងស្រីវ័យក្មេងដោយបង្ខំដើម្បីបង្ខិតបង្ខំឪពុកម្ដាយឱ្យសងបំណុល និងរបាយការណ៍ជាច្រើនទៀតអំពីភ្នាក់ងារ MFI ដែលបង្ខំឱ្យអតិថិជនធ្វើអត្តឃាត ដើម្បីប្រើប្រាស់ធានារ៉ាប់រងអាយុជីវិតដើម្បីសងប្រាក់កម្ចី។ Philip Mader ការកើនឡើង និងការធ្លាក់ចុះនៃមីក្រូហិរញ្ញវត្ថុនៅប្រទេសឥណ្ឌា៖ វិបត្តិ Andhra Pradesh តាមការយល់ឃើញ ទំ. ៥៥ https://bit.ly/4hxHTMs។ Sam Mendelson និង Daniel Rozas វិបត្តិមីក្រូហិរញ្ញវត្ថុដែលបានជ្រើសរើស៖ អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល *ការត្រួតពិនិត្យគោលនយោបាយសេដ្ឋកិច្ចរបស់ Oxford* លេខ ៤០ ច្បាប់ទី១ រដូវផ្ការីក ឆ្នាំ២០២៤ ទំព័រ ៣០-៤៣ https://bit.ly/44eNuEE និង Biswas, Soutik, "ការរីករាលដាលនៃការធ្វើអត្តឃាតនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅប្រទេសឥណ្ឌា" *សារព័ត៌មាន BBC* ខែធ្នូ ឆ្នាំ២០១០ មាននៅ https://bit.ly/3OMLOKD។

[62] CGAP គោលការណ៍ណែនាំរួមអំពីមីក្រូហិរញ្ញវត្ថុ៖ គោលការណ៍ណែនាំស្ដីពីបទប្បញ្ញត្តិ និងការត្រួតពិនិត្យមីក្រូហិរញ្ញវត្ថុ https://bit.ly/3DrIzFy។

[63] Patrick McAllister. ទំនុកចិត្តតាមរយៈតម្លាភាព៖ ការអនុវត្តបទប្បញ្ញត្តិការការពារអ្នកប្រើប្រាស់មីក្រូហិរញ្ញវត្ថុដោយខ្លួនឯង។ ក្រុមការងារការពារអ្នកប្រើប្រាស់បណ្ដាញ SEEP ខែមីនា ឆ្នាំ ២០០៣; កំណត់សម្គាល់ចំណុចផ្ដោតរបស់ CGAP លេខ ២៧៖ ការការពារអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ខែឧសភា ឆ្នាំ២០២៥។ CGAP គឺជាភាពជាដៃគូជាសកលរបស់ អង្គការអភិវឌ្ឍន៍ឈានមុខគេជាង ៣៥ អង្គការ រួមទាំង IFC និងធនាគារពិភពលោកផងដែរ ដែលធ្វើការដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ជាពិសេសស្ត្រីតាមរយៈបរិយាប័ន្នហិរញ្ញវត្ថុ។ សូមមើល https://bit.ly/4itj2L5។

[64] សូមមើល យុទ្ធនាការឆ្លាតវៃ SPTF CERISE គោលការណ៍ការពារអតិថិជន https://bit.ly/3Fqg2AR។ សូមមើល មជ្ឈមណ្ឌលបរិយាប័ន្នហិរញ្ញវត្ថុ Accion ការដាក់គោលការណ៍ឱ្យដំណើរការ៖ ការណែនាំលម្អិតអំពីគោលការណ៍ការពារអតិថិជន ការការពារ និងការផ្ដល់ភាពអង់អាចដល់អ្នកប្រើប្រាស់ហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ https://www.centerforfinancialinclusion.org/wp-content/uploads/2024/02/Principles-Guidelines_Aug-2021-update-1.pdf។

[65] SPTF+Cerise គឺជាការបណ្ដាក់ទុនរួមគ្នារវាងអ្នកដឹកនាំជាសកលចំនួនពីរ ក្នុងការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន

លេចឡើងនៃការអនុវត្តល្អ ក្នុងការគ្រប់គ្រងហានិភ័យសង្គម និងផលប៉ះពាល់នៃការវិនិយោគមីក្រូហិរញ្ញវត្ថុ (សូមមើលផ្នែក ៣.៧.២ និងឧបសម្ព័ន្ធ ខ សម្រាប់ខ្សែបន្ទាត់ពេលវេលាកាន់តែលម្អិតបន្ថែមទៀត)។

## ១.២ មីក្រូហិរញ្ញវត្ថុ និងបំណុលវ័ណ្ឌកនៅកម្ពុជា

ឧស្សាហកម្មមីក្រូហិរញ្ញវត្ថុនៅកម្ពុជាភាគច្រើនឆ្លុះបញ្ចាំងពីការវិវត្តនៃវិស័យនេះនៅទូទាំងពិភពលោក។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដំបូងគេរបស់ប្រទេសនេះបានបើកដំណើរការនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ដោយមានការផ្តល់មូលនិធិពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងទីភ្នាក់ងារផ្តល់ជំនួយ ដែលជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍ជនបទ[66] និងត្រូវបានធ្វើស្ថាប័នីយកម្មជាអង្គការមិនមែនរដ្ឋាភិបាលក្នុងរយៈពេលពីរបីឆ្នាំ។[67] នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៃប្រទេសនេះ នៅចុងទសវត្សរ៍ឆ្នាំ១៩៩០[68] អង្គការមិនមែនរដ្ឋាភិបាលមីក្រូហិរញ្ញវត្ថុភាគច្រើនបានវិវត្តទៅជាធនាគារពាណិជ្ជ ដែលត្រូវបានរួមបញ្ចូលទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ។[69] អតីតអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ បច្ចុប្បន្ន គឺជាគ្រឹះស្ថានធនាគារធំជាងគេចំនួនប្រាំមួយក្នុងចំណោមស្ថាប័នធនាគារធំជាងគេទាំងដប់នៅក្នុងប្រទេស និងបានរាយការណ៍ថាមានប្រាក់កម្ចីសកម្មលើសពី ៩០% នៅខែធ្នូ ឆ្នាំ២០២៣ ហើយពួកគេក៏ជា BFIs កម្ពុជា ទាំងប្រាំមួយ ដែលជាកម្មវត្ថុនៃពាក្យបណ្តឹងរបស់ស៊ីអេអូ និងជាអតិថិជន និងអតិថិជនបន្តរបស់ IFC នៅក្នុងសំណុំរឿងនេះដែរ (សូមមើលតារាងទី១ ខាងក្រោម)។[70]

---

នៅក្នុងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ SPTF ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៥ បានបង្កើត និងធ្វើបច្ចុប្បន្នភាពស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថានជាទៀងទាត់។ Cerise ដែលជាអង្គការមិនស្វែងរកប្រាក់ចំណេញរបស់ប្រទេសបារាំង បានបង្កើតឡើងក្នុងឆ្នាំ១៩៩៨ បានត្រួសត្រាយផ្លូវនៃការអនុវត្តការគ្រប់គ្រងការអនុវត្តការងារសង្គម ដោយធ្វើការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលប្តេជ្ញាចិត្តចាប់ផ្តើមអនុវត្តគំនិតផ្តួចផ្តើមនៃសូចនាករការអនុវត្តការងារសង្គម ក្នុងឆ្នាំ២០០១។ សូមមើល៖ https://bit.ly/41Rk3FM។ នៅខណៈពេលដែល Cerise+SPTF បានបង្កើតធនធានដែលរៀបរាប់លម្អិតអំពីស្តង់ដារវិជ្ជាជីវៈ និងសីលធម៌ ដែលអ្នកពិនិត្យខាងក្រៅគួរតែបំពេញតាម និងលក្ខណៈសម្បត្តិដែលពួកគេគួរតែមាន Cerise+SPTF មិនបានស៊ើបអង្កេត ឬបញ្ជាក់ពីកភាពអនុលោមរបស់ភាគីទីបី ចំពោះគោលការណ៍ណែនាំ និងក្របខណ្ឌការពារអតិថិជន និងមិនបានផ្តល់អនុសាសន៍ អនុម័ត ឬធ្វើការបញ្ជាក់អះអាងណាមួយទាក់ទងនឹងភាគីទីបីឡើយ។ សូមមើល៖ SPTF ការធ្វើសុពលកម្មភាគីទីបី https://cerise-sptf.org/third-party-validation/។

[66] CGAP ការត្រួតពិនិត្យប្រសិទ្ធភាព និងគណនេយ្យភាពកម្រិតប្រទេស ខែមករា ឆ្នាំ២០០៥ ទំ. ៣ https://bit.ly/4bPkS6y

[67] CGAP ការត្រួតពិនិត្យប្រសិទ្ធភាព និងគណនេយ្យភាពកម្រិតប្រទេស ខែមករា ឆ្នាំ២០០៥ ទំ. CGAP ការត្រួតពិនិត្យប្រសិទ្ធភាព និងគណនេយ្យភាពកម្រិតប្រទេស ខែមករា ឆ្នាំ២០០៥ ទំ. ៤ https://bit.ly/4bPkS6y

[68] ប្រទេសកម្ពុជាបានអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុរបស់ខ្លួនស្របពេលនឹងការអភិវឌ្ឍប្រព័ន្ធធនាគាររបស់ប្រទេសកាន់តែទូលំទូលាយ។ ខ្មែរក្រហម កាលពីមុន បានលុបបំបាត់ប្រព័ន្ធហិរញ្ញវត្ថុ និងបានបំផ្ទុះទីស្នាក់ការកណ្តាលរបស់ធនាគារកណ្តាល ហើយជាលទ្ធផល កម្ពុជាត្រូវកសាងវិស័យធនាគារទាំងមូលឡើងវិញ។ សូមមើល https://bit.ly/43JCRcw

[69] កម្លាំងជម្រុញដ៏សំខាន់មួយ នៅពីក្រោយការវិវត្តនៃអង្គការមិនមែនរដ្ឋាភិបាលទៅជាធនាគារពាណិជ្ជគឺ ការធ្វើឱ្យ MFIs ទទួលបានប្រាក់បញ្ញើ និងប្រើប្រាស់វាដើម្បីពង្រីកប្រតិបត្តិការរបស់ពួកគេយ៉ាងខ្លាំងក្លា ដូចដែល MFIs ពាណិជ្ជកម្មកំពុងធ្វើនៅក្នុងប្រទេសដទៃទៀត។ CGAP ការត្រួតពិនិត្យប្រសិទ្ធភាព និងគណនេយ្យភាពកម្រិតប្រទេស ខែមករា ឆ្នាំ២០០៥ ទំ. CGAP ការត្រួតពិនិត្យប្រសិទ្ធភាព និងគណនេយ្យភាពកម្រិតប្រទេស ខែមករា ឆ្នាំ២០០៥ ទំ. ៥ https://bit.ly/4bPkS6y

[70] សូមមើល MIMOSA កម្ពុជា ឆ្នាំ២០២០។ ការវិភាគបង្ហាញថា សមាជិកសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) មានចំនួន ៧៣% នៃប្រាក់កម្ចីសរុបតាមការគ្រោងទុក ទោះបីជាចំនួននេះចាត់ទុកអតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេស៊ីលីដា និងស្ថាបនា ជាធនាគារក៏ដោយ។ ការរួមបញ្ចូលគ្នានៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងពីរនេះ រួមជាមួយសមាជិក CMA ធ្វើឲ្យចំណែកអ្នកផ្តល់ប្រាក់កម្ចីដែលជា MFI និងអតីត MFI មានចំនួនរហូតដល់ ៩១% នៃចំនួនសរុប។

**តារាងទី១៖ ធនាគារ/គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេទាំង១០ នៅកម្ពុជា តាមផលបត្រប្រាក់កម្ចី (គិតត្រឹមខែធ្នូ ឆ្នាំ២០២៣)[71]**

| | ធនាគារ/គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬអតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ប្រាក់កម្ចីសរុប (លានរៀល) | ទ្រព្យសកម្មសរុប (លានរៀល) | ឆ្នាំបង្កើត |
|---|---|---|---|---|
| ១ | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (អេប៊ីអេ) | ៣១.៦១២.២៧៥ | ៤៦.៩៦៩.៩៥៣ | ១៩៩៦ |
| ២ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២៦.៦៤១.៣៣២ | ៣៨.៦២០.៥២៩ | ១៩៩៣ |
| ៣ | ធនាគារ ខេប៊ីប្រាសាក់ ម.ក | ២០.៧៨៩.០៥១ | ២៣.៧១១.២៩៣ | ១៩៩៥ |
| ៤ | ធនាគារ កាណាឌីយ៉ា ភីអិលស៊ី | ១៩.៨៦៥.៦៧៣ | ៣២.៦៧៧.៤៦៩ | ១៩៩១ |
| ៥ | ធនាគារ ស្ថាបនា ភីអិលស៊ី | ៨.៩៥២.០២៧ | ១១.៤១៤.៤៦៩ | ១៩៩៥ |
| ៦ | អម្រឹត ម.ក | ៦.៥៦៨.០២៣ | ៨.៥១៤.៨៤៤ | ១៩៩១ |
| ៧ | ធនាគារ ហត្ថា ភីអិលស៊ី | ៦.៤២៤.៤៦៥ | ៨.៦៤៤.៦១៤ | ១៩៩៤ |
| ៨ | ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី | ៥.៧៣៩.៣២០ | ៨.៩២៤.៨៥២ | ១៩៩២ |
| ៩ | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៥.១៧៧.២៦៧ | ៨.២១០.៣៨១ | ១៩៧៩[72] |
| ១០ | អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី | ៥.១២៥.២៤០ | ៦.៤៣៨.៥១៤ | ១៩៩៤ |

ការវិនិយោគដោយ IFC និង DFIs ដទៃទៀត បានដើរតួនាទីយ៉ាងសំខាន់ក្នុងការវិវត្តរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនេះទៅជាធនាគារពាណិជ្ជ[73] តាមរយៈការវិនិយោគទាំងភាគហ៊ុន និងបំណុល។[74] ទោះបីជាយ៉ាងណាក៏ដោយ ការវិនិយោគទាំងនេះបានចាប់ផ្តើមធ្លាក់ចុះនៅឆ្នាំ២០១៩ ចំពេលដែលមានការកើនឡើងនៃកង្វល់អំពីបំណុលវ័ណ្ឌក តិត្ថិភាពទីផ្សារ និងការខូចខាតដល់សង្គម។

---

[71] ទិន្នន័យពី NBC គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (https://bit.ly/3SOE7of)។ ឆ្នាំបង្កើតត្រូវបានយកពីគេហទំព័ររបស់ស្ថាប័នដោយផ្ទាល់។ នៅពេលធ្វើសេចក្តីព្រាងរបាយការណ៍នេះ ទិន្នន័យឆ្នាំ២០២៤ មិនមាននៅលើគេហទំព័ររបស់ NBC នោះទេ។

[72] ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា គឺជាផ្នែកមួយនៃធនាគារកណ្តាល រហូតដល់វាបានបំបែកខ្លួនជាធនាគារពាណិជ្ជរបស់រដ្ឋឯករាជ្យ នៅឆ្នាំ២០០០ (https://bit.ly/4kMUPku)។

[73] Frank Bliss "មីក្រូ" ហិរញ្ញវត្ថុនៅកម្ពុជា៖ ការអភិវឌ្ឍ បញ្ហាប្រឈម និងអនុសាសន៍ កំណែបានធ្វើបច្ចុប្បន្នភាពនៅខែសីហា ឆ្នាំ២០២២ វិទ្យាស្ថានអភិវឌ្ឍន៍ និងសន្តិភាព (INEF) សាកលវិទ្យាល័យ DuisburgEssen (ការសិក្សា AVE ៣០/២០២២) ទំ. ៣១ https://bit.ly/3XRpDXv (តទៅនេះ ហៅថា "របាយការណ៍ Bliss")។ គម្រោងដែលផ្តល់មូលនិធិដោយក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ)។ CGAP ការត្រួតពិនិត្យប្រសិទ្ធភាព និងគណនេយ្យភាពកម្រិតប្រទេស ខែមករា ឆ្នាំ២០០៥ ទំ. CGAP ការត្រួតពិនិត្យប្រសិទ្ធភាព និងគណនេយ្យភាពកម្រិតប្រទេស ខែមករា ឆ្នាំ២០០៥ https://bit.ly/4bPkS6y។

[74] នៅឆ្នាំ២០១២ អ្នកផ្តល់មូលនិធិអន្តរជាតិមានចំនួន ៨៧% នៃការកាន់កាប់ភាគហ៊ុន ក្នុងចំណោម MFIs ធំជាងគេទាំង ១៥ នៅកម្ពុជា ទោះបីជាការវិនិយោគភាគហ៊ុនស្ទើរតែទាំងអស់នេះត្រូវបានលក់ទៅឱ្យវិនិយោគិនពាណិជ្ជកម្ម នៅឆ្នាំ២០២៣ ក៏ដោយ។ DFIs ក៏បានវិនិយោគយ៉ាងច្រើននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាតាមរយៈបំណុលផងដែរ ហើយនៅឆ្នាំ២០១៥ កម្ពុជាគឺជាគោលដៅធំបំផុតតែមួយគត់សម្រាប់ការវិនិយោគពីមូលនិធិមីក្រូហិរញ្ញវត្ថុ។ Sanjay Sinha *មីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ កន្លែងកម្សាន្តសម្រាប់វិនិយោគិន ឬកម្លាំងជម្រុញសម្រាប់បរិយាប័ន្នហិរញ្ញវត្ថុ?* M-CRIL ខែធ្នូ ឆ្នាំ២០១៣។ Daniel Rozas *អត្តិភាពនៃភាគហ៊ុនដែលមានទំនួលខុសត្រូវ៖ មេរៀនពីប្រទេសកម្ពុជា* Findev Gateway ខែមីនា ឆ្នាំ២០២៤៖ https://bit.ly/424aEMj; ការស្ទង់មតិអំពីយាននៃការវិនិយោគមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០១៥ Symbiotics ខែកញ្ញា ឆ្នាំ២០១៥ ១៩; ការស្ទង់មតិអំពីមូលនិធិផលប៉ះពាល់នៃទ្រព្យសកម្មឯកជន Tameo ឆ្នាំ២០២០-២៣; ការស្ទង់មតិអំពីយាននៃការវិនិយោគមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០១៥ Symbiotics ខែកញ្ញា ឆ្នាំ២០១៥ ១៩; ការស្ទង់មតិអំពីមូលនិធិផលប៉ះពាល់នៃទ្រព្យសកម្មឯកជន Tameo ឆ្នាំ២០២០-២៣។

វិនិយោគិនពាណិជ្ជកម្មបានជួយសម្រួលដល់ការពង្រីកឧស្សាហកម្មនេះយ៉ាងឆាប់រហ័ស។ ប្រទេសកម្ពុជាបច្ចុប្បន្ន មានចំនួនអ្នកខ្ចីមីក្រូហិរញ្ញវត្ថុច្រើនជាងគេបំផុតនៅលើពិភពលោក ហើយគិតត្រឹមឆ្នាំ២០២២ គឺជាប្រទេសដែលមានតិត្ថិភាពឥណទានច្រើនជាងគេលំដាប់ទី៣ នៅលើពិភពលោក។[75] នៅប្រទេសកម្ពុជា ការរីករាលដាលនៃកម្មសិទ្ធិដីធ្លីក្នុងចំណោមអតិថិជនមីក្រូហិរញ្ញវត្ថុ និងការទទួលបានប្លង់ទន់ដីធ្លីយ៉ាងងាយស្រួល បានធ្វើឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធ្វើការធានាចំពោះប្រាក់កម្ចីរបស់ពួកគេភាគច្រើន ដោយប្រើដីធ្លីជាវត្ថុបញ្ចាំ។[76]
ទំហំប្រាក់កម្ចីក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ពីជាមធ្យម ៤០៩ ដុល្លារអាមេរិក ក្នុងឆ្នាំ២០០៦[77] ដល់ ៤.៥៧៨ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣[78] នៅប្រទេសដែលមាន GDP សម្រាប់មនុស្សម្នាក់ ចំនួន ២.៤២៩ ដុល្លារអាមេរិក។[79] ចំនួនប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុក្នុងអំឡុងឆ្នាំ២០០៤-២០១៤ បានកើនឡើងលឿនជាងប្រាក់ចំណូលរបស់អ្នកខ្ចីលើសពីបួនដង (សូមមើលរូបភាពទី២)។[80]

**រូបភាពទី២៖ ការប្រែប្រួលនៃសមតុល្យប្រាក់កម្ចីជាមធ្យម/GNI ក្នុងប្រជាជនម្នាក់ (ឆ្នាំ២០០៤-២០១៤)**




Source: MIX Market, change calculated for MFI panel using each MFI's average loan balance during 2004-14, then aggregate average calculated by weighting by number of active borrowers in 2014; only countries with a panel of at least 4 MFIs are included.

---

[75] សារាចរណែនាំពិសេសស្ដីពី Mimosa កម្ពុជា ឆ្នាំ២០២៣។ ការវិវត្តនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាទៅជាធនាគារពាណិជ្ជក៏នាំឱ្យមានការផ្លាស់ប្ដូរពីការខ្ចីប្រាក់ជាក្រុម (ដែលបំណុលសមូហភាព មានន័យថា ប្រាក់កម្ចីទំនងជាត្រូវបានសងវិញ) ទៅជាការខ្ចីប្រាក់ជាលក្ខណៈបុគ្គល។ ដូចនៅប្រទេសដទៃទៀតដែរ ការផ្លាស់ប្ដូរនេះត្រូវបានជំរុញដោយការរួមបញ្ចូលគ្នានៃតម្រូវការអតិថិជននូវប្រាក់កម្ចីកាន់តែច្រើន និងការលើកទឹកចិត្តរបស់ MFI ក្នុងការពង្រីកផលបត្ររបស់ពួកគេ។ ទិន្នន័យពីទីផ្សារ MIX៖ https://bit.ly/41KUNAZ; W. Nathan Green, Theavy Chhom, Reach Mony និង Jennifer Estes ផ្នែកខាងក្រោមនៃមីក្រូហិរញ្ញវត្ថុ៖ សូចនាករសមិទ្ធកម្ម និងបំណុលក្រៅប្រព័ន្ធនៅកម្ពុជា ការអភិវឌ្ឍ និងការផ្លាស់ប្ដូរ លេខ ៥៤ ច្បាប់ទី ៤ វិទ្យាស្ថានអន្តរជាតិសិក្សាសង្គម ខែមិថុនា ឆ្នាំ២០២៣ https://bit.ly/3DvvET0

[76] របាយការណ៍ Bliss ទំ. ៦៧ https://bit.ly/3XRpDXv និង W. Nathan Green, Theavy Chhom, Reach Mony និង Jennifer Estes ផ្នែកខាងក្រោមនៃមីក្រូហិរញ្ញវត្ថុ៖ សូចនាករសមិទ្ធកម្ម និងបំណុលក្រៅប្រព័ន្ធនៅកម្ពុជា ការអភិវឌ្ឍ និងការផ្លាស់ប្ដូរ លេខ ៥៤ ច្បាប់ទី ៤ វិទ្យាស្ថានអន្តរជាតិសិក្សាសង្គម ខែមិថុនា ឆ្នាំ២០២៣ https://bit.ly/3DvvET0។ ការវាយតម្លៃផលប៉ះពាល់នៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជា M-CRIL ខែវិច្ឆិកា ឆ្នាំ២០២៣ https://bit.ly/42XlvHc ទំ. ៥៩ (តទៅនេះ ហៅថា "ការវាយតម្លៃផលប៉ះពាល់ M-CRIL – CMA ឆ្នាំ២០២៣") ពាក្យ *ប្លង់ទន់* សំដៅលើការអនុវត្តរបស់អាជ្ញាធរមូលដ្ឋាននៅប្រទេសកម្ពុជា ក្នុងការចេញវិញ្ញាបនប័ត្រកម្មសិទ្ធិដីធ្លី ដែលបន្ទាប់មក ត្រូវបានជួញដូរនៅក្រៅប្រព័ន្ធសុរិយោដីផ្លូវការ។

[77] បានគណនាពី CMA NIX ឆ្នាំ២០០៦

[78] ការវាយតម្លៃផលប៉ះពាល់ M-CRIL – CMA ឆ្នាំ២០២៣ ទំ. ៣ – ផ្អែកលើទិន្នន័យ CMA ដូចគ្នា។ ស៊ីអេអូកត់សម្គាល់ថា តួលេខនេះអាចរួមបញ្ចូលប្រាក់កម្ចីមិនមែនមីក្រូហិរញ្ញវត្ថុមួយចំនួន ដូចជា ប្រាក់កម្ចី SME ជាដើម ដែលចេញដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs)។

[79] ក្រុមធនាគារពិភពលោក GDP សម្រាប់មនុស្សម្នាក់ – ប្រទេសកម្ពុជា ឆ្នាំ២០២៣ https://bit.ly/46Dq9vQ។

[80] សារាចរណែនាំពិសេសស្ដីពី Mimosa កម្ពុជា ខែមិថុនា ឆ្នាំ២០១៦ ទំ. ២។ នៅចន្លោះឆ្នាំ២០១៦-១៩ កំណើន ចំនួនអតិថិជនបាន

មីក្រូហិរញ្ញវត្ថុបានធ្វើឱ្យអ្នកខ្ចីនៅកម្ពុជា អាចវិនិយោគលើសកម្មភាពបង្កើតប្រាក់ចំណូល និងទទួលបានទ្រព្យសកម្មនានា ដូចជាលំនៅឋាន និងទំនិញប្រើប្រាស់ដែលមានតម្លៃខ្ពស់។[81] ស្របពេលជាមួយគ្នានេះ និន្នាការដែលបានពិពណ៌នាខាងលើបានធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលជំពាក់បំណុលគេច្រើនជាងគេនៅលើពិភពលោក ដោយសារបរិមាណបំណុលមីក្រូហិរញ្ញវត្ថុ ដែលបណ្តាលឱ្យមានការបាត់បង់មុខរបរចិញ្ចឹមជីវិតជាច្រើន ក្នុងចំណោមជនក្រីក្របំផុតនៅក្នុងប្រទេសនេះ។[82] កង្វល់អំពីហានិភ័យនៃបំណុលវ័ណ្ឌក ដែលអាចកើតឡើង ត្រូវបានលើកឡើងជាលើកដំបូងនៅក្នុងការវាយតម្លៃ ដែលផ្តល់មូលនិធិដោយធនាគារពិភពលោក ឆ្នាំ២០០៩ ហើយចាប់ពីឆ្នាំ២០១១ មក របាយការណ៍បន្ថែមបានកត់សម្គាល់ជាពិសេសលើហានិភ័យនៃការបាត់បង់ដីធ្លី ការកាត់បន្ថយគុណភាព ឬបរិមាណអាហារនៅក្នុងគ្រួសារ និងផលប៉ះពាល់សង្គមជាអវិជ្ជមានដទៃទៀត។ នៅឆ្នាំ២០១៥ IFC បានកំណត់ហានិភ័យដែលបំណុលវ័ណ្ឌក និងក្របខណ្ឌការពារហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់មានភាពទន់ខ្សោយ អាចបង្កដល់សេដ្ឋកិច្ចកម្ពុជា និងអ្នកប្រើប្រាស់ម្នាក់ៗ រួមទាំង ហានិភ័យនៃការបាត់បង់ដីធ្លី ផងដែរ ហើយនៅឆ្នាំ២០១៦ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាដោះស្រាយបញ្ហានេះ។[83]

ជាការឆ្លើយតប នៅឆ្នាំ២០១៦ CMA ដែលជាសមាគមវិជ្ជាជីវៈសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បានបង្កើតគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី[84] តាមរយៈគោលការណ៍ណែនាំនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានប្តេជ្ញាចិត្តដោយស្ម័គ្រចិត្ត ធ្វើការកាត់បន្ថយបំណុលវ័ណ្ឌក តាមរយៈវិធានចំនួនបួន ក្នុងការរាយការណ៍ទៅកាន់ CBC ពហុប្រាក់កម្ចី បុនហិរញ្ញប្បទាន និងការការពារអតិថិជន។[85] ចាប់ពីឆ្នាំ២០១៧ មក រដ្ឋាភិបាល

---

ថយចុះយ៉ាងខ្លាំង (៣% ក្នុងមួយឆ្នាំ) ទោះបីជាផលបត្របន្តកើនឡើងយ៉ាងឆាប់រហ័សស្ទើរតែដូចកាលពីមុន (២៤% ក្នុងមួយឆ្នាំ) ក៏ដោយពោលគឺ ទំហំប្រាក់កម្ចីចាប់ផ្តើមកើនឡើងលឿនជាងមុន (៣២% ក្នុងមួយឆ្នាំ)។ បុនហិរញ្ញប្បទានប្រាក់កម្ចី ក្នុងនោះ អ្នកខ្ចីទទួលបានប្រាក់កម្ចីច្រើនជាងមុន ដែលមួយផ្នែកដើម្បីសងប្រាក់កម្ចីដែលមានស្រាប់នោះ ទំនងជាមូលហេតុនៃកំណើននេះមួយចំនួន។ សូមមើល W. Nathan Green និង Maryann Bylander អំណាចផ្តាច់មុខនៃមីក្រូហិរញ្ញវត្ថុ៖ បំណុលវ័ណ្ឌក និងការដកហូតដីធ្លីនៅកម្ពុជា ខែមិថុនា ឆ្នាំ២០២១ សង្គមវិទ្យានៃការអភិវឌ្ឍ លេខ ៧ ច្បាប់ទី២ ខែមិថុនា ឆ្នាំ២០២១ ទំ. ២០៩ https://bit.ly/3R9HzsA (តទៅនេះហៅថា "Green, Bylander អំណាចផ្តាច់មុខនៃមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០២១")។

[80] របាយការណ៍ Bliss ទំ. ១០ ១១៩ ១២០

[81] របាយការណ៍ Bliss ទំ. ១០ ១១៩ ១២០

[82] សូមមើល Green, Bylander, អំណាចផ្តាច់មុខនៃមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០២១; សូមមើលការវាយតម្លៃផលប៉ះពាល់ M-CRIL – CMA ឆ្នាំ២០២៣ ទំ. ៤៩ និង ៦០ ដេស៊ីបែល ការយល់ដឹងអំពីកម្ពុជាពីសន្ទស្សន៍មីក្រូហិរញ្ញវត្ថុ ៦០ ដេស៊ីបែល ឆ្នាំ២០២៤ https://bit.ly/43JJ6xl ទាញអាគតដ្ឋាន The World from PRX (ខែតុលា ឆ្នាំ២០២៣)។ មីក្រូហិរញ្ញវត្ថុមានបំណងជួយប្រជាជនក្រីក្រនៅលើពិភពលោក ប៉ុន្តែនៅកម្ពុជា វាកំពុងធ្វើឱ្យប្រជាជនមានបំណុលកាន់តែច្រើន។ https://bit.ly/3ZPhVyn

[83] IFC ការលើកកម្ពស់ការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ឆ្នាំ២០១៥ ទំ. ២៩-៣៣ មាននៅ https://bit.ly/41LJkma និង Green, Bylander អំណាចផ្តាច់មុខនៃមីក្រូហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០២១ ទំ. ២០២-២០៣ https://bit.ly/3R9HzsA។

[84] Incofin, Incofin ចាប់ផ្តើមត្រួតត្រាយផ្លូវគំនិតផ្តួចផ្តើមនិយ័តកម្មដោយខ្លួនឯង ដើម្បីទប់ស្កាត់បំណុលវ័ណ្ឌកនៅកម្ពុជា ឆ្នាំ២០១៨ https://bit.ly/3RepKbP។

[85] ដោយត្រូវបានអនុម័តក្នុងខែធ្នូ ឆ្នាំ២០១៦ គោលការណ៍ណែនាំនេះត្រូវបានចារអនុម័តដោយស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍ (DFI) ស្ទើរតែទាំងអស់ ដែលបន្ទាប់មក មានភាពសកម្មនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែមិនត្រូវបានចារអនុម័តជាបឋម ដោយអនុស្សរណៈនៃការយោគយល់គ្នារបស់ IFC ស្តីពីគោលការណ៍ណែនាំអំពីការខ្ចីប្រាក់បណ្តោះអាសន្នទៅនោះទេ MOU ខេត្តព្រះសីហនុ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦។ គោលការណ៍ណែនាំអ្នកផ្តល់ប្រាក់កម្ចី CMA ឧបសម្ព័ន្ធទី២៖ សេចក្តីថ្លែងការណ៍អំពីការចារអនុម័តដោយអ្នកផ្តល់ប្រាក់កម្ចី ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

កម្ពុជាក៏បានដាក់ចេញនូវវិធានការនិយ័តកម្មក្នុងការកំណត់ពិដានអត្រាការប្រាក់ ត្រឹម ១៨% ក្នុងមួយឆ្នាំ ដោយតម្រូវឱ្យ FIs ទាំងអស់ បង្កើតយន្តការពាក្យបណ្ដឹងរបស់អ្នកប្រើប្រាស់ ហាមឃាត់អាជ្ញាធរមូលដ្ឋានមិនឲ្យគាំទ្រសកម្មភាពប្រមូលបំណុល អនុញ្ញាតឱ្យមានការរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ[86] និងហាមឃាត់គ្រប់ទម្រង់ទាំងអស់នៃការគំរាមកំហែង និងការបំភិតបំភ័យ ក្នុងអំឡុងពេលដំណើរការប្រមូលប្រាក់កម្ចី។[87]

ទោះបីជាមានវិធានការទាំងនេះក៏ដោយ ក៏នៅតែមានកង្វល់អំពីបំណុលមីក្រូហិរញ្ញវត្ថុដែរ។ នៅឆ្នាំ២០១៩ ធនាគារពិភពលោកបានព្រមានអំពីការកើនឡើងនៃផលធៀបបំណុល និងការប្រើប្រាស់នៃវិស័យនេះ[88] នៅឆ្នាំ២០២០ របាយការណ៍មួយរបស់ IFC ដែលបានប្រគល់ជូន MIMOSA បានសន្និដ្ឋានថា កម្ពុជាបានឈានដល់កម្រិតអតិបរិមានៃតត្តិភាពទីផ្សារ ហើយបទប្បញ្ញត្តិស្ដីពីការការពារអតិថិជននៅក្នុងវិស័យ MFI របស់កម្ពុជា ចាំបាច់ត្រូវមានការពង្រឹងយ៉ាងខ្លាំង។[89] អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សជាច្រើន និងអង្គការសហប្រជាជាតិបានលើកឡើងនូវកង្វល់អំពីផលប៉ះពាល់នៃកម្រិតបំណុលខ្ពស់ លើជនងាយរងគ្រោះខ្លាំងបំផុត[90] និងការសិក្សាតាមបែបបរិមាណវិស័យ ដែលធ្វើឡើងដោយរដ្ឋាភិបាលអាល្លឺម៉ង់ និង CMA បានសម្គាល់

---

[86] ដើម្បីឆ្លើយតបនឹងវិបត្តិជំងឺកូវីដ ១៩ ធនាគារជាតិនៃកម្ពុជាបានណែនាំគោលនយោបាយរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ ក្នុងខែមីនា ឆ្នាំ២០២០ ហើយនៅខែសីហា ឆ្នាំ២០២៤ បានចេញសារាចរមួយ ដែលផ្ដល់ការណែនាំបន្ថែមសម្រាប់កិច្ចខិតខំប្រឹងប្រែងរៀបចំរចនាសម្ព័ន្ធឡើងវិញ។ សារាចរ ឆ្នាំ២០២៤ អនុញ្ញាតឱ្យ BFIs រៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ រហូតដល់ពីរដង ដោយមិនកែប្រែចំណាត់ថ្នាក់របស់ពួកគេ ឬតម្រូវឱ្យមានការផ្ដល់ជូនបន្ថែមនោះទេ ដោយកំណត់ថាការរៀបចំរចនាសម្ព័ន្ធឡើងវិញត្រូវតែមានលក្ខខណ្ឌអំណោយផល (កាត់បន្ថយប្រាក់ដើម ឬការប្រាក់ ពន្យារពេលទូទាត់ប្រាក់ ឬការកែប្រែអ្នកខ្ចី) និងមានបំណងអនុវត្តសម្រាប់តែអតិថិជនដែលកំពុងប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុរយៈពេលខ្លី ដែល FIs ត្រូវតែជូនដំណឹងទៅកាន់អតិថិជនឱ្យបានច្បាស់លាស់ រាយការណ៍ទៅកាន់ NBC ជាទៀងទាត់ និងប្រើលក្ខណៈវិនិច្ឆ័យគោលនយោបាយផ្ទៃក្នុង ដែលលើសពីទិន្នន័យ CBC នៅពេលអនុម័តប្រាក់កម្ចី។ NBC សារាចរណែនាំស្ដីពីការរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ; Phasy Res មីក្រូហិរញ្ញវត្ថុក្នុងពេលមានជំងឺកូវីដ ១៩៖ ការការពារអ្នកប្រើប្រាស់ និងដំណើរការរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ នៅកម្ពុជា ខែមិថុនា ឆ្នាំ២០២១ ទំ. ៦៥ https://bit.ly/4iLFoap និងច្បាប់ RHT កម្ពុជា បច្ចុប្បន្នភាពច្បាប់ប្រចាំខែ ខែសីហា ឆ្នាំ២០២៤ https://bit.ly/4mTBzCU

[87] អនុក្រឹត្យ (ប្រកាស) ស្ដីពីពិដានអត្រាការប្រាក់ ឆ្នាំ២០១៧ មាត្រា ៣ ៤៖ https://bit.ly/4iKjTXC; អនុក្រឹត្យ (ប្រកាស) ស្ដីពីការដោះស្រាយពាក្យបណ្ដឹងរបស់អ្នកប្រើប្រាស់ ឆ្នាំ២០១៧ https://bit.ly/3FGuxAB; ក្រសួងមហាផ្ទៃ (ឆ្នាំ២០១៧)។ សារាចរណែនាំលេខ ៥៥៦ ស/ជ/ណ ស្ដីពីករណីធនាគារឯកជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទឯកជន ភ្នំពេញ មាត្រា ១៩ នៃច្បាប់ស្ដីពីការការពារអ្នកប្រើប្រាស់ - រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០១៩)។ ច្បាប់ស្ដីពីការការពារអ្នកប្រើប្រាស់ (នស/រកម /១១១៩/០១៦) ភ្នំពេញ។ បទប្បញ្ញត្តិនេះចែងថា គ្មានបុគ្គលណាម្នាក់ត្រូវបង្ខិតបង្ខំដោយកម្លាំង ការរំខាន ឬការគំរាមកំហែងផ្លូវចិត្តទាក់ទងនឹងការផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម ឬការទូទាត់ប្រាក់សម្រាប់ទំនិញ ឬសេវាកម្មនោះទេ។ ច្បាប់កម្ពុជាស្ដីពីការការពារអ្នកប្រើប្រាស់មិនគ្របដណ្ដប់លើសេវាហិរញ្ញវត្ថុរបស់អ្នកផ្ដល់សេវាមិនមែនធនាគារនោះទេ។ ដូចនៅចំណុច ១៤ នៃមាត្រា ៤ ចែងថា "សេវាកម្មសំដៅលើសិទ្ធិ អត្ថប្រយោជន៍ អាទិភាព ការសម្របសម្រួល ដែលបានផ្ដល់ ឬស្នើផ្ដល់ តាមប្រភេទកិច្ចសន្យាដូចខាងក្រោម លើកលែងចំពោះសេវាហិរញ្ញវត្ថុមិនមែនធនាគារ"។

[88] ក្រុមធនាគារពិភពលោក កំណត់សម្គាល់គោលនយោបាយកម្ពុជាស្ដីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ ឆ្នាំ២០១៩ ទំ.១១ https://bit.ly/3NITywL

[89] សន្ទស្សន៍មីក្រូហិរញ្ញវត្ថុនៃការទំនាក់ទំនង និងតិត្ថិភាពទីផ្សារ (MIMOSA) របាយការណ៍ស្ដីពីប្រទេសកម្ពុជា ខែមីនា ឆ្នាំ២០២០ ទំ. ៧-៨

[90] របាយការណ៍ដំបូងរបស់អង្គការលីកាដូស្ដីពីការបាត់បង់ដីធ្លីក្នុងចំណោមអតិថិជនមីក្រូហិរញ្ញវត្ថុ ត្រូវបានចេញផ្សាយក្នុងខែសីហា ឆ្នាំ២០១៩ https://bit.ly/3DOHDLi។ បន្ទាប់ពីមានរបាយការណ៍របស់ Mimosa អង្គការឃ្លាំមើលសិទ្ធិមនុស្សបានជម្រុញឱ្យក្រុម

ឃើញការកាត់បន្ថយអាហារ ការលក់ដីធ្លីដែលទាក់ទងនឹងបំណុល និងកុមារឈប់រៀនដើម្បីទៅធ្វើការ និងជួយសងបំណុល ជាយន្តការទប់ទល់។[91]

នៅឆ្នាំ២០២២ និង ២០២៣ សមាគមធនាគារនៅកម្ពុជា (ABC) CMA និងសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា បានអនុម័តក្រមប្រតិបត្តិមួយ ដែលរួមបញ្ចូលគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី និងគន្លងនៃការការពារអតិថិជន SPTF+Cerise ហើយ CMA បានបង្កើតកិច្ចសន្យាគំរូសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ក្នុងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់តម្លាភាព ប្រសិទ្ធភាព និងការការពារអ្នកប្រើប្រាស់។[92] IFC បានចូលរួម និងបានគាំទ្រគំនិតផ្តួចផ្តើមទាំងអស់នេះ។ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ បន្ថែមពីលើកិច្ចខិតខំប្រឹងប្រែងដែលបានពិពណ៌នាខាងលើ IFC បានដោះស្រាយផលប៉ះពាល់សង្គមនៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជាតាមរយៈគំនិតផ្តួចផ្តើមនៅកម្រិតវិស័យ និងបានផ្តល់ការគាំទ្រផ្នែកទីប្រឹក្សាដល់ស្ថាប័នហិរញ្ញវត្ថុ រួមទាំង ធនាគារហត្ថា ផងដែរ ដើម្បីលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងកែលម្អអភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យ (សូមមើលព័ត៌មានលម្អិតបន្ថែម នៅផ្នែក ៤.១)។

---

ធនាគារពិភពលោកធ្វើការស៊ើបអង្កេតអំពីប្រាក់កម្ចីខ្នាតមីក្រូនៃប្រទេសកម្ពុជា និងបានផ្ញើលិខិតពីរច្បាប់ ទៅកាន់ IFC ដែលបង្ហាញពីការរំលោភបំពានក្នុងការផ្តល់ប្រាក់កម្ចីខ្នាតមីក្រូ (ដូចជា ការចោទប្រកាន់អំពីការបង្ខំឱ្យលក់ដី) និងការកើនឡើងយ៉ាងខ្លាំងនៃការរំលោភបំពានទាំងនេះ ក្នុងអំឡុងពេលមានជំងឺកូវីដ ១៩។ សូមមើល https://bit.ly/426kuxa។ សូមមើល អង្គការលើកលែងទោសអន្តរជាតិ របាយការណ៍ឆ្នាំ២០២០/២១ ទំ. ១០៦ ១០៨៖ https://bit.ly/3p9M8bE។ សម្រាប់ UN សូមមើលរបាយការណ៍អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិស្តីពីបំណុលឯកជន និងសិទ្ធិមនុស្ស របាយការណ៍ប្រចាំឆ្នាំរបស់ OHCHR របាយការណ៍របស់អ្នកជំនាញឯករាជ្យស្តីពីផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធដទៃទៀតរបស់រដ្ឋ ស្តីពីការទទួលបានសិទ្ធិមនុស្សពេញលេញ ជាពិសេសសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ឆ្នាំ២០២០) A/HRC/43/45 នៅ ទំ. ១ និងកថាខណ្ឌ ៣២-៣៤; របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍ប្រចាំឆ្នាំរបស់ OHCHR តួនាទី និងសមិទ្ធផលរបស់ OHCHR ក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ A/HRC/51/63 កថាខណ្ឌ ៤២; របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស តួនាទី និងសមិទ្ធផលរបស់ OHCHR ក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ A/HRC/48/49 កថាខណ្ឌ ៤០; គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ការបញ្ចប់ការសង្កេតលើរបាយការណ៍រយៈពេលទីពីរនៃប្រទេសកម្ពុជា ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ E/C.12/KHM/CO/2 កថាខណ្ឌ ៣៨ និង ៣៩ (ខ); របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក Vitit Muntarbhorn ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (ឆ្នាំ២០២៣) A/HRC/54/75 កថាខណ្ឌ ៦០៖ https://bit.ly/3Fr4FbH; របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក Vitit Muntarbhorn ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (ឆ្នាំ២០២៤) A/HRC/57/82 ទំ. ១៣ ១៨៖ https://bit.ly/4bSj6S7។

[91] របាយការណ៍ Bliss ទំ. ៤៥ និង ៧៦ គម្រោងដែលផ្តល់មូលនិធិដោយក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ); ការវាយតម្លៃផលប៉ះពាល់របស់ M-CRIL - CMA ឆ្នាំ២០២៣ រៀបចំដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ ការស្ទង់មតិ ឆ្នាំ២០២៤ លើអតិថិជនចំនួន ២.៩៣៩ នាក់ របស់អ្នកផ្តល់សេវាហិរញ្ញវត្ថុធំបំផុតនៅកម្ពុជា បានបន្តឆ្លុះបញ្ចាំងពីភាពតានតឹងក្នុងការទូទាត់សងក្នុងចំណោមអ្នកខ្ចី ដែលនាំឱ្យមានផលប៉ះពាល់សង្គមអវិជ្ជមាន ដូចជា ការលក់ដីធ្លី និងកុមារបោះបង់ការសិក្សា។ ៦០ ដេស៊ីបែល ការយល់ដឹងអំពីកម្ពុជាពីសន្ទស្សន៍មីក្រូហិរញ្ញវត្ថុ ៦០ ដេស៊ីបែល ឆ្នាំ២០២៤ ទំ. ៦។

[92] CMA គំនិតផ្តួចផ្តើមរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា https://bit.ly/3XMq7y8 និង Hin Pisei កិច្ចសន្យាស្តង់ដារសម្រាប់ប្រាក់កម្ចីទាំងអស់ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា *ការសែតភ្នំពេញប៉ុស្តិ៍* ខែសីហា ឆ្នាំ២០២៣ https://bit.ly/43IqXzK។

## ២. ការវិនិយោគរបស់ IFC នៅក្នុងស្ថាប័នហិរញ្ញវត្ថុចំនួនប្រាំមួយ ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងរបស់ស៊ីអេអូ

IFC បានផ្តល់ការគាំទ្រយ៉ាងទូលំទូលាយដល់វិស័យហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈជំនួយបច្ចេកទេស និងការវិនិយោគដោយផ្ទាល់ ដោយផ្តោតលើបរិយាប័ន្នហិរញ្ញវត្ថុ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ។ [93] IFC បានធ្វើការវិនិយោគសំខាន់ៗនៅក្នុងស្ថាប័នហិរញ្ញវត្ថុជាច្រើន ដែលផ្តល់មីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា យ៉ាងហោចណាស់ ចាប់តាំងពីឆ្នាំ១៩៩៨ មក។

ពាក់ព័ន្ធនឹងសំណុំរឿងនេះ IFC មានការវិនិយោគដោយផ្ទាល់ នៅអេស៊ីលីដា អម្រឹត និងធនាគារហត្ថា និងការប្រឈមផ្នែកហិរញ្ញវត្ថុដោយប្រយោល នៅប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា តាមរយៈការវិនិយោគលើឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ (MEF) មូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA) ក្រុមហ៊ុន North Haven Thai (ក្រុមហ៊ុនភាគហ៊ុនឯកជន) Advans S.A. (ក្រុមហ៊ុនហូលឌីងមីក្រូហិរញ្ញវត្ថុ) (សូមមើលរូបភាពទី៣)។[94] សរុបមក សំណុំរឿងនេះពាក់ព័ន្ធនឹងគម្រោងរបស់ IFC ចំនួន ១៣ គម្រោង ដែលគាំទ្រការផ្តល់ប្រាក់កម្ចីរបស់អតិថិជន ដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs)។[95]

---

[93] ក្របខណ្ឌភាពជាដៃគូប្រចាំប្រទេសរបស់ក្រុមធនាគារពិភពលោកសម្រាប់ប្រទេសកម្ពុជា (FY ២០១៩-២០២៣) ទំ. ២៥៖ https://bit.ly/3R82Dje។

[94] BFIs កម្ពុជាទាំងប្រាំមួយ ដែលការអនុវត្តរបស់ពួកគេមានទំនាក់ទំនងនឹងពាក្យបណ្តឹងនេះ រួមមាន អេស៊ីលីដា អម្រឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា។ អតិថិជន IFC ដោយផ្ទាល់ទាំងប្រាំពីរ ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះរួមមាន អេស៊ីលីដា អម្រឹត ធនាគារហត្ថា MEF MIFA, ក្រុមហ៊ុន North Haven Thai និង Advans។

[95] គម្រោងទាំងអស់នេះមានភាពសកម្ម នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ជូនស៊ីអេអូ ក្នុងខែកុម្ភៈ ឆ្នាំ២០២២។ គិតត្រឹមពេលធ្វើរបាយការណ៍នេះ គម្រោងចំនួនប្រាំបីនៅតែមានភាពសកម្ម និងគម្រោងចំនួនប្រាំទៀតត្រូវបានបិទ។ ព័ត៌មានលម្អិតត្រូវបានពន្យល់នៅផ្នែកខាងក្រោម។

**រូបភាពទី៣៖ ការវិនិយោគរបស់ IFC ត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះ**[96]




### ២.១.១ អេស៊ីលីដា និង ក្រុមហ៊ុន North Haven Thai

អេស៊ីលីដា ត្រូវបានបង្កើតឡើងក្នុងខែមករា ឆ្នាំ១៩៩៣ ដោយមានការគាំទ្រពី ILO និង UNDP ជាអង្គការមិនមែនរដ្ឋាភិបាលជាតិ ដើម្បីផ្តល់ប្រាក់កម្ចីដល់អតិថិជននៃវិស័យកសិកម្ម និងសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSME) ហើយបច្ចុប្បន្នជាធនាគារពាណិជ្ជធំបំផុតទីពីរនៅប្រទេសកម្ពុជា។[97] អេស៊ីលីដាគឺជាគម្រោងទីផ្សារហិរញ្ញវត្ថុដំបូងគេរបស់ IFC នៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៩៨ ហើយភាពជាដៃគូនេះនៅតែមានភាពសកម្ម។[98] នៅឆ្នាំ២០០០ IFC បានធ្វើការវិនិយោគភាគហ៊ុន ដែលមួយផ្នែក បានគាំទ្រដល់ការផ្លាស់ប្តូរអេស៊ីលីដាពី NGO ទៅជា MFI ហើយក្រោយមកទៅជាធនាគារពាណិជ្ជដែលផ្តល់ប្រាក់កម្ចីដល់អតិថិជនខ្នាតមីក្រូ កសិកម្ម និង MSME (គម្រោងលេខ ៩៦៧៥ មិនពាក់ព័ន្ធនឹងសំណុំរឿងនេះទេ)។[99] IFC បានផ្តល់ជំនួយបច្ចេកទេស និងបានគាំទ្រអេស៊ីលីដា អស់រយៈពេលជាច្រើនឆ្នាំ ក្នុងការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

---

[96] ការវិនិយោគដែលបានបញ្ចប់ ដែលបានចង្អុលបង្ហាញនៅក្នុងក្រាហ្វ តំណាងឱ្យតែគម្រោងដែលមានភាពសកម្មក្នុងខែកុម្ភៈ ឆ្នាំ ២០២២ នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ប៉ុណ្ណោះ។ IFC បានបញ្ចប់គម្រោងបន្ថែមជាច្រើនទៀត ជាមួយអតិថិជនទាំងនេះ មុនពេលពាក្យបណ្តឹងត្រូវបានដាក់។

[97] គេហទំព័ររបស់ធនាគារអេស៊ីលីដា៖ https://bit.ly/4kRmocr។ សម្រាប់ប្រវត្តិតួនាទីរបស់អេស៊ីលីដា និង IFC សូមពិគ្រោះយោបល់ជាមួយ៖ Clark, Heather ឆ្នាំ២០០៦៖ ពេលគ្មានលុយ៖ ការកសាងធនាគារអេស៊ីលីដានៅក្នុងវិស័យហិរញ្ញវត្ថុដែលកំពុងវិវត្តនៅកម្ពុជា និង Clark, Heather ឆ្នាំ២០២០៖ ហួសព្រំដែន លើសពីធនាគារ៖ សាច់រឿងរបស់ធនាគារអេស៊ីលីដា ឆ្នាំ២០០៥-២០១៩។

[98] IFC ធនាគារចំពោះនិរន្តរភាព៖ ការផ្តល់ហិរញ្ញប្បទានដល់ឱកាសផ្នែកបរិស្ថាន និងសង្គម នៅក្នុងទីផ្សារដែលកំពុងរីកចម្រើន ឆ្នាំ ២០០៧ ទំ. ៧០ https://bit.ly/4iKkb0E។

[99] IFC ការពង្រីកលទ្ធភាពទទួលបានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាតាមរយៈភាពជាដៃគូយុទ្ធសាស្ត្រ សាច់រឿងអំពីផលប៉ះពាល់នៃមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០១៤ https://bit.ly/3XRw5xH។

ធនាគារបានដោយជោគជ័យ ក្នុងឆ្នាំ២០០៣។[100] IFC បានបញ្ឈប់ការវិនិយោគភាគហ៊ុនរបស់ខ្លួននៅឆ្នាំ២០១៤ ប៉ុន្តែបានបន្តការវិនិយោគផ្សេងទៀតជាមួយអេស៊ីលីដា។ ចាប់ពីឆ្នាំ២០០០ មក IFC បានផ្តល់ហិរញ្ញប្បទានដល់ ២៦ គម្រោង ដោយផ្តោតលើអតិថិជន MSME[101] និងបានគាំទ្រគម្រោងទីប្រឹក្សាចំនួន ៦ ដើម្បីជួយអតិថិជនក្នុងការកសាងសមត្ថភាពស្ថាប័ន ពង្រឹងភាពធន់ អភិវឌ្ឍផលិតផលប្រកបដោយនវានុវត្តន៍ និងពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងការគ្រប់គ្រងហានិភ័យរួមបញ្ចូលគ្នា។[102] សំណុំរឿងនេះគ្របដណ្តប់លើប្រាក់កម្ចីបច្ចុប្បន្នរបស់ IFC ចំនួនពីរ នៅអេស៊ីលីដា (គម្រោងលេខ ៤២៤៨០ និង ៤៤៨៨២) ដើម្បីគាំទ្រកម្មវិធីផ្តល់ប្រាក់កម្ចីដល់សហគ្រាសធុនតូច និងមធ្យម (SMEs) ដែលមានទឹកប្រាក់វិនិយោគសរុបចំនួន ២៧៩ លានដុល្លារអាមេរិក ដែលបានអនុម័តក្នុងឆ្នាំ២០១៩ និង ឆ្នាំ២០២១ ដាច់ដោយឡែកពីគ្នា ហើយប្រាក់កម្ចីទាំងពីរប្រភេទនេះត្រូវបានចាត់ថ្នាក់ជា FI-២ (ហានិភ័យកម្រិតស្រាល/មធ្យម)។[103]

ការវិនិយោគទីបី ការវិនិយោគដែលពាក់ព័ន្ធរបស់ IFC ក៏ត្រូវបានគ្របដណ្តប់នៅក្នុងសំណុំរឿងនេះដែរ។ នៅឆ្នាំ២០១៨ IFC បានទិញភាគហ៊ុន ៣,៣៨% នៅក្នុងក្រុមហ៊ុន North Haven Thai (គម្រោងលេខ ៣៨៦០៩) ជាមូលនិធិភាគហ៊ុនឯកជនមួយ ដែលគ្រប់គ្រងដោយ Morgan Stanley[104] ក្រោយមក បានទិញភាគហ៊ុន ៣,៥% នៅអេស៊ីលីដា ក្នុងខែមេសា ឆ្នាំ២០២២[105] ដែលតំណាងឱ្យ ១០,២% នៃទំហំមូលនិធិ។ ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិ (AMC) របស់ IFC ក៏បានវិនិយោគនៅក្នុងក្រុមហ៊ុន North Haven Thai តាមរយៈមូលនិធិ GEM របស់ IFC ក្នុងខែមិថុនា ឆ្នាំ២០១៨ ផងដែរ។[106]

នៅចុងឆ្នាំ២០២៣ ផលបត្រប្រាក់កម្ចីរបស់អេស៊ីលីដានៅកម្ពុជាមានចំនួនសរុប ៦,៦ ពាន់លានដុល្លារអាមេរិក ដោយមានប្រាក់កម្ចីប្រមាណ ៦៦០.០០០ គ្រប់គ្រងដោយបុគ្គលិក ១២.០៤៥ នាក់នៅទូទាំង ២៦៤ សាខា

[100] IFC ការពង្រីកលទ្ធភាពទទួលបានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាតាមរយៈភាពជាដៃគូយុទ្ធសាស្ត្រ សាច់រឿងអំពីផលប៉ះពាល់នៃមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០១៤ https://bit.ly/៣XRw5xH។

[101] គម្រោង IFC លេខ ៩៦៧៥ ២១៤៨៩ ២២៣២០ ២៤៥៩០ ២៥៥០១ ២៥៧១២ ២៦៥៩៦ ២៧៨៨២ ៣០៦០៧ ៣១៧២៨ ៣២២០៧ ៣២៦៤២ ៣៣១២៤ ៣៣៦៩៧ ៣៤៣៨៦ ៣៥២៤២ ៣៥៩៦៣ ៣៦៧៦៨ ៣៧៥៩៤ ៣៨៥៦០ ៣៨៩៤៣ ៣៩៩៨៩ ៤០៩៣១ ៤១១៧០ ៤២៤៨០ និង ៤៤៨៨២។

[102] គម្រោងទីប្រឹក្សាលេខ ៥០៣៨៣២ ៥៣៥៦៦៤ ៥៣៧៣៥០ ៥៥៤០០៦ ៦០៥០៥៩ និង ៦០៧២៣៦។

[103] FI–២៖ នៅពេលដែលផលបត្រដែលមានស្រាប់ ឬដែលបានស្នើ របស់ FI រួមមាន ឬត្រូវបានរំពឹងថានឹងមាន សកម្មភាពអាជីវកម្មដែលមានហានិភ័យ ឬផលប៉ះពាល់បរិស្ថាន ឬសង្គមតិចតួច ដែលអាចកើតឡើង មានចំនួនតិច ដែលជាទូទៅ មានទីតាំងជាក់លាក់ អាចកែតម្រូវវិញបានភាគច្រើន និងងាយស្រួលដោះស្រាយ តាមរយៈវិធានការកាត់បន្ថយ ឬរួមបញ្ចូលសកម្មភាពអាជីវកម្មមួយចំនួនតូច ដែលមានហានិភ័យ ឬផលប៉ះពាល់បរិស្ថាន ឬសង្គមអវិជ្ជមានខ្លាំងក្លា ដែលមានលក្ខណៈចម្រុះ មិនអាចកែតម្រូវវិញបាន ឬមិនធ្លាប់មានពីមុនមក”។ IFC គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៤០។

[104] ក្រុមហ៊ុន North Haven Thai គឺជាមូលនិធិភាគហ៊ុនឯកជនទូទៅមួយ ដែលផ្តោតលើក្រុមហ៊ុនពាក់កណ្តាលទីផ្សារ នៅក្នុងប្រទេសថៃ ជាចម្បង។ មូលនិធិនេះត្រូវបានគ្រប់គ្រងដោយ Morgan Stanley Private Equity Asia។

[105] ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ទំ. ៨

[106] IFC Global Emerging Markets Fund, LP និងយានស្របគ្នារបស់ពួកគេ IFC Global Emerging Markets (Japan) Fund, LP (រួមគ្នា ហៅថា “មូលនិធិ IFC GEM”) ត្រូវបានដាក់ឱ្យដំណើរការនៅឆ្នាំ២០១៥ មូលនិធិ IFC GEM គឺជាមូលនិធិដែលមានទឹកប្រាក់ចំនួន ៨០០ លានដុល្លារ ដែលវិនិយោគលើមូលនិធិភាគហ៊ុនឯកជន មូលនិធិបន្ទាប់បន្សំ និងការវិនិយោគរួមគ្នានៅក្នុងទីផ្សារដែលកំពុងរីកចម្រើន ជាមួយ IFC។ សូមមើល៖ https://bit.ly/4iIN656។

ដែលបង្កើតប្រាក់ចំណេញសុទ្ធចំនួន ១៤៨ លានដុល្លារអាមេរិកនៅឆ្នាំនោះ។[107] អេស៊ីលីដាផ្តល់ប្រាក់កម្ចីដល់អតិថិជន និងអាជីវកម្មខ្នាតតូចរហូតដល់ ៥០.០០០ ដុល្លារអាមេរិក។[108] នៅឆ្នាំ២០២៣ ផលបត្រប្រាក់កម្ចីរបស់អេស៊ីលីដា ៥,៧៧% មិនដំណើរការនោះទេ (NPL/PAR>៣០) ដោយសារប្រាក់កម្ចីទាំងនេះបានជំពាក់លើសពី ៣០ ថ្ងៃ។[109] អេស៊ីលីដា ទទួលបានវិញ្ញាបនបត្រអនុវត្តការការពារអតិថិជនរបស់ខ្លួនក្នុងឆ្នាំ២០១៧ ពីយុទ្ធនាការឆ្លាតវៃ វាជាធនាគារពាណិជ្ជដំបូងគេនៅក្នុងប្រទេស ដែលទទួលបានវិញ្ញាបនបត្រនេះ។ វាក៏ទទួលបានវិញ្ញាបនបត្រការពារអតិថិជន នៅឆ្នាំ២០២១ ពី MicroRate និង នៅឆ្នាំ២០២៤ ពី MFR ផងដែរ។[110]

### ២.១.២ អម្រឹត និង Advans

អម្រឹត គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងជាគ្រឹះស្ថានហិរញ្ញវត្ថុកំពូលមួយក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុកំពូលៗទាំង ១០ នៅកម្ពុជា។ វាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩១ ដោយអង្គការបារាំង GRET ជាគម្រោងឥណទានជនបទ ដែលដំណើរការតាមរយៈសមាគមភូមិ នៅខេត្តចំនួនបី (កណ្តាល កំពង់ស្ពឺ និងព្រៃវែង)។[111] នៅឆ្នាំ២០០៥ IFC ទទួលបានភាគហ៊ុនដោយប្រយោលនៅអម្រឹត តាមរយៈការវិនិយោគភាគហ៊ុននៅ Advans ដែលជាក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុអន្តរជាតិ និងជាក្រុមហ៊ុនហូលឌីង ដែលបានបង្កើតឡើងនៅឆ្នាំនោះ ដើម្បីផ្តល់ហិរញ្ញប្បទានដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅប្រទេសដែលមានប្រាក់ចំណូលទាប (គម្រោងលេខ ២១៨៥៦)។[112] Advans បានក្លាយជាម្ចាស់ភាគហ៊ុនធំរបស់អម្រឹត (ដោយមានភាគហ៊ុន ៥២,៧៨%) នៅឆ្នាំ២០១៤-២០១៥ ហើយបច្ចុប្បន្ន IFC កាន់កាប់ភាគហ៊ុន Advans ១៥,៩៩%។ នៅឆ្នាំ២០១៤ IFC ក៏បានទិញភាគហ៊ុនផ្ទាល់ ចំនួន ១៩,៩៩% នៅក្នុងអម្រឹត (គម្រោងលេខ ៣៤៧៤៨)[113] ជាផ្នែកមួយនៃផែនការរៀបចំរចនាសម្ព័ន្ធឡើងវិញ ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរអម្រឹតទៅជាធនាគារពាណិជ្ជ។[114] ស្រដៀងគ្នានេះដែរ ធនាគារសហគ្រិនហូឡង់ (FMO) បានបង្កើនភាគហ៊ុនរបស់ខ្លួនដល់ ១៩,៩% នៅឆ្នាំ២០១៥។ នៅខែមីនា ឆ្នាំ២០២៤ ធនាគារ SinoPac បានទិញភាគហ៊ុន ៨០% របស់អម្រឹត ក្នុងតម្លៃប្រហែល

---

107 អេស៊ីលីដា របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ. ៨ ១២ និង ២៨ https://bit.ly/41RnjRs។

108 អេស៊ីលីដា ប្រាក់កម្ចីផ្ទាល់ខ្លួន https://bit.ly/43KjWOR។

109 អេស៊ីលីដា របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ. ២ https://bit.ly/41RnjRs។ របាយការណ៍ត្រួតពិនិត្យដោយធនាគារជាតិនៃកម្ពុជា របាយការណ៍ថាផលធៀប NPL មានចំនួន ៦%។ ធនាគារជាតិនៃកម្ពុជា របាយការណ៍ត្រួតពិនិត្យ ឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ៣៨ https://bit.ly/4iskMnQ។

110 គេហទំព័ររបស់ធនាគារអេស៊ីលីដា https://bit.ly/3FtSqv7។
បញ្ជីស្ថាប័ននៅក្នុងគន្លង៖ https://bit.ly/4isl5Pw។

111 សូមមើលអម្រឹត អំពីអម្រឹត https://bit.ly/41Ruk40។

112 IFC, La Fayette La Fayette Investissements, https://bit.ly/4hB9v3o។

113 IFC សំណើសុំការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាលលើការសម្រេចចិត្តធ្វើការស៊ើបអង្កេតពាក្យបណ្តឹងរបស់ស៊ីអេអូ ពាក់ព័ន្ធនឹងអតិថិជន IFC ចំនួនបី៖
អេស៊ីលីដា (គម្រោងលេខ ៤២៤៨០ ៤៤៨៨២) អម្រឹត (គម្រោងលេខ ៣៤៧៤៨ ៤៤២៣១) ធនាគារហត្ថា (គម្រោងលេខ ៤៤៧៤២ ៤៥៥៣៥) និងអនុគម្រោងចំនួនបួន ពាក់ព័ន្ធនឹងធនាគារអេស៊ីលីដា ធនាគារហត្ថា អម្រឹត ប្រាសាក់ ស្ថាបនា និងអិលអូអិលស៊ី (គម្រោងលេខ ២៧៨២៧ ៣១៤៦៧ ២១៨៥៦ ៣៨៦០៩) ឆ្នាំ២០២៣ ទំ. ៩ https://bit.ly/3XU2nlr។

114 FMO អម្រឹត ភីអិលស៊ី៖ គម្រោងលេខ ៤៣៤៦០ https://bit.ly/426oLAI។

៥៤៣ លានដុល្លារអាមេរិក[115] ដោយ IFC និង FMO លក់ភាគហ៊ុនរបស់ពួកគេ ៥0% ហើយ Advans លក់ភាគហ៊ុនរបស់ខ្លួនទាំងអស់។[116] ផែនការចាកចេញពីអម្រឹត របស់ IFC ដើម្បីគាំទ្រដល់ភាពរីកចម្រើនបន្ថែមទៀតរបស់អម្រឹត ទៅជាធនាគារពាណិជ្ជ ត្រូវបានរៀបចំផែនការអស់រយៈពេលជាង ៣ ឆ្នាំ ដើម្បីធានាបាននូវការចាកចេញប្រកបដោយទំនួលខុសត្រូវ[117] ការផ្លាស់ប្តូរដោយរលូន និងការបន្តអនុវត្តការការពារ ដើម្បីពង្រឹងសមិទ្ធកម្មសង្គមរបស់ស្ថាប័ន។[118]

បន្ថែមពីលើភាគហ៊ុនរបស់ខ្លួន IFC បានផ្តល់ជូនអម្រឹតនូវប្រាក់កម្ចីចំនួនបី និងសេវាទីប្រឹក្សាចំនួនមួយ នៅចន្លោះឆ្នាំ២០១៤ និង ឆ្នាំ២០២០ ដែលប្រាក់កម្ចី និងសេវាទាំងអស់នេះត្រូវបានបញ្ឈប់មុនពេលបញ្ចប់របាយការណ៍នេះ។ [119] ប្រាក់កម្ចីចំនួនពីរ ក្នុងចំណោមប្រាក់កម្ចីទាំងនេះ (គម្រោងលេខ ៤១២៩៤ និង ៤៤២៣១) ដែលមានភាពសកម្មនៅចន្លោះឆ្នាំ២០១៨-២០២២ និង ឆ្នាំ២០២០-២០២៣ ដាច់ដោយឡែកពីគ្នា ទាក់ទងនឹងពាក្យបណ្តឹងនេះ និងត្រូវបានរួមបញ្ចូលនៅក្នុងការស៊ើបអង្កេតអំពីភាពអនុលោមនេះ។ ប្រាក់កម្ចីទាំងពីរគឺជាប្រាក់កម្ចី MSME រហូតដល់ ៣៥ លានដុល្លារអាមេរិក និងត្រូវបានចាត់ថ្នាក់ជា FI-២ និង FI-៣[120] ដាច់ដោយឡែកពីគ្នា។[121]

លើសពីនេះទៀត ការប្រឈមផ្នែកហិរញ្ញវត្ថុដោយប្រយោលរបស់ IFC នៅអម្រឹត តាមរយៈភាគហ៊ុនរបស់ខ្លួននៅក្នុងឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុជាសកល (MEF បានប្តូរឈ្មោះទៅជាមូលនិធិឆ្លាតវៃផ្នែកយេនឌ័រជាសកល ឬ GGSF) និងមូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA) មានពិពណ៌នានៅខាងក្រោម។ អម្រឹត បានកាន់កាប់ផលបត្រប្រាក់កម្ចីបង្វិលជាមួយ MEF ចាប់ពីខែកុម្ភៈ ឆ្នាំ២០១២ មក ដែលមានតម្លៃ ១៣,៨ លានដុល្លារអាមេរិក នៅពេលដែលពាក្យបណ្តឹងស៊ីអេអូនេះត្រូវបានដាក់ជូន នៅឆ្នាំ២០២២។ នៅពេលធ្វើរបាយការណ៍នេះ ប្រាក់កម្ចីទាំងអស់ពី MEF ទៅកាន់ អម្រឹត ត្រូវបានសងវិញរួចរាល់ហើយ។ MIFA បានផ្តល់ប្រាក់កម្ចីចំនួនប្រាំបី ដល់អម្រឹត ចាប់ពីខែមេសា ឆ្នាំ២០១៣ មក ដែលក្នុងនោះប្រាក់កម្ចីចំនួន ២ នៅមិនទាន់សង និងមានផលបត្រប្រាក់កម្ចីបើកចំហចំនួន ៥,៥ លានដុល្លារអាមេរិក នៅពេលមានពាក្យបណ្តឹងនេះ។[122]

---

115 Josh Sayle កាសែតភ្នំពេញប៉ុស្ដិ៍ MFI ក្នុងស្រុកលក់ភាគហ៊ុនជិតកន្លះពាន់លាន ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤ https://bit.ly/4iujpol។ សូមមើល ធនាគារ SinoPac៖ កម្រងព័ត៌មានសាជីវកម្ម https://bit.ly/3DPCUcf។

116 Advans, The Advans Group ប្រកាសបិទការលក់ភាគហ៊ុនរបស់ខ្លួននៅក្នុងអម្រឹត ទៅឲ្យធនាគារ SinoPac ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ https://bit.ly/48XNE5v។

117 អភិក្រមរបស់ IFC ចំពោះការចាកចេញប្រកបដោយទំនួលខុសត្រូវ នៅទីនេះ៖ https://bit.ly/4jEbqFF

118 សូមមើល https://bit.ly/442UaVG និង https://bit.ly/3ZPJEyy។

119 គម្រោងរបស់ IFC លេខ ៣៧៥០៥ ៤១២៩៤ ៤៤២៣១ និង ៦០១៦០២។

120 "FI–៣៖ នៅពេលដែលផលបត្រដែលមានស្រាប់ ឬផលបត្រដែលស្នើ របស់ FI រួមបញ្ចូលការប្រឈមផ្នែកហិរញ្ញវត្ថុចំពោះសកម្មភាពអាជីវកម្មដែលមានផលប៉ះពាល់បរិស្ថា និងសង្គមតិចតួច ឬគ្មានទាល់តែសោះ" គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៤០។

121 ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២) ទំ. ១៩។

122 ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២) ទំ. ២០។

នៅចុងឆ្នាំ២០២៣ ផលបត្រប្រាក់កម្ចីរបស់អម្រឹតមានតម្លៃ ១,៦ ពាន់លានដុល្លារអាមេរិក ដែលគ្រប់គ្រងដោយនិយោជិត ៤.៣៩១ នាក់ នៅទូទាំង ១៥០ សាខា និងបង្កើតបានប្រាក់ចំណេញសុទ្ធ ២៧,៦ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។[123] នៅខែមករា ឆ្នាំ២០២៥ វាបានរាយការណ៍ថាមានអតិថិជន ៦៩២.៣១៥ នាក់។[124] អម្រឹតផ្តល់ប្រាក់កម្ចីផ្ទាល់ខ្លួនរហូតដល់ ៣០.០០០ ដុល្លារអាមេរិក[125] និងកម្ចីកសិកម្ម និង MSME រហូតដល់ ១០០.០០០ ដុល្លារអាមេរិក។[126] ទាក់ទងនឹងប្រាក់កម្ចីមិនដំណើរការ អម្រឹតបានរាយការណ៍ពី PAR30 ចំនួន ៣ ភាគរយ នៅចុងបញ្ចប់ឆ្នាំ២០២៣។[127] ជាយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុលើកទឹកចិត្តអតិថិជនឱ្យទិញធានារ៉ាប់រងសងប្រាក់កម្ចីពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA ដើម្បីការពារគ្រួសារអតិថិជនពីបំណុល ក្នុងករណីមរណភាព ឬពិការភាព។[128] អម្រឹតបានទទួលវិញ្ញាបនបត្រការពារអតិថិជនពីយុទ្ធនាការឆ្លាតវៃជាលើកដំបូង នៅឆ្នាំ២០១៦ ដែលត្រូវបានបន្តសុពលភាពនាពេលថ្មីៗនេះ ក្នុងឆ្នាំ២០២៣ ដោយ CERISE+SPTF។[129]

### ២.១.៣ ធនាគារហត្ថា

នៅឆ្នាំ១៩៩៤ អង្គការមិនមែនរដ្ឋាភិបាល OCSD/OXFAM Quebec បានបើកដំណើរការ ហត្ថាកសិករលីមីតធីត ជាគម្រោងសន្តិសុខស្បៀង ដែលផ្តល់ប្រាក់កម្ចីខ្នាតមីក្រូដល់កសិករ។ នៅឆ្នាំ២០០៧ ហត្ថាកសិករលីមីតធីត បានទទួលអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា នៅឆ្នាំ២០១៦ វាបានក្លាយជាសាខា ដែលគ្រប់គ្រងទាំងស្រុងដោយ Krungsri ដែលជាធនាគារធំបំផុតលំដាប់ទីប្រាំនៅប្រទេសថៃ ហើយនៅឆ្នាំ២០២០ វាបានផ្លាស់ប្តូរទៅជាធនាគារ ហត្ថា ភីអិលស៊ី។[130]

ចាប់ពីឆ្នាំ២០១៥ មក IFC បានផ្តល់ប្រាក់កម្ចីចំនួនប្រាំបួនដល់ធនាគារហត្ថា ដើម្បីគាំទ្រការផ្លាស់ប្តូរពី MFI ទៅជាធនាគារពាណិជ្ជ ព្រមទាំងគម្រោងសេវាទីប្រឹក្សាចំនួនពីរ[131] ដើម្បីជួយស្ថាប័នក្នុងការពង្រឹងភាពធន់អភិវឌ្ឍហិរញ្ញវត្ថុយេនឌ័រ និងការផ្តល់ប្រាក់កម្ចីដល់ SME និងពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។[132] ពាក្យបណ្តឹងរបស់ស៊ីអេអូ ពីអ្នកខ្ចីទាំងឡាយ គ្របដណ្តប់លើប្រាក់កម្ចី IFC ចំនួនបួន ដល់ធនាគារហត្ថា (គម្រោងលេខ ៣៩១៦៧ ៤៤២១១ ៤៥៥៣៥ និង ៤៤៧៤២) ដែលបានផ្តល់ជូននៅចន្លោះឆ្នាំ២០១៧ និង ឆ្នាំ២០២១ ដែលក្នុងចំណោមប្រាក់កម្ចីទាំងនេះ មានតែប្រាក់កម្ចីចុងក្រោយមួយប៉ុណ្ណោះ

---

[123] អម្រឹត របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ. ៦ ២៨-២៩ ៣១ ៥១ https://bit.ly/4hDcM25។

[124] សូមមើល អម្រឹត រូបភាពគន្លឹះ ខែមករា ឆ្នាំ២០២៥ https://bit.ly/3Fprsor។

[125] អម្រឹត ប្រាក់កម្ចីផ្ទាល់ខ្លួន https://bit.ly/3Fn1NMT។

[126] អម្រឹត ប្រាក់កម្ចីកសិកម្ម https://bit.ly/3FEtZed; អម្រឹត ប្រាក់កម្ចីអាជីវកម្ម https://bit.ly/41QJZRS។

[127] អម្រឹត របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ. ១១, https://bit.ly/4hDcM25។

[128] អម្រឹត ធានារ៉ាប់រងសងប្រាក់កម្ចី https://bit.ly/3DBYst1។

[129] Advans អម្រឹតទទួលបានវិញ្ញាបនប័ត្រការពារអតិថិជនកម្រិតមាស ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ https://bit.ly/43JQVCU។ នៅខែមករា ឆ្នាំ២០២៣ វាទទួលបានវិញ្ញាបនបត្រកម្រិតមាសពី M-CRIL ប្រភព៖ https://bit.ly/41MOqNC។

[130] ធនាគារហត្ថា ព័ត៌មានអំពីធនាគារ https://bit.ly/3DuRWUV។

[131] គម្រោង IFC លេខ ៣៦២៤២ ៣៨២៣៩ ៣៩១៦៧ ៤១២២៣ ៤០៨៩៨ ៤៤២១១ ៤៤៧៤២ ៤៥៩៩៦ និង ៤៥៥៣៥ គម្រោងទីប្រឹក្សារបស់ IFC លេខ ៦០២៣៨៦ និង ៦០៦១១៩។

[132] ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ទំ. ៩។

ដែលនៅមានភាពសកម្ម។[133] ប្រាក់កម្ចីទាំងនេះគឺ ដើម្បីគាំទ្រដល់ផលបត្រ MSME របស់ធនាគារហត្ថា និងការទទួលបានហិរញ្ញវត្ថុក្នុងអំឡុងពេលមានជំងឺរាតត្បាត ដែលមានទឹកប្រាក់សរុបចំនួន ១៤០ លានដុល្លារអាមេរិក ដោយប្រាក់កម្ចីចំនួនពីរដំបូង ត្រូវបានចាត់ថ្នាក់ជា FI-៣ និង FI-២។

IFC ក៏មានការប្រឈមផ្នែកហិរញ្ញវត្ថុដោយប្រយោលនៅក្នុងធនាគារហត្ថា តាមរយៈភាគហ៊ុនរបស់ខ្លួននៅក្នុង MEF ដែលបានផ្តល់ពហុប្រាក់កម្ចីដល់ធនាគារហត្ថា នៅចន្លោះឆ្នាំ២០១០ ដល់ ឆ្នាំ២០២២ ផងដែរ។ ប្រាក់កម្ចីថ្មីបំផុត ត្រូវបានផ្តល់ជូនក្នុងខែឧសភា ឆ្នាំ២០១៩ និងបានសងវិញក្នុងខែឧសភា ឆ្នាំ២០២២ ដោយមានទឹកប្រាក់ចំនួន ៣,៥ លានដុល្លាអាមេរិកមិនទាន់សង នៅពេលមានពាក្យបណ្តឹង។[134]

នៅចុងឆ្នាំ២០២៣ ផលបត្រប្រាក់កម្ចីរបស់ធនាគារហត្ថា មានចំនួនសរុប ១,៥ ពាន់លានដុល្លារអាមេរិក ដោយមានអតិថិជនប្រហែល ១៦៧,០០០ នាក់[135] ដែលគ្រប់គ្រងដោយនិយោជិត ចំនួន ៤.៦៦៥ នាក់ នៅទូទាំង ១៧១ សាខា។[136] ធនាគារផ្តល់កម្ចីបរិភោគផ្ទាល់ខ្លួន និងកម្ចីកសិកម្ម រហូតដល់ ៥០.០០០ ដុល្លារអាមេរិក[137] និងកម្ចី MSME រហូតដល់ ៣០០.០០០ ដុល្លារអាមេរិក។[138] វាបានទទួលវិញ្ញាបនបត្រ SMART នៅឆ្នាំ ២០១៦[139] ប៉ុន្តែមិនបានបន្តសុពលភាព ក្រោយពេលផុតកំណត់នៅឆ្នាំ២០១៨ នោះទេ។[140] នៅក្នុងបរិបទប្រាក់កម្ចីរបស់ IFC នៅឆ្នាំ២០២១ (គម្រោងលេខ ៤៥៥៣៥ និង ៤៤៧៤២) ធនាគារ ហត្ថា បានទទួលការវាយតម្លៃផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ នៅចន្លោះខែធ្នូ ឆ្នាំ២០២១ និង ខែកក្កដា ឆ្នាំ២០២២ (គម្រោងសេវាទីប្រឹក្សារបស់ IFC លេខ ៦០៦១១៩) ដែលត្រូវបានរកឃើញថា មានការអនុវត្តជាវិជ្ជមាន ប៉ុន្តែក៏មានចន្លោះប្រហោងមួយចំនួននៅក្នុងគោលនយោបាយ និងនីតិវិធីរបស់ខ្លួន ក្នុងការបំពេញតាមស្តង់ដារហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវផងដែរ ដែលអ្នកវាយតម្លៃបានផ្តល់អនុសាសន៍ដែលមានរយៈពេលកំណត់។

### ២.១.៤ MEF

នៅឆ្នាំ២០០៩ IFC និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) បានដាក់ឱ្យដំណើរការនូវឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ (MEF) ជាសកល ចំនួន ៥០០ លានដុល្លារអាមេរិក ដែលត្រូវបានរៀបចំឡើងដើម្បីផ្តល់ហិរញ្ញប្បទានរយៈពេលខ្លី និងមធ្យមដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលកំពុងប្រឈមមុខនឹងកង្វះខាតថវិកាក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុពិភពលោក នៅពេលដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនជួបការលំបាកក្នុងការធ្វើបុនហិរញ្ញប្បទានបំណុលរបស់ពួកគេ ដូច្នេះធ្វើឱ្យមានប្រាក់កម្ចី ជាមូលដ្ឋានដែលពីក្រោយភាពរឹងមាំនៃ

---

[133] ប្រាក់កម្ចីដំបូងចំនួនពីរ ត្រូវបានសងវិញនៅមិថុនា ឆ្នាំ២០២២ នៅខណៈពេលដែលប្រាក់កម្ចីទីបី ត្រូវបានសងវិញនៅខែកក្កដា ឆ្នាំ ២០២៤។

[134] ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២) ទំ ២០។

[135] ធនាគារហត្ថា របាយការណ៍ប្រចាំឆ្នាំ២០២៣ ២០២៤ ទំ. ២, https://bit.ly/43IwHcM។

[136] ធនាគារជាតិនៃកម្ពុជា របាយការណ៍ត្រួតពិនិត្យ ឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ២៥-២៦ https://bit.ly/4iskMnQ។

[137] ធនាគារហត្ថា កម្ចីបរិភោគ https://bit.ly/3FoCfPu; ធនាគារហត្ថា កម្ចីកសិកម្ម https://bit.ly/43JSdhe។

[138] ធនាគារហត្ថា កម្ចី SME https://bit.ly/4bSqEEr។

[139] យុទ្ធនាការឆ្លាតវៃ អង្គការដែលបានទទួលវិញ្ញាបនបត្រ https://bit.ly/3DrXvn6។

[140] ធនាគារ ហត្ថា មិនបានទទួលវិញ្ញាបនបត្រនៅក្រោមយុទ្ធនាការឆ្លាតវៃ ឬគន្លង SPTF+ Cerise នៅក្រោយឆ្នាំ២០១៨ នោះទេ ប៉ុន្តែបានអនុវត្តការវាយតម្លៃការការពារអតិថិជនដោយខ្លួនឯង និងបានចូលរួមជាមួយគន្លង SPTF+Cerise របស់ស្ថាប័ននានា ដែលបានប្តេជ្ញាចិត្តការពារអតិថិជន នៅខែសីហា ឆ្នាំ២០២៣៖ https://officecao.org/4g1B5aQ។

ផលបត្ររបស់ពួកគេ។[141] IFC មានភាពសកម្មភាពក្នុងការវិនិយោគនៅក្នុង MEF។ នៅឆ្នាំ២០០៩ IFC បានធ្វើការវិនិយោគភាគហ៊ុនចំនួន ១៥០ លានដុល្លារអាមេរិក នៅក្នុង MEF (គម្រោងលេខ ២៧៨២៧) ដោយទទួលបានភាគហ៊ុន ២២,២% នៅក្នុងមូលនិធិនេះ។[142] MEF ត្រូវបានអនុវត្តតាមរយៈអគ្គលេខាធិការដ្ឋាន ដែលដំណើរការដោយក្រុមហ៊ុនគ្រប់គ្រងមូលនិធិ Innpact និងគណៈកម្មាធិការវិនិយោគ ដែលរួមមានតំណាងឯករាជ្យនៃទីប្រឹក្សាចម្បងៗ។ ទីប្រឹក្សាផ្នែកវិនិយោគចំនួនបួន រួមមាន BlueOrchard Finance, ResponsAbility Social Investments AG, Cyrano Fund Management និង Symbiotics បានបង្ហាញសំណើផ្តល់មូលនិធិដល់គណៈកម្មាធិការវិនិយោគរបស់ MEF។ នៅឆ្នាំ២០១៩ Incofin បានចូលរួមជំនួស Cyrano។ BlueOrchard និង Symbiotics ឈប់ចូលរួមចាប់ពីឆ្នាំ២០២៤ មក ហើយនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ MEF បានប្តូរឈ្មោះទៅជាមូលនិធិឆ្លាតវៃផ្នែកយេនឌ័រជាសកល (GGSF)។[143] នៅចន្លោះឆ្នាំ២០១០ និង ២០២២ MEF បានផ្តល់ពហុប្រាក់កម្ចីដល់គ្រឹះស្ថានហិរញ្ញវត្ថុចំនួនបួន ដែលត្រូវបានគ្របដណ្តប់នៅក្នុងការស៊ើបអង្កេតនេះ រួមមាន អម្រឹត ធនាគារហត្ថា អិលអូអិលស៊ី និងប្រាសាក់ ដែលប្រាក់កម្ចីទាំងអស់នេះត្រូវបានទូទាត់សងតាំងពីពេលនោះ។[144] ការវិនិយោគរបស់ MEF នៅក្នុងអម្រឹត និង អិលអូអិលស៊ី ត្រូវបានគ្រប់គ្រងដោយ Cyrano និងក្រោយមកដោយ Incofin នៅខណៈពេលដែលការវិនិយោគនៅធនាគារហត្ថា និង ប្រាសាក់ ត្រូវបានគ្រប់គ្រងដោយ BlueOrchard និងក្រោយមកដោយ ResponsAbility។

នៅខែមករា ឆ្នាំ២០២៤ MEF ត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ ទៅក្នុង Global Gender-Smart Fund S.A. ដោយមានបេសកកម្មគាំទ្រការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយភាពវៃឆ្លាត និងមានទំនួលខុសត្រូវផ្នែកយេនឌ័រ ដល់ស្ត្រីដែលបានទទួលសេវាមិនគ្រប់គ្រាន់ និងអាជីវកម្មដែលគ្រប់គ្រងដោយស្ត្រី ឬដឹកនាំស្ត្រី នៅក្នុងទីផ្សារកំពុងអភិវឌ្ឍន៍។[145]

### *២.១.៤.១ អតិថិជនបន្ត អិលអូអិលស៊ី*

សេវាសង្គ្រោះកាតូលិកសប្បុរសធម៌ បានបង្កើតអិលអូអិលស៊ី នៅឆ្នាំ១៩៩៤ ជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍សហគ្រាសធុនតូចរបស់ខ្លួននៅកម្ពុជា។[146] នៅ ឆ្នាំ២០០៣ អិលអូអិលស៊ីបានទទួលអាជ្ញាប័ណ្ណ MFI របស់

---

141 IFC របាយការណ៍ប្រចាំឆ្នាំ២០០៩ ឆ្នាំ២០០៩ ទំ. ៣៦ https://bit.ly/3FEa6E8។ IFC តម្រូវការក្នុងការបង្កើនល្បឿន៖ ការជួយឲ្យឧស្សាហកម្មមីក្រូហិរញ្ញវត្ថុនៅតែមានស្ថិតស្ថេរ ក្នុងពេលមានវិបត្តិ ខែមីនា ឆ្នាំ២០១៥ ទំ. ១-២ https://bit.ly/43JSL6M។

142 IFC របាយការណ៍ប្រចាំឆ្នាំ២០០៩ ឆ្នាំ២០០៩ ទំ. ៣៦ https://bit.ly/3FEa6E8។ IFC ក៏មានគម្រោងបីបន្ថែមទៀត ដើម្បីគាំទ្រ MEF រួមមាន គម្រោងលេខ ២៦៣២៧ ២៩២០៦ និង ២៨៨៧៩។ MEF ដំបូងឡើយ ត្រូវបានគេហៅថា ឥណទានជម្រុះបញ្ជីមីក្រូហិរញ្ញវត្ថុ នៅពេលដែលមានការអនុម័តជាលើកដំបូងដោយក្រុមប្រឹក្សាភិបាលរបស់ IFC ក្នុងខែមករា ឆ្នាំ២០០៩។ នៅពេលដែលវាបានចាប់ផ្តើមបញ្ចេញប្រាក់ នៅខែឧសភានៃឆ្នាំដដែលនោះ ឈ្មោះរបស់វាបានប្តូរទៅជា ឥណទានពង្រឹងមីក្រូហិរញ្ញវត្ថុ (MEF)។ Microrate, Role Reversal Revisited៖ តើស្ថាប័នអភិវឌ្ឍន៍សាធារណៈនៅតែប្រមូលផ្តុំការវិនិយោគឯកជននៅក្នុងមីក្រូហិរញ្ញវត្ថុដែរឬទេ? ឆ្នាំ២០១១ ទំ. ៦ https://bit.ly/4hrQuAx។

143 MEF របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ. ១-២ https://bit.ly/4ctdVbX។

144 ប្រាក់កម្ចីចុងក្រោយ ដែល MEF មិនទាន់សងស្ថាប័នទាំងនេះ ត្រូវបានសងរួចរាល់នៅកាលបរិច្ឆេទដូចតទៅ៖ ធនាគារ ហត្ថា នៅខែឧសភា ឆ្នាំ ២០២២, អម្រឹតនៅខែមិថុនា ឆ្នាំ២០២៤, ប្រាសាក់នៅខែកក្កដា ឆ្នាំ២០២៤ និងអិលអូអិលស៊ីនៅខែតុលា ឆ្នាំ ២០២៤។

145 Innpact សេចក្តីប្រកាសព័ត៌មានអំពីមូលនិធិឆ្លាតវៃផ្នែកយេនឌ័រជាសកល (GGSF) ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ https://bit.ly/4iQnnYv។

146 អិលអូអិលស៊ី ព្រឹត្តិការណ៍សំខាន់ៗ https://bit.ly/422IQYK។

ខ្លួនពីធនាគារជាតិនៃកម្ពុជា[147] និង LOLC Asia Private Limited ពីប្រទេសសិង្ហបុរី ដែលបច្ចុប្បន្នកាន់កាប់ ៩៧% នៃគ្រឹះស្ថានហិរញ្ញវត្ថុនេះ ដោយ ៣% ទៀតជាកម្មសិទ្ធិរបស់បុគ្គលិកអិលអូអិលស៊ី។[148]

កន្លងមក IFC បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដោយផ្ទាល់ដល់អិលអូអិលស៊ី សម្រាប់ផ្តល់ប្រាក់កម្ចីដល់អ្នកខ្ចី MSME នៅក្នុងវិស័យកសិកម្ម។[149] ទោះបីជាយ៉ាងណាក៏ដោយ សំណុំរឿងនេះគ្របដណ្តប់តែការប្រឈមផ្នែកហិរញ្ញវត្ថុដោយប្រយោលរបស់ IFC ជាមួយអិលអូអិលស៊ី តាមរយៈភាគហ៊ុនរបស់ខ្លួននៅក្នុង MEF និង MIFA តែប៉ុណ្ណោះ (សូមមើលផ្នែក ២.១.៥ ខាងក្រោម)។ MEF បានផ្តល់ប្រាក់កម្ចីចំនួន ១៩ ដល់អិលអូអិលស៊ី ចាប់ពីខែកុម្ភៈឆ្នាំ២០១២ ដែលមានតម្លៃ ១៤,២ លានដុល្លារអាមេរិក នៅពេលដែលមានពាក្យបណ្តឹងនេះ ដែលប្រាក់កម្ចីទាំងអស់ត្រូវបានសងវិញ និងបានបញ្ចប់ត្រឹមខែតុលា ឆ្នាំ២០២៤។ MIFA បានផ្តល់ប្រាក់កម្ចីចំនួនប្រាំមួយដល់អិលអូអិលស៊ី នៅចន្លោះឆ្នាំ ២០១៤ និង ខែឧសភា ឆ្នាំ២០២២ ដែលមានផលបត្រប្រាក់កម្ចីបើកចំហចំនួន ៩ លានដុល្លារអាមេរិក នៅពេលមានពាក្យបណ្តឹង ហើយប្រាក់កម្ចីចំនួនបីនៅតែមានភាពសកម្ម[150] (សូមមើលផ្នែក ២.១.៥ ខាងក្រោម)។

នៅឆ្នាំ២០២៣ ផលបត្រប្រាក់កម្ចីរបស់អិលអូអិលស៊ី មានតម្លៃសរុប ១,២ ពាន់លានដុល្លារអាមេរិក ដោយមានអតិថិជនប្រហែល ៣៣៥.០០០ នាក់ ដែលគ្រប់គ្រងដោយនិយោជិត ៣.៩៩០ នាក់ នៅទូទាំង ៨៣ សាខា និងមានប្រាក់ចំណេញសុទ្ធ ៦៥,៧ លានដុល្លារអាមេរិក។[151] អិលអូអិលស៊ីផ្តល់ប្រាក់កម្ចីបុគ្គលរហូតដល់ ១០.០០០ ដុល្លារអាមេរិក កម្ចីកសិកម្មតាមរដូវកាលរហូតដល់ ៣០.០០០ ដុល្លារអាមេរិក និងកម្ចី MSME រហូតដល់ ២០០.០០០ ដុល្លារអាមេរិក[152]។ នៅឆ្នាំ២០២៣ អិលអូអិលស៊ី មានអត្រា NPL (PAR> ៣០) ២,១%។[153] នៅឆ្នាំ២០១៥ វាបានក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដំបូងគេនៅកម្ពុជា ដែលទទួលបានវិញ្ញាបនបត្រពីយុទ្ធនាការឆ្លាតវៃ និងត្រូវបានបញ្ជាក់ឡើងវិញនៅឆ្នាំ២០១៨[154] និងនៅឆ្នាំ២០២២ នៅក្រោមគោលការណ៍ SPTF+Cerise។[155]

---

[147] អិលអូអិលស៊ី ព្រឹត្តិការណ៍សំខាន់ៗ https://bit.ly/422IQYK។ នៅចន្លោះឆ្នាំ២០០២ និង ឆ្នាំ២០១៥ វាត្រូវបានគេហៅថា ធនាគារភូមិ (TPC)។

[148] អិលអូអិលស៊ី របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ. ២៧ https://bit.ly/៣FG1cWH។

[149] នៅឆ្នាំ២០១៥ រហូតមកដល់ពេលនេះ IFC បានផ្តល់ប្រាក់កម្ចីលើកដំបូង និងតែមួយគត់របស់ខ្លួនដល់អិលអូអិលស៊ី ដែលមានតម្លៃ ១០ លានដុល្លារ (គម្រោងលេខ ៣៨៤២២) និងបានបញ្ចប់តាំងពីពេលនោះ។ នៅឆ្នាំ២០២៣ IFC បានអនុម័តសេវាទីប្រឹក្សាហិរញ្ញវត្ថុបៃតងនៅកម្ពុជា ដើម្បីគាំទ្រ NBC ក្នុងការអភិវឌ្ឍ និងជម្រុញហិរញ្ញវត្ថុបៃតងនៅក្នុងប្រទេស។ យោងតាមរបាយការណ៍ជាសាធារណៈ អិលអូអិលស៊ី គឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនទាំងបីដែលត្រូវបានជ្រើសរើសដើម្បីទទួលហិរញ្ញប្បទានបៃតង។ សូមមើល៖ ផតថលព័ត៌មាន និងទិន្នន័យអំពីគម្រោងរបស់ IFC ហិរញ្ញវត្ថុបៃតងនៅកម្ពុជា គម្រោងលេខ ៦០៦៧៦៣ https://bit.ly/3DF6npn និង Dialogue Earth សញ្ញាប័ណ្ណបៃតង ទង់ក្រហម៖ វិបត្តិមីក្រូហិរញ្ញវត្ថុនៅកម្ពុជាកាន់តែស៊ីជម្រៅ ចំពេលដែលមានការជម្រុញប្រកបដោយនិរន្តរភាព Cambodianess ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៤ https://bit.ly/4hwJ2E7។

[150] ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២) ទំ. ១១ និង ២០។

[151] អិលអូអិលស៊ី របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ. ៧ https://bit.ly/3FG1cWH។

[152] អិលអូអិលស៊ី កម្ចីបុគ្គល https://bit.ly/៣XQwr៧H កម្ចីតាមរដូវកាល https://bit.ly/4ir5tvD អិលអូអិលស៊ី កម្ចី SME https://bit.ly/៤irdvon; អិលអូអិលស៊ី របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ. ៣៦ https://bit.ly/3FG1cWH។

[153] ធនាគារជាតិនៃកម្ពុជា របាយការណ៍ត្រួតពិនិត្យ ឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ៦៥ https://bit.ly/4iskMnQ។

[154] អិលអូអិលស៊ី របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ. ១០៤, https://bit.ly/3FG1cWH។

[155] អិលអូអិលស៊ី ព្រឹត្តិការណ៍សំខាន់ៗ https://bit.ly/422IQYK.

### *២.១.៤.២ អតិថិជនបន្ត ប្រាសាក់*

សហភាពអឺរ៉ុប (EU) បានផ្តល់មូលនិធិដល់ការបើកដំណើរការរបស់ប្រាសាក់ នៅឆ្នាំ១៩៩៥ ជាគម្រោងអភិវឌ្ឍន៍មួយ ដើម្បីគាំទ្រដល់វិស័យកសិកម្ម។[156] នៅឆ្នាំ២០០៤ ប្រាសាក់បានវិវត្តទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដល់សហគមន៍ជនបទ និងសហគ្រាសធុនមីក្រូ។[157] នៅឆ្នាំ២០២១ ប្រាសាក់ត្រូវបានទិញដោយធនាគារ ខេប៊ី គូកមីន របស់ប្រទេសកូរ៉េ និងបានប្តូរទៅជាធនាគារពាណិជ្ជ ខេប៊ី ប្រាសាក់។[158] ចាប់ពីឆ្នាំ២០១២ មក កម្ចី IFC ចំនួនប្រាំមួយបានគាំទ្រដល់ការពង្រីកការផ្តល់ប្រាក់កម្ចីរបស់ប្រាសាក់ ជាពិសេសការផ្តល់កម្ចីដល់អ្នកខ្ចីខ្នាតមីក្រូ។ IFC បានបញ្ចប់រាល់កម្ចីទាំងនេះ នៅពេលដែលពាក្យបណ្តឹងរបស់ស៊ីអេអូត្រូវបានដាក់ជូន នៅខែកុម្ភៈ ឆ្នាំ២០២២[159] ដូច្នេះសំណុំរឿងនេះគ្របដណ្តប់តែការប្រឈមផ្នែកហិរញ្ញវត្ថុដោយប្រយោលរបស់ IFC នៅប្រាសាក់ តាមរយៈភាគហ៊ុននៅក្នុង MEF តែប៉ុណ្ណោះ។ នៅចន្លោះឆ្នាំ២០១០ និង ឆ្នាំ២០២២ MEF បានផ្តល់ពហុប្រាក់កម្ចីដល់ប្រាសាក់ ដែលប្រាក់កម្ចីលើកចុងក្រោយត្រូវបានផ្តល់ជូននៅខែកក្កដា ឆ្នាំ២០២១ និងត្រូវបានទូទាត់សងនៅខែកក្កដា ឆ្នាំ២០២៤ ដោយមានទឹកប្រាក់ចំនួន ៧,៨ លានដុល្លារអាមេរិក មិនទាន់បានសងនៅពេលមានពាក្យបណ្តឹង។[160]

ផលបត្រប្រាក់កម្ចីរបស់ធនាគារ ខេប៊ី ប្រាសាក់ នៅឆ្នាំ២០២៣ មានតម្លៃសរុប ៥,៧ ពាន់លានដុល្លារអាមេរិក ដោយមានអតិថិជនប្រហែល ៥៤៨.០០០ នាក់ ដែលត្រូវបានគ្រប់គ្រងដោយនិយោជិត ១០.២២៤ នាក់ នៅទូទាំង ១៩២ សាខា[161] និងមានប្រាក់ចំណេញសុទ្ធចំនួន ៨៧ លានដុល្លារអាមេរិក។[162] ធនាគារនេះផ្តល់ប្រាក់កម្ចីអ្នកធ្វើការរហូតដល់ ៥.០០០ ដុល្លារអាមេរិក[163] និងកម្ចីអាជីវកម្មធុនមីក្រូ និងតូច រហូតដល់ ១០.០០០ ដុល្លារអាមេរិក។[164] នៅឆ្នាំ២០២៣ ប្រាសាក់មានអត្រា NPL (PAR>៣០) ចំនួន ៣,៧៥%។[165] ធនាគារនេះបានទទួលលិខិតបញ្ជាក់ពីយុទ្ធនាការឆ្លាតវៃ នៅឆ្នាំ២០១៥ ប៉ុន្តែបានបាត់បង់ការបញ្ជាក់នេះចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៨ មក។[166]

---

156 ធនាគារ ខេប៊ី ប្រាសាក់ របាយការណ៍ប្រចាំឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ១៣ https://bit.ly/4265gbC។

157 ធនាគារ ខេប៊ី ប្រាសាក់ របាយការណ៍ប្រចាំឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ១៣ https://bit.ly/4265gbC។

158 ធនាគារ ខេប៊ី ប្រាសាក់ របាយការណ៍ប្រចាំឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ១៣ https://bit.ly/4265gbC។

159 គម្រោង IFC លេខ ៣២១៤១ ៣៣២០៦ ៣៤៩៩៣ ៣៧១៨០ ៣៦២៨០ និង ៣៨២៣៥។ ឧទាហរណ៍ សូមមើល IFC ប្រាក់កម្ចី Snr របស់ប្រាសាក់ https://bit.ly/4lbNiuT។

160 ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២) ទំ. ១១ និង ២០។

161 ធនាគារ ខេប៊ី ប្រាសាក់ របាយការណ៍ប្រចាំឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ៤ https://bit.ly/4265gbC។

162 ធនាគារ ខេប៊ី ប្រាសាក់ របាយការណ៍ប្រចាំឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ១១ https://bit.ly/4265gbC។

163 ធនាគារ ខេប៊ី ប្រាសាក់ ប្រាក់កម្ចីអ្នកធ្វើការ https://bit.ly/43JXPrO។

164 ធនាគារ ខេប៊ី ប្រាសាក់ ប្រាក់កម្ចីអាជីវកម្មខ្នាតមីក្រូ https://bit.ly/4iJK6We។

165 ធនាគារ ខេប៊ី ប្រាសាក់ របាយការណ៍ប្រចាំឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ១១ https://bit.ly/4265gbC។ យោងតាមធនាគារជាតិនៃកម្ពុជា អត្រា NPL មានចំនួន ៤,១% នៅឆ្នាំ២០២៣។ ធនាគារជាតិនៃកម្ពុជា របាយការណ៍ត្រួតពិនិត្យឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ៣៨ https://bit.ly/4iskMnQ។

166 យោងតាមទីភ្នាក់ងារវាយតម្លៃ វិញ្ញាបនបត្រនៃយុទ្ធនាការឆ្លាតវៃ "បានប្រែជាពណ៌ប្រផេះ នៅខែវិច្ឆិកា ឆ្នាំ២០០៨"។ ទីភ្នាក់ងារវាយតម្លៃជាសកល MFR, វិញ្ញាបនបត្រការពារអតិថិជន https://bit.ly/3R5XLv0។

### ២.១.៥ MIFA

នៅឆ្នាំ២០១២ IFC បានអនុម័តទឹកប្រាក់ចំនួន ២០ លានដុល្លារអាមេរិក ដើម្បីជួយចាប់ផ្តើមដំណើរការមូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី (MIFA) ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់អ្នកខ្ចីខ្នាតមីក្រូ និងគ្រួសារដែលមានប្រាក់ចំណូលទាបនៅទូទាំងអាស៊ី (គម្រោងលេខ ៣១៤៦៧)។[167] MIFA មានបំណង "(i) ផ្តល់ហិរញ្ញប្បទានបំណុលនៅលើទីផ្សារ [... ] ដល់អង្គភាពហិរញ្ញវត្ថុដែលផ្តល់សេវាដល់អាជីវកម្មខ្នាតមីក្រូ ដោយផ្តោតលើការឆ្ពោះទៅកាន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខ្នាតតូច និងអភិវឌ្ឍន៍តិចតួច ii) ជួយបង្កើតមីក្រូហិរញ្ញវត្ថុជាក្រុមទ្រព្យសកម្មមួយ ជាមួយវិនិយោគិនចម្បងៗ និងបង្កើនមូលនិធិម្ចាស់ជំនួយរួមជាមួយដើមទុនឯកជន និង iii) គាំទ្រការកសាងសមត្ថភាពក្នុងចំណោមអង្គភាពហិរញ្ញវត្ថុ ដែលផ្តល់សេវាដល់អង្គភាពខ្នាតមីក្រូ"។[168] MIFA ត្រូវបានគ្រប់គ្រងដោយ BlueOrchard[169] និងបានផ្តល់ពហុប្រាក់កម្ចីដល់ MFIs ចំនួនបី ដែលត្រូវបានគ្របដណ្តប់នៅក្នុងការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូនេះ។ ប្រាក់កម្ចីទាំងនេះ រួមមាន ប្រាក់កម្ចីចំនួនប្រាំបីដល់អម្រឹត ដែលក្នុងនោះមិនមានប្រាក់កម្ចីណាមួយដែលមិនទាន់សងនោះទេ ប្រាក់កម្ចីចំនួនមួយដល់ស្ថាបនា ដែលនៅមិនទាន់សង និងប្រាក់កម្ចីចំនួនប្រាំមួយដល់អិលអូអិលស៊ី (សូមមើលផ្នែក ២.១.៤.១ ខាងលើ) ដែលប្រាក់កម្ចីចំនួនបីនៅមានភាពសកម្ម។

#### *២.១.៥.១ អតិថិជនបន្ត ស្ថាបនា*

នៅឆ្នាំ១៩៩៥ អគារសហគមន៍កម្ពុជា (បច្ចុប្បន្ន ស្ថាបនា) ត្រូវបានបង្កើតឡើងជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលក្រោយមកបានវិវត្តទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ នៅឆ្នាំ២០១២ ស្ថាបនាត្រូវបានទិញដោយធនាគារ Maruhan Japan Bank Plc ហើយបច្ចុប្បន្នជាធនាគារពាណិជ្ជធំជាងគេលំដាប់ទីប្រាំនៅកម្ពុជា។[170] ស្ថាបនា គឺជាអតិថិជនបន្តរបស់ IFC តាមរយៈ MIFA ដែលបានផ្តល់ប្រាក់កម្ចីចំនួនមួយនៅខែកក្កដា ឆ្នាំ២០១៨ ដែលមានទឹកប្រាក់ចំនួន ៣,២ លានដុល្លារអាមេរិក នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ជូនស៊ីអេអូ និងនៅមិនទាន់សង នៅពេលបោះពុម្ពផ្សាយរបាយការណ៍នេះ។[171]

នៅឆ្នាំ២០២៣ ផលបត្រប្រាក់កម្ចីរបស់ស្ថាបនាមានតម្លៃសរុប ២,២ ពាន់លានដុល្លារអាមេរិក ដោយមានអតិថិជនប្រហែល ៦០០.០០០ នាក់ ដែលត្រូវបានគ្រប់គ្រងដោយនិយោជិត ៤.៦០០ នាក់ នៅទូទាំង ១៧៥ សាខា និងមានប្រាក់ចំណេញសុទ្ធចំនួន ១២ លានដុល្លារអាមេរិក។[172] ស្ថាបនាផ្តល់ប្រាក់កម្ចីបុគ្គល និង MSME រហូតដល់ ២០០.០០០ ដុល្លារអាមេរិក។[173] នៅឆ្នាំ២០២៣ ស្ថាបនាមានអត្រា NPL (PAR>៣០) ចំនួន

---

[167] IFC មូលនិធិបំណុល MIFA https://bit.ly/3DJCC6P។

[168] IFC មូលនិធិបំណុល MIFA https://bit.ly/3DJCC6P។ IFC ក៏មានគម្រោងបីបន្ថែមទៀត ដើម្បីគាំទ្រ MIFA ផងដែរ រួមមានគម្រោងលេខ ៥៥៧៩៨៥ ៥៦៣៨៣២ និង ៥៦៦៦០៧។

[169] BlueOrchard គឺជាអ្នកគ្រប់គ្រងការវិនិយោគលើផលជះ ដែលមានបទពិសោធន៍ជាង ២០ ឆ្នាំនៅក្នុងមីក្រូហិរញ្ញវត្ថុពាណិជ្ជកម្ម។ សូមមើល https://bit.ly/3FEafYc និង https://bit.ly/3DBvkC9។

[170] ស្ថាបនា អំពីយើងខ្ញុំ https://bit.ly/41MVPwo។

[171] ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២) ទំ. ១១ និង ២០។

[172] ធនាគារស្ថាបនា របាយការណ៍ប្រចាំឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ៥ ៣០-៣១, https://bit.ly/3R6toED។

[173] ធនាគារស្ថាបនា កម្ចីអាជីវកម្ម https://bit.ly/3R9AOHg; ធនាគារស្ថាបនា កម្ចីផ្ទាល់ខ្លួន https://bit.ly/4iP0k0h។

៧,៨%។[174] ស្ថាបនាបានទទួលវិញ្ញាបនបត្រពីយុទ្ធនាការឆ្លាតវៃនៅខែឧសភា ឆ្នាំ២០១៦[175] និងវិញ្ញាបនបត្របន្ថែមនៅឆ្នាំ២០២១ នៅក្រោមគន្លងកិច្ចគាំពារសង្គម SPTF+Cerise។[176]

## ៣. ការស៊ើបអង្កេតអំពីភាពអនុលោម

ផ្នែកនេះសង្ខេបអំពីពាក្យបណ្ដឹងដែលដាក់ជូនស៊ីអេអូ និងដំណើរការ និងវិសាលភាពនៃការស៊ើបអង្កេតភាពអនុលោមជាបន្តបន្ទាប់របស់ស៊ីអេអូ លើការវិនិយោគរបស់ IFC នៅអេស៊ីលីដា, អម្រ៉ឹត, ធនាគារហត្ថា, Advans, North Haven Thai, MEF, MIFA និងអនុគម្រោងនៃមូលនិធិពីរចុងក្រោយនេះ នៅអិលអូអិលស៊ី ស្ថាបនា និងប្រាសាក់។ វាក៏សង្ខេបការឆ្លើយតបរបស់ IFC ចំពោះពាក្យបណ្ដឹង និងគោលនយោបាយ នីតិវិធី និងលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងសង្គម (E&S) របស់ IFC ដែលអនុវត្តចំពោះសំណុំរឿងនេះផងដែរ ដូច្នេះវាពាក់ព័ន្ធនឹងការវិភាគរបស់ស៊ីអេអូ។

### ៣.១ ពាក្យបណ្ដឹង

នៅខែកុម្ភៈ ឆ្នាំ២០២២ ស៊ីអេអូបានទទួលពាក្យបណ្ដឹងពីអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរគឺ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) និង អង្គការសមធម៌កម្ពុជា (EC) តាងនាមឲ្យក្រុមអ្នកខ្ចីប្រាក់មួយក្រុម ចំនួន ១៨ នាក់ ដែលបានខ្ចីប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុមួយ ឬច្រើន ក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុទាំងប្រាំមួយដែលបានលើកឡើងខាងលើ។ ពាក្យបណ្ដឹងបានលើកឡើងអំពីកង្វល់ទាក់ទងនឹងផលប៉ះពាល់សង្គមនៃការអនុវត្តការផ្ដល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារចំនួនប្រាំមួយដែលដំណើរការនៅក្នុងប្រទេស។[177]

ដោយខ្លាចការសងសឹក ពួកគេបានស្នើសុំឱ្យស៊ីអេអូ រក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់។[178] ព័ត៌មានបន្ថែមអំពីបញ្ហាបុគ្គល ដែលគ្រួសារដើមបណ្ដឹងនីមួយៗបានជួបប្រទះ ត្រូវបានផ្ដល់ជូនជាសម្ងាត់ នៅក្នុងឧបសម្ព័ន្ធ ដែលបានចែករំលែកជាមួយភាគីពាក់ព័ន្ធ។

ដើមបណ្ដឹងចោទប្រកាន់ថា ពួកគេ គ្រួសារពួកគេ និងសហគមន៍របស់ពួកគេ បានទទួលរងគ្រោះថ្នាក់ដោយសារការអនុវត្តការផ្ដល់កម្ចី និងការប្រមូលប្រាក់របស់ MFIs និងធនាគារពាណិជ្ជ ហើយពួកគេត្រូវបានដាក់សម្ពាធឱ្យលក់ទ្រព្យសម្បត្តិរបស់ពួកគេដើម្បីសងប្រាក់កម្ចី។ ពួកគេអះអាងថា អ្នកផ្ដល់ប្រាក់កម្ចីមិនបានផ្ដល់ព័ត៌មាន

---

[174] ធនាគារជាតិនៃកម្ពុជា របាយការណ៍ត្រួតពិនិត្យឆ្នាំ២០២៣ ឆ្នាំ២០២៤ ទំ. ៣៨ https://bit.ly/4iskMnQ។

[175] ហ្វេសប៊ុក អបអរសាទរ ធនាគារ ស្ថាបនា ភីអិលស៊ី ទទួលបានវិញ្ញាបនបត្រពីយុទ្ធនាការឆ្លាតវៃ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ https://bit.ly/3XQx8xP។

[176] សូមមើល Cerise+SPTF អ្នកដែលនៅលើគន្លង https://bit.ly/4isl5Pw និងមីក្រូសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ននៃ M-CRIL សារព័ត៌មាន https://bit.ly/3R8D7u9។

[177] BFIs ទាំងប្រាំមួយ នៅកម្ពុជា ដែលការអនុវត្តរបស់ពួកគេជាកម្មវត្ថុនៃពាក្យបណ្ដឹង រួមមាន អេស៊ីលីដា អម្រ៉ឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា។ អតិថិជនផ្ទាល់របស់ IFC ចំនួនប្រាំពីរ ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ រួមមាន អេស៊ីលីដា, អម្រ៉ឹត, ធនាគារហត្ថា, MEF, MIFA, ក្រុមហ៊ុន North Haven Thai និង Advans។

[178] កំណែពាក្យបណ្ដឹងដែលត្រូវបានកែសម្រួល ត្រូវបានភ្ជាប់មកជាមួយរបាយការណ៍វាយតម្លៃនេះនៅក្នុងឧបសម្ព័ន្ធទី៤ និងបានចុះផ្សាយនៅលើគេហទំព័រសំណុំរឿងរបស់ស៊ីអេអូ នៅទីនេះ៖ https://bit.ly/3B16eHG។

ដល់ពួកគេឲ្យបានគ្រប់គ្រាន់ ដើម្បីវាយតម្លៃអំពីផលវិបាកនៃការចុះកិច្ចព្រមព្រៀងប្រាក់កម្ចីនោះទេ រួមទាំងកង្វះខាតព័ត៌មានជាភាសាជនជាតិដើមភាគតិចផងដែរ។

ដើមបណ្តឹងផ្តល់ទឡ្ហីករណ៍ថា ការរួមបញ្ចូលគ្នានៃការជ្រៀតចូលទីផ្សារកម្រិតខ្ពស់ តិត្ថិភាពខ្ពស់ កង្វះខាតកិច្ចការពារអ្នកប្រើប្រាស់ និងការអនុវត្តច្បាប់ដែលមានស្រាប់របស់រដ្ឋាភិបាលមិនគ្រប់គ្រាន់ បានជំរុញឱ្យមានកលយុទ្ធដែលមានការឈ្លានពាន ការបោកប្រាស់ និងឃោឃៅ ដោយមន្ត្រីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ។ ពួកគេចោទប្រកាន់ថា វាគឺជាការអនុវត្តទូទៅសម្រាប់អ្នកផ្តល់ប្រាក់កម្ចីនៅកម្ពុជា រួមទាំងអ្វីដែលបានទាញអាគតដ្ឋាននៅក្នុងពាក្យបណ្តឹងនេះផងដែរ ដើម្បីពង្រីកអាជីវកម្មរបស់ពួកគេ តាមរយៈការផ្តល់ប្រាក់កម្ចីលើសចំនួនកំណត់ ដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម នៅពេលខ្លះ ម្តងហើយម្តងទៀត និងក្នុងចំនួនទឹកប្រាក់កាន់តែច្រើន ដោយមិនបានវាយតម្លៃយ៉ាងពេញលេញអំពីសមត្ថភាពរបស់អ្នកខ្ចីក្នុងការសងប្រាក់កម្ចីនោះទេ។ ដើមបណ្តឹងអះអាងថា នៅពេលដែលអ្នកខ្ចីខកខានមិនបានបង់ប្រាក់ សូម្បីតែពីរបីថ្ងៃ អ្នកផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ ជាញឹកញាប់ បានប្រើកលយុទ្ធក្នុងការប្រមូលប្រាក់ក្រៅប្រព័ន្ធតុលាការដោយបង្ខំ ដូចជា ការបៀតបៀនអ្នកខ្ចីនៅផ្ទះ ការគំរាមនាំពួកគេទៅជួបអាជ្ញាធរមូលដ្ឋាន ការដាក់សម្ពាធឲ្យពួកគេខ្ចីប្រាក់បន្ថែមដើម្បីអាចសងប្រាក់កម្ចីបាន លក់ដីធ្លីដែលពួកគេដាក់បញ្ចាំ និងស្នើឲ្យពួកគេបញ្ឈប់កូនពីសាលារៀនដើម្បីមកធ្វើការសងប្រាក់កម្ចី ជាជាងការបន្តប្រមូលប្រាក់តាមនីតិវិធីច្បាប់។

ដើមបណ្តឹងផ្តល់ទឡ្ហីករណ៍ថា IFC បានបរាជ័យម្តងហើយម្តងទៀត ទាំងក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវឲ្យបានគ្រប់គ្រាន់ លើការវិនិយោគរបស់ខ្លួននៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះ និងត្រួតពិនិត្យពួកគេ នៅពេលដែលពួកគេមានភាពសកម្ម ដូចដែលបានតម្រូវដោយគោលនយោបាយនិរន្តរភាពរបស់ IFC។ ជាពិសេស ពួកគេចោទប្រកាន់ថា IFC មិនបានត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់លើប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) របស់អតិថិជនដែលជាអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដែលពួកគេពិពណ៌នាថា "មិនគ្រប់គ្រាន់យ៉ាងច្បាស់លាស់ក្នុងការដោះស្រាយការអនុវត្តប្រាក់កម្ចីដ៏ឃោឃៅ និងបោកប្រាស់ ការផ្តល់ប្រាក់កម្ចីគ្មានទំនួលខុសត្រូវ [...] និងការបង្ខិតបង្ខំ និងការគំរាមកំហែងពីមន្ត្រីឥណទាន"។ ពួកគេចោទប្រកាន់ថា កង្វះខាតការត្រួតពិនិត្យភាពត្រឹមត្រូវនៃគម្រោង និងការត្រួតពិនិត្យហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវនេះ ធ្វើឱ្យមានគ្រោះថ្នាក់ផ្នែកសង្គមដែលពាក់ព័ន្ធ ចំពោះដើមបណ្តឹង គ្រួសារពួកគេ និងសហគមន៍របស់ពួកគេ "ក្នុងការបន្តប្រព្រឹត្តិផ្ទុយពីស្តង់ដារសមិទ្ធកម្មរបស់ IFC យ៉ាងច្បាស់លាស់ ឥតឈប់ឈរ"។

អ្នកខ្ចីក៏ចោទប្រកាន់ផងដែរថា តម្លាភាពរបស់ IFC ទាក់ទងនឹងការវិនិយោគនៅក្នុងអន្តរការីហិរញ្ញវត្ថុ (FIs) នៅមានកម្រិត មិនគ្រប់គ្រាន់ និងផ្ទុយពីគោលនយោបាយសិទ្ធិទទួលបានព័ត៌មានរបស់ IFC។ ពួកគេផ្តល់ទឡ្ហីករណ៍ថា ការលាតត្រដាងរបស់ IFC អំពីគម្រោងអន្តរការីហិរញ្ញវត្ថុ (FI) ដូចជា គម្រោងដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះ ផ្តល់ព័ត៌មានតិចតួច និងអសង្គតិភាពនឹង ESMS ការវាយតម្លៃ E&S ដែលពាក់ព័ន្ធ និងផែនការសកម្មភាពបរិស្ថាន និងសង្គម (ESAP) ដែលបានព្រមព្រៀងគ្នារវាង IFC និងអតិថិជន ព្រមទាំងការត្រួតពិនិត្យគម្រោងរបស់ IFC ជាបន្តបន្ទាប់ផងដែរ។

ដោយសារការអនុវត្ត និងការខកខានមិនបានអនុវត្តទាំងនោះ ដើមបណ្ដឹងអះអាងថា ពួកគេបានរងគ្រោះដោយសារផលប៉ះពាល់អវិជ្ជមាន ដូចខាងក្រោម ដោយសារការរំលោភបំពានលើគោលនយោបាយ E&S របស់ IFC៖

- **ការបាត់បង់ដីធ្លី៖** ដើមបណ្ដឹងអះអាងថា អ្នកផ្ដល់កម្ចីមីក្រូហិរញ្ញវត្ថុតែងតែស្នើសុំឱ្យពួកគេដាក់ដីធ្លីរបស់ពួកគេ រួមទាំងដីសហគមន៍ជនជាតិដើមភាគតិច ជាវត្ថុបញ្ចាំ ដើម្បីទទួលបានការអនុម័តលើប្រាក់កម្ចី និងបន្ទាប់មក បង្ខំពួកគេឱ្យលក់ដីធ្លីមុនពេលកំណត់ ដើម្បីប្រមូលប្រាក់។ ពួកគេអះអាងថា អ្នកផ្ដល់ប្រាក់កម្ចីចាប់អារម្មណ៍លើការធានាកម្មសិទ្ធិដីធ្លីច្រើនជាងលទ្ធភាពរបស់អ្នកខ្ចីក្នុងការសងប្រាក់កម្ចី។ ពួកគេអះអាងថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនត្រឹមតែរក្សាទុកប័ណ្ណកម្មសិទ្ធដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែ ជាញឹកញាប់ ពួកគេថែមទាំងតម្រូវឱ្យអ្នកខ្ចីតម្កល់ប័ណ្ណកម្មសិទ្ធិជាច្រើន លើសពីតម្លៃប្រាក់កម្ចីថែមទៀត ដើម្បីទប់ស្កាត់ពួកគេមិនឲ្យប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីដើម្បីធានាប្រាក់កម្ចីពីគ្រឹះស្ថានដទៃទៀត។ យោងតាមដើមបណ្ដឹង អ្នកផ្ដល់ប្រាក់កម្ចីបានបង្ខំពួកគេឱ្យលក់ដីធ្លីនៅក្រៅនីតិវិធីច្បាប់ ដើម្បីប្រមូលវត្ថុបញ្ចាំ និងពុំមានផ្ដល់ព័ត៌មានគ្រប់គ្រាន់ជាមុននោះទេ។ យោងតាមដើមបណ្ដឹង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាញយកផលប្រយោជន៍ពីភាពគ្មានចំណេះដឹងរបស់អ្នកខ្ចីអំពីដំណើរការតាមផ្លូវច្បាប់ និងសិទ្ធិរបស់ពួកគេក្នុងការបញ្ជាក់ថា ការសងយឺតនឹងនាំមកនូវផលវិបាកបន្ថែមទៀត និងគំរាមកំហែងថានឹងត្រូវដោះស្រាយជាមួយអាជ្ញាធរមូលដ្ឋាន។
- **ផលប៉ះពាល់លើមុខរបរចិញ្ចឹមជីវិត៖** ដើមបណ្ដឹងបញ្ជាក់ថា ពួកគេមិនត្រឹមតែត្រូវលក់ដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទ្រព្យសកម្ម និងបរិក្ខារប្រើប្រាស់សម្រាប់បង្កើតមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ និងប្រភពប្រាក់ចំណូលដទៃទៀត ដើម្បីសងបំណុលដល់អ្នកផ្ដល់ប្រាក់កម្ចី។ ជាលទ្ធផល ប្រភពប្រាក់ចំណូលរបស់ពួកគេបានថយចុះ ហើយពួកគេមានការលំបាកយ៉ាងខ្លាំងក្នុងការបំពេញតម្រូវការមូលដ្ឋាន ដូចជា អាហារ និងទីជម្រក ដែលមានផលប៉ះពាល់លើអាហារូបត្ថម្ភ និងសុខភាព ដើម្បីឆ្លើយតបនឹងការទូទាត់ប្រាក់កម្ចី។
- **ផលប៉ះពាល់លើការអប់រំ សុខភាព និងគ្រួសារ៖** ដើមបណ្ដឹង រួមទាំងគ្រួសារ ដែលត្រូវបញ្ឈប់កូនពីសាលារៀន ដោយសារពួកគេពុំមានលទ្ធភាពបង់ថ្លៃសិក្សា និងត្រូវការឲ្យកូនរបស់ពួកគេទៅធ្វើការ និងរួមចំណែកដល់ការសងបំណុល។ គ្រួសារមួយចំនួនបានរាយការណ៍ថា បានធ្វើចំណាកស្រុក ឬចាំបាច់ត្រូវឲ្យកូនរបស់ពួកគេធ្វើចំណាកស្រុក ដើម្បីបង្កើតប្រាក់ចំណូលបន្ថែមដើម្បីសងប្រាក់កម្ចី។ លើសពីនេះទៀត ដើមបណ្ដឹងបានគូសបញ្ជាក់ពីរបាយការណ៍ជាសាធារណៈស្ដីពីការកើនឡើងនៃការធ្វើអត្តឃាតដែលទាក់ទងនឹងបំណុលនៅកម្ពុជា ដោយសារវិបត្តិបំណុលវ័ណ្ឌក។
- **ផលប៉ះពាល់លើជនជាតិដើមភាគតិច៖** ដើមបណ្ដឹងមួយចំនួនជាសមាជិកសហគមន៍ជនជាតិដើមភាគតិច។ ពួកគេអះអាងថា អ្នកផ្ដល់ប្រាក់កម្ចី ជាញឹកញាប់ បានទទួលយកដីជនជាតិដើមភាគតិចជាវត្ថុបញ្ចាំ ដែលក្រោយមក ត្រូវបានលក់ទៅឱ្យជនដែលមិនមែនជាសមាជិកសហគមន៍ ដែលរំលោភបំពានលើសិទ្ធិរបស់ជនជាតិដើមភាគតិច និងប៉ះពាល់ដល់អត្តសញ្ញាណវប្បធម៌ ប្រពៃណី និងជីវភាពរស់នៅ។ យោងតាមដើមបណ្ដឹង អ្នកផ្ដល់ប្រាក់កម្ចី ជាញឹកញាប់ លើកទឹកចិត្តឲ្យសមាជិកសហគមន៍ជនជាតិ

ដើមភាគតិចស្នើសុំប្លង់ទន់ដីធ្លីផ្ទាល់ខ្លួន[179] និងបោះបង់ចោលប័ណ្ណកម្មសិទ្ធិសហគមន៍របស់ពួកគេ ដើម្បីធានាប្រាក់កម្ចី។

- **ការគំរាមកំហែង និងការសងសឹក៖** ដើមបណ្តឹងបានសម្តែងភាពភ័យខ្លាចចំពោះការសងសឹកពីអ្នកផ្តល់កម្ចីខ្នាតមីក្រូរបស់ពួកគេ និងអាជ្ញាធរមូលដ្ឋាន ដោយបញ្ជាក់ថា មន្ត្រីឥណទាន ជាញឹកញាប់ ងាកទៅធ្វើការគំរាមកំហែង បំភិតបំភ័យ និងបៀតបៀន។ អង្គការមិនមែនរដ្ឋាភិបាល ដែលតំណាងឱ្យដើមបណ្តឹងក៏រាយការណ៍ថា កំពុងទទួលរងការគំរាមកំហែងពីវិធានការផ្លូវច្បាប់ និងការចោទប្រកាន់ពីបទញុះញង់ ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងនេះផងដែរ។

ដើមបណ្តឹងបញ្ជាក់ថា IFC បានដឹងពីព័ត៌មានដែលមានជាសាធារណៈ ទាក់ទងនឹងគ្រោះថ្នាក់ផ្នែកសង្គមយ៉ាងទូលំទូលាយ និងការការពារអ្នកប្រើប្រាស់មិនបានគ្រប់គ្រាន់ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ចាប់តាំងពីឆ្នាំ ២០១៦ មកម្ល៉េះ ប៉ុន្តែវាបានអនុម័តហិរញ្ញប្បទានបន្ថែម និងចាត់ថ្នាក់គម្រោងថ្មីៗថា មានហានិភ័យទាប។ ពួកគេអះអាងថា ទោះបីជាមានការកើនឡើងនូវគ្រោះថ្នាក់ផ្នែកសង្គមក៏ដោយ ក៏ពុំមានការចង្អុលបង្ហាញថា IFC បានវាយតម្លៃឡើងវិញលើការប្តេជ្ញាចិត្ត ឬសមត្ថភាពរបស់អតិថិជន FI របស់ខ្លួន ក្នុងការគ្រប់គ្រងគម្រោងប្រចាំថ្ងៃ ដែលមានហានិភ័យ និងផលប៉ះពាល់សង្គមខ្ពស់ មុនពេលអនុម័តការវិនិយោគបន្ថែមទៀតដែរ។

ពួកគេអះអាងបន្ថែមទៀតថា IFC មិនបានត្រួតពិនិត្យឱ្យបានត្រឹមត្រូវលើសកម្មភាពអាជីវកម្មរបស់អតិថិជនមីក្រូហិរញ្ញវត្ថុរបស់ខ្លួននោះទេ ដោយសារអតិថិជនទាំងនេះមិនត្រូវបានតម្រូវឱ្យត្រួតពិនិត្យសកម្មភាពផ្តល់កម្ចីរបស់ពួកគេ ដើម្បីពិនិត្យមើលហានិភ័យ E&S និងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកខ្ចី។ ពាក្យបណ្តឹងពិពណ៌នាអំពីចន្លោះប្រហោងនៅក្នុងការត្រួតពិនិត្យ E&S ថា មានសារៈសំខាន់ ពីព្រោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ជាញឹកញាប់ ជាប្រជាជនដែលងាយរងគ្រោះ ដូច្នេះហើយទាមទារឲ្យមានការការពារ និងការពិនិត្យតាមដានបន្ថែមទៀត ដើម្បីធានាថាគម្រោង IFC ពុំមានផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់ដល់សង្គម។

## ៣.២ ការវាយតម្លៃរបស់ស៊ីអេអូ

នៅខែមេសា ឆ្នាំ២០២២ ស៊ីអេអូយល់ថាពាក្យបណ្តឹងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបានចាប់ផ្តើមការវាយតម្លៃរបស់ខ្លួន។[180] ដោយសារតែមិនមានការឯកភាពគ្នាជាឯកច្ឆន្ទចំពោះដំណើរការដោះស្រាយវិវាទដែលគាំទ្រដោយស៊ីអេអូ និងដោយមានការយល់ព្រមពីដើមបណ្តឹង សំណុំរឿងនេះត្រូវបានបញ្ជូនទៅកាន់មុខងារភាពអនុលោមរបស់ស៊ីអេអូ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីធ្វើការវាយតម្លៃភាពអនុលោម។[181]

---

[179] ពាក្យ *ប្លង់ទន់ដីធ្លី* សំដៅលើ ការអនុវត្តរបស់អាជ្ញាធរមូលដ្ឋាននៅកម្ពុជា ដែលចេញលិខិតបញ្ជាក់ភាពជាកម្មសិទ្ធិដីធ្លី ដែលបន្ទាប់មក ត្រូវបានជួញដូរនៅក្រៅប្រព័ន្ធសុរិយោដីផ្លូវការ។

[180] ដំណើរការវាយតម្លៃរបស់ស៊ីអេអូផ្តល់នូវវេទិកាអព្យាក្រឹតមួយសម្រាប់ភាគីទាំងឡាយក្នុងការយល់ដឹងអំពីបញ្ហា ស្វែងយល់ពីជម្រើស និងសម្រេចចិត្តថាតើត្រូវបន្តដំណើរការដោះស្រាយវិវាទ ឬដំណើរការភាពអនុលោម។ (គោលនយោបាយរបស់ស៊ីអេអូ ឆ្នាំ ២០២១ កថាខណ្ឌ ៧៦)។

[181] របាយការណ៍វាយតម្លៃរបស់ស៊ីអេអូ ស្តីពីកង្វល់ទាក់ទងនឹងគម្រោង និងអនុគម្រោងរបស់ IFC នៅកម្ពុជា ពាក់ព័ន្ធនឹងស្ថាប័នហិរញ្ញវត្ថុចំនួន ៧ និងមូលនិធិចំនួន ៣ ខែវិច្ឆិកា ឆ្នាំ ២០២២ https://bit.ly/3Vu62LH។

## ៣.៣ ការឆ្លើយតបរបស់ IFC

ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ចំពោះពាក្យបណ្ដឹង នៅតែអះអាងថា នៅខណៈពេលដែលគ្រោះថ្នាក់ដែលត្រូវបានអះអាងនៅក្នុងពាក្យបណ្ដឹងមានភាពធ្ងន់ធ្ងរនោះ វាមិនមែនជាលទ្ធផលនៃបដិលោមភាពតាមគោលនយោបាយ E&S របស់ IFC នោះទេ។[182]

យោងតាមគណៈគ្រប់គ្រង IFC ផលប៉ះពាល់នៃការផ្ដល់កម្ចីមីក្រូហិរញ្ញវត្ថុលើអ្នកខ្ចីស្ថិតនៅក្រៅវិសាលភាពនៃគោលនយោបាយ E&S របស់ IFC សម្រាប់ហេតុផលដូចខាងក្រោម៖[183]

a) អ្នកប្រើប្រាស់ផលិតផលរបស់អតិថិជនមិនត្រូវបានយោងដល់ នៅក្នុងគោលនយោបាយនិរន្តរភាព ឬស្តង់ដារសមិទ្ធកម្មថា ជាភាគីពាក់ព័ន្ធមួយប្រភេទ ដែលវិធានការកាត់បន្ថយហានិភ័យ E&S គួរតែអនុវត្តចំពោះពួកគេនោះទេ។

b) ក្របខណ្ឌនិរន្តរភាពអនុវត្តចំពោះហានិភ័យ E&S ដែលអាចកើតឡើង និងផលប៉ះពាល់នៃ "សកម្មភាពអាជីវកម្ម" ដែលបានទទួលការគាំទ្រលើ "សហគមន៍ជុំវិញ និងកម្មករ" ប៉ុន្តែវាមិនអនុវត្តចំពោះផលប៉ះពាល់ E&S លើអតិថិជនបន្តនោះទេ (នៅក្នុងសំណុំរឿងនេះ ជាអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ)។

c) សកម្មភាពអាជីវកម្ម ដែល IFC គាំទ្រតាមរយៈអតិថិជន FI មិនមែនជាការផ្ដល់កម្ចីមីក្រូហិរញ្ញវត្ថុដោយផ្ទាល់នោះទេ ប៉ុន្តែជាសកម្មភាពដែលកើតចេញពីការប្រើប្រាស់ប្រាក់កម្ចីទាំងនោះដោយអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ (ឧទាហរណ៍ កសិកម្មខ្នាតតូច ឬសកម្មភាពពាណិជ្ជកម្ម ដូចជា ហាងទំនិញ ជាដើម)។

d) IFC ដោះស្រាយបញ្ហាទាក់ទងនឹងការអនុវត្តការផ្ដល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជនតាមរយៈក្របខណ្ឌហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកហិរញ្ញវត្ថុដ៏ទូលំទូលាយរបស់ខ្លួន មិនមែននៅក្នុងក្របខណ្ឌនិរន្តរភាពនោះទេ។

លើសពីនេះទៀត IFC ពន្យល់ថា ខ្លួនបានធ្វើការនៅកម្រិតស្ថាប័ន និងកម្រិតវិស័យ ដើម្បីពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅកម្ពុជា។

នៅកម្រិតស្ថាប័ន សកម្មភាពទាំងនេះ រួមមាន ការធ្វើការជាមួយអន្តរការីហិរញ្ញវត្ថុ ដែលអនុវត្តការផ្ដល់ប្រាក់

[182] សូមមើល ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ នៅក្នុងឧបសម្ព័ន្ធទី៥ នៃការវាយតម្លៃភាពអនុលោមរបស់ពាក្យបណ្ដឹង ពាក់ព័ន្ធនឹងការប្រឈមរបស់ IFC នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនប្រាំមួយនៅកម្ពុជា (អេស៊ីលីដា អម្រឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា) ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ https://bit.ly/424plcQ។

[183] របាយការណ៍វាយតម្លៃរបស់ស៊ីអេអូ ឆ្លើយតបនឹងចំណុចទាំងនេះ និងបានកំណត់ថា ការស៊ើបអង្កេតភាពអនុលោមត្រូវបានធានា។ IFC បានស្នើសុំការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍វាយតម្លៃរបស់ស៊ីអេអូ ដោយផ្អែកលើគោលជំហររបស់ខ្លួនថា ផលប៉ះពាល់លើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុមិនត្រូវបានគ្របដណ្ដប់ដោយគោលនយោបាយ E&S នោះទេ។ សំណើនេះត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ (CODE) របស់ក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ IFC បានដកសំណើរសុំការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល។ សូមមើល៖ ស៊ីអេអូ ការវាយតម្លៃភាពអនុលោមនៃពាក្យបណ្ដឹង ទាក់ទងនឹងការប្រឈមរបស់ IFC នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនប្រាំមួយនៅកម្ពុជា (អេស៊ីលីដា អម្រឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា) ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ ទំ. ២៤-២៨ https://bit.ly/424plcQ; គណៈគ្រប់គ្រង IFC សំណើសុំការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាលលើការសម្រេចចិត្តធ្វើការស៊ើបអង្កេតពាក្យបណ្ដឹងទាក់ទងនឹងការប្រឈមរបស់ IFC នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនប្រាំមួយនៅកម្ពុជា (អេស៊ីលីដា អម្រឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា) ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ https://bit.ly/3XU2nlr និងគេហទំព័រសំណុំរឿងរបស់ស៊ីអេអូ នៅទីនេះ៖ https://bit.ly/4mDvNFs។

កម្ចីប្រកបដោយទំនួលខុសត្រូវ វាយតម្លៃការអនុវត្តការធានា និងការប្រមូលប្រាក់របស់ពួកគេ ក្នុងអំឡុងពេលដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវ និងពិនិត្យតាមដានការវិវត្តនៃការអនុវត្តទាំងនេះ តាមរយៈការត្រួតពិនិត្យផលបត្រ។[184] លើសពីនេះទៀត IFC បានផ្តល់សេវាទីប្រឹក្សាដល់ FIs មួយចំនួន ដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងនេះ ដោយជួយពួកគេកែលម្អអភិបាលកិច្ចសាជីវកម្ម សមត្ថភាពគ្រប់គ្រងហានិភ័យ និងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ នៅខែមេសា ឆ្នាំ២០២១ IFC បានផ្សព្វផ្សាយអំពីគំនិតផ្តួចផ្តើមផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដើម្បីវាយតម្លៃការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជន FI កម្ពុជា និងជួយពួកគេធ្វើការកែលម្អតាមពេលវេលាកំណត់។[185]

នៅកម្រិតវិស័យ IFC បញ្ជាក់ថា ខ្លួនបានធ្វើការជាមួយធនាគារជាតិនៃកម្ពុជា (NBC) តាំងពីឆ្នាំ២០០៦ ដើម្បីបង្កើតក្រុមហ៊ុនក្រេឌីតប៊្យូរូកម្ពុជា (CBC) ដែលជាប្រភពនៃតម្លាភាព និងព័ត៌មានសម្រាប់ការរាយការណ៍អំពីឥណទាន ក៏ដូចជាឧបករណ៍ដើម្បីកាត់បន្ថយហានិភ័យនៃការជំពាក់បំណុលវ័ណ្ឌក របស់អ្នកខ្ចី។ លើសពីនេះទៀត IFC បានសហការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) CBC និងយុទ្ធនាការឆ្លាតវៃ ដើម្បីលើកកម្ពស់គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីដល់មីក្រូហិរញ្ញវត្ថុ និងបានអនុវត្តគម្រោងអសាធនភាព និងការដោះស្រាយបំណុល ដើម្បីពង្រឹងការអនុវត្តការប្រមូលបំណុលដោយយុត្តិធម៌ និងមានតម្លាភាពនៅប្រទេសកម្ពុជា ឲ្យកាន់តែទូលំទូលាយ។

ការឆ្លើយតបរបស់ IFC បញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការត្រួតពិនិត្យ និងដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង រួមជាមួយភាគីពាក់ព័ន្ធដទៃទៀត ដូចជា ធនាគារពិភពលោក NBC CMA សមាគមធនាគារនៅកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុពហុភាគីដទៃទៀត។ នៅខណៈពេលទទួចថា បញ្ហាទាំងនេះស្ថិតនៅក្រៅក្របខណ្ឌនិរន្តរភាពនោះ IFC ស្នើឱ្យធ្វើសកម្មភាពនៅកម្រិតគម្រោង វិស័យ និងនិយ័តកម្ម។ យោងតាម IFC សកម្មភាពទាំងនេះនឹងដោះស្រាយ "ភាពមិនប្រក្រតីតាមគម្រោងជាក់លាក់" ដែលត្រូវបានអះអាងដោយដើមបណ្តឹង ហានិភ័យនៃការសងសឹក អភិក្រមរបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និង

[184] ក្នុងន័យនេះ IFC បានចង្អុលបង្ហាញថា ខ្លួនបានរួមបញ្ចូលការព្រមព្រៀងមានការបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចីរបស់អតិថិជនដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះ ដើម្បីទាមទារឱ្យមានការអនុលោមតាមគោលការណ៍ការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដែលគ្របដណ្តប់លើការជៀសវាងការជំពាក់បំណុលវ័ណ្ឌក ការកំណត់តម្លៃប្រកបដោយតម្លាភាព ការអនុវត្តការប្រមូលប្រាក់យ៉ាងសមស្រប អាកប្បកិរិយារបស់បុគ្គលិកប្រកបដោយសីលធម៌ យន្តការដោះស្រាយបណ្តឹងសារទុក្ខ និង/ឬការការពារឯកជនភាពនៃទិន្នន័យ។ នៅក្នុងការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC បានចង្អុលបង្ហាញថា ខ្លួនបានរួមបញ្ចូលការព្រមព្រៀងមានការបញ្ជាក់ស្តីពីគោលការណ៍ការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ នៅក្នុងប្រាក់កម្ចីដោយផ្ទាល់របស់ខ្លួន ដល់ប្រាសាក់ ក្នុងឆ្នាំ ២០១៥ និង ឆ្នាំ២០១៦ (គម្រោងលេខ ៣៦២៨០ និង ៣៨២៣៥) អេស៊ីលីដា (គម្រោងលេខ ៣៨៣៨៦) HTB (គម្រោងលេខ ៤៤៧៤២ និង ៤៥៥៣៥) អម្រឹត (គម្រោងលេខ ៣៧៥០៥ និង ៤៤២៣១) ព្រមទាំងនៅក្នុងការវិនិយោគភាគហ៊ុននៅក្នុង MEF (គម្រោងលេខ ២៧៨២៧) និង MIFA (គម្រោងលេខ ៣១៤៦៧)។ សូមមើលការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC (ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២) ទំ. ៥ https://bit.ly/424plcQ។

[185] សេវាទីប្រឹក្សានៅកម្ពុជា RF លេខ ៦០៦១១៩។

បទប្បញ្ញត្តិស្តីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) នៅប្រទេសកម្ពុជា។[186]

ពុំមានអតិថិជន IFC ណាម្នាក់បានផ្តល់ជូនស៊ីអេអូនូវការឆ្លើយតបទៅនឹងពាក្យបណ្តឹង នៅដំណាក់កាលវាយតម្លៃភាពអនុលោមនោះទេ។[187]

## ៣.៤ ការវាយតម្លៃរបស់ស៊ីអេអូ

នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ ស៊ីអេអូបានបញ្ចប់ការវាយតម្លៃរបស់ខ្លួន ដោយបានសន្និដ្ឋានថា ការចោទប្រកាន់របស់អ្នកខ្ចីសមស្របនឹងការស៊ើបអង្កេតភាពអនុលោម។ [188] ការវាយតម្លៃនេះពិចារណាលើសម្ភារៈនានាដែលផ្តល់ជូនដោយដើមបណ្តឹង និង IFC រួមទាំងការឆ្លើយតបរបស់គណៈគ្រប់គ្រង ក៏ដូចជាព័ត៌មានដទៃទៀតដែរ។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ គណៈគ្រប់គ្រង IFC បានដាក់សំណើសុំឱ្យក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការសម្រេចចិត្តរបស់ស៊ីអេអូ ក្នុងការស៊ើបអង្កេត។[189] អនុវត្តតាមគោលនយោបាយរបស់ស៊ីអេអូ (កថាខណ្ឌ ១០៧-១១១) ក្រុមប្រឹក្សាភិបាលមានពេល ១០ ថ្ងៃធ្វើការ ក្នុងការពិចារណាលើសំណើរបស់ IFC។ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាលបានពន្យាពេលត្រួតពិនិត្យ រហូតដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។ ទោះបីជាយ៉ាងណាក៏ដោយ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ IFC បានដកសំណើសុំឲ្យក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការសម្រេចចិត្តរបស់ស៊ីអេអូ ក្នុងការស៊ើបអង្កេត ហេតុដូចនេះ ស៊ីអេអូបានបើកការស៊ើបអង្កេតនេះនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣។

## ៣.៥ វិសាលភាពនៃការស៊ើបអង្កេត

អាណត្តិភាពអនុលោមរបស់ស៊ីអេអូគឺ អនុវត្តការត្រួតពិនិត្យលើភាពអនុលោមរបស់ IFC តាមគោលនយោបាយ

---

[186] ព័ត៌មានបន្ថែមអំពីសកម្មភាពដែលបានស្នើដោយ IFC អាចស្វែងរកបាននៅទំព័រទី៦ នៃឧបសម្ព័ន្ធទី៥៖ ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ចំពោះការវាយតម្លៃភាពអនុលោមរបស់ស៊ីអេអូ មាននៅទីនេះ៖ https://officecao.org/45vKqmw។ ស៊ីអេអូបានសន្និដ្ឋានថា សកម្មភាពដែលបានស្នើទាំងនេះមិនបង្កើតបានជាសេចក្តីថ្លែងការណ៍អំពីសកម្មភាពដោះស្រាយនោះទេ ហើយក៏មិនបានដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនោះដែរ។ សូមមើល៖ ការវាយតម្លៃភាពអនុលោមរបស់ស៊ីអេអូ ទំ. ៣៤-៣៥។

[187] នៅពេលដែលសំណុំរឿងត្រូវបានបញ្ជូនទៅមុខងារភាពអនុលោម គោលនយោបាយរបស់ស៊ីអេអូផ្តល់ឱកាសជូនអតិថិជនរបស់ IFC ក្នុងការឆ្លើយតបជាលាយលក្ខណ៍អក្សរចំពោះបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ក្នុងរយៈពេល ១០ ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបញ្ជូន។ គោលនយោបាយរបស់ស៊ីអេអូ កថាខណ្ឌទី ៨៧។

[188] ស៊ីអេអូ ការវាយតម្លៃភាពអនុលោមនៃពាក្យបណ្តឹង ទាក់ទងនឹងការប្រឈមរបស់ IFC នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនប្រាំមួយនៅកម្ពុជា (អេស៊ីលីដា អម្រឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា) (គម្រោងរបស់ IFC លេខ ២១៨៥៦ ២៧៨២៧ ៣១៤៦៧ ៣៤៧៤៨ ៣៨៦០៩ ៣៩១៦៧ ៤១២៩៤ ៤២៤៨០ ៤៤២១១ ៤៤២៣១ ៤៤៧៤២ ៤៤៨៨២ ៤៥៥៣៥) ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ មាននៅ https://bit.ly/45muCUR។

[189] សំណើសុំការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាលរបស់គណៈគ្រប់គ្រង IFC (ត្រូវបានដកចេញវិញ) ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ មាននៅ https://bit.ly/3XU2nlr។ គណៈគ្រប់គ្រង IFC នៅតែរក្សាគោលជំហររបស់ខ្លួនថា ផលប៉ះពាល់អវិជ្ជមានលើអ្នកខ្ចី និងស្តង់ដារការពារអតិថិជននៅខាងក្រៅវិសាលភាពនៃគោលនយោបាយ E&S របស់ IFC ហេតុដូច្នេះ IFC បានចាត់ទុកថាវានៅក្រៅវិសាលភាពនៃអាណត្តិរបស់ស៊ីអេអូ។ IFC បានចង្អុលបង្ហាញថា ខ្លួនគាំទ្រអតិថិជន និងអតិថិជនបន្តរបស់ខ្លួនក្នុងការអភិវឌ្ឍប្រកបដោយវឌ្ឍនភាព និងពង្រឹងការអនុវត្តការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ តាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ និងការពិនិត្យតាមដាន និងសេវាកម្មទីប្រឹក្សា—កម្មវិធីសេដ្ឋកិច្ចសង្គម យុទ្ធសាស្ត្រ និងឧបករណ៍សម្រាប់ការគ្រប់គ្រងហានិភ័យនៅក្នុងវិស័យហិរញ្ញវត្ថុកាន់តែទូលំទូលាយ របស់ IFC—ដែលពួកគេជឿជាក់ថា ស្ថិតនៅក្រៅអាណត្តិរបស់ស៊ីអេអូ។ ស៊ីអេអូទទួលស្គាល់ និងពិចារណាលើអភិក្រមដាច់ដោយឡែករបស់ IFC ចំពោះការការពារអ្នកប្រើប្រាស់ នៅក្នុងការវិនិយោគមីក្រូហិរញ្ញវត្ថុ នៅពេលត្រួតពិនិត្យភាពអនុលោមរបស់ IFC ចំពោះគោលនយោបាយ E&S របស់ខ្លួន នៅក្នុងផ្នែកទី ៤ នៃរបាយការណ៍នេះ។

E&S របស់ខ្លួន វាយតម្លៃគ្រោះថ្នាក់ដែលពាក់ព័ន្ធ និងផ្តល់អនុសាសន៍អំពីវិធានការដោះស្រាយ តាមភាពសមស្រប។ (សូមមើលឧបសម្ព័ន្ធ គ សម្រាប់សេចក្តីសង្ខេបអំពីដំណើរការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូ)។ ស៊ីអេអូនឹងរួមបញ្ចូលតាមភាពសមស្រប នូវការវាយតម្លៃថាតើ IFC បានបង្វែរទិសដៅយ៉ាងសំខាន់ពីការណែនាំ និងនីតិវិធីដែលពាក់ព័ន្ធដែរឬទេ។[190] ការស៊ើបអង្កេតរបស់ស៊ីអេអូ ត្រូវបានធ្វើឡើងនៅចន្លោះខែសីហា ឆ្នាំ២០២៣ ដល់ ខែមិថុនា ឆ្នាំ២០២៥ ដោយមានសេចក្តីព្រាងរបាយការណ៍ផ្ញើទៅ IFC និងដើមបណ្តឹងដើម្បីត្រួតពិនិត្យអង្គហេតុ និងផ្តល់យោបល់នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥។ របាយការណ៍ចុងក្រោយរបស់ស៊ីអេអូ ពិចារណាលើមតិយោបល់របស់ភាគីទាំងឡាយ លើសេចក្តីព្រាងរបាយការណ៍នេះ។

របាយការណ៍នេះចងក្រងគំហើញនៃការស៊ើបអង្កេតភាពអនុលោម ទាក់ទងនឹងភាពអនុលោមរបស់ IFC ភាពបដិលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធចំពោះដើមបណ្តឹង។ វាក៏រួមបញ្ចូលសេចក្តីសន្និដ្ឋានរបស់ស៊ីអេអូ អំពីមូលហេតុឫសគល់នៃភាពបដិលោម ដែលបានកំណត់ និងអនុសាសន៍សម្រាប់ IFC ដើម្បីពិចារណា ក្នុងការបង្កើតផែនការសកម្មភាពគ្រប់គ្រង ដើម្បីដោះស្រាយភាពបដិលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ នៅកម្រិតគម្រោង និងអនុគម្រោង និងចាត់វិធានការរបស់ស្ថាប័ន ដើម្បីបង្ការភាពបដិលោមនាពេលអនាគត។[191]

លក្ខខណ្ឌយោង (TOR) ពីខែមិថុនា ឆ្នាំ២០២៣[192] កំណត់សំណួរដូចខាងក្រោម ដើម្បីឆ្លើយតបនៅក្នុងការស៊ើបអង្កេតនេះ៖

1. ថាតើ IFC បានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួនដែរឬទេ ដែលរួមមាន៖
   a. ថាតើ IFC បានធ្វើការត្រួតពិនិត្យ E&S មុនពេលវិនិយោគ (ESDD) លើការវិនិយោគរបស់ខ្លួន នៅអេស៊ីលីដា, អម្រឹត, ធនាគារហត្ថា, Advans, North Haven Thai, MEF និង MIFA ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ដែលសមស្របនឹងហានិភ័យ និង ផលប៉ះពាល់នៃការវិនិយោគទាំងនេះលើអ្នកខ្ចី MSME (អតិថិជនបន្តនៅក្នុងការវិនិយោគទាំងនេះ) ដែរឬទេ
   b. ថាតើ IFC បានអនុវត្តបញ្ញត្តិនៃកិច្ចសន្យា ដែលតម្រូវឱ្យអតិថិជនរបស់ខ្លួន ដែលមានឈ្មោះខាងលើ បំពេញតាមច្បាប់ជាតិកម្ពុជា បញ្ជីផាត់ចេញរបស់ IFC និងស្តង់ដារសមិទ្ធកម្មរបស់ IFC ដែលពាក់ព័ន្ធនឹងការវិនិយោគនីមួយៗ ទាក់ទងនឹងហានិភ័យ និងផលប៉ះពាល់លើអ្នកខ្ចី MSME ដែរឬទេ
   c. ថាតើ IFC បានត្រួតពិនិត្យការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា, អម្រឹត, ធនាគារហត្ថា, Advans, North Haven Thai, MEF និង MIFA ដើម្បីធានាថា ពួកគេអនុលោមតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាព ស្តង់ដារសមិទ្ធកម្ម បញ្ជីផាត់ចេញរបស់ IFC និងច្បាប់ជាតិដែលពាក់ព័ន្ធ ចំពោះការវិនិយោគនីមួយៗ ទាក់ទងនឹងហានិភ័យ និងផលប៉ះពាល់លើអ្នកខ្ចី MSME ដែរឬទេ។

---

[190] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ៧៦ ១១២។

[191] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី១១៣។

[192] លក្ខខណ្ឌយោងសម្រាប់ការស៊ើបអង្កេតភាពអនុលោម៖ ប្រទេសកម្ពុជា៖ អន្តរការីហិរញ្ញវត្ថុ-០៤ មាននៅទីនេះ៖ https://bit.ly/42547B5។

2. ថាតើគ្រោះថ្នាក់ និងគ្រោះថ្នាក់ដែលអាចកើតឡើង ដែលបានលើកឡើងដោយដើមបណ្តឹង មានទំនាក់ទំនងនឹងភាពបដិលោមរបស់ IFC ដែរឬទេ។[193]

ដោយពិចារណាលើគំហើញអំពីគ្រោះថ្នាក់ និងថាតើមានគ្រោះថ្នាក់ណាមួយទាក់ទងនឹងភាពបដិលោមរបស់ IFC ដែរឬទេនោះ ស៊ីអេអូនឹងវាយតម្លៃលើការត្រួតពិនិត្យឡើងវិញ និងការត្រួតពិនិត្យរបស់ IFC លើលក្ខខណ្ឌតម្រូវ E&S របស់ខ្លួន ស្របតាមគោលនយោបាយនិរន្តរភាព និងគោលនយោបាយសិទ្ធិទទួលបានព័ត៌មាន។ ស៊ីអេអូនឹងពិចារណាលើសមិទ្ធកម្ម E&S របស់គម្រោង និងអនុគម្រោងដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹង រួមទាំងទំនាក់ទំនងនឹងការអនុវត្តស្តង់ដារសមិទ្ធកម្មទី១ (ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម) ស្តង់ដារសមិទ្ធកម្មទី៧ (ជនជាតិដើមភាគតិច) និងបញ្ជីផាត់ចេញរបស់ IFC តាមការពាក់ព័ន្ធ។[194]

## ៣.៦ វិធីសាស្ត្រស៊ើបអង្កេត

ក្រុមស៊ើបអង្កេតរបស់ស៊ីអេអូ មានបុគ្គលិកស៊ីអេអូ អ្នកបកប្រែភាសាខ្មែរ និងភាសាជនជាតិដើមភាគតិច និងអ្នកពិគ្រោះយោបល់ជំនាញពីខាងក្រៅចំនួនបីនាក់៖

- អ្នកឯកទេសផ្នែកសង្គម និងបរិស្ថានដែលមានបទពិសោធន៍ច្រើនជាង ៣០ ឆ្នាំក្នុងការវាយតម្លៃ និងគ្រប់គ្រងបញ្ហា E&S នៅក្នុងអន្តរការីហិរញ្ញវត្ថុ មីក្រូហិរញ្ញវត្ថុ និង MSMEs នៅជាង ៧០ ប្រទេស។ អ្នកពិគ្រោះយោបល់ត្រួតពិនិត្យឡើងវិញលើគ្រប់ទិដ្ឋភាពនៃពាក្យបណ្តឹង។
- ទីប្រឹក្សាដែលមានបទពិសោធន៍យ៉ាងទូលំទូលាយនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា រួមទាំងការវិភាគទីផ្សារ និងការការពារអតិថិជន ដែលធ្លាប់បានត្រួតពិនិត្យ និងផ្តល់ការណែនាំដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និយ័តករ វិនិយោគិន និងអ្នកគ្រប់គ្រងការវិនិយោគ បណ្តាញ និងអង្គការគាំទ្រ លើឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ។
- អ្នកវិទ្យាសាស្ត្រសង្គមក្នុងស្រុកដែលមានចំណេះដឹង និងបទពិសោធន៍ក្នុងការវាយតម្លៃផលប៉ះពាល់សង្គមប្រកបដោយគុណភាពនៅកម្ពុជា ជាពិសេសទាក់ទងនឹងមីក្រូហិរញ្ញវត្ថុ ដែលស្ទាត់ជំនាញផ្នែកភាសាខ្មែរ និងមានជំនាញ និងបទពិសោធន៍នៅក្នុងបរិបទនៃប្រទេសកម្ពុជា។

របាយការណ៍ស៊ើបអង្កេតនេះត្រូវបានរៀបចំឡើងដោយផ្អែកលើ៖

- ការត្រួតពិនិត្យឡើងវិញលើឯកសារគម្រោង IFC និងសម្ភារៈដទៃទៀត ដែលផ្តល់ជូនដោយ IFC អតិថិជន និងអតិថិជនបន្ត
- ការត្រួតពិនិត្យឡើងវិញលើឯកសារដែលមានជាសាធារណៈអំពីទីផ្សារហិរញ្ញវត្ថុកម្ពុជា ជាពិសេសទាក់ទងនឹងមីក្រូហិរញ្ញវត្ថុ ផលប៉ះពាល់សង្គម និងការជំពាក់បំណុលវ័ណ្ឌក នៅកម្ពុជា អតិថិជន និងអតិថិជនបន្ត និងស្តង់ដារឧស្សាហកម្ម គំនិតផ្តួចផ្តើម និងព័ត៌មាន

[193] គោលនយោបាយរបស់ស៊ីអេអូ កថាខណ្ឌទី ១១២-១១៤។

[194] គោលនយោបាយរបស់ស៊ីអេអូ កថាខណ្ឌទី៧៧។

- កិច្ចសម្ភាសន៍ជាមួយបុគ្គលិក IFC ចំនួន ៣៦ នាក់ ដែលពាក់ព័ន្ធនឹងគម្រោង ឬព័ត៌មានពាក់ព័ន្ធទាក់ទងនឹងបញ្ហានៅក្នុងសំណុំរឿង បុគ្គលិករបស់អតិថិជន និងអតិថិជនបន្ត នៅការិយាល័យកណ្តាល និងការិយាល័យសាខា ដើមបណ្តឹង មន្ត្រីនៃរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធជាច្រើនទៀត។

ស៊ីអេអូបានធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា រយៈពេលបីសប្តាហ៍ ក្នុងខែមីនា-មេសា ឆ្នាំ២០២៤។ ក្រុមការងារនៅទីវាលបានជួប និងសម្ភាសគ្រួសារទាំង ១៨ ដែលដាក់ពាក្យបណ្តឹងនេះ។ ក្រុមការងារក៏បានជួបជាមួយបុគ្គលិកនៅការិយាល័យកណ្តាល និងសាខានៃគ្រឹះស្ថានហិរញ្ញវត្ថុទាំងប្រាំមួយផងដែរ។ បន្ថែមពីលើកិច្ចប្រជុំដោយផ្ទាល់ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ ស៊ីអេអូក៏បានចុះទៅកាន់សាខាចំនួនប្រាំបី ដោយបានសម្ភាសអ្នកគ្រប់គ្រងសាខា មន្ត្រីឥណទាន និងមន្ត្រីស្តារឥណទានឡើងវិញ ចំនួន ២៨ នាក់ និងធ្វើការត្រួតពិនិត្យប្រាក់កម្ចីនៅនឹងកន្លែង។[195] ស៊ីអេអូបានទទួលឯកសារ និងព័ត៌មានជាច្រើនពីអតិថិជន និងអតិថិជនបន្ត ទាក់ទងនឹងបញ្ហាដែលបានលើកឡើង។ ដើម្បីជានាបាននូវការវាយតម្លៃគ្រប់ជ្រុងជ្រោយ និងមានតុល្យភាពលើគោលនយោបាយ និងការអនុវត្តរបស់អតិថិជន និងអតិថិជនបន្តរបស់ IFC តាមស្តង់ដារ និងអនុសាសន៍របស់ GIIP នៅពេលវាយតម្លៃគោលនយោបាយមីក្រូហិរញ្ញវត្ថុនោះ[196] ស៊ីអេអូបានធ្វើការសម្ភាសតាមទូរស័ព្ទជាលក្ខណៈផ្ទាល់ខ្លួន ជាមួយអ្នកខ្ចីដែលត្រូវបានជ្រើសរើសដោយចៃដន្យ ចំនួន ៣០ នាក់ - ៥ នាក់មកពីគ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ ក្នុងចំណោមគ្រឹះស្ថានទាំងប្រាំមួយ ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង - បន្ថែមពីលើការសម្ភាសផ្ទាល់ខ្លួនជាមួយដើមបណ្តឹងទាំង ១៨ គ្រួសារ។ អ្នកខ្ចីគ្រប់រូបដែលត្រូវបានសម្ភាសដោយស៊ីអេអូ គឺជាអតិថិជន និងអតិថិជនបន្តរបស់ IFC ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតពាក្យបណ្តឹងនេះ។ អ្នកខ្ចីទាំង ៣០ នាក់ ដែលត្រូវបានជ្រើសរើសដោយចៃដន្យនេះ ត្រូវបានជ្រើសរើសពីបញ្ជីដែលផ្តល់ជូនដោយអតិថិជន និងអតិថិជនបន្តរបស់ IFC និងរួមបញ្ចូលអ្នកខ្ចីនៅដំណាក់កាលខុសៗគ្នា នៃការទូទាត់សង (រួមទាំងអ្នកដែលបានសងប្រាក់ទាន់ពេលវេលា អ្នកសងប្រាក់យឺតយ៉ាវ ប៉ុន្តែតិចជាង ៣០ ថ្ងៃ និងអ្នកសងប្រាក់យឺតយ៉ាវ ចាប់ពី ៣០ ថ្ងៃឡើងទៅ)។

---

[195] ការជ្រើសរើស៖
- ខេត្ត ២ ត្រូវបានជ្រើសរើសដោយផ្អែកលើពាក្យបណ្តឹង និងទីតាំង
- សាខាចំនួន ៨ ត្រូវបានជ្រើសរើសដោយផ្អែកលើភាពចម្រុះនៃសមិទ្ធកម្មរបស់សាខា និងការការពារអត្តសញ្ញាណរបស់ដើមបណ្តឹង
- បុគ្គលិកនៅតាមសាខានីមួយៗ ដែលត្រូវបានជ្រើសរើស៖ អ្នកគ្រប់គ្រងសាខាម្នាក់ មន្ត្រីឥណទានម្នាក់ (មានសមិទ្ធកម្មកំពូល/មធ្យម/ទាប) មន្ត្រីស្តារឥណទានឡើងវិញម្នាក់ និងបុគ្គលិកជាក់លាក់មួយចំនួន ក្នុងករណីសាខាជាក់លាក់

[196] វាគឺជាស្តង់ដារ និងការអនុវត្តដែលត្រូវបានណែនាំ ក្នុងការសម្ភាសសំណាកអតិថិជនដែលត្រូវបានជ្រើសរើសដោយចៃដន្យ នៅពេលត្រួតពិនិត្យការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដើម្បីត្រួតពិនិត្យការប្រកាន់ខ្ជាប់នូវ GIIP តាមរយៈការសម្ភាសអតិថិជន ដែលមិនពឹងផ្អែកតែលើគោលនយោបាយជាលាយលក្ខណ៍អក្សរ ឬកិច្ចសម្ភាសជាមួយបុគ្គលិកអតិថិជននោះទេ។ ចំណុចនេះក៏ពាក់ព័ន្ធជាពិសេសនឹងការទប់ស្កាត់បំណុលវ័ណ្ឌក និងកាតព្វកិច្ចរបស់អតិថិជនក្នុងការពិនិត្យតាមដាន និងឆ្លើយតបទៅនឹងហានិភ័យនៃការជំពាក់បំណុលវ័ណ្ឌក ដែលមានការកើនឡើងផងដែរ។ សូមមើល ក្នុងចំណោមការណែនាំដទៃទៀត៖ SPTF+Cerise មគ្គុទ្ទេសក៍ណែនាំអំពីការវាយតម្លៃ និងការអនុវត្តស្តង់ដារសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន វិមាត្រ ៤.A និង ៤B ស្តីពីការការពារអតិថិជន https://bit.ly/3FqqZ5L; មជ្ឈមណ្ឌលបរិយាប័ន្នហិរញ្ញវត្ថុ Accion ការដាក់ឲ្យគោលការណ៍ដំណើរការ៖ ការណែនាំលម្អិតអំពីគោលការណ៍ការពារអតិថិជន ការការពារ និងការផ្តល់ភាពអង់អាចដល់អ្នកប្រើប្រាស់ហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ ទំ. ១៣, https://bit.ly/4kw6Dao និង Cerise+ SPTF, ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ទំ.១៩ https://bit.ly/41RDorH។

ស៊ីអេអូក៏បានជួបជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងស្រុក តំណាងសហគមន៍ និងអ្នកខ្ចីដែលមិនមែនជាដើមបណ្តឹង ចំនួន ១២ នាក់ ដែលត្រូវបានណែនាំដោយអង្គការសង្គមស៊ីវិល[197] តំណាងអង្គការសហប្រជាជាតិ ស្ថាប័នតាមវិស័យចំនួនប្រាំ អាជ្ញាធរជាតិចំនួនពីរ និងអ្នកជំនាញផ្នែកឧស្សាហកម្ម និងអ្នកសិក្សា ចំនួន ១៣ នាក់។

ដោយពិចារណាលើសមិទ្ធកម្ម E&S របស់ IFC ភស្តុតាងដែលពាក់ព័ន្ធត្រូវបានទាមទារដើម្បីផ្តល់មូលដ្ឋានសមហេតុផលសម្រាប់គំហើញ និងសេចក្តីសន្និដ្ឋានអំពីភាពអនុលោម ដោយស៊ីអេអូ។ ដូចបានតម្រូវដោយគោលនយោបាយស៊ីអេអូ[198] របាយការណ៍នេះមិនរួមបញ្ចូលគំហើញ ឬសេចក្តីសន្និដ្ឋានណាមួយដែលត្រូវបានដកចេញ ដែលមានអត្ថប្រយោជន៍នៃការមើលមិនឃើញនោះទេ។ ផ្ទុយទៅវិញ ស៊ីអេអូបានវាយតម្លៃថាតើមានភស្តុតាងដែលថា IFC បានអនុវត្តលក្ខខណ្ឌតម្រូវ E&S ដែលពាក់ព័ន្ធដែរឬទេ ដោយពិចារណាលើប្រភពព័ត៌មានដែលមាន នៅពេលធ្វើការសម្រេចចិត្ត។

## ៣.៧ គោលនយោបាយ IFC ស្តង់ដារ និងការអនុវត្តការវិនិយោគមីក្រូហិរញ្ញវត្ថុ ដែលពាក់ព័ន្ធ

ស៊ីអេអូបានកំណត់កាតព្វកិច្ចរបស់ IFC ក្នុងករណីអតិថិជនមីក្រូហិរញ្ញវត្ថុ និងការវិនិយោគ ដោយត្រួតពិនិត្យ (១) គោលនយោបាយ E&S របស់ IFC ដែលពាក់ព័ន្ធ (២) បទប្បញ្ញត្តិពាក់ព័ន្ធនៅប្រទេសកម្ពុជា និង (៣) ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) ដែលត្រូវបានប្រើប្រាស់នៅក្នុងវិស័យនេះ។ ផ្នែកនេះផ្តល់ជូននូវសេចក្តីសង្ខេបអំពីការវិភាគរបស់ស៊ីអេអូ។

### ៣.៧.១ គោលនយោបាយរបស់ IFC ដែលពាក់ព័ន្ធ

IFC បានជាប់ពាក់ព័ន្ធនឹងការវិនិយោគនៅក្នុងសំណុំរឿងនេះ ចាប់តាំងពីពេលត្រួតពិនិត្យភាពត្រឹមត្រូវលើប្រាក់កម្ចីរបស់ Advans ឆ្នាំ២០០៤ មកទល់បច្ចុប្បន្ន។ គោលនយោបាយរបស់ IFC បានវិវត្តក្នុងអំឡុងពេលនេះ រួមជាមួយលទ្ធផលដែលគោលនយោបាយ និងលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងសង្គម (E&S) អនុវត្តចំពោះការវិនិយោគ ដែលមានរាយនាមនៅក្នុងពាក្យបណ្តឹងនេះ ដែលប្រែប្រួលតាមពេលវេលា។

#### *៣.៧.១.១ គោលនយោបាយរបស់ IFC ដែលពាក់ព័ន្ធ មុនឆ្នាំ២០០៦*

ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC នៅឆ្នាំ២០០៤ និងការត្រួតពិនិត្យរបស់ Advans ចាប់ពីឆ្នាំ២០០៥ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៦[199] ត្រូវបានគ្រប់គ្រងដោយគោលនយោបាយប្រតិបត្តិការ (OP) របស់ IFC គិតត្រឹមថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៨ ជាពិសេស OP ៤.០១ (ការវាយតម្លៃផ្នែកបរិស្ថាន ឆ្នាំ១៩៩៨) ដែលគ្រប់គ្រងដំណើរការគ្រប់គ្រងហានិភ័យ E&S របស់ IFC។ គោលនយោបាយការពារនេះ រួមជាមួយ ESRP ដែលពាក់ព័ន្ធ បញ្ជីផាត់ចេញរបស់ IFC និងគោលនយោបាយបង្ហាញព័ត៌មានរបស់ IFC ឆ្នាំ១៩៩៨ និងគោលនយោបាយការពារជាក់លាក់ដទៃទៀត ដូចជា គោលនយោបាយស្តីពីជនជាតិដើមភាគតិច បាន

[197] ការសម្ភាសដោយផ្ទាល់ (៨) និងក្រុមបង្គោល (៤) ជាមួយអ្នកខ្ចីដែលមិនមែនជាដើមបណ្តឹង ដែលត្រូវបានណែនាំដោយ CSOs ដែលពាក់ព័ន្ធនៅក្នុងពាក្យបណ្តឹងនេះ លើបញ្ហាតាមកម្មវត្ថុជាក់លាក់។ អ្នកទាំងអស់នោះសុទ្ធតែបានខ្ចីប្រាក់ពីអតិថិជន និងអតិថិជនបន្តរបស់ IFC។

[198] គោលនយោបាយស៊ីអេអូ កថាខណ្ឌទី ១១៦។

[199] នៅខែមេសា ឆ្នាំ២០០៦ គោលនយោបាយនិរន្តរភាពទីមួយរបស់ IFC ត្រូវបានចេញផ្សាយ។

បង្កើតក្របខណ្ឌនិរន្តរភាពនៅពេលនោះ។

គោលការណ៍ និងនីតិវិធីទាំងនេះតម្រូវឱ្យ IFC ធ្វើការវាយតម្លៃបរិស្ថានលើផលប៉ះពាល់ E&S នៃការវិនិយោគដែលបានគ្រោងទុកទាំងអស់។[200] នីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គម (ESRP) របស់ IFC នៅពេលនោះបានពិពណ៌នាការវាយតម្លៃនេះថាជា "ដំណើរការដែលអាចបត់បែនបាន" ដែល "ពុំមានសារពើភ័ណ្ឌថេរនៃបញ្ហាដែលត្រូវបានត្រួតពិនិត្យនោះទេ [...] ផ្ទុយទៅវិញ នីតិវិធីរបស់ធនាគារពឹងផ្អែកលើការត្រួតពិនិត្យ [...] និងការពិភាក្សារវាងធនាគារ និងអ្នកខ្ចី [...] ការពិគ្រោះយោបល់ជាមួយក្រុមដែលរងផលប៉ះពាល់ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នៅដំណាក់កាលដំបូង ដើម្បីធានាថា បានគ្របដណ្តប់លើបញ្ហាបរិស្ថាន [និងសង្គម] សំខាន់ៗទាំងអស់។[201] នៅក្នុងកាលៈទេសៈ "ដែលគម្រោងអាចបង្កផលប៉ះពាល់សង្គមសំខាន់ៗ និងចម្រុះ IFC នឹងប្រមូលព័ត៌មានអំពីផលប៉ះពាល់សង្គមដែលអាចកើតឡើង នៃគម្រោងដែលបានស្នើ ហើយពិចារណាបញ្ហាទាំងនេះជាផ្នែកនៃដំណើរការវាយតម្លៃគម្រោងរបស់ខ្លួន"។[202] ការវាយតម្លៃរបស់ IFC លើគម្រោងអន្តរការីហិរញ្ញវត្ថុ ក៏តម្រូវឱ្យ IFC ត្រួតពិនិត្យភាពគ្រប់គ្រាន់នៃការរៀបចំ E&S របស់ FI ដែលបានស្នើសម្រាប់អនុគម្រោង រួមទាំងយន្តការ និងទំនួលខុសត្រូវក្នុងការពិនិត្យ និងត្រួតពិនិត្យឡើងវិញលើ E&S និងការផ្ទៀងផ្ទាត់ថា FI នឹងមានសមត្ថភាព និងប្តេជ្ញាចិត្តបំពេញតាមលក្ខខណ្ឌតម្រូវរបស់ IFC។[203] ការពិនិត្យតាមដានរបស់ IFC ត្រូវបានធ្វើឡើងតាមរយៈរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ បេសកកម្មត្រួតពិនិត្យ និងការចុះត្រួតពិនិត្យទីតាំងគម្រោង និងអនុគម្រោង ដោយផ្តោតលើប្រព័ន្ធគ្រប់គ្រង E&S ការបណ្តុះបណ្តាល និងឧបករណ៍គ្រប់គ្រងហានិភ័យរបស់អតិថិជន។[204]

### *៣.៧.១.២ កាតព្វកិច្ចនៃគោលនយោបាយនិរន្តរភាពរបស់ IFC ក្រោយឆ្នាំ២០០៦*

IFC បានធ្វើបច្ចុប្បន្នភាពក្របខណ្ឌនិរន្តរភាពរបស់ខ្លួន នៅឆ្នាំ២០០៦ និងម្តងទៀត នៅឆ្នាំ២០១២។ ក្របខណ្ឌទាំងពីរមានគោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម (គោលនយោបាយនិរន្តរភាព) ដែលកំណត់កាតព្វកិច្ចរបស់ IFC និងស្តង់ដារសមិទ្ធកម្មដែលពាក់ព័ន្ធ ដែលបង្កើតកាតព្វកិច្ចរបស់អតិថិជន។

---

[200] OP ៤.០១ បានចង្អុលបង្ហាញថា ដំណើរការវាយតម្លៃបរិស្ថាន (EA) គឺជាដំណើរការដែលវិសាលភាព ជម្រៅ និងប្រភេទនៃការវិភាគអាស្រ័យលើលក្ខណៈ មាត្រដ្ឋាន និងផលប៉ះពាល់បរិស្ថានដែលអាចកើតឡើង នៃគម្រោងដែលបានស្នើ ដែលគិតគូរពីបរិស្ថានធម្មជាតិ និងទិដ្ឋភាពសង្គម ហើយពិចារណាលើទិដ្ឋភាពធម្មជាតិ និងសង្គម តាមរបៀបរួមបញ្ចូលគ្នា រួមជាមួយការវិភាគសេដ្ឋកិច្ច ហិរញ្ញវត្ថុ ស្ថាប័ន សង្គម និងបច្ចេកទេសនៃគម្រោងដែលបានស្នើ ព្រមទាំងពិចារណាលើបរិបទប្រទេស និងក្របខណ្ឌគោលនយោបាយជារួម និងសមត្ថភាព E&S របស់អ្នកឧបត្ថម្ភគម្រោងផងដែរ។ "លក្ខខណ្ឌតម្រូវសម្រាប់ប្រតិបត្តិការ FI ត្រូវបានទាញចេញពីដំណើរការ EA [...]។ ដំណើរការ EA គិតគូរពីប្រភេទហិរញ្ញវត្ថុដែលកំពុងត្រូវបានពិចារណា លក្ខណៈ និងមាត្រដ្ឋាននៃអនុគម្រោង ដែលបានរំពឹងទុក និងលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាននៃយុត្តាធិការដែលអនុគម្រោងនឹងស្ថិតនៅ។ OP ៤.០១ កថាខណ្ឌ ១-៣។

[201] IFC OP ៤.០១ ចង្អុលបង្ហាញថា "ព័ត៌មានបន្ថែម ទាក់ទងនឹង OP នេះ ត្រូវបានផ្តល់ជូននៅក្នុង ធនាគារពិភពលោក ឆ្នាំ១៩៩១៖ សៀវភៅប្រភពវាយតម្លៃបរិស្ថាន"។ ធនាគារពិភពលោក ឆ្នាំ១៩៩១៖ សៀវភៅប្រភពវាយតម្លៃបរិស្ថាន បង្ហាញពីអត្ថបទខាងលើ និងថា "បរិស្ថាន" ត្រូវបានកំណត់និយមន័យ "យ៉ាងទូលំទូលាយ [...] ថាជា "លក្ខខណ្ឌធម្មជាតិ និងសង្គម ជុំវិញមនុស្សគ្រប់រូប និងរួមទាំងមនុស្សជំនាន់ក្រោយផងដែរ"៖ លេខ ១ ទំ. ១១ សូមមើល IFC ESRP ឆ្នាំ១៩៩៨ ទំ. ៨ កថាខណ្ឌ ១៧ ស្តីពីលក្ខខណ្ឌតម្រូវនៃការត្រួតពិនិត្យផ្នែកសង្គមក្នុងអំឡុងពេលដំណើរការ EA https://bit.ly/4mXGHWE។

[202] IFC ESRP ឆ្នាំ១៩៩៨ ទំ. ៨។

[203] IFC OP ៤.០១ កថាខណ្ឌ ១០ និង IFC ESRP ឆ្នាំ១៩៩៨ ទំ. ១០ ១២-១៣ ឧបសម្ព័ន្ធ ច។

[204] IFC ESRP ឆ្នាំ១៩៩៨ ទំ. ៣៣ ឧបសម្ព័ន្ធ ច កថាខណ្ឌ ១០-១២

ការត្រួតពិនិត្យ និងការពិនិត្យតណាទានដំបូងរបស់ IFC លើការវិនិយោគរបស់ MEF ដែលធ្វើឡើងនៅចន្លោះ ឆ្នាំ២០០៩ និង ឆ្នាំ២០១២[205] ត្រូវបានគ្រប់គ្រងដោយគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦[206] ស្តង់ដារសមិទ្ធកម្ម (PS) ឆ្នាំ២០០៦[207] និងគោលនយោបាយសិទ្ធិទទួលបានព័ត៌មាន (AIP)[208] របស់ IFC។ គោលនយោបាយនិរន្តរភាពឆ្នាំ២០១២[209] ស្តង់ដារការអនុវត្ត (PS)[210] របស់ IFC បញ្ជីផាត់ចេញរបស់ IFC និង គោលនយោបាយសិទ្ធិទទួលបានព័ត៌មាន (AIP)[211] រួមគ្នាហៅកាត់ថា ក្របខណ្ឌនិរន្តរភាព អនុវត្តចំពោះការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែក E&S នៃការវិនិយោគដែលនៅសល់ នៅក្នុងសំណុំរឿងនេះ ព្រមទាំងការត្រួតពិនិត្យ E&S ទាំងអស់ នៅក្រោយឆ្នាំ២០១២។

ក្របខណ្ឌនិរន្តរភាពរបស់ IFC ទាំងឆ្នាំ២០០៦ និង ឆ្នាំ២០១២ ចែងថា "កិច្ចខិតខំប្រឹងប្រែងអនុវត្តសកម្មភាពវិនិយោគ និងការផ្តល់ប្រឹក្សា ដោយមានបំណង "មិនបង្កគ្រោះថ្នាក់" ដល់មនុស្ស និងបរិស្ថាន" និង "ពង្រឹងនិរន្តរភាពនៃប្រតិបត្តិការរបស់វិស័យឯកជន និងទីផ្សារដែលពួកគេធ្វើការ" គឺជា "ចំណុចស្នូលនៃបេសកកម្មអភិវឌ្ឍន៍របស់ IFC"។[212] ពួកគេក៏ធ្វើឲ្យ IFC ប្តេជ្ញាចិត្តធានាថា "សោហ៊ុយលើការអភិវឌ្ឍសេដ្ឋកិច្ចមិនធ្លាក់លើជនក្រីក្រ ឬងាយរងគ្រោះដោយមិនសមាមាត្រនោះទេ"[213] និង "ព្យាយាមធានាថា តាមរយៈកិច្ចខិតខំប្រឹងប្រែងធ្វើការត្រួតពិនិត្យភាពត្រឹមត្រូវ ពិនិត្យតាមដាន និងត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួន សកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ហិរញ្ញប្បទាន ត្រូវបានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម"។[214]

ការប្តេជ្ញាចិត្តរបស់ IFC នៅក្រោមគោលនយោបាយនិរន្តរភាព ទាំងឆ្នាំ២០០៦ និង ឆ្នាំ២០១២ ត្រូវបានអនុវត្តជាបីដំណាក់កាលនៃវដ្តគម្រោង៖[215]

- *ការត្រួតពិនិត្យភាពត្រឹមត្រូវ៖* ការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកបរិស្ថាន និងសង្គមរបស់ IFC ត្រូវបានរួមបញ្ចូលទៅក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវជាទូទៅរបស់ IFC ចំពោះសកម្មភាពអាជីវកម្មដែលស្ថិតក្រោមការពិចារណា។ ការត្រួតពិនិត្យនេះរួមបញ្ចូលទាំងការត្រួតពិនិត្យឡើងវិញលើហានិភ័យផ្នែក E&S រួមជាមួយការត្រួតពិនិត្យហានិភ័យផ្នែកហិរញ្ញវត្ថុ និងកេរ្តិ៍ឈ្មោះផងដែរ។[216] ការត្រួតពិនិត្យភាព

---

[205] ក្របខណ្ឌនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ អាចអនុវត្តបានចាប់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ មក។

[206] IFC "គោលនយោបាយនិរន្តរភាពសង្គម និងបរិស្ថានរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ" IFC (ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៦) កថាខណ្ឌ ៨ https://bit.ly/4fy6hgP

[207] ស្តង់ដារសមិទ្ធកម្មរបស់ IFC ឆ្នាំ២០០៦ មាននៅ https://bit.ly/4nlUqXR

[208] IFC ឆ្នាំ២០០៦ គោលនយោបាយបង្ហាញព័ត៌មាន (ខែមេសា ឆ្នាំ២០០៦)

[209] IFC "គោលនយោបាយនិរន្តរភាពសង្គម និងបរិស្ថានរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ" IFC (ថ្ងៃទី០១ ខែមករា ឆ្នាំ២០១២) https://bit.ly/៤0TvfTI

[210] ស្តង់ដារសមិទ្ធកម្មរបស់ IFC ឆ្នាំ២០១២ មាននៅ https://bit.ly/3HKcGd6

[211] IFC ឆ្នាំ២០១២ គោលនយោបាយទទួលបានព័ត៌មាន មាននៅ https://bit.ly/42zRGep

[212] គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ៨ និង គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៩

[213] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៩ និង គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ៨

[214] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣ និង ៧ និងគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ៥ និង ៨

[215] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ១៩ ២០ ២១ ២២ ២៤ ៣២ ៣៣ ៣៤ ៣៥ ៤០ និង ៤៥ និងសម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៣-១៨ ២៦ និង ២៧-២៩

[216] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ២១ និងគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៦

ត្រឹមត្រូវផ្នែកបរិស្ថាន និងសង្គមមុនពេលវិនិយោគ ត្រូវតែសមស្របនឹងហានិភ័យ និងផលប៉ះពាល់នៃសកម្មភាពអាជីវកម្មរបស់អតិថិជន ដែលអាចកើតឡើង និងស្របតាមលក្ខណៈ និងវិសាលភាពនៃគម្រោង។[217] សម្រាប់អតិថិជន FI ចំណុចនេះរួមបញ្ចូលទាំងការត្រួតពិនិត្យផលបត្រដែលមានស្រាប់ និងសកម្មភាពអាជីវកម្មនាពេលអនាគត ដើម្បីកំណត់សកម្មភាពដែលអាចធ្វើឲ្យ IFC និងអតិថិជនរបស់ខ្លួនប្រឈមមុខនឹងហានិភ័យ និងកំណត់លក្ខខណ្ឌតម្រូវសម្រាប់គ្រប់គ្រងហានិភ័យទាំងនេះ ដែលសមាមាត្រនឹងកម្រិតនៃហានិភ័យ។[218] គោលនយោបាយឆ្នាំ២០១២ ណែនាំឲ្យ IFC ត្រួតពិនិត្យឡើងវិញលើ "សមត្ថភាពអនុវត្តរបស់ FIs ព្រមទាំង ESMS របស់ពួកគេ ដូចបានតម្រូវដោយស្តង់ដារសមិទ្ធកម្មទី១"។[219] សម្រាប់ FIs ដែលផ្តល់ហិរញ្ញប្បទានគម្រោង លក្ខខណ្ឌតម្រូវ E&S របស់ IFC ត្រូវតែរួមបញ្ចូល "ស្តង់ដារសមិទ្ធកម្ម ដែលសកម្មភាព ដែលត្រូវបានផ្តល់ហិរញ្ញប្បទាន បង្ហាញពីហានិភ័យសង្គម ឬបរិស្ថានសំខាន់ៗ"។[220] ក្នុងគ្រប់ករណីទាំងអស់ FIs ត្រូវបានតម្រូវឱ្យបង្កើត និងបន្តអនុវត្តប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន ដើម្បីធានាថាការវិនិយោគរបស់ខ្លួនបំពេញតាមលក្ខខណ្ឌតម្រូវរបស់ IFC។[221]

- *ការប្តេជ្ញាចិត្ត៖* ផ្អែកលើ ESDD IFC កំណត់លក្ខខណ្ឌតម្រូវសម្រាប់អតិថិជន ដើម្បីគ្រប់គ្រងហានិភ័យដែលត្រូវបានកំណត់។[222] លក្ខខណ្ឌតម្រូវ E&S ទាំងនេះ គួរតែត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងវិនិយោគ ដែលកំណត់លក្ខខណ្ឌសម្រាប់ការវិនិយោគរបស់ IFC។[223] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ ទទួលស្គាល់ថា មីក្រូហិរញ្ញវត្ថុរួមបញ្ចូលហានិភ័យ E&S ជាក់លាក់[224] និងថា អតិថិជន FI ត្រូវតែ៖
    - បង្កើត និងដំណើរការប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដែលរួមបញ្ចូលគោលការណ៍ពាក់ព័ន្ធនៃស្តង់ដារសមិទ្ធកម្មទី១ និងសមស្របនឹងហានិភ័យ E&S នៅក្នុងផលបត្ររបស់ FI។ ប្រព័ន្ធគ្រប់គ្រងនេះគួរតែត្រូវបានប្រើ "ដើម្បីធ្វើការវាយតម្លៃប្រតិបត្តិការបុគ្គល និងពិនិត្យ

[217] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ១៩-២២ និងគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៣

[218] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៥ និង គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៨

[219] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៤

[220] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៨ និង គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៣ និង ៣៥

[221] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៩ សូមមើលគោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៣ និង ៣៥

[222] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៥ និង គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៨

[223] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ២៤ និង គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៦

[224] អតិថិជន FI របស់ IFC បានចូលរួមនៅក្នុងសកម្មភាពចម្រុះ ដែលរួមមាន ហិរញ្ញវត្ថុសហគ្រាសធុនតូច និងមធ្យម មីក្រូហិរញ្ញវត្ថុ ភតិសន្យា ហិរញ្ញវត្ថុពាណិជ្ជកម្ម ការធានា ហិរញ្ញវត្ថុលំនៅឋាន ហិរញ្ញវត្ថុអ្នកប្រើប្រាស់ និងក្នុងករណីមួយចំនួន ហិរញ្ញវត្ថុសាជីវកម្ម និងគម្រោង និងភាគហ៊ុន ដែលសកម្មភាពនីមួយៗមានទម្រង់ហានិភ័យបរិស្ថាន និងសង្គមផ្ទាល់ខ្លួន" (គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣២)។

តាមដាន ព្រមទាំងគ្រប់គ្រងផលបត្រទាំងមូល ស្របតាមព័ត៌មានអំពីហានិភ័យ E&S នៃសកម្មភាព និងប្រតិបត្តិការនីមួយៗ"[225]

- ប្រើបញ្ជីផាត់ចេញរបស់ IFC និងអនុវត្តច្បាប់ជាតិដែលពាក់ព័ន្ធ
- អនុវត្តតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្មទី២ ចំពោះបុគ្គលិករបស់ពួកគេ
- អនុវត្តតាមលក្ខខណ្ឌតម្រូវនៃ PS ដែលពាក់ព័ន្ធ សម្រាប់សកម្មភាពអាជីវកម្មដែលមានហានិភ័យខ្ពស់ ដែលពួកគេគាំទ្រ នៅក្នុងការវិនិយោគរបស់ FI ដែលមានហានិភ័យ E&S ពីស្រាលទៅខ្លាំង (ប្រភេទ FI-១ និង FI-២)។[226]

- *ការត្រួតពិនិត្យ៖* ក្នុងរយៈពេលវិនិយោគទាំងមូល IFC ត្រួតពិនិត្យភាពអនុលោមតាមការប្តេជ្ញាចិត្តផ្នែក E&S របស់អតិថិជន នៅក្នុងកិច្ចព្រមព្រៀងវិនិយោគចងកាតព្វកិច្ច និងការប្តេជ្ញាចិត្តបន្ថែម នៅក្នុងផែនការសកម្មភាព E&S (ESAP) នៃគម្រោង ព្រមទាំងសមិទ្ធកម្មរបស់ FI ក្នុងការអនុវត្ត ESMS របស់ខ្លួនផងដែរ។[227] ប្រសិនបើអតិថិជនមិនបានអនុលោមតាមការប្តេជ្ញាចិត្ត E&S ទាំងនេះទេ IFC ត្រូវតែ "ធ្វើការជាមួយអតិថិជនដើម្បីធ្វើឲ្យអតិថិជនត្រឡប់ទៅអនុលោមតាម តាមកម្រិតដែលអាចធ្វើបាន ហើយប្រសិនបើអតិថិជនមិនបានបង្កើតភាពអនុលោមឡើងវិញទេនោះ សូមអនុវត្តដំណោះស្រាយនៅពេលសមស្រប"។[228] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ ក៏តម្រូវឱ្យ IFC គាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់អតិថិជន FI ដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យ E&S នៃការវិនិយោគរបស់ពួកគេផងដែរ។[229]

### *៣.៧.១.៣ ស្តង់ដារសមិទ្ធកម្មរបស់ IFC ដែលពាក់ព័ន្ធនឹងសកម្មភាពមីក្រូហិរញ្ញវត្ថុរបស់អតិថិជន*

ស្តង់ដារសមិទ្ធកម្មទី១ ស្តង់ដារសមិទ្ធកម្មទី៧ និងបញ្ជីផាត់ចេញរបស់ IFC រួមគ្នា ដោះស្រាយហានិភ័យ និងផលប៉ះពាល់សង្គមនៃមីក្រូហិរញ្ញវត្ថុចំពោះជនងាយរងគ្រោះ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់អំពីគ្រោះថ្នាក់

---

[225] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៣ និង ៣៥។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ ដែលត្រូវបានអនុម័ត មានលក្ខខណ្ឌតម្រូវស្រដៀងគ្នា នៅក្នុងកថាខណ្ឌ ២៩។

[226] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៥។ សម្រាប់ការវិនិយោគ ដែលត្រូវបានចាត់ថ្នាក់ជា FI-៣ (ផលប៉ះពាល់ E&S តិចតួចបំផុត ឬគ្មានផលប៉ះពាល់) SP គ្រាន់តែតម្រូវឱ្យ ESMS មានការត្រួតពិនិត្យសកម្មភាពអាជីវកម្មដែលពួកគេគាំទ្រ ធៀបនឹងបញ្ជីផាត់ចេញរបស់ IFC និងច្បាប់ជាតិតែប៉ុណ្ណោះ។ ក្នុងករណីនេះ ការវិនិយោគផ្ទាល់ចំនួន ៦ ក្នុងចំណោមការវិនិយោគចំនួន ៩ នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់ជា FI-២ និង ការវិនិយោគ ៣ ទៀតត្រូវបានចាត់ថ្នាក់ជា FI-៣។ អតិថិជនផ្ទាល់ទាំងអស់មានការវិនិយោគលើ FI-២ យ៉ាងតិចមួយ ដែល IFC គួរតែត្រួតពិនិត្យ ESMS របស់ពួកគេ ដោយគិតគូរពីគោលការណ៍ដែលពាក់ព័ន្ធនៃ PS1 នៅខណៈពេលដែលការវិនិយោគមូលនិធិភាគច្រើនត្រូវបានចាត់ថ្នាក់ជា FI នៅក្រោមគោលនយោបាយមុនៗ និង North Haven Thai ជា FI-២។ MIFA ហាក់បីដូចជាត្រូវបានចាត់ថ្នាក់ខុសថាជា FI តែប៉ុណ្ណោះ ទោះបីជាវាត្រូវបានអនុម័តនៅក្រោមគោលនយោបាយ ឆ្នាំ២០១២ ក៏ដោយ។

[227] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៦ និង ២៨ គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ២៤ ៣២-៣៥ និង ៤៥

[228] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ២៤ និង ៤៥ គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៦

[229] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៣

របស់ដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។[230] នៅក្នុងបរិបទនៃការស៊ើបអង្កេតនេះ ការយោងដល់ជនងាយរងគ្រោះត្រូវបានធ្វើឡើងចំពោះអ្នកដែលមានការលំបាកផ្នែកសេដ្ឋកិច្ចសង្គម ដោយសារឋានៈដែលមានប្រាក់ចំណូលទាប អក្ខរកម្មទូទៅមានកម្រិតទាប ជាពិសេសអក្ខរកម្មផ្នែកហិរញ្ញវត្ថុ និងច្បាប់ និងមានហានិភ័យនៃភាពក្រីក្រ។

- ស្តង់ដារសមិទ្ធកម្មទី១ (PS1)៖ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម) តម្រូវឲ្យអតិថិជន៖
  - បង្កើត និងបន្តដំណើរការ ESMS ដែលរួមបញ្ចូលដំណើរការកំណត់ហានិភ័យ និងផលប៉ះពាល់ E&S ដែលពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្ម ដែល IFC កំពុងគាំទ្រ ព្រមទាំងកម្មវិធីគ្រប់គ្រង ដើម្បីកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ ដែលត្រូវបានកំណត់។[231] វិសាលភាពនៃដំណើរការកំណត់នេះ និងជាលទ្ធផល ការបង្កើតវិធានការបង្ការ និងកាត់បន្ថយឱ្យបានគ្រប់គ្រាន់ គួរតែស្របតាមការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP)។[232] អតិថិជនត្រូវតែគិតគូរពីហានិភ័យ និងផលប៉ះពាល់ E&S ដែលពាក់ព័ន្ធទាំងអស់ រួមទាំងចំណុចដែលគ្របដណ្តប់នៅក្នុងស្តង់ដារសមិទ្ធកម្មទី២ ដល់ ទី៨ របស់ IFC (ដូចជា ចំណុចដែលទាក់ទងទៅនឹងជនជាតិដើមភាគតិចនៅក្នុងស្តង់ដារសមិទ្ធកម្មទី៧ ជាដើម) ហើយពួកគេត្រូវតែកំណត់ចំនួនប្រជាជនដែលទំនងជារងផលប៉ះពាល់ដោយហានិភ័យ និងផលប៉ះពាល់ E&S ទាំងនោះ និងរួមបញ្ចូលវិធានការខុសៗគ្នានៅក្នុង ESMS ដូច្នេះផលប៉ះពាល់អវិជ្ជមានមិនធ្លាក់លើជនឬក្រុមដែលមានការលំបាក ឬងាយរងគ្រោះដោយមិនសមមាត្រនោះទេ (PS1 កថាខណ្ឌ ៧ ១២ និង ១៣)[233]

---

[230] ការវាយតម្លៃរបស់ស៊ីអេអូបានកំណត់ថា PS2 PS4 និង PS5 មិនអនុវត្តចំពោះផលប៉ះពាល់ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងនេះទេ ដែលជាទូទៅ នឹងត្រូវដោះស្រាយស្របតាម PS1 ច្រើនជាង PS ជាក់លាក់ដទៃទៀត នៅក្នុងបរិបទការវិនិយោគទាក់ទងនឹងមីក្រូហិរញ្ញវត្ថុ។ ស៊ីអេអូ ការវាយតម្លៃភាពអនុលោមនៃពាក្យបណ្តឹង ទាក់ទងនឹងការប្រឈមរបស់ IFC នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនប្រាំមួយនៅកម្ពុជា (អេស៊ីលីដា អម្រឹត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា) (គម្រោងរបស់ IFC លេខ ២១៨៥៦ ២៧៨២៧ ៣១៤៦៧ ៣៤៧៤៨ ៣៨៦០៩ ៣៩១៦៧ ៤១២៩៤ ៤២៤៨០ ៤៤២១១ ៤៤២៣១ ៤៤៧៤២ ៤៤៨៨២ ៤៥៥៣៥) ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ មាននៅ https://bit.ly/៤៤១BhBz។

[231] ESMS នឹងរួមបញ្ចូលធាតុដូចតទៅ៖ (i) គោលនយោបាយ (ii) ការកំណត់ហានិភ័យ និងផលប៉ះពាល់ (iii) កម្មវិធីគ្រប់គ្រង (iv) សមត្ថភាព និងសមត្ថកិច្ចរបស់អង្គការ (v) ការត្រៀមខ្លួន និងការឆ្លើយតបក្នុងគ្រាអាសន្ន (vi) ការចូលរួមរបស់ភាគីពាក់ព័ន្ធ និង (vii) ការពិនិត្យតាមដាន និងការត្រួតពិនិត្យ។ គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៥។

[232] សូមមើល ផ្នែក ៣.៧.២ ៣.៧.៣ និង ឧបសម្ព័ន្ធ ខ សម្រាប់ការអភិវឌ្ឍក្នុងរយៈពេលពីរទសវត្សចុងក្រោយរបស់ GIIP ទាក់ទងនឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដើម្បីបង្ការ និងកាត់បន្ថយគ្រោះថ្នាក់ចំពោះអ្នកខ្ចីក្រីក្រ និងងាយរងគ្រោះ។

[233] នៅក្នុងករណីការវិនិយោគរបស់ MEF ស្រដៀងគ្នាដែរ PS1 ឆ្នាំ២០០៦ នឹងក្លាយជាស្តង់ដារសមិទ្ធកម្ម ដែលអាចអនុវត្តបាន ក្នុងអំឡុងពេល ESDD ដែលបង្កើតលក្ខខណ្ឌតម្រូវសម្រាប់ ESMS ដែលរួមបញ្ចូលដំណើរការវាយតម្លៃ E&S ដែលពិចារណាពីហានិភ័យ និងផលប៉ះពាល់សង្គម និងបរិស្ថាន ដែលពាក់ព័ន្ធទាំងអស់ របស់គម្រោង ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិដែលអាចអនុវត្តបាន និងតម្រូវការនៃវិធានការខុសៗគ្នាសម្រាប់ក្រុមដែលមានការលំបាក និងងាយរងគ្រោះ។ PS1 ឆ្នាំ២០០៦ កថាខណ្ឌ ៣ ៤ ៨ និង ១២។

  - បង្កើតយន្តការបណ្តឹងសារទុក្ខ ដើម្បីទទួល ឆ្លើយតប និងជួយសម្រួលដល់ការដោះស្រាយកង្វល់ និងបណ្តឹងសារទុក្ខរបស់សហគមន៍ដែលរងផលប៉ះពាល់ អំពីសមិទ្ធកម្ម E&S របស់អតិថិជន។[234]

- ស្តង់ដារសមិទ្ធកម្មទី៧ (PS7 ជនជាតិដើមភាគតិច) និងបញ្ជីផាត់ចេញរបស់ IFC សុទ្ធតែតម្រូវឲ្យអតិថិជនកំណត់ និងបញ្ចៀសផលប៉ះពាល់អវិជ្ជមានលើជនជាតដើមភាគតិច (IPs)។ ពាក់ព័ន្ធនឹងសំណុំរឿងនេះ បញ្ជីផាត់ចេញចែងថា អតិថិជនមិនគួរផ្តល់មីក្រូហិរញ្ញវត្ថុដល់សកម្មភាពណាមួយដែលប៉ះពាល់ដល់ដីធ្លីដែលកាន់កាប់ ឬត្រូវបានទាមទារក្រោមការវិនិច្ឆ័យដោយជនជាតិដើមភាគតិចដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះទេ នៅខណៈពេលដែល PS7 តម្រូវឱ្យអតិថិជន IFC ចូលរួមជាមួយ IPs បន្ថែម តាមភាពសមស្របផ្នែកវប្បធម៌[235] (PS7 កថាខណ្ឌ ៨ ៩[236] និងបញ្ជីផាត់ចេញរបស់ IFC)។

ក្នុងការពិនិត្យភាពអនុលោមរបស់ IFC ចំពោះគោលនយោបាយ E&S របស់ខ្លួន ស៊ីអេអូបានពិចារណាលើគោលជំហររបស់ IFC ដែលបច្ចុប្បន្ន IFC អនុវត្តគោលនយោបាយ E&S របស់ខ្លួនដោយមិនបានពិចារណាលើផលប៉ះពាល់អវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុដែលអាចកើតឡើងចំពោះអ្នកខ្ចី និងក្រុមគ្រួសាររបស់ពួកគេនោះទេ។[237] ស្របពេលជាមួយគ្នានេះ ស៊ីអេអូក៏បានពិចារណាលើអត្ថបទ និងគោលបំណងនៃគោលនយោបាយ E&S ផងដែរ។ ជាពិសេស ស៊ីអេអូយល់ថា ផលប៉ះពាល់សង្គមអវិជ្ជមាន ដែលដើមបណ្តឹងបានអះអាងនៅក្នុងសំណុំរឿងនេះគឺជាផលប៉ះពាល់ដែលក្របខណ្ឌនិរន្តរភាពរបស់ IFC ព្យាយាមទប់ស្កាត់ ឬកាត់បន្ថយ (ឧ. ការបាត់បង់ដីធ្លី និងការថយចុះនៃប្រាក់ចំណូល រួមជាមួយផលប៉ះពាល់ជាបន្តបន្ទាប់លើមុខរបរចិញ្ចឹមជីវិតរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ ការបាត់បង់អត្តសញ្ញាណ និងមុខរបរចិញ្ចឹមជីវិតដែលផ្អែកលើធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច)។ លើសពីនេះទៀត ដូចដែលបានពន្យល់ខាងលើ មានតម្រូវការជាក់លាក់ ទាក់ទង

[234] PS1 ឆ្នាំ២០១២ កថាខណ្ឌ ៣៥។ សម្រាប់ការវិនិយោគរបស់ MEF បញ្ញត្តិដែលពាក់ព័ន្ធមាននៅក្នុង PS1 ឆ្នាំ២០០៦ កថាខណ្ឌ ២៣។

[235] បញ្ជីផាត់ចេញរបស់ IFC មានចំណុចបន្ថែមចំនួនបី នៅពេល FIs កំពុងវិនិយោគលើសកម្មភាពមីក្រូហិរញ្ញវត្ថុ។ ចំណុចបន្ថែមទាំងនេះអនុវត្ត "បន្ថែមពីលើ [ចំណុចដទៃទៀត] នៃបញ្ជីផាត់ចេញរបស់ IFC" និងទាក់ទងនឹងការហាមឃាត់សកម្មភាព ដែលអាចពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ ពលកម្មកុមារ សារធាតុគីមីដែលមានគ្រោះថ្នាក់ និងដីធ្លីរបស់ជនជាតិដើមភាគតិច។ បញ្ជីផាត់ចេញរបស់ IFC រួមជាមួយការហាមឃាត់មីក្រូហិរញ្ញវត្ថុទាំងនេះ ជាញឹកញាប់ ត្រូវបានហៅថា បញ្ជីផាត់ចេញ MFI របស់ IFC។ ជាពិសេស ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច បញ្ជីផាត់ចេញ MFI របស់ IFC នេះ ចង្អុលបង្ហាញថា "IFC មិនផ្តល់ហិរញ្ញប្បទានដល់គម្រោងដូចតទៅ៖ [...] នៅពេលវិនិយោគលើសកម្មភាព**មីក្រូហិរញ្ញវត្ថុ** [...] ផលិតកម្ម ឬសកម្មភាព ដែលប៉ះពាល់ដល់ដីធ្លី ដែលត្រូវបានកាន់កាប់ ឬទាមទារស្របតាមការវិនិច្ឆ័យក្តី ដោយជនជាតិដើមភាគតិច ដោយពុំមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះ"។ បញ្ជីផាត់ចេញរបស់ IFC៖ https://bit.ly/3FqDjTf។ IFC ផ្តល់ទឡ្ហីករណ៍ថា បញ្ជីផាត់ចេញអនុវត្តចំពោះសកម្មភាពរបស់សហគ្រាសធុនមីក្រូ មិនមែនចំពោះអ្នកខ្ចីដោយផ្ទាល់នោះទេ។ ស៊ីអេអូកត់សម្គាល់ថា ចំណុចនេះគឺជាដែនកំណត់ដែលមិនមានសសេរនៅក្នុងបញ្ជីផាត់ចេញរបស់ IFC នោះទេ ដែលវាមានបំណងបង្ការថា រាល់សកម្មភាពដែលផ្តល់ហិរញ្ញប្បទានដោយ IFC ដោយមិនដាក់កម្រិតលើជនដែលកំពុងអនុវត្តបញ្ជីនេះ មិនប៉ះពាល់ដល់ដីធ្លីរបស់ជនជាតិដើមភាគតិចនោះទេ។

[236] សម្រាប់ការវិនិយោគរបស់ MEF PS ឆ្នាំ២០០៦ បានរួមបញ្ចូលបញ្ញត្តិស្ទើរតែដូចគ្នា នៅក្នុងកថាខណ្ឌ ៣ ៧ ៨។

[237] IFC យល់ឃើញថា គោលនយោបាយ E&S របស់ខ្លួន មានបំណងដោះស្រាយផលប៉ះពាល់ និងហានិភ័យផ្នែកបរិស្ថាន និងសង្គមដែលទាក់ទងនឹងការប្រើប្រាស់ចុងក្រោយនៃប្រាក់ចំណូលពីការផ្តល់ហិរញ្ញប្បទានរបស់ IFC តែប៉ុណ្ណោះ ដូច្នេះការអនុវត្តការផ្តល់ប្រាក់កម្ចី និងការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) និងផលប៉ះពាល់លើអ្នកខ្ចីបន្ត នៅក្នុងបរិបទនេះ មិនស្ថិតនៅក្នុងវិសាលភាពនេះទេ។

នឹងផលប៉ះពាល់ប្រភេទនេះ សម្រាប់គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ IFC នៅក្នុងគោលនយោបាយនិរន្តរភាព PS1 PS7 និងបញ្ជីផាត់ចេញរបស់ IFC។ លើសពីនេះទៀត ក្របខណ្ឌនិរន្តរភាពអនុវត្តចំពោះគម្រោង IFC ទាំងអស់ និងវិសាលភាពពេញលេញនៃហានិភ័យ និងផលប៉ះពាល់ E&S របស់គម្រោងទាំងនោះ រួមទាំង "ផលប៉ះពាល់ពិសេសៗ" ណាមួយ ដែលមិនត្រូវបានលើកឡើងជាពិសេសនៅក្នុងគោលនយោបាយនេះ "លើកលែងតែត្រូវបានផាត់ចេញជាពិសេស"។[238]

ស៊ីអេអូកត់សម្គាល់ថា មិនមានការផាត់ចេញ ឬការរឹតបន្តឹងណាមួយ ក្នុងការអនុវត្តក្របខណ្ឌនិរន្តរភាពរបស់ IFC ចំពោះអ្នកប្រើប្រាស់ហិរញ្ញវត្ថុ អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ឬជាទូទៅ អ្នកប្រើប្រាស់សេវាដែលផ្តល់ហិរញ្ញប្បទានដោយ IFC នោះទេ (ទោះបីជាសេវាហិរញ្ញវត្ថុ ដូចជា មីក្រូហិរញ្ញវត្ថុ ឬសេវាដទៃទៀត ដូចជា ការអប់រំ ឬការដឹកជញ្ជូន ជាដើម)។ ក្របខណ្ឌនិរន្តរភាពរបស់ IFC សំដៅលើ "សហគមន៍ដែលរងផលប៉ះពាល់"។[239] ស្តង់ដារសមិទ្ធកម្មទី១ អំពាវនាវឱ្យអតិថិជនកំណត់ ដោះស្រាយ និងគ្រប់គ្រងផលប៉ះពាល់លើ "សហគមន៍ដែលរងផលប៉ះពាល់" និងជាទូទៅលើ "ជនដែលទំនងជារងផលប៉ះពាល់ដោយសារហានិភ័យ និងផលប៉ះពាល់ដែលពាក់ព័ន្ធ" នៃគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ IFC។[240] អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ និងក្រុមគ្រួសាររបស់ពួកគេទំនងជារងផលប៉ះពាល់ដោយសារហានិភ័យ និងផលប៉ះពាល់ដែលពាក់ព័ន្ធ ដូចដែលបានយោងដល់នៅក្នុង PS1។ នៅក្នុងសំណុំរឿងនេះ ស៊ីអេអូត្រួតពិនិត្យភាពអនុលោមរបស់ IFC ចំពោះបទប្បញ្ញត្តិនៃក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ដែលពាក់ព័ន្ធនឹងការវិនិយោគមីក្រូហិរញ្ញវត្ថុ។

### ៣.៧.២ ខ្សែបន្ទាត់ពេលវេលាសម្រាប់ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) ដែលពាក់ព័ន្ធ បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា និងការវិនិយោគរបស់ IFC

ស្តង់ដារសមិទ្ធកម្មរបស់ IFC តម្រូវឱ្យប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមរបស់អតិថិជនស្របតាមការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP)។ GIIP តំណាងឱ្យស្តង់ដារនៃការថែទាំដែលត្រូវបានទទួលស្គាល់ជាសកលដែលអនុវត្តដោយអង្គភាពដែលមានទំនួលខុសត្រូវ ដែលបានវិវត្តក្នុងការឆ្លើយតបទៅនឹងបញ្ហា និងកង្វល់ ដែលកើតឡើងនៅក្នុងវិស័យឧស្សាហកម្មជាក់លាក់មួយ។ នៅក្នុងលក្ខខណ្ឌជាក់ស្តែង GIIP ផ្តល់សកម្មភាព និងដំណើរការជាក់ស្តែង ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្មរបស់ IFC នៅក្នុងបរិបទជាក់លាក់មួយ។

ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) ដែលអនុវត្តចំពោះការវិនិយោគមីក្រូហិរញ្ញវត្ថុ នៅក្រោម PS1 មានការអភិវឌ្ឍយ៉ាងខ្លាំង ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះ ដែលជារយៈពេលនៃការវិនិយោគ ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ។ តារាងពេលវេលាខាងក្រោមពិពណ៌នាអំពីការអភិវឌ្ឍទាំងនេះ និងការអភិវឌ្ឍដែលពាក់ព័ន្ធ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ទាក់ទងនឹងការវិនិយោគរបស់ IFC។ ខ្សែបន្ទាត់ពេលវេលាកាន់តែលម្អិតបន្ថែមទៀត អាចស្វែងរកបាននៅក្នុងឧបសម្ព័ន្ធ ខ។

---

[238] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ១ ៣ ២០ និង ២២ និងកំណត់សម្គាល់ការណែនាំរបស់ IFC ចំពោះ PS1 កថាខណ្ឌ ១៦ និង ១៧

[239] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ FN2។ ព្រមទាំងនៅក្នុង PS1 FN3 ផងដែរ។

[240] PS1 ឆ្នាំ២០១២ កថាខណ្ឌ ៧។ PS1 សំដៅលើគោលនយោបាយដែលអនុវត្តចំពោះ "សហគមន៍ដែលរងផលប៉ះពាល់" ដែលត្រូវបានកំណត់និយមន័យកាន់តែទូលំទូលាយថាជា "សហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោងដោយផ្ទាល់" (PS1 កថាខណ្ឌ ១)។

## ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIP) ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គមពីមីក្រូហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងសំណុំរឿងនេះ។

- ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ដែលពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា
- ការវិនិយោគរបស់ IFC ដែលពាក់ព័ន្ធ និងការស៊ើបអង្កេតរបស់ ស៊ីអេអូ

2002

**ឆ្នាំ២០០២**
ក្រុមប្រឹក្សាយោបល់ដើម្បីជួយជនក្រីក្រ (CGAP) គោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិ និងការត្រួតពិនិត្យមីក្រូហិរញ្ញវត្ថុ

2003

**ឆ្នាំ២០០៣**
បណ្តាញ SEEP បោះពុម្ពផ្សាយបណ្តុំគោលការណ៍លើកដំបូងស្តីពីការធ្វើនិយ័តកម្មដោយខ្លួនឯង។

2004

**ឆ្នាំ២០០៤**
Accion អន្តរជាតិអនុម័តគោលការណ៍ធ្វើនិយ័តកម្មដោយខ្លួនឯងស្រដៀងគ្នា។

2005

**ឆ្នាំ២០០៥**
លេខ ២១៨៥៦៖ IFC ធ្វើការវិនិយោគភាគហ៊ុននៅ Advans S.A។

2006

**ឆ្នាំ២០០៦**
FMO បង្កើតគោលការណ៍ណែនាំផ្ទៃក្នុងដើម្បីវាយតម្លៃ FSP ដែលគ្រប់ដណ្តប់លើគោលការណ៍ណែនាំស្តីពីហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់ និងឧត្តមានុវត្តន៍។

2007

**ឆ្នាំ២០០៧**
CGAP និងអ្នកដឹកនាំឧស្សាហកម្មដទៃទៀត បង្កើតក្រុមការងារអនុវត្តការងារសង្គម (SPTF)

2008

**ឆ្នាំ ២០០៨**
អ្នកដឹកនាំមីក្រូហិរញ្ញវត្ថុ រួមទាំង ធនាគារ Deutsch និង CGAP ចេញ សេចក្តីប្រកាស Pocantico

2009

**ឆ្នាំ២០០៩-២០១៩**
គោលការណ៍ការពារអតិថិជននៃយុទ្ធនាការឆ្លាតវៃ ត្រូវបានបោះពុម្ពផ្សាយ

**ឆ្នាំ ២០០៩**
ការវាយតម្លៃអំពីវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលផ្តល់មូលនិធិដោយធនាគារពិភពលោក ពិពណ៌នាអំពីអសមត្ថភាពក្នុងការសងប្រាក់កម្ចីថាជា "កង្វល់ដ៏ធ្ងន់ធ្ងរមួយសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ" នៅកម្ពុជា

**ឆ្នាំ ២០០៩**
លេខ ២៧៨២៧៖ ការវិនិយោគភាគហ៊ុនរបស់ IFC នៅក្នុង MEF

**ឆ្នាំ ២០០៩**
បើកដំណើរការ វេទិកាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដែលគ្រប់គ្រងដោយ IFC និង រួមបញ្ចូលយុទ្ធនាការឆ្លាតវៃនៅក្នុងការងាររបស់ខ្លួន។

2010

**ឆ្នាំ ២០១០**
ប្រាក់កម្ចីលើកដំបូង ដែល MEF ផ្តល់ជូនធនាគារហត្ថា (ប្រាក់កម្ចីចុងក្រោយត្រូវបានសងវិញនៅខែឧសភា ឆ្នាំ២០២២។

**ឆ្នាំ ២០១០**
CGAP ធ្វើបច្ចុប្បន្នភាព និងបោះពុម្ពផ្សាយ មគ្គុទ្ទេសក៍ណែនាំផ្នែកបច្ចេកទេសសម្រាប់វិនិយោគិន ស្តីពីការអនុវត្តគោលការណ៍ការពារអតិថិជន។

**ឆ្នាំ ២០១០**
ប្រាក់កម្ចីលើកដំបូង ដែល MEF ផ្តល់ជូនប្រាសាក់ (ប្រាក់កម្ចីចុងក្រោយត្រូវបានសងវិញនៅខែកក្កដា ឆ្នាំ២០២២)។

2011

**ឆ្នាំ ២០១១**
IFC បញ្ជូនអនុស្សរណៈស្តីពីហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវទៅកាន់គណៈកម្មាធិការប្រតិបត្តិការសាជីវកម្ម (COC)

**ឆ្នាំ ២០១១**
CGAP បញ្ជាក់ថា ឧស្សាហកម្ម MFI នៅកម្ពុជា មានហានិភ័យខ្ពស់ចំពោះការជំពាក់បំណុលវ័ណ្ឌក

**ឆ្នាំ ២០១១**
ចាប់ផ្តើមដំណើរការ គោលការណ៍សម្រាប់វិនិយោគិននៅក្នុងបរិយាប័ន្នហិរញ្ញវត្ថុ (PIIF) ក្នុងអំឡុងពេលនៃវេទិកាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវលើកទី ២ ដែលជម្រុញឱ្យវិនិយោគិនធ្វើសមាហរណកម្មគោលការណ៍ការពារអតិថិជន។

2012

**ឆ្នាំ ២០១២**
MEF ផ្តល់ប្រាក់កម្ចីលើកដំបូង ដល់អម្រ៉ឹត (ប្រាក់កម្ចីលើកចុងក្រោយត្រូវបានសងនៅខែមិថុនា ឆ្នាំ២០២៤)

**ឆ្នាំ២០១២**
SPTF បោះពុម្ពផ្សាយស្តង់ដារសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម (USSPM) ជាលើកដំបូង ដែលរួមបញ្ចូលគោលការណ៍ការពារអតិថិជនរបស់យុទ្ធនាការឆ្លាតវៃ។

**ឆ្នាំ ២០១២**
លេខ ៣១៤៦៧៖ ការវិនិយោគភាគហ៊ុនរបស់ IFC នៅ MIFA

**ឆ្នាំ២០១២**
ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ ខេមបូឌា (CBC) ត្រូវបានបង្កើតឡើងដោយមានការគាំទ្រពី IFC។

ត

## ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិ(GIIP) ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គមហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងសំណុំរឿងនេះ។

- ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ដែលពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា
- ការវិនិយោគរបស់IFCដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ស៊ីអេអូ

**2013**

ឆ្នាំ ២០១៣
MIFA ផ្តល់ប្រាក់កម្ចីលើកដំបូង ដល់អម្រឹត (គ្មានប្រាក់កម្ចីរបស់ MIFA នៅអម្រឹត ដែលមិនទាន់សងនោះទេ)

ឆ្នាំ២០១៣
វិទ្យាស្ថានអភិវឌ្ឍន៍កម្ពុជាបោះពុម្ពផ្សាយការសិក្សាមួយដែលគូសបញ្ជាក់ពីហានិភ័យនៃការជំពាក់បំណុលវ័ណ្ឌក ក្នុងចំណោមអតិថិជនមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

ឆ្នាំ ២០១៣
MIFA ផ្តល់ប្រាក់កម្ចីលើកដំបូង ដល់អិលអូអិលស៊ី (ប្រាក់កម្ចីចំនួនប នៅមិនទាន់បានសង)

ឆ្នាំ២០១៣
យុទ្ធនាការឆ្លាតវៃចាប់ផ្តើមដំណើរការកម្មវិធីវិញ្ញាបនប័ត្ររបស់ខ្លួន ជាមួយអង្គការចំនួន ៥០ ដែលបានធ្វើការបញ្ជាក់ក្នុងរយៈពេលបឆ្នាំ ហើយជាង ១២០ យុទ្ធនាការត្រូវបានបញ្ចប់នៅឆ្នាំ២០២០។

**2014**

ឆ្នាំ ២០១៤
លេខ ៣៤៧៤៨៖ IFC ធ្វើការវិនិយោគភាគហ៊ុននៅអម្រឹត

**2015**

ឆ្នាំ២០១៥
TPK (ក្រោយមកជា អិលអូអិលស៊ី) ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាដំបូងគេ ដែលទទួលបានវិញ្ញាបនប័ត្រពីយុទ្ធនាការឆ្លាតវៃ។

ឆ្នាំ២០១៥
IFC បោះពុម្ពសៀវភៅគោលនយោបាយស្តីពីការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ដែលបង្ហាញថា ការជំពាក់បំណុលវ័ណ្ឌក រួមជាមួយក្របខណ្ឌការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុទន់ខ្សោយ កើតឡើងទាំងចំពោះសេដ្ឋកិច្ចកម្ពុជា និងអ្នកប្រើប្រាស់ម្នាក់ៗ។

ឆ្នាំ ២០១៥
MEF ផ្តល់ប្រាក់កម្ចីលើកដំបូង ដល់អិលអូអិលស៊ី (ប្រាក់កម្ចីចុងក្រោយត្រូវបានសងនៅខែតុលា ឆ្នាំ ២០២៤)។

ឆ្នាំ២០១៥–២០១៦
ក្រុមការងារវិនិយោគិន SPTF ធ្វើការប្រមូលផ្តុំទិន្នន័យសង្គមទូទៅសម្រាប់វិនិយោគិន - ការតម្រឹមការត្រួតពិនិត្យភាពត្រឹមត្រូវរបស់វិនិយោគិន និងការត្រួតពិនិត្យតាមស្តង់ដារសកល (ALINUS)។

**2016**

ឆ្នាំ ២០១៦
CMA ដោយមានការគាំទ្រពីវិនិយោគិនសង្គម និង DFIs (ADA BIO FMO Incofin និង Proparco) ចេញគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី។

**2017**

ឆ្នាំ ២០១៧
លេខ ៣៩១៦៧៖ IFC ផ្តល់ប្រាក់កម្ចី MSME ដល់ហត្ថាកសិករលីមីតធីត បច្ចុប្បន្នជាធនាគារហត្ថា ចំនួន ៥ MM ដុល្លារអាមេរិក (ត្រូវបានសងនៅខែមិថុនា ឆ្នាំ២០២២)។

**2018**

ឆ្នាំ២០១៨
CMA បានធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីដើម្បីរួមបញ្ចូលលក្ខខណ្ឌនៃភាពអនុលោមជាកាតព្វកិច្ច ចំពោះសូចនាករជាក់លាក់ ដែលដាក់កម្រិតលើបុនហិរញ្ញប្បទាន។

ឆ្នាំ ២០១៨
លេខ ៤១២៩៤៖ IFC ផ្តល់ប្រាក់កម្ចី MSME ដល់អម្រឹត ចំនួន ១០ MM ដុល្លារអាមេរិក (ត្រូវបានសងនៅខែកក្កដា ឆ្នាំ២០២២)។

ឆ្នាំ២០១៨
យុទ្ធនាការឆ្លាតវៃគាំទ្រគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីរបស់ CMA និងតម្រូវឲ្យមានការផ្ទៀងផ្ទាត់ភាពអនុលោម សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលកំពុងព្យាយាមទទួលបានវិញ្ញាបនបត្រឆ្លាតវៃ។

ឆ្នាំ ២០១៨
MIFA ផ្តល់ប្រាក់កម្ចីដល់ស្ថាបនា ដែលមិនទាន់បានសង គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ។

ឆ្នាំ ២០១៨
លេខ ៣៨៦០៩៖ IFC ធ្វើការវិនិយោគភាគហ៊ុននៅ North Haven Thai

**2019**

ឆ្នាំ២០១៩
ធនាគារពិភពលោកបានចេញកំណត់សម្គាល់គោលនយោបាយរបស់ប្រទេសកម្ពុជាស្តីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ ដែលបានព្រមានអំពី "ការកើនឡើងយ៉ាងឆាប់រហ័សនូវផលធៀបបំណុលនឹងការប្រើប្រាស់"។

ឆ្នាំ២០១៩
របាយការណ៍ការខូចខាតវត្ថុបញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានបោះពុម្ពផ្សាយដោយសមាគមធាងត្នោត និងលីកាដូ

ឆ្នាំ២០១៩
ធនាគារពិភពលោកបានចេញ កំណត់សម្គាល់ផ្នែកបច្ចេកទេសស្តីពីការដោះស្រាយពាក្យបណ្តឹងនៅក្នុងគោលការណ៍អ្នកផ្តល់សេវាហិរញ្ញវត្ថុ

ឆ្នាំ២០១៩
លេខ ៤២៤៨០៖ IFC ផ្តល់ប្រាក់កម្ចីគាំទ្រសហគ្រាសធុនតូច និងមធ្យម ដល់អេស៊ីលីដា ចំនួន ១១០ MM ដុល្លារអាមេរិក។

**ត**

## ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិ(GIIP)ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គមមីក្រូហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគរបស់IFCនៅក្នុងសំណុំរឿងនេះ។

- ការវិវត្តនៃការអនុវត្តឧស្សាហកម្មជាតិល្អ ដែលពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា
- ការវិនិយោគរបស់IFCដែលពាក់ព័ន្ធ និងការស៊ើបអង្កេតរបស់ស៊ីអេអូ

**2020**

**ឆ្នាំ២០២០**
លេខ ៤៤២៣១៖ IFC ផ្តល់ប្រាក់កម្ចីក្ស័យដែលសម្រាប់ MSME ដល់អម្រឹត ចំនួន ២៥ MM ដុល្លារអាមេរិក (ត្រូវបានសងវិញនៅខែមិថុនា ឆ្នាំ២០២៣)។

**ឆ្នាំ២០២០**
IFC រៀបចំរបាយការណ៍ MIMOSA ដែលសន្និដ្ឋានថា ប្រទេសកម្ពុជាបានឈានដល់កម្រិតតិត្ថិភាពទីផ្សារអតិបរមា និងកត់សម្គាល់អំពីកង្វះខាតកិច្ចការពារអ្នកប្រើប្រាស់ និងលំនៅឋានទន្ទឹមគ្នាក្នុងគតិយុត្ត។

**ឆ្នាំ២០២០**
លេខ ៤៤២១១៖ IFC ផ្តល់ប្រាក់កម្ចីក្ស័យដែលសម្រាប់MSME ជាន់ខ្ពស់ដល់ធនាគារហត្ថា ចំនួន ២៥ MM ដុល្លារអាមេរិក (ត្រូវបានសងវិញនៅខែមិថុនា ឆ្នាំ២០២២)។

**ឆ្នាំ២០២០**
យុទ្ធនាការឆ្លាតវៃប្រកាសពីការបញ្ចប់របស់ខ្លួន។ គម្រោង និងសមាសធាតុទាំងអស់ត្រូវបានផ្ទេរទៅកាន់ CERISE+SPTF។

**2021**

**ឆ្នាំ ២០២១**
លេខ ៤៤៨៨២៖ IFC ផ្តល់ប្រាក់កម្ចី SME ដល់អេស៊ីលីដា ចំនួន ១៦៩ MM ដុល្លារអាមេរិក។

**ឆ្នាំ២០២១**
CERISE+SPTF ចាប់ផ្តើមដំណើរការ គន្លងការពារអតិថិជន ដែលរួមបញ្ចូលវិញ្ញាបនបត្រ ដែលអនុម័តដោយទីភ្នាក់ងារវាយតម្លៃ។

**ឆ្នាំ២០២១**
លេខ ៤៤៧៤២៖ IFC ផ្តល់ប្រាក់កម្ចីក្ស័យដែលសម្រាប់ MSME ដល់ធនាគារ ហត្ថា ចំនួន ៤0 MM ដុល្លារអាមេរិក។

**ឆ្នាំ២០២១**
ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអ្នកជំនាញឯករាជ្យជាច្រើននាក់ បានសម្តែងការព្រួយបារម្ភអំពីផលប៉ះពាល់សង្គមអវិជ្ជមាននៃការជំពាក់បំណុលវណ្ឌកនៅកម្ពុជា ចាប់ពីឆ្នាំ២០២០ ដល់ ២០២៤។

**ឆ្នាំ២០២១**
លេខ ៤៥៥៣៥៖ IFC ផ្តល់ប្រាក់កម្ចីក្ស័យដែលសម្រាប់ MSME ដល់ធនាគារ ហត្ថា ចំនួន ៧0 MM ដុល្លារអាមេរិក (ត្រូវបានសងវិញនៅខែកក្កដា ឆ្នាំ២០២៤)។

**ឆ្នាំ២០២១**
សិទ្ធិទទួលបានជំនួយសង្គ្រោះ៖ របាយការណ៍បញ្ចេញមតិរបស់សហគមន៍ដីធ្លីដែលជំពាក់បំណុលត្រូវបានបោះពុម្ពផ្សាយដោយអង្គការសមធម៌កម្ពុជា និង លីកាដូ។

**ឆ្នាំ២០២១**
របាយការណ៍ផលប៉ះពាល់ និងការផ្សព្វផ្សាយរបស់ MIFA បានរកឃើញថា អ្នកឆ្លើយតបក្នុងការស្ទង់មតិចំនួន ៧២% ឡើងទៅ នៅប្រទេសកម្ពុជា អះអាងថា គុណភាពជីវិតជារួម មានភាពប្រសើរឡើង បន្ទាប់ពីមានការផ្តល់ប្រាក់កម្ចីដោយ MFIs

**2022**

**ឆ្នាំ២០២២**
ABC CMA និងសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា អនុម័តក្រមប្រតិបត្តិនៃវិស័យធនាគារ និងហិរញ្ញវត្ថុ ដែលតម្រូវឱ្យមានការអនុលោមតាមគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី និងការត្រួតពិនិត្យដោយ CBC។

**ឆ្នាំ២០២២**
ការវិនិយោគដោយ North Haven Thai នៅអេស៊ីលីដា។

**ឆ្នាំ២០២២**
ការសិក្សាមួយដែលរៀបចំដោយរដ្ឋាភិបាលអាល្លឺម៉ង់បានសម្គាល់ឃើញការកាត់បន្ថយអាហារដែលទាក់ទងនឹងបំណុល ការលក់ដីធ្លី និងកុមារដែលបោះបង់ការសិក្សាដើម្បីទៅធ្វើការ ក្នុងចំណោមអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ។

**2023**

**ឆ្នាំ២០២៣**
ក្នុងខែសីហា វិញ្ញាបនប័ត្រ CPP សម្រាប់ អម្រឹត អិលអូអិលស៊ី និងស្ថាបនា ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យដោយស្ថាប័នផ្តល់វិញ្ញាបនបត្រដាច់ដោយឡែកពីគ្នា និងនៅខែវិច្ឆិកា ការសិក្សាមួយ ដែលរៀបចំឡើងដោយ CMA បានរកឃើញផលប៉ះពាល់សង្គមស្រដៀងគ្នានឹងការសិក្សាឆ្នាំ២០២២ ដែលឧបត្ថម្ភដោយប្រទេសអាល្លឺម៉ង់ដែរ។

**ឆ្នាំ២០២៣**
របាយការណ៍ស្តីពីការគំរាមកំហែងបំណុល៖ ការសិក្សាបែបបរិមាណវិស័យលើអ្នកខ្ចីប្រាក់កម្ចីខ្នាតមីក្រូនៅកម្ពុជា ត្រូវបានបោះពុម្ពផ្សាយដោយអង្គការសមធម៌កម្ពុជា និង លីកាដូ។

**2024**

**ឆ្នាំ២០២៤**
ក្រុមហ៊ុនទិន្នន័យផលប៉ះពាល់ ៦០ ដេស៊ីប៊ែល ចេញផ្សាយការស្ទង់មតិលើអតិថិជន MFI ចំនួនជិត ៣ ពាន់នាក់នៅកម្ពុជា ដែលបញ្ជាក់ថា ភាពតានតឹងក្នុងការសងប្រាក់មានកម្រិតខ្ពស់ ដែលនាំឲ្យមានផលប៉ះពាល់សង្គមអវិជ្ជមាន។

### ៣.៧.៣ ការគូសបញ្ជាក់អំពី GIIP នៅក្នុងការវិនិយោគមីក្រូហិរញ្ញវត្ថុ

**ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អសម្រាប់ការវិនិយោគប្រកបដោយទំនួលខុសត្រូវ**

ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះ បានបង្កើតស្តង់ដារពាក់ព័ន្ធ ទាំងសម្រាប់វិនិយោគិន នៅក្នុងគ្រឹះស្ថានផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និងសម្រាប់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដោយផ្ទាល់។ ការអភិវឌ្ឍដែលពាក់ព័ន្ធ សម្រាប់ករណីនេះ មានន័យថា ការវិនិយោគដែលពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុ ត្រូវបានគេរំពឹងថានឹងអនុវត្តតាមជំហានសំខាន់ៗ ដូចខាងក្រោម ដើម្បីបញ្ចៀសផលប៉ះពាល់សង្គមអវិជ្ជមានដល់ជនក្រីក្រ និងងាយរងគ្រោះ ដោយរាំកំណត់គោលដៅលើ៖

- **ការត្រួតពិនិត្យជាបឋម៖** វិនិយោគិនគួរតែអនុវត្តការត្រួតពិនិត្យឡើងវិញជាបឋម លើគំរូអាជីវកម្មរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ (FSP) បរិបទប្រទេស បរិយាកាសផ្នែកនិយ័តកម្ម និងកត្តាពាក់ព័ន្ធដទៃទៀត ដើម្បីកំណត់ហានិភ័យដែលអាចកើតឡើងចំពោះអ្នកប្រើប្រាស់ ទាក់ទងនឹងគោលនយោបាយ និងការអនុវត្តរបស់ពួកគេ។
- **ការវាយតម្លៃហានិភ័យ៖** វិនិយោគិនគួរតែវាយតម្លៃកម្រិត និងលក្ខណៈហានិភ័យរបស់អ្នកប្រើប្រាស់ ក្នុងការអនុវត្តការផ្តល់ប្រាក់កម្ចីរបស់ FSP។ ការវាយតម្លៃនេះគួរតែរួមបញ្ចូលការត្រួតពិនិត្យគោលនយោបាយ និងការអនុវត្ត ទាក់ទងនឹងការបង្ហាញ ការប្រព្រឹត្តិចំពោះអតិថិជនដោយយុត្តិធម៌ និងយន្តការបណ្តឹងសារទុក្ខ។ គន្លងនៃការការពារអតិថិជន (និងពីមុន យុទ្ធនាការឆ្លាតវៃ) ផ្តល់ស្តង់ដារឧស្សាហកម្មអន្តរជាតិដ៏ល្អ ដែលគួរតែអនុវត្តដោយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដើម្បីបង្កគ្រោះថ្នាក់ចំពោះអ្នកខ្ចី។ ទាក់ទងនឹងបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ ការវាយតម្លៃហានិភ័យគួរតែត្រួតពិនិត្យឡើងវិញ ថាតើអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ៖
    - ធានាថាមានការរចនា និងការផ្តល់ផលិតផលសមស្រប ដើម្បីទប់ស្កាត់ការជំពាក់បំណុលវ័ណ្ឌក និងជៀសវាងការបង្កគ្រោះថ្នាក់ រួមទាំងកំណត់ទ្រព្យសកម្មដែលមិនអាចដាក់ធានាជាវត្ថុបញ្ចាំបាន ដើម្បីជៀសវាងការលំបាកធ្ងន់ធ្ងរ ឬការបាត់បង់សមត្ថភាពស្វែងរកប្រាក់ចំណូលដ៏សំខាន់របស់អតិថិជន
    - ទប់ស្កាត់ការជំពាក់បំណុលវ័ណ្ឌក តាមរយៈការវាយតម្លៃសមត្ថភាពសងបំណុលរបស់អ្នកខ្ចី
    - ធានាបាននូវតម្លាភាព តាមរយៈការផ្តល់ព័ត៌មានច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់ការសម្រេចចិត្តដែលមានព័ត៌មានគ្រប់គ្រាន់
    - ធានាបាននូវការប្រព្រឹត្តិដោយយុត្តិធម៌ និងប្រកបដោយការគោរពចំពោះអតិថិជន ដោយមានការការពារប្រឆាំងនឹងការអនុវត្តដែលឈ្លានពាន ឬបំពាន
    - ធានាចំពោះភាពអាចស្វែងរកបាននៃយន្តការដែលអាចប្រើប្រាស់ សមស្រប មានប្រសិទ្ធភាព ទាន់ពេលវេលា និងឆ្លើយតបនឹងពាក្យបណ្តឹង និងការដោះស្រាយបញ្ហា។
- **ការកាត់បន្ថយ/ផែនការសកម្មភាព៖** វិនិយោគិនគួរតែបង្កើតផែនការដោះស្រាយហានិភ័យ និងផលប៉ះពាល់ចំពោះអតិថិជន ដែលត្រូវបានកំណត់ ដែលអាចរួមបញ្ចូលការផ្តល់អនុសាសន៍ដើម្បីផ្លាស់ប្តូរគោលនយោបាយ និងការអនុវត្តរបស់អ្នកផ្តល់សេវា និងផ្តល់ជំនួយបច្ចេកទេស។
- **លក្ខខណ្ឌតម្រូវនៃកិច្ចសន្យា៖** រួមបញ្ចូលកាតព្វកិច្ចនៃកិច្ចសន្យាជាក់លាក់ សម្រាប់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ក្នុងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។
- **ការពិនិត្យតាមដាន៖** តម្រូវឱ្យអ្នកផ្តល់សេវាហិរញ្ញវត្ថុរាយការណ៍ជាទៀងទាត់អំពីវឌ្ឍនភាពក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនៃកិច្ចសន្យារបស់ពួកគេ ទាក់ទងនឹងហានិភ័យ និងផលប៉ះពាល់ចំពោះអ្នកប្រើប្រាស់។
- **ការកសាងសមត្ថភាព៖** ពិចារណាបណ្តុះបណ្តាលអ្នកផ្តល់សេវាហិរញ្ញវត្ថុ អំពីការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងឧត្តមានុវត្តន៍នៃកិច្ចការពារអ្នកប្រើប្រាស់។

**ប្រភព៖** សៀវភៅណែនាំអំពីស្តង់ដារការពារអតិថិជន ពី Cerise + ក្រុមការងារការពារសង្គម (SPTF) មាននៅ ទីនេះ គោលការណ៍ការពារអតិថិជនពីយុទ្ធនាការឆ្លាតវៃ និង CGAP - មគ្គុទ្ទេសក៍ណែនាំផ្នែកបច្ចេកទេសសម្រាប់វិនិយោគិន ស្តីពីការអនុវត្តគោលការណ៍ការពារអតិថិជន មាននៅទីនេះ។

## ៤. ការវិភាគ និងគំហើញ

ផ្នែកនេះបង្ហាញពីការវិភាគរបស់ស៊ីអេអូ អំពីភាពអនុលោម របស់ IFC ចំពោះកាតព្វកិច្ច E&S របស់ខ្លួន ទាក់ទងនឹងបញ្ហានៃពាក្យបណ្ដឹងដែលបានលើកឡើងនៅក្នុងសំណុំរឿងនេះ។ នៅក្នុងការវិភាគនេះ ដូចបានយោងដល់ខាងលើ ស៊ីអេអូបានពិចារណាលើគោលជំហររបស់ IFC ដែលថា គោលនយោបាយ E&S មានបំណងដោះស្រាយហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម ដែលទាក់ទងនឹង*ការប្រើប្រាស់ចុងក្រោយនៃប្រាក់ចំណូល*ពីហិរញ្ញប្បទានរបស់ IFC។ ដូច្នេះ តាមទស្សនៈរបស់ IFC ការអនុវត្តការផ្តល់ប្រាក់កម្ចី បញ្ហាការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) និងផលប៉ះពាល់ដែលកើតឡើងលើអ្នកខ្ចីបន្ត នៅក្នុងបរិបទមីក្រូហិរញ្ញវត្ថុគឺ ស្ថិតនៅក្រៅវិសាលភាពនៃលក្ខខណ្ឌតម្រូវ E&S របស់ខ្លួន។[241]

ទោះបីជាយ៉ាងណាក៏ដោយ ការវិភាគរបស់ស៊ីអេអូមិនគាំទ្រទស្សនៈនេះទេ។ លក្ខខណ្ឌ និងការអនុវត្តមិនល្អដែលត្រូវបានចងក្រងជាឯកសារយ៉ាងទូលំទូលាយ ទាក់ទងនឹងការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ ដូចជា ការវាយតម្លៃមិនគ្រប់គ្រាន់លើសមត្ថភាពសងប្រាក់ បំណុលវ័ណ្ឌក និងវិធីសាស្ត្រប្រមូលបំណុលមានការឈ្លានពានអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់សង្គមយ៉ាងធ្ងន់ធ្ងរ រួមទាំងការបាត់បង់ដីធ្លី ការថយចុះនៃជីវភាពរស់នៅ ភាពក្រីក្រ និងគ្រោះថ្នាក់ដល់ជនជាតិដើមភាគតិចផងដែរ (សូមមើលផ្នែកទី១)។ ហានិភ័យ និងផលប៉ះពាល់ទាំងនេះ ទាក់ទងដោយផ្ទាល់ទៅនឹងគោលបំណង និងលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាព និងស្តង់ដារសមិទ្ធកម្មរបស់ IFC។ លើសពីនេះទៀត គោលនយោបាយនិរន្តរភាពរបស់ IFC ដែលកំណត់កាតព្វកិច្ច E&S របស់ខ្លួន អនុវត្តចំពោះគម្រោង IFC ទាំងអស់ និងវិសាលភាពពេញលេញនៃហានិភ័យ និងផលប៉ះពាល់ E&S របស់គម្រោងទាំងនោះ រួមទាំង "ផលប៉ះពាល់ពិសេសៗ" ណាមួយដែលមិនត្រូវបានលើកឡើងជាពិសេសនៅក្នុងគោលនយោបាយនេះ "លើកលែងតែត្រូវបានផាត់ចេញជាពិសេស"។[242] មិនមានការផាត់ចេញ ឬការដាក់កម្រិតលើការអនុវត្តក្របខណ្ឌនិរន្តរភាពរបស់ IFC ចំពោះអ្នកប្រើប្រាស់ហិរញ្ញវត្ថុ អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ឬជាទូទៅ អ្នកប្រើប្រាស់សេវាដែលផ្តល់ហិរញ្ញប្បទានដោយ IFC នោះទេ (ទោះបីជាសេវាហិរញ្ញវត្ថុ ដូចជា មីក្រូហិរញ្ញវត្ថុ ឬសេវាដទៃទៀត ដូចជា ការអប់រំ ឬការដឹកជញ្ជូន ជាដើម)។ តាមទស្សនៈរបស់ស៊ីអេអូ ដោយសារសកម្មភាពមីក្រូហិរញ្ញវត្ថុមិនត្រូវបានលើកលែង សកម្មភាពអាជីវកម្មរបស់អតិថិជនអន្តរការីហិរញ្ញវត្ថុរបស់ IFC គួរតែត្រូវបានកំណត់ វាយតម្លៃ និងគ្រប់គ្រង ជាផ្នែកមួយនៃការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យ E&S របស់ IFC ស្របតាមគោលនយោបាយនិរន្តរភាព។ ការវិភាគរបស់ស៊ីអេអូចំពោះសំណុំរឿងនេះ ត្រួតពិនិត្យភាពអនុលោមរបស់ IFC ចំពោះគោលនយោបាយ E&S របស់ខ្លួន ទាក់ទងនឹងការបញ្ចៀស និងការកាត់បន្ថយផលប៉ះពាល់សង្គម ដែលទាក់ទងនឹងសេវាមីក្រូហិរញ្ញវត្ថុ លើជនងាយរងគ្រោះ រួមទាំងដើមបណ្ដឹង គ្រួសារពួកគេ និងសហគមន៍របស់ពួកគេផងដែរ ដែលក្របខណ្ឌនិរន្តរភាពរបស់ IFC ព្យាយាមការពារ។

---

[241] សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត សូមមើលការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ដែលបានភ្ជាប់មកជាមួយរបាយការណ៍វាយតម្លៃរបស់ស៊ីអេអូ មាននៅ https://bit.ly/45muCUR។

[242] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ២០ ចែងថា "ការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកបរិស្ថាន និងសង្គមអនុវត្តចំពោះគ្រប់សកម្មភាពវិនិយោគរបស់ IFC។ សូមមើលកថាខណ្ឌ ១ ៣ និង ២២ និងកំណត់សម្គាល់ការណែនាំរបស់ IFC ចំពោះ PS1 កថាខណ្ឌ ១៦ និង ១៧ ផងដែរ។

ផ្នែកនេះវាយតម្លៃថាតើ IFC បានបំពេញកាតព្វកិច្ចទាំងនេះ នៅក្នុងបរិបទនៃការវិនិយោគចំនួន ១៣ ដែលត្រូវបានគ្របដណ្តប់ដោយការស៊ើបអង្កេតនេះដែរឬទេ។ ស៊ីអេអូកត់សម្គាល់ថា សេចក្តីសម្រេច និងគំហើញរបស់ខ្លួន ត្រូវបានដាក់កម្រិតចំពោះការវាយតម្លៃអំពីភាពអនុលោមរបស់ IFC ចំពោះលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងសង្គម (E&S) របស់ IFC ទាក់ទងនឹងការវិនិយោគរបស់ IFC ទាំង ១៣ នេះ និងចំពោះគ្រោះថ្នាក់ដែលពាក់ព័ន្ធ ដែលបានជួបប្រទះដោយដើមបណ្តឹងទាំង ១៨ នាក់ ដែលបានដាក់ពាក្យបណ្តឹង។ ក្នុងការបង្កើតគំហើញពាក់ព័ន្ធនឹងគ្រោះថ្នាក់ ដែលទាក់ទងនឹងភាពបដិលោមរបស់ IFC ចំពោះលក្ខខណ្ឌតម្រូវ E&S របស់ខ្លួននោះ ស៊ីអេអូបានពិចារណាលើសមិទ្ធកម្ម E&S របស់គម្រោង និងអនុគម្រោង។ ការពិចារណានេះមិនបង្កើតបានជាការវាយតម្លៃលើវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាទាំងមូលនោះទេ។

## ៤.១ អភិក្រមទូទៅរបស់ IFC ចំពោះការត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគ (ESDD) និងការត្រួតពិនិត្យការវិនិយោគមីក្រូហិរញ្ញវត្ថុ

ផ្នែកនេះនឹងត្រួតពិនិត្យសកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគ និងការត្រួតពិនិត្យ ទាក់ទងនឹងការចោទប្រកាន់របស់ដើមបណ្តឹង។

ដូចដែល IFC បានលើកឡើងនៅក្នុងការឆ្លើយតបរបស់ខ្លួនចំពោះពាក្យបណ្តឹង បច្ចុប្បន្ន IFC មិនអនុវត្តស្តង់ដារសមិទ្ធកម្មផ្នែក E&S របស់ខ្លួន ចំពោះការវិនិយោគមីក្រូហិរញ្ញវត្ថុ ដើម្បីកំណត់ និងគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងចំពោះអ្នកខ្ចីនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីឆ្នាំ២០១១ មក IFC បានចាត់វិធានការដើម្បីរួមបញ្ចូលការពិចារណាផ្នែកហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ នៅក្នុងដំណើរការវិនិយោគរបស់ខ្លួន ជាពិសេសនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ តាមរយៈ *យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់*។ យុទ្ធសាស្ត្រនេះ ដែលត្រូវបានសង្ខេបនៅក្នុងប្រអប់ទី១ អនុវត្តគោលការណ៍ការពារអតិថិជន និងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ (សូមមើលប្រអប់ទី២) ចំពោះការវិនិយោគលើមីក្រូហិរញ្ញវត្ថុតាមរយៈនាយកដ្ឋានហិរញ្ញវត្ថុ។

តាមរយៈក្របខណ្ឌនេះ IFC តម្រូវឱ្យអតិថិជន និងអតិថិជនបន្ត FI អនុវត្តស្តង់ដារនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អមួយចំនួន ដែលស៊ីអេអូបានកំណត់ថាពាក់ព័ន្ធនឹងការទប់ស្កាត់ផលប៉ះពាល់សង្គមអវិជ្ជមាន លើអ្នកខ្ចីនៅក្នុងការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ខ្លួន។

ដូច្នេះ នៅក្នុងការត្រួតពិនិត្យភាពអនុលោមរបស់ IFC ចំពោះគោលនយោបាយនិរន្តរភាព ស៊ីអេអូបានគិតគូរពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួននៅក្រោម *យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់* ដើម្បីលើកកម្ពស់មីក្រូហិរញ្ញវត្ថុដែលមានទំនួលខុសត្រូវជាងមុន។ ដោយប្រើអភិក្រមនេះ ស៊ីអេអូធានាថា ការវាយតម្លៃរបស់ខ្លួនលើភាពអនុលោមរបស់ IFC គឺផ្អែកលើការយល់ដឹងយ៉ាងពេញលេញ និងដោយយុត្តិធម៌ អំពីកិច្ចខិតខំប្រឹងប្រែងរបស់ IFC។ ជាចុងក្រោយ សំណួរស្នូលសម្រាប់ការត្រួតពិនិត្យភាពអនុលោមរបស់ស៊ីអេអូ គឺ ថាតើ IFC បានបំពេញតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាពដែរឬទេ ដោយមិនគិតពីក្របខណ្ឌផ្លូវការ ឬកម្មវិធី ដែលសកម្មភាពរបស់វាត្រូវអនុវត្តតាមនោះទេ។

វិសាលភាពដែលយុទ្ធសាស្ត្រនេះបំពេញតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយ E&S របស់ IFC មានពន្យល់បន្ថែមនៅក្នុងផ្នែក ៤.៣ នៃរបាយការណ៍នេះ។

**ប្រអប់ទី១៖ យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់របស់ IFC**
**សេចក្ដីសង្ខេបអំពីការអនុវត្តដែលពាក់ព័ន្ធ**

នៅកម្រិតគម្រោង៖

- ការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ៖ ជាធម្មតា IFC បានរួមបញ្ចូលអ្នកឯកទេសមីក្រូហិរញ្ញវត្ថុ ជាផ្នែកមួយនៃក្រុមការងារផ្នែកហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធ្វើការត្រួតពិនិត្យគោលនយោបាយ និងនីតិវិធីហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជន FI រួមទាំងថាតើអតិថិជនបានអនុវត្តតាមស្តង់ដារ GIIP ស្តីពីការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុដែរឬទេ។ ដំណើរការនេះមិនរួមបញ្ចូលការផ្ទៀងផ្ទាត់របស់ IFC លើការអនុវត្តគោលការណ៍ និងនីតិវិធីទាំងនេះនោះទេ។
- ការព្រមព្រៀងមានការបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងតាមផ្លូវច្បាប់៖ កិច្ចព្រមព្រៀងវិនិយោគមួយចំនួនរួមបញ្ចូលការព្រមព្រៀងមានការបញ្ជាក់ ដែលតម្រូវឱ្យមានការអនុលោមតាមគោលការណ៍ស្តីពីការការពារអតិថិជន និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ IFC (សូមមើលប្រអប់ទី២)។ គោលការណ៍ទាំងនេះជាញឹកញាប់ ត្រូវបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ប៉ុន្តែមិនមានកាតព្វកិច្ចរាយការណ៍របស់អតិថិជន ឬការផ្ទៀងផ្ទាត់ភាពអនុលោមរបស់ IFC ជាប់មកជាមួយនោះទេ។

ភាពអនុលោមតាមគោលការណ៍ទាំងនេះរបស់អតិថិជន ឬគោលនយោបាយ និងការអនុវត្តរបស់អតិថិជន ដែលត្រូវបានត្រួតពិនិត្យក្នុងអំឡុងពេលនៃការត្រួតពិនិត្យភាពត្រឹមត្រូវ មិនត្រូវបានពិនិត្យតាមដានដោយ IFC ក្នុងអំឡុងពេលនៃការត្រួតពិនិត្យការវិនិយោគនោះទេ។ ដូច្នេះ មិនមានការត្រួតពិនិត្យឯកទេសលើការអនុវត្តការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ នៅពេលដែលគម្រោងមួយត្រូវបានអនុម័តដោយ IFC នោះទេ។

នៅកម្រិតគោលនយោបាយតាមវិស័យ៖

- IFC បានធ្វើការជាមួយ និងគាំទ្ររដ្ឋាភិបាល សមាគមឧស្សាហកម្ម និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីបង្កើនសមត្ថភាពនៅក្នុងប្រទេស ពង្រឹងក្របខណ្ឌនិយ័តកម្ម និងផ្តល់សេវាទីប្រឹក្សាអំពីគោលនយោបាយ និងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។
- នៅកម្ពុជា IFC បានគាំទ្រដល់ការបង្កើតក្រុមហ៊ុនក្រេឌីតប៊្យូរកម្ពុជា (CBC) ដើម្បីពង្រឹងការវាយតម្លៃបំណុលនៅថ្នាក់ជាតិ បានផ្តល់ការប្រឹក្សាដល់រដ្ឋាភិបាលអំពីលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ និងបានផ្តល់ការប្រឹក្សា និងជាតុចូលដល់សមាគមឧស្សាហកម្មនានា ដូចជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងសមាគមធនាគារកម្ពុជា (ABC) ស្តីពីការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។

**ប្រអប់ទី២៖ គោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងការការពារអតិថិជនរបស់ IFC**[243]

- **ការបញ្ចៀសបំណុលវ័ណ្ឌក៖** អ្នកខ្ចី (IFC) នឹងចាត់វិធានការយ៉ាងសមហេតុផលដើម្បីធានាថា ឥណទាននឹងត្រូវបានបន្ត លុះត្រាតែអ្នកខ្ចីបានបង្ហាញថាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសងប្រាក់ ហើយប្រាក់កម្ចីនឹងមិនធ្វើឱ្យអតិថិជនប្រឈមនឹងហានិភ័យខ្ពស់នៃបំណុលវ័ណ្ឌកនោះទេ។
- **តម្លាភាព និងការកំណត់តម្លៃប្រកបដោយទំនួលខុសត្រូវ៖** ការកំណត់តម្លៃ ខ និងលក្ខខណ្ឌនៃផលិតផលហិរញ្ញវត្ថុនឹងមានតម្លាភាព និងត្រូវបានបង្ហាញយ៉ាងគ្រប់គ្រាន់ នៅក្នុងទម្រង់ដែលអាចយល់បាន សម្រាប់អតិថិជន។

---

[243] គោលការណ៍ទាំងនេះ ជាញឹកញាប់ ត្រូវបានរាយនៅក្នុងការព្រមព្រៀងនានា នៅក្នុងកិច្ចព្រមព្រៀងស្របច្បាប់របស់ IFC (សំណើសុំការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល IFC ឧបសម្ព័ន្ធ ក – គោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងការការពារអតិថិជន ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ https://bit.ly/4nenNuC ទំ. ១៤)។ គោលការណ៍ទាំងនេះមិនមានកាតព្វកិច្ចរាយការណ៍របស់អតិថិជន ឬការផ្ទៀងផ្ទាត់ភាពអនុលោមរបស់ IFC ជាប់មកជាមួយនោះទេ។ របាយការណ៍ស៊ើបអង្កេតរបស់ស៊ីអេអូពិចារណាលើការអនុវត្តគោលការណ៍ទាំងនេះដោយ IFC ចំពោះការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ខ្លួន លើកលែងចំពោះការកំណត់តម្លៃប្រកបដោយទំនួលខុសត្រូវ និងឯកជនភាពនៃទិន្នន័យ ដែលមិនពាក់ព័ន្ធនឹងការស៊ើបអង្កេតនេះទេ។

- **ការអនុវត្តការប្រមូលប្រាក់យ៉ាងសមស្រប៖** ការអនុវត្តការប្រមូលបំណុលរបស់អ្នកខ្ចី (IFC) នឹងមិនរំលោភបំពាន និងមិនបង្ខិតបង្ខំឡើយ។
- **ឥរិយាបថបុគ្គលិកប្រកបដោយក្រមសីលធម៌៖** បុគ្គលិករបស់អ្នកខ្ចី (IFC) នឹងអនុលោមតាមស្តង់ដារសីលធម៌កម្រិតខ្ពស់ ក្នុងការធ្វើអន្តរកម្មជាមួយអតិថិជនរបស់ខ្លួន ហើយអ្នកផ្តល់សេវានឹងធានាបាននូវការការពារយ៉ាងគ្រប់គ្រាន់ដើម្បីរកឃើញ និងកែតម្រូវអំពើពុករលួយ ឬការប្រព្រឹត្តមិនល្អចំពោះអតិថិជន។
- **យន្តការដោះស្រាយបណ្តឹងសារទុក្ខ៖** អ្នកខ្ចីនឹងមានយន្តការទាន់ពេលវេលា និងឆ្លើយតបនឹងការត្អូញត្អែរ និងការដោះស្រាយបញ្ហាសម្រាប់អតិថិជនរបស់ពួកគេ។
- **ឯកជនភាពនៃទិន្នន័យអតិថិជន៖** ឯកជនភាពនៃទិន្នន័យរបស់អតិថិជនម្នាក់ៗ នឹងត្រូវបានគោរព ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃយុត្តាធិការនីមួយៗ ហើយទិន្នន័យទាំងនោះមិនត្រូវប្រើប្រាស់សម្រាប់គោលបំណងដទៃទៀត ដោយមិនមានការអនុញ្ញាតយ៉ាងច្បាស់លាស់ពីអតិថិជននោះទេ។

## អភិក្រមរបស់ IFC នៅកម្រិតគម្រោង

ស្របតាម *យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់* របស់ខ្លួន IFC បានចាត់វិធានការដូចខាងក្រោម ទាក់ទងនឹងការស៊ើបអង្កេតភាពអនុលោមនេះ។ ចាប់ពីឆ្នាំ២០១១ មក[244] នៅប្រទេសកម្ពុជា IFC បានអនុវត្តជាទៀងទាត់ដូចខាងក្រោម៖

- បានរួមបញ្ចូលអ្នកឯកទេសមីក្រូហិរញ្ញវត្ថុក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវលើការវិនិយោគដែលពាក់ព័ន្ធ។ អ្នកឯកទេសមីក្រូហិរញ្ញវត្ថុ ជាធម្មតា ធ្វើការត្រួតពិនិត្យគោលនយោបាយ និងនីតិវិធីហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់អតិថិជន FI ដែលអាចកើតឡើង ដែលរួមបញ្ចូលថាតើអតិថិជនអនុវត្តតាមស្តង់ដារ GIIP លើ ចំពោះការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ដូចបានពិពណ៌នាខាងលើដែរឬទេ រួមទាំងការកំណត់តម្លៃប្រកបដោយតម្លាភាព អត្រាការប្រាក់ និងឯកជនភាពនៃទិន្នន័យផងដែរ។[245]

[244] នៅឆ្នាំ២០១១ ជាការឆ្លើយតបទៅនឹងវិបត្តិមីក្រូហិរញ្ញវត្ថុ ដូចជា វិបត្តិមួយនៅរដ្ឋ Andhra Pradesh (សូមមើលផ្នែក ១.១ ខាងលើ) កំណត់សម្គាល់ផ្ទៃក្នុងមួយបានគូសបញ្ជាក់ពីតម្រូវការក្នុងការរួមបញ្ចូលវិធានការមីក្រូហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដើម្បីការពារអតិថិជនមីក្រូហិរញ្ញវត្ថុពីការអនុវត្តដោយបង្ខិតបង្ខំ។ វានិយាយអំពីតម្រូវការនៃវិធានការ ដែលទាក់ទងនឹងការកំណត់តម្លៃប្រកបដោយតម្លាភាព ការបញ្ចៀសការជំពាក់បំណុលវ័ណ្ឌក កិច្ចសន្យាមានភាពយុត្តិធម៌ ផលិតផលសមស្រប ឯកជនភាពនៃទិន្នន័យ និងសីលធម៌របស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ។ កំណត់សម្គាល់នេះរំលេចការពិភាក្សានៅពេលនោះ ទាក់ទងនឹងតុល្យភាពដែលចាំបាច់ រវាងការត្រឡប់មកវិញ តួនាទីរបស់វិនិយោគិនផ្នែកពាណិជ្ជកម្មសុទ្ធសាធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ កិច្ចគាំពារសង្គម និងអភិបាលកិច្ចសាជីវកម្ម និងតម្រូវការរបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងវិនិយោគិននានា ដូចជា IFC ផងដែរ ដើម្បីមានតួនាទីក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសមស្រប និងកែលម្អប្រតិបត្តិការនីមួយៗរបស់ពួកគេ ដើម្បីធានាថា ឧស្សាហកម្មនេះស្ថិតនៅជួរមុខនៃហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ នៅខណៈពេលដែលទិដ្ឋភាពមួយចំនួននៃអនុសាសន៍ត្រូវបានយកមកអនុវត្ត និងរួមបញ្ចូលនៅក្នុងនីតិវិធីវិនិយោគរបស់ IFC ឬតាមរយៈសេវាទីប្រឹក្សានោះ ការផ្តល់យោបល់ដទៃទៀត ដូចជា ការផ្តល់យោបល់ឲ្យពិនិត្យតាមដានការអនុវត្តគោលការណ៍ការពារអតិថិជនតាមរយៈការរាយការណ៍ និងការពិនិត្យតាមដានជាទៀតទាត់ មិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការអនុវត្តរបស់ IFC នាពេលបច្ចុប្បន្ននោះទេ។

[245] អង្គភាព/នាយកដ្ឋានអ្នកឯកទេសមីក្រូហិរញ្ញវត្ថុរបស់ IFC ត្រូវបានកាត់បន្ថយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ពីអ្នកឯកទេសមីក្រូហិរញ្ញវត្ថុប្រហែល ៨-១០ នាក់ មកអ្នកឯកទេសមីក្រូហិរញ្ញវត្ថុពេញម៉ោងពីរនាក់ និងក្រៅម៉ោងមួយនាក់ប៉ុណ្ណោះ ដែលគ្រប់គ្រងការវិនិយោគមីក្រូហិរញ្ញវត្ថុនៅទូទាំងពិភពលោក។ លើសពីនេះទៀត ក្រុមការងារនេះត្រូវបានគាំទ្រដោយអ្នកឯកទេសមីក្រូហិរញ្ញវត្ថុពេញម៉ោងម្នាក់នៅអាហ្វ្រិក ដែលធ្វើការទាំងសេវាវិនិយោគ និងសេវាប្រឹក្សាយោបល់ និងអ្នកឯកទេសសេវាប្រឹក្សាយោបល់ពេញម៉ោងដែលធ្វើការនៅអាមេរិកឡាទីន ការីប៊ីន និងអាស៊ី ព្រមទាំងបុគ្គលិកពេញម៉ោងដទៃទៀត ដែលមានចំណេះដឹងផ្នែកមីក្រូហិរញ្ញវត្ថុ ដែលត្រូវបានអំពាវនាវឱ្យគាំទ្រលើបញ្ហាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ នៅក្នុងការវិនិយោគមួយចំនួន អ្នកឯកទេសផ្នែកធនាគារទូទៅ ដែលមិនមែនតែងតែមានចំណេះដឹងអំពីមីក្រូហិរញ្ញវត្ថុនោះទេ ពេលខ្លះបានបំពេញតួនាទីជាអ្នកឯកទេសមីក្រូហិរញ្ញវត្ថុ ហើយបានធ្វើការវាយតម្លៃហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ក្នុងដំណាក់កាលត្រួតពិនិត្យភាពត្រឹមត្រូវនៃការវិនិយោគ។

ដំណើរការនេះមិនរួមបញ្ចូលការផ្ទៀងផ្ទាត់ការអនុវត្តរបស់អតិថិជនលើគោលនយោបាយ និងនីតិវិធីទាំងនេះនោះទេ ហើយកម្រជាប់ពាក់ព័ន្ធនឹងការចុះទៅមើលទីតាំង និងការសម្ភាសជាមួយអ្នកខ្ចី ឬភាគីពាក់ព័ន្ធដទៃទៀតណាស់។ [246] ទាក់ទងនឹងថាតើការត្រួតពិនិត្យហិរញ្ញវត្ថុទាំងនេះបំពេញតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយ E&S របស់ IFC ដែរឬទេនោះ ស៊ីអេអូកត់សម្គាល់ថា IFC មានកាតព្វកិច្ច នៅក្រោមគោលនយោបាយនិរន្តរភាពរបស់ខ្លួន ធ្វើការផ្ទៀងផ្ទាត់ថាតើគោលនយោបាយ នីតិវិធី និងវិធានការដទៃទៀតរបស់អតិថិជន មានភាពគ្រប់គ្រាន់ក្នុងការបំពេញតាមស្តង់ដារសមិទ្ធកម្មដែរឬទេ។ នៅខណៈពេលដែល IFC មិនគ្រប់គ្រងប្រព័ន្ធគោលនយោបាយ ស្តង់ដារ និងនីតិវិធីរបស់អតិថិជនដោយផ្ទាល់នោះ វាត្រូវតែធ្វើឱ្យប្រាកដថា ប្រព័ន្ធនេះកំពុងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងបង្កើតលទ្ធផលដែលចង់បាន[247] (សូមមើលផ្នែក ៤.៣ សម្រាប់ការពិចារណារបស់ស៊ីអេអូ លើការត្រួតពិនិត្យហិរញ្ញវត្ថុទាំងនេះ)។

- បានបញ្ចូលកិច្ចព្រមព្រៀងដែលមានការឯកភាព នៅក្នុងការវិនិយោគមួយចំនួន ដែលតម្រូវឱ្យមានភាពអនុលោមតាមគោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងការការពារអតិថិជន។ ជាជាទូទៅ កិច្ចសន្យាបែបនេះបានបញ្ចូលឧបសម្ព័ន្ធមួយ ដែលមានបញ្ជាក់អំពីគោលការណ៍ ប៉ុន្តែមិនមានភ្ជាប់កាតព្វកិច្ចរាយការណ៍មកជាមួយនោះទេ។

ស៊ីអេអូកត់សម្គាល់ថា ភាពអនុលោមរបស់អតិថិជនតាមគោលការណ៍ទាំងនេះ ឬគោលនយោបាយ និងការអនុវត្តរបស់អតិថិជនផ្ទាល់ ដែលត្រូវបានត្រួតពិនិត្យក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ មិនត្រូវបានពិនិត្យតាមដានដោយ IFC ក្នុងអំឡុងពេលត្រួតពិនិត្យការវិនិយោគនោះទេ។ ដូច្នេះ មិនមានការត្រួតពិនិត្យឯកទេសលើការអនុវត្តការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ បន្ទាប់ពី IFC អនុម័តគម្រោងនោះទេ។

## អភិក្រមរបស់ IFC នៅកម្រិតវិស័យ

គួរកត់សម្គាល់ថា នៅខណៈពេលដែល IFC មិនមែនតែងតែធ្វើការដោយផ្ទាល់ជាមួយអតិថិជនម្នាក់ៗ ដើម្បីកែលម្អការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់ពួកគេ ដើម្បីជៀសវាង និងកាត់បន្ថយផលប៉ះពាល់សង្គមអវិជ្ជមាននៃប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនោះ វាមានភាពសកម្មក្នុងការដោះស្រាយផលប៉ះពាល់ទាំងនេះនៅកម្រិតវិស័យ និងឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ ជាពិសេស IFC បានគាំទ្រការកសាងសមត្ថភាពផ្នែកមីក្រូហិរញ្ញវត្ថុ និងសេវាទីប្រឹក្សា និងគំនិតផ្តួចផ្តើមដូចខាងក្រោម៖

[246] IFC បានជម្រាបជូនស៊ីអេអូថា ដំណើរការនេះលើសពីការត្រួតពិនិត្យឯកសារយោង ហើយប្រសិនបើមានការយល់ឃើញថាមានហានិភ័យខ្ពស់ IFC បានខិតខំគាំទ្រអតិថិជនឱ្យកែលម្អការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ពួកគេ ដោយមានឧទាហរណ៍នៅទូទាំងទ្វីបអាហ្វ្រិក អាស៊ីខាងត្បូង មជ្ឈិមបូព៌ា អាស៊ីបូព៌ា រួមទាំងប្រទេសកម្ពុជា និងប្រទេសថៃ។

[247] គោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គមរបស់ IFC (ឆ្នាំ២០១២)៖ កថាខណ្ឌ ២៧ (IFC ត្រួតពិនិត្យ ESMS និងការអនុវត្តការគ្រប់គ្រងហានិភ័យរបស់អតិថិជន ដើម្បីវាយតម្លៃភាពគ្រប់គ្រាន់ ធៀបនឹងស្តង់ដារសមិទ្ធកម្ម); កថាខណ្ឌ ២៨ (ការត្រួតពិនិត្យភាពត្រឹមត្រូវ រួមមាន ការត្រួតពិនិត្យការវាយតម្លៃ ការចុះត្រួតពិនិត្យទីតាំង ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការកំណត់ចន្លោះប្រហោង/សកម្មភាព); កថាខណ្ឌ ៤៥ (ការត្រួតពិនិត្យ រួមមាន ការពិនិត្យរបាយការណ៍ពិនិត្យតាមដាន វឌ្ឍនភាពនៃផែនការសកម្មភាព និងការធានាចំពោះភាពអនុលោមជាបន្តបន្ទាប់)។ សូមមើល IFC នីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គម (ឆ្នាំ២០១៦)៖ ទំ. ៩ ដែលបញ្ជាក់ថាការវាយតម្លៃ និងការគ្រប់គ្រងផលប៉ះពាល់គឺជាទំនួលខុសត្រូវរបស់អតិថិជន នៅខណៈពេលដែល IFC មានតួនាទីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សមិទ្ធកម្ម។

- នៅកម្រិតវិស័យ IFC បានធ្វើការជាមួយធនាគារជាតិនៃកម្ពុជា (NBC) តាំងពីឆ្នាំ២០០៦ ដើម្បីបង្កើតក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា (CBC) ដែលមានដំណើរការចាប់ពីឆ្នាំ២០១២។ CBC ដើរតួជាប្រភពចែករំលែកព័ត៌មានសម្រាប់ការរាយការណ៍អំពីឥណទាន និងជាឧបករណ៍មួយដើម្បីកាត់បន្ថយហានិភ័យនៃការជំពាក់បំណុលវ័ណ្ឌក របស់អ្នកខ្ចី។ គិតត្រឹមឆ្នាំ២០១៨ វាមានសមាជិកចំនួន ៨៦ ដែលរួមមាន MFIs និងធនាគារពាណិជ្ជដែលបានធ្វើនិយ័តកម្មទាំងអស់ ដែលត្រូវបានតម្រូវឲ្យផ្តល់ព័ត៌មានឥណទាន។ ស៊ីអេអូបានពិចារណាអំពីផលជះ និងប្រសិទ្ធភាពរបស់ CBC ក្នុងការកាត់បន្ថយការជំពាក់បំណុលវ័ណ្ឌក របស់អ្នកខ្ចី នៅក្នុងផ្នែក ៤.២.១ ខាងក្រោម នៅពេលពិភាក្សាអំពីគោលនយោបាយ និងការអនុវត្តរបស់អ្នកផ្តល់ប្រាក់កម្ចី នៅក្នុងសំណុំរឿងនេះ ដើម្បីវាយតម្លៃសមត្ថភាពសងបំណុលរបស់អ្នកខ្ចី។
- តាមរយៈក្រុមគ្រឹះស្ថានហិរញ្ញវត្ថុរបស់ខ្លួន នៅក្នុងសេវាទីប្រឹក្សា IFC បានធ្វើការជាមួយ NBC និង CBC ចាប់តាំងពីឆ្នាំ ២០១៣ ដើម្បីពង្រឹងក្របខណ្ឌការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCP) នៅកម្ពុជា ដែលបណ្តាលឱ្យមានកំណែទម្រង់នានា ដូចជា ប្រកាស (អនុក្រឹត្យ) ស្តីពីការដោះស្រាយពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់ ក្រមសីលធម៌ដែលបានកែសម្រួលសម្រាប់ធនាគារ និង MFIs និងឯកសារបន្ថែមនៃគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីជាបណ្តោះអាសន្នរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)។ លើសពីនេះទៀត IFC បានសហការជាមួយ CMA CBC និងយុទ្ធនាការឆ្លាតវៃ ដើម្បីផ្សព្វផ្សាយពីគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីនៅកម្ពុជា។[248] ស៊ីអេអូពិចារណាអំពីផលជះដែលបទប្បញ្ញត្តិ និងគំនិតផ្តួចផ្តើមទាំងនេះមាន ក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ នៅកម្រិតអតិថិជន និងអតិថិជនបន្តរបស់ IFC ម្នាក់ៗ នៅក្នុងផ្នែក ៤.២ ដល់ ៤.៥ ខាងក្រោម។
- នៅឆ្នាំ២០២០ IFC បានចាប់ផ្តើមអនុវត្តគម្រោងអសាធនភាព និងដំណោះស្រាយបំណុលសម្រាប់កម្ចីមិនដំណើរការ ដើម្បីពង្រឹងការអនុវត្តប្រកបដោយយុត្តិធម៌ និងតម្លាភាព។ គម្រោងសេវាទីប្រឹក្សានេះ កំពុងគាំទ្រដល់មជ្ឈមណ្ឌលមជ្ឈត្តកម្មពាណិជ្ជកម្មជាតិ (NCAC) នៃប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍការសម្របសម្រួលពាណិជ្ជកម្មជាយន្តការដោះស្រាយវិវាទជំនួស និងធ្វើការជាមួយក្រសួងយុត្តិធម៌ ដើម្បីពង្រឹងប្រព័ន្ធដោះស្រាយអសាធនភាព។ IFC បង្ហាញគម្រោងនេះជាផ្នែកមួយនៃកញ្ចប់វិធានការដែលខ្លួនបានអនុវត្ត ដើម្បីដោះស្រាយវិបត្តិបំណុលវ័ណ្ឌក នៅកម្ពុជា និងបញ្ហាសង្គមដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូកត់សម្គាល់ថា យន្តការដែលកំពុងបង្កើតឡើងនេះគឺ សម្រាប់អង្គភាពអាជីវកម្ម និងមិនមានភស្តុតាងដែលថា ពួកគេអាចបម្រើតម្រូវការ

[248] យុទ្ធនាការឆ្លាតវៃ គឺជាស្ថាប័នកំណត់ស្តង់ដារសកលសម្រាប់ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងការការពារអតិថិជន ដែលផ្តល់វិញ្ញាបនបត្រជូនស្ថាប័នសម្រាប់ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌នៃហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ យុទ្ធនាការឆ្លាតវៃត្រូវបានបញ្ចប់នៅឆ្នាំ២០២០ ហើយការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងស្តង់ដារការពារអតិថិជនត្រូវបានផ្ទេរទៅឱ្យក្រុមការងារអនុវត្តការងារសង្គម (SPTF) និង CERISE។ នៅខែកញ្ញា ឆ្នាំ២០២១ SPTF និង CERISE បានបើកដំណើរការគន្លងការពារអតិថិជន ដែលជាគំនិតផ្តួចផ្តើមថ្មីមួយដើម្បីគាំទ្រដល់ការអនុវត្តការការពារអតិថិជន។

ឬកាលៈទេសៈរបស់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុម្នាក់ៗបានទេ។[249]

- នៅឆ្នាំ២០២៤ តាមរយៈសេវាទីប្រឹក្សា IFC បានចាប់ផ្តើមគម្រោងមួយដើម្បីពង្រឹងក្របខណ្ឌ FCP កម្ពុជា រួមទាំងគាំទ្រ NBC ក្នុងការបង្កើត និងចេញបទប្បញ្ញត្តិទូទៅស្តីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ និងបង្កើនសមត្ថភាពត្រួតពិនិត្យនៅក្នុងវិស័យនេះ។ IFC ក៏បានធ្វើការជាមួយឧស្សាហកម្ម ដើម្បីបង្កើនសមត្ថភាពហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់ និងលើកកម្ពស់ការគ្រប់គ្រងដោយខ្លួនឯង និងការស្វែងរកមតិគាំទ្រសម្រាប់ការបង្កើតយន្តការដោះស្រាយវិវាទដោយឯករាជ្យសម្រាប់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុនៅកម្ពុជាផងដែរ។ គម្រោងនេះនៅដំណាក់កាលពិគ្រោះយោបល់ដំបូង (រំពឹងថានឹងបញ្ចប់នៅឆ្នាំ២០២៨) និងមិនទាន់មានផលជះដោយផ្ទាល់លើគោលនយោបាយ និងការអនុវត្តរបស់អតិថិជន និងអតិថិជនបន្តរបស់ IFC នៅក្នុងសំណុំរឿងនេះទេ។

លើសពីនេះទៀត IFC បានផ្តល់សេវាទីប្រឹក្សាជាច្រើនដល់គ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា រួមទាំងគ្រឹះស្ថានមួយចំនួនក្នុងចំណោមគ្រឹះស្ថានទាំងប្រាំមួយ ដែលត្រូវបានគ្របដណ្តប់នៅក្នុងសំណុំរឿងនេះដែរ ដើម្បីគាំទ្រការធ្វើពាណិជ្ជកម្ម កែលម្អអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងហានិភ័យ[250] និងនាពេលថ្មីៗនេះ លើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ (សូមមើលផ្នែក ១.២ ខាងលើ សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត)។ ឧទាហរណ៍ នៅឆ្នាំ២០២១ IFC បានគាំទ្រការវាយតម្លៃលើការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ធនាគារហត្ថា និងផ្តល់ការណែនាំជាបន្តបន្ទាប់ដល់ធនាគារ ក្នុងការអនុវត្តអនុសាសន៍នៃការវាយតម្លៃនោះ។ IFC ចាត់ទុកកិច្ចខិតខំប្រឹងប្រែងនេះជាផ្នែកមួយនៃគំនិតផ្តួចផ្តើមដ៏ទូលំទូលាយ ក្នុងការគាំទ្រអតិថិជននៅកម្ពុជា ក្នុងការកែលម្អការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវតាមពេលវេលាកំណត់។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលធ្វើរបាយការណ៍នេះ ការគាំទ្រនេះត្រូវបានផ្តល់ជូនធនាគារហត្ថាតែមួយប៉ុណ្ណោះ (រៀបរាប់លម្អិតបន្ថែម នៅក្នុងផ្នែក ៤.៣ ខាងក្រោម)។

ដូចបានទទួលស្គាល់ដោយ IFC កិច្ចខិតខំប្រឹងប្រែងនៅកម្រិតវិស័យទាំងនេះបានឆ្លុះបញ្ចាំងពីកង្វល់ដែលកំពុងកើតឡើង ទាក់ទងនឹងហានិភ័យសង្គម និងផលប៉ះពាល់នៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងផ្តោតលើគោលដៅចុងក្រោយនៃការកែលម្អការអនុវត្ត និងគោលនយោបាយរបស់គ្រឹះស្ថានផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ។ ស៊ីអេអូ

[249] ជាផ្នែកមួយនៃការស៊ើបអង្កេតនេះ ស៊ីអេអូបានចូលរួមជាមួយ NCAC ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីវិសាលភាព និងតួនាទីជាសក្តានុពលរបស់ខ្លួនក្នុងការដោះស្រាយវិវាទ ពាក់ព័ន្ធនឹងអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ។ នៅខណៈពេលដែលក្របខណ្ឌរបស់ NCAC គ្របដណ្តប់លើវិវាទពាណិជ្ជកម្ម និងតាមទ្រឹស្តី អនុញ្ញាតឱ្យមានការដាក់បញ្ចូលទាំងអ្នកខ្ចី និងអ្នកផ្តល់កម្ចីនៅក្នុងដំណើរការមជ្ឈត្តកម្មនោះ អាណត្តិរបស់ NCAC មិនត្រូវបានរៀបចំឡើងជាពិសេសដើម្បីដោះស្រាយវិវាទពាក់ព័ន្ធនឹងអតិថិជនមីក្រូហិរញ្ញវត្ថុនោះទេ។ នៅក្នុងការអនុវត្តជាក់ស្តែង NCAC បានដោះស្រាយប្រហែល ៤០ ករណី មកទល់បច្ចុប្បន្ន ដោយមានតម្លៃនៃការទាមទារចាប់ពី ៦.០០០ ដល់ ២៩ លានដុល្លារអាមេរិក។ សូមមើល៖ NCAC របាយការណ៍ប្រចាំឆ្នាំសម្រាប់ឆ្នាំ២០២២ https://bit.ly/4j8tli0 និង NCAC របាយការណ៍ប្រចាំឆ្នាំ សម្រាប់ឆ្នាំ២០២៣ និងត្រីមាសទី១ នៃឆ្នាំ២០២៤ https://bit.ly/4j4fYEZ។ គួរកត់សម្គាល់ថា NCAC បានជូនដំណឹងដល់ស៊ីអេអូថា ករណីទាំងនេះមិនពាក់ព័ន្ធនឹងអ្នកខ្ចីមីក្រូហិរញ្ញវត្ថុនោះទេ។ ស្រដៀងគ្នានេះដែរ ការពង្រឹងប្រព័ន្ធដោះស្រាយអសាធនភាព នៅក្រោមច្បាប់ស្តីពីអសាធនភាព ឆ្នាំ២០០៧ ដែលគាំទ្រដោយ IFC ហាក់ដូចជាត្រូវបានរៀបចំឡើងសម្រាប់អង្គភាពអាជីវកម្មជាចម្បង។ សូមមើល៖ https://bit.ly/45dKUz7 ស៊ីអេអូរកមិនឃើញភស្តុតាងនៃយន្តការនៅក្នុងក្របខណ្ឌណាមួយ ដែលត្រូវបានកែសម្រួលជាពិសេស តាមតម្រូវការ ឬកាលៈទេសៈរបស់អតិថិជនមីក្រូហិរញ្ញវត្ថុនីមួយៗនោះទេ។

[250] ឧទាហរណ៍ IFC បានផ្តល់ជំនួយបច្ចេកទេស និងការគាំទ្រដល់អេស៊ីលីដា អស់រយៈពេលជាច្រើនឆ្នាំ ដើម្បីកែប្រែវាពី NGO ទៅជាធនាគារពាណិជ្ជនៅឆ្នាំ២០០៣។ IFC ក៏បានធ្វើការវិភាគអំពីសមិទ្ធលទ្ធភាព និងចន្លោះប្រហោងនៃការផ្លាស់ប្តូរធនាគារហត្ថា ពី MFI ទៅជាធនាគារផងដែរ ដោយជួយត្រួសត្រាយផ្លូវសម្រាប់ការផ្លាស់ប្តូរស្ថាប័ននេះ នៅឆ្នាំ២០២០ (សូមមើលផ្នែកទី ២ ខាងលើ)។

បានគិតគូរពីគំនិតផ្តួចផ្តើមទាំងនេះនៅក្នុងវិស័យ ឧស្សាហកម្ម និងនៅកម្រិតអតិថិជន នៅក្នុងករណីរបស់ធនាគារហត្ថា (សូមមើលផ្នែក ៤.៣-៤.៥ ខាងក្រោម)។

### ៤.២ ការពិចារណាលើសមិទ្ធកម្ម E&S នៃគម្រោង និងអនុគម្រោងរបស់ IFC ទាក់ទងនឹងបញ្ហានៃពាក្យបណ្តឹង ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យរបស់ IFC

បញ្ហានៃពាក្យបណ្តឹង ដែលបានលើកឡើងនៅក្នុងសំណុំរឿងនេះ ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃគោលនយោបាយ E&S របស់ IFC ទាក់ទងនឹងជនងាយរងគ្រោះ ជនជាតិដើមភាគតិច និងលទ្ធភាពប្រើប្រាស់យន្តការបណ្តឹងសារទុក្ខបានយ៉ាងគ្រប់គ្រាន់។ នៅផ្នែក ៤.២ ដល់ ៤.៥ ស៊ីអេអូត្រួតពិនិត្យការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យរបស់ IFC លើអតិថិជនរបស់ខ្លួន ចំពោះបញ្ហាទាំងនេះ ដោយ៖

១. ពិចារណាលើសមិទ្ធកម្ម E&S ដែលពាក់ព័ន្ធ របស់អតិថិជន និងអតិថិជនបន្ត ជាពិសេសការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់ពួកគេ ទាក់ទងនឹងបញ្ហាដែលបានលើកឡើង[251]
២. ត្រួតពិនិត្យសកម្មភាពរបស់ IFC ទាក់ទងនឹងជនងាយរងគ្រោះ និងការអនុលោមតាមគោលនយោបាយ E&S របស់ខ្លួន
៣. ត្រួតពិនិត្យសកម្មភាពរបស់ IFC ក្នុងអំឡុងពេលនោះ ទាក់ទងនឹងជនជាតិដើមភាគតិច និងការអនុលោមតាមគោលនយោបាយ E&S របស់ខ្លួន
៤. ត្រួតពិនិត្យមើលសកម្មភាពរបស់ IFC ទាក់ទងនឹងយន្តការបណ្តឹងសារទុក្ខរបស់អតិថិជន និងអតិថិជនបន្ត និងការអនុលោមតាមគោលនយោបាយ E&S របស់ខ្លួន។

ការវិភាគភាពអនុលោមរបស់ស៊ីអេអូនៅខាងក្រោម ត្រួតពិនិត្យសកម្មភាពរបស់ IFC នៅក្នុងគម្រោងទាំង ១៣។[252] សកម្មភាពនេះរួមបញ្ចូលទាំងសកម្មភាពរបស់មន្ត្រី E&S និងសមាជិកក្រុមវិនិយោគ ដូចជា អ្នកឯកទេសផ្នែកមីក្រូហិរញ្ញវត្ថុ ឬឧស្សាហកម្ម ដែលបានត្រួតពិនិត្យការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន តាមទស្សនៈហិរញ្ញវត្ថុ។ ការវិភាគនេះវាយតម្លៃលើសង្គតិភាពនៃសកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យ ជាមួយគោលនយោបាយនិរន្តរភាពរបស់ IFC រួមទាំងការព្យាយាមធានាថាអតិថិជន និងអតិថិជនបន្តបានប្រកាន់ខ្ជាប់នូវស្តង់ដារសមិទ្ធភាពរបស់ IFC ដោយមិនគិតថាតើសកម្មភាពទាំងនោះត្រូវបានអនុវត្តដោយអ្នកឯកទេសផ្នែក E&S ឬអ្នកឯកទេសនៃឧស្សាហកម្មមីក្រូហិរញ្ញវត្ថុដែរឬអត់នោះទេ។

---

[251] គោលនយោបាយស៊ីអេអូ (កថាខណ្ឌ ១១៤) ចែងថា "ការស៊ើបអង្កេតភាពអនុលោមមិនបង្កើតគំហើញអំពីភាពបដិលោម ទាក់ទងនឹងគម្រោង ឬអនុគម្រោងណាមួយឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងការបង្កើតគំហើញទាក់ទងនឹងគ្រោះថ្នាក់ និងថាតើមានគ្រោះថ្នាក់ណាមួយទាក់ទងនឹងភាពបដិលោមរបស់ IFC/MIGA ចំពោះគោលនយោបាយ E&S របស់ខ្លួនដែរឬទេនោះ ស៊ីអេអូនឹងវាយតម្លៃការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ IFC/MIGA លើលក្ខខណ្ឌតម្រូវនៃ E&S នៅកម្រិតគម្រោង ឬអនុគម្រោង និងពិចារណាលើសមិទ្ធកម្មផ្នែកបរិស្ថាន និងសង្គមនៅកម្រិតគម្រោង ឬអនុគម្រោង"។

[252] ពាក្យបណ្តឹងត្រូវបានដាក់ដោយដើមបណ្តឹងមួយក្រុម ដែលមាន ១៨ គ្រួសារ ដែលជាអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា។ BFIs ទាំងប្រាំមួយ នៅកម្ពុជា ដែលការអនុវត្តរបស់ពួកគេជាកម្មវត្ថុនៃពាក្យបណ្តឹង រួមមាន អេស៊ីលីដា អម្រ៊ីត ធនាគារហត្ថា ប្រាសាក់ អិលអូអិលស៊ី និងស្ថាបនា។ អតិថិជនផ្ទាល់របស់ IFC ចំនួនប្រាំពីរ ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ រួមមាន អេស៊ីលីដា, អម្រ៊ីត, ធនាគារហត្ថា, MEF, MIFA, ក្រុមហ៊ុន North Haven Thai និង Advans។ សរុបមក សំណុំរឿងនេះជាប់ពាក់ព័ន្ធនឹងគម្រោងវិនិយោគរបស់ IFC ចំនួន ១៣ គម្រោង ដែលគាំទ្រអតិថិជនដែលផ្តល់ប្រាក់កម្ចីដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs)។

ការសម្រេចថាតើ IFC បានអនុលោមតាមកាតព្វកិច្ចរបស់ខ្លួន នៅក្រោមក្របខណ្ឌនិរន្តរភាព ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងត្រួតពិនិត្យការវិនិយោគរបស់ខ្លួនឬអត់ដែរឬទេនោះ តម្រូវឱ្យមានការពិចារណាលើវិសាលភាព ដែលការអនុវត្តរបស់អតិថិជន និងអតិថិជនបន្តរបស់ IFC ស្របនឹងលក្ខខណ្ឌតម្រូវ E&S របស់ IFC រួមទាំង GIIP និងច្បាប់ជាតិដែលពាក់ព័ន្ធផងដែរ ដែលត្រូវបានរចនាឡើងដើម្បីបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់សង្គមអវិជ្ជមានលើប្រជាជនងាយរងគ្រោះ និងជនជាតិដើមភាគតិច។[253]

ក្នុងអំឡុងពេលវិនិយោគនេះ ស៊ីអេអូបានត្រួតពិនិត្យគោលនយោបាយ និងការអនុវត្តរបស់អតិថិជន និងអតិថិជនបន្ត ជា FI ចំនួនប្រាំមួយ (អេស៊ីលីដា អម្រឹត ធនាគារហត្ថា អិលអូអិលស៊ី ប្រាសាក់ និងស្ថាបនា) តាមរយៈការត្រួតពិនិត្យឯកសារ កិច្ចសម្ភាសជាមួយបុគ្គលិកទីស្នាក់ការកណ្តាល និងបុគ្គលិកសាខានៃគ្រឹះស្ថានទាំងប្រាំមួយ និងកិច្ចសម្ភាសជាមួយអ្នកខ្ចីដែលមកពីគ្រឹះស្ថានទាំងប្រាំមួយនេះផងដែរ។ ស៊ីអេអូក៏បានសម្ភាសអ្នកគ្រប់គ្រងមូលនិធិ MEF, MIFA, Advans និង North Haven Thai ផងដែរ។ ការត្រួតពិនិត្យនេះ ត្រូវបានជូនដំណឹងបន្ថែមដោយព័ត៌មានដែលមានជាសាធារណៈ និងការពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សា និងអ្នកជំនាញផ្នែកឧស្សាហកម្ម (សូមមើលផ្នែក ៣.៦)។

### ៤.២.១ ការពិចារណាអំពីសមិទ្ធកម្មបរិស្ថាន និងសង្គមរបស់ IFC ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃ PS1 ពាក់ព័ន្ធនឹងប្រជាជនដែលងាយរងគ្រោះ

នៅក្រោមគោលនយោបាយនិរន្តរភាពរបស់ខ្លួន IFC ប្តេជ្ញាចិត្តធានាថា សោហ៊ុយនៃការអភិវឌ្ឍសេដ្ឋកិច្ចមិនធ្លាក់លើជនក្រីក្រ ឬងាយរងគ្រោះដោយអសមាមាត្រនោះទេ និងព្យាយាមការធានាថា តាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវ ការពិនិត្យតាមដាន និងការគ្រប់គ្រងរបស់ខ្លួន សកម្មភាពដែលខ្លួនផ្តល់ហិរញ្ញប្បទាន ត្រូវបានអនុវត្តស្របតាមស្តង់ដារសមិទ្ធកម្ម។ ដើម្បីសម្រេចគោលដៅនេះ ស្តង់ដារសមិទ្ធកម្មទី១ តម្រូវឲ្យអតិថិជនកំណត់អត្តសញ្ញាណក្រុមដែលងាយរងគ្រោះ ឬមានការលំបាក វាយតម្លៃហានិភ័យមិនសមាមាត្រចំពោះពួកគេ និងអនុវត្តវិធានការនានាដើម្បីបញ្ចៀសគ្រោះថ្នាក់ និងធានាថា ពួកគេមិនមានការលំបាកក្នុងការចែករំលែកអត្ថប្រយោជន៍គម្រោងនោះទេ។

អតិថិជន FI របស់ IFC ត្រូវតែបង្កើត និងដំណើរការប្រព័ន្ធគ្រប់គ្រង E&S ស្របតាម PS1។[254] ក្នុងការបង្កើតប្រព័ន្ធនេះ អតិថិជនគួរតែកំណត់ហានិភ័យ និងផលប៉ះពាល់ ហើយអនុវត្តវិធានការកាត់បន្ថយ យោងតាម GIIP ព្រមទាំងកំណត់ក្រុម "មានការលំបាក ឬងាយរងគ្រោះ" និងអនុវត្ត "វិធានការខុសៗគ្នា ដូច្នេះផលប៉ះពាល់អវិជ្ជមានមិនធ្លាក់មកលើពួកគេដោយមិនសមាមាត្រ"។[255] PS1 ក៏តម្រូវឲ្យបុគ្គលិករបស់អតិថិជន FI ដែលប្រាស្រ័យទាក់ទងជាមួយបុគ្គល ឬក្រុមដែលងាយរងគ្រោះ ឬជួបការលំបាក មានសមត្ថកិច្ចក្នុងការ

[253] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ១១៤។ របាយការណ៍នេះយោងដល់គោលនយោបាយ និងការអនុវត្តដែលត្រូវបានពិចារណាដោយស៊ីអេអូ នៅពេលស៊ើបអង្កេត។ គោលនយោបាយ និងការអនុវត្តទាំងនេះអាចមានការប្រែប្រួល ដោយសារសេចក្តីសន្និដ្ឋាននៃការស៊ើបអង្កេត។

[254] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៣ និង ៣៥ និង សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨-២៩។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

[255] PS1 ឆ្នាំ២០១២ កថាខណ្ឌ ១២។ សម្រាប់ការវិនិយោគនៅ MEF សូមមើល PS1 ឆ្នាំ២០០៦ កថាខណ្ឌ ១២។ សម្រាប់ការវិនិយោគនៅ Advans សូមមើល ESRP ឆ្នាំ១៩៩៨ កថាខណ្ឌ ២២ ជើងទំព័រទី ៧។

ស្វែងយល់ពីបញ្ហាជាក់លាក់ដែលពាក់ព័ន្ធ ទាក់ទងនឹងបុគ្គល ឬក្រុមទាំងនោះ ដែលអាចធានាចំពោះការបណ្ដុះបណ្ដាលជាក់លាក់ផងដែរ។[256]

GIIP បង្ហាញថា ផលប៉ះពាល់អវិជ្ជមានលើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុគួរតែត្រូវបានទប់ស្កាត់ និងកាត់បន្ថយ តាមរយៈការរួមបញ្ចូលស្តង់ដារនានានៅក្នុងគោលនយោបាយ និងនីតិវិធីរបស់ BFIs ដែលព្យាយាមកាត់បន្ថយផលប៉ះពាល់អវិជ្ជមានជាអប្បបរមា។ ស្តង់ដារដែលពាក់ព័ន្ធ ទាក់ទងនឹងការចោទប្រកាន់ ដែលបានលើកឡើងនៅក្នុងសំណុំរឿងនេះគឺថា អ្នកផ្តល់សេវាហិរញ្ញវត្ថុគួរតែ៖[257]

- ធានាថាមានការរចនាផលិតផលសមស្រប និងការវាយតម្លៃសមត្ថភាពសងប្រាក់ ដើម្បីទប់ស្កាត់ការជំពាក់បំណុលវ័ណ្ឌក និងជៀសវាងគ្រោះថ្នាក់ ដូចជា ការបាត់បង់ដីធ្លី ការថយចុះនៃមុខរបរចិញ្ចឹមជីវិត និងការធ្វើឲ្យជនងាយរងគ្រោះកាន់តែក្រីក្រថែមទៀត
- ផ្តល់ព័ត៌មានច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលា ដើម្បីអនុញ្ញាតឲ្យប្រជាជនដែលអាចរងផលប៉ះពាល់ ធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់
- ធានាបាននូវការប្រព្រឹត្តិដោយយុត្តិធម៌ និងប្រកបដោយការគោរពចំពោះអតិថិជន ដោយមានការការពារយ៉ាងគ្រប់គ្រាន់ចំពោះការអនុវត្តដែលឈ្លានពាន ឬបំពាន ដែលអាចមានផលប៉ះពាល់យ៉ាងខ្លាំងក្លាចំពោះប្រជាជនដែលងាយរងគ្រោះ។

ចំពោះលក្ខខណ្ឌតម្រូវនៃក្របខណ្ឌនិរន្តរភាព ដែលតម្រូវឱ្យអតិថិជនអនុលោមតាមច្បាប់ជាតិ ដែលពាក់ព័ន្ធ[258] នោះ ច្បាប់កម្ពុជាចែងថា ម្ចាស់បំណុលមិនមានអំណាចដោយផ្ទាល់ ក្នុងការរឹបអូសវត្ថុបញ្ចាំនោះទេ ហើយត្រូវតែអនុវត្តតាមដំណើរការតុលាការ[259]។ វាកំណត់បន្ថែមទៀតថា អាជ្ញាធរមូលដ្ឋាន (ឧ. នគរបាល មេភូមិ មេឃុំ និងអភិបាលស្រុក) ត្រូវបានហាមឃាត់មិនឱ្យចូលរួមក្នុងសកម្មភាពរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ឬ "ធ្វើសកម្មភាពរួមគ្នា" ជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុនោះទេ លើកលែងតែអនុវត្តតាមដីកាតុលាការ ដើម្បីជៀសវាងការយល់ច្រឡំរវាងសកម្មភាពរបស់រដ្ឋាភិបាល និងវិស័យឯកជន។ វាក៏ហាមឃាត់យ៉ាងជាក់លាក់ មិនឲ្យអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ ធ្វើសកម្មភាពជាភ្នាក់ងារលក់ សាក្សី ឬអ្នកធានា ឬចូលរួមក្នុងការផ្សាយពាណិជ្ជកម្មអំពីប្រាក់កម្ចី និងការប្រមូលបំណុលនោះទេ។[260] ជាចុងក្រោយ ច្បាប់ជាតិហាមឃាត់អ្នកផ្តល់សេវាមិនឲ្យ

[256] PS1 ឆ្នាំ២០១២ កថាខណ្ឌ ១៨ និង GN៧៩។ សម្រាប់ការវិនិយោគនៅ MEF សូមមើល PS1 ឆ្នាំ២០០៦ កថាខណ្ឌ ១៨។

[257] សូមមើល យុទ្ធនាការឆ្លាតវៃ គោលការណ៍ការពារអតិថិជន https://bit.ly/3Fqg2AR; មជ្ឈមណ្ឌលបរិយាប័ន្នហិរញ្ញវត្ថុ Accion ការដាក់គោលការណ៍ឱ្យដំណើរការ៖ ការណែនាំលម្អិតអំពីគោលការណ៍ការពារអតិថិជន ការការពារ និងការផ្តល់ភាពអង់អាចដល់អ្នកប្រើប្រាស់ហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ https://bit.ly/4kw6Dao និង Cerise+ SPTF ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ទំ. ១៩ https://bit.ly/41RDorH។

[258] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៥ និងទិដ្ឋភាពទូទៅអំពីស្តង់ដារសមិទ្ធកម្ម ឆ្នាំ២០១២ កថាខណ្ឌ ៥។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨, ទិដ្ឋភាពទូទៅអំពីស្តង់ដារសមិទ្ធកម្ម ឆ្នាំ ២០០៦ កថាខណ្ឌ ៣ និងសម្រាប់ការវិនិយោគនៅ Advans, IFC OP ៤.០១ កថាខណ្ឌ ៩។

[259] មាត្រា ៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ឆ្នាំ២០០៦។

[260] ក្រសួងមហាផ្ទៃ (ឆ្នាំ២០១៧)។ បទបញ្ជារបស់ក្រសួង (ប្រកាស) លេខ ៥៥៦ ស/ជ/ណ ស្តីពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង

អនុវត្តគ្រប់ទម្រង់នៃការគំរាមកំហែង និងការបំភិតបំភ័យ នៅក្នុងដំណើរការទារប្រាក់កម្ចីនោះទេ។[261]

ក្នុងការវាយតម្លៃភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចរបស់ខ្លួននៅក្រោមគោលនយោបាយនិរន្តរភាព ស៊ីអេអូពិចារណាលើសមិទ្ធកម្ម E&S នៃគម្រោង និងអនុគម្រោង ដែលផ្តល់ហិរញ្ញប្បទានដោយ IFC។ ជាផ្នែកមួយនៃការត្រួតពិនិត្យឡើងវិញនេះ ស៊ីអេអូបានកត់សម្គាល់ការអនុវត្តសំខាន់ៗចំនួនបីប្រភេទ ដែលអាចបានរួមចំណែកដល់ផលប៉ះពាល់អវិជ្ជមានលើប្រជាជនងាយរងគ្រោះ។ ការអនុវត្តទាំងនេះ ក្នុងករណីមួយចំនួន នៅពេលវាស់ស្ទង់ដោយ GIIP និងច្បាប់ជាតិដែលអាចអនុវត្តបាន នៅក្រោម PS1 បង្ហាញពីចន្លោះប្រហោងដែលត្រូវតែដោះស្រាយដើម្បីការពារក្រុមជនងាយរងគ្រោះ។ ការអនុវត្តទាំងនេះ ដែលបានបង្ហាញនៅខាងក្រោម មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការវាយតម្លៃរបស់ស៊ីអេអូលើភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ និងការគ្រប់គ្រងរបស់ខ្លួន នៅក្រោមក្របខណ្ឌនិរន្តរភាព។

*a) ការអនុម័តប្រាក់កម្ចីលើសលុប លើសពីសមត្ថភាពសងប្រាក់*

ប្រាក់កម្ចីដែលផ្តល់ជូនប្រជាជនដែលមានប្រាក់ចំណូលទាប ដោយអតិថិជន និងអតិថិជនបន្តរបស់ IFC អាចមានទំហំធំ រហូតដល់ ៥0.000 ដុល្លារ។[262] នៅខណៈពេលដែលមិនមានការរឹតបន្តឹងច្បាស់លាស់លើទំហំប្រាក់កម្ចីនៅកម្ពុជានោះ PS1 តម្រូវឲ្យអតិថិជន និងអតិថិជនបន្តរបស់ IFC មាន ESMS ដែលអនុលោមតាម PS1 ដែលកំណត់ និងអនុម័តវិធានការពិសេសៗ សម្រាប់ប្រជាជនដែលងាយរងគ្រោះ និងអនុវត្តតាមស្តង់ដារ GIIP រួមទាំងវិធានការទាក់ទងនឹងការរចនាផលិតផល ព័ត៌មាន និងការប្រព្រឹត្តដោយគោរពចំពោះអតិថិជនដែលបានរៀបរាប់ខាងលើ។ ជាលទ្ធផល វាទាមទារឱ្យអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុនៅក្នុងសំណុំរឿងនេះ ចាត់វិធានការសមស្របនៅគ្រប់ដំណាក់កាលនៃដំណើរការឥណទាន ដើម្បីផ្ទៀងផ្ទាត់សមត្ថភាពរបស់អ្នកខ្ចីក្នុងការសងប្រាក់ និងការពារអតិថិជនពីការខ្ចីប្រាក់ច្រើនជាងចំនួនដែលពួកគេអាចសងបាន ឬប្រើប្រាស់ផលិតផល

---

ប្រតិបត្តិករឥណទានជនបទ ភ្នំពេញ។ បទបញ្ជានេះហាមឃាត់អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិមិនឲ្យចូលរួមជាមួយ MFIs នោះទេ ដើម្បីបញ្ចៀសការយល់ច្រឡំរវាងរដ្ឋ និងវិស័យឯកជន ក្នុងចំណោមប្រជាជនទូទៅ។ ជាពិសេស បញ្ញត្តិទីពីរនៅក្នុងបទបញ្ជានេះ ណែនាំដូចតទៅ៖ "លើកលែងតែត្រូវបានតម្រូវឲ្យចូលរួមតាមផ្លូវច្បាប់ ក្នុងការអនុវត្តសាលក្រមតុលាការ អាជ្ញាធរថ្នាក់ស្រុក/ក្រុង/ខណ្ឌ ឃុំ/សង្កាត់ និងភូមិ មិនត្រូវធ្វើសកម្មភាពរួមគ្នាជាមួយធនាគារឯកជន MFIs និងប្រតិបត្តិករឥណទានជនបទនោះទេ (ដែលអាចបង្កការយល់ច្រឡំក្នុងចំណោមប្រជាជនទូទៅថា ធនាគារ MFIs និងប្រតិបត្តិករទាំងនេះ ជាកម្មសិទ្ធិរបស់រដ្ឋ) រួមទាំងការដើរតួជាអ្នកធានានៅក្នុងប្រតិបត្តិការប្រាក់កម្ចី ឬជាភ្នាក់ងារ ឬអ្នកធានាសងប្រាក់កម្ចី ឬទាមទារឲ្យមានការសងប្រាក់ពីប្រជាជន ធ្វើការផ្សាយពាណិជ្ជកម្មសម្រាប់ស្ថាប័នហិរញ្ញវត្ថុណាមួយ ឬចូលរួមក្នុងការរិបអូសវត្ថុបញ្ចាំរបស់ប្រជាជន"។ *[ឯកសារច្បាប់ដើមជាភាសាខ្មែរ - ត្រូវបានបកប្រែដោយស៊ីអេអូ]*

[261] មាត្រា ១៩ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ – រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០១៩). ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ (នស/រកម /១១១៩/០១៦) ភ្នំពេញ។

[262] អម្រឹត៖ ៣0.000 ដុល្លារអាមេរិក សូមមើល https://bit.ly/3WwYAj6; អេស៊ីលីដា និង ធនាគារហត្ថា ៥0.000 ដុល្លារអាមេរិក សូមមើល https://bit.ly/4nlzZnB និង https://bit.ly/48XvXTJ គួរកត់សម្គាត់ថា កម្ចីមីក្រូរបស់ប្រាសាក់ត្រូវបានដាក់កម្រិតត្រឹម ១.៥00 ដុល្លារអាមេរិក និង ៥.000 ដុល្លារអាមេរិក សម្រាប់កម្ចីបុគ្គលិក សូមមើល https://bit.ly/3VUOCIj និង https://bit.ly/4mVkEi4។

ដែលមិនចាំបាច់។[263]

នៅដើមឆ្នាំ២០០៩-២០១០ ស្តង់ដារនៃយុទ្ធនាការឆ្លាតវៃអន្តរជាតិ សម្រាប់មីក្រូហិរញ្ញវត្ថុបានចែងថា ការវិភាគរបស់អ្នកផ្តល់ប្រាក់កម្ចីអំពីសមត្ថភាពសងបំណុលរបស់អ្នកខ្ចីគួរតែរួមបញ្ចូល "លំហូរប្រាក់ចំណូល ទ្រព្យសកម្មរាវ និងប្រាក់ឧបត្ថម្ភមួយចំនួនសម្រាប់ប្រាក់ចំណូលនាពេលអនាគត ដែលអាចតិចជាងប្រាក់ចំណូលបច្ចុប្បន្ន ជាការទ្រទ្រង់ ដើម្បីអនុញ្ញាតឱ្យអតិថិជនអាចទប់ទល់នឹងវិបត្តិនាពេលអនាគត ឬទូទាត់ប្រាក់នៅគ្រាអាសន្ន"។ ក្នុងការរចនា និងចែកចាយផលិតផល យុទ្ធនាការឆ្លាតវៃបានសង្កត់ធ្ងន់ថា ដើម្បីជៀសវាងការមានគ្រោះថ្នាក់ដល់អតិថិជន ការធានាមិនគួរជាកត្តាតែមួយគត់ ដែលមានសារៈសំខាន់ចំពោះការអនុម័តប្រាក់កម្ចីនោះទេ។[264] នៅឆ្នាំ២០១៦ និង ឆ្នាំ២០២២ បច្ចុប្បន្នភាពនៃស្តង់ដារទាំងនេះបានសង្កត់ធ្ងន់លើតម្រូវការរបស់អ្នកផ្តល់ប្រាក់កម្ចីក្នុងការវិភាគលំហូរសាច់ប្រាក់ ដែលពិចារណាលើប្រាក់ចំណូល ការចំណាយ និងសេវាបំណុលរបស់អ្នកខ្ចី ទាក់ទងនឹងអាជីវកម្ម និងគ្រួសារ ព្រមទាំងប្រាក់ចំណូលដទៃទៀត រួមទាំងប្រភពមិនផ្លូវការផងដែរ។ អ្នកផ្តល់ប្រាក់កម្ចីត្រូវបានណែនាំមិនឱ្យប្រើការធានា ប្រាក់ចំណូលរបស់អ្នកធានា វត្ថុបញ្ចាំ និង/ឬការធានារ៉ាប់រងជាប្រូកស៊ីសម្រាប់សមត្ថភាពសងបំណុល ឬជាមូលដ្ឋានចម្បងសម្រាប់ការអនុម័តប្រាក់កម្ចីនោះទេ។[265]

ជាទូទៅ ស៊ីអេអូសង្កេតឃើញថា អេស៊ីលីដា អម្រឹត ធនាគារហត្ថា ស្ថាបនា ប្រាសាក់ និងអិលអូអិលស៊ី បានចងក្រងជាឯកសារគោលនយោបាយដែលកំពុងអនុវត្ត ដើម្បីវាយតម្លៃសមត្ថភាពសងប្រាក់របស់អ្នកខ្ចី ដែលគិតគូរពីលក្ខណៈ លទ្ធភាពក្នុងការសងប្រាក់ ដើមទុន វត្ថុបញ្ចាំ ការវិភាគលំហូរសាច់ប្រាក់ និងព័ត៌មានពីក្រុមហ៊ុនក្រេឌីតប៊្យូរ៉ូកម្ពុជា (CBC)។ អ្នកផ្តល់ប្រាក់កម្ចីក៏មានប្រព័ន្ធផ្ទៀងផ្ទាត់ប្រភពប្រាក់ចំណូលផងដែរ ទោះបីជាមានបញ្ហាប្រឈមនានា ទាក់ទងនឹងភាពជឿជាក់លើប្រាក់ចំណូលដែលបានរាយការណ៍នៅក្នុងវិស័យមិនផ្លូវការក៏ដោយ។ ពួកគេភាគច្រើនពឹងផ្អែកខ្លាំងលើសមត្ថភាពរបស់បុគ្គលិកនៅទីវាល ពីព្រោះមានទិន្នន័យភាគីទីបីតិចតួច ដើម្បីជួយផ្ទៀងផ្ទាត់ព័ត៌មានដែលបានរាយការណ៍។[266]

តាមការត្រួតពិនិត្យដោយចៃដន្យលើឯកសារប្រាក់កម្ចីរបស់អេស៊ីលីដា អម្រឹត ហត្ថាកសិករ ប្រាសាក់ និងស្ថាបនា[267] ស៊ីអេអូបានកត់សម្គាល់ឃើញថា ស្ថាប័នទាំងនេះគណនាសមត្ថភាពសងបំណុលរបស់អតិថិជន

---

[263] Cerise+ SPTF ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២, ៤.A.១៖ អ្នកផ្តល់សេវាធ្វើការសម្រេចចិត្តលើប្រាក់កម្ចី ដោយផ្អែកលើសមត្ថភាពសងប្រាក់របស់អតិថិជន https://bit.ly/41RDorH។ សូមមើល៖ Elisabeth Rhyne ការការពារអ្នកប្រើប្រាស់នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ - អភិក្រមមិនធ្វើនិយ័តកម្ម ខែតុលា ឆ្នាំ២០០៣; កំណត់សម្គាល់ចំណុចផ្តោតរបស់ CGAP លេខ ២៧៖ ការការពារអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ។ ខែឧសភា ឆ្នាំ២០០៥ យុទ្ធនាការ Smart, SPTF, Cerise គោលការណ៍ស្តីពីកិច្ចការពារអតិថិជន https://bit.ly/3Fqg2AR។

[264] ការអនុវត្តការវាយតម្លៃកិច្ចការពារអតិថិជន៖ មគ្គុទ្ទេសក៍ណែនាំ។ យុទ្ធនាការ Smart ខែកុម្ភៈ ឆ្នាំ២០១០ https://bit.ly/3QNuSUh។

[265] ស្តង់ដារកិច្ចការពារអតិថិជន ២.0. យុទ្ធនាការឆ្លាតវៃ ខែឧសភា ឆ្នាំ២០១៦ https://bit.ly/4hNvgxe, Cerise SPTF ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ទំ.២៥។

[266] ដំណើរការអនុម័តប្រាក់កម្ចីនៅក្នុង BFIs ជាទូទៅ អាស្រ័យលើចំនួនប្រាក់កម្ចី ដោយប្រាក់កម្ចីធំៗ ជាធម្មតា តម្រូវឱ្យមានការអនុញ្ញាតពីគណៈកម្មាធិការដែលត្រូវបានកំណត់ ឬបុគ្គលិកជាន់ខ្ពស់ ជាជាងបុគ្គលិកនៅទីវាល។ ស្ថាប័នហិរញ្ញវត្ថុមួយក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុទាំងប្រាំមួយដែលមានឈ្មោះនៅក្នុងសំណុំរឿងនេះបានបង្កើតទម្រង់ស្តង់ដារអាជីវកម្មសម្រាប់សកម្មភាពកសិកម្ម រួមមាន អង្ករ ដំឡូងមី កៅស៊ូ ស្វាយចន្ទី និងម្រេច ដើម្បីជួយមន្ត្រីឥណទានធ្វើការវាយតម្លៃប្រាក់ចំណូលឲ្យបានត្រឹមត្រូវ។ អតិថិជន FI មួយទៀត ប្រើឧបករណ៍ឌីជីថល ប៉ុន្តែប្រាក់ចំណូលពីការដាំដុះតាមរដូវ ត្រូវតែគណនាដោយដៃ។

[267] អិលអូអិលស៊ី មិនបានផ្តល់ឯកសារកម្ចីជូនស៊ីអេអូ ដើម្បីត្រួតពិនិត្យឡើងវិញនោះទេ។

ក្នុងកម្រិត ៧០% នៃផលធៀបបំណុល/ប្រាក់ចំណូល ដូចបានណែនាំដោយស្តង់ដារ SPTF+Cerise ដែលបានរួមបញ្ចូលនៅក្នុងក្រមប្រតិបត្តិរបស់គ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា។ វាមានភាពច្បាស់លាស់ថាតើ ផលធៀប ៧០-៣០% នោះត្រូវបានគណនានៅគ្រប់ករណី ដែលពាក់ព័ន្ធនឹងប្រាក់ចំណូល "ដែលអាចដាក់បញ្ញើបាន" ដូចបានណែនាំដោយស្តង់ដារ SPTF+Cerise ឬផ្អែកលើមូលដ្ឋានប្រាក់ចំណូលទាំងអស់របស់អ្នកខ្ចី។[268]

លើសពីនេះទៀត គោលនយោបាយ និងការអនុវត្តរបស់ BFI ដែលបានពិចារណានៅក្នុងការស៊ើបអង្កេតនេះ នៅក្នុងបរិបទកាតព្វកិច្ចក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ និងការគ្រប់គ្រងរបស់ IFC មិនចាំបាច់ធានាចំពោះការវាយតម្លៃយ៉ាងគ្រប់គ្រាន់លើសមត្ថភាពសងប្រាក់នោះទេ ដោយពួកគេមិនបានពិចារណាលើហានិភ័យទាក់ទងនឹងប្រាក់ចំណូលទូទៅ កំហុសឆ្គងក្នុងការរាយការណ៍អំពីឥណទាន និងការពឹងផ្អែកលើតម្លៃនៃវត្ថុបញ្ចាំខ្លាំងពេកនោះទេ។

ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើប្រជាជនងាយរងគ្រោះ IFC គួរតែត្រួតពិនិត្យ និងគ្រប់គ្រង ក្នុងវិសាលភាពដែលអតិថិជនរបស់ខ្លួនបានពិចារណាលើកត្តាសំខាន់ៗដូចខាងក្រោម ពាក់ព័ន្ធនឹងសមត្ថភាពសងប្រាក់ ស្របតាម GIIP ដូចបានតម្រូវដោយ PS1៖

- *ហានិភ័យទាក់ទងនឹងប្រាក់ចំណូល៖* លើកលែងចំពោះអតិថិជនរបស់ IFC ស៊ីអេអូមិនបានមើលឃើញការចង្អុលបង្ហាញថា BFIs មានប្រព័ន្ធគ្រប់ជ្រុងជ្រោយក្នុងការគណនីហានិភ័យទាក់ទងនឹងប្រាក់ចំណូល ដែលទាក់ទងនឹងប្រភេទ និងប្រភពប្រាក់ចំណូលរបស់អ្នកខ្ចី ឬកត្តាខាងក្រៅ ដូចជា គំរូអាកាសធាតុ បាតុភូតអាកាសធាតុ ឬហានិភ័យផ្នែកសុខភាពនោះទេ។[269] ឧទាហរណ៍ ស៊ីអេអូមិនអាចផ្ទៀងផ្ទាត់ថា ហានិភ័យនៃការបាត់បង់ប្រាក់ចំណូល ដែលអាចកើតឡើងដោយសារភាពបរាជ័យក្នុងការដាំដំណាំ ការបាត់បង់ការងារនៅរោងចក្រ ឬការផ្អាកការងារបណ្តោះអាសន្ន ឬការកាត់បន្ថយសកម្មភាពម៉ោការសំណង់បន្ត ត្រូវបានយកមកពិចារណាជាប្រព័ន្ធ ដោយអ្នកផ្តល់សេវាហិរញ្ញវត្ថុទាំងនេះទេ។ អ្នកខ្ចីមួយភាគធំ ដែលត្រូវបានសម្ភាសដោយស៊ីអេអូ ដែលសុទ្ធតែជាអតិថិជនរបស់អតិថិជន និងអតិថិជនរងរបស់ IFC បានរាយការណ៍ពីការលំបាកក្នុងការសងប្រាក់កម្ចីដោយសារការបរាជ័យក្នុងការដាំដំណាំ ឬជំងឺសត្វ ក៏ដូចជាគ្រោះថ្នាក់ផ្ទាល់ខ្លួន ឬជំងឺ ដែលបានដាក់កម្រិតលើ

[268] ស្តង់ដារ SPTF+Cerise ពិចារណាលើប្រាក់ចំណូលដែលអាចដាក់បញ្ញើបាន ដែលនៅសល់ បន្ទាប់ពីមានការប្រើប្រាស់សម្រាប់កត្តាអាជីវកម្ម ឬចំណាយក្នុងគ្រួសារ (ឧ. វាគួរតែផ្អែកលើអតិរេករបស់គ្រួសារ) និងសង្កត់ធ្ងន់លើតម្រូវការក្នុងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យតាមបែបស្ថាបនា នៅពេលគណនាប្រាក់ចំណូល នៅក្នុងស្ថានភាពដែលតិត្ថិភាពទីផ្សារមានកម្រិតខ្ពស់ និងដែលអតិថិជនអាចងាយរងគ្រោះដោយសារការជំពាក់បំណុលវ័ណ្ឌក។ SPTF+Cerise មគ្គុទ្ទេសក៍ណែនាំសម្រាប់ការវាយតម្លៃ និងការអនុវត្តស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២, ៤.A.១ ស្តីពីកិច្ចការពារអតិថិជន https://bit.ly/3FGgUkJ។

[269] អតិថិជន/អតិថិជនបន្តរបស់ IFC ពីររូប បានកំណត់អត្តសញ្ញាណឧស្សាហកម្មមួយចំនួនយ៉ាងច្បាស់ថាជាវិស័យដែលមានហានិភ័យខ្ពស់នៅក្នុងឯកសារគោលនយោបាយ និងសម្ភារៈបណ្តុះបណ្តាលរបស់ពួកគេ និងបានណែនាំមន្ត្រីរបស់ពួកគេឱ្យកែសម្រួលប្រាក់ចំណូលនៅក្នុងការវាយតម្លៃសមត្ថភាពសងប្រាក់ ឬមិនឱ្យផ្តល់ប្រាក់កម្ចីដល់អ្នកដែលមានប្រភពប្រាក់ចំណូលមកពីវិស័យទាំងនេះតែមួយមុខនោះទេ។ ក្នុងអំឡុងពេលត្រួតពិនិត្យការពិត និងផ្តល់មតិយោបល់ BFI មួយ បានកត់សម្គាល់ថា ពួកគេបន្តផ្តល់ជូននូវដំណោះស្រាយសម្រាលបំណុលដែលអាចបត់បែនបាន រួមទាំងការរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញសម្រាប់អតិថិជនដែលរងផលប៉ះពាល់ដោយសារព្រឹត្តិការណ៍នានា ដូចជា ជំងឺកូវីដ១៩ ទឹកជំនន់ គ្រោះរាំងស្ងួត អគ្គិភ័យ ឬជំងឺជាដើម។ ជម្រើសរួមមាន ការអនុគ្រោះរហូតដល់ ៦ ខែ លើប្រាក់ដើម និងការប្រាក់ ការទូទាត់តែការប្រាក់ ឬការពន្យារពេលឥណប្រតិទាន។

សមត្ថភាពស្វែងរកប្រាក់ចំណូលរបស់ពួកគេ។[270] ចំណុចនេះមានសង្គតិភាពនឹងគំហើញនៃការសិក្សាថ្នាក់ជាតិដែលថា គ្រួសារកសិករបានជំពាក់បំណុលកាន់តែច្រើន ឬបានលក់ដីធ្លីដើម្បីសងបំណុលដោយសារបញ្ហាប្រភេទនេះ។[271]

- *ការរាយការណ៍អំពីឥណទាន៖* BFIs ទាំងប្រាំមួយដែលមានឈ្មោះនៅក្នុងការស៊ើបអង្កេតនេះ ពឹងផ្អែកលើរបាយការណ៍ពីក្រុមហ៊ុនក្រេឌីតប៊ឺរ៉ូកម្ពុជា (CBC) ក្នុងការផ្តល់ប្រវត្តិប្រាក់កម្ចីរបស់អ្នកខ្ចី និងចង្អុលបង្ហាញពីដែនកំណត់នៃប្រាក់កម្ចី ដើម្បីវាយតម្លៃបន្ទុកបំណុលរបស់អ្នកខ្ចី។ នៅខណៈពេលដែល IFC បានជួយបង្កើត CBC និងចាត់ទុកក្រុមហ៊ុននេះជាតួអង្គសំខាន់ក្នុងការដោះស្រាយវិបត្តិបំណុលវ័ណ្ឌករបស់ប្រទេសកម្ពុជានោះ[272] របាយការណ៍ CBC មានដែនកំណត់មួយចំនួន។ ពួកគេមិនបានគិតគូរពីបំណុលក្រៅប្រព័ន្ធរបស់អ្នកខ្ចីនោះទេ ហើយរបាយការណ៍សសេរជាភាសាអង់គ្លេស ដែលមន្ត្រីឥណទាន និងបុគ្គលិក FI នៅប្រទេសកម្ពុជាភាគច្រើន ដែលធ្វើការវាយតម្លៃសមត្ថភាពសងប្រាក់មិននិយាយភាសានេះទេ។ [273] ក្នុងអំឡុងពេលចុះត្រួតពិនិត្យទីតាំង ស៊ីអេអូបានសួរមន្ត្រីឥណទានជាច្រើននាក់ ដែលមកពីអតិថិជន និងអតិថិជនបន្តរបស់ IFC ខុសៗគ្នា អំពីអត្ថន័យនៃផ្នែកតែមួយ នៅក្នុងរបាយការណ៍ឥណទាន CBC។ ទោះបីជាការបណ្តុះបណ្តាលដែលផ្តល់ជូនដោយ BFIs ក៏ដោយ ក៏មន្ត្រីឥណទាននីមួយៗបានផ្តល់ចម្លើយខុសគ្នា។ [274] ចំណុចនេះបង្ហាញពីរបៀបដែលសមត្ថភាពរបស់មន្ត្រីឥណទានក្នុងការស្វែងយល់ឱ្យបានត្រឹមត្រូវ និងវិភាគអំពីស្ថានភាពបំណុលរបស់អតិថិជនប្រហែលជាមានភាពទន់ខ្សោយ ទោះបីជាមានការណែនាំមួយចំនួន ដែលផ្តល់ជូនដោយ

[270] បញ្ហាប្រឈមនៃការសងប្រាក់កម្ចីត្រូវបានរាយការណ៍ទៅស៊ីអេអូ នៅទូទាំងវិស័យនានា ដោយសារតែអស្ថិរភាពនៃប្រាក់ចំណូល។ នៅក្នុងវិស័យកសិកម្ម ដើមបណ្តឹងចំនួនប្រាំមួយនាក់ និងអ្នកខ្ចី ២៣% ដែលត្រូវបានសម្ភាសន៍ មានការលំបាកយ៉ាងខ្លាំងក្នុងការសងប្រាក់កម្ចី បន្ទាប់ពីមានភាពបរាជ័យក្នុងការដាំដំណាំ ឬជំងឺសត្វពាហនៈ។ នៅក្នុងវិស័យកាត់ដេរ ដើមបណ្តឹងម្នាក់ និងអ្នកខ្ចី ១០% បានលើកឡើងពីប្រាក់ចំណូលរោងចក្រមិនទៀងទាត់ ដែលប៉ះពាល់ដល់ស្ត្រីជាពិសេស ជាឧបសគ្គចំពោះការសងប្រាក់។ នៅក្នុងវិស័យសំណង់ អ្នកខ្ចី ១៣% មិនអាចសងប្រាក់បានទេ នៅពេលដែលតម្រូវការសេវាម៉ៅការបន្ត ដូចជា ការដឹកជញ្ជូនដី និងខ្សាច់ បានធ្លាក់ចុះ។
[271] Res, Phasy, មីក្រូហិរញ្ញវត្ថុនៅពេលមានជំងឺកូវីដ ១៩ កិច្ចការពារអ្នកប្រើប្រាស់ និងដំណើរការរៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ នៅកម្ពុជា ឆ្នាំ២០២១ ទំ. ៣៨-៤០ https://bit.ly/4iLFoap; Brickell K., Lawrenniuk S., Chhom Th., Mony R., So H., និង McCarthy L. (២០២៣). "ខូចខាតអស់ហើយ"៖ វិន័យបំណុល ភាពអត់ឃ្លាន និងយេនឌ័រ នៅពេលមានការរាតត្បាតនៃជំងឺកូវីដ ១៩ ក្នុងចំណោមកម្មករកាត់ដេរនៅកម្ពុជា។ ភូមិសាស្ត្រសង្គម និងវប្បធម៌។ គ្រោះថ្នាក់ផ្ទាល់ខ្លួន និងជំងឺក៏បង្កហានិភ័យទាក់ទងនឹងប្រាក់ចំណូលដល់សមត្ថភាពសងប្រាក់របស់អ្នកខ្ចីផងដែរ ដោយមានដើមបណ្តឹងពីរនាក់ និងអ្នកខ្ចី ៧% ដែលត្រូវបានជ្រើសរើសដោយចៃដន្យ និងត្រូវបានសម្ភាសន៍ដោយស៊ីអេអូ បានជួបប្រទះការលំបាកក្នុងការសងប្រាក់ដោយសារហេតុផលទាំងនេះ។ លើកលែងចំពោះ BFI មួយ ស៊ីអេអូមិនបានឃើញការចង្អុលបង្ហាញថា BFI នៅក្នុងសំណុំរឿងនេះ បានរួមបញ្ចូលការពិចារណាលើសុខភាពរបស់អ្នកខ្ចី និងអ្នកខ្ចីរួម ក្នុងការគណនាសមត្ថភាពសងប្រាក់របស់ពួកគេនោះទេ។
[272] ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ទំ. ៥ ១៣-១៤; សំណើសុំរបស់ IFC ឲ្យក្រុមប្រឹក្សាភិបាលត្រួតពិនិត្យការសម្រេចចិត្តធ្វើការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ https://bit.ly/3XU2nlr ទំ. ៨។
[273] នៅខណៈពេលដែលមន្ត្រីជាន់ខ្ពស់នៃ BFIs ទំនងជានិយាយភាសាអង់គ្លេសនោះ មន្ត្រីឥណទានភាគច្រើនដែលត្រួតពិនិត្យសមត្ថភាពសងប្រាក់របស់អ្នកខ្ចីមិននិយាយភាសាអង់គ្លេសនោះទេ។ ចំណុចនេះត្រូវបានផ្ទៀងផ្ទាត់ដោយស៊ីអេអូ ក្នុងអំឡុងពេលចុះត្រួតពិនិត្យទីតាំងស៊ើបអង្កេតរបស់ខ្លួន តាមរយៈការសម្ភាសជាមួយមន្ត្រីឥណទានដែលមកពី BFIs នីមួយៗ ទាំងនៅទីស្នាក់ការកណ្តាល និងនៅតាមសាខា។
[274] ផ្នែកជាក់លាក់នៅក្នុងរបាយការណ៍ CBC ដែលនាំឱ្យមានការបកស្រាយខុសគ្នា សំដៅលើដែនកំណត់នៃចំនួនប្រាក់កម្ចីសរុប ដែលមានសារៈសំខាន់ចំពោះការវាយតម្លៃសមត្ថភាពសងប្រាក់របស់អ្នកខ្ចី។

CBC ជាភាសាខ្មែរក៏ដោយ។[275] លើសពីនេះទៀត របាយការណ៍ក៏មិនបានគិតគូរពីបំណុលក្រៅប្រព័ន្ធនោះទេ ហើយពុំមាន BFIs ណាមួយ នៅក្នុងសំណុំរឿងនេះ ផ្តល់ការណែនាំជាក់លាក់ដល់បុគ្គលិកអំពីរបៀបវាយតម្លៃ ឬកំណត់បំណុលក្រៅប្រព័ន្ធដែលមានស្រាប់នោះទេ។[276] ការវាយតម្លៃឥណទានក៏បានរងឥទ្ធិពលពីការអនុវត្តយ៉ាងទូលំទូលាយក្នុងចំណោម BFIs ទាំងប្រាំមួយ ក្នុងការវាយតម្លៃសមត្ថភាពសងប្រាក់របស់អតិថិជន ដោយរាប់បញ្ចូលប្រាក់ចំណូលរបស់សមាជិកគ្រួសារទាំងអស់ ទោះបីជាពួកគេទាំងអស់គ្នាមិនមែនជាសហអ្នកខ្ចីផ្លូវការ និងមិនមែនជាបំណុលរបស់ពួកគេក៏ដោយ។[277] ចំណុចនេះបណ្តាលឲ្យមានប្រាក់កម្ចីត្រូវបានអនុម័តលើសពីសមត្ថភាពរបស់អ្នកខ្ចីក្នុងការទូទាត់សង ដោយសារការសន្មតថាមានប្រាក់ចំណូលរបស់គ្រួសារទាំងអស់សម្រាប់សងបំណុល នៅខណៈពេលដែលពួកគេមិនមាននោះទេ។

- *ការពឹងផ្អែកលើវត្ថុបញ្ចាំ៖* ផលបត្ររបស់អតិថិជន និងអតិថិជនបន្តរបស់ IFC ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ ភាគច្រើនមានប្រាក់កម្ចីដែលមានវត្ថុបញ្ចាំ។[278] ការកាន់កាប់ដីធ្លីយ៉ាងទូលំទូលាយក្នុងចំណោមអតិថិជនមីក្រូហិរញ្ញវត្ថុបាននាំឱ្យ BFIs ផ្តោតលើដីធ្លីជាទម្រង់វត្ថុបញ្ចាំដែលអាចប្រើប្រាស់បានច្រើនបំផុត ដោយមិនគិតពីការលំបាក ដែលការបាត់បង់ដីធ្លីទាំងនោះអាចបង្កឡើងនោះទេ ជាពិសេសចំពោះគ្រួសារដែលមានប្រាក់ចំណូលទាប និងជនដែលមុខរបរចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើដីធ្លីនោះទេ។[279] ក្នុងករណីមួយចំនួន BFIs ថែមទាំងណែនាំមន្ត្រីឥណទានឱ្យស្នើសុំ ឬផ្តល់

---

[275] SPTF+Cerise មគ្គុទ្ទេសក៍ណែនាំសម្រាប់ការវាយតម្លៃ និងការអនុវត្តស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២, ៤.A.១ ស្តីពីកិច្ចការពារអតិថិជន https://bit.ly/3FGgUkJ។

[276] ស៊ីអេអូបានរកឃើញឧបករណ៍វាយតម្លៃឌីជីថលមួយក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុទាំងប្រាំមួយ ដែលអនុញ្ញាតឱ្យអ្នកខ្ចីរាយការណ៍អំពីប្រាក់កម្ចីពី "ភាគីទីបី" ដោយមិនមានការពន្យល់បន្ថែមដើម្បីផ្តល់មគ្គុទ្ទេសក៍ណែនាំដល់មន្ត្រីឥណទាននោះទេ។ បុគ្គលិកទីស្នាក់ការកណ្តាល និងបុគ្គលិកសាខាបានប្រាប់ស៊ីអេអូថា មន្ត្រីឥណទានវាយតម្លៃបំណុលក្រៅប្រព័ន្ធជាមួយអ្នកខ្ចីនាពេលអនាគតដោយផ្ទាល់ អ្នកជិតខាងរបស់ពួកគេ និងអាជ្ញាធរមូលដ្ឋាន។

[277] អតិថិជនបន្តរបស់ IFC មួយ ហាក់បីដូចជាស្ថាប័នតែមួយគត់ក្នុងចំណោមអតិថិជន/អតិថិជនបន្តរបស់ IFC ទាំងប្រាំមួយ ដែលត្រូវបានកំណត់ទង់ក្រហម ដោយរួមបញ្ចូលប្រាក់ចំណូលរបស់បុគ្គលទីបីនៅក្នុងការវិភាគលំហូរសាច់ប្រាក់ នៅខណៈពេលដែលពួកគេមិនមែនជាសហអ្នកខ្ចីនោះទេ។

[278] នៅខណៈពេលដែលផលបត្ររបស់អិលអូអិលស៊ីភាគច្រើនមានប្រាក់កម្ចីដែលមានទ្រព្យបញ្ចាំនោះ (៧៩,៦% ក្នុងឆ្នាំ២០២៣) ចំពោះគណនី អិលអូអិលស៊ីគឺជាករណីលើកលែង ដោយគណនីភាគច្រើនត្រូវបានរាយការណ៍ថាមិនមានទ្រព្យបញ្ចាំនោះទេ (៥៥,៨% ក្នុងឆ្នាំ២០២៣)។ គណនីភាគច្រើនដែលមិនមានទ្រព្យបញ្ចាំ គឺជាប្រាក់កម្ចីជាក្រុម ឬជាលក្ខណៈបុគ្គល ក្រោម ៣.០០០ ដុល្លារ ដូច្នេះផលបត្រប្រាក់កម្ចីសរុបមានចំណែកតូចជាងប្រាក់កម្ចីដែលមានទ្រព្យបញ្ចាំរបស់អិលអូអិលស៊ី ដែលមានសមតុល្យសរុបជាមធ្យម ៥.៦៤៩ ដុល្លារ ក្នុងឆ្នាំ២០២៣។ សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់អិលអូអិលស៊ី សម្រាប់ឆ្នាំ២០២៣ ទំ. https://bit.ly/3FG1cWH។

[279] IFC បានទទួលស្គាល់ហានិភ័យនេះ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ដោយបានចេញផ្សាយរបាយការណ៍មួយក្នុងឆ្នាំ២០១៥ ដែលបានកំណត់ការអនុវត្តការតម្រូវឲ្យដាក់ដីធ្លីជាវត្ថុបញ្ចាំដោយគ្រួសារក្រីក្រដែលមានអត្រាកម្មករម្រិតទាប ជាហានិភ័យអ្នកប្រើប្រាស់ដ៏សំខាន់មួយ។ IFC, ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ឆ្នាំ២០១៥, ទំព័រ ២៩-៣២. មាននៅ https://bit.ly/3VCU817។ នៅឆ្នាំ២០២៤ IFC បានកត់សម្គាល់ថា បញ្ហាប្រឈមនេះនៅតែមាន ដោយប្រាក់កម្ចីខ្នាតមីក្រូប្រហែល ៦០% នៅកម្ពុជា មានវត្ថុធានា ដែលភាគច្រើនជាប័ណ្ណកម្មសិទ្ធិដីធ្លី។ ទំនាក់ទំនងរវាងដីធ្លី និងឥណទាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៃប្រទេសកម្ពុជាត្រូវបានបង្កើតឡើងយ៉ាងល្អ ហើយវាក៏មានហានិភ័យផងដែរ នៅពេលដែលអ្នកផ្តល់ប្រាក់កម្ចីផ្តល់ប្រាក់កម្ចីធំៗដោយ

អាទិភាពដល់ដីធ្លីដែលមាន "មានសារៈសំខាន់បំផុត" របស់អតិថិជន ជាធម្មតា ជាដីលំនៅឋាន ឬ អាជីវកម្ម) ជាវត្ថុបញ្ចាំ។ ការអនុវត្តបែបនេះ ជាញឹកញាប់ នាំឱ្យមានស្ថានភាពដែលអ្នកខ្ចីត្រូវបាន អនុម័តឲ្យខ្ចីប្រាក់កម្ចីច្រើនជាងតម្រូវការ ឬការស្នើសុំ។ អភិក្រមនេះផ្ទុយពីស្តង់ដារ GIIP[280] ដែល ព្រមានមិនឱ្យប្រើវត្ថុបញ្ចាំជាប្រូកស៊ីសម្រាប់សមត្ថភាពសងប្រាក់នោះទេ និងតម្រូវឱ្យអ្នកផ្តល់សេវា កំណត់ និងផាត់ចេញនូវវត្ថុបញ្ចាំ ដែលការបាត់បង់ទ្រព្យសកម្មទាំងនោះនឹងបង្កការលំបាកធ្ងន់ធ្ងរ ឬ កាត់បន្ថយសមត្ថភាពរបស់អ្នកខ្ចីប្រាក់យ៉ាងខ្លាំង ក្នុងការរកប្រាក់ចំណូល។[281] GIIP ផ្តល់អនុសាសន៍ ថា អ្នកផ្តល់សេវាហិរញ្ញវត្ថុគួរតែមានបញ្ជីទ្រព្យសម្បត្តិដែលមិនអាចដាក់បញ្ចាំបាន ជាពិសេសទ្រព្យ សម្បត្តិដែលមានសារៈសំខាន់ចំពោះការរស់រានមានជីវិតប្រចាំថ្ងៃ ឬសមត្ថភាពរកប្រាក់ចំណូលដ៏ សំខាន់របស់អ្នកខ្ចី។[282]

ទាំងប្រាំមួយនៅក្នុងសំណុំរឿងនេះ ដែលមានគោលនយោបាយកំណត់ប្រភេទដីមួយចំនួនដែលមិន អាចទទួលយកបានជាវត្ថុបញ្ចាំបាន ដែលរួមមាន តំបន់អភិរក្ស និងដីរបស់ជនជាតិដើមភាគតិច។ មិនមានអ្នកឱ្យខ្ចីណាមួយហាមឃាត់ការប្រើប្រាស់ដីលំនៅឋានចម្បង ឬដីបង្កើតប្រាក់ចំណូលជាវត្ថុ

ផ្អែកលើតម្លៃដីធ្លីរបស់អ្នកខ្ចីជាជាងសមត្ថភាពសងប្រាក់របស់ពួកគេ។ សូមមើល៖ សារាចរពិសេសរបស់ Mimosa ខែមិថុនា ឆ្នាំ ២០២៣ ទំ. ៧។ FMO គំនិតផ្តួចផ្តើមវិស័យដែលអាចមាន - ប្រទេសកម្ពុជា ទំ. ១ https://bit.ly/3R7beCL។ *"ការដែលអ្នកនេសាទ និងកម្មករ រោងចក្ររកប្រាក់ចំណូលបានតែពីរបីរយដុល្លារក្នុងមួយខែ នៅតែអាចទទួលបានកម្ចីខ្នាតតូចដែលមានតម្លៃជាច្រើនរយដុល្លារ គឺជា ភស្តុតាងបញ្ជាក់ថា លំហូរសាច់ប្រាក់អាចស្ទើរតែមិនមែនជាកត្តាកំណត់សំខាន់ចំពោះទំហំកម្ចីឡើយ។"* A. Seiff, Sokummono Khan, គ្រោះថ្នាក់នៃមីក្រូហិរញ្ញវត្ថុ, *The Dial*, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣, https://bit.ly/4hwQizR។

[280] កថាខណ្ឌ ៧ នៃគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ ធ្វើឲ្យ IFC មានកាតព្វកិច្ចព្យាយាមធានាថា តាមរយៈកិច្ចខិតខំប្រឹងប្រែង ក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ ការពិនិត្យតាមដាន និងការត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួន សកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ហិរញ្ញប្ប ទានជូន បានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម ដែលរួមមាន PS1 ដែលតម្រូវឲ្យអតិថិជនរបស់ IFC បង្កើត ESMS ដើម្បីកំណត់ និងអនុវត្តវិធានការកាត់បន្ថយសម្រាប់ជនងាយរងគ្រោះ ស្របតាមការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP)។

[281] Cerise+ SPTF, ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ទំ. ២១ និង ២៥ https://bit.ly/41RDorH។

[282] ភាពអាចរកបាននៃវត្ថុបញ្ចាំមិនគួរជាលក្ខណៈវិនិច្ឆ័យនៃការអនុម័តប្រាក់កម្ចីចម្បងនោះទេ។ ការដាក់បញ្ចាំច្រើនពេកអាចបង្កើតការ លំបាកហួសហេតុសម្រាប់អតិថិជន ប្រសិនបើវត្ថុបញ្ចាំត្រូវបានរំលាយ និងគួរតែមានការពិចារណាយ៉ាងប្រុងប្រយ័ត្នផងដែរ ចំពោះ លទ្ធផលនៃការទូទាត់វត្ថុបញ្ចាំដែលមានសារៈសំខាន់ចំពោះជីវភាពរស់នៅ ឬផ្ទះរបស់អ្នកខ្ចី។ វាមានសារៈសំខាន់ចំពោះអ្នកឱ្យខ្ចីក្នុង ការមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់អ្វីដែលជាវត្ថុបញ្ចាំដែលអាចទទួលយកបាន។ ការណែនាំនេះគឺទាក់ទងទៅនឹង ស្តង់ដារដែលទាក់ទងនឹងការការពារការជំពាក់បំណុលហួសហេតុ ការរចនាផលិតផលសមស្រប ដើម្បីការពារការបង្កគ្រោះថ្នាក់ និងការ ប្រព្រឹត្តិដោយយុត្តិធម៌ និងការគោរពចំពោះអតិថិជន។ មជ្ឈមណ្ឌលសម្រាប់ការរួមបញ្ចូលផ្នែកហិរញ្ញវត្ថុ ការចូលរួម ការដាក់គោលការណ៍ ដើម្បីដំណើរការ៖ ការណែនាំលម្អិតអំពីគោលការណ៍ការពារអតិថិជន ការការពារ និងការផ្តល់សិទ្ធិអំណាចដល់អ្នកប្រើប្រាស់ហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ ទំ. ៨ https://bit.ly/4kw6Dao និង Cerise+ SPTF ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ទំ. ២១ https://bit.ly/41RDorH។ ការណែនាំដែលចេញដោយ SPTF+Cerise ស្តីពីស្តង់ដារក្នុងការរចនា ផលិតផលដើម្បីជៀសវាងគ្រោះថ្នាក់ចំពោះអ្នកខ្ចី បានចង្អុលបង្ហាញថា អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុគួរតែមានបញ្ជីទ្រព្យសកម្មដែល មិនអាចទទួលយកជាទ្រព្យបញ្ចាំបាន "រួមទាំងវត្ថុដែលនឹងបង្កើតការលំបាកធ្ងន់ធ្ងរ (ឧ. លំនៅឋានរបស់អ្នកខ្ចី និងសមាជិកគ្រួសារ របស់គាត់) ឬការបាត់បង់សមត្ថភាពរកប្រាក់ចំណូលយ៉ាងខ្លាំង (ឧ. ឧបករណ៍ និងគ្រឿងចក្រផលិតកម្ម សត្វពាហនៈ។ល។)" ឬ "ដែល នឹងធ្វើឲ្យអតិថិជនបាត់បង់តម្រូវការចាំបាច់។ ប្រសិនបើអតិថិជនមិនមានទ្រព្យសកម្មដើម្បីផ្តល់ជូនជាទ្រព្យបញ្ចាំទេនោះ តម្រូវឲ្យមាន មធ្យោបាយជំនួសដើម្បីធានាប្រាក់កម្ចីរបស់ពួកគេ"។ Cerise+ SPTF មគ្គុទ្ទេសក៍ណែនាំសម្រាប់ការវាយតម្លៃ និងការអនុវត្តស្តង់ដារ ជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ស្តង់ដារ ៣B https://bit.ly/4mIrsRz។

បញ្ហាំនោះទេ។[283]

ផ្អែកលើព័ត៌មានដែលបានត្រួតពិនិត្យ រួមទាំងការសង្កេតនៅទីវាលរបស់ស៊ីអេអូដោយផ្ទាល់ ការអនុម័តប្រាក់កម្ចីដែលមានទំហំលើសពីសមត្ថភាពសងប្រាក់ ដោយអតិថិជន និងអតិថិជនបន្តរបស់ IFC នៅក្នុងសំណុំរឿងនេះ បង្ហាញពីចន្លោះប្រហោងនៃសមិទ្ធកម្មផ្នែកសង្គមនៃការវិនិយោគទាំងនេះ ទាក់ទងនឹងលក្ខខណ្ឌតម្រូវរបស់ PS1។ លក្ខខណ្ឌតម្រូវទាំងនេះ រួមមាន ការកំណត់ និងវាយតម្លៃហានិភ័យ និងផលប៉ះពាល់សង្គម ជាពិសេសលើក្រុមជនងាយរងគ្រោះ ការបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមប្រកបដោយប្រសិទ្ធភាព ស្របតាម GIIP រួមទាំងវិធានការសមស្របដើម្បីធានាចំពោះសមត្ថភាពសងប្រាក់របស់អ្នកខ្ចី និងការពិនិត្យតាមដានការអនុវត្តរបស់អតិថិជន ដើម្បីធានាថាផលប៉ះពាល់អវិជ្ជមានលើសហគមន៍ដែលរងផលប៉ះពាល់ ត្រូវបានបញ្ចៀស ឬកាត់បន្ថយ។

*b) បុនហិរញ្ញប្បទានយ៉ាងឆាប់រហ័ស និងមានហានិភ័យខ្ពស់*

បុនហិរញ្ញប្បទានយ៉ាងឆាប់រហ័ស និងមានហានិភ័យខ្ពស់កើតឡើងនៅពេលដែលអតិថិជនជំនួសប្រាក់កម្ចីសកម្មមួយ ដោយប្រាក់កម្ចីថ្មី ដែលមានទំហំធំជាងមុន ដើម្បីសងប្រាក់កម្ចីដែលមានស្រាប់ ដែលជាញឹកញាប់មិនមានសមត្ថភាពសងប្រាក់គ្រប់គ្រាន់នោះទេ។ ចំពោះជនងាយរងគ្រោះ ចំណុចនេះអាចនាំឱ្យមានបំណុលកាន់តែច្រើន ដោយមានលទ្ធភាពសងបំណុលតិចតួច ប្រសិនបើមាន និងសក្តានុពលក្នុងការងើបឡើងវិញផ្នែកហិរញ្ញវត្ថុកាន់តែទាប។

គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី ឆ្នាំ២០១៦ ដែលចេញដោយ CMA ហើយក្រោយមក អនុម័តដោយ ABC មានបំណងកំណត់ពិដានពហុប្រាក់កម្ចី និងបុនហិរញ្ញប្បទាន។ គោលការណ៍ណែនាំទាំងនេះរឹតត្បិតលើអ្នកផ្តល់ប្រាក់កម្ចី ពីការចេញប្រាក់កម្ចីលើសពីបី ដល់អតិថិជនតែម្នាក់ និងត្រូវបែងចែកការអនុវត្តបុនហិរញ្ញប្បទានតាមប្រភេទហានិភ័យ (ខ្ពស់ មធ្យម និងទាប) ដែលត្រូវតែរាយការណ៍ទៅកាន់ CBC។ ទោះបីជាមានវិធានការទាំងនេះក៏ដោយ ក៏របាយការណ៍បង្ហាញថា បុនហិរញ្ញប្បទានដែលមានហានិភ័យខ្ពស់បានបន្តអស់រយៈពេលជាច្រើនឆ្នាំ [284] ដោយមានការកើនឡើងនៃទំហំប្រាក់កម្ចីនៅកម្ពុជា ដែលមួយផ្នែកធំត្រូវបានជម្រុញដោយបុនហិរញ្ញប្បទាន។[285] តាមបរិបទ របាយការណ៍ឆ្នាំ២០២០ បានរកឃើញថា ចំនួនអ្នកខ្ចីបានកើនឡើង ១៩% នៅចន្លោះឆ្នាំ២០១៥ និង ឆ្នាំ២០២០ នៅខណៈពេលដែលប្រាក់កម្ចីរបស់ពួកគេបានកើនឡើង ១៥៨% ដែលលើសពីកំណើនផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាចំនួន ៣៩% ក្នុងអំឡុងពេល

[283] Cerise+ SPTF, ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ទំ.២១ និង ២៥ https://bit.ly/41RDorH។

[284] នៅឆ្នាំ២០១៨ ការសិក្សាមួយបានរកឃើញថា ប្រាក់កម្ចី ៥០% ដែលត្រូវបានបញ្ចេញនៅឆ្នាំ២០១៧ គឺសម្រាប់ធ្វើបុនហិរញ្ញប្បទានដោយមានចំនួន ៣០% ខ្ពស់ជាង ១៣០% នៃចំនួនប្រាក់កម្ចីដើម។ Incofin, Incofin ចាប់ផ្តើមត្រួតត្រាយផ្លូវគំនិតផ្តួចផ្តើមនិយ័តកម្មដោយខ្លួនឯង ដើម្បីទប់ស្កាត់បំណុលវណ្ឌកនៅកម្ពុជា ឆ្នាំ២០១៨ https://bit.ly/3RepKbP។

[285] សូមមើល សារាចរណ៍ពិសេសនៃរបាយការណ៍ Mimosa, ដីធ្លី និងឥណទាននៃប្រទេសកម្ពុជា៖ ជាតុផ្សំនៃភាពជោគជ័យរយៈពេលខ្លី? ខែមិថុនា ឆ្នាំ២០២៣

ដូចគ្នា។[286] ទោះជាយ៉ាងណាក៏ដោយ នៅចន្លោះខែតុលា ឆ្នាំ២០២០ និង ខែឧសភា ឆ្នាំ២០២៤ ទិន្នន័យពិនិត្យតាមដានគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីរបស់ CBC បានរាយការណ៍ថា បុនហិរញ្ញប្បទានដែលមានហានិភ័យខ្ពស់បានថយចុះ ១,៧% នៅកម្រិតឧស្សាហកម្ម ដែលទាបជាងដែនកំណត់ ៥% របស់គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី។

អតិថិជន និងអតិថិជនបន្តរបស់ IFC ទាំងប្រាំមួយ បានចុះឈ្មោះដោយស្ម័គ្រចិត្តចំពោះគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី និងបានចងក្រងឯកសារគោលនយោបាយ ដែលស្របតាមគោលការណ៍ណែនាំទាំងនោះ។[287] ទោះបីជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យរបស់ស៊ីអេអូលើឯកសាររបស់អតិថិជន និងការសម្ភាសជាមួយអ្នកខ្ចីបង្ហាញថា គោលនយោបាយមួយចំនួននៅតែលើកកម្ពស់ការធ្វើបុនហិរញ្ញប្បទាន ដើម្បីទទួលបានអតិថិជនថ្មី។ អ្នកខ្ចីជាច្រើន រួមទាំងដើមបណ្តឹងផងដែរ ដែលត្រូវបានសម្ភាសដោយអេអូ បានលើកឡើងថា អតិថិជន/អតិថិជនបន្តរបស់ IFC មួយចំនួន បានលើកទឹកចិត្តពួកគេឲ្យធ្វើបុនហិរញ្ញប្បទានដល់ប្រាក់កម្ចីដែលមានចំនួនកាន់តែច្រើន ដែលបណ្តាលឱ្យមានបំណុលដែលមិនចង់បានកាន់តែច្រើន។[288]

ការស្ទង់មតិដោយ CMA នៅឆ្នាំ២០២៣ បានរកឃើញថា ២៤% នៃសំណាកគ្រួសារ មានប្រើប្រាស់ប្រាក់ចំណូលរបស់ពួកគេ ជាង ៧០% ដើម្បីសងបំណុលជារៀងរាល់ខែ។[289] ផលធៀបដ៏ខ្ពស់បែបនេះ ជាពិសេសរួមជាមួយការកាន់កាប់រយៈពេលវែង ដោយសារបុនហិរញ្ញប្បទាន និងទំហំប្រាក់កម្ចីកើនឡើង ធ្វើឱ្យគ្រួសារកាន់តែងាយរងគ្រោះដោយសម្ពាធហិរញ្ញវត្ថុដែលបន្តប្រមូលផ្តុំ និងហានិភ័យសង្គម ដូចជា ការថយចុះយ៉ាង

[286] សន្ទស្សន៍មីក្រូហិរញ្ញវត្ថុនៃការទំនាក់ទំនង និងតិត្ថិភាពទីផ្សារ (MIMOSA) របាយការណ៍ស្តីពីប្រទេសកម្ពុជា ខែមីនា ឆ្នាំ២០២០ ទំ. ៧-៨។ របាយការណ៍នេះបានលើកឡើងថា "ប្រាក់កម្ចីខ្នាតតូចបំផុតចំនួន ៥០០ ដុល្លារ ឬតិចជាងនេះ ដែលប្រាក់កម្ចីស្ទើរតែទាំងអស់ស្ថិតនៅតំបន់ជនបទ បានថយចុះពី ៤៤% នៃការទំនាក់ទំនងសរុប នៅឆ្នាំ២០១៦ ទៅ ១៧% នៅឆ្នាំ២០១៩... ទន្ទឹមនឹងនេះ ចំណែកប្រាក់កម្ចីទំហំខ្នាតមធ្យម និងខ្នាតធំ (៥.០០០-២០.០០០ ដុល្លារ) បានកើនឡើងទ្វេដង ហើយប្រាក់កម្ចីខ្នាតធំបំផុត (២០.០០០ ដុល្លារឡើងទៅ) បានកើនឡើងបីដង"។

[287] គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីដាក់ចេញនូវវិធានចំនួនបួន៖ (១) លក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ទៅកាន់ CBC ដែលប្រសើរឡើង (២) ដែនកំណត់លើពហុប្រាក់កម្ចី ដែលមានប្រាក់កម្ចីជាលក្ខណៈបុគ្គលចំនួន ២ ឬប្រាក់កម្ចីជាក្រុមចំនួនបី ជាអតិបរមា (៣) ការទទួលស្គាល់ហានិភ័យនៃបុនហិរញ្ញប្បទានដែលមានភាពឈ្លានពាន (ដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាមួយដែនកំណត់ជាក់លាក់ នៅឆ្នាំ២០១៨) (៤) ការលើកកម្ពស់កិច្ចការពារអតិថិជន តាមរយៈ (i) ការទទួលស្គាល់សារៈសំខាន់នៃទ្រព្យសម្បត្តិដែលមានផលិតភាពចំពោះអតិថិជនដែលមានប្រាក់ចំណូលទាប និងទំនាក់ទំនងដែលថា កិច្ចខិតខំប្រឹងប្រែងដែលអាចធ្វើបានទាំងអស់គួរតែត្រូវបានធ្វើឡើង ដើម្បីបញ្ចៀសការលក់ទ្រព្យសម្បត្តិទាំងនោះ ជាពិសេសដីធ្លី ដើម្បីសងប្រាក់កម្ចី (ii) ការប្តេជ្ញាចិត្តត្រួតពិនិត្យឡើងវិញលើគ្រោងការណ៍លើកទឹកចិត្តដើម្បីបង្កើនកិច្ចការពារអតិថិជននៅក្នុងដំណើរការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ (iii) ការប្តេជ្ញាចិត្តបង្កើត និងអនុវត្តគោលនយោបាយច្បាស់លាស់សម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញ និងរៀបចំកាលវិភាគនៃប្រាក់កម្ចីឡើងវិញ សម្រាប់អតិថិជនដែលមិនអាចបំពេញតាមការសន្យាសងប្រាក់របស់ពួកគេ ស្របតាមគោលការណ៍ណែនាំរបស់យុទ្ធនាការឆ្លាតវៃ និង (iv) កាត់បន្ថយបន្តិចម្តងៗ នូវការចូលរួមរបស់អាជ្ញាធរមូលដ្ឋានជាភ្នាក់ងារគ្រប់គ្រងធនាគារភូមិ ជាពិសេសសម្រាប់ការប្រមូលការបង់រំលោះប្រាក់កម្ចី។ វិធានទីបួននេះមិនមានលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ជាក់លាក់ ឬគ្រោងការណ៍ពិនិត្យតាមដាននោះទេ។ របាយការណ៍ពិនិត្យតាមដានគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី ឆ្នាំ២០២៣ របស់អតិថិជន/អតិថិជនបន្តចំនួនបីរបស់ IFC បានបង្ហាញពីហានិភ័យកម្រិតខ្ពស់ និងមធ្យម ក្នុងការផ្តល់បុនហិរញ្ញប្បទាននៅក្នុងដែនកំណត់ដែលបានកំណត់។

[288] ស៊ីអេអូទទួលស្គាល់ថា អ្នកខ្ចី ពេលខ្លះ ស្នើសុំប្រាក់កម្ចីកាន់តែច្រើន ដោយដឹងថា ជាធម្មតា ប្រាក់កម្ចីទាំងនេះផ្តល់រយៈពេលសងប្រាក់យូរជាង នៅខណៈពេលដែលមានការបង់រំលស់ប្រចាំខែស្រដៀងគ្នា។ នៅខណៈពេលដែលបុនហិរញ្ញប្បទានមិនត្រូវបានផ្តួចផ្តើមឡើងដោយអ្នកឱ្យខ្ចីប្រាក់ទាំងស្រុងនោះ ស៊ីអេអូបានទទួលសក្ខីកម្មដែលបង្ហាញថា អ្នកឱ្យខ្ចីប្រាក់មួយចំនួនបានលើកទឹកចិត្តអ្នកខ្ចីឱ្យយកប្រាក់កម្ចីដែលបានផ្តល់បុនហិរញ្ញប្បទានក្នុងចំនួនច្រើនជាងការស្នើសុំលើកដំបូង។

[289] ការវាយតម្លៃផលប៉ះពាល់ MCRIL-CMA ឆ្នាំ២០២៣ ទំ. ៤៩

ខ្លាំងនៃមុខរបរចិញ្ចឹមជីវិត សន្តិសុខស្បៀង ឬការបាត់បង់ដីធ្លី។ នៅខណៈពេលដែលផលធៀបបំណុល និងប្រាក់ចំណូល អាចចាត់ទុកថាអាចទទួលយកសម្រាប់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ ដែលមានរយៈពេល ១-២ ឆ្នាំនោះ ការប្រឈមនឹងបំណុលកម្រិតនេះក្នុងរយៈពេលវែងអាចកាត់បន្ថយយ៉ាងខ្លាំងក្លានូវភាពធន់របស់គ្រួសារចំពោះវិបត្តិប្រាក់ចំណូល ការបាត់បង់មុខរបរចិញ្ចឹមជីវិត ឬការរឹបអូសទ្រព្យសម្បត្តិ។ ថាមវន្តនេះជាលក្ខណៈពិសេសមួយនៃទីផ្សារមីក្រូហិរញ្ញវត្ថុកម្ពុជា។ ប៉ុន្តែ ការត្រួតពិនិត្យរបស់ស៊ីអេអូបានរកឃើញភស្តុតាងតិចតួចដែលថា អតិថិជន និងអតិថិជនបន្តរបស់ IFC មិនបានគិតគូរជាប្រព័ន្ធលើហានិភ័យដែលអាចកើតឡើងនេះនៅពេលវាយតម្លៃសមត្ថភាពសងប្រាក់របស់អ្នកខ្ចី។

ផ្អែកលើព័ត៌មានដែលបានត្រួតពិនិត្យ រួមទាំងការសង្កេតនៅទីវាលរបស់ស៊ីអេអូដោយផ្ទាល់ ការអនុវត្តបុនហិរញ្ញប្បទានយ៉ាងឆាប់រហ័ស និងមានហានិភ័យខ្ពស់ បង្ហាញពីចន្លោះប្រហោងនៃសមិទ្ធកម្មផ្នែកនៃការវិនិយោគទាំងនេះ ទាក់ទងនឹងលក្ខខណ្ឌតម្រូវរបស់ PS1 ដើម្បីធានាថា ផលប៉ះពាល់អវិជ្ជមានលើសហគមន៍ដែលរងផលប៉ះពាល់ ត្រូវបានបញ្ចៀស ឬកាត់បន្ថយ។

c) *ការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ដែលឈ្លានពាន*

ដោយពិចារណាលើភាពងាយរងគ្រោះរបស់ប្រជាជន ដែលកម្ចីមីក្រូហិរញ្ញវត្ថុព្យាយាមផ្តល់សេវាជូន GIIP សង្កត់ធ្ងន់លើតម្រូវការការការពារ ដើម្បីទប់ស្កាត់ និងកែតម្រូវការប្រព្រឹត្តិដោយឈ្លានពាន ឬបំពាន ដោយបុគ្គលិក និងភ្នាក់ងារ FI ជាពិសេសក្នុងអំឡុងពេលផ្តល់ប្រាក់កម្ចី និងដំណើរការប្រមូលបំណុល។[290] ការការពារទាំងនេះក៏គួរតែគ្របដណ្តប់លើបច្ចេកទេសលក់ដែលឈ្លានពាន និងការអនុវត្តការប្រមូលបំណុលដោយមិនសមស្រប[291] ដូចជា ការបំភិតបំភ័យ ភាសារំលោភបំពាន ការប្រើកម្លាំងបាយ ការដាក់កម្រិតលើសេរីភាពផ្លូវកាយ ការបៀតបៀនផ្លូវភេទ ការចូលទៅក្នុងផ្ទះអតិថិជនដោយមិនបានអញ្ជើញ ការបង្កភាពអាម៉ាស់ជាសាធារណៈ និងការគំរាមកំហែង។ បន្ថែមពីលើគោលការណ៍ណែនាំរបស់ GIIP ទាក់ទងនឹងសិទ្ធិរបស់អតិថិជនចំពោះការប្រព្រឹត្តិដោយការគោរព ក្នុងអំឡុងពេលដំណើរការប្រមូលប្រាក់កម្ចីទៀតនោះ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នៃកម្ពុជាក៏ហាមឃាត់រាល់ទម្រង់នៃការគំរាមកំហែង និងការបំភិតបំភ័យ នៅក្នុងដំណើរការទារប្រាក់កម្ចីដោយធនាគារផងដែរ។[292] បទបញ្ជារបស់ក្រសួង ឆ្នាំ២០១៧ ហាមឃាត់អាជ្ញាធរមូលដ្ឋានបន្ថែមទៀត (ឧ. នគរបាល មេភូមិ មេឃុំ និងអភិបាលស្រុក) ពីការចូលរួមនៅក្នុងសកម្មភាពរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ឬ "ធ្វើសកម្មភាពរួមគ្នា" ជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុ លើកលែងតែអនុវត្តតាមដីកាតុលាការ។[293]

នៅកម្រិតវិស័យ ក្រមប្រតិបត្តិធនាគារ និងហិរញ្ញវត្ថុ ឆ្នាំ២០២២ ហាមឃាត់ការប្រព្រឹត្តិអំពើហិង្សា ភាសាគំរាម

[290] យុទ្ធនាការឆ្លាតវៃ, SPTF, Cerise គោលការណ៍ការពារអតិថិជន https://bit.ly/3Fqg2AR.

[291] Cerise+ SPTF ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ទំ. ៣១

[292] Cerise+ SPTF ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ទំ. ៣១ "មិនមានជនណាម្នាក់បង្ខិតបង្ខំដោយប្រើកម្លាំង ការរំខាន ឬការគំរាមកំហែងផ្លូវចិត្ត ពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ឬការទូទាត់ថ្លៃទំនិញ និងសេវាកម្មនោះទេ"។ មាត្រា ១៩ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ – រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០១៩)។ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ (នស/រកម/១១១៩/០១៦) ភ្នំពេញ។ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់កម្ពុជាមិនគ្របដណ្តប់លើសេវាហិរញ្ញវត្ថុរបស់អ្នកផ្តល់សេវាមិនមែនធនាគារនោះទេ។

[293] ក្រសួងមហាផ្ទៃ (ឆ្នាំ២០១៧) បទបញ្ជាក្រសួង (ប្រកាស) លេខ ៥៥៦ ស/ជ/ណ ស្តីពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ ភ្នំពេញ។

គំហែង ការរំលោភបំពាន ការបំភិតបំភ័យ និងការបៀតបៀនអតិថិជន និងសាច់ញាតិរបស់ពួកគេ កំណត់ពេលវេលាដែលបុគ្គលិក MFI អាចទាក់ទងអតិថិជន និងទប់ស្កាត់ពួកគេមិនឲ្យព្យាយាមទាក់ទងអ្នកប្រើប្រាស់ដែលបានបដិសេធផលិតផលយ៉ាងច្បាស់លាស់រួចហើយ។[294]

ទោះបីជាមានក្របខណ្ឌការពារទាំងនេះក៏ដោយ ក៏ការស៊ើបអង្កេតរបស់ស៊ីអេអូបានចងក្រងភស្តុតាងពីសក្ខីកម្មរបស់អ្នកខ្ចីដែលថា ការអនុវត្តដោយឈ្លានពាននៅតែកើតឡើងក្នុងចំណោម BFIs ទាំងប្រាំមួយ ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ។ ការអនុវត្តទាំងនេះអាចធ្វើឱ្យជនងាយរងគ្រោះនៅកម្ពុជាទទួលបានប្រាក់កម្ចីលើសលុបដែលពួកគេមិនមានលទ្ធភាពសង ហើយងាកទៅរកយន្តការទប់ទប់ដែលអស់សង្ឃឹម និងបង្កគ្រោះថ្នាក់ដើម្បីសងប្រាក់កម្ចីរបស់ពួកគេ៖

*ការអនុវត្តការផ្តល់ប្រាក់កម្ចីដែលឈ្លានពាន*

ជនងាយរងគ្រោះដែលទទួលប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ ជាញឹកញាប់ មានប្រាក់ចំណូលទាប មានអក្ខរកម្មផ្នែកច្បាប់ និងហិរញ្ញវត្ថុកម្រិតទាប ហើយក្នុងករណីជាច្រើន មានចំណេះដឹងភាសាខ្មែរតិចតួច។ ជាលទ្ធផល ពួកគេជាញឹកញាប់ មិនមានការយល់ដឹងយ៉ាងពេញលេញអំពីលក្ខខណ្ឌនៃប្រាក់កម្ចី ថ្លៃសេវាដែលពាក់ព័ន្ធ និងសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេ ទាក់ទងនឹងការទូទាត់ប្រាក់ និងការអនុវត្តច្បាប់លើវត្ថុបញ្ចាំ ជម្រើសនៃការសងប្រាក់ និងឧបាស្រ័យនោះទេ។ ដូច្នេះ ពួកគេងាយទទួលរងសម្ពាធក្នុងការទទួលយកប្រាក់កម្ចី លើសពីចំនួនដែលពួកគេត្រូវការ និង/ឬមិនមានសមត្ថភាពសងប្រាក់។

ការអនុវត្តដែលបានរាយការណ៍មកកាន់ស៊ីអេអូ រួមមាន៖

- **ការផ្សព្វផ្សាយដោយផ្ទាល់ជាប្រចាំ៖** អ្នកផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុជាច្រើន ពឹងផ្អែកលើការផ្សាយពាណិជ្ជកម្មដោយផ្ទាល់ ជាយុទ្ធសាស្រ្តលក់ចម្បងរបស់ពួកគេ ដែលអាចបង្កើតសម្ពាធសង្គម និងផ្លូវចិត្តលើសហគមន៍ក្នុងការខ្ចីប្រាក់។[295] ការសិក្សាមួយ នៅឆ្នាំ២០២២ បានរកឃើញថា ភូមិដែលមានគ្រួសារជំពាក់បំណុលគេ ប្រហែល ៦០% បានទទួលការចុះសួរសុខទុក្ខ ៤៥០ ដងក្នុងមួយខែ ពីតំណាង MFIs។[296] ស៊ីអេអូបានត្រួតពិនិត្យឯកសារបណ្តុះបណ្តាលផ្ទៃក្នុងរបស់ BFIs មួយចំនួន ដែលបានលើកទឹកចិត្តឲ្យមានការផ្សព្វផ្សាយដោយផ្ទាល់ម្តងហើយម្តងទៀត រួមទាំងការចុះទៅតាមគេហដ្ឋាន ឬកន្លែងធ្វើការផងដែរ ទោះបីជាអតិថិជនប្រហែលជាមិនទាន់ត្រៀមខ្លួនរួចរាល់សម្រាប់ប្រាក់កម្ចីក៏ដោយ។[297]
- **ការកំណត់ទំហំប្រាក់កម្ចីដោយផ្អែកលើតម្លៃវត្ថុបញ្ចាំ** ជាជាងសមត្ថភាពសងប្រាក់។ អ្នកដែលត្រូវបានសម្ភាសបាននិយាយថា ពួកគេត្រូវបានបញ្ចុះបញ្ចូលឱ្យខ្ចីប្រាក់ច្រើនជាងការស្នើសុំលើកដំបូង

[294] ក្របប្រតិបត្តិធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ឆ្នាំ២០២២ ទំ. ១០-១១ https://bit.ly/41ZQnX8។

[295] នៅខែសីហា ឆ្នាំ២០២៥ BFI មួយបានលើកឡើងថា គិតត្រឹមឆ្នាំ២០២៥ ពួកគេបានបង្កើតគោលការណ៍ណែនាំថ្មីមួយស្តីពីការអនុវត្តការលក់ប្រកបដោយសីលធម៌ និងទំនួលខុសត្រូវ (រួមទាំងការលក់ដោយឈ្លានពានផងដែរ) ដើម្បីអនុលោមតាមស្តង់ដារការពារអតិថិជន។

[296] របាយការណ៍ Bliss ទំ. ៧២

[297] ស៊ីអេអូកត់សម្គាល់ថា មានតែ BFI ដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងនេះ តែមួយគត់ ដែលហាក់បីដូចជាហាមឃាត់យ៉ាងច្បាស់លាស់ចំពោះការផ្តល់ប្រាក់កម្ចី នៅពេលដែលអតិថិជនមិនត្រូវការថវិកា។ នៅខែសីហា ឆ្នាំ២០២៥ BFI មួយបានលើកឡើងថា គិតត្រឹមឆ្នាំ២០២៥ ពួកគេបានបង្កើតគោលការណ៍ណែនាំថ្មីមួយស្តីពីការអនុវត្តការលក់ប្រកបដោយសីលធម៌ និងទំនួលខុសត្រូវ (រួមទាំងការលក់ដោយឈ្លានពានផងដែរ) ដើម្បីអនុលោមតាមស្តង់ដារការពារអតិថិជន។

ដោយផ្អែកលើតម្លៃវត្ថុបញ្ចាំរបស់ពួកគេ ជាជាងតម្រូវការជាក់ស្តែង ឬសមត្ថភាពក្នុងការសងប្រាក់ ដែលបង្កើនហានិភ័យនៃបំណុលវ័ណ្ឌក។

- **ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន**ក្នុងការលើកកម្ពស់ប្រាក់កម្ចី។ អ្នកដែលត្រូវបានសម្ភាសបានរាយការណ៍ថា មេភូមិ និងមេឃុំ ជារឿយៗចូលរួមក្នុងការផ្សព្វផ្សាយផលិតផលប្រាក់កម្ចី និងក្នុងករណីខ្លះ ក្នុងការផ្តល់ប្រាក់កម្ចី ទោះបីជាមានការហាមឃាត់ពីរដ្ឋាភិបាលលើការចូលរួមបែបនេះក៏ដោយ។[298] CAO បានសង្កេតឃើញថា យុទ្ធសាស្ត្រលក់របស់អតិថិជន/អតិថិជនបន្តរបស់ IFC ចំនួនពីរ បានណែនាំយ៉ាងច្បាស់លាស់ដល់បុគ្គលិកឱ្យចូលរួមជាមួយអាជ្ញាធរមូលដ្ឋានក្នុងការផ្សព្វផ្សាយ និងការកំណត់គោលដៅអតិថិជនសក្តានុពល ដែលម្នាក់ក្នុងចំណោមពួកគេជាថ្នូរនឹងអត្ថប្រយោជន៍។

*ការអនុវត្តការប្រមូលប្រាក់ដោយឈ្លានពាន*

អតិថិជន និងអតិថិជនបន្តរបស់ IFC ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ ជាទូទៅបានចារអនុម័តលើគោលការណ៍អនុវត្តដោយយុត្តិធម៌ និងការគោរពចំពោះអ្នកខ្ចី ហើយបានអនុម័តក្រមសីលធម៌ ការបណ្តុះបណ្តាល និងគោលនយោបាយ ដែលហាមឃាត់ការគំរាមកំហែង និងការបង្ខិតបង្ខំ និងទាមទារឱ្យមានការប្រព្រឹត្តិដោយយុត្តិធម៌ និងការគោរពចំពោះអតិថិជនរបស់ពួកគេ។ ឧទាហរណ៍ អតិថិជន/អតិថិជនបន្តរបស់ IFC ចំនួនពីរ ផ្តល់ជូនបុគ្គលិកនូវកម្មវិធីបណ្តុះបណ្តាល និងបញ្ជីការអនុវត្តសមរម្យ និងមិនសមរម្យ (ក្រោយមក រួមបញ្ចូលការដាក់ស្លាកសញ្ញា "សម្រាប់លក់" នៅលើផ្ទះរបស់អ្នកខ្ចី ការចាក់សោផ្ទះរបស់ពួកគេ ឬការរឹបអូសទ្រព្យសម្បត្តិដូចជា រថយន្ត គ្រឿងសង្ហារឹម និងបសុសត្វ ជាដើម)។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងទាំងនេះក៏ដោយ ក៏ស៊ីអេអូបានទទួលរបាយការណ៍ជាច្រើនស្តីពីការអនុវត្តដែលផ្ទុយពីការប្តេជ្ញាចិត្តទាំងនេះ។[299] ក្រៅពីករណីនេះ ភាគីពាក់ព័ន្ធនៅក្នុងវិស័យនេះ និងការសិក្សានានា ទទួលស្គាល់បន្ថែមទៀតលើការអនុវត្តការប្រមូលប្រាក់ដែលមានការបោកបញ្ឆោតមួយចំនួន និងរបាយការណ៍របស់បុគ្គលិកនៅទីវាលរបស់ BFI អំពីការប្រើកលយុទ្ធទារប្រាក់កម្ចីដោយបង្ខំ ដូចជា "ការរាយការណ៍ទៅកាន់នគរបាល" ឬការគំរាមកំហែងនៃសម្ពាធសហគមន៍ ឬវិធានការតាមផ្លូវច្បាប់។[300] ការស្ទង់មតិដែលបានធ្វើឡើងក្នុងឆ្នាំ២០២៣ អ្នកខ្ចីប្រាក់នៃប្រទេសកម្ពុជាចំនួន ២.៩៣៩ នាក់ បានរាយការណ៍ថា មានអ្នកខ្ចីតែ ៤០% ប៉ុណ្ណោះដែល 'យល់ស្របយ៉ាងខ្លាំង' ថា ភ្នាក់ងារអ្នកផ្តល់សេវាហិរញ្ញវត្ថុប្រព្រឹត្តចំពោះពួកគេដោយយុត្តិធម៌ និងការគោរព បើធៀបនឹងអតិថិជន ៦៨% នៅតាមបណ្តាប្រទេសដទៃទៀតនៅអាស៊ី។[301]

ការអនុវត្តការទារប្រាក់កម្ចីដោយឈ្លានពានអាចដាក់សម្ពាធលើជនងាយរងគ្រោះ ឲ្យងាកទៅរកដំណោះស្រាយ

---

298 ជាពិសេស អ្វីដែលអាចបង្កើតការយល់ច្រឡំក្នុងចំណោមប្រជាជនទូទៅ រវាងគំនិតផ្តួចផ្តើមរបស់រដ្ឋ និងសកម្មភាពរបស់វិស័យឯកជន រួមទាំងការធ្វើជាភ្នាក់ងារផ្តល់ប្រាក់កម្ចីផងដែរ។ ក្រសួងមហាផ្ទៃ (ឆ្នាំ២០១៧) បទបញ្ជាក្រសួង លេខ ៥៥៦ ស/ជ/ណ ស្តីពី ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ ភ្នំពេញ។

299 ព័ត៌មាននេះត្រូវបានទទួលតាមរយៈការសម្ភាសអតិថិជនរបស់ BFIs ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះ រួមទាំងអ្នកខ្ចីប្រាក់ដែលមិនមែនជាដើមបណ្តឹង ព្រមទាំងតាមរយៈការត្រួតពិនិត្យការសិក្សាដែលពាក់ព័ន្ធផងដែរ។

300 Incofin, មីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្នុងសំណួរសំខាន់ៗចំនួន ៨ ខែកញ្ញា ឆ្នាំ២០២៣ https://bit.ly/៤៣URuKg; របាយការណ៍ Bliss បានសន្និដ្ឋានថា ករណីបែបនេះជាករណីភាគតិច ឬជារឿងតូចតាច (ករណីតិចជាង ១%) របាយការណ៍ Bliss ទំ. ៦៧; https://bit.ly/4hQ៩b15 300 L.Goldstein, E.Sea, សញ្ញាបណ្ណបៃតង ទង់ក្រហម៖ វិបត្តិមីក្រូហិរញ្ញវត្ថុនៅកម្ពុជាធ្វើឲ្យនិរន្តរភាពនៃការងារតាមផ្ទះមានភាពស៊ីជម្រៅ Dialogue Earth, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ https://bit.ly/3DVJZrT

301 ការស្ទង់មតិ ៦០ ដេស៊ីបែល ទំ.៨

ដែលអស់សង្ឃឹម និងមានគ្រោះថ្នាក់ ក្នុងការសងប្រាក់កម្ចីរបស់ពួកគេ។ ឧទាហរណ៍ពីសក្ខីកម្មរបស់ដើមបណ្តឹង រួមមាន ការលក់ដី ឬផ្ទះរបស់ពួកគេ នៅពេលខ្លះទាបជាងតម្លៃទីផ្សារ ហើយក្នុងករណីមួយចំនួន លក់ប្រភពចំណូលចម្បងរបស់ពួកគេ កាត់បន្ថយបរិមាណ និងគុណភាពអាហាររបស់ពួកគេ បញ្ឈប់កូនពីសាលារៀន និងដាក់ពួកគេឱ្យធ្វើការ សមាជិកគ្រួសារធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើ ជាញឹកញាប់ ក្នុងលក្ខខណ្ឌអសុវត្ថិភាព ឬមានការកេងប្រវ័ញ្ច និងទទួលយកប្រាក់កម្ចីកាន់តែច្រើន ឬខ្ចីប្រាក់ពីអ្នកផ្តល់ប្រាក់កម្ចីក្រៅប្រព័ន្ធ។

ក្នុងអំឡុងពេលស៊ើបអង្កេតនេះ អ្នកខ្ចី រួមទាំងដើមបណ្តឹង បានរាយការណ៍ទៅកាន់ស៊ីអេអូថា អ្នកផ្តល់ប្រាក់កម្ចីនៅក្នុងសំណុំរឿងនេះ ជាញឹកញាប់ ងាកទៅរកការអនុវត្តការប្រមូលប្រាក់ដោយឈ្លានពាន ដូចខាងក្រោម៖

- **ការចុះជួបជាញឹកញាប់ និងរយៈពេលយូរ៖** អ្នកខ្ចីប្រាក់បានរាយការណ៍ថា បុគ្គលិក BFI បានទៅផ្ទះ កន្លែងធ្វើការ និងភូមិរបស់ពួកគេជាញឹកញាប់ នៅពេលខ្លះ ជាច្រើនដងក្នុងមួយសប្តាហ៍។[302] ការចុះជួបទាំងនេះ ជាញឹកញាប់ អូសបន្លាយពេលជាច្រើនម៉ោង ហើយក្នុងករណីមួយចំនួន មានការចូលរួមពីមន្ត្រីមូលដ្ឋាន។ ស៊ីអេអូបានត្រួតពិនិត្យសម្ភារៈបណ្តុះបណ្តាលពី BFI មួយចំនួន ដែលណែនាំបុគ្គលិកឱ្យដាក់សម្ពាធផ្លូវចិត្ត ក្នុងអំឡុងពេលប្រមូលប្រាក់ រួមទាំងការហៅទូរសព្ទម្តងហើយម្តងទៀត និងការជម្រុញអ្នកខ្ចីឲ្យលក់ដីផងដែរ។ អ្នកខ្ចីជាច្រើននាក់បានយល់ឃើញថា កលយុទ្ធទាំងនេះគឺជាការបំភិតបំភ័យ និងការគំរាមកំហែង។ ស្របតាមការរាយការណ៍ជាសាធារណៈ[303] ដើមបណ្តឹងបានពិពណ៌នាពីការចុះជួបម្តងហើយម្តងទៀត ដែលបុគ្គលិក BFI មួយចំនួន មានឥរិយាបថឈ្លានពាន ស្តីបន្ទោស ឬគំរាមកំហែង រួមទាំងការនាំមន្ត្រីមូលដ្ឋានទៅជាមួយផងដែរ។ ក្នុងករណីមួយចំនួន មានការចូលរួមពីវិមាត្រយេនឌ័រ ដែលអ្នកខ្ចីជាស្ត្រី ឬសមាជិកគ្រួសារជាស្ត្រីរបស់អ្នកខ្ចីគឺជាអ្នកចុងក្រោយដែលទទួលការគម្រាមកំហែង សម្ពាធ ឬការចុះជួប នៅពេលដែលមន្ត្រីប្រមូលប្រាក់មានវត្តមាននៅផ្ទះរបស់អ្នកខ្ចីជាច្រើនម៉ោង។ ឯកសារដែលត្រូវបានត្រួតពិនិត្យដោយស៊ីអេអូបង្ហាញថា អតិថិជន និងអតិថិជនបន្តរបស់ IFC មួយចំនួន រួមបញ្ចូលនៅក្នុងដំណើរការទារប្រាក់កម្ចីរបស់ពួកគេ នូវការអនុវត្តការទាក់ទងទៅកាន់សាច់ញាតិ និយោជក ឬអ្នកដទៃទៀត ដែលមានឥទ្ធិពលលើអ្នកខ្ចី ដែលនៅពីក្រោយការទូទាត់ប្រាក់របស់ពួកគេ។[304] ដោយសារទំនាក់ទំនងផ្នែកវប្បធម៌រវាងបំណុល និងភាពអាម៉ាស់ ឥរិយាបថអាចត្រូវបានយល់ឃើញថា មានការបង្ខិតបង្ខំ និងដាក់សម្ពាធកាន់តែខ្លាំង នៅពេលមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន។[305]

---

302 ដើមបណ្តឹង ១៥ នាក់បានយល់ឃើញថា វត្តមានរបស់បុគ្គលិកនៅផ្ទះ ឬភូមិរបស់ពួកគេដោយមិនស្វាគមន៍ គឺជាការបំភិតបំភ័យ។

303 អ្នកខ្ចីម្នាក់បានពន្យល់ប្រាប់អង្គភាពសារព័ត៌មានមួយ ក្នុងអំឡុងពេលសម្ភាសន៍នាពេលថ្មីៗនេះជាមួយ VOA ខ្មែរ ថា៖ "ពួកគេនឹងមកផ្ទះខ្ញុំជាមួយមនុស្សជាច្រើននាក់ ម៉ូតូពី ៣ ទៅ ៥ គ្រឿង ហើយក៏នាំមេភូមិមកជាមួយដែរ"។ នាងមិនអាចទប់ទល់នឹងភាពតានតឹង និងភាពអាម៉ាស់បានទេ។ នាងបានបោះបង់ចោលផ្ទះរបស់នាង ហើយជួលបន្ទប់មួយក្នុងតម្លៃ ៤០ ដុល្លារក្នុងមួយខែ។ Narin Sun ប្រជាជនកម្ពុជាប្រឈមមុខនឹងការឈឺចុកចាប់កាន់តែខ្លាំងពីបំណុលមីក្រូហិរញ្ញវត្ថុ VOA ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៤ មាននៅ៖ https://bit.ly/4hQ9b15។

304 បន្ថែមពីលើឯកសារបណ្តុះបណ្តាលរបស់ BFIs ទៀតនោះ ដើមបណ្តឹងចំនួនប្រាំមួយនាក់បានរាយការណ៍ថា BFIs ដែលមានឈ្មោះនៅក្នុងការស៊ើបអង្កេតនេះ បានទាក់ទងសាច់ញាតិរបស់ពួកគេ ទាក់ទងនឹងបំណុលដែលហួសកាលកំណត់របស់ពួកគេ។

305 Green, Bylander អំណាចផ្តាច់មុខនៃមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០២១ ទំ. ២១៩-២២០។

- **ការចូលរួមរបស់មេភូមិ និងមេឃុំ ក្នុងការទារបំណុល៖** ទោះបីជាក្រសួងមហាផ្ទៃបានចេញបទបញ្ជារបស់ក្រសួងនៅឆ្នាំ២០១៧ ហាមឃាត់អាជ្ញាធរមូលដ្ឋានមិនឱ្យចូលរួមក្នុងការប្រមូលបំណុលក៏ដោយ [306] ក៏ BFIs ចំនួនប្រាំ ក្នុងចំណោម BFIs ទាំងប្រាំមួយ មានគោលនយោបាយដែលរួមបញ្ចូលការស្នើសុំការគាំទ្រពីអាជ្ញាធរមូលដ្ឋាន សម្រាប់យុទ្ធសាស្ត្រប្រមូលបំណុល។ អ្នកខ្ចីដែលត្រូវបានសម្ភាសដោយស៊ីអេអូ បានរាយការណ៍ថា អតិថិជន និងអតិថិជនបន្តរបស់ IFC ទាំងប្រាំមួយបានរួមបញ្ចូលអាជ្ញាធរមូលដ្ឋាននៅក្នុងដំណើរការប្រមូលបំណុលរបស់ពួកគេ[307] ដោយស្នើសុំឱ្យមេភូមិ ឬមេឃុំចេញលិខិតទៅកាន់អ្នកសងបំណុលយឺតយ៉ាវ ឬកោះហៅពួកគេទៅកាន់ការិយាល័យ ឬសាលសាធារណៈ ដើម្បីពន្យល់ពីការលំបាក ឬបញ្ជាក់ពីចេតនារបស់ពួកគេទាក់ទងនឹងការសងប្រាក់។ យោងតាមដើមបណ្តឹង សង្គមស៊ីវិល និងអ្នកសិក្សាដែលមានចំណេះដឹងអំពីបរិបទសង្គមកម្ពុជា ការអនុវត្តទាំងនេះអាចបង្កើតការភ័យខ្លាច ការចប់បារម្ភ និងភាពអាម៉ាស់ក្នុងចំណោមអ្នកខ្ចីប្រាក់មីក្រូហិរញ្ញវត្ថុ។ [308] IFC និង BFI មួយ ដែលត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះ ផ្តល់ទឡ្ហីករណ៍ថា ការអនុវត្តមួយចំនួនមិនត្រូវបានហាមឃាត់ នៅក្រោមបទប្បញ្ញត្តិរបស់ប្រទេសកម្ពុជានោះទេ ពីព្រោះវាអាចជាតួនាទីរបស់អាជ្ញាធរមូលដ្ឋាន ក្នុងការសម្របសម្រួល និងជួយដោះស្រាយវិវាទ។ ស្របពេលជាមួយគ្នានេះ BFI មួយផ្សេងទៀត នាពេលថ្មីៗនេះ បានចេញសេចក្តីក្រើនរំឭកដល់បុគ្គលិកឱ្យចៀសវាងការស្នើសុំការគាំទ្រពីអាជ្ញាធរមូលដ្ឋានសម្រាប់ការដោះស្រាយប្រាក់កម្ចីនៅខាងក្រៅប្រព័ន្ធតុលាការ ពីព្រោះវាត្រូវបានហាមឃាត់ដោយបទប្បញ្ញត្តិរបស់រដ្ឋាភិបាល។

ការកំណត់ថាតើការអនុវត្តការចូលរួមរបស់អាជ្ញាធរមូលដ្ឋានរំលោភលើអនុក្រឹត្យជាតិជាក់លាក់ដែរឬទេនោះ ស្ថិតនៅក្រៅអាណត្តិរបស់ស៊ីអេអូ ហើយវាជាបញ្ហារបស់អាជ្ញាធរជាតិ។ ដោយមិនគិតថាតើមេភូមិ និងមេឃុំធ្វើសកម្មភាពក្នុងតួនាទីសម្របសម្រួលជាផ្លូវការដែរឬទេនោះ ស៊ីអេអូតែងតែស្តាប់ឮពីដើមបណ្តឹង សង្គមស៊ីវិល និងអ្នកសិក្សាថា អាជ្ញាធរមូលដ្ឋានគឺជាតួអង្គដែលមានឥទ្ធិពលនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកភូមិនៅប្រទេសកម្ពុជា។ [309] ហើយការអនុវត្តទាំងនេះអាចបង្កើតការភ័យខ្លាច និងការយល់ច្រឡំក្នុងចំណោមអ្នកខ្ចីប្រាក់ដែលងាយរងគ្រោះ ដែលពួកគេភាគច្រើនមិនបានដឹងច្បាស់អំពីភាពខុសគ្នារវាងរដ្ឋាភិបាល និងតួអង្គឯកជននោះទេ។ ការដោះស្រាយបញ្ហានេះហាក់បីដូចជាគោល

[306] ក្រសួងមហាផ្ទៃ (ឆ្នាំ២០១៧) បទបញ្ជារបស់ក្រសួង លេខ ៥៥៦ ស/ជ/ណ ស្តីពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ ភ្នំពេញ។ អត្ថបទ ឬបទបញ្ជានេះបង្ហាញថា "លុះត្រាតែត្រូវបានតម្រូវតាមផ្លូវច្បាប់ឲ្យមានការចូលរួមអនុវត្តសាលក្រមតុលាការ អាជ្ញាធរស្រុក/ក្រុង/ខណ្ឌ ឃុំ/សង្កាត់ និងភូមិ មិនត្រូវធ្វើសកម្មភាពរួមគ្នាជាមួយធនាគារឯកជន MFIs និងប្រតិបត្តិករឥណទានជនបទ (ដែលបង្កឱ្យមានការយល់ច្រឡំក្នុងចំណោមប្រជាជន ថាធនាគារ MFIs និងប្រតិបត្តិករទាំងនេះជារបស់រដ្ឋ) រួមទាំងការដើរតួជាអ្នកធានាក្នុងប្រតិបត្តិការប្រាក់កម្ចី ឬជាភ្នាក់ងារ ឬអ្នកធានាសងបំណុល ឬទាមទារការសងប្រាក់ពីប្រជាជន ការផ្សាយពាណិជ្ជកម្មសម្រាប់ស្ថាប័នហិរញ្ញវត្ថុណាមួយ ឬចូលរួមក្នុងការរឹបអូសវត្ថុបញ្ចាំរបស់ប្រជាជននោះទេ"។

[307] ដើមបណ្តឹងប្រាំនាក់ ត្រូវបានអតិថិជន/អតិថិជនបន្តរបស់ IFC ចំនួនបួន កោះហៅទៅជួបមេភូមិ និងមេឃុំរបស់ពួកគេ នៅពេលដែលពួកគេមិនអាចសងបំណុលបាន។ ស៊ីអេអូបានទទួលភស្តុតាងនៃលិខិតចំនួនដប់ពីរច្បាប់ ចុះកាលបរិច្ឆេទនៅចន្លោះឆ្នាំ២០១៩ និង ឆ្នាំ២០២៣ ដែលអញ្ជើញ ឬកោះហៅអ្នកខ្ចីប្រាក់ឱ្យចូលរួមកិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋានទាក់ទងនឹងប្រាក់កម្ចីយឺតយ៉ាវរបស់ពួកគេ ជាមួយអតិថិជន/អតិថិជនបន្តរបស់ IFC ចំនួនបី។

[308] Green, Bylander អំណាចផ្តាច់មុខនៃមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០២១ ទំ. ២២០។

[309] N. Green និយ័តកម្មបំណុលវ័ណ្ណកៈ អំណាចរដ្ឋក្នុងស្រុក នៅក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុកម្ពុជា ការអភិវឌ្ឍ និងការផ្លាស់ប្តូរ វិទ្យាស្ថានសិក្សាសង្គមអន្តរជាតិ ឆ្នាំ២០២០

បំណងចម្បងមួយរបស់អនុក្រឹត្យ។ ការរួមបញ្ចូលគ្នានៃអំណាចមូលដ្ឋាន ភាពអាម៉ាស់ និងទំនួលខុសត្រូវផ្នែកសីលធម៌ ជាញឹកញាប់ ជម្រុញឱ្យអ្នកខ្ចីប្រាក់ដែលងាយរងគ្រោះប្រើយុទ្ធសាស្ត្រទប់ទល់ដើម្បីសងបំណុលរបស់ពួកគេ។[310] ដើមបណ្តឹងប្រាំនាក់ ក្នុងចំណោមដើមបណ្តឹងទាំងប្រាំបីនាក់ ដែលបានប្រឈមមុខនឹងការកោះហៅជាកស្តែង ឬគំរាមកោះហៅទៅជួបអាជ្ញាធរមូលដ្ឋានទាក់ទងនឹងបំណុលយឺតយ៉ាវរបស់ពួកគេ បានបញ្ចប់ដោយការលក់ដីមួយចំនួនដើម្បីសងប្រាក់អតិថិជន/អតិថិជនបន្តរបស់ IFC ដោយបាត់បង់មុខរបរចិញ្ចឹមជីវិតរបស់ពួកគេមួយផ្នែក នៅក្នុងដំណើរការនេះ (សូមមើលព័ត៌មានលម្អិតបន្ថែមនៅក្នុងផ្នែក ៥.២)។

- **ការគំរាមកំហែងទាក់ទងនឹងការរឹបអូសយកដី ឬផ្ទះ៖** ដីគឺជាទម្រង់វត្ថុបញ្ចាំទូទៅបំផុត ដែលប្រើសម្រាប់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដោយដើមបណ្តឹង ១២ នាក់ នៅក្នុងសំណុំរឿងនេះបានដាក់បញ្ចាំប្លង់ទន់នៅអតិថិជន/អតិថិជនបន្តរបស់ IFC។[311] នៅខណៈពេលដែលច្បាប់ស្តីពីសិទ្ធិប្រាតិភោគនៃប្រទេសកម្ពុជាមិនផ្តល់ជូនម្ចាស់បំណុលនូវអំណាចដោយផ្ទាល់ក្នុងការរឹបអូសវត្ថុបញ្ចាំ ដោយចំណាត់ការនោះត្រូវតែអនុវត្តដោយតុលាការនោះ[312] ក្នុងអំឡុងពេលស៊ើបអង្កេត ស៊ីអេអូទទួលបានសម្ភារៈបណ្តុះបណ្តាលរបស់អតិថិជន និងអតិថិជនបន្តរបស់ IFC ដែលណែនាំបុគ្គលិកឱ្យដាក់សម្ពាធផ្លូវចិត្តលើអ្នកខ្ចីឲ្យលក់ដីក្នុងអំឡុងពេលប្រមូលបំណុល។ ការអនុវត្តតាមផ្លូវតុលាការលើវត្ថុបញ្ចាំ កម្រកើតឡើងចំពោះកម្ចីមីក្រូហិរញ្ញវត្ថុណាស់។[313] ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ប្លង់ទន់ជាវត្ថុបញ្ចាំ និងការពិតដែលថា BFIs រក្សាច្បាប់ចម្លងរូបវន្ត បង្កើតសម្ពាធសង្គម[314] ហើយនៅពេលដែលអ្នកខ្ចីងាយរងគ្រោះប្រឈមមុខនឹងការមិនបំពេញកាតព្វកិច្ចចំពោះប្រាក់កម្ចី ពួកគេ ជាញឹកញាប់ ត្រូវបានបង្ខំឱ្យ

[310] Green, Bylander, អំណាចផ្តាច់មុខនៃមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០២១ ទំ. ២២០។ ដើមបណ្តឹងជាងពាក់កណ្តាល នៅក្នុងសំណុំរឿងស៊ីអេអូនេះ ត្រូវបានកោះហៅឲ្យទៅជួបអាជ្ញាធរមូលដ្ឋាន ដូចជា មេភូមិ ឬមេឃុំ ឬត្រូវបានគំរាមកំហែងដោយដីកាកោះ បានលក់ដីធ្លីមួយចំនួនដើម្បីសងបំណុល។

[311] មជ្ឈមណ្ឌលមីក្រូហិរញ្ញវត្ថុ (MFC), Good Return, CBC ការសិក្សាអំពីបំណុលវ័ណ្ឌក នៅកម្ពុជា II៖ របាយការណ៍ចុងក្រោយ ខែតុលា ឆ្នាំ ២០១៧ ទំ. ៦២-៦៣ និងរបាយការណ៍ MIMOSA ស្តីពីប្រទេសកម្ពុជា ខែមីនា ឆ្នាំ២០២០ ទំ. ៧។

[312] មាត្រា ៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ឆ្នាំ២០០៦

[313] ដោយសារប្រព័ន្ធកាន់កាប់ដីធ្លីនៅកម្ពុជា ម្ចាស់ដីភាគច្រើនមិនមានប័ណ្ណកម្មសិទ្ធិផ្លូវការ (ប្លង់រឹង) នោះទេ ប៉ុន្តែ "ប្លង់ទន់" ជាលិខិតកម្មសិទ្ធិ ដែលចុះហត្ថលេខាដោយអាជ្ញាធរឃុំនៅក្នុងមូលដ្ឋាន។ ប្លង់ទន់ត្រូវបានទទួលយកជាវត្ថុបញ្ចាំជាទូទៅ ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ។ នៅក្នុងសំណុំរឿងនេះ អ្នកផ្តល់ប្រាក់កម្ចីកាន់កាប់ឯកសារកម្មសិទ្ធិ ហើយប្រគល់ជូនពួកគេវិញនៅពេលសងប្រាក់កម្ចីគ្រប់ចំនួន។ មាត្រា ៤០ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ នៃប្រទេសកម្ពុជា https://bit.ly/3IIiynWhttps://bit.ly/3ISheid។ Sovannroeun Samreth, Daiju Aiba និង Vandy Phal, អក្ខរកម្មហិរញ្ញវត្ថុក្នុងចំណោមអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ៖ សារៈសំខាន់ និងកត្តាកំណត់ ពីការស្ទង់មតិគ្រួសារនៅកម្ពុជា ឯកសារពិភាក្សារបស់វិទ្យាស្ថានស្រាវជ្រាវ JIVA Ogata ឆ្នាំ២០២៤ ទំ. ១១-១២ https://bit.ly/3DEdsGU។ S. Hem, ដំណើរការចុះបញ្ជីដីនៅកម្ពុជា៖ សាវតារ នីតិវិធី និងលទ្ធផល, *Cambodian J. Int. Stud.* ឆ្នាំ ២០១៩ ទំ. ៥៦, https://bit.ly/3FQRFw2។ អតិថិជន និងអតិថិជនបន្តរបស់ IFC មិនបានផ្តល់ទិន្នន័យអំពីការអនុវត្តចំពោះវត្ថុបញ្ចាំនោះទេ ប៉ុន្តែជាទូទៅ ត្រូវបានបង្ហាញថា វាគឺជាវិធានការដោះស្រាយចុងក្រោយ។

[314] របាយការណ៍ Bliss ទំ. ៥៦

លក់ដីរបស់ពួកគេ។[315] នៅក្នុងកំណត់សម្គាល់ទស្សនាទានស្តីពីការប្រឹក្សាយោបល់នៅឆ្នាំ២០២១ IFC ផ្ទាល់ បានគូសបញ្ជាក់ថា ការអនុវត្តការលក់ដីដោយបង្ខំដើម្បីសងបំណុល គឺជាកង្វល់ចំពោះមុខ។[316] ការត្រួតពិនិត្យរបស់ស៊ីអេអូលើគោលនយោបាយរបស់ BFI បង្ហាញថា មានអតិថិជន/អតិថិជនបន្តរបស់ IFC តែបីនាក់ប៉ុណ្ណោះ ដែលហាមឃាត់យ៉ាងច្បាស់លាស់នូវការរឹបអូសដីធ្លី ឬបង្ខំឱ្យលក់វត្ថុបញ្ចាំ តាមរយៈការដាក់សម្ពាធ និងការគំរាមកំហែង។ គោលនយោបាយរបស់អតិថិជនបន្តមួយ ដែលត្រូវបានត្រួតពិនិត្យដោយស៊ីអេអូ មានសេចក្តីណែនាំឲ្យបុគ្គលិកលើកទឹកចិត្តអតិថិជនឱ្យលក់វត្ថុបញ្ចាំរបស់ពួកគេសម្រាប់បំណុលហួសកាលកំណត់ និងស្នើសុំឱ្យអាជ្ញាធរមូលដ្ឋានជួយពួកគេក្នុងការលើកទឹកចិត្តបែបនោះ។

នៅក្នុងកិច្ចសម្ភាសជាមួយស៊ីអេអូ អ្នកខ្ចីបានពិពណ៌នាអំពីការគំរាមកំហែងរឹបអូសយកដីធ្លី ឬផ្ទះ ឬការលក់ដីធ្លីក្រោមតម្លៃទីផ្សារ ប្រសិនបើអ្នកខ្ចីមិនសងប្រាក់កម្ចីរបស់ពួកគេ។[317] យោងតាមព័ត៌មានពីអ្នកខ្ចី ការគំរាមកំហែងទាំងនេះត្រូវបានធ្វើឡើងដោយបុគ្គលិករបស់អតិថិជន និងអតិថិជនបន្តរបស់ IFC ទាំងប្រាំមួយ ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ។ ដោយសារប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានកាន់កាប់ដោយ BFIs អ្នកខ្ចីយល់ឃើញថា ការគំរាមកំហែងការកាន់កាប់ដី និងផ្ទះក្នុងករណីមិនបំពេញកាតព្វកិច្ចនេះ ជាហានិភ័យពិតប្រាកដ ជាពិសេសការយល់ឃើញដោយអ្នកខ្ចីមីក្រូហិរញ្ញវត្ថុដែលខ្វះខាតការយល់ដឹងផ្នែកច្បាប់អំពីការរឹបអូស ឬសិទ្ធិរបស់ពួកគេ ទាក់ទងនឹងដីរបស់ពួកគេ និងនៅក្នុងដំណើរការដកហូត។ ការយល់ឃើញនេះត្រូវបានពង្រឹងបន្ថែមទៀត នៅពេលដែលអាជ្ញាធរមូលដ្ឋាន ដែលមិនមានតួនាទីផ្លូវការតាមផ្លូវច្បាប់ នៅក្នុងនីតិវិធីរឹបអូស ឬដកហូត បានចូលរួមក្នុងការប្រមូលបំណុល ដែលបង្ហាញជារូបភាពនៃដំណើរការអនុវត្តតាមផ្លូវច្បាប់។

ស៊ីអេអូកត់សម្គាល់ថា ដោយសារភាពងាយរងគ្រោះរបស់អ្នកខ្ចីជាច្រើននាក់ អំណះអំណាង ឬសកម្មភាពរបស់បុគ្គលិក BFI ទោះបីជាមិនមានចេតនាបង្កជាការគំរាមកំហែងជាក់លាក់ក៏ដោយ បុគ្គលដែលមានការយល់ដឹងតិចតួចអំពីប្រព័ន្ធហិរញ្ញវត្ថុ និងសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេ អាចយល់ឃើញថាជាការគំរាមកំហែង។ កិច្ចសម្ភាសដែលធ្វើឡើងដោយស៊ីអេអូ ជាមួយអ្នកខ្ចី បានបង្ហាញថា មនុស្សជាច្រើនមានចំណេះដឹងតិចតួចអំពីការការពារតាមផ្លូវច្បាប់របស់ពួកគេ។ ការយល់ច្រឡំទូទៅ

---

[315] ដើមបណ្តឹងទាំង ១៥ នាក់ ដែលបានលក់ ឬដាក់លក់ដីរបស់ពួកគេដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ បានធ្វើវានៅក្រៅប្រព័ន្ធតុលាការ។ របាយការណ៍ជាច្រើនបានចងក្រងជាឯកសារ ករណីដែលអ្នកខ្ចីយឺតយ៉ាវក្នុងការទូទាត់សង ហើយប្រឈមមុខនឹងការគំរាមកំហែងពីមន្ត្រីឥណទាន ក្នុងការរឹបអូសយកដីរបស់ពួកគេដោយបង្ខំឱ្យពួកគេលក់វា។ N. Green និយ័តកម្មបំណុលវ័ណ្ឌកៈ អំណាចរដ្ឋក្នុងស្រុកនៅក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុកម្ពុជា ការអភិវឌ្ឍ និងការផ្លាស់ប្តូរ វិទ្យាស្ថានសិក្សាសង្គមអន្តរជាតិ ឆ្នាំ២០២០ ទំ. ៣ Green, Bylander អំណាចផ្តាច់មុខនៃមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០២១ ទំ. ២១៩ M. Bateman ការផ្តល់កម្មសិទ្ធិដីធ្លី និងមីក្រូឥណទាននៅកម្ពុជា៖ ការពិនិត្យមើលការពិតរបស់ Hernando de Soto′s "បីជំហានទៅកាន់ឋានសួគ៌" ដីធ្លី Sohtoen's Stepen, Hernan ឆ្នាំ២០២៤ ទំ.១០។

[316] របាយការណ៍របស់ ៦០ ដេស៊ីប៊ែល នាពេលថ្មីៗនេះ បានរកឃើញថា ២% នៃអតិថិជនកម្ពុជាចំនួន ២.៩៣៩ នាក់ ដែលបានចូលរួមនៅក្នុងការអង្កេត បានរាយការណ៍អំពីសម្ពាធឱ្យលក់ទ្រព្យសកម្ម ដើម្បីសងបំណុល។ ការអង្កេតរបស់ ៦០ ដេស៊ីប៊ែល ទំ. ៨. ចំនួនអតិថិជនមីក្រូហិរញ្ញវត្ថុសកម្មនៅក្នុងប្រទេសនេះ គឺផ្អែកលើទិន្នន័យពីសមាគមមីក្រូហិរញ្ញវត្ថុនៅកម្ពុជាពីឆ្នាំ២០២២។

[317] ដើមបណ្តឹងប្រាំបីនាក់បានរាយការណ៍ថាបានទទួលការគំរាមកំហែងរឹបអូសដីធ្លី ឬផ្ទះពីបុគ្គលិកអតិថិជន/អតិថិជនបន្តរបស់ IFC ចំនួនបួននាក់។ ដើមបណ្តឹងបីនាក់ដែលបានរាយការណ៍ពីការគំរាមកំហែងបែបនោះ បានលក់ដីមួយចំនួនដើម្បីសងប្រាក់កម្ចីរបស់ពួកគេ។ ស៊ីអេអូក៏បានទទួលភស្តុតាងនៃមន្ត្រីឥណទានរបស់ BFI មួយ ក្នុងចំណោម BFI ទាំងនេះ ដែលពន្យល់ពីនីតិវិធីរបស់ធនាគារទៅកាន់ដើមបណ្តឹងម្នាក់ និងណែនាំនាងឱ្យលក់ដីរបស់នាងមុនពេលវាត្រូវបានដាក់ដេញថ្លៃក្នុងតម្លៃទាបជាងតម្លៃទីផ្សារ។

រួមមាន ការជឿថាស្ថាប័នមីក្រូហិរញ្ញវត្ថុអាចលក់ដីរបស់ពួកគេបាន ប្រសិនបើពួកគេសងប្រាក់យឺត សូម្បីតែមួយថ្ងៃ និងប្រសិនបើពួកគេមិនលក់ដីដោយខ្លួនឯងទេ អ្នកផ្តល់ប្រាក់កម្ចីអាចលក់វាក្នុងតម្លៃទាបជាងតម្លៃទីផ្សារ ដោយគ្មានដំណើរការតុលាការ។ អ្នកខ្ចីប្រាក់ភាគច្រើនដែលត្រូវបានសម្ភាស មិនដឹងថាការគំរាមកំហែងបែបនេះត្រូវបានហាមឃាត់យ៉ាងច្បាស់លាស់ នៅក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នៃកម្ពុជានោះទេ និងថាស្ថាប័នហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវបានតម្រូវឱ្យបន្តអនុវត្តយន្តការបណ្តឹងសារទុក្ខ ដែលអ្នកខ្ចីប្រាក់អាចរាយការណ៍ពីការអនុវត្តបែបនោះ និងស្វែងរកឧបាស្រ័យបាន។

- **ការណែនាំដែលមានគ្រោះថ្នាក់ដោយបុគ្គលិកទៅកាន់អ្នកខ្ចី អំពីរបៀបសងប្រាក់កម្ចី៖** នៅខណៈពេលដែលអតិថិជន និងអតិថិជនបន្តរបស់ IFC ទំនងជាចាត់ទុកដំបូន្មានដែលមានគ្រោះថ្នាក់ ដែលផ្តល់ដោយបុគ្គលិក BFI ជាហេតុការណ៍ដាច់ដោយឡែកពីគ្នានោះ ស៊ីអេអូបានទទួលសក្ខីកម្មជាច្រើន ដែលស្របនឹងការសិក្សាស្រាវជ្រាវ និងរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយអំពីការផ្តល់យោបល់ដែលមានគ្រោះថ្នាក់អំពីរបៀបសងបំណុល ដែលធ្វើឡើងដោយបុគ្គលិក BFI។ ការខ្ចីប្រាក់ពីទីផ្សារ ឬអ្នកផ្តល់ប្រាក់កម្ចីក្រៅប្រព័ន្ធ គឺជាយន្តការទប់ទល់ដែលត្រូវបានប្រើប្រាស់ជាញឹកញាប់ដោយអ្នកខ្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។[318] ផ្អែកលើឯកសារដែល BFIs បានចែករំលែកជាមួយស៊ីអេអូនៅក្នុងសំណុំរឿងនេះ មាន BFI តែមួយប៉ុណ្ណោះដែលហាក់ដូចជាហាមឃាត់យ៉ាងច្បាស់លាស់ មិនឲ្យបុគ្គលិកស្នើសុំឱ្យអតិថិជនរបស់ពួកគេខ្ចីប្រាក់ពីអ្នកផ្តល់ប្រាក់កម្ចីក្រៅប្រព័ន្ធ ដើម្បីសងប្រាក់នោះទេ។ អ្នកខ្ចីដប់នាក់ ដែលត្រូវបានសម្ភាសដោយស៊ីអេអូ រួមទាំងដើមបណ្តឹងមួយចំនួនផងដែរ បានរាយការណ៍ថា បុគ្គលិករបស់អតិថិជន និងអតិថិជនបន្តរបស់ IFC មួយចំនួន បានណែនាំ ឬស្នើសុំឱ្យអតិថិជនដែលមិនបំពេញកាតព្វកិច្ច ខ្ចីប្រាក់ពីអ្នកផ្តល់កម្ចីក្រៅប្រព័ន្ធ ឬហាងបញ្ចាំ ដើម្បីសងបំណុលរបស់ពួកគេ ជាញឹកញាប់ ក្នុងអត្រាការប្រាក់ខ្ពស់ខ្លាំង (លើសពីដែនកំណត់តាមផ្លូវច្បាប់ សម្រាប់ BFIs) និងមិនមានការការពារតាមផ្លូវច្បាប់នោះទេ។[319] អ្នកខ្ចីមួយចំនួនបានធ្វើតាមការណែនាំនេះ។ ដើមបណ្តឹងពីរនាក់ក៏បានរាយការណ៍ផងដែរថា មន្ត្រីនៅទីវាលបានលើកទឹកចិត្តពួកគេឱ្យបញ្ឈប់កូនពីសាលារៀនដើម្បីសន្សំថ្លៃសិក្សា ឬដើម្បីឲ្យកូនៗអាចធ្វើការងារជួយសងបំណុលបាន។ ស៊ីអេអូបានទទួលរបាយការណ៍ពីអ្នកខ្ចីបីនាក់ (មិនមែនដើមបណ្តឹង នៅក្នុងសំណុំរឿងនេះ) ដែលបានចោទប្រកាន់ថា តំណាងអតិថិជន

[318] ការវាយតម្លៃផលប៉ះពាល់របស់ MCRIL-CMA ឆ្នាំ២០២៣ ទំ. ៥២ និងរបាយការណ៍ Bliss ទំ. ៣៩។

[319] នៅឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជា (NBC) បានចេញអនុក្រឹត្យ (ប្រកាស) កំណត់ពិដានអត្រាការប្រាក់ត្រឹម ១៨% ក្នុងមួយឆ្នាំ សម្រាប់ប្រាក់កម្ចីដែលចេញដោយ MFIs។ អ្នកផ្តល់ប្រាក់កម្ចីក្រៅប្រព័ន្ធមិនស្ថិតនៅក្រោមបទប្បញ្ញត្តិរបស់ NBC នោះទេ ដូច្នេះហើយពួកគេគិតការប្រាក់ជាមធ្យម ៥% ទៅ ១០% ក្នុងមួយខែ។ ក្នុងករណីធ្ងន់ធ្ងរមួយចំនួន ទោះបីជាមិនមែនជារឿងចម្លែកក៏ដោយ អ្នកផ្តល់ប្រាក់កម្ចីនៅកម្ពុជាបានគិតប្រាក់ ១% ក្នុងមួយថ្ងៃ (៣០ ភាគរយក្នុងមួយខែ) ឬ ១០% ក្នុងមួយសប្តាហ៍ (៤០% ក្នុងមួយខែ)។ ការការពារតាមផ្លូវច្បាប់ដទៃទៀត ដូចជា ដំណើរការជាផ្លូវការក្នុងការរឹបអូស សូមមើល៖ អនុក្រឹត្យ (ប្រកាស) ស្តីពីពិដានអត្រាការប្រាក់ ឆ្នាំ២០១៧ មាត្រា ៣ និង ៤៖ https://bit.ly/4iKjTXC; របាយការណ៍ Bliss ទំ. ៦៥, W. Nathan Green, Theavy Chhom, Reach Mony និង Jennifer Estes ផ្នែកខាងក្រោមនៃមីក្រូហិរញ្ញវត្ថុ៖ សូចនាករសមិទ្ធកម្ម និងបំណុលក្រៅប្រព័ន្ធនៅកម្ពុជា ការអភិវឌ្ឍ និងការផ្លាស់ប្តូរ លេខ ៥៤ ច្បាប់ទី ៤វិទ្យាស្ថានអន្តរជាតិសិក្សាសង្គម ខែមិថុនា ឆ្នាំ២០២៣ https://bit.ly/4kPOMe7។

របស់ IFC បានស្នើឱ្យពួកគេ "លក់" កូនរបស់ពួកគេដើម្បីសងប្រាក់កម្ចី។[320] ស៊ីអេអូមិនមានព័ត៌មានលម្អិតបន្ថែមអំពីអត្ថន័យនៃសំណើដែលបានរាយការណ៍ទាំងនេះទេ ហើយក៏ពុំមានគ្រួសារណាមួយបានធ្វើសកម្មភាពតាមពួកគេដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេទាំងបីគ្រួសារបានរាយការណ៍ថាមានទុក្ខវេទនាផ្លូវចិត្តដោយសារការផ្តល់យោបល់បែបនោះ ជាពិសេសស្ត្រីក្នុងគ្រួសារ ដែលយល់ឃើញថា វាជាការគំរាមកំហែងពិតៗ ដោយសារការជួញដូរកុមារ និងពលកម្មកុមារ ត្រូវបានគេស្គាល់ថាជាហានិភ័យនៅក្នុងប្រទេសកម្ពុជា។[321] ស៊ីអេអូសង្កត់ធ្ងន់ថា ខ្លួនអាចសម្រេចថាតើហេតុការណ៍ទាំងនេះបានកើតឡើងតាមការចោទប្រកាន់មែនដែរឬអត់នោះទេ។ សក្ខីកម្មដែលបានបង្ហាញនៅទីនេះ បង្ហាញពីកង្វល់លើភាពគ្រប់គ្រាន់នៃការការពារ ដើម្បីទប់ស្កាត់ឥរិយាបថមិនសមរម្យពីបុគ្គលិកជួរមុខ ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកខ្ចីងាយរងគ្រោះ។[322]

ស៊ីអេអូកត់សម្គាល់ថា ការអនុវត្ត និងការផ្តល់យោបល់ខាងលើមិនត្រូវបានអនុម័តជាផ្លូវការដោយ BFIs ទាំងប្រាំមួយ ឬត្រូវបានរួមបញ្ចូលនៅក្នុងគោលនយោបាយដែលបានចងក្រងជាឯកសាររបស់ពួកគេនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ កង្វះខាតការត្រួតពិនិត្យ និងការពិនិត្យតាមដាន E&S នៃការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន/អតិថិជនបន្តរបស់ IFC ដើម្បីធានាចំពោះភាពស្របតាម GIIP[323] បានបង្កើតចំណុចដឹងងឹតមួយ ទាក់ទងនឹងហានិភ័យ និងផលប៉ះពាល់ពីការ

[320] T.Wester 'ពួកគេបានផ្តល់យោបល់ឱ្យខ្ញុំលក់កូនស្រីរបស់ខ្ញុំ'៖ ផ្នែកងងឹតនៃមីក្រូហិរញ្ញវត្ថុសកល The Telegraph ខែមិថុនា ឆ្នាំ ២០២៤ https://bit.ly/3Rk5OV7។ ទោះបីជាវាមិនត្រូវបានរួមបញ្ចូលនៅក្នុងពាក្យបណ្តឹងដែលបានដាក់ជូនស៊ីអេអូ នៅឆ្នាំ២០២២ ក៏ដោយ ក៏ក្នុងអំឡុងពេលធ្វើបេសកកម្ម ស៊ីអេអូបានទទួលសក្ខីកម្មពីតំណាងសហគមន៍អំពីការផ្តល់យោបល់បែបនេះ និងបានដឹងពីហេតុការណ៍នៃការចោទប្រកាន់ចំនួនបី ដែលពាក់ព័ន្ធនឹងមន្ត្រីនៅទីវាល ពីអតិថិជនរបស់ IFC ដែលផ្តល់យោបល់ឲ្យសមាជិកសហគមន៍ជនជាតិដើមភាគតិចលក់កុមារដែលមានអាយុពី ១១ ដល់ ១៥ឆ្នាំ។ ក្នុងករណីទាំងបីនេះ ហេតុការណ៍មានភាពដាច់ដោយឡែកពីគ្នា ហើយមន្ត្រីមិនបានត្រឡប់មកវិញទេ។ វានៅតែមិនច្បាស់ថាតើពួកគេត្រូវបានបណ្តេញចេញ ឬត្រូវបានផ្ទេរទៅកាន់ទីតាំងថ្មីនោះទេ។

[321] ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ឆ្នាំ២០២៤ របាយការណ៍ស្តីពីការជួញដូរមនុស្ស៖ ប្រទេសកម្ពុជា ឆ្នាំ២០២៤ https://bit.ly/4iB2EZb; របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក Vitit Muntarbhorn A/HRC/57/82 ខែសីហា ឆ្នាំ២០២៤ https://bit.ly/4bSj6S7 ឆ្នាំ២០២២ របាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តសិទ្ធិមនុស្ស៖ ប្រទេសកម្ពុជា ក្រសួងការបរទេសសហរដ្ឋអាមេរិក https://bit.ly/៣XsgQez។

[322] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ១១៧

[323] SPTF+Cerise ស្តង់ដារការពារអតិថិជន ស្តង់ដារ ៤C ស្តង់ដារនេះបញ្ជាក់ថា អ្នកផ្តល់សេវាហិរញ្ញវត្ថុមានគោលនយោបាយ ដែលរួមបញ្ចូលបញ្ជីការអនុវត្តការប្រមូលបំណុលដែលសមរម្យ និងមិនសមរម្យ ដែលមានដំណើរការដែលបានដឹង និងកំណត់ពេលប្រមូលប្រាក់ ដែលអនុញ្ញាតឱ្យមានពេលវេលាសម្រាប់អ្នកប្រមូលបំណុលក្នុងការកំណត់ពីហេតុផលអតិថិជនមិនបានបំពេញកាតព្វកិច្ច និងទុកពេលឲ្យអតិថិជនស្វែងរកដំណោះស្រាយ ប៉ុន្តែអ្នកខ្ចីត្រូវទទួលបានការជូនដំណឹងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរអំពីឥរិយាបថដែលត្រូវបានហាមឃាត់។ GIIP មានភាពច្បាស់លាស់ថា ការមានគោលនយោបាយគឺមិនគ្រប់គ្រាន់នោះទេ ហើយបុគ្គលិកនៅទីវាល ត្រូវទទួលបានការបណ្តុះបណ្តាល និងពិនិត្យតាមដានថាតើពួកគេគោរពតាមគោលនយោបាយដែរឬទេ និងត្រូវតែទទួលបានការបណ្តុះបណ្តាល ដើម្បីជូនដំណឹងដល់អ្នកខ្ចីឱ្យបានជាប់លាប់អំពីឥរិយាបថរបស់បុគ្គលិកដែលរំពឹងទុក និងមិនអាចទទួលយកបាន។ អ្នកខ្ចីគួរតែយល់ពីឥរិយាបថរបស់បុគ្គលិកដែលត្រូវបានរំពឹងទុក និងត្រូវបានហាមឃាត់ ដូច្នេះក្នុងករណីដែលពួកគេមានអារម្មណ៍ថា បុគ្គលិកអនុវត្តហួសព្រំដែន ពួកគេដឹងយ៉ាងច្បាស់ថា ពួកគេមិនចាំបាច់រងទុក្ខនោះទេ ហើយពួកគេគួរតែរាយការណ៍ទៅកាន់អ្នកផ្តល់សេវា។ SPTF+Cerise មគ្គុទ្ទេសក៍ណែនាំសម្រាប់ការវាយតម្លៃ និងការអនុវត្តស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន វិមាត្រ ៤ ស្តីពីកិច្ចការពារអតិថិជន https://bit.ly/4dMfmTr។

អនុវត្តគោលនយោបាយ BFI មិនបានល្អ និងការអនុវត្តរបស់បុគ្គលិកមិនសមរម្យ ចំពោះអ្នកខ្ចីដែលងាយរងគ្រោះ ដែលត្រូវបានកំណត់គោលដៅដោយការវិនិយោគទាំងនេះ។

លើសពីនេះទៀត ការលើកទឹកចិត្តបុគ្គលិក ដែលជាទូទៅ មានប្រសិទ្ធភាពចំពោះការកែលម្អការលក់របស់ FI ទាំងមូល ឬការអនុវត្តគោលដៅប្រមូលប្រាក់នោះ ក៏អាចមានឥទ្ធិពលដោយអចេតនាក្នុងការដាក់សម្ពាធបុគ្គលិកឱ្យផ្តោតលើកំណើន ជំនួសឱ្យផលបត្រ និងគុណភាពសេវាកម្មផងដែរ។[324] តាមបរិបទ ចាប់ពីឆ្នាំ២០១០ មក CGAP បានកំណត់ថា នៅក្រោមសម្ពាធក្នុងការអនុវត្តតាមគោលដៅ និងដោយមានការត្រួតពិនិត្យដែលមានកម្រិត បុគ្គលិក BFI ជួរមុខ ម្តងម្កាល ងាកទៅរកការអនុវត្តការប្រមូលប្រាក់ដែលមិនមានប្រយោជន៍ ដែលបំផ្លាញទំនាក់ទំនងអតិថិជនយូរអង្វែង។[325] ស្របតាមការសង្កេតទាំងនេះ GIIP បានផ្តល់អនុសាសន៍ថា គម្រោងលើកទឹកចិត្តបុគ្គលិកមិនគួរជម្រុញការលក់ដោយឈ្លានពាននោះទេ ផ្ទុយមកវិញ វាគួរតែពិចារណាទាំងការលក់ និងលក្ខណៈវិនិច្ឆ័យការអនុវត្តការងារសង្គម ដូចជា គុណភាពផលបត្រ និងកម្រិតនៃភាពអនុលោមតាមការអនុវត្តកិច្ចការពារអតិថិជន ដើម្បីធានាថា បុគ្គលិកផ្នែកលក់អនុវត្តការថែទាំសមរម្យ ក្នុងការផ្តល់ប្រាក់កម្ចីដែលអតិថិជនត្រូវការ និងអាចសងវិញបាន។[326] ក្នុងចំណោម BFIs កម្ពុជាទាំងប្រាំមួយ នៅក្នុងសំណុំរឿងនេះ ស្ថាប័នចំនួនបីបានរួមបញ្ចូលលក្ខណៈវិនិច្ឆ័យនៃការអនុវត្តការងារសង្គមមួយចំនួននៅក្នុងគម្រោងលើកទឹកចិត្តបុគ្គលិករបស់ពួកគេ។[327] ស៊ីអេអូយល់ថា ការពិចារណាដែលមានកម្រិតលើលក្ខណៈវិនិច្ឆ័យផ្នែកសង្គម ដោយ BFIs ទាំងនេះ នៅក្នុងគម្រោងលើកទឹកចិត្តមន្ត្រីឥណទាន និងមន្ត្រីប្រមូលប្រាក់របស់ពួកគេ គឺជាកត្តាដ៏សំខាន់មួយ ដែល IFC និងអតិថិជនរបស់ខ្លួន ត្រូវតែពិចារណានៅពេលវាយតម្លៃភាពអនុលោមរបស់ស្ថាប័នទាំងនេះតាមស្តង់ដារ GIIP។ GIIP តម្រូវឱ្យអ្នកផ្តល់ប្រាក់កម្ចីជៀសវាងការអនុវត្តការលក់ និងការប្រមូលប្រាក់ដោយឈ្លានពាន ដែលអាចមានផលប៉ះពាល់អវិជ្ជមានចំពោះអ្នកខ្ចីដែលងាយរងគ្រោះ។

ផ្អែកលើព័ត៌មានដែលបានត្រួតពិនិត្យ រួមទាំងការសង្កេតនៅទីវាលរបស់ស៊ីអេអូដោយផ្ទាល់ ការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន និងអតិថិជនបន្តរបស់ IFC នៅក្នុងសំណុំរឿងនេះ បង្ហាញពីចន្លោះប្រហោងក្នុងការអនុវត្តផ្នែកសង្គមនៃការវិនិយោគទាំងនេះ ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃ PS1។ វារួមមាន ការកំណត់ និងការវាយតម្លៃហានិភ័យ និងផលប៉ះពាល់សង្គម ជាពិសេសចំពោះក្រុមជនងាយរងគ្រោះ

---

[324] CGAP, Greg Chen, Stephen Rasmussen និង Xavier Reille កំណើន និងភាពងាយរងគ្រោះនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ កំណត់សម្គាល់ចំណុចផ្តោត ខែកុម្ភៈ ឆ្នាំ២០១០ ទំ. ១០-១១ https://bit.ly/4iKaYFC។ ក្នុងអំឡុងពេលត្រួតពិនិត្យការពិត និងការផ្តល់យោបល់ អតិថិជនបន្តម្នាក់បានកត់សម្គាល់ថា ពួកគេរក្សាកម្រិតអតិបរមាលើផលបត្រប្រាក់កម្ចីអតិបរមាសម្រាប់មន្ត្រីឥណទានម្នាក់ ដើម្បីទប់ស្កាត់ការកើនឡើងលើសពីដែនកំណត់នេះ។

[325] CGAP, Greg Chen, Stephen Rasmussen, and Xavier Reilleកំណើន និងភាពងាយរងគ្រោះនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ កំណត់សម្គាល់ចំណុចផ្តោត ខែកុម្ភៈ ឆ្នាំ២០១០ ទំ. ១១ https://bit.ly/4iKaYFC។

[326] SPI អនឡាញ មគ្គុទ្ទេសក៍ណែនាំសម្រាប់ការវាយតម្លៃ និងការអនុវត្តស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ៤.C.២.២.២ https://bit.ly/41XKxWg។

[327] BFIs ទាំងបីត្រួតពិនិត្យភាពអនុលោមរបស់និយោជិតរបស់ពួកគេ រួមជាមួយក្រមសីលធម៌ និងពាក្យបណ្តឹង ដែលមន្ត្រីបានទទួលដោយមានការត្រួតពិនិត្យពីក្រុមធានាគុណភាពឥណទាន ដែលចុះត្រួតពិនិត្យដល់ទីតាំង និងមន្ត្រីហានិភ័យដែលត្រួតពិនិត្យឯកសារ ដែលជាផ្នែកមួយនៃគម្រោងលើកទឹកចិត្តរបស់បុគ្គលិក និងមិនត្រឹមតែផ្អែកលើចំនួននៃការលក់ និងការប្រមូលប្រាក់របស់ពួកគេប៉ុណ្ណោះទេ។ ក្នុងអំឡុងពេលត្រួតពិនិត្យការពិត និងការផ្តល់យោបល់ អតិថិជនបន្តម្នាក់បានកត់សម្គាល់ថា ពួកគេរក្សាកម្រិតអតិបរមាលើផលបត្រប្រាក់កម្ចីអតិបរមាសម្រាប់មន្ត្រីឥណទានម្នាក់ ដើម្បីទប់ស្កាត់ការកើនឡើងលើសពីដែនកំណត់នេះ។

ការបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមប្រកបដោយប្រសិទ្ធភាព ដែលអនុវត្តតាមស្តង់ដារ GIIP រួមទាំងវិធានការទាក់ទងនឹងការប្រព្រឹត្តិដោយក្តីគោរពចំពោះអតិថិជន និងការពិនិត្យតាមដានការអនុវត្តរបស់អតិថិជន ដើម្បីធានាថាផលប៉ះពាល់អវិជ្ជមានលើសហគមន៍ដែលរងផលប៉ះពាល់ត្រូវបានជៀសវាង ឬកាត់បន្ថយ។

### ៤.២.២ ការពិចារណាអំពីសមិទ្ធកម្មបរិស្ថាន និងសង្គមរបស់ IFC ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃ PS7 ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច

អតិថិជនមីក្រូហិរញ្ញវត្ថុរបស់ IFC នៅកម្ពុជា ធ្វើប្រតិបត្តិការនៅក្នុងតំបន់ ដែលជនជាតិដើមភាគតិច (IPs) រស់នៅ។ នៅឆ្នាំ២០១៨ ការសិក្សារបស់អង្គការសហប្រជាជាតិបានរាយការណ៍ថា គ្រួសារជនជាតិដើមភាគតិច ៧0-៨0% ដែលត្រូវបានស្ទង់មតិនៅក្នុងខេត្តចំនួនបីនៃប្រទេសកម្ពុជា បានជំពាក់បំណុល តាមរយៈកម្ចីមីក្រូហិរញ្ញវត្ថុ ឬឥណទានប្រភេទផ្សេងទៀត។[328] លើសពីផលប៉ះពាល់ទូទៅលើសហគមន៍ដែលរងផលប៉ះពាល់ទាំងអស់ ដែលបានពិពណ៌នានៅខាងលើទៀតនោះ ការអនុវត្តយ៉ាងទូលំទូលាយនៃការទាមទារឲ្យដាក់ដីជាវត្ថុបញ្ចាំបាននាំឱ្យមានការបាត់បង់ដីធ្លីរបស់ជនជាតិដើមភាគតិច ធ្វើឱ្យខូចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជនជាតិដើមភាគតិច និងបង្កើតជម្លោះនៅក្នុងសហគមន៍ជនជាតិដើមភាគតិច។[329]

ទាក់ទងនឹងសំណុំរឿងនេះ អ្នកខ្ចីជាលក្ខណៈបុគ្គលចំនួនប្រាំពីរនាក់ ដែលបានដាក់ពាក្យបណ្តឹងមកកាន់ស៊ីអេអូ គឺជាជនជាតិដើមភាគតិច។ គោលនយោបាយ E&S របស់ IFC មានបទប្បញ្ញត្តិជាក់លាក់ក្នុងការបង្ការគ្រោះថ្នាក់ដល់ជនជាតិដើមភាគតិច ពីសកម្មភាពដែលខ្លួនផ្តល់ហិរញ្ញប្បទាន រួមទាំងតម្រូវឲ្យ IFC ធានាថាអតិថិជនរបស់ខ្លួនវាយតម្លៃផលប៉ះពាល់ និងអនុវត្តវិធានការស្របតាមស្តង់ដារសមិទ្ធកម្មផងដែរ។[330] ស្តង់ដារសមិទ្ធកម្មទី៧ (ជនជាតិដើមភាគតិច PS7) ទទួលស្គាល់ថា ជនជាតិដើមភាគតិច ជាញឹកញាប់ ស្ថិតក្នុងចំណោមប្រជាជនដែលគេមិនអើពើ និងងាយរងគ្រោះបំផុត និងថា ភាពងាយរងគ្រោះរបស់ពួកគេអាចធ្វើឱ្យពួកគេបាត់បង់អត្តសញ្ញាណ វប្បធម៌ និងជីវភាពរស់នៅផ្អែកលើធនធានធម្មជាតិ ក៏ដូចជាការកើនឡើងនៃការប្រឈមនឹងភាពក្រីក្រផងដែរ។[331] PS7 អនុវត្តចំពោះ "គ្រប់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់ដែលជះឥទ្ធិពលពីគម្រោង ដែលអាចរងផលប៉ះពាល់ដោយគម្រោង"។[332] ក្នុងកាលៈទេសៈបែបនេះ អតិថិជនរបស់ IFC ត្រូវបានតម្រូវឱ្យវាយតម្លៃ និងកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ E&S ដែលទាក់ទងនឹងគម្រោងដោយផ្អែកលើការពិគ្រោះយោបល់ និងការចូលរួមដោយមានព័ត៌មានគ្រប់គ្រាន់របស់សហគមន៍ជនជាតិដើម

[328] ការសិក្សារបស់ OHCHR បានស្ទង់មតិសហគមន៍ជនជាតិដើមភាគតិចចំនួន ១0 នៅក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ។ សហគមន៍ទាំង ១0 នេះ ស្ថិតក្នុងចំណោមសហគមន៍ចំនួន ១៨ នៅកម្ពុជា ដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាព នៅពេលធ្វើការសិក្សា ក្នុងឆ្នាំ២០១៧។ OHCHR ប្រចាំកម្ពុជា ការវាយតម្លៃពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ការកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ ខែតុលា ឆ្នាំ២០១៨ ទំ. ៧ និង ២៥ https://bit.ly/4bShI1P។

[329] សូមមើលផ្នែក ៥.៣ និង De Lange, Emiel, Raj, Sushil Raj, និង Yun Mane, សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច គឺជាគន្លឹះសម្រាប់ការអភិរក្សនៅកម្ពុជា (សេចក្តីអធិប្បាយ), *Mongabay*, ខែធ្នូ ឆ្នាំ២0២៣, https://bit.ly/4kRGaob។ Baird, Ian G., ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច ឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ និងការប្រែប្រួលនៃវិស័យកសិកម្មនៅខេត្តរតនគីរី ភាគឦសាននៃប្រទេសកម្ពុជា *ទិនានុប្បវត្តិការសិក្សាអំពីកសិករ* ឆ្នាំ២0២៤។

[330] គោលនយោបាយនិរន្តរភាពរបស់ IFC (ឆ្នាំ២០១២) កថាខណ្ឌ ៧

[331] PS7 ឆ្នាំ២០១២ កថាខណ្ឌ ១

[332] PS7 ឆ្នាំ២០១២ កថាខណ្ឌ ៨

ភាគតិចដែលរងផលប៉ះពាល់។[333] លើសពីនេះទៀត បញ្ជីផាត់ចេញរបស់ IFC ក៏បញ្ជាក់ផងដែរថា អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុមិនត្រូវបន្ត "សកម្មភាពដែលប៉ះពាល់ដល់ដីធ្លី ដែលជាកម្មសិទ្ធិ ឬត្រូវបានទាមទារ ស្របតាមការវិនិច្ឆ័យក្តី ដោយជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះទេ"។[334] ស៊ីអេអូកត់សម្គាល់ថាការហាមឃាត់នៅក្រោម PS7 និងបញ្ជីផាត់ចេញ មិនអាស្រ័យលើការទទួលស្គាល់ដីធ្លីស្របច្បាប់ ឬដំណាក់កាលនៃដំណើរការ ICLT នោះទេ។

បន្ថែមពីលើការបំពេញតាមលក្ខខណ្ឌតម្រូវ PS7 ខាងលើ អតិថិជនរបស់ IFC ត្រូវតែអនុវត្តតាមច្បាប់ជាតិជាធរមាន និងកាតព្វកិច្ចរបស់ប្រទេសម្ចាស់ផ្ទះនៅក្រោមច្បាប់អន្តរជាតិផងដែរ។ នៅក្នុងសំណុំរឿងនេះ ច្បាប់ជាតិនៃប្រទេសកម្ពុជាហាមឃាត់យ៉ាងច្បាស់លាស់ មិនឲ្យអ្នកផ្តល់ប្រាក់កម្ចីទទួលយកប័ណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិច (ICLTs) ជាវត្ថុបញ្ចាំនោះទេ (សូមមើលផ្នែក ១.២)។ ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អក៏ផ្តល់ដំបូន្មានដល់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុឱ្យរចនាផលិតផលតាមរបៀបដែលជៀងវាងគ្រោះថ្នាក់ដល់អតិថិជន និងផ្តល់អត្ថប្រយោជន៍ដល់ពួកគេផងដែរ។[335]

ទាក់ទងនឹងសំណុំរឿងនេះ ស៊ីអេអូបានសង្កេតឃើញចន្លោះប្រហោងដូចខាងក្រោម រវាងការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់ BFIs ទាំងប្រាំមួយ និងលក្ខខណ្ឌតម្រូវ E&S របស់ IFC ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ដែលទាក់ទងនឹងការវាយតម្លៃរបស់ស៊ីអេអូលើភាពអនុលោមរបស់ IFC ចំពោះក្របខណ្ឌនិរន្តរភាពរបស់ខ្លួន។

### *a) ការទទួលយកវត្ថុបញ្ចាំជាដីធ្លីរបស់ជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមពីសហគមន៍*

ស្តង់ដារសមិទ្ធកម្មទី៧ និងបញ្ជីផាត់ចេញរបស់ (ជនជាតិដើមភាគតិច PS7) ទទួលស្គាល់ថា ជនជាតិដើមភាគតិច ជាញឹកញាប់ IFC ហាមឃាត់សកម្មភាពដែលប៉ះពាល់ដល់ដីធ្លីជនជាតិដើមភាគតិច (IP) ទោះបីជាដីនោះត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ឬស្ថិតក្រោមការវិនិច្ឆ័យក៏ដោយ ប្រសិនបើគ្មានការយល់ព្រមជាឯកសារ

[333] PS7 ឆ្នាំ២០១២ កថាខណ្ឌ ៩

[334] បញ្ជីផាត់ចេញរបស់ IFC មាននៅទីនេះ៖ https://bit.ly/4hNPcA6។ PS7 របស់ IFC កំណត់លក្ខខណ្ឌតម្រូវអប្បបរមារបស់ IFC សម្រាប់ "ការយល់ព្រមជាឯកសារពេញលេញ" នេះ និងរំឭកថា "ដីជនជាតិដើមភាគតិច" ក្នុងករណីភាគច្រើន មិនមែនជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬរបស់គ្រួសារនោះទេ ប៉ុន្តែជាកម្មសិទ្ធិតាមបែបប្រពៃណី ប្រើប្រាស់តាមទំនៀមទម្លាប់ និង/ឬមានសារៈសំខាន់ផ្នែកវប្បធម៌ចំពោះសហគមន៍ជនជាតិដើមភាគតិច។ PS7 ឆ្នាំ២០១២ កថាខណ្ឌ ១២-១៣។

[335] ស្របតាមយុទ្ធនាការ Smart នេះគឺជាស្តង់ដារដែលទាក់ទងនឹង "ការរចនាផលិតផល និងការផ្តល់សេវាសមស្រប" ដែលគេរំពឹងថាអ្នកផ្តល់សេវាហិរញ្ញវត្ថុ "នឹងយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការរចនាផលិតផល និងបណ្តាញផ្តល់សេវា ដែលមិនបង្កគ្រោះថ្នាក់ដល់អតិថិជន" ហើយនឹងរចនាផលិតផល និងបណ្តាញផ្តល់សេវា "ដែលគិតគូរពីលក្ខណៈរបស់អតិថិជន" យុទ្ធនាការ Smart ស្តង់ដារទី១។ ស្របតាមគំរូ SPTF+Cerise ស្តង់ដារនេះត្រូវបានព្រាង ដើម្បីឲ្យ "ផលិតផល សេវាកម្ម និងបណ្តាញរបស់អ្នកផ្តល់សេវា ផ្តល់អត្ថប្រយោជន៍ដល់អតិថិជន" មានន័យថា ក្នុងចំណោមអ្វីផ្សេងទៀត "ផលិតផលគួរតែកាត់បន្ថយឧបសគ្គក្នុងការទទួលបាន ដោយអនុញ្ញាតឱ្យ [...] ការធានាប្រាក់កម្ចីដោយវត្ថុបញ្ចាំ ដែលត្រូវបានកែសម្រួលតាមទ្រព្យសម្បត្តិរបស់ប្រជាជនដែលមិនត្រូវបានរួមបញ្ចូលនៅក្នុងផ្នែកសេដ្ឋកិច្ច [...]។ល។ និងថា "គោលនយោបាយដែលផ្អែកលើនិយាមនៅក្នុងមូលដ្ឋានគួរតែពិពណ៌នាអំពីនិក្ខេបនៃវត្ថុបញ្ចាំដែលអាចទទួលយកបាន មិនអាចទទួលបាន [...]។ គោលនយោបាយបែបនេះមិនគួរទទួលយកវត្ថុបញ្ចាំដែលនឹងបង្កការលំបាកធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សមត្ថភាពរកប្រាក់ចំណូលរបស់អតិថិជន ឬធ្វើឲ្យអតិថិជនបាត់បង់តម្រូវការចាំបាច់នោះទេ។ [...] ប្រសិនបើអតិថិជនមិនមានទ្រព្យសកម្មដើម្បីផ្តល់ជូនជាវត្ថុបញ្ចាំទេនោះ នឹងទាមទារឲ្យមានវិធីជំនួសក្នុងការធានាប្រាក់កម្ចីរបស់ពួកគេ ដូចជាអ្នកធានា និក្ខេបជាយានជំនិះ។ល។" SPTF+Cerise មគ្គុទ្ទេសក៏ណែនាំសម្រាប់ការវាយតម្លៃ និងការអនុវត្តស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន។

ពេញលេញពីពួកគេនោះទេ។ ការហាមឃាត់នេះរួមបញ្ចូលទាំងការប្រើប្រាស់ដីទាំងនោះជាវត្ថុបញ្ចាំសម្រាប់ប្រាក់កម្ចីផងដែរ។

ប្រទេសកម្ពុជាមានការរឹតបន្តឹងតាមច្បាប់ជាតិ ចំពោះការទទួលយកប្លង់ទន់ដែលត្រូវគ្នាជាមួយប័ណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិច (ICLTs) ជាវត្ថុបញ្ចាំសម្រាប់ធានាប្រាក់កម្ចី។ ទោះបីជាមានការរឹតបន្តឹងទាំងនេះក៏ដោយ ក៏ OHCHR នៃអង្គការសហប្រជាជាតិ រដ្ឋាភិបាលកម្ពុជា និងសមាគមឧស្សាហកម្មបានចង្អុលបង្ហាញ ឬទទួលស្គាល់ថា ជនជាតិដើមភាគតិចតែងតែប្រើប្រាស់ប្លង់ទន់ដែលត្រូវគ្នាជាមួយដីសហគមន៍ជនជាតិដើមភាគតិចជាវត្ថុបញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចី ហើយអ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុទទួលយកវា។[336] OHCHR បញ្ជាក់ថា ជនជាតិដើមភាគតិចធ្វើសកម្មភាពបែបនេះ មួយផ្នែកដោយសារសម្ពាធ និងការអនុវត្តដោយបង្ខំរបស់គ្រឹះស្ថានហិរញ្ញវត្ថុ។[337] ដូចបានពិពណ៌នានៅក្នុងផ្នែក ៤.២.១ ការត្រួតពិនិត្យរបស់ស៊ីអេអូលើសក្ខីកម្មរបស់អ្នកខ្ចី របាយការណ៍របស់សង្គមស៊ីវិល និងការសិក្សាជាសាធារណៈចង្អុលបង្ហាញថា ការពឹងផ្អែករបស់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុលើដីដែលជាវត្ថុបញ្ចាំខ្លាំងពេក រួមផ្សំជាមួយកង្វះខាតផលិតផលជំនួស ដែលមិនទាមទារឲ្យមានវត្ថុបញ្ចាំនោះ ចូលរួមចំណែកដល់ស្ថានភាពដែលអ្នកខ្ចីជា IPs ដាក់ដីសហគមន៍ជាវត្ថុបញ្ចាំ។ ការសិក្សាបានរាយការណ៍ថា ក្នុងករណីមួយចំនួន ពួកគេបានងាកទៅរកការកាប់បំផ្លាញព្រៃឈើ ឬបោះបង់ចោលការទទួលស្គាល់ដីសហគមន៍ជាផ្លូវការ ដើម្បីបន្តលទ្ធភាពទទួលបានឥណទាន។[338]

ការអនុវត្តបែបនេះបង្ហាញពីហានិភ័យចំពោះសុចរិតភាពនៃដីសហគមន៍ជនជាតិដើមភាគតិច វប្បធម៌ និងលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ ហានិភ័យដែល PS7 ព្យាយាមបញ្ចៀស។ ការប្រើប្រាស់ដីសហគមន៍ជាវត្ថុបញ្ចាំអាចបំបែកមូលដ្ឋានដីសហគមន៍យ៉ាងទូលំទូលាយ ដែលក្នុងករណីមួយចំនួន នាំឲ្យមានការលក់ដីរបស់ជនជាតិដើមភាគតិចទៅឱ្យជនដែលមិនមែនជាសមាជិកសហគមន៍ជនជាតិដើមភាគតិច។ វាក៏អាចកាត់បន្ថយវិសាលភាព និងការប្រើប្រាស់ព្រៃឈើសហគមន៍ និងការប្រើប្រាស់ធនធានធម្មជាតិ និងកាត់បន្ថយការប្រើប្រាស់ដីសហគមន៍ជាអង្គភាពដែលមិនអាចបំបែកបាន ដោយមានសារៈសំខាន់ផ្នែកវប្បធម៌ និងវិញ្ញាណ ដែលជាកម្មសិទ្ធិរបស់សហគមន៍ទាំងមូល។ [339] ហានិភ័យទាំងនេះត្រូវបានចងក្រងជាឯកសារនៅក្នុងរបាយការណ៍

---

[336] OHCHR ប្រចាំកម្ពុជា ការវាយតម្លៃពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ការកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ ខែតុលា ឆ្នាំ២០១៨ ទំ. ២៧ https://bit.ly/4bShI1P និង Brook, Jack "ការបាត់បង់ដីធ្លី និងបំណុល៖ ខ្សែបន្ទាត់ខាងក្រោមនៃការយល់ខុសអំពីមីក្រូឥណទាន" *South East Asia Globe* ខែឧសភា ឆ្នាំ២០២២ មាននៅ https://bit.ly/44C6L0s និងសេចក្តីប្រកាសព័ត៌មានរួមគ្នារបស់ ABC និង CMA ស្តីពីបញ្ជីវត្ថុបញ្ចាំដែលត្រូវបានហាមឃាត់ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤។ ក្នុងអំឡុងពេលត្រួតពិនិត្យការពិត និងការផ្តល់យោបល់ BFIs ពីរបន្ថែមទៀតបានជូនដំណឹងដល់ស៊ីអេអូថា ពួកគេក៏មានគោលនយោបាយហាមឃាត់ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិ ICLT ជាវត្ថុបញ្ចាំដែរ។ ស៊ីអេអូមិនបានផ្ទៀងផ្ទាត់គោលនយោបាយទាំងនេះដោយឯករាជ្យនោះទេ។

[337] OHCHR ប្រចាំកម្ពុជា ការវាយតម្លៃពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ការកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ ខែតុលា ឆ្នាំ២០១៨ ទំ. ២៧ https://bit.ly/4bShI1P។

[338] De Lange, Emiel, Raj, Sushil Raj, និង Yun Mane, សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច គឺជាគន្លឹះសម្រាប់ការអភិរក្សនៅកម្ពុជា (សេចក្តីអធិប្បាយ), *Mongabay*, ខែធ្នូ ឆ្នាំ២០២៣, https://bit.ly/4kRGaob។ Baird, Ian G., ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច ឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ និងការប្រែប្រួលនៃវិស័យកសិកម្មនៅខេត្តរតនគីរី ភាគឦសាននៃប្រទេសកម្ពុជា *ទិនានុប្បវត្តិការសិក្សាអំពីកសិករ* ឆ្នាំ២០២៤។

[339] Baird, Ian G., ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច ឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ និងការប្រែប្រួលនៃវិស័យកសិកម្មនៅខេត្តរតនគីរី ភាគឦសាននៃប្រទេសកម្ពុជា *ទិនានុប្បវត្តិការសិក្សាអំពីកសិករ* ឆ្នាំ២០២៤។

របស់ OHCHR និងអង្គការសង្គមស៊ីវិលកម្ពុជា និងត្រូវបានពិពណ៌នាដោយផ្ទាល់។

បុគ្គលិករបស់អតិថិជន និងអតិថិជនរបស់ IFC ចំនួនប្រាំមួយនាក់ ដែលមានឈ្មោះនៅក្នុងពាក្យបណ្ដឹង បាននិយាយទៅកាន់ស៊ីអេអូថា ពួកគេមិនទទួលយកប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិចនោះទេ។ [340] ទោះបីជាយ៉ាងណាក៏ដោយ អ្នកខ្ចី IP ដែលត្រូវបានសម្ភាសដោយស៊ីអេអូ អង្គការសង្គមស៊ីវិល និងរបាយការណ៍សាធារណៈទាំងអស់ បញ្ជាក់ថា BFIs ទទួលយកប្លង់ទន់ដែលត្រួតស៊ីគ្នានឹងដីជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមពីសហគមន៍នោះទេ។ ដើមបណ្ដឹង IP ទាំងប្រាំពីរបានរាយការណ៍ថា អតិថិជន/អតិថិជនបន្តរបស់ IFC ចំនួនបួន បានទទួលយកប្លង់ទន់ដី ដែលត្រួតស៊ីគ្នានឹងវិញ្ញាបនបត្រ ICLT របស់ពួកគេ។ ដើមបណ្ដឹងចំនួនប្រាំមួយនាក់ក្នុងចំណោមដើមបណ្ដឹងទាំងប្រាំពីរនាក់ក៏បានរាយការណ៍ផងដែរថា BFIs ទាំងនេះ មិនផ្ដល់ប្រាក់កម្ចីដែលគ្មានប្រាតិភោគនោះទេ នៅពេលដែលដើមបណ្ដឹងបានចូលរួមជាមួយធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាលើកដំបូងនោះ។ នៅក្នុងសហគមន៍ដែលមានវិញ្ញាបនបត្រ ICLT ដើមបណ្ដឹង ជា IP បានរាយការណ៍ថា បុគ្គលិកមកពីអតិថិជនបន្តរបស់ IFC បានដឹងពីភាពត្រួតស៊ីគ្នានេះ ប៉ុន្តែមិនបានចាត់ទុកការអនុវត្តបែបនេះថាជាអំពើខុសច្បាប់នោះទេ និងបានទទួលយកប្លង់ទន់ត្រួតស៊ីគ្នានោះជាវត្ថុបញ្ចាំសម្រាប់ប្រាក់កម្ចីបុគ្គលរបស់ពួកគេ ដោយមិនមានលក្ខខណ្ឌតម្រូវបន្ថែមទៀតទេ។ ដើមបណ្ដឹង ជា IP ម្នាក់ទៀត បានរាយការណ៍ថា បានបញ្ចាំដីរបស់គាត់នៅក្នុង ICLT របស់សហគមន៍ ជាវត្ថុបញ្ចាំសម្រាប់ប្រាក់កម្ចីពីអតិថិជនបន្តដែលនោះ ហើយក្រោយមក មានអារម្មណ៍ថាមានសម្ពាធក្នុងការលក់ដីនោះទៅឱ្យជនដែលមិនមែនជាសមាជិកសហគមន៍ បន្ទាប់ពីបានចោទប្រកាន់ថា ត្រូវបានគំរាមកំហែងដោយមន្ត្រីឥណទាន ថានឹងការរឹបអូសយកដីរបស់គាត់។ យោងតាមដើមបណ្ដឹងរូបនេះ អតិថិជនបន្តរបស់ IFC មិនបានសួរថាតើប្លង់ទន់របស់គាត់ត្រួតស៊ីគ្នានឹង ICLT សហគមន៍ដែរឬអត់នោះទេ នៅពេលគាត់ស្នើសុំប្រាក់កម្ចី។[341]

ស៊ីអេអូក៏បានទទួលដំណឹងផងដែរថា កាលពីខែឧសភា ឆ្នាំ២០២២ ធនាគារហត្ថាបានប្រគល់ប្លង់ទន់ចំនួន ១៦ ច្បាប់ ជូនសមាជិកគណៈកម្មាធិការ ICLT នៅក្នុងខេត្តរតនគិរី ដែលត្រួតស៊ីគ្នានឹង ICLTs របស់សហគមន៍គ្រឹង។[342] ស៊ីអេអូមិនមានព័ត៌មានអំពីពេលវេលា ដែល ICLTs ទាំងនេះត្រូវបានទទួលយកជាវត្ថុបញ្ចាំ ឬអ្វីដែលជំរុញឱ្យពួកគេប្រគល់ជូនវិញនោះទេ ប៉ុន្តែកត់សម្គាល់ថា ធនាគារហត្ថា បានធ្វើការវាយតម្លៃកាន់តែហ្មត់ចត់លើការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅពេលនេះ ដោយមានការគាំទ្រពីសេវាទីប្រឹក្សារបស់ IFC (គម្រោងលេខ ៦០៦១១៩ – សូមមើលផ្នែក ៤.១ ខាងលើ និង ៤.៣)។ ស៊ីអេអូសង្កេតឃើញថា កង្វះខាតគោលការណ៍ណែនាំ និងនីតិវិធីលម្អិតពីរដ្ឋាភិបាល ឬសមាគមឧស្សាហកម្ម ដើម្បីវាយតម្លៃថាតើប្លង់ទន់របស់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុអាចត្រួតស៊ីគ្នាលើដី IP ដែរឬទេ។ អ្នកផ្ដល់ប្រាក់កម្ចីភាគច្រើនពឹងផ្អែកលើអាជ្ញាធរមូលដ្ឋាន

[340] មានអតិថិជន IFC តែមួយប៉ុណ្ណោះ ដែលបញ្ជាក់យ៉ាងច្បាស់នៅក្នុងឯកសារគោលនយោបាយរបស់ពួកគេ ដែលត្រូវបានផ្ទៀងផ្ទាត់ដោយស៊ីអេអូថា ដីដែលពាក់ព័ន្ធនឹងសហគមន៍ជនជាតិដើមភាគតិច គឺជាវត្ថុបញ្ចាំដែលមិនអាចទទួលយកបាននោះទេ។ ក្នុងអំឡុងពេលត្រួតពិនិត្យការពិត និងការផ្ដល់យោបល់ BFIs បីបន្ថែមទៀត បានជូនដំណឹងដល់ស៊ីអេអូថា គោលនយោបាយរបស់ពួកគេក៏ហាមឃាត់ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិ ICLT ជាវត្ថុបញ្ចាំដែរ។ ស៊ីអេអូមិនបានផ្ទៀងផ្ទាត់ការហាមឃាត់យ៉ាងច្បាស់លាស់នៅក្នុងគោលនយោបាយរបស់ពួកគេនោះទេ។

[341] ឧទាហរណ៍ ដើមបណ្ដឹង ជា IP មួយរូប បាននិយាយថា នៅពេលដែលនាងដាក់ពាក្យស្នើសុំប្រាក់កម្ចីពីធនាគារហត្ថា នៅឆ្នាំ២០១៩ មន្ត្រីធនាគារហត្ថា មិនបានសាកសួរថាតើប្លង់ទន់នោះត្រួតស៊ីគ្នានឹង ICLT ដែរឬទេ នោះទេ។

[342] Res, Phasy. ការមកដល់នៅពេលខាងមុខ ការប្រែប្រួលនៃមីក្រូហិរញ្ញវត្ថុ៖ មូលធននិយមតាមព្រំដែន អំពើហិង្សានៃបំណុល និងការប្រកួតប្រជែងក្នុងមូលដ្ឋាន នៅភាគឦសាននៃប្រទេសកម្ពុជា។ និក្ខេបបទថ្នាក់បណ្ឌិត សាកលវិទ្យាល័យ Paris 1 Panthéon-Sorbonne។

(មេភូមិ និងមេឃុំ) ដើម្បីផ្តល់ព័ត៌មាននេះ។ ទោះបីជាយ៉ាងណាក៏ដោយ យោងតាមកិច្ចសម្ភាស និងរបាយការណ៍ដែលបានត្រួតពិនិត្យដោយស៊ីអេអូ វិធីសាស្ត្រផ្ទៀងផ្ទាត់នេះ ជាញឹកញាប់ មានភាពមិនគ្រប់គ្រាន់នោះទេ ពីព្រោះអាជ្ញាធរមូលដ្ឋានបន្តចេញប្លង់ទន់ដីដែលត្រួតស៊ីគ្នានឹង ICLT ជាញឹកញាប់ ជាថ្នូរនឹងទឹកប្រាក់ចំនួន ៥០-១០០ ដុល្លារអាមេរិកក្នុងមួយប័ណ្ណដែលបានចេញ។[343] ស៊ីអេអូកត់សម្គាល់ថា ចំណេះដឹង និងជំនាញរបស់អ្នកឯកទេស E&S របស់ IFC លើបញ្ហាជនជាតិដើមភាគតិច អាចមានអត្ថប្រយោជន៍ជាពិសេស ចំពោះអតិថិជន និងអតិថិជនបន្តរបស់ខ្លួន លើបញ្ហានេះ។ ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូរកមិនឃើញភ័ស្តុតាងថា IFC បានផ្តល់ប្រឹក្សា និងការណែនាំអំពីវិធីសាស្ត្រ និងដំណើរការកំណត់អត្តសញ្ញាណដីជនជាតិដើមភាគតិចនោះទេ ជាពិសេសនៅពេលដែលដីធ្លីទាំងនោះមិនទាន់មានការទទួលស្គាល់ជាផ្លូវការ[344] ឬរបៀបបញ្ចូលដំណើរការទាំងនេះនៅក្នុងប្រតិបត្តិការអតិថិជន រួមទាំងគោលនយោបាយ និងនីតិវិធីផងដែរ ដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច។

ផ្អែកលើព័ត៌មានដែលបានត្រួតពិនិត្យ រួមទាំងការសង្កេតនៅទីវាលរបស់ស៊ីអេអូដោយផ្ទាល់ ស៊ីអេអូបានកំណត់ចន្លោះប្រហោងនៅក្នុងសមិទ្ធកម្មសង្គមនៃការវិនិយោគរបស់ IFC ចំពោះលក្ខខណ្ឌតម្រូវនៃ PS7 និងបញ្ជីផាត់ចេញរបស់ IFC ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច និងការពារដីធ្លី និងធនធានរបស់ពួកគេ។

*b) អ្នកផ្តល់ប្រាក់កម្ចីនៅក្នុងតំបន់ IP ភាគច្រើន មិនផ្តល់ជូននូវផលិតផលដែលគិតគូរពីវប្បធម៌របស់ IP នៅកម្ពុជា និងអាចផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ជនជាតិដើមភាគតិចនោះទេ*

ស្របតាមលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងសង្គម (E&S) របស់ IFC (PS7) អតិថិជនត្រូវបានតម្រូវឲ្យជៀសវាងផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច[345] និងធានាថា រាល់សកម្មភាពដែលប៉ះពាល់ពួកគេគឺ ផ្អែកលើការពិគ្រោះយោបល់ និងការចូលរួមដោយមានព័ត៌មានគ្រប់គ្រាន់។ បញ្ជីផាត់ចេញរបស់ IFC ហាមឃាត់បន្ថែមទៀតចំពោះសកម្មភាពរបស់មីក្រូហិរញ្ញវត្ថុ ដែលប៉ះពាល់ដីធ្លីរបស់ជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីពួកគេ។[346] លើសពីនេះទៀត GIIP ស្តីពីការវិនិយោគមីក្រូហិរញ្ញវត្ថុ ដែលតម្រូវឱ្យមានការអនុវត្តស្របតាម PS1 អំពាវនាវឲ្យមានការរចនាផលិតផលហិរញ្ញវត្ថុតាមវិធីដែលជៀសវាងគ្រោះថ្នាក់ចំពោះអតិថិជន BFI និងផ្តល់អត្ថប្រយោជន៍ដល់ពួកគេ។ ចំណុចនេះរួមបញ្ចូលទាំងការកែសម្រួល

[343] Brook, Jack "ការបាត់បង់ដីធ្លី និងបំណុលៈ ខ្សែបន្ទាត់ខាងក្រោមនៃការយល់ខុសអំពីមីក្រូឥណទាន" *South East Asia Globe* ខែឧសភា ឆ្នាំ២០២២ មាននៅ https://bit.ly/3SNDDyP។

[344] ស៊ីអេអូកត់សម្គាល់ថា មានតែអតិថិជនរបស់ IFC តែមួយប៉ុណ្ណោះ ដែលហាក់បីដូចជាបានរៀបរាប់យ៉ាងច្បាស់លាស់ថា ដីដែលពាក់ព័ន្ធនឹងសហគមន៍ IP ជាវត្ថុបញ្ចាំដែលមិនអាចទទួលយកបាន។ ជាវិជ្ជមាន វាមិនបានចងភ្ជាប់ការរឹតបន្តឹងនេះទៅនឹងអត្ថិភាពនៃ ICLT ដែលត្រូវបានទទួលស្គាល់ជាផ្លូវការនោះទេ។

[345] PS7 ឆ្នាំ២០១២ កថាខណ្ឌ ៨ និង ៩

[346] បញ្ជីផាត់ចេញរបស់ IFC មាននៅទីនេះ៖ https://bit.ly/4hNPcA6។ PS7 របស់ IFC កំណត់លក្ខខណ្ឌតម្រូវអប្បបរមារបស់ IFC សម្រាប់ "ការយល់ព្រមជាឯកសារពេញលេញ" នេះ និងរំឭកថា "ដីជនជាតិដើមភាគតិច" ក្នុងករណីភាគច្រើន មិនមែនជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬរបស់គ្រួសារនោះទេ ប៉ុន្តែជាកម្មសិទ្ធិតាមបែបប្រពៃណី ប្រើប្រាស់តាមទំនៀមទម្លាប់ និង/ឬវប្បធម៌ ដែលមានសារៈសំខាន់ចំពោះសហគមន៍ជនជាតិដើមភាគតិច។ PS7 ឆ្នាំ២០១២ កថាខណ្ឌ ១២-១៣។

ផលិតផលតាមតម្រូវការពិសេស និងកាលៈទេសៈរបស់សហគមន៍ដែលទទួលសេវាផងដែរ។[347] ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូកត់សម្គាល់ថា អតិថិជន និងអតិថិជនបន្តរបស់ IFC ធ្វើការនៅក្នុងតំបន់ដែលមានជនជាតិដើមភាគតិចភាគច្រើននៃប្រទេសកម្ពុជា ដោយមិនបានផ្តល់ជូននូវផលិតផលដែលគិតគូរពីវប្បធម៌របស់ពួកគេនោះទេ។ នៅខណៈពេលដែល BFIs មួយចំនួន ទទួលយកទម្រង់ផ្សេងៗនៃវត្ថុបញ្ចាំ ដូចជា សាច់ប្រាក់ ចលនទ្រព្យ ឬការធានានោះ ជម្រើសទាំងនេះមិនត្រូវបានរៀបចំជាពិសេសតាមតម្រូវការរបស់ជនជាតិដើមភាគតិចនោះទេ និងជាចំណែកតូចមួយនៃផលបត្ររបស់ BFIs។[348] ឧទាហរណ៍ ស៊ីអេអូរកមិនឃើញភស្តុតាងនៃផលិតផលដែលត្រូវបានរចនាឡើងជាពិសេស ដើម្បីកាត់បន្ថយហានិភ័យនៃការបាត់បង់ដីធ្លីសម្រាប់អ្នកខ្ចីជាជនជាតិដើមភាគតិចនោះទេ ដូចជា ប្រាក់កម្ចីខ្នាតធំ ជាដើម។[349] ផ្ទុយទៅវិញ ផលិតផលភាគច្រើនដែលផ្តល់ជូនដោយអតិថិជន និងអតិថិជនបន្តរបស់ IFC តម្រូវឲ្យមានដីជាវត្ថុបញ្ចាំ ដោយមិនគិតពីគ្រោះថ្នាក់ដែលការបាត់បង់ដីដោយសារការលំបាកក្នុងការសងប្រាក់ អាចបង្កចំពោះជនជាតិដើមភាគតិចនោះទេ។[350]

ហានិភ័យនៃគ្រោះថ្នាក់ដែលអាចកើតឡើងមានសារៈសំខាន់ណាស់ ដោយសារ៖

- ជីវភាពរស់នៅរបស់ IP នៅកម្ពុជា ពឹងផ្អែកលើដីធ្លី ដែលធ្វើឲ្យពួកគេងាយរងគ្រោះជាពិសេស ចំពោះការបាត់បង់ដីធ្លីទាំងនោះ។[351]

---

[347] ឧទាហរណ៍ ប្រាក់កម្ចីជាក្រុមធំៗដោយគ្មានវត្ថុបញ្ចាំ - ជាការអនុវត្តជាទូទៅនៅកម្ពុជា - មិនត្រូវបានផ្តល់ជូនក្នុងទំហំដែលអាចបំពេញតាមតម្រូវការរបស់សហគមន៍បាននោះទេ។ ផ្ទុយទៅវិញ ផលិតផលដែលផ្តល់ជូន និងផ្តល់ហិរញ្ញប្បទាន ហាក់បីដូចជាមិនបានគិតគូរពីគ្រោះថ្នាក់ ដែលការបាត់បង់ដីធ្លីដោយសារការលំបាកក្នុងការសងប្រាក់ អាចបង្កឡើងចំពោះជនជាតិដើមភាគតិចនោះទេ។

[348] ធនាគារហត្ថា ឆ្នាំ២០២៤ របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើវិសោធនកម្ម ទំ. ១០៣ https://bit.ly/3VIljsjhttps://bit.ly/3VIljsj; ធនាគារអេស៊ីលីដា ឆ្នាំ២០២៤ របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើវិសោធនកម្ម ទំ. ១១៧ https://bit.ly/4nlxhyc; អម្រ៉ឹត ឆ្នាំ២០២៤ របាយការណ៍ប្រចាំឆ្នាំ ទំ. ១១៥ https://bit.ly/3WpH8Nn; ប្រាសាក់ ឆ្នាំ២០២៤ របាយការណ៍ប្រចាំឆ្នាំ ទំ. ៥៩ https://bit.ly/4nYvepz។ របាយការណ៍ Bliss ទំ. ៦៧ https://bit.ly/3XRpDXv៖ របាយការណ៍វាយតម្លៃ M-CRIL – CMA ឆ្នាំ២០២៣ ទំ. ៥៩។ នៅខណៈពេលដែលផលបត្ររបស់អិលអូអិលស៊ីក៏មានប្រាក់កម្ចីដែលមានវត្ថុបញ្ចាំភាគច្រើនដែរនោះ ផលបត្រប្រាក់កម្ចីរបស់វា មួយផ្នែកធំ (៤៣%) ត្រូវបានបង្កើតឡើងដោយប្រាក់កម្ចីជាក្រុមដែលមិនមានវត្ថុបញ្ចាំ។ អតិថិជន និងអតិថិជនបន្តរបស់ IFC ភាគច្រើន ផ្តល់ជូនប្រាក់កម្ចីបុគ្គលដែលមានវត្ថុបញ្ចាំ។ អិលអូអិលស៊ី របាយការណ៍ប្រចាំឆ្នាំ ២០២៣ ទំ. ១៤ https://bit.ly/3FG1cWH។

[349] ដូចនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុសកលភាគច្រើនដែរ BFI នៅកម្ពុជា ដំបូងឡើយ ពឹងផ្អែកយ៉ាងខ្លាំងទៅលើការផ្តល់ប្រាក់កម្ចីជាក្រុម។ អភិក្រមនេះគឺផ្អែកលើគោលការណ៍ដែលថា អត្រាសងប្រាក់មានភាពប្រសើរឡើងនៅពេលដែលអ្នកខ្ចីប្រាក់មានទំនួលខុសត្រូវរួមគ្នា ទោះបីជាគ្មានវត្ថុបញ្ចាំក៏ដោយ។ ប្រាក់កម្ចីជាក្រុមបានគ្របដណ្តប់លើវិស័យនេះរហូតដល់ទសវត្សរ៍ឆ្នាំ ២០១០ ប៉ុន្តែចាប់តាំងពីពេលនោះមក ត្រូវបានជំនួសដោយប្រាក់កម្ចីបុគ្គល ដែលនៅពេលនេះ បង្កើតបានជាគំរូផ្តល់ប្រាក់កម្ចីដ៏លេចធ្លោ។ សូមមើល៖ ទិន្នន័យពីទីផ្សារ MIX៖ https://bit.ly/41KUNAZ; W. Nathan Green, Theavy Chhom, Reach Mony និង Jennifer Estes ផ្នែកខាងក្រោមនៃមីក្រូហិរញ្ញវត្ថុ៖ សូចនាករសមិទ្ធកម្ម និងបំណុលក្រៅប្រព័ន្ធនៅកម្ពុជា ការអភិវឌ្ឍ និងការផ្លាស់ប្តូរ លេខ ៥៤ ច្បាប់ទី ៤ វិទ្យាស្ថានអន្តរជាតិសិក្សាសង្គម ខែមិថុនា ឆ្នាំ២០២៣ https://bit.ly/4kPOMe7។

[350] ដើមបណ្តឹងចំនួនប្រាំមួយនាក់ក្នុងចំណោមដើមបណ្តឹងទាំងប្រាំពីរនាក់បានរាយការណ៍ថា អតិថិជន/អតិថិជនបន្តរបស់ IFC ចំនួនបួន មិនផ្តល់ប្រាក់កម្ចីដែលគ្មានប្រាតិភោគនោះទេ នៅពេលដែលពួកគេបានទៅជួបភ្នាក់ងារ BFI ជាលើកទីមួយ ឬនៅពេលដែលភ្នាក់ងារទាំងនោះមកជួបពួកគេ។

[351] ច្បាប់ភូមិបាលកម្ពុជា ទទួលស្គាល់ថា ជនជាតិដើមភាគតិចនៅកម្ពុជា គឺជាជនដែលសមាជិកបង្ហាញឯកភាពជាតិសាសន៍ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ហើយជាអ្នកអនុវត្តរបៀបរស់នៅបែបប្រពៃណី និងដាំដុះដីនៅក្នុងកម្មសិទ្ធិរបស់ពួកគេតាមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។ ច្បាប់ភូមិបាលទទួលស្គាល់ថា ជនជាតិដើមភាគតិច គឺជាកន្លែងដែលពួកគេបានតាំងលំនៅ និងប្រកបរបរកសិកម្មបែបប្រពៃណី រួមទាំងដីដាំដុះ និងដីដែលចាំបាច់សម្រាប់ផ្លាស់ប្តូរការដាំដុះទៅតាមវិធីកសិកម្មដែលពួកគេអនុវត្ត។ រាជរដ្ឋាភិបាលកម្ពុជា (២០០១) ច្បាប់ភូមិបាល (នស/រកម/០៨០១/១៤) ភ្នំពេញ មាត្រា ២៣ និង ២៥ https://bit.ly/41OhoOA។ សូមមើល របាយការណ៍ Bliss ឆ្នាំ២០២២។

- អត្តសញ្ញាណ IP ត្រូវបានចងភ្ជាប់នឹងដីធ្លីរបស់ពួកគេ ហើយការបាត់បង់ដីធ្លីអាចធ្វើឱ្យប៉ះពាល់ដល់ការចងចាំរួម ប្រវត្តិសាស្ត្រ និងបេតិកភណ្ឌវប្បធម៌របស់ពួកគេ ដែលបង្កប់អត្ថន័យយ៉ាងជ្រៅនៅក្នុងទេសភាពធម្មជាតិ និងលទ្ធភាពទទួលបានធនធានធម្មជាតិ។[352]
- សហគមន៍ជនជាតិដើមភាគតិចនៅភាគឦសាននៃប្រទេសកម្ពុជាភាគច្រើន មានលក្ខណៈសាច់ញាតិ (ដែលដីត្រូវបានផ្ទេរពីម្ដាយទៅកូនស្រី) និងគ្រួសារ (ដែលកូនស្រីនៅតែបន្តរស់នៅក្នុងភូមិរបស់ម្ដាយពួកគេ) ផ្ដល់ការការពារផ្នែកសេដ្ឋកិច្ច និងសន្តិសុខផ្ទាល់ខ្លួនដល់ស្ត្រី។[353] ការបាត់បង់ដីធ្លី ដោយសារកង្វះខាតសមត្ថភាពសងប្រាក់ ធ្វើឱ្យប៉ះពាល់ដល់ស្ត្រី និងការថែរក្សាខ្សែបន្ទាត់សាច់ញាតិ ទាំងនេះ។

យោងតាមព័ត៌មានដែលបានត្រួតពិនិត្យ រួមទាំងការសង្កេតនៅទីវាលដោយស៊ីអេអូដោយផ្ទាល់ផងដែរ កង្វះផលិតផល និងការអនុវត្តដែលបានកែសម្រួលតាមតម្រូវការពិសេស និងកាលៈទេសៈរបស់សហគមន៍ដែលទទួលសេវាពីអតិថិជន និងអតិថិជនបន្តរបស់ IFC នៅក្នុងសំណុំរឿងនេះ បង្ហាញពីចន្លោះប្រហោងនៅក្នុងសមិទ្ធកម្មសង្គមនៃការវិនិយោគទាំងនេះ ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃ PS1 និង PS7។ លក្ខខណ្ឌតម្រូវទាំងនេះ រួមមាន ការកំណត់ និងការវាយតម្លៃហានិភ័យ និងផលប៉ះពាល់សង្គម ជាពិសេស លើក្រុមងាយរងគ្រោះ និងជនជាតិដើមភាគតិច ការបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមប្រកបដោយប្រសិទ្ធភាព ស្របតាម GIIP រួមទាំងការកែសម្រួល និងកែប្រែផលិតផល និងសេវាដែលមានស្រាប់របស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងផលសម្រេចរបស់អតិថិជនផងដែរ[354] និងពិនិត្យតាមដានការអនុវត្តរបស់អតិថិជន ដើម្បីធានាថា ផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិចត្រូវបានជៀសវាង ឬកាត់បន្ថយ។ ដូចបានរៀបរាប់នៅក្នុងផ្នែក ៤.៤ ខាងក្រោម ស៊ីអេអូរកមិនឃើញភស្តុតាងណាមួយដែលបង្ហាញថា IFC បានបំពេញតាមលក្ខខណ្ឌតម្រូវ E&S របស់ខ្លួន ក្នុងការធ្វើការជាមួយអតិថិជន និងអតិថិជនបន្តរបស់ខ្លួន ដើម្បីកែសម្រួលផលិតផលរបស់ពួកគេ ដើម្បីដោះស្រាយហានិភ័យ និងតម្រូវការជាក់លាក់របស់អ្នកខ្ចីជាជនជាតិដើមភាគតិចនោះទេ។

### *c) កង្វះការប្រាស្រ័យទាក់ទងសមរម្យសម្រាប់ជនជាតិដើមភាគតិច*

---

[352] J. Padwe *ព្រៃឈើដែលរងការរំខាន ការចងចាំដែលបែកបាក់ ចារ៉ាយ និងជីវិតដទៃទៀត នៅតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា* សារព័ត៌មាននៃសាកលវិទ្យាល័យ Washington ឆ្នាំ២០២០; Milne, Sarah នៅក្រោមស្បែកខ្លារខិន៖ ការធ្វើជំនួញដីធ្លី និងបញ្ហាការសម្រេចចិត្តចំពោះប័ណ្ណកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា។ *ទស្សនៈនៅអាស៊ីប៉ាស៊ីហ្វិក* ៥៤ (៣) ឆ្នាំ២០១៣ ទំ. ៣២៣-៣៣៩; Ironside, Jeremy ឆ្នាំ២០១៣ ការគិតនៅក្រៅរបង៖ ស្វែងយល់ពីទំនាក់ទំនងរវាងវប្បធម៌/ដីធ្លី៖ ករណីសិក្សានៅខេត្តរតនគិរី ប្រទេសកម្ពុជា និក្ខេបបទថ្នាក់បណ្ឌិត សាកលវិទ្យាល័យ Otago, Dunedin, នូវែលហ្សេឡង់; Uk, Krishna. ឆ្នាំ២០១១. ការរស់នៅចំពេលមានសំណល់នៃសង្គ្រាម៖ យុទ្ធសាស្ត្រចិញ្ចឹមជីវិត និងការរស់រានមានជីវិត នៅក្នុងភូមិចារ៉ាយនៅភាគឦសាននៃប្រទេសកម្ពុជា និក្ខេបបទថ្នាក់បណ្ឌិត មហាវិទ្យាល័យ Darwin សាកលវិទ្យាល័យ Cambridge, និង Bourdier, Frédéric (ឆ្នាំ២០០៦) *ភ្នំត្បូងរតនគិរី ប្រទេសកម្ពុជា* រាជធានីភ្នំពេញ៖ មជ្ឈមណ្ឌលខេមរសិក្សា។

[353] Res, មីក្រូហិរញ្ញវត្ថុនៅតាមព្រំដែនព្រៃឈើ ឆ្នាំ២០២៤ ទំ. ៣៩ ៥៣។ Salemink, Oscar ឆ្នាំ១៩៩៩ 'លើសពីភាពស្មុគស្មាញ និង naiveté៖ ការកំណត់បរិបទនៃជនជាតិភាគតិចនៃតំបន់ខ្ពង់រាបភាគកណ្ដាលនៃប្រទេសវៀតណាម ឆ្នាំ១៨៥0-១៩៩០' សារណាថ្នាក់បណ្ឌិតផ្នែកប្រវត្តិសាស្ត្រ សាកលវិទ្យាល័យ Vrijdag ហូឡង់ ទំ. ១៣៦-១៣៨; Salemink, Oscar ឆ្នាំ១៩៩៩ 'លើសពីភាពស្មុគស្មាញ និង naiveté៖ ការកំណត់បរិបទនៃជនជាតិភាគតិចនៃតំបន់ខ្ពង់រាបភាគកណ្ដាលនៃប្រទេសវៀតណាម ឆ្នាំ១៨៥0-១៩៩០' សារណាថ្នាក់បណ្ឌិតផ្នែកប្រវត្តិសាស្ត្រ សាកលវិទ្យាល័យ Vrijdag ហូឡង់ ទំ. ១៣៩។

[354] Cerise+ SPTF មគ្គុទ្ទេសក៍ណែនាំអំពីការវាយតម្លៃ និងការអនុវត្តស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ស្តង់ដារ 3B https://bit.ly/4mIrsRz។

PS7 ទទួលស្គាល់ថា ជនជាតិដើមភាគតិច ច្រើនតែមានភាសាខុសៗគ្នាពីសង្គមភាគច្រើន ហើយព័ត៌មានគម្រោងគួរតែផ្តល់ជូនពួកគេនៅក្នុងទម្រង់ដែលអាចយល់បាន ដោយប្រើភាសាសមស្រប។[355] លើសពីនេះទៀត ស្តង់ដារ GIIP ស្តីពីតម្លាភាព ដែលអតិថិជនរបស់ IFC ត្រូវតែអនុវត្តស្របតាម PS1 នោះ តម្រូវឱ្យអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុផ្តល់ព័ត៌មានច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលា ដល់អ្នកខ្ចី ក្នុងលក្ខណៈ និងភាសាដែលពួកគេអាចយល់បាន ដូច្នេះពួកគេអាចធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់។[356] ស៊ីអេអូមិនឃើញមានការបង្ហាញថា អតិថិជន និងអតិថិជនបន្តរបស់ IFC ដែលធ្វើប្រតិបត្តិការនៅក្នុងតំបន់ដែលមានជនជាតិដើមភាគតិចភាគច្រើន បានបកប្រែព័ត៌មាន ឬឯកសារ ជាភាសាក្នុងមូលដ្ឋាននោះទេ។ កង្វះខាតឯកសារទាំងនេះអាចរារាំងដល់ការប្រាស្រ័យទាក់ទងយ៉ាងសមស្របជាមួយជនជាតិដើមភាគតិច ដែលជាប្រជាជនគោលដៅនៃមីក្រូហិរញ្ញវត្ថុនៅក្នុងតំបន់ទាំងនេះ។ នៅខណៈពេលដែលបុគ្គលិក BFI ក្នុងមូលដ្ឋានមួយចំនួនក៏ជា IP និងនិយាយភាសារបស់ពួកគេដែរនោះ ការសម្ភាសរបស់ស៊ីអេអូបង្ហាញថា កាលៈទេសៈនេះមិនបានដោះស្រាយឧបសគ្គនៃការប្រាស្រ័យទាក់ទងយ៉ាងជាប់លាប់នោះទេ។[357] ក្នុងអំឡុងពេលធ្វើបេសកកម្មនៅទីវាល ស៊ីអេអូបានដឹងថា ដើមបណ្តឹងយ៉ាងតិចបីនាក់ មានបញ្ហាក្នុងការយល់ដឹងអំពីលក្ខខណ្ឌ និងគោលនយោបាយនៃប្រាក់កម្ចីរបស់ពួកគេ ឬសំណើរបស់បុគ្គលិក FI ពីព្រោះមន្ត្រីឥណទាននិយាយតែភាសាខ្មែរ។[358] ចន្លោះប្រហោងនៃការប្រាស្រ័យទាក់ទងទាំងនេះអាចដាក់កម្រិតលើសមត្ថភាពរបស់អ្នកខ្ចីក្នុងការយល់ដឹងយ៉ាងពេញលេញអំពីកាតព្វកិច្ច សិទ្ធិ និងដំណោះស្រាយដែលមាន របស់ពួកគេ ដូច្នេះហើយ វាធ្វើឲ្យប៉ះពាល់ដល់លក្ខខណ្ឌតម្រូវក្នុងការពិគ្រោះយោបល់ និងការចូលរួមដោយមានព័ត៌មានពេញលេញនៃ PS7 ក៏ដូចជាស្តង់ដារ GIIP ស្តីពីតម្លាភាពផងដែរ។

ផ្អែកលើព័ត៌មានដែលបានត្រួតពិនិត្យ រួមទាំងការសង្កេតនៅទីវាលរបស់ស៊ីអេអូដោយផ្ទាល់ ស៊ីអេអូបានកំណត់ចន្លោះប្រហោងនៅក្នុងសមិទ្ធកម្មសង្គមនៃការវិនិយោគរបស់ IFC ជាមួយលក្ខខណ្ឌតម្រូវនៃ PS1 និង PS7 ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច និងផ្តល់ការចូលរួម និងអត្ថប្រយោជន៍ ដែលសមស្របតាមវប្បធម៌។

---

[355] PS7 កថាខណ្ឌ ១ ៥ និង ១០ កំណត់សម្គាល់ការណែនាំទី៧ ជនជាតិដើមភាគតិច GN១៩។

[356] មជ្ឈមណ្ឌលបរិយាប័ន្នហិរញ្ញវត្ថុ Accion ការដាក់គោលការណ៍ឱ្យដំណើរការ៖ ការណែនាំលម្អិតអំពីគោលការណ៍ការពារអតិថិជន ការការពារ និងការផ្តល់ភាពអង់អាចដល់អ្នកប្រើប្រាស់ហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ ទំ. ៨ https://bit.ly/4kw6Dao និង Cerise+ SPTF ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ស្តង់ដារ ៤.B ទំ. ២៨ https://bit.ly/41RDorH និង Cerise+ SPTF មគ្គុទ្ទេសក៍ណែនាំសម្រាប់ការវាយតម្លៃ https://bit.ly/4dTJIU8។ BFI មួយ បានបង្ហាញទៅកាន់ស៊ីអេអូថា កិច្ចព្រមព្រៀងប្រាក់កម្ចីត្រូវបានសរសេរជាភាសាខ្មែរ ដែលជាភាសាផ្លូវការរបស់ប្រទេសកម្ពុជា ហើយអ្នកខ្ចីបានទទួលព័ត៌មានអំពី ខ និងលក្ខខណ្ឌនៃប្រាក់កម្ចី ដោយមានជំនួយជារូបភាព។ BFI មិនបានបង្ហាញថាតើសម្ភារៈទាំងនេះត្រូវបានបកប្រែ ឬបកស្រាយជាភាសា IP ដល់អ្នកខ្ចីជា IP ដែរឬអត់នោះទេ។

[357] ក្នុងអំឡុងពេលចុះត្រួតពិនិត្យនៅទីវាលរបស់ស៊ីអេអូ BFIs ជាច្រើនបានលើកឡើងថា នៅក្នុងតំបន់ IP មន្ត្រីឥណទានរបស់ពួកគេក៏តែងតែនិយាយភាសាជនជាតិដើមភាគតិចដែរ ហើយពួកគេជាអ្នកទំនាក់ទំនងជាមួយអ្នកខ្ចីជា IP។

[358] ផ្អែកលើកម្រិតអក្ខរកម្មភាសាខ្មែរ ដែលបានរាយការណ៍ដោយដើមបណ្តឹងជា IP វាទំនងថា ដើមបណ្តឹងបន្ថែមបានប្រឈមមុខនឹងបញ្ហាប្រឈមផ្នែកអក្ខរកម្ម និងភាពស្ទាត់ជំនាញ ដែលអាចប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការយល់ដឹងយ៉ាងពេញលេញអំពីព័ត៌មានដែលបានផ្តល់ជូន។

### ៤.២.៣ ការពិចារណាអំពីសមិទ្ធកម្ម E&S របស់អតិថិជន និងអតិថិជនបន្តរបស់ IFC ទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃ PS1 ពាក់ព័ន្ធនឹងយន្តការបណ្តឹងសារទុក្ខ

PS1 តម្រូវឱ្យអតិថិជន FI របស់ IFC បង្កើតយន្តការទំនាក់ទំនងខាងក្រៅសម្រាប់គម្រោង និងមនុស្សដែលរងផលប៉ះពាល់ពីគម្រោង។ នេះគួររួមបញ្ចូលវិធីសាស្ត្រក្នុងការទទួល ចុះឈ្មោះ ត្រួតពិនិត្យ វាយតម្លៃ តាមដានឆ្លើយតប និងធ្វើសកម្មភាពលើការសាកសួរ និងការតវ៉ាពីសាធារណជនអំពីប្រតិបត្តិការរបស់ពួកគេផងដែរ។ IFC ក៏រំពឹងថា FIs នឹងតម្រូវឱ្យអនុគម្រោងរបស់ពួកគេបង្កើត និងថែរក្សាយន្តការបណ្តឹងសារទុក្ខ ប្រសិនបើអនុគម្រោងដែលចោទជាសំណួរនោះ ស្ថិតនៅក្រោមស្តង់ដារសមិទ្ធកម្ម E&S របស់ IFC។[359] លើសពីនេះទៀត ប្រសិនបើប្រតិបត្តិការផ្ទាល់របស់ FI អាចបង្កើតផលប៉ះពាល់អវិជ្ជមានលើសហគមន៍ដែលរងផលប៉ះពាល់ ឬបរិស្ថាននោះ FI ត្រូវបានគេរំពឹងថានឹងមានយន្តការសារទុក្ខជាផ្នែកមួយនៃ ESMS របស់ខ្លួន។ PS1 បញ្ជាក់ថា យន្តការសារទុក្ខគួរតែព្យាយាមដោះស្រាយកង្វល់របស់សហគមន៍ដែលរងផលប៉ះពាល់ភ្លាមៗ ដោយប្រើដំណើរការប្រឹក្សាយោបល់ដែលអាចយល់បាន និងមានតម្លាភាព ដែលសមស្របតាមវប្បធម៌ និងអាចចូលដំណើរការបាន ដោយមិនគិតថ្លៃ និងដោយគ្មានការសងសឹកចំពោះភាគីដែលបង្កើតបញ្ហា ឬកង្វល់នោះ។[360] បន្ថែមពីលើកាតព្វកិច្ចនៃ PS1 ប្រឆាំងនឹងការសងសឹកចំពោះបណ្តឹងសារទុក្ខទៀតនោះ IFC បានចេញសេចក្តីថ្លែងការណ៍គោលជំហរចំពោះការសងសឹកសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនៅឆ្នាំ២០១៨។ សេចក្តីថ្លែងការណ៍នេះតម្រូវឱ្យអតិថិជនបង្កើតយន្តការបណ្តឹងសារទុក្ខនៅកម្រិតគម្រោង ដែលអាចប្រើប្រាស់បាន អនុវត្តដោយគ្មានការសងសឹក ដើម្បីធានាថា ភាគីពាក់ព័ន្ធអាចចូលរួមដោយសេរីជាមួយ IFC និងអតិថិជនរបស់ខ្លួន ផ្តល់មតិកែលម្អ បញ្ចេញមតិប្រឆាំង និងលើកឡើងនូវកង្វល់ដោយគ្មានភាពភ័យខ្លាច។[361]

ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អចំពោះមីក្រូហិរញ្ញវត្ថុ ដែលអាចអនុវត្តបាន នៅក្រោម PS1 សង្កត់ធ្ងន់បន្ថែមទៀត អំពីសារៈសំខាន់នៃការធានាឱ្យមានយន្តការដែលអាចប្រើប្រាស់បាន ត្រូវបានកែសម្រួល មានប្រសិទ្ធភាពទាន់ពេលវេលា និងឆ្លើយតបនឹងពាក្យបណ្តឹង និងដោះស្រាយបញ្ហា។[362] យោងតាមគោលការណ៍ណែនាំរបស់ GIIP យន្តការទាំងនេះគួរតែត្រូវបានរចនាឡើងមិនត្រឹមតែដើម្បីដោះស្រាយបញ្ហាបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកែលម្អផលិតផល និងសេវាកម្មផងដែរ។ អ្នកខ្ចីគួរតែអាចដាក់ពាក្យបណ្តឹងទៅកាន់បុគ្គលដទៃទៀតក្រៅពីមន្ត្រីឥណទាន ឬមន្ត្រីផលិតផលរបស់ពួកគេ និងអ្នកគ្រប់គ្រងបុគ្គលទាំងនោះ អ្នកផ្តល់សេវាហិរញ្ញវត្ថុគួរតែមានបណ្តាញពាក្យបណ្តឹងឥតគិតថ្លៃ និងអាចប្រើប្រាស់បាន យ៉ាងតិចពីរ និងថាគោលនយោបាយពាក្យ

---

[359] កំណត់សម្គាល់ការណែនាំអំពីអន្តរការីហិរញ្ញវត្ថុ ខែកញ្ញា ឆ្នាំ២០២៣ កថាខណ្ឌ ៥៥ https://bit.ly/4l7hHLW និងកំណត់សម្គាល់ការបកស្រាយអំពីអន្តរការីហិរញ្ញវត្ថុ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ IN៤៩ និង IN៥០ https://bit.ly/3HF4wlZ។

[360] PS1 ឆ្នាំ២០១២ កថាខណ្ឌ ៣៥ និងសម្រាប់ការវិនិយោគនៅ MEF សូមមើល PS1 ឆ្នាំ២០០៦ កថាខណ្ឌ ២៣។

[361] សេចក្តីថ្លែងការណ៍គោលជំហររបស់ IFC ចំពោះការសងសឹកសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនៃគម្រោង ខែតុលា ឆ្នាំ ២០១៨ https://bit.ly/4600H1m។

[362] CGAP ការអនុវត្តគោលការណ៍ស្តីពីកិច្ចការពារអតិថិជន មគ្គុទ្ទេសក៍ណែនាំផ្នែកបច្ចេកទេសសម្រាប់វិនិយោគិន ឆ្នាំ២០១០ ទំ.៣ https://bit.ly/4jdwMKb; មជ្ឈមណ្ឌលបរិយាប័ន្នហិរញ្ញវត្ថុ Accion ការដាក់គោលការណ៍ឱ្យដំណើរការ៖ ការណែនាំលម្អិតអំពីគោលការណ៍ការពារអតិថិជន ការការពារ និងការផ្តល់ភាពអង់អាចដល់អ្នកប្រើប្រាស់ហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ ទំ. ៣១-៣៣, https://officecao.org/4mlrWqV និង Cerise+ SPTF ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ ២០២២ ទំ. ៣៥-៣៦ https://bit.ly/41RDorH។

បណ្តឹងគួរតែកំណត់កម្រិតភាពធ្ងន់ធ្ងរ និងបញ្ជូនពាក្យបណ្តឹងធ្ងន់ធ្ងរទៅកាន់អ្នកគ្រប់គ្រងជាន់ខ្ពស់ភ្លាមៗ។[363] សម្រាប់ផ្នែករបស់ខ្លួន កំណត់សម្គាល់បច្ចេកទេស ឆ្នាំ២០១៩ របស់ក្រុមធនាគារពិភពលោក ស្តីពីការដោះស្រាយពាក្យបណ្តឹងក្នុងចំណោមអ្នកផ្តល់សេវាហិរញ្ញវត្ថុ ផ្តល់អនុសាសន៍អំពីការគ្រប់គ្រងពាក្យបណ្តឹងនៅក្នុងរចនាសម្ព័ន្ធតាមលំដាប់ថ្នាក់ តាមរយៈក្រុមការងារដោះស្រាយពាក្យបណ្តឹងផ្តាច់មុខ ដាច់ដោយឡែកពីអង្គភាពអាជីវកម្មដែលកំពុងធ្វើប្រតិបត្តិការ។[364] អភិក្រមនេះព្យាយាមធានាឲ្យមានដំណើរការពាក្យបណ្តឹងដោយយុត្តិធម៌ និងតម្លាភាព ជៀសវាងជម្លោះផលប្រយោជន៍ដែលអាចកើតឡើង និងកាត់បន្ថយភាពភ័យខ្លាចរបស់អតិថិជនចំពោះការសងសឹក។ កំណត់សម្គាល់បច្ចេកទេសសង្កត់ធ្ងន់ថា មន្ត្រីឥណទានអាចមានឥទ្ធិពលលើសមត្ថភាពខ្ចីរបស់អ្នកខ្ចី ដែលអាចរារាំងអតិថិជនពីការរាយការណ៍អំពីពាក្យបណ្តឹង។[365]

នៅកម្ពុជា ស្ថាប័នហិរញ្ញវត្ថុបានដោះស្រាយបញ្ហានេះនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ធនាគារជាតិនៃកម្ពុជា (NBC) បានអនុម័តលិខិតបទដ្ឋានគតិយុត្តិសម្រាប់ដោះស្រាយពាក្យបណ្តឹងអំពីគ្រឹះស្ថានហិរញ្ញវត្ថុ[366] នៅឆ្នាំ២០១៧ ហើយសមាគមធនាគារនៅកម្ពុជា (ABC) និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) បានអនុវត្តក្រមប្រតិបត្តិរបស់ពួកគេនៅឆ្នាំ២០២២។ ក្រមនេះចែងពីជម្រើសក្នុងការដោះស្រាយវិវាទ ដែលជម្រើសនីមួយៗមានជំហាន និងកម្រិតខុសៗគ្នា។ ដើមបណ្តឹងអាចទាក់ទងធនាគារ និងអ្នកផ្តល់ហិរញ្ញវត្ថុដោយផ្ទាល់ សម្រាប់ដំណោះស្រាយ ហើយប្រសិនបើមិនពេញចិត្តនឹងលទ្ធផលទេនោះ ដាក់ពាក្យបណ្តឹងស្នើសុំការសម្រុះសម្រួលនៅចំពោះមុខ ABC ឬ CMA។ ពួកគេក៏អាចទាក់ទង NBC ដោយផ្ទាល់ សម្រាប់ដំណោះស្រាយ ហើយប្រសិនបើមិនពេញចិត្តនឹងលទ្ធផលទេនោះ ដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច និង/ឬតុលាការដើម្បីដោះស្រាយ។[367] បទប្បញ្ញត្តិរបស់ NBC ក៏បានចែងអំពីលក្ខខណ្ឌតម្រូវ ជំហាន និងដំណើរការនៃយន្តការពាក្យបណ្តឹងទាំងនេះផងដែរ ដោយបានរួមបញ្ចូលរបាយការណ៍ប្រចាំត្រីមាសស្តីពីការគ្រប់គ្រងពាក្យបណ្តឹងដែលមានទិន្នន័យ និងព័ត៌មានជាក់លាក់នៅក្នុងយន្តការទាំងនេះ។[368] NBC ABC និង CMA បានអនុវត្ត

[363] Cerise+ SPTF Cerise+ SPTF ស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ឆ្នាំ២០២២ ស្តង់ដារ ៤.E.១.២ និង SPTF+Cerise មគ្គុទ្ទេសក៍ណែនាំអំពីការវាយតម្លៃ និងការអនុវត្តស្តង់ដារសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ស្តង់ដារ ៤.E https://bit.ly/4jAKC95។

[364] ក្រុមធនាគារពិភពលោក កំណត់សម្គាល់ផ្នែកបច្ចេកទេស៖ ការដោះស្រាយពាក្យបណ្តឹងនៅក្នុងគោលការណ៍ ការអនុវត្ត និងអភិក្រមនិយ័តកម្មរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ ទំ. ២-៥ https://bit.ly/3DscZre។

[365] ក្រុមធនាគារពិភពលោក កំណត់សម្គាល់ផ្នែកបច្ចេកទេស៖ ការដោះស្រាយពាក្យបណ្តឹងនៅក្នុងគោលការណ៍ ការអនុវត្ត និងអភិក្រមនិយ័តកម្មរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ ទំ. ៥ https://bit.ly/3DscZre។

[366] អនុក្រឹត្យ (ប្រកាស) ធ៧-០១៧-២៩៩ ស្តីពី "ដំណោះស្រាយពាក្យបណ្តឹងរបស់អតិថិជន" https://bit.ly/3FGuxAB។

[367] ក្រមសីលធម៌របស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ឆ្នាំ២០២២ ទំ.១១-១២ https://bit.ly/41ZQnX8។

[368] គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានតម្រូវឱ្យផ្តល់ជូន NBC នូវរបាយការណ៍ប្រចាំត្រីមាសស្តីពីការគ្រប់គ្រង និងការដោះស្រាយបណ្តឹង។ របាយការណ៍ប្រចាំត្រីមាសនេះ គួរតែរួមបញ្ចូលចំនួនពាក្យបណ្តឹងដែលបានទទួល ចំនួនពាក្យបណ្តឹងដែលបានដោះស្រាយក្នុងអំឡុងពេលរាយការណ៍ ផលិតផល និងសេវាកម្មដែលពាក្យបណ្តឹងពាក់ព័ន្ធ បញ្ហាជាប្រព័ន្ធ ពេលវេលាជាមធ្យម ដែលត្រូវដោះស្រាយពាក្យបណ្តឹង វិធានការកាត់បន្ថយចំនួនបណ្តឹងសំខាន់ៗជាញឹកញាប់បំផុត និងជាប្រព័ន្ធ និងពាក្យបណ្តឹងនៅក្នុងដំណើរការដោះស្រាយក្នុងអំឡុងពេលរាយការណ៍។ វាក៏តម្រូវឱ្យស្ថាប័នហិរញ្ញវត្ថុបង្ហាញជាសាធារណៈនូវឯកសារនីតិវិធីដោះស្រាយពាក្យបណ្តឹង ដែលត្រូវតែច្បាស់លាស់ និងងាយស្រួលយល់ជាភាសាខ្មែរ និងភាសាអង់គ្លេស នៅតាមទីតាំងលក់រាយ ដែលផលិតផល និងសេវាកម្មត្រូវបានផ្តល់ជូនផងដែរ។ អនុក្រឹត្យ (ប្រកាស) ធ៧-០១៧-២៩៩ ស្តីពី "ដំណោះស្រាយពាក្យបណ្តឹងរបស់អតិថិជន" មាត្រា ១០ និង ១២ https://bit.ly/3FGuxAB។

ប្រព័ន្ធទូរសព្ទទាន់ហេតុការណ៍របស់អតិថិជន បន្ថែមពីលើយន្តការពាក្យបណ្តឹងផ្ទៃក្នុងរបស់ធនាគារសមាជិក ឬ MFI នីមួយៗ។[369] ក្រៅពីការតម្រូវឲ្យការរក្សាការសម្ងាត់នៃព័ត៌មានពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់ទៀតនោះ បទប្បញ្ញត្តិរបស់រដ្ឋាភិបាលបច្ចុប្បន្ន និងបទប្បញ្ញត្តិដោយខ្លួនឯងនៃឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជា មិនលើកឡើងពីការបង្ការការគំរាមកំហែង និងការសងសឹកចំពោះអ្នកដាក់ពាក្យបណ្តឹងនោះទេ។[370]

ដោយសារការអនុវត្តដែលបានកំណត់ខាងលើ ភាពងាយរងគ្រោះរបស់អ្នកខ្ចី និងការត្រួតពិនិត្យមានកម្រិតនៅក្នុងវិស័យនេះ យន្តការបណ្តឹងសារទុក្ខ ដែលតាមរយៈអ្នកខ្ចីមីក្រូហិរញ្ញវត្ថុកម្ពុជា អាចរាយការណ៍ពីការផ្តល់ប្រាក់កម្ចីប្រកបដោយគ្រោះថ្នាក់ និងការអនុវត្តការដើបឡើងវិញ អាចជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូរកឃើញថា IFC មិនបានធ្វើការជាមួយអតិថិជនរបស់ខ្លួនដើម្បីតម្រឹមការវិនិយោគ និងការវិនិយោគបន្តរបស់ខ្លួនជាមួយលក្ខខណ្ឌតម្រូវ E&S សម្រាប់យន្តការបណ្តឹងសារទុក្ខខាងក្រៅ ស្របតាម PS1 ដូចបានសង្ខេបនៅខាងក្រោមនោះទេ។

*a) យន្តការបណ្តឹងសារទុក្ខមិនត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយពាក្យបណ្តឹងឲ្យបានគ្រប់គ្រាន់ ហើយជាញឹកញាប់ ត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់ដាក់សម្ពាធលើអ្នកខ្ចីបន្ថែមទៀត*

អតិថិជន និងអតិថិជនបន្តរបស់ IFC ទាំងប្រាំមួយ នៅក្នុងពាក្យបណ្តឹងនេះ អនុវត្តតាមគោលនយោបាយ និងនីតិវិធីគ្រប់គ្រងពាក្យបណ្តឹងមួយដែលអាចឱ្យអ្នកខ្ចីដាក់ពាក្យបណ្តឹងតាមរយៈគេហទំព័ររបស់ពួកគេ ឬដោយផ្ទាល់។ នីតិវិធីទាំងនេះ រួមមាន ការទទួលយក ការចុះបញ្ជី ការវាយតម្លៃ និងការឆ្លើយតបជាផ្លូវការ ទៅនឹងពាក្យបណ្តឹងពីសាធារណជន និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងមាននីតិវិធីបញ្ជូន។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង BFIs មួយចំនួន មិនបានប្រើប្រាស់ និងមិនមានធនធានសម្រាប់ដោះស្រាយពាក្យបណ្តឹងឲ្យបានគ្រប់គ្រាន់នោះទេ។ ដូចបានពិពណ៌នានៅក្នុងផ្នែក ៤.៥ កាន់តែលម្អិតបន្ថែមទៀត អតិថិជន និងអតិថិជនបន្តរបស់ IFC ភាគច្រើនមានការរាយការណ៍មិនស្របគ្នាអំពីចំនួនពាក្យបណ្តឹង ហើយក្នុងករណីមួយចំនួន បានរាយការណ៍ពីចំនួនពាក្យបណ្តឹងតិចតួចបំផុត ឬគ្មានពាក្យបណ្តឹង ទៅកាន់ IFC។[371] ដោយគិតពីចំនួនអតិថិជនដែលគ្រឹះស្ថានទាំងនេះផ្តល់សេវាជូន និងផលប៉ះពាល់សង្គមរយៈពេលវែង និងត្រូវបានរាយការណ៍យ៉ាងទូលំទូលាយនៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជា (សូមមើលផ្នែក ១.២) ពាក្យបណ្តឹងត្រូវបានរាយការណ៍នៅកម្រិតទាបខ្លាំង ដែលបង្ហាញថា យន្តការពាក្យបណ្តឹងរបស់ FIs ដែលពាក់ព័ន្ធ មានភាពមិនគ្រប់គ្រាន់ ក្នុងការផ្តល់សេវាតាមគោលបំណងរបស់ពួកគេនោះទេ និងអាចមានបញ្ហាប្រឈមក្នុងការរចនា និងលទ្ធភាពប្រើប្រាស់។ កិច្ចសម្ភាសរវាងស៊ីអេអូ ជាមួយអ្នកខ្ចី ឆ្លុះបញ្ចាំងពីគំហើញនៃការសិក្សាថ្នាក់ជាតិ ដែលថា អ្នកខ្ចីមីក្រូហិរញ្ញវត្ថុលើសពីមួយភាគបី មិនដឹងអំពីយន្តការពាក្យបណ្តឹងនោះទេ និងមិនបាន

---

[369] NBC បញ្ជីប្រព័ន្ធទូរសព្ទទាន់ហេតុការណ៍របស់ NBC ដើម្បីឆ្លើយតបនឹងសំណួរ និងពាក្យបណ្តឹងរបស់អតិថិជនស្តីពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ https://bit.ly/428AAFH; ABC ប្រព័ន្ធទូរសព្ទទាន់ហេតុការណ៍ https://bit.ly/4izxXn8 និង CMA ពាក្យបណ្តឹងតាមប្រព័ន្ធទូរសព្ទទាន់ហេតុការណ៍ https://bit.ly/3DW8fKv។

[370] ប្រកាស ធ៧-០១៧-២៩៩ ស្តីពី "ដំណោះស្រាយពាក្យបណ្តឹងរបស់អតិថិជន" https://bit.ly/3FGuxAB; ក្រមសីលធម៌របស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ https://bit.ly/41ZQnX8។

[371] ស៊ីអេអូមិនបានទទួលព័ត៌មានអំពីការអនុវត្តវិធានការវិន័យចំពោះបុគ្គលដែលធ្វើការឲ្យអតិថិជន ឬអតិថិជនបន្តរបស់ IFC ណាមួយនោះទេ។

ទទួលព័ត៌មានអំពីយន្តការនេះពីអ្នកផ្តល់ប្រាក់កម្ចី ដូចបានតម្រូវដោយស្តង់ដារ GIIP នោះទេ។[372] ក្នុងចំណោមអ្នកទទួលការសម្ភាសជាមួយស៊ីអេអូ ពាក្យបណ្តឹងត្រូវបានដាក់ជូនភាគច្រើន ក្នុងករណីដែលអ្នកខ្ចីមានជំនួយ និងការណែនាំពីអង្គការសង្គមស៊ីវិល។

អង្គការសិទ្ធិមនុស្សជាច្រើនក៏បានលើកឡើងពីកង្វល់អំពីឯករាជ្យភាព និងសុវត្ថិភាពនៃយន្តការពាក្យបណ្តឹងទាំងនេះ ទៅកាន់ស៊ីអេអូផងដែរ។ នៅខណៈពេលដែលបទប្បញ្ញត្តិ NBC បានចែងពីអភិក្រមពហុកម្រិតដែលអ្នកខ្ចីអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ទៅកាន់អ្នកផ្តល់សេវាហិរញ្ញវត្ថុ សមាគមឧស្សាហកម្មដែលពាក់ព័ន្ធ (ABC ឬ CMA) ឬ NBC នោះ ដើមបណ្តឹងបីនាក់បានរាយការណ៍ទៅកាន់ស៊ីអេអូថា ពាក្យបណ្តឹងដែល NBC ឬ ABC/CMA បានទទួល បែរជាត្រូវបានបញ្ជូនទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុដែលផ្តល់ប្រាក់កម្ចីនោះទៅវិញ។ នេះមានន័យថា ស្ថាប័នតែមួយ ដែលជាកម្មវត្ថុនៃពាក្យបណ្តឹង ក៏កាន់កាប់ពាក្យបណ្តឹងដែរ និងលើកឡើងនូវសំណួរថាតើ អ្នកខ្ចីអាចទទួលបានដំណោះស្រាយដោយឯករាជ្យបានដែរទេ។[373] កិច្ចសម្ភាសរវាងស៊ីអេអូ និងដើមបណ្តឹងក៏បានគូសបញ្ជាក់នូវករណីនានាដែលបានចោទប្រកាន់នៅក្នុងពាក្យបណ្តឹងនេះផងដែរ ដែលដាក់សម្ពាធបន្ថែម ធ្វើឲ្យមានការបំភិតបំភ័យ និងការចុះសួរសុខទុក្ខដោយមន្ត្រីឥណទានរបស់ BFIs ជាជាងការផ្តល់ជម្រើស ដើម្បីដោះស្រាយបញ្ហាបំណុលរបស់អ្នកខ្ចី។ ឧទាហរណ៍៖

- ដើមបណ្តឹងម្នាក់បានដាក់ពាក្យបណ្តឹងទៅកាន់ NBC ដោយស្នើសុំជំនួយដើម្បីលុបចោលការប្រាក់ និងការផាកពិន័យសម្រាប់ប្រាក់កម្ចីរបស់ពួកគេជាមួយអតិថិជនបន្តរបស់ IFC។ ដើមបណ្តឹងបានអះអាងថា មិនបានទទួលការឆ្លើយតបជាផ្លូវការពី NBC នោះទេ និងបានចែករំលែកឯកសារគាំទ្រអំពីការចុះសួរសុខទុក្ខដោយមន្ត្រីឥណទានរបស់នាង និងអ្នកគ្រប់គ្រងរបស់ពួកគេជាបន្តបន្ទាប់ ហើយនាងត្រូវបានលើកទឹកចិត្តឱ្យខ្ចីប្រាក់ក្រៅប្រព័ន្ធ លក់ទ្រព្យសកម្មដើម្បីសងបំណុល ឱ្យកូនឈប់រៀន និងទទួលខុសត្រូវសងបំណុល។
- ដើមបណ្តឹងម្នាក់ទៀតបានរាយការណ៍ថា បានទាក់ទង NBC ដើម្បីរាយការណ៍ពីការរងសម្ពាធពីបុគ្គលិកម្នាក់ ដែលមកពីអតិថិជនដទៃទៀត របស់ IFC។ នាងបានអះអាងថា NBC បានបញ្ជូនសំណុំរឿងនេះទៅកាន់ទីស្នាក់ការកណ្តាលរបស់អតិថិជន IFC ដែលបន្ទាប់មក ត្រូវបានបញ្ជូនបន្តទៅកាន់សាខាប្រចាំខេត្តរបស់ពួកគេ។ យោងតាមដើមបណ្តឹង សាខាបានតម្រូវឲ្យនាងផ្តិតមេដៃនៅលើឯកសារដែលទទួលស្គាល់ថា នាងបានដាក់ពាក្យប្តឹងទៅកាន់ NBC និងបានចោទសួរថាតើគ្រួសាររបស់នាងកំពុងជួបប្រទះនឹងបញ្ហាទាំងនោះមែនដែរឬទេ។

---

[372] របាយការណ៍ Bliss ទំ.៦៩។ នៅខែសីហា ឆ្នាំ២០២៥ BFI មួយ បានចែករំលែកការកែលម្អបន្ថែមចំពោះយន្តការពាក្យបណ្តឹងរបស់ពួកគេ ចាប់តាំងពីឆ្នាំ២០២៤ មក តាមរយៈការបង្ហាញវានៅតាមសាខា គេហទំព័ររបស់ពួកគេ និងការបញ្ចូលលេខទូរសព្ទទាន់ហេតុការណ៍សម្រាប់ដាក់ពាក្យបណ្តឹង នៅក្នុងសម្ភារៈធ្វើទីផ្សារ កិច្ចសន្យាប្រាក់កម្ចី កាលវិភាគសងប្រាក់កម្ចី និងវេទិកានៃប្រព័ន្ធផ្សព្វផ្សាយសង្គមទាំងអស់។

[373] WBG បានពន្យល់ថា GIIP ចង្អុលបង្ហាញថា អ្នកប្រើប្រាស់គួរតែទទួលបានយន្តការដោះស្រាយវិវាទជំនួស ដែលពួកគេអាចប្តឹងជំទាស់នឹងសេចក្តីសម្រេចចិត្តណាមួយ ដែលកើតចេញពីការដោះស្រាយពាក្យបណ្តឹងផ្ទៃក្នុងនៅទីតាំងរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ដែលក្នុងចំណោមលក្ខខណ្ឌផ្សេងទៀត យន្តការជំនួសនេះមានឯករាជ្យភាពពីភាគីទាំងពីរ អនុវត្តមុខងាររបស់ខ្លួនដោយឥតលម្អៀង និងមានអំណាចក្នុងការចេញសេចក្តីសម្រេចដែលចងកាតព្វកិច្ចលើអ្នកផ្តល់សេវាហិរញ្ញវត្ថុ។ WBG, ការអនុវត្តល្អៗចំពោះកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ, ឆ្នាំ២០១៧, ទំ. ៥១-៥២, https://bit.ly/41PWcWT។

- ដើមបណ្ដឹងទីបីបានប្រាប់ស៊ីអេអូថា បន្ទាប់ពីដាក់ពាក្យបណ្ដឹងទៅកាន់ NBC មន្ត្រីនៃអតិថិជនបន្តរបស់ IFC បានទៅលេងផ្ទះនាង និងសុំឱ្យនាងចុះហត្ថលេខាលើឯកសារមួយច្បាប់ទាក់ទងនឹងការទូទាត់ប្រាក់ឃើតយ៉ាវ។ នាងបានបញ្ជាក់ថា បុគ្គលិកសាខាបានបំភិតបំភ័យនាង និងស្វាមី និងគំរាមថា នឹងមានការចូលរួមពីអាជ្ញាធរឃុំ និងនគរបាល បន្ទាប់ពីនាងបាននិយាយអំពី ការទាក់ទងទៅកាន់ NBC។[374]

*b) ដំណើរការដោះស្រាយពាក្យបណ្ដឹងគឺជាវិធីកាត់បន្ថយភាពគួរឲ្យជឿជាក់របស់ដើមបណ្ដឹង*

ស៊ីអេអូបានទទួលរបាយការណ៍ និងបានកត់សម្គាល់ក្នុងអំឡុងពេលសម្ភាសជាមួយបុគ្គលិក BFI ថា អ្នកផ្ដល់ប្រាក់កម្ចីមួយចំនួនអាចប្រើដំណើរការដោះស្រាយពាក្យបណ្ដឹងតាមវិធី ដែលដើមបណ្ដឹង និងអង្គការសង្គមស៊ីវិលយល់ឃើញថាជា "ដំណើរការស្វែងរកការពិត" ដែលមានបំណងកាត់បន្ថយភាពគួរឲ្យជឿជាក់របស់ដើមបណ្ដឹង និងគ្រប់គ្រងហានិភ័យផ្នែកកេរ្តិ៍ឈ្មោះដែលអាចនឹងកើតឡើងចំពោះ FIs ជាជាងការផ្ដោតលើការដោះស្រាយបញ្ហាផ្ដល់ប្រាក់កម្ចីដែលបានលើកឡើង។ អភិក្រមនេះត្រូវបានកត់សម្គាល់ជាពិសេស ពាក់ព័ន្ធនឹងការចោទប្រកាន់ ឬពាក្យបណ្ដឹងធ្ងន់ធ្ងរជាងនេះ ដូចជា ពាក្យបណ្ដឹងដែលបានធ្វើឡើងនៅក្នុងពាក្យបណ្ដឹងរបស់ស៊ីអេអូ និងការរាយការណ៍ជាសាធារណៈអំពីការធ្វើអត្តឃាតដោយសារបំណុល។ ភ្លាមៗបន្ទាប់ពីពាក្យបណ្ដឹងរបស់ស៊ីអេអូត្រូវបានប្រកាសថាមានសិទ្ធិអនុវត្ត នៅឆ្នាំ២០២២ បុគ្គលិកមកពីអតិថិជន និងអតិថិជនបន្តរបស់ IFC ជាច្រើន បានចុះទៅកាន់សហគមន៍ ដើម្បីព្យាយាមកំណត់អត្តសញ្ញាណដើមបណ្ដឹង។ យោងតាមសមាជិកសហគមន៍ ការចុះទៅកាន់សហគមន៍ទាំងនេះបានបង្កើតភាពតានតឹង និងភាពភ័យខ្លាចនៅក្នុងសហគមន៍ និងបានរួមចំណែកដល់ជម្លោះនៅក្នុងសហគមន៍។

ហេតុការណ៍ទាំងនេះបានកើតឡើង នៅពេលក្រោយការរាយការណ៍អំពីការគំរាមកំហែង និងការសងសឹកយ៉ាងទូលំទូលាយ លើដើមបណ្ដឹង និងតំណាងអង្គការមិនមែនរដ្ឋាភិបាលរបស់ពួកគេ នៅកម្ពុជា ដែលបានលើកឡើងនូវកង្វល់ជាសាធារណៈអំពីការសងសឹកលើអ្នករិះគន់អំពីឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ។

*c) ការសងសឹកចំពោះអ្នករិះគន់អំពីការផ្ដល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា*

យោងតាមសេចក្ដីថ្លែងការណ៍ជាសាធារណៈ និងរបាយការណ៍ប្រព័ន្ធផ្សព្វផ្សាយ BFI មួយចំនួនបានចោទប្រកាន់អង្គការមិនមែនរដ្ឋាភិបាលពីបទបរិហារកេរ្តិ៍ និងការសម្របសម្រួលដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ឧស្សាហកម្ម។[375] តួអង្គទាំងនេះបានអំពាវនាវឱ្យអង្គការមិនមែនរដ្ឋាភិបាល "ធ្វើការកែតម្រូវជាបន្ទាន់" ចំពោះ

---

374 ជាដំបូង ដើមបណ្ដឹងបានស្នើសុំជួបជាមួយអ្នកគ្រប់គ្រងមន្ត្រីឥណទាន ហើយត្រូវបានស្នើសុំឱ្យមកកាន់ការិយាល័យអតិថិជនបន្តរបស់ IFC។ បន្ទាប់ពីរង់ចាំពេញមួយរសៀល មន្ត្រីដដែលដែលបានទារបំណុលរបស់នាង បានបង្ហាញខ្លួន និងបានបដិសេធសំណើរបស់នាង។ នៅពេលដែលនាងនិយាយអំពីការទាក់ទង NBC មន្ត្រីនោះបានទះតុ សួរអំពីមូលហេតុនៃការពាក់ព័ន្ធនឹង NBC និងបានគំរាមហៅនគរបាល និងអាជ្ញាធរមូលដ្ឋាន នៅពេលដែលនាងបដិសេធមិនផ្តិតមេដៃលើឯកសារ។ ទោះបីជាយ៉ាងណាក៏ដោយ នាងបានទាក់ទង NBC ហើយ NBC បានជូនដំណឹងថា ពួកគេនឹងរាយការណ៍ពីពាក្យបណ្ដឹងនោះទៅកាន់អតិថិជនបន្តរបស់ IFC។ ពីរបីថ្ងៃក្រោយមក ដើមបណ្ដឹងបាននិយាយថា មន្ត្រីឥណទានបានទុកសារជាសំឡេងនៃការស្ដីបន្ទោស ហើយបន្ទាប់មកបានចុះទៅកាន់ផ្ទះរបស់នាងម្ដងហើយម្ដងទៀត ដើម្បីទារបំណុល និងបានណែនាំឱ្យកូនៗរបស់នាងឈប់រៀន ដើម្បីជួយសងបំណុល។ ដើមបណ្ដឹងបានពិពណ៌នាអំពីស្ថានភាពធ្លាក់ទឹកចិត្ត និងការថប់បារម្ភ ដែលនាងបានជួបប្រទះបន្ទាប់ពីមានដំណើរការទាំងនេះ។

375 NGO មួយ ក្នុងចំណោម NGOs ទាំងនោះគឺ អង្គការលីកាដូ ដែលជាផ្នែកមួយនៃពាក្យបណ្ដឹងបច្ចុប្បន្ន។ សូមមើល៖ អ្នករិះគន់របាយការណ៍ MFI សំខាន់ៗ សូមមើលប្រព័ន្ធផ្សព្វផ្សាយ 'ការសម្របសម្រួល' សង្គមនិយម កង្វះខាតព័ត៌មានលម្អិត ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ នៅក្នុង VOD https://bit.ly/4iDGANt។

របាយការណ៍របស់ពួកគេ ជម្រុញឱ្យអាជ្ញាធររដ្ឋាភិបាលចាត់វិធានការប្រឆាំងនឹងបុគ្គល ឬក្រុមដែលត្រូវបានចោទប្រកាន់ថា កំពុងញុះញង់ឱ្យមានភាពចលាចល ឬធ្វើឱ្យបាត់បង់ទំនុកចិត្តលើប្រព័ន្ធធនាគារ និងបានព្រមានអំពីសកម្មភាពផ្លូវច្បាប់ដែលអាចកើតឡើងផងដែរ។[376] នៅឆ្នាំ២០២០ របាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយបានពិពណ៌នាអំពីជនដែលត្រូវបានប្ដឹងពីបទបរិហារកេរ្តិ៍ បន្ទាប់ពីបានរិះគន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងសកម្មជនដែលត្រូវបានចាប់ខ្លួនពីការធ្វើបាតុកម្មប្រឆាំងនឹង BFIs និងអំពាវនាវឱ្យផ្អាកការសងប្រាក់កម្ចី។ [377]

ហេតុការណ៍ទាំងនេះបានកើតឡើង ដោយមានហេតុការណ៍នៅពីក្រោយកាន់តែទូលំទូលាយ ដែលត្រូវបានចងក្រងឯកសារដោយស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ។ អ្នករាយការណ៍ពិសេសពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គណៈកម្មាធិការសិទ្ធិមនុស្សស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងក្រុមការងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជាសុទ្ធតែបានរាយការណ៍អំពីកង្វល់នៃការប្រើប្រាស់ការកាត់ទោសព្រហ្មទណ្ឌលើបទបរិហារកេរ្តិ៍ និងញុះញង់ ក្នុងគោលបំណងរឹតត្បិតសកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្ស អ្នកការពារបរិស្ថាន អ្នកសារព័ត៌មាន អ្នកប្រឆាំងនឹងនយោបាយ និងអ្នកដទៃទៀត ដែលត្រូវបានមើលឃើញថាជាអ្នកប្រឆាំងនឹងអាជ្ញាធរ។[378] ក្នុងបរិបទនេះ ស៊ីអេអូកត់សម្គាល់ថា ក្នុងអំឡុងពេលស៊ើបអង្កេត ដីកាចាប់ខ្លួនមួយត្រូវបានចេញជូននាយកប្រតិបត្តិនៃអង្គការសង្គមស៊ីវិលមួយ ដែលតំណាងឱ្យដើមបណ្ដឹង។[379]

ផ្អែកលើព័ត៌មានដែលបានត្រួតពិនិត្យ រួមទាំងការសង្កេតនៅទីវាលរបស់ស៊ីអេអូដោយផ្ទាល់ ស៊ីអេអូបានកំណត់ចន្លោះប្រហោងនៅក្នុងសមិទ្ធកម្មសង្គមនៃការវិនិយោគរបស់ IFC ចំពោះលក្ខខណ្ឌតម្រូវនៃ PS1 ក្នុងការ

[376] សេចក្ដីថ្លែងការណ៍រួមរបស់ ABC និង CMA ឆ្លើយតបទៅនឹងអត្ថបទ និងរបាយការណ៍ដែលមិនគួរឱ្យទុកចិត្ត ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ https://bit.ly/4mwIQIV។ ប្រទេសកម្ពុជា៖ ធនាគារអេស៊ីលីដាចោទប្រកាន់អង្គការសង្គមស៊ីវិលចំនួនបីពីបទបរិហារកេរ្តិ៍ នៅក្នុងសេចក្ដីថ្លែងការណ៍របស់ខ្លួន និងជម្រុញឱ្យរដ្ឋាភិបាលចាត់វិធានការ បន្ទាប់ពីមានរបាយការណ៍របស់អង្គការសង្គមស៊ីវិលស្ដីពីអសមត្ថភាពរបស់កម្មករក្នុងការសងបំណុល https://bit.ly/3FG7BRW; អ្នករិះគន់របាយការណ៍ MFI សំខាន់ៗ សូមមើលប្រព័ន្ធផ្សព្វផ្សាយ 'ការសម្របសម្រួល' សង្គមនិយម កង្វះខាតព័ត៌មានលម្អិត ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ នៅក្នុង VOD https://bit.ly/4iDGANt; ស្ថាប័នហិរញ្ញវត្ថុ និងសង្គមស៊ីវិលឈ្លោះប្រកែកគ្នាពីរបាយការណ៍បំណុល ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ នៅក្នុង VOA នៅទីនេះ៖ https://bit.ly/4c2QUwd និងធនាគារកម្ពុជាទាមទារឲ្យធ្វើ "សកម្មភាព" ប្រឆាំងនឹងអង្គការមិនមែនរដ្ឋាភិបាលដែលនិយាយថាកម្មករត្រូវការការបន្ធូរបន្ថយបំណុល ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០ នៅក្នុង RFA នៅទីនេះ៖ https://bit.ly/4iB3GEx។
[377] ក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុប្ដឹងពីបទបរិហារកេរ្តិ៍បន្ទាប់ពីអ្នកគ្រប់គ្រងសាខាអស់សង្ឃឹម ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០ VOD https://bit.ly/4bZKVrK; មនុស្សប្រាំមួយនាក់ត្រូវបានឃុំខ្លួនពីបទតវ៉ាប្រឆាំងនឹងការសងប្រាក់មីក្រូហិរញ្ញវត្ថុ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ ខេមបូចាព័ត៌មាន https://bit.ly/3RiFeeW និងអ្នកកាសែត សកម្មជនប្រឆាំង និងសហជីពដែលត្រូវបានកំណត់គោលដៅក្នុងអំឡុងពេលមានជំងឺរាតត្បាតនៅកម្ពុជា ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ Civicus https://bit.ly/440Fbft។
[378] អង្គការសហប្រជាជាតិ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ខែកក្កដា ឆ្នាំ២០២៣ ឯកសារអង្គការសហប្រជាជាតិ A/HRC/54/75 កថាខណ្ឌ ២៥ ៣០។ OHCHR តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ឯកសារអង្គការសហប្រជាជាតិ A/HRC/54/72 ទំ. ៣៤ ៤១; គណៈកម្មាធិការសិទ្ធិមនុស្ស ការបញ្ចប់ការសង្កេតលើរបាយការណ៍តាមកាលកំណត់ទី៣ របស់ប្រទេសកម្ពុជា ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ឯកសារអង្គការសហប្រជាជាតិ CCPR/C/KHM/CO/3 កថាខណ្ឌ ៣៤។ ប្រទេសកម្ពុជា៖ ការចងក្រងព័ត៌មាន ដែលរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សម្រាប់ការត្រួតពិនិត្យជាសកល ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកសារអង្គការសហប្រជាជាតិ A/HRC/WG.6/46/KHM/2 កថាខណ្ឌ ៣៥-៥៤។
[379] សេចក្ដីថ្លែងការណ៍របស់អង្គការសង្គមស៊ីវិល ទាមទារចំណាត់ការរបស់ធនាគារពិភពលោកលើការសងសឹកនៅកម្ពុជា ឆ្នាំ២០២៤ https://bit.ly/4iLONPO; មជ្ឈមណ្ឌលធនធានធុរកិច្ច និងសិទ្ធិមនុស្ស លោក អៀង វុទ្ធី អង្គការសមធម៌កម្ពុជា https://bit.ly/4hNUU4K។

បង្កើតយន្តការទំនាក់ទំនងដែលសមស្របនឹងវប្បធម៌ ងាយស្រួលប្រើប្រាស់ និងមិនមានការសងសឹកសម្រាប់គម្រោង និងអនុគម្រោង ស្របតាម GIIP។

## ៤.៣ ភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចនៃក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ទាក់ទងនឹងប្រជាជនដែលងាយរងគ្រោះ

ផ្នែកនេះវាយតម្លៃថាតើ IFC តាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួន បានបំពេញតាមកាតព្វកិច្ចនៃគោលនយោបាយនិរន្តរភាពរបស់ខ្លួន ក្នុងការធានាថា សកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ហិរញ្ញប្បទាន បំពេញតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម (PS) ដែរឬទេ។[380] ជាពិសេស ស៊ីអេអូវិភាគថាតើ IFC បំពេញតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់ហិរញ្ញប្បទានដល់តែសកម្មភាពវិនិយោគដែលរំពឹងថានឹងបំពេញតាមលក្ខខណ្ឌតម្រូវ PS "ក្នុងរយៈពេលសមស្របមួយ" ដែរឬទេ [381] ដោយមានបំណង "មិនបង្កគ្រោះថ្នាក់" ដល់ប្រជាជន និងធានាថា "សោហ៊ុយនៃការអភិវឌ្ឍសេដ្ឋកិច្ចមិនធ្លាក់លើជនក្រីក្រ ឬងាយរងគ្រោះដោយមិនសមាមាត្រ" មែនដែរឬទេ។[382]

ចំពោះការវិនិយោគនៅក្នុងក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុ ក្របខណ្ឌនិរន្តរភាពតម្រូវឱ្យ IFC ពិនិត្យមើល ត្រួតពិនិត្យ តម្រូវឱ្យមានការកាត់បន្ថយ និងពិនិត្យតាមដានហានិភ័យ និងផលប៉ះពាល់ E&S នៃការវិនិយោគមីក្រូហិរញ្ញវត្ថុ ដែលអាចរួមបញ្ចូលទាំងអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ជាអ្នករងផលប៉ះពាល់ផងដែរ។ គោលនយោបាយនិរន្តរភាពតម្រូវឱ្យ IFC ចាត់វិធានការទាំងនេះ ស្របតាមលក្ខណៈ និងព័ត៌មានអំពីហានិភ័យនៃការវិនិយោគមីក្រូហិរញ្ញវត្ថុ និងលក្ខខណ្ឌតម្រូវជាក់លាក់នៃ PS1 (ដែលតម្រូវឱ្យអតិថិជនអនុវត្ត GIIP និង PS7) និងបញ្ជីផាត់ចេញ (សូមមើលផ្នែក៣.៧)។[383]

### ៤.៣.១ ការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែក E&S របស់ IFC នៃការវិនិយោគរបស់ខ្លួន នៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា, North Haven Thai, Advans, MEF និង MIFA

ស្របតាមគោលនយោបាយនិរន្តរភាព ការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែក E&S (ESDD) របស់ IFC មុនពេលវិនិយោគសម្រាប់អ្នកផ្តល់ប្រាក់កម្ចីដែលជាមីក្រូហិរញ្ញវត្ថុ រួមទាំងអតិថិជន និងអតិថិជនបន្តនៅក្នុងសំណុំរឿងនេះ គួរតែដំណើរការដូចខាងក្រោម៖

1. ចាត់ថ្នាក់គម្រោង ដើម្បីឆ្លុះបញ្ចាំងពីទំហំនៃហានិភ័យ និងផលប៉ះពាល់ទាំងអស់ និងបញ្ជាក់លក្ខខណ្ឌតម្រូវ E&S របស់អតិថិជន

---

[380] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៧ និងសម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ៨។

[381] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ២២ និងសម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៣។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨ សម្រាប់បញ្ញត្តិសមមូលសម្រាប់អតិថិជន ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC។

[382] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៩ និងសម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ៨។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨ សម្រាប់លក្ខខណ្ឌតម្រូវសមមូល ដើម្បីបញ្ចៀសផលប៉ះពាល់ E&S និងអនុវត្តគម្រោងប្រកបដោយនិរន្តរភាព។

[383] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ១៩ ២០-២២ ៣២ ៣៣ និង ៣៥ និង PS1 កថាខណ្ឌ ៥ ៧ និង ១២។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៣-១៧ ២៦ និង ២៧-២៩; PS1 ឆ្នាំ២០០៦ ៣ ៤ ៨ និង ១២។

2. ត្រួតពិនិត្យសមត្ថភាពរបស់អតិថិជន FI ក្នុងការគ្រប់គ្រងហានិភ័យ E&S នៃមីក្រូហិរញ្ញវត្ថុ ស្របតាម GIIP រួមទាំងហានិភ័យសង្គមនៃការបង្កគ្រោះថ្នាក់ចំពោះអ្នកខ្ចីផងដែរ
3. ពិចារណាលើហានិភ័យ E&S ដែលមានស្រាប់ សម្រាប់វិស័យជាក់លាក់មួយ ព្រមទាំងបរិបទនៃទីតាំងរបស់សកម្មភាពអាជីវកម្មនោះផងដែរ និង
4. ត្រួតពិនិត្យ ESMS របស់អតិថិជន FI និងសមត្ថភាពរបស់វា ក្នុងការកំណត់ ទប់ស្កាត់ ឬកាត់បន្ថយហានិភ័យសង្គមចំពោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ។

ដំណើរការនេះគួរតែអនុវត្តតាម GIIP សម្រាប់ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ តាមរយៈការវាយតម្លៃគោលនយោបាយ និងការអនុវត្តរបស់ FI ដើម្បីធានាថា ពួកគេទប់ស្កាត់ និងកាត់បន្ថយហានិភ័យ និងផលប៉ះពាល់សង្គម ដែលអាចកើតឡើងចំពោះប្រជាជនដែលងាយរងគ្រោះ បញ្ចៀស និងកាត់បន្ថយលទ្ធភាពនៃការបាត់បង់ដីធ្លី ការថយចុះនៃមុខរបរចិញ្ចឹមជីវិត ផលប៉ះពាល់លើដីធ្លី និងវប្បធម៌របស់ជនជាតិដើមភាគតិច ផ្តល់យន្តការបណ្តឹងសារទុក្ខ និងដោះស្រាយ និងបង្កើតផែនការសកម្មភាពសម្រាប់ចន្លោះប្រហោងណាមួយដែលត្រូវបានកំណត់ (គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣១-៣៤ ៤០ និង ៤២)។[384]

លើសពីនេះទៀត IFC គួរតែតម្រូវឱ្យអតិថិជន FI បង្កើត និងអនុវត្ត ESMS ដែលកំណត់ និងវាយតម្លៃហានិភ័យ និងផលប៉ះពាល់ E&S របស់គម្រោងដែលពាក់ព័ន្ធទាំងអស់ ហើយគ្រប់គ្រងវាដោយវិធានការទប់ស្កាត់ និងកាត់បន្ថយ ស្របតាម PS1 PS7 បញ្ជីផាត់ចេញរបស់ IFC GIIP និងលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិ ទាក់ទងនឹងអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ និងស្របតាមលក្ខណៈ និងទំហំនៃហានិភ័យ និងផលប៉ះពាល់នៃគម្រោង (គោលនយោបាយនិរន្តរភាពឆ្នាំ២០១២ កថាខណ្ឌ ៣៣ និង ៣៥ និង PS1 កថាខណ្ឌ ៥ ៦ ៧ និង ១២)។[385]

### *៤.៣.១.១ ការបែងចែកប្រភេទ៖ ការវិនិយោគដែលត្រូវបានចាត់ទុកថាមានហានិភ័យទាប ឬមធ្យម ដោយមិនពិចារណាលើភាពងាយរងគ្រោះរបស់អ្នកខ្ចីគោលដៅ*

គោលនយោបាយនិរន្តរភាពកំណត់ថា IFC ត្រូវអនុវត្តការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែក E&S (ESDD) មុនពេលវិនិយោគ ស្របតាមលក្ខណៈ វិសាលភាព និងភាពជាក់លាក់នៃគម្រោង[386] ដោយពិចារណាលើហានិភ័យដែលបានដឹងនៃសកម្មភាពអាជីវកម្មរបស់ FI និងការបែងចែកប្រភេទគម្រោង ដើម្បីឆ្លុះបញ្ចាំងពីទំហំនៃហានិភ័យ និងផលប៉ះពាល់នៃគម្រោង។[387] ទោះបីជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់

[384] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣១-៣៤ ៤០ និង ៤២។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៨ ២៧-២៩។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨ សម្រាប់លក្ខខណ្ឌតម្រូវក្នុងការវាយតម្លៃផលប៉ះពាល់សង្គមដែលអាចកើតឡើង និងសមត្ថភាព E&S របស់ FI ក្នុងបំពេញតាមលក្ខខណ្ឌតម្រូវ E&S។

[385] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៣ និង ៣៥ និង PS1 កថាខណ្ឌ ៥ ៦ ៧ និង ១២។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨ និង ២៩ PS1 ឆ្នាំ២០០៦ ៣ ៤ និង ១២។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

[386] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ១៩ ២១ ៣២ និង ៣៣។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៣ ២៧-២៩។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨ ។

[387] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៤ និង ៤០។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៨។ សម្រាប់ការវិនិយោគនៅ Advans សូមមើល ESRP ឆ្នាំ១៩៩៨ ទំព័រ ១០ និង ឧបសម្ព័ន្ធ ច។

IFC នៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA មិនបានកំណត់ភាពងាយរងគ្រោះរបស់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុថាជាហានិភ័យ និងមិនបានកំណត់លក្ខខណ្ឌតម្រូវសមស្រប ដើម្បីគ្រប់គ្រងហានិភ័យទាំងនោះទេ។

IFC បានចាត់ថ្នាក់ការវិនិយោគដោយផ្ទាល់ចំនួនប្រាំមួយក្នុងចំណោមការវិនិយោគដោយផ្ទាល់ចំនួនប្រាំបួនរបស់ខ្លួននៅគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជា ជា FI-2 និង បីទៀត ជា FI-3។[388] សកម្មភាពអាជីវកម្ម F1-2 មានហានិភ័យ ឬផលប៉ះពាល់អវិជ្ជមាន E&S ដែលអាចកើតឡើង តិចតួច ជាទូទៅ មានទីតាំងជាក់លាក់ ភាគច្រើនអាចកែប្រែវិញបាន និងត្រូវបានដោះស្រាយយ៉ាងងាយស្រួលតាមរយៈវិធានការកាត់បន្ថយ នៅខណៈពេលដែលសកម្មភាពអាជីវកម្ម F1-3 "ភាគច្រើនមានផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន ឬសង្គម តិចតួច ឬគ្មានផលប៉ះពាល់"។ ដូចគ្នានេះដែរ IFC បានចាត់ថ្នាក់ការវិនិយោគរបស់ខ្លួននៅ North Haven Thai ដែលជាមូលនិធិភាគហ៊ុនឯកជនដែលក្រោយមកបានវិនិយោគនៅក្នុងអេស៊ីលីដាជា FI-2 នៅខណៈពេលដែលការវិនិយោគរបស់ខ្លួននៅក្នុងមូលនិធិ MEF និង MIFA និងក្រុមហ៊ុនកាន់កាប់ Advans ទាំងអស់ត្រូវបានចាត់ថ្នាក់ជា FI[389] នៅក្រោមក្របខណ្ឌនិរន្តរភាពចាស់ ដែលមិនរួមបញ្ចូលប្រភេទរងនោះទេ។[390] ការវិនិយោគទាំង ១៣ ត្រូវបានចាត់ទុកថាមានហានិភ័យទាប ឬមធ្យម ដែលតាមការយល់ឃើញរបស់ IFC វាមានហានិភ័យ E&S អវិជ្ជមាន និងផលប៉ះពាល់ដែលអាចកើតឡើង តិចតួច។[391]

ចំពោះប្រាក់កម្ចីផ្ទាល់ចំនួន ៣ ដែលត្រូវបានចាត់ថ្នាក់ជា FI-3 IFC បានចាត់ថ្នាក់ថាមិនមានលទ្ធភាព ឬមានលទ្ធភាពទាប ដែលអនុគម្រោងនឹងប្រឈមនឹងហានិភ័យ E&S សំខាន់ៗ រួមទាំងទាក់ទងនឹងជនជាតិដើមភាគតិចផងដែរ។[392] ចំពោះការវិនិយោគដោយផ្ទាល់ចំនួន ៦ ដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យមធ្យម IFC បានពិចារណាថាស្ថាប័នហិរញ្ញវត្ថុទាំងនេះបានចូលរួមក្នុងសកម្មភាពផ្តល់ប្រាក់កម្ចីដែលមានហានិភ័យកម្រិតទាបទៅមធ្យម ដោយឈរលើមូលដ្ឋាននៃអនុគម្រោងដែលមានស្រាប់ និងទំនងជាមានរបស់ពួកគេ។

---

[388] ត្រូវបានចាត់ថ្នាក់ជា FI-2៖ គម្រោងអេស៊ីលីដា លេខ ៤៤៨៨២ និង ៤២៤៨០ អម្រឹត គម្រោងលេខ ៣៤៧៤៨ និង ៤១២៩៤ និងធនាគារហត្ថា គម្រោងលេខ ៤៥៥៣៥ និង ៤៤៧៤២។ ត្រូវបានចាត់ថ្នាក់ជា FI-3៖ អម្រឹត គម្រោងលេខ ៤៤២៣១ និងធនាគារហត្ថា គម្រោងលេខ ៣៩១៦៧ និង ៤៤២១១។ គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៤០។

[389] North Haven Thai គម្រោងលេខ ៣៨៦០៩ និង MEF គម្រោងលេខ ២៧៨២៧ MIFA គម្រោងលេខ ៣១៤៦៧ និង Advans S.A. គម្រោងលេខ ២១៨៥៦។ ការវិនិយោគនៅ MIFA ហាក់បីដូចជាត្រូវបានចាត់ថ្នាក់ខុស ថាជា FI តែប៉ុណ្ណោះ ទោះបីជាវាត្រូវបានអនុម័តនៅឆ្នាំ២០១២ បន្ទាប់ពីគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ បានចូលជាធរមានហើយក៏ដោយ។

[390] ស្របតាមគោលនយោបាយនិរន្តរភាព ឆ្នាំ ២០០៦ "រាល់គម្រោង FI ដែលមិនរួមបញ្ចូលគម្រោងប្រភេទ C (សូមមើលកថាខណ្ឌ ២៧ ដល់ ២៩ ខាងក្រោម)" ត្រូវបានចាត់ថ្នាក់ជា FI។ ដូចគ្នានេះដែរ ក្របខណ្ឌនិរន្តរភាព ឆ្នាំ១៩៩៨ មានតែប្រភេទ FI សម្រាប់ការវិនិយោគលើអន្តរការីហិរញ្ញវត្ថុប៉ុណ្ណោះ ដែលត្រូវបានកំណត់ថា "គម្រោងដែលបានស្នើឡើងត្រូវបានចាត់ថ្នាក់ជា ប្រភេទ FI ប្រសិនបើវាពាក់ព័ន្ធនឹងការវិនិយោគមូលនិធិ IFC តាមរយៈអន្តរការីហិរញ្ញវត្ថុ នៅក្នុងអនុគម្រោងដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន។ សមធម៌នៅក្នុងស្ថាប័នហិរញ្ញវត្ថុ ដូចជាធនាគារពាណិជ្ជ) ប៉ុន្តែស្ថាប័នហិរញ្ញវត្ថុមានប្រតិបត្តិការដែលអាចមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន (ឧ. ហិរញ្ញប្បទានគម្រោង)។ ក្នុងករណីនេះ IFC ក៏អាចចាត់ថ្នាក់គម្រោងជាប្រភេទ FI បានដែរ"។

[391] សូមមើល សេចក្តីសង្ខេប E&S និងការបង្ហាញព័ត៌មាន សម្រាប់គម្រោងអេស៊ីលីដា លេខ ៤២៤៨០៖ https://bit.ly/4hMGUIz; គម្រោងលេខ ៤៤៨៨២ https://bit.ly/4j1vEJj; អម្រឹត គម្រោងលេខ ៤១២៩៤ https://bit.ly/3QNFd2E គម្រោងលេខ ៤៤២៣១ https://bit.ly/42fxkt3; ធនាគារហត្ថា គម្រោងលេខ ៣៩១៦៧ https://bit.ly/3FDYn8B លេខ ៤៤២១១ https://bit.ly/3Xz7PjY លេខ ៤៤៧៤២ https://bit.ly/4c3Tlyt លេខ ៤៥៥៣៥ https://bit.ly/4j0IqHU; MEF គម្រោងលេខ ២៧៨២៧ https://bit.ly/3FHjOG4; MIFA គម្រោងលេខ ៣១៤៦៧ https://bit.ly/3DJCC6P; Advans គម្រោងលេខ ២១៨៥៦ https://bit.ly/4hB៩v3o និង North Haven Thai គម្រោងលេខ ៣៨៦០៩ https://bit.ly/43rK6pI។

[392] អម្រឹត គម្រោងលេខ ៤៤២៣១ និងធនាគារហត្ថា គម្រោងលេខ ៣៩១៦៧ និង ៤៤២១១។

អនុគម្រោងទាំងនេះភាគច្រើនជាកម្ចី SME ឬ MSME ប៉ុន្តែក្នុងករណីមួយចំនួន ក៏រួមបញ្ចូលការផ្តល់ប្រាក់កម្ចីសាជីវកម្មខ្នាតធំដែលមានស្រាប់ ឬនឹងកើតឡើងនាពេលអនាគត និងហិរញ្ញប្បទានគម្រោងនៅក្នុងវិស័យនានា ដូចជា កសិពាណិជ្ជកម្ម ការលក់ដុំ ការធ្វើជំនួញលក់រាយ សេវាកម្ម និងការសាងសង់ខ្នាតតូច។ IFC បានចាត់ទុកថា ការវិនិយោគទាំងនេះមានហានិភ័យ E&S ជារួម កម្រិតស្រាល ឬមធ្យម ដែលជាទូទៅអាចត្រូវបានដោះស្រាយតាមរយៈវិធានការកាត់បន្ថយជាស្តង់ដារ។[393] ពុំមានការពិចារណាលើហានិភ័យ និងការចាត់ថ្នាក់ទាំងនេះ ដែលគិតគូរពីហានិភ័យដែលអាចកើតឡើងចំពោះអ្នកខ្ចីគោលដៅសម្រាប់ការផ្តល់ប្រាក់កម្ចី MSME នោះទេ។

ទាក់ទងនឹងការវិនិយោគភាគហ៊ុន IFC បានចាត់ថ្នាក់ North Haven Thai ជាមូលនិធិភាគហ៊ុនឯកជន[394] ថាមានហានិភ័យកម្រិតមធ្យម ដោយផ្អែកលើមូលដ្ឋានថា អតិថិជនទំនងជាមិនវិនិយោគនៅក្នុងក្រុមហ៊ុនដែលប្រឈមនឹងហានិភ័យ E&S កម្រិតមធ្យម-ខ្ពស់នោះទេ ពីព្រោះមូលនិធិផ្តោតជាចម្បងលើវិស័យដែលមានហានិភ័យ E&S កម្រិតមធ្យម និងកម្រិតមធ្យម-ទាប ដូចជា ទំនិញប្រើប្រាស់ សម្ភារៈសំណង់ ការកែច្នៃចំណីអាហារ ប្រព័ន្ធផ្សព្វផ្សាយ និងសេវាថែទាំសុខភាព ជាដើម។[395] ផ្ទុយពី North Haven Thai អម្រឹត Advans MEF និង MIFA សុទ្ធតែជាការវិនិយោគលើភាគហ៊ុនដែលផ្តោតជាពិសេសលើមីក្រូហិរញ្ញវត្ថុ។ ការវិនិយោគរបស់ IFC នៅ Advans ដែលជាក្រុមហ៊ុនឯកជន សម្រាប់បង្កើត MFIs មានវ័យចំណាស់ជាងគេបំផុត ដែលត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះ (ត្រូវបានអនុម័តនៅឆ្នាំ២០០៤) ហើយ ESDD ត្រូវបានអនុវត្តនៅក្រោមគោលនយោបាយការពារ របស់ IFC ឆ្នាំ១៩៩៨ ដែលបានចាត់ថ្នាក់គម្រោងនេះជាFI ប្រភេទទី ១ (ការវិនិយោគ FI មានហានិភ័យទាប ស្របតាមគោលនយោបាយនោះ)។ ការវិនិយោគនៅ Advans និង MFI ជាបន្តបន្ទាប់ ត្រូវបានតម្រូវឱ្យអនុលោមតាមនីតិវិធីត្រួតពិនិត្យ E&S (ESRP) របស់ IFC រួមទាំងបង្កើតប្រព័ន្ធរាយការណ៍ពីបរិស្ថាន ដែល IFC អាចទទួលយកបាន។[396] អម្រឹតគឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅពេលដែល

---

[393] ក្នុងករណីភាគច្រើន IFC បានបង្ហាញថា "គម្រោងនេះនឹងមិនគាំទ្រសកម្មភាពអាជីវកម្មដែលមានហានិភ័យខ្ពស់ដែលអាចរួមមាន ក) ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ខ) ហានិភ័យនៃផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច គ) ហានិភ័យ ឬផលប៉ះពាល់សំខាន់ៗ លើបរិស្ថាន សុខភាព និងសុវត្ថិភាពសហគមន៍ ជីវចម្រុះ បេតិកភណ្ឌវប្បធម៌ ឬ ឃ) ហានិភ័យផ្នែកសុវត្ថិភាព និងសុខភាពការងារសំខាន់ៗ"។ សូមមើល សេចក្តីសង្ខេប E&S និងការបង្ហាញព័ត៌មាន សម្រាប់គម្រោងអេស៊ីលីដា លេខ ៤២៤៨០៖ https://bit.ly/4hMGUIz; គម្រោងលេខ ៤៤៨៨២ https://bit.ly/4j1vEJj; អម្រឹត គម្រោងលេខ ៤១២៩៤ https://bit.ly/3QNFd2E និង ៣៤៧៤៨ https://bit.ly/4mLtQH0; ធនាគារហត្ថលេខា គម្រោងលេខ ៤៤៧៤២ https://bit.ly/4c3Tlyt ៤៥៥៣៥ https://bit.ly/4j0IqHU។

[394] មូលនិធិនេះមានក្រុម E&S នៅពេលអនុវត្ត ESDD ប៉ុន្តែមិនមាន ESMS ហើយលក្ខខណ្ឌតម្រូវមួយ ក្នុងចំណោមលក្ខខណ្ឌតម្រូវ E&S គឺការបង្កើត ESMS ដ៏ទូលំទូលាយ ដោយផ្អែកលើការអនុវត្តការគ្រប់គ្រងហានិភ័យ E&S អន្តរជាតិដ៏ល្អ។ IFC ក៏បានរកឃើញថាអ្នកគ្រប់គ្រងមូលនិធិមានបទពិសោធន៍ក្នុងការប្រើប្រាស់ក្រុមហ៊ុនប្រឹក្សា E&S ខាងក្រៅដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងដំណើរការឧស្សាហ៍ព្យាយាមរបស់ខ្លួន។ គម្រោង North Haven Thai គម្រោងលេខ ៣៨៦០៩ https://bit.ly/43rK6pI។

[395] North Haven Thai គម្រោងលេខ ៣៨៦០៩ https://bit.ly/43rK6pI។

[396] ESRP ឆ្នាំ១៩៩៨ ដែលអាចអនុវត្តបានចំពោះការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ Advans បង្ហាញថា "៥. ប្រភេទ FI អនុញ្ញាតឱ្យមានភាពបត់បែនក្នុងការកែសម្រួលតម្រូវការបរិស្ថាន និងសង្គមទៅនឹងគម្រោង និងអនុគម្រោងដែលបានរំពឹងទុក។ លក្ខខណ្ឌតម្រូវសម្រាប់ស្ថានភាពផ្សេងៗត្រូវបានដាក់ជាក្រុមតាមប្រភេទ ឬប្រភេទដូចតទៅ។ ក. លក្ខខណ្ឌតម្រូវប្រភេទទី១។ នៅពេលមូលនិធិ IFC

IFC បានទិញភាគហ៊ុន នៅឆ្នាំ ២០១៤[397] ហើយជាថ្មីម្តងទៀត ESDD របស់ IFC បានត្រួតពិនិត្យហានិភ័យ និងផលប៉ះពាល់តែពីសកម្មភាពរបស់អ្នកខ្ចីបន្តដែលអាចកើតឡើងប៉ុណ្ណោះ និងមិនត្រួតពិនិត្យហានិភ័យដែលអាចកើតឡើងចំពោះអ្នកខ្ចីបន្ត ដែលជាគោលដៅនៃការវិនិយោគនោះទេ។[398] ក្នុងករណី MEF និង MIFA IFC បានចាត់ទុកជាការវិនិយោគដែលមានហានិភ័យទាប ដោយផ្អែកលើសកម្មភាពប្រកបដោយសក្តានុពលរបស់អ្នកខ្ចីបន្ត និងបទពិសោធន៍ដែលអ្នកគ្រប់គ្រងមូលនិធិមានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ IFC បានបង្ហាញថា មូលនិធិទាំងនេះនឹងផ្អែកលើប្រតិបត្តិការរបស់ពួកគេលើការអនុវត្តល្អបំផុតសម្រាប់មីក្រូហិរញ្ញវត្ថុពាណិជ្ជកម្ម ដោយមិនចាំបាច់បញ្ជាក់លម្អិតបន្ថែមទៀតទេ។

ការពិចារណារបស់ IFC លើគម្រោងទាំងនេះថាជាហានិភ័យទាប និងមធ្យម មានន័យថាការត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគរបស់ខ្លួនជាញឹកញាប់ នៅមានកម្រិត។ ក្នុងចំណោមគម្រោងទាំងអស់ មាន ESDDs តែ ៣ ប៉ុណ្ណោះ សម្រាប់ការវិនិយោគទាំង ១៣ ដែលមានការត្រួតពិនិត្យឯកសារយោងនៃចម្លើយរបស់អតិថិជនចំពោះកម្រងសំណួរ E&S ដោយមិនមានការចុះត្រួតពិនិត្យទីតាំង ឬការវិភាគយ៉ាងទូលំទូលាយអំពីគោលនយោបាយ និងនីតិវិធីរបស់អតិថិជននោះទេ។[399] សម្រាប់ធនាគារហត្ថា (គម្រោងលេខ ៤៤២១១) និងអម្រឹត (គម្រោងលេខ ៤៤២៣១ និង ៤១២៩៤) ESDD ត្រូវបានដាក់កម្រិតចំពោះការត្រួតពិនិត្យឯកសាររបស់ IFC ដែលតម្កល់ទុកសម្រាប់អតិថិជនដែលមានស្រាប់ទាំងនេះ ជាពិសេសរបាយការណ៍ E&S ឆ្នាំមុនៗ។ ការវាយតម្លៃកាន់តែហ្មត់ចត់ ត្រូវបានធ្វើឡើងតាមរយៈកម្មវិធីអេស៊ីលីដាចំនួនពីរ នៅឆ្នាំ ២០១៩ (រួមបញ្ចូលការវាយតម្លៃទីតាំង) និង ឆ្នាំ២០២១ (បេសកកម្មអនឡាញ) និងសម្រាប់ការវិនិយោគភាគហ៊ុននៅអម្រឹត ក្នុងឆ្នាំ២០១៤ ដែលរួមបញ្ចូលការវាយតម្លៃទីតាំង និងការត្រួតពិនិត្យយ៉ាងទូលំទូលាយលើផលបត្រប្រាក់កម្ចីរបស់អម្រឹត និងដំណើរការសរសេរធានា។ ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែនៅក្នុងករណីនៃការត្រួតពិនិត្យឱ្យកាន់តែ

---

មិនបានកំណត់គោលដៅចំពោះអនុគម្រោងជាក់លាក់ ប៉ុន្តែគ្រឹះស្ថានហិរញ្ញវត្ថុបានធ្វើប្រតិបត្តិការ ដែលអាចមានផលប៉ះពាល់បរិស្ថាន និង/ឬសង្គមអវិជ្ជមាន IFC ផ្តោតលើដំណើរការនៃការគ្រប់គ្រងបរិស្ថាន និងសង្គមនៅក្នុងគ្រឹះស្ថាន ច្រើនជាងលើអនុគម្រោងជាក់លាក់។ លក្ខខណ្ឌតម្រូវ ប្រភេទ១ ក៏អនុវត្តនៅក្នុងស្ថានភាព ដែលស្ថាប័នហិរញ្ញវត្ថុមិនអាចអនុវត្ត ឬមិនមានសមិទ្ធលទ្ធភាពក្នុងការកំណត់លក្ខខណ្ឌតម្រូវលើអនុគម្រោង ក្រៅពីច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសម្ចាស់ផ្ទះ ឧ. មីក្រូហិរញ្ញវត្ថុ ហិរញ្ញវត្ថុពាណិជ្ជកម្ម។ លក្ខខណ្ឌតម្រូវដូចតទៅ អនុវត្តៈ FI ត្រូវតែបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (គោលនយោបាយ នីតិវិធី ធនធាន) សម្រាប់ប្រតិបត្តិការពាក់ព័ន្ធ (ឧទាហរណ៍ ហិរញ្ញវត្ថុគម្រោង កម្ចីសាជីវកម្ម ឬប្រតិបត្តិការជួលក្នុងធនាគារពាណិជ្ជ) ហើយតម្រូវឱ្យសកម្មភាពដែលធ្វើឡើងក្រោមប្រតិបត្តិការទាំងនោះអនុលោមតាមតម្រូវការបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ប្រទេសម្ចាស់ផ្ទះ។ ii. FI ត្រូវតែតែងតាំងមន្ត្រីជាន់ខ្ពស់ដែលមានទំនួលខុសត្រូវរួមសម្រាប់បញ្ហាបរិស្ថាន និងសង្គម ហើយកំណត់អត្តសញ្ញាណបុគ្គលដែលនឹងគ្រប់គ្រង និង/ឬធ្វើការត្រួតពិនិត្យ។ អ្នកទាំងពីរត្រូវចូលរួមវគ្គបណ្តុះបណ្តាលដែលឧបត្ថម្ភ ឬយល់ព្រមពី IFC ក្នុងការគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់ស្ថាប័នហិរញ្ញវត្ថុ។ iii. FI ត្រូវតែបញ្ជូនរបាយការណ៍លទ្ធផលការងារបរិស្ថានប្រចាំឆ្នាំ ដែលផ្តោតលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមរបស់ខ្លួន។ iv. គម្រោងមីក្រូហិរញ្ញវត្ថុ ដែលជាធម្មតាត្រូវបានចាត់ថ្នាក់ជាប្រភេទ I តម្រូវឱ្យអនុលោមតាមតម្រូវការបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ប្រទេសម្ចាស់ផ្ទះ ហើយត្រូវតែគោរពតាមលក្ខខណ្ឌតម្រូវក្នុងតារាងទី ៤ បញ្ជីផាត់ចេញនៃមីក្រូហិរញ្ញវត្ថុ។

[397] IFC ក៏មានការប្រឈមផ្នែកហិរញ្ញវត្ថុដោយប្រយោល តាមរយៈ Advans ចាប់តាំងពី២០០៥ មកផងដែរ។

[398] អម្រឹត គម្រោងលេខ #៣៤៧៤៨ សេចក្តីសង្ខេបអំពី E&S និងការបង្ហាញព័ត៌មាន https://bit.ly/3XyuZXz. អម្រឹត ការគ្រប់គ្រងការអនុវត្តការងារសង្គម https://bit.ly/4k449PI។

[399] ក្នុងករណីមូលនិធិ MEF MIFA និង North Haven Thai, ESDD បានត្រួតពិនិត្យសមត្ថភាព E&S និងការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងមូលនិធិដែលមានសក្តានុពល ដោយសារមូលនិធិកំពុងត្រូវបានបង្កើតឡើង ហើយនៅពេលត្រួតពិនិត្យភាពត្រឹមត្រូវ មូលនិធិទាំងនេះមិនមានគោលនយោបាយដែលមានស្រាប់នោះទេ។ ក្នុងករណី Advans មានកំណត់ត្រាតិចតួចនៃ ESDD ដែលបានធ្វើឡើងក្នុងឆ្នាំ២០០៤ ប៉ុន្តែវាជាការត្រួតពិនិត្យឯកសារយោងដែលមានកម្រិតខ្លាំងណាស់ ដែលរួមបញ្ចូលការត្រួតពិនិត្យមួយចំនួនលើសមត្ថភាព MFI របស់អ្នកឧបត្ថម្ភ និងអនាគតអ្នកគ្រប់គ្រងមូលនិធិផងដែរ ប៉ុន្តែមិនមែនសមត្ថភាព ESDD របស់វាទេ។

ហ្មត់ចត់ ដែលរួមបញ្ចូលគោលនយោបាយ និងការអនុវត្តការផ្តល់ប្រាក់កម្ចីរបស់អតិថិជនក៏ដោយ ក៏ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC មិនបានលាតសន្ធឹងដល់ការកំណត់អត្តសញ្ញាណ ការពិភាក្សា ឬការត្រួតពិនិត្យផលប៉ះពាល់លើប្រជាជនដែលងាយរងគ្រោះ និងរបៀបដែលពួកគេអាចរងផលប៉ះពាល់ដោយគម្រោងទាំងនេះទេ។

ស៊ីអេអូទទួលស្គាល់គោលជំហររបស់ IFC ដែលគិតថាអ្នកខ្ចីមីក្រូហិរញ្ញវត្ថុមិនត្រូវបានគ្របដណ្តប់ដោយលក្ខខណ្ឌតម្រូវ E&S របស់ខ្លួននោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការវិនិយោគទាំងនេះត្រូវបានរចនាឡើងដើម្បីផ្តល់សេវាដល់ជនក្រីក្រ ឬក្រីក្រខ្លាំង និងក្រុមដែលមិនទទួលបានសេវា និងទទួលបានសេវាមិនគ្រប់គ្រាន់ ដែលស្របតាម PS1 គឺជាប្រជាជនងាយរងគ្រោះ។[400] PS1 បង្ហាញថា ស្ថានភាពងាយរងគ្រោះអាចកើតចេញពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា នយោបាយ ឬទស្សនៈដទៃទៀត សញ្ជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀត ព្រមទាំងកត្តានានា ដូចជា ភេទ អាយុ ជាតិសាសន៍ វប្បធម៌ អក្ខរកម្ម ជំងឺ ពិការផ្លូវកាយ ឬផ្លូវចិត្ត ភាពក្រីក្រ ឬគុណវិបត្តិសេដ្ឋកិច្ច និងការពឹងផ្អែកលើធនធានធម្មជាតិជាពិសេស របស់បុគ្គល ឬក្រុមប្រជាជន។[401] តាមបរិបទ យោងតាមសន្ទស្សន៍ភាពក្រីក្រពហុវិមាត្ររបស់ Oxford ប្រជាជនកម្ពុជា ៤១% មានជីវភាពក្រីក្រ ឬប្រឈមនឹងហានិភ័យនៃការធ្លាក់ចូលទៅក្នុងភាពក្រីក្រនៅឆ្នាំ២០២១/២០២២។[402] នៅឆ្នាំ២០២៣ ការស្ទង់មតិរបស់ CMA លើគ្រួសារដែលខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុជាង ៣.០០០ គ្រួសារ បានរក

[400] នៅក្នុងការវិនិយោគទាំងនេះ ក្រុមគោលដៅគឺជនដែលកំពុងស្វែងរកកម្ចីសហគ្រាសធុនតូច និងមធ្យម ដែលជា "បាតពីរ៉ាមីត" (BOP) ជាផ្នែកទីផ្សារ ដែលរួមបញ្ចូលប្រជាជនគ្រប់រូប ដែលមានប្រាក់ចំណូលក្រោម ៨ ដុល្លារក្នុងមួយថ្ងៃ ក្នុងភាពស្មើគ្នានៃអំណាចទិញ ឬដែលខ្វះលទ្ធភាពទទួលបានទំនិញ និងសេវាកម្មជាមូលដ្ឋាន (ធនាគារហត្ថា គម្រោងលេខ ៤៥៣៥ និង ៤៤៧៤២) សហគ្រាសធុនតូច និងមធ្យម ដែលទទួលបានសេវាមិនគ្រប់គ្រាន់ ឬមិនបានទទួលសេវា ដែលភាគច្រើនលើសលុបក្នុងវិស័យកសិកម្ម និងតំបន់ជនបទនៃប្រទេសកម្ពុជា (អម្រឹត គម្រោងលេខ ៤១២៩៤) សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាតកូវីដ ១៩ ជាពិសេស វិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ និងជាពិសេសចំពោះស្ត្រី និងសហគ្រាសដែលគ្រប់គ្រងដោយស្ត្រី (ធនាគារហត្ថា គម្រោងលេខ ៤៤២១១ និង អម្រឹត គម្រោងលេខ ៤៤២៣១) ផ្នែកសហគ្រាសធុនតូច និងមធ្យម ដែលទទួលបានសេវាមិនគ្រប់គ្រាន់ រួមមាន WSMEs និង SMEs ដែលកំពុងធ្វើប្រតិបត្តិការក្នុងវិស័យកសិកម្ម (អេស៊ីលីដា គម្រោងលេខ ៤៤៨៨២ និង ៤២៤៨០) ជាក្រុមដែលទទួលបានសេវាមិនគ្រប់គ្រាន់ជាពិសេស រួមទាំង WSMEs និងប្រជាជនរស់នៅតំបន់ដាច់ស្រយាល។ មូលនិធិ ៖ អ្នកខ្ចីដែលមានប្រាក់ចំណូលទាប រួមទាំងស្ត្រី និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានសក្តានុពលផ្សព្វផ្សាយទៅកាន់ជនដែលត្រូវបានដកចេញពីវិស័យហិរញ្ញវត្ថុ ដែលមានការលំបាក និងជាប្រពៃណី (លេខគម្រោង MIFA) និងសហគ្រាសធុនមីក្រូ ដែលទទួលបានបានសេវាមិនគ្រប់គ្រាន់ ដោយផ្តោតលើយ៉ាងតិច ២០ ប្រទេស នៃ IDA ដែលជាឧបករណ៍មួយដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ (MEF គម្រោងលេខ ២៧៨២៧); ប្រជាជនដែលមានប្រាក់ចំណូលទាបនៅក្នុងទីផ្សារព្រំដែនដែលអភិវឌ្ឍន៍តិចតួចខ្លាំង (Advans គម្រោងលេខ ២១៨៥៦)

[401] PS1 កថាខណ្ឌ ១២ ជើងទំព័រ ១៨

[402] គំនិតផ្តួចផ្តើមភាពក្រីក្រ និងការអភិវឌ្ឍមនុស្សរបស់ Oxford, UNDP សន្ទស្សន៍ភាពក្រីក្រពហុវិមាត្រ ឆ្នាំ២០២៤, ភាពក្រីក្រនៅចំកណ្តាលជម្លោះ ឆ្នាំ ២០២៤ https://bit.ly/4iEWCGO ទំ. ២៤ https://bit.ly/4iEWCGO, p. សម្រាប់ជនជាតិដើមភាគតិច (IPs) របាយការណ៍ស្តីពីស្ថានភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមនៅកម្ពុជា បង្ហាញថា ស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេនៅទាបជាងប្រជាជនកម្ពុជាទូទៅ។ លើសពីនេះទៀត ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា បង្ហាញថា នៅឆ្នាំ២០២១ អត្រាអក្ខរកម្មជាតិសម្រាប់មនុស្សពេញវ័យគឺ ៨៤,៧% (ស្ត្រី៨០,៣% និងបុរស ៨៩,៥%)។ ផ្ទុយទៅវិញ ទិន្នន័យពីឆ្នាំ២០១៩ បង្ហាញថា មានជនជាតិដើមភាគតិច ដែលមានអាយុ ៧ ឆ្នាំឡើងទៅ តែ ៥៦,៥% ប៉ុណ្ណោះ ដែលចេះភាសាខ្មែរ (ស្ត្រី ៥០,៨% និង បុរស ៦២,៥%)។
សូមមើល៖ អង្គការជនជាតិដើមភាគតិចកម្ពុជា របាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គមនៃជនជាតិដើមភាគតិចនៅកម្ពុជា ឆ្នាំ២០២៤ https://bit.ly/42hE9KO; Seila Nhiep, Bandeth Ros, របាយការណ៍គូរផែនទី ស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ICLT) ជាមួយកញ្ចក់យេនឌ័រនៅកម្ពុជា ខែតុលា ឆ្នាំ២០២៤ https://bit.ly/4c1XYce ទំ.១-២; និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ២០២១ https://bit.ly/3FHiZNu ទំ.៥៨។

ឃើញថា ពួកគេ ៥៩% រស់នៅក្នុងភាពក្រីក្រ ឬប្រឈមនឹងភាពក្រីក្រ[403] ហើយការស្ទង់មតិដាច់ដោយឡែកមួយ នៅឆ្នាំ២០២៤ លើអ្នកខ្ចី ២.៩៣៩ នាក់ បានរកឃើញថា ប្រជាជន ១៩% មានប្រាក់ចំណូលតិចជាង ៨ ដុល្លារ ក្នុងមួយថ្ងៃ ដោយអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុមានលទ្ធភាពច្រើនក្នុងការចូលទៅជិតប្រជាជននៅតំបន់ជនបទ។[404] នៅខណៈពេលដែលចំណុចនេះស្របតាមគោលបំណងដើមរបស់វិស័យនេះក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនោះ វាក៏បង្ហាញថា ហានិភ័យនៃមីក្រូហិរញ្ញវត្ថុមានផលប៉ះពាល់មិនសមាមាត្រចំពោះផ្នែកប្រជាជនដែលងាយរងគ្រោះខ្លាំងបំផុតដែរ។[405]

គ្រួសារដែលមានចំណូលទាប ក៏ទំនងជាមានកម្រិតចំណេះដឹងផ្នែកហិរញ្ញវត្ថុទាបផងដែរ[406] ដែលធ្វើឲ្យពួកគេងាយយល់ខុសអំពីលក្ខខណ្ឌនៃប្រាក់កម្ចី។ ការស្ទង់មតិរបស់ S&P Global FinLit ឆ្នាំ២០១៤ បានរកឃើញថា មានមនុស្សពេញវ័យកម្ពុជា តែ ១៨%ប៉ុណ្ណោះដែលមានចំណេះដឹងផ្នែកហិរញ្ញវត្ថុ[407] ហើយអ្នកឆ្លើយតបនឹងការស្ទង់មតិ CMA ឆ្នាំ២០២៣ ៥០% មិនដឹងពីអត្រាការប្រាក់ដែលគិតលើប្រាក់កម្ចីសកម្មរបស់ពួកគេ និង/ឬមិនបានដឹងពីថ្លៃសេវាដំណើរការទេ។[408] កត្តាទាំងនេះបង្ហាញថា អ្នកខ្ចីជាច្រើននាក់នៅក្នុងគម្រោងមីក្រូហិរញ្ញវត្ថុរបស់អតិថិជន/អតិថិជនបន្តរបស់ IFC មានស្ថានភាពងាយរងគ្រោះ ប៉ុន្តែ IFC មិនបានត្រួតពិនិត្យ ឬពិចារណាលើភាពងាយរងគ្រោះរបស់អ្នកប្រើប្រាស់មីក្រូហិរញ្ញវត្ថុគោលដៅ ជាផ្នែកមួយនៃការត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគនោះទេ។

IFC ក៏មិនបានរួមបញ្ចូលយ៉ាងពេញលេញនូវបរិបទដ៏ទូលំទូលាយនៃហានិភ័យមីក្រូហិរញ្ញវត្ថុដែលបានដឹង

---

[403] ប្រជាជនប្រហែល ១២% ត្រូវបានចាត់ថ្នាក់ជាជនក្រីក្រខ្លាំង ២៧% ជាជនក្រីក្រ និង ២០% មានហានិភ័យនៃភាពក្រីក្រ ការវាយតម្លៃផលប៉ះពាល់នៃ MCRIL-CMA ឆ្នាំ ២០២៣ ទំ.២៨។

[404] ៦០ ដេស៊ីបែល ការយល់ដឹងអំពីកម្ពុជាពីសន្ទស្សន៍មីក្រូហិរញ្ញវត្ថុ ៦០ ដេស៊ីបែល ឆ្នាំ២០២៤ https://bit.ly/43JJ6xl (តទៅនេះហៅថា ការអង្កេត ៦០ ដេស៊ីបែល) ទំ. ១១

[405] ការអង្កេត ៦០ ដេស៊ីបែល សង្កត់ធ្ងន់ថា គោលដៅនៃមីក្រូហិរញ្ញវត្ថុគឺដើម្បីទៅដល់អ្នកដែលមិនមានលទ្ធភាពទទួលបានឥណទាន ឬសេវាហិរញ្ញវត្ថុផ្សេងទៀត គេបានរកឃើញថា អ្នកផ្តល់សេវាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាកំពុងចូលទៅជិតប្រជាជននៅជនបទក្នុងប្រទេសកម្ពុជា ប៉ុន្តែកំពុងខ្វះខាតការផ្តល់សេវាដល់ប្រជាជនក្រីក្របំផុត។ ដូចគ្នានេះដែរ ការស្រាវជ្រាវរបស់ CMA និង M-CRIL បានរកឃើញថា គ្រួសារ ១២ ភាគរយ នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ដែលទាបជាងចំនួនជាមធ្យមនៃគ្រួសារដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រនៅថ្នាក់ជាតិ។ សូមមើល៖ ការអង្កេត ៦០ ដេស៊ីបែល ទំ. 6 និង MCRIL *ការវាយតម្លៃផលប៉ះពាល់នៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជា* ឆ្នាំ២០២៣ (តទៅនេះ ការវាយតម្លៃផលប៉ះពាល់នៃ MCRIL-CMA ឆ្នាំ២០២៣)។ របាយការណ៍ដែលរៀបចំដោយ CMA បានធ្វើការស្ទង់មតិប្រជាជន ៣.២៦២ គ្រួសារនៅទូទាំងដប់ខេត្ត។

[406] Sovannroeun Samreth, Daiju Aiba និង Vandy Phal អក្ខរកម្មហិរញ្ញវត្ថុក្នុងចំណោមអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ៖ សារៈសំខាន់ និងកត្តាកំណត់ ពីការស្ទង់មតិគ្រួសារនៅកម្ពុជា ឯកសារពិភាក្សារបស់វិទ្យាស្ថានស្រាវជ្រាវ JIVA Ogata, ខែមករា ឆ្នាំ២០២៤ ទំ.២៨, https://bit.ly/3DEdsGU។

[407] Leora Klapper, Annamaria Lusardi, Peter van Oudheusden, អក្ខរកម្មហិរញ្ញវត្ថុជុំវិញពិភពលោក៖ ការយល់ដឹងដែលទទួលបានពីការស្ទង់មតិអំពីអក្ខរកម្មហិរញ្ញវត្ថុជាសកលចំពោះសេវាវាយតម្លៃស្តង់ដារ និងជនក្រីក្រ ឆ្នាំ២០១៤ ទំ. ៧ ២៣ https://bit.ly/3DYxID2។

[408] ការវាយតម្លៃផលប៉ះពាល់របស់ MCRIL-CMA ឆ្នាំ២០២៣ ទំ.២៣ ២៤។ ដូចគ្នានេះដែរ ការវាយតម្លៃអក្ខរកម្មហិរញ្ញវត្ថុក្នុងចំណោមអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ដែលត្រូវបានធ្វើឡើងនៅឆ្នាំ ២០២១ ជាមួយប្រជាជន ១.២១៦ គ្រួសារនៅរាជធានី និងខេត្តចំនួនប្រាំមួយនៃប្រទេសកម្ពុជា បានរកឃើញថា មានអ្នកឆ្លើយតបតែ ១៩ ភាគរយប៉ុណ្ណោះ ដែលបានផ្តល់ចម្លើយត្រឹមត្រូវចំពោះការគណនាអត្រាការប្រាក់បង្គរ។ Sovannroeun Samreth, Daiju Aiba, និង Vandy Phal, អក្ខរកម្មហិរញ្ញវត្ថុក្នុងចំណោមអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ៖ សារៈសំខាន់ និងកត្តាកំណត់ ពីការស្ទង់មតិគ្រួសារនៅកម្ពុជា ឯកសារពិភាក្សារបស់វិទ្យាស្ថានស្រាវជ្រាវ JIVA Ogata, ខែមករា ឆ្នាំ២០២៤ ទំ.២៨, https://bit.ly/3DEdsGU។

ចំពោះអ្នកខ្ចីងាយរងគ្រោះ នៅក្នុងការវាយតម្លៃហានិភ័យនៅកម្រិតគម្រោងរបស់ខ្លួនដែរ។ របាយការណ៍ស្តីពីគ្រោះថ្នាក់សង្គមដែលអាចកើតឡើង ពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បានលេចឡើងនៅជុំវិញឆ្នាំ២០០៩ និងបានបន្តនៅឆ្នាំ២០១១ និង ឆ្នាំ២០១៣ រួមទាំងរបាយការណ៍ពី CGAP ដែល IFC ជាសមាជិកផងដែរ (សូមមើលផ្នែក ១.២ និងខ្សែបន្ទាត់ពេលវេលានៅក្នុងឧបសម្ព័ន្ធ ខ)។ នៅឆ្នាំ២០១៥ IFC បានចេញឯកសារគោលនយោបាយមួយ ដើម្បីលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ដែលបង្ហាញពីហានិភ័យសង្គមដែលអាចកើតឡើងពីការជំពាក់បំណុលវ័ណ្ឌក លើអ្នកប្រើប្រាស់ម្នាក់ៗ។[409] នៅឆ្នាំ២០១៩ ធនាគារពិភពលោកបានចេញកំណត់សម្គាល់គោលនយោបាយដែលបង្ហាញថា ហានិភ័យចំពោះសុខុមាលភាពគ្រួសារកំពុងមានការកើនឡើង នៅពេលដែលកម្រិតបំណុលកំពុងមានការកើនឡើងដែរ។[410] ចាប់ពីឆ្នាំ២០១៩ មក អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអង្គការសហប្រជាជាតិ បានរាយការណ៍ជាបន្តបន្ទាប់អំពីគ្រោះថ្នាក់សង្គមយ៉ាងខ្លាំងក្លាចំពោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលរួមមាន ការបាត់បង់ដីធ្លី និងការថយចុះនៃមុខរបរចិញ្ចឹមជីវិត ក្នុងចំណោមគ្រោះថ្នាក់ផ្សេងទៀត (សូមមើលផ្នែក ១.២ និងការខ្សែបន្ទាត់ពេលវេលានៅក្នុងឧបសម្ព័ន្ធ ខ)។

IFC បានអនុម័តការវិនិយោគចំនួនប្រាំ នៅក្នុងសំណុំរឿងនេះ នៅក្រោយឆ្នាំ២០១៩ ប៉ុន្តែស៊ីអេអូរកមិនឃើញភស្តុតាងថា របាយការណ៍ខាងលើត្រូវបានយកមកពិចារណាក្នុងការកំណត់ និងវាយតម្លៃប្រជាជនដែលអាចរងផលប៉ះពាល់ ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវនោះទេ។ របាយការណ៍ ESDD សម្រាប់ការវិនិយោគដោយផ្ទាល់របស់ IFC ចំនួនបី នៅអេស៊ីលីដា អម្រឹត និងធនាគារហត្ថា ដែលបានបញ្ចប់នៅក្រោយឆ្នាំ២០២០[411] បញ្ជាក់ថា មិនមានការរាយការណ៍ពីបញ្ហា E&S នោះទេ។ របាយការណ៍ត្រួតពិនិត្យភាពត្រឹមត្រូវបានកត់សម្គាល់ពីហានិភ័យផ្នែកកេរ្តិ៍ឈ្មោះ និងការចោទប្រកាន់លើការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ដ៏ឃោរឃៅរបស់គ្រឹះស្ថានទាំងនេះ ប៉ុន្តែមិនបានចាត់ទុកហានិភ័យទាំងនេះជាបញ្ហា E&S នោះទេ។

សរុបមក ការត្រួតពិនិត្យរបស់ស៊ីអេអូបានរកឃើញថា មិនមានការវាយតម្លៃ E&S របស់ IFC ណាមួយ ដែលចាត់ទុកថា អាចមានភាពងាយរងគ្រោះ ឬមានផលប៉ះពាល់ចំពោះប្រជាជនគោលដៅ សម្រាប់ការវិនិយោគទាំងនេះទេ ទោះបីជាមានផលប៉ះពាល់សង្គម និងហានិភ័យនៃមីក្រូហិរញ្ញវត្ថុដែលត្រូវបានចងក្រងឯកសារយ៉ាងល្អក៏ដោយ។ ជាលទ្ធផល ការវិនិយោគទាំងអស់ ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងនេះ ត្រូវបានចាត់ថ្នាក់ថាមានហានិភ័យកម្រិតមធ្យមទៅទាប ដោយផ្អែកលើការវាយតម្លៃរបស់ IFC លើហានិភ័យ E&S អវិជ្ជមានតិចតួចនៃអនុគម្រោងដែលទំនងនឹងកើតឡើង។ IFC បានតម្រូវឱ្យពួកគេអនុវត្តបញ្ជីផាត់ចេញរបស់ IFC ច្បាប់ E&S កម្ពុជា និងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ ហើយក្នុងករណីមួយចំនួន ស្តង់ដារសមិទ្ធកម្មរបស់ IFC សម្រាប់គម្រោងរយៈពេលវែង និងហិរញ្ញវត្ថុសាជីវកម្ម ដែលមានសកម្មភាពនានា ទាក់ទងនឹងហានិភ័យ និង

[409] IFC ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ឆ្នាំ២០១៥ ទំ. ២៩–៣៣. មាននៅ https://bit.ly/3VCU817។

[410] ក្រុមធនាគារពិភពលោក កំណត់សម្គាល់គោលនយោបាយនៃប្រទេសកម្ពុជាស្តីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ ឆ្នាំ២០១៩ ទំ.១១ មាននៅ https://bit.ly/3NITywL។

[411] អេស៊ីលីដាក គម្រោងលេខ ៤៩៨៨២ (ឆ្នាំ២០២១); អម្រឹត លេខ ៤៤២៣១ (ឆ្នាំ២០២០) និងធនាគារហត្ថា លេខ ៤៤២១១ (ឆ្នាំ២០២០)។

ផលប៉ះពាល់សំខាន់ៗនៃអនុគម្រោង។[412]

### *៤.៣.១.២ ការត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រង E&S របស់អតិថិជនដើម្បីវាយតម្លៃសមត្ថភាពរបស់អតិថិជនក្នុងការកំណត់ និងគ្រប់គ្រងហានិភ័យ ស្របតាមស្តង់ដារសមិទ្ធកម្មទី១*

*លក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធ*

ជាផ្នែកមួយនៃការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន IFC មានកាតព្វកិច្ចពិចារណាអំពីហានិភ័យ E&S ដែលមានមកជាមួយនឹងវិស័យជាក់លាក់មួយ ផលបត្រដែលមានស្រាប់ និងសកម្មភាពអាជីវកម្មនាពេលអនាគតរបស់អតិថិជន និងបរិបទនៃទីតាំងធ្វើសកម្មភាពអាជីវកម្ម។

IFC ក៏ត្រូវតែត្រួតពិនិត្យសមត្ថភាពផ្នែក E&S របស់អតិថិជន និងតម្រូវឱ្យពួកគេបង្កើត និងអនុវត្តប្រព័ន្ធគ្រប់គ្រង E&S (ESMS) សម្រាប់ការវិនិយោគផងដែរ។ ចំណុចនេះស្របតាម PS1[413] ដែលកំណត់លក្ខខណ្ឌតម្រូវក្នុងការកំណត់ និងដោះស្រាយហានិភ័យ និងផលប៉ះពាល់លើជនងាយរងគ្រោះ តាមរយៈការអនុវត្ត GIIP។[414] ទំនួលខុសត្រូវរបស់អតិថិជនស្របតាម PS1 រួមមាន ការកំណត់អត្តសញ្ញាណ "ក្រុមដែលអាចរងផលប៉ះពាល់ដោយផ្ទាល់ និងខុសគ្នា ឬមិនសមាមាត្រដោយគម្រោង ដោយសារស្ថានភាពនៃការលំបាក ឬងាយរងគ្រោះរបស់ពួកគេ" ការអនុវត្ត "វិធានការខុសៗគ្នា ដើម្បីកុំឱ្យមានផលប៉ះពាល់អវិជ្ជមានធ្លាក់លើពួកគេដោយមិនសមាមាត្រ" និងធានាថា ពួកគេមិន "មានការលំបាកក្នុងការចែករំលែកអត្ថប្រយោជន៍ និងឱកាសក្នុងការអភិវឌ្ឍ" នោះទេ។[415] គោលនយោបាយនិរន្តរភាពចែងបន្ថែមទៀតថា IFC រំពឹងឲ្យអតិថិជនរបស់ខ្លួនកាត់បន្ថយជាអប្បបរមានូវហានិភ័យទាក់ទងនឹងយេនឌ័រពីសកម្មភាពអាជីវកម្ម និងផលប៉ះពាល់ខុសគ្នាតាមយេនឌ័រដោយអចេតនា។[416]

*សកម្មភាពរបស់ IFC*

---

[412] សូមមើល សេចក្តីសង្ខេប E&S និងការបង្ហាញព័ត៌មាន សម្រាប់គម្រោងអេស៊ីលីដា លេខ ៤២៤៨០៖ https://bit.ly/4hMGUIz; គម្រោងលេខ ៤៤៨៨២ https://bit.ly/4j1vEJj; អម្រឹត គម្រោងលេខ ៤១២៩៤ https://bit.ly/3QNFd2E គម្រោងលេខ ៤៤២៣១ https://bit.ly/42fxkt3; ធនាគារហត្ថា គម្រោងលេខ ៣៩១៦៧ https://bit.ly/3FDYn8B លេខ ៤៤២១១ https://bit.ly/3Xz7PjY លេខ ៤៤៧៤២ https://bit.ly/4c3Tlyt លេខ ៤៥៥៣៥ https://bit.ly/4j0IqHU; MEF គម្រោងលេខ ២៧៨២៧ https://bit.ly/3FHjOG4; MIFA គម្រោងលេខ ៣១៤៦៧ https://bit.ly/3DJCC6P; Advans គម្រោងលេខ ២១៨៥៦ https://bit.ly/4hB៩v3o និង North Haven Thai គម្រោងលេខ ៣៨៦០៩ https://bit.ly/43rK6pI។

[413] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៣ និង ៣៥។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨-២៩ និងសម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

[414] PS1 ឆ្នាំ២០១២ កថាខណ្ឌ ៧ និងសម្រាប់ការវិនិយោគនៅ MEF សូមមើល PS1 ឆ្នាំ២០០៦ កថាខណ្ឌ ១២។ សម្រាប់ការវិនិយោគនៅ Advans សូមមើល OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។ សូមមើលផ្នែក ៣.៦.២ និង ៣.៦.៣ សម្រាប់ការវិវត្តនៃ GIIP ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ ពាក់ព័ន្ធនឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដើម្បីទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចំពោះអ្នកខ្ចីដែលក្រីក្រ និងងាយរងគ្រោះ។

[415] PS1 ឆ្នាំ២០១២ កថាខណ្ឌ ១២ និងសម្រាប់ការវិនិយោគនៅ MEF សូមមើល PS1 ឆ្នាំ២០០៦ កថាខណ្ឌ ១២។ សម្រាប់ការវិនិយោគនៅ Advans សូមមើល ESRP ឆ្នាំ១៩៩៨ កថាខណ្ឌ ២២ ជើងទំព័រទី ៧។ PS1 ក៏តម្រូវឲ្យបុគ្គលិករបស់អតិថិជន FI ដែលប្រាស្រ័យទាក់ទងជាមួយបុគ្គល ឬក្រុមដែលងាយរងគ្រោះ ឬជួបការលំបាក មានសមត្ថកិច្ចក្នុងការស្វែងយល់ពីបញ្ហាជាក់លាក់ដែលពាក់ព័ន្ធ ទាក់ទងនឹងបុគ្គល ឬក្រុមទាំងនោះ ដែលអាចធានាចំពោះការបណ្តុះបណ្តាលជាក់លាក់ផងដែរ។ PS1 ឆ្នាំ២០១២ កថាខណ្ឌ ១៨ និង GN៧៩។ សម្រាប់ការវិនិយោគនៅ MEF សូមមើល PS1 ឆ្នាំ២០០៦ កថាខណ្ឌ ១៨។

[416] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ១៣

សម្រាប់ការវិនិយោគប្រាក់កម្ចីដោយផ្ទាល់នៅអេស៊ីលីដា អម្រឹត និងធនាគារហត្ថា ការកំណត់របស់ IFC ចំពោះភាពគ្រប់គ្រាន់នៃសមត្ថភាព និងប្រព័ន្ធគ្រប់គ្រង E&S របស់ពួកគេ ផ្តោតយ៉ាងខ្លាំងលើការពិតដែលថា ពួកគេជាអតិថិជនដ៏យូរអង្វែងរបស់ IFC។ ដូច្នេះ IFC មិនបានរួមបញ្ចូលការវាយតម្លៃជាក់លាក់ និងដាច់ដោយឡែកពីគ្នាលើភាពគ្រប់គ្រាន់បែបនោះ នៅពេលត្រួតពិនិត្យគម្រោងមុនពេលវិនិយោគនីមួយៗនោះទេ។ សម្រាប់ការវិនិយោគភាគហ៊ុននៅអម្រឹត IFC បានចាត់ទុកសមត្ថភាព E&S របស់អតិថិជន ថាគ្រប់គ្រាន់ និងបានកំណត់ថា អតិថិជនមាន ESMS ជាទីពេញចិត្ត ស្របតាមកម្រិតហានិភ័យ ដែលបានបង្ហាញដោយសកម្មភាពអាជីវកម្មរបស់ខ្លួន ដែលគ្រប់សកម្មភាពទាំងអស់ត្រូវបានត្រួតពិនិត្យធៀបនឹងបញ្ជីផាត់ចេញរបស់ IFC និងច្បាប់ និងបទប្បញ្ញត្តិជាតិ។ [417] IFC បានកំណត់តម្រូវការក្នុងការកែលម្អ ឬកែប្រែ ESMS របស់អតិថិជននៅក្នុងការវិនិយោគដោយផ្ទាល់តែពីរប៉ុណ្ណោះ ក្នុងចំណោមការវិនិយោគដោយផ្ទាល់របស់ខ្លួនទាំងប្រាំបួនគឺ គម្រោងធនាគារហត្ថា លេខ ៤៤៧៤២ (ឆ្នាំ២០២១)[418] និង គម្រោងអេស៊ីលីដា លេខ ៤២៤៨០ (ឆ្នាំ២០១៩)[419] ប៉ុន្តែមិនមានករណីណាមួយទាក់ទងនឹងការកំណត់ និងកាត់បន្ថយផលប៉ះពាល់លើជនងាយរងគ្រោះ ស្របតាមស្តង់ដារ GIIP។ នៅក្នុងការវិនិយោគដោយផ្ទាល់ទាំង ៩ មិនមានការវិនិយោគណាមួយ ដែល IFC តម្រូវឱ្យ ESMS កំណត់អត្តសញ្ញាណប្រជាជនដែលងាយរងគ្រោះ ឬជួបការលំបាក និងអនុវត្តវិធានការផ្សេងៗ ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានដែលធ្លាក់លើពួកគេដោយមិនសមាមាត្រ ឬស្របតាម GIIP សម្រាប់ការវិនិយោគមីក្រូហិរញ្ញវត្ថុនោះទេ។

តាមរយៈការវិនិយោគរបស់ខ្លួន នៅក្នុងមូលនិធិ MEF MIFA និង North Haven Thai IFC បានប្រយោលដោយប្រយោលទៅនឹង BFIs កម្ពុជាចំនួនបី។ ដោយសារតែមូលនិធិទាំងបីនេះត្រូវបានបង្កើតឡើងនៅពេលនោះ ពួកគេមិនមានគោលនយោបាយសម្រាប់អនុវត្តក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវនោះទេ ដោយ IFC វាយតម្លៃនីតិវិធី E&S របស់អ្នកគ្រប់គ្រងមូលនិធិជាសក្តានុពល ឬកម្រងសំណួរ E&S និងពិភាក្សាអំពីលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍។[420] ជាទូទៅ IFC បានតម្រូវឲ្យអតិថិជននៃមូលនិធិរបស់ខ្លួន ដែលរួមមាន Advans MEF MIFA និង North Haven Thai ចាត់តាំងមន្ត្រី E&S និងបង្កើត និងអនុវត្ត ESMS។ កម្រិតព័ត៌មានលម្អិត និងលក្ខខណ្ឌតម្រូវ មានការប្រែប្រួល។ ចំពោះ Advans នៅឆ្នាំ២០០៥ IFC បានតម្រូវឲ្យមន្ត្រី E&S របស់វា ទទួលការបណ្តុះបណ្តាល ESMS សម្រាប់ MFIs ដោយណែនាំប្រព័ន្ធគ្រប់គ្រងអតិថិជនមួយ ដែលត្រូវបានកែសម្រួលជាពិសេសសម្រាប់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុ។ ចំពោះ MEF និង MIFA ដោយមិនប្រើ

[417] អម្រិត គម្រោងលេខ ៣៨៧៤៨ សេចក្តីសង្ខេបអំពី E&S និងការបង្ហាញព័ត៌មាន https://bit.ly/3XyuZXz។ អម្រឹត ការគ្រប់គ្រងការអនុវត្តការងារសង្គម https://bit.ly/4k449PI។

[418] IFC បានរកឃើញថា ធនាគារ ហត្ថា ចាំបាច់ត្រូវកែលម្អ ESMS របស់ខ្លួន ដើម្បីឲ្យស្របតាមកំណើននៃការផ្តល់ប្រាក់កម្ចី SME និងតម្រូវឱ្យ ហត្ថា ពង្រឹងនីតិវិធីរបស់ខ្លួន ដើម្បីគាំទ្រការកំណត់ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ E&S ស្របតាមលក្ខខណ្ឌតម្រូវ E&S ដែលអាចអនុវត្តបាន ព្រមទាំងរួមបញ្ចូលលក្ខខណ្ឌតម្រូវ និងនីតិវិធីនានា ដូចជា យន្តការទំនាក់ទំនងខាងក្រៅ សម្រាប់ប្រតិបត្តិការដែលមានហានិភ័យខ្ពស់។

[419] IFC បានពិចារណាលើ ESMS ដែលមានស្រាប់ របស់អេស៊ីលីដា ស្របតាមសកម្មភាពមីក្រូហិរញ្ញវត្ថុ និងការផ្តល់កម្ចីដល់ SME ដែលមានហានិភ័យ E&S ទាបជាង ប៉ុន្តែតម្រូវឲ្យ FI កែលម្អការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែក E&S នៃការផ្តល់កម្ចីសាជីវកម្ម ដែលមានហានិភ័យ E&S ខ្ពស់ជាង តាមរយៈការកែសម្រួលការអនុវត្ត PS និងការកសាងសមត្ថភាព E&S។

[420] ក្នុងករណី Advans មានកំណត់ត្រាតិចតួចអំពី ESDD ត្រូវបានធ្វើឡើងនៅឆ្នាំ២០០៤ ប៉ុន្តែឯកសារគម្រោងណែនាំថា វាមានការត្រួតពិនិត្យឯកសារយោងតិចតួចណាស់ ដែលបានរួមបញ្ចូលការត្រួតពិនិត្យមួយចំនួនលើសមត្ថភាព MFI របស់អ្នកឧបត្ថម្ភ និងអ្នកគ្រប់គ្រងមូលនិធិនាពេលអនាគត ប៉ុន្តែមិនរួមបញ្ចូលការត្រួតពិនិត្យសមត្ថភាព ESDD នោះទេ។

ពាក្យ ESMS នោះទេ IFC បានតម្រូវឱ្យអ្នកគ្រប់គ្រងមូលនិធិបង្កើត និងអនុវត្តនីតិវិធីត្រួតពិនិត្យ ដើម្បីធានាថា ការវិនិយោគទាំងអស់បានជៀសវាងសកម្មភាពគាំទ្រទៅក្នុងបញ្ជីផាត់ចេញរបស់ IFC រួមទាំងសកម្មភាពដែលត្រូវបានដកចេញយ៉ាងច្បាស់លាស់ សម្រាប់សកម្មភាពមីក្រូហិរញ្ញវត្ថុ (សូមមើលផ្នែក ៣.៧.១ ខាងលើ)។ IFC ក៏បានតម្រូវឲ្យមូលនិធិតម្រូវឱ្យ MFIs ដែលពួកគេគាំទ្រ អនុវត្តនីតិវិធីនេះក្នុងការជួលបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មកគ្រប់គ្រង និងអនុវត្តនីតិវិធីទាំងនេះ និងអនុវត្តស្តង់ដារការងារនៅក្នុងស្តង់ដារសមិទ្ធកម្មទី២ និងដាក់ជូនរបាយការណ៍តាមកាលកំណត់ទៅកាន់ IFC លើប្រធានបទទាំងនេះផងដែរ។[421] កិច្ចព្រមព្រៀងស្របច្បាប់ ដែលបង្កើត MEF និង MIFA ក៏បានប្តេជ្ញាចិត្តធ្វើប្រតិបត្តិការរបស់ពួកគេ ដោយផ្អែកលើឧត្តមានុវត្តន៍សម្រាប់មីក្រូហិរញ្ញវត្ថុពាណិជ្ជកម្មផងដែរ។ ក្នុងករណី North Haven Thai, IFC តម្រូវឱ្យពួកគេបង្កើត និងអនុវត្ត ESMS គ្រប់ជ្រុងជ្រោយ ដោយផ្អែកលើការអនុវត្តការគ្រប់គ្រងហានិភ័យ E&S អន្តរជាតិដ៏ល្អ។[422] ទោះបីជាយ៉ាងណាក៏ដោយ IFC មិនបានតម្រូវឱ្យ ESMS របស់អតិថិជនមូលនិធិទាំងនេះមានសមត្ថភាពកំណត់អត្តសញ្ញាណប្រជាជនដែលងាយរងគ្រោះ ឬជួបការលំបាក និងអនុវត្តវិធានការផ្សេងៗ ដើម្បីឲ្យផលប៉ះពាល់អវិជ្ជមានមិនធ្លាក់លើពួកគេដោយមិនសមាមាត្រ ឬស្របតាម GIIP នោះទេ។ ក្រុមគោលដៅនៃការវិនិយោគទាំងនេះ គឺជាជនងាយរងគ្រោះ ដូចបានកត់សម្គាល់នៅក្នុងផ្នែក ៤.៣.១។ ទោះបីជាយ៉ាងណាក៏ដោយ IFC មិនបានតម្រូវឱ្យអតិថិជនប្រាក់កម្ចីដោយផ្ទាល់ ឬមូលនិធិរបស់ខ្លួន មាន ESMS ដែលកំណត់ និងអនុវត្តវិធានការសម្រាប់ជនងាយរងគ្រោះនោះទេ ទោះបីជាហានិភ័យ និងផលប៉ះពាល់សង្គមនៃមីក្រូហិរញ្ញវត្ថុលើជនងាយរងគ្រោះ ត្រូវបានដឹងយ៉ាងច្បាស់ ដូចបានទទួលស្គាល់ដោយក្រុមធនាគារពិភពលោក និង IFC ក៏ដោយ។[423] នៅឆ្នាំ២០០៩ មុនពេលដែលការត្រួតពិនិត្យភាពត្រឹមត្រូវមួយសម្រាប់ការវិនិយោគនៅក្នុងសំណុំរឿងនេះ ត្រូវបានធ្វើឡើង ការវាយតម្លៃដែលផ្តល់មូលនិធិដោយធនាគារពិភពលោកលើវិបត្តិសេដ្ឋកិច្ចពិភពលោកនៅកម្ពុជាបានបង្ហាញថា អសមត្ថភាពក្នុងការសងប្រាក់កម្ចីគឺជា "កង្វល់ដ៏ធ្ងន់ធ្ងរមួយសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ"។[424] ដូចគ្នានេះដែរ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០ មក CGAP ដែល IFC ជាសមាជិក បានគូសបញ្ជាក់ពីតម្រូវការក្នុងការអនុវត្តការការពារ ដើម្បីការពារអ្នកខ្ចីដែលងាយរងគ្រោះពីហានិភ័យ និងផលប៉ះពាល់អវិជ្ជមាន ពីការវិនិយោគមីក្រូហិរញ្ញវត្ថុ (សូមមើលខ្សែបន្ទាត់ពេលវេលានៅក្នុងផ្នែក ៣.៧.២ និងឧបសម្ព័ន្ធ ខ)។

*ការធានាបាននូវសង្គតិភាពនឹងច្បាប់ជាតិ*

ស្របតាមគោលនយោបាយនិរន្តរភាពរបស់ខ្លួន IFC ត្រូវតែត្រួតពិនិត្យ និងតម្រូវឱ្យអតិថិជនរបស់ខ្លួនមានការគ្រប់គ្រងហានិភ័យ E&S ដើម្បីធានាថាវាមានសង្គតិភាពនឹងការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ និងច្បាប់ជាតិ។

---

[421] MEF គម្រោងលេខ ២៧៨២៧ https://bit.ly/៣FHjOG4; MIFA គម្រោងលេខ ៣១៤៦៧ https://bit.ly/3DJCC6P។

[422] North Haven Thai គម្រោងលេខ ៣៨៦០៩ https://bit.ly/៤iHCvbi។

[423] ក្នុងចំណោមឯកសារផ្សេងទៀត សូមមើល ធនាគារពិភពលោក ស្ថានភាពជាសកលនៃបរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់ របាយការណ៍ឆ្នាំ២០២២ https://bit.ly/4hzPj1M, ក្រុមធនាគារពិភពលោក ការអនុវត្តល្អសម្រាប់ការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ កំណែឆ្នាំ២០១៧ https://bit.ly/3FndD9N, IFC ការចាប់ផ្តើមតូចតាចសម្រាប់ឱកាសដ៏អស្ចារ្យ៖ មេរៀនដែលទទួលបាននៅក្នុងគម្រោងមីក្រូហិរញ្ញវត្ថុរយៈពេល ២០ ឆ្នាំ នៅ IFC ឆ្នាំ២០១៧ https://bit.ly/4bPhtVk; IFC វឌ្ឍនភាពនៃបរិយាប័ន្នហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ៖ របាយការណ៍ផែនទីសកល និងករណីសិក្សាដែលត្រូវបានជ្រើសរើស ឆ្នាំ២០១៣ https://bit.ly/4hrB1R5។

[424] Theng Vuthy និង Kem Sothorn ការវាយតម្លៃយ៉ាងឆាប់រហ័សលើផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោកលើគ្រួសារកម្ពុជា៖ ឥទ្ធិពល និងយុទ្ធសាស្ត្រទប់ទល់ ការត្រួតពិនិត្យការអភិវឌ្ឍកម្ពុជា លេខ ១៣ ច្បាប់ទី៣ ខែកក្កដា-កញ្ញា ឆ្នាំ២០០៩ https://bit.ly/3FotK72 ។

នៅក្នុងបរិបទនៃការវិនិយោគនេះ ចំណុចនេះរួមបញ្ចូលការបង្កើតវិធានការជាក់លាក់ដើម្បីការងារក្រុមងាយរងគ្រោះ។

នៅកម្ពុជា ជាផ្នែកមួយនៃការត្រួតពិនិត្យភាពត្រឹមត្រូវ IFC ក៏ត្រូវបានតម្រូវឱ្យត្រួតពិនិត្យភាពអនុលោមរបស់អតិថិជន FI ទៅនឹងលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែលពាក់ព័ន្ធ ទាក់ទងនឹងការហាមឃាត់អាជ្ញាធរមូលដ្ឋានមិនឲ្យចូលរួមក្នុងសកម្មភាពផ្តល់ប្រាក់កម្ចី និងប្រមូលប្រាក់ (ចាប់តាំងពីឆ្នាំ២០១៧ មក[425]) និងវាល់ទម្រង់នៃការគំរាមកំហែង និងការបំភិតបំភ័យនៅក្នុងការដំណើរការទារប្រាក់កម្ចី (ចាប់ពីឆ្នាំ២០១៩ មក[426])។ ទោះបីជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC លើការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់ BFIs ត្រូវបានដាក់កម្រិតចំពោះទស្សនវិស័យផ្នែកហិរញ្ញវត្ថុ (សូមមើលផ្នែក ៤.៣.១) ហើយស៊ីអេអូរកមិនឃើញភស្តុតាងដែលថា IFC បានធានាថា អតិថិជន និងអតិថិជនបន្តរបស់ខ្លួនបានអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែលពាក់ព័ន្ធ ចំពោះការគំរាមកំហែង និងការបំភិតបំភ័យ ឬការចូលរួមរបស់អាជ្ញាធរមូលដ្ឋាននោះទេ។ ផ្ទុយទៅវិញ ដូចបានរៀបរាប់ខាងលើ BFIs ចំនួនពីរ នៅក្នុងសំណុំរឿងនេះ បានណែនាំបុគ្គលិករបស់ពួកគេឲ្យរួមបញ្ចូលអាជ្ញាធរមូលដ្ឋាននៅក្នុងការលក់ នៅខណៈពេលដែលអតិថិជន និងអតិថិជនបន្តរបស់ IFC ទាំងប្រាំមួយបានរួមបញ្ចូលអាជ្ញាធរមូលដ្ឋាននៅក្នុងយុទ្ធសាស្ត្រប្រមូលបំណុលរបស់ពួកគេ (សូមមើលផ្នែក ៤.២)។ IFC បានផ្តល់ទឡ្ហីករណ៍ថា ការអនុវត្តមួយចំនួន ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹងថាជា "ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន" នោះ គឺជាផ្នែកមួយនៃតួនាទីរបស់អាជ្ញាធរមូលដ្ឋាននៅកម្ពុជា ក្នុងការសម្របសម្រួលវិវាទ ដូច្នេះវាមិនត្រូវបានហាមឃាត់ ស្របតាមលិខិតបទដ្ឋានគតិយុត្តិរបស់ប្រទេសកម្ពុជានោះទេ។ ទោះបីជាការអនុវត្តជាក់លាក់ ដែលរំលោភលើអនុក្រឹត្យជាតិដែលពាក់ព័ន្ធ ស្ថិតនៅក្រៅអាណត្តិរបស់ស៊ីអេអូក៏ដោយ និងសម្រាប់ការសម្រេចចិត្តដោយអាជ្ញាធរជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូកត់សម្គាល់ថា មិនមានភស្តុតាងនៅក្នុងឯកសារគម្រោងដែលថា IFC បានត្រួតពិនិត្យ និងធានាថា អតិថិជន និងអតិថិជនបន្តរបស់ខ្លួនបានអនុលោមតាមលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែលពាក់ព័ន្ធនោះទេ ទោះបីជាអនុក្រឹត្យរបស់ក្រសួងមហាផ្ទៃទំនងជាបានចេញដើម្បីឆ្លើយតបទៅនឹងបញ្ហាសង្គម ដែលបានសង្កេតឃើញនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាក៏ដោយ (សូមមើលផ្នែក ១.២)។

*ការធានាចំពោះសង្គតិភាពតាម GIIP*

ស្តង់ដារសមិទ្ធកម្មទី១ តម្រូវឲ្យអតិថិជនរចនា និងអនុវត្តវិធានការកាត់បន្ថយ និងកម្មវិធីគ្រប់គ្រង ស្របតាម GIIP។ ជាងពីរទសវត្សរ៍កន្លងមកនេះ ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ សម្រាប់មីក្រូហិរញ្ញវត្ថុ មានការវិវត្តដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមាន និងគ្រោះថ្នាក់ ដែលមីក្រូហិរញ្ញវត្ថុ ដែលត្រូវបានរចនា ឬអនុវត្តមិន

---

[425] ក្រសួងមហាផ្ទៃ (ឆ្នាំ២០១៧) បទបញ្ជារបស់ក្រសួង លេខ ៥៥៦ ស/ជ/ណ ស្តីពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ ភ្នំពេញ។ អត្ថបទ ឬបទបញ្ជានេះបង្ហាញថា "លុះត្រាតែត្រូវបានតម្រូវតាមផ្លូវច្បាប់ឲ្យមានការចូលរួមអនុវត្តសាលក្រមតុលាការ អាជ្ញាធរស្រុក/ក្រុង/ខណ្ឌ ឃុំ/សង្កាត់ និងភូមិ មិនត្រូវធ្វើសកម្មភាពរួមគ្នាជាមួយធនាគារឯកជន MFIs និងប្រតិបត្តិករឥណទានជនបទ (ដែលបង្កឱ្យមានការយល់ច្រឡំក្នុងចំណោមប្រជាជន ថាធនាគារ MFIs និងប្រតិបត្តិករទាំងនេះជារបស់រដ្ឋ) រួមទាំងការដើរតួជាអ្នកធានាក្នុងប្រតិបត្តិការប្រាក់កម្ចី ឬជាភ្នាក់ងារ ឬអ្នកធានាសងបំណុល ឬទាមទារការសងប្រាក់ពីប្រជាជន ការផ្សាយពាណិជ្ជកម្មសម្រាប់ស្ថាប័នហិរញ្ញវត្ថុណាមួយ ឬចូលរួមក្នុងការរឹបអូសវត្ថុបញ្ចាំរបស់ប្រជាជននោះទេ"។

[426] មាត្រា ១៩ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ - រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០១៩)។ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ (នស/រកម/១១១៩/០១៦) ភ្នំពេញ។

បានល្អ អាចមានលើប្រជាជនងាយរងគ្រោះ។ ជាលទ្ធផល ស្តង់ដារនានាបានផ្តល់មគ្គុទ្ទេសក៍ណែនាំដល់អ្នកផ្តល់ប្រាក់កម្ចីឲ្យ (i) រចនាផលិតផល ដើម្បីបញ្ជៀសគ្រោះថ្នាក់ចំពោះអ្នកខ្ចី (ii) វាយតម្លៃសមត្ថភាពសងបំណុលរបស់អ្នកខ្ចីឲ្យបានត្រឹមត្រូវ (iii) ផ្តល់ព័ត៌មានច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលា សម្រាប់ការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ និង (iv) ធានាថាមានការប្រព្រឹត្តិដោយយុត្តិធម៌ និងដោយការគោរព រួមជាមួយការការពារប្រឆាំងនឹងការអនុវត្តដោយឈ្លានពាន ឬរំលោភបំពាន (សូមមើលខ្សែបន្ទាត់ពេលវេលានៅក្នុងផ្នែក ៣.៧.២)។

ការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែក E&S របស់ IFC មិនបានរួមបញ្ចូលការត្រួតពិនិត្យការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់ BFIs នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចបានពន្យល់នៅក្នុងផ្នែក ៤.១ នៅក្នុងការវិនិយោគភាគច្រើន នៅក្នុងសំណុំរឿងនេះ ការអនុវត្តទាំងនោះត្រូវបានត្រួតពិនិត្យដោយអ្នកឯកទេសផ្នែកមីក្រូហិរញ្ញវត្ថុរបស់ IFC ឬអ្នកជំនាញផ្នែកឧស្សាហកម្មនេះ ជាផ្នែកមួយនៃយុទ្ធសាស្រ្តបរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់។[427] នៅរាល់ការវិនិយោគទាំងអស់ ការត្រួតពិនិត្យដោយអ្នកជំនាញផ្នែកឧស្សាហកម្មរបស់ IFC លើគោលនយោបាយរបស់អតិថិជន ផ្តោតលើផ្នែកហិរញ្ញវត្ថុ ដែលពិចារណាលើផលប៉ះពាល់នៃការវិនិយោគលើប្រាក់ចំណេញរបស់ FI និងលើទីផ្សារ ប៉ុន្តែមិនបានត្រួតពិនិត្យថាតើគោលនយោបាយ និងការអនុវត្តរបស់ FIs ស្របនឹងលក្ខខណ្ឌតម្រូវរបស់ PS1 ក្នុងការកំណត់ និងកាត់បន្ថយផលប៉ះពាល់លើក្រុមងាយរងគ្រោះ ដូចបានផ្តល់ព័ត៌មានដោយ GIIP នោះទេ។ នៅខណៈពេលដែល IFC បានកត់សម្គាល់ពីកង្វល់នៃការពង្រីកទីផ្សារយ៉ាងឆាប់រហ័ស ការប្រកួតប្រជែងកម្រិតខ្ពស់នៅក្នុងចំណោមអ្នកផ្តល់ប្រាក់កម្ចី និងការដែលអ្នកខ្ចីអាចមានបំណុលវ័ណ្ឌក នោះ វាមិនបានវាយតម្លៃហានិភ័យ និងផលប៉ះពាល់សង្គមដែលអាចកើតឡើងនោះទេ ដែលកាលៈទេសៈទាំងនេះអាចកើតឡើងចំពោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ និងប្រជាជនងាយរងគ្រោះ។

ដូច្នេះ នៅគ្រប់ការវិនិយោគទាំងអស់ លើកលែងចំពោះការវិនិយោគមួយនៅក្នុងធនាគារ ហត្ថា (ដូចបានពន្យល់នៅខាងក្រោម) IFC មិនបានតម្រូវឱ្យអតិថិជនរបស់ខ្លួនតម្រឹមគោលនយោបាយនឹងស្តង់ដារ GIIP និងច្បាប់ជាតិដែលពាក់ព័ន្ធនោះទេ។ ជាទូទៅ ការត្រួតពិនិត្យហិរញ្ញវត្ថុមិនបានពិនិត្យមើលភាពស៊ីសង្វាក់គ្នានៃការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់ FIs ជាមួយ GIIP ដើម្បីជៀសវាងហានិភ័យ និងផលប៉ះពាល់សង្គមចំពោះប្រជាជនដែលងាយរងគ្រោះពីការអនុវត្តដែលមានគ្រោះថ្នាក់ ដូចបានកំណត់នៅក្នុងផ្នែក ៤.២.១ ខាងលើ នោះទេ។

នៅឆ្នាំ២០១១ និង ឆ្នាំ២០១៧ ការអនុវត្តនានា ដូចជា ការប្រើប្រាស់អាជ្ញាធរមូលដ្ឋាននៅក្នុងដំណើរការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ ឬការពឹងផ្អែកលើវត្ថុបញ្ចាំជាដីធ្លីខ្លាំងពេក ត្រូវបានកត់សម្គាល់នៅក្នុងការត្រួតពិនិត្យហិរញ្ញវត្ថុរបស់ IFC សម្រាប់គម្រោងជាមួយអតិថិជន FI កម្ពុជាចំនួនពីរ ប៉ុន្តែ IFC មិនបានលើកឡើងពីកង្វល់ចំពោះអតិថិជន ទាក់ទងនឹងផលប៉ះពាល់ដែលអាចបង្កគ្រោះថ្នាក់ដល់អ្នកខ្ចីនោះទេ។ នៅឆ្នាំ២០១៤ ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវរបស់អតិថិជន FI មួយ ក្នុងចំណោមអតិថិជន FI ទាំងនេះ IFC បានទទួលស្គាល់ថា វិស័យនេះកំពុងមានក្រុមអតិថិជនដែលជំពាក់បំណុលវ័ណ្ឌក ដែលអាចជួបប្រទះនឹងការថយចុះនៃគុណភាព និងជីវភាពរស់នៅរបស់ពួកគេ និងថា វាតម្រូវឱ្យមានវិធានការជាច្រើន ក្នុងចំណោមវិធានការ

[427] មិនមានភស្តុតាងដែលថា អ្នកជំនាញផ្នែកមីក្រូហិរញ្ញវត្ថុ ឬធនាគារដទៃទៀត បានចូលរួមក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ ពាក់ព័ន្ធនឹងការវិនិយោគនៅ Advans (ឆ្នាំ២០០៤) ឬ North Haven Thai (ឆ្នាំ២០១៨) នោះទេ។

ដទៃទៀត ការប្រឹក្សាយោបល់អំពីបំណុល ការទប់ស្កាត់ការអនុវត្ត និងសេវាកម្មហួសហេតុ ឬអយុត្តិធម៌ចំពោះអ្នកខ្ចីដែលមានបញ្ហា និងវិធានការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវរបស់ពួកគេ ប្រកបដោយប្រតិសកម្ម។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានវិធានការជាក់លាក់ណាមួយត្រូវបានអនុម័ត ដើម្បីឆ្លើយតបទៅនឹងការសង្កេតទាំងនេះ សម្រាប់ការវិនិយោគជាក់លាក់នោះទេ។

គិតត្រឹមឆ្នាំ២០២០ IFC បានដឹងអំពីហានិភ័យនៃការជំពាក់បំណុលវ័ណ្ឌក នៅកម្ពុជា និងការចោទប្រកាន់អំពីការអនុវត្តការផ្តល់ប្រាក់កម្ចីមានគ្រោះថ្នាក់ ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ផ្នែកសង្គម[428] (សូមមើលផ្នែក ១.២ និងខ្សែបន្ទាត់ពេលវេលានៅក្នុងផ្នែក ៣.៧.២)។ ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវនៃការវិនិយោគដោយផ្ទាល់ចំនួនប្រាំរបស់ខ្លួន ដែលត្រូវបានអនុម័តក្រោយឆ្នាំ២០២០ (ដែលពាក់ព័ន្ធនឹងអេស៊ីលីដា អម្រឹត និងធនាគារហត្ថា) IFC តាមរយៈសកម្មភាពនៅកម្រិតឧស្សាហកម្ម និងគោលនយោបាយរបស់ខ្លួននៅកម្ពុជា (សូមមើលផ្នែក ៤.១ ខាងលើ) បានដឹងពីការចោទប្រកាន់នៅទូទាំងវិស័យថាមានគ្រោះថ្នាក់ផ្នែកសង្គមចំពោះអ្នកខ្ចី។ ទោះបីជាយ៉ាងណាក៏ដោយ នៅគ្រប់ករណីទាំងអស់ ជំនួសឲ្យការអនុវត្តការត្រួតពិនិត្យការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជននៅកម្រិតគម្រោងឲ្យកាន់តែហ្មត់ចត់ ដើម្បីកាត់បន្ថយជៀសវាង និងបន្ធូរបន្ថយគ្រោះថ្នាក់ផ្នែកសង្គមនោះ IFC បានឆ្លើយតបដោយសំដៅលើសកម្មភាពរបស់ខ្លួននៅកម្រិតឧស្សាហកម្ម និងគោលនយោបាយ។ សកម្មភាពទាំងនេះ រួមមាន ឧទាហរណ៍ ការបង្កើត CBC ការសហការរបស់ IFC ជាមួយ CBC NBC និង CMA ដើម្បីលើកកម្ពស់គោលការណ៍ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវដោយស្ម័គ្រចិត្ត និងការអនុវត្តការការពារអតិថិជននៅក្នុងវិស័យនេះ និងសេវាទីប្រឹក្សាដទៃទៀតដែល IFC បានផ្តល់ជូននៅកម្រិតឧស្សាហកម្ម ឬគោលនយោបាយ (សូមមើលផ្នែកទី ៤.១ ខាងលើ)។

អភិក្រមនេះមិនបានគិតគូរពីវិសាលភាព និងការអនុវត្តផ្នែកនិយ័តកម្មដែលកម្រិតនៃវិស័យនេះទេ ទោះបីជាមានការកំណត់ដោយផ្ទាល់របស់ IFC នៅឆ្នាំ២០១៥ ថា ការត្រួតពិនិត្យកាន់តែខ្លាំងក្លាមានសារៈសំខាន់ណាស់ដើម្បីជៀសវាងគ្រោះថ្នាក់ផ្នែកសង្គម និងគំហើញនៃរបាយការណ៍ MIMOSA ដែលរៀបចំដោយ IFC នៅឆ្នាំ២០២០ ថា បទប្បញ្ញត្តិការពារអតិថិជនចាំបាច់ត្រូវមាន "ការពង្រឹងយ៉ាងខ្លាំងក្លា"[429] (សូមមើលផ្នែក ១.១ និង

---

[428] នៅឆ្នាំ២០២០ របាយការណ៍ MIMOSA ដែលរៀបចំដោយ IFC បានសន្និដ្ឋានថា ប្រទេសកម្ពុជាបានឈានដល់កម្រិតអតិបរមានៃតិត្ថិភាពទីផ្សារ។ របាយការណ៍នេះបានគូសបញ្ជាក់ពីអវត្តមាននៃការការពារអ្នកប្រើប្រាស់ និងការត្រួតពិនិត្យផ្នែកនិយ័តកម្ម ជាពិសេសលើការអនុវត្តការប្រមូលបំណុល និងការព្រមានអំពីការកើននៃហានិភ័យនៃការជំពាក់បំណុលវ័ណ្ឌក។ របាយការណ៍ MIMOSA ឆ្នាំ ២០២០ ទំ. ៧ នៅខណៈពេលដែលកង្វល់អំពីផលប៉ះពាល់សង្គមនៃការជំពាក់បំណុលវ័ណ្ឌក ត្រូវបានលើកឡើងជាសាធារណៈយ៉ាងហោចណាស់ចាប់ពីឆ្នាំ២០០៩ មកនោះ ចាប់តាំងពីឆ្នាំ២០០៩ មក ការសិក្សា និងរបាយការណ៍ជាច្រើន (ដែលរៀបចំដោយក្រុមធនាគារពិភពលោក សមាគមឧស្សាហកម្មកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នអង្គការសហប្រជាជាតិ និងស្ថាប័នដទៃទៀត) ត្រូវបានកំណត់ អំពាវនាវ និងព្រមានយ៉ាងជាប់លាប់ អំពីការអនុវត្តហិរញ្ញវត្ថុអវិជ្ជមាន ដែលជម្រុញឱ្យអ្នកខ្ចីកម្ពុជាដែលងាយរងគ្រោះបំផុតងាកទៅរកដំណោះស្រាយដោយការកាត់បន្ថយអាហារ ការលក់ដីធ្លី ការបញ្ឈប់ការសិក្សារបស់កូនៗ ជាយន្តការទប់ទល់នឹងកង្វះខាតសមត្ថភាពក្នុងការសងប្រាក់ រួមជាមួយនឹងការត្រួតពិនិត្យ និងបទប្បញ្ញត្តិរបស់រដ្ឋាភិបាលមានភាពទន់ខ្សោយក្នុងការការពារអ្នកប្រើប្រាស់ និងកង្វះខាតធនធានជំនួស ដើម្បីដោះស្រាយបំណុលរបស់ពួកគេ (សូមមើលផ្នែក ១.២ ខាងលើ)។

[429] នៅឆ្នាំ២០១៦ CMA បានចេញគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីដោយស្ម័គ្រចិត្ត ហើយនៅឆ្នាំ២០២២ ABC និង CMA បានអនុម័តគោលការណ៍ណែនាំទាំងនេះ ជាផ្នែកមួយនៃក្រមសីលធម៌ ដែលត្រូវបានពង្រីកទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់។

ឧបសម្ព័ន្ធ ខ)។[430] ទោះបីជាមានការយល់ដឹងបែបនេះក៏ដោយ ក៏ IFC មិនបានកែសម្រួលដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន ចំពោះការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់ BFIs កម្ពុជា ដើម្បីត្រួតពិនិត្យ និងធានាបាននូវសង្គតិភាពនឹងស្តង់ដារ GIIP និងច្បាប់ជាតិដែលពាក់ព័ន្ធ ស្របតាមលក្ខខណ្ឌតម្រូវនៅក្នុង PS1 នោះទេ។ នៅក្នុងការវិនិយោគភាគច្រើនដែលបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះ IFC បានពឹងផ្អែកលើការរាយការណ៍ដោយខ្លួនឯងរបស់អតិថិជនអំពីភាពអនុលោមនៃគោលនយោបាយរបស់ពួកគេចំពោះ GIIP សម្រាប់ការវិនិយោគមីក្រូហិរញ្ញវត្ថុ ដោយមិនមានការផ្ទៀងផ្ទាត់ ឬពិនិត្យតាមដាននោះទេ។ ក្រោយឆ្នាំ២០១៣ ការដាក់ឱ្យដំណើរការនូវវិញ្ញាបនប័ត្រនៃយុទ្ធនាការឆ្លាតវៃ (សូមមើលខ្សែបន្ទាត់ពេលវេលានៅក្នុងផ្នែក ៣.៧.២) IFC ក៏បានគិតគូរពីសវនកម្មភាគីទីបី និងការបញ្ជាក់អំពីអនុលោមភាពរបស់អតិថិជនចំពោះ GIIP សម្រាប់មីក្រូហិរញ្ញវត្ថុ នៅក្នុងការវិនិយោគដោយផ្ទាល់ចំនួនប្រាំពីរក្នុងចំណោមការវិនិយោគទាំងប្រាំបួន។[431] IFC មិនបានផ្ទៀងផ្ទាត់ភាពអនុលោមនោះដោយផ្ទាល់ទេ ប៉ុន្តែបានរួមបញ្ចូលការព្រមព្រៀងនៅក្នុងកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ ដែលប្តេជ្ញាចិត្តធ្វើឱ្យអតិថិជនអនុលោមតាមស្តង់ដារនៃយុទ្ធនាការឆ្លាតវៃ ឬ GIIP ជាទូទៅ ដើម្បីការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ។[432] ទាំងនេះគឺជាការព្រមព្រៀងមានការបញ្ជាក់ ដែលពុំមានកាតព្វកិច្ចក្នុងការរាយការណ៍នោះទេ។

នៅខណៈពេលដែលការបញ្ជាក់របស់ភាគីទីបីអាចមានប្រយោជន៍ ស៊ីអេអូកត់សម្គាល់ថា វាមិនគួរត្រូវបានចាត់ទុកថាជាការជំនួសឲ្យកាតព្វកិច្ចរបស់ IFC ក្នុងការត្រួតពិនិត្យសមត្ថភាព E&S របស់អតិថិជន និងសមត្ថភាព ESMS ដើម្បីកំណត់ ទប់ស្កាត់ និងកាត់បន្ថយហានិភ័យចំពោះជនងាយរងគ្រោះដែលអនុវត្តតាម GIIP ដូចបានតម្រូវដោយក្របខណ្ឌនិរន្តរភាពនោះទេ។ ការបញ្ជាក់ដែលគួរឲ្យទុកចិត្ត នៅពេលដែលធ្វើឡើងដោយអង្គការឯករាជ្យ អាចផ្តល់ជូននូវការធ្វើសុពលកម្មខាងក្រៅដ៏មានប្រយោជន៍ថា គោលនយោបាយ និងនីតិវិធីរបស់ស្ថាប័នហិរញ្ញវត្ថុបំពេញតាមស្តង់ដារឧស្សាហកម្មដែលត្រូវបានទទួលស្គាល់ ដែលជួយផ្តល់ព័ត៌មានដល់ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC។ ការបញ្ជាក់ទាំងនេះក៏អាចជួយកំណត់ចន្លោះប្រហោង វាយតម្លៃការអនុវត្តធៀបនឹងដៃគូប្រកួតប្រជែង និងលើកទឹកចិត្តឲ្យមានការកែលម្អជាបន្តបន្ទាប់។ ទោះបីជាយ៉ាងណាក៏ដោយ

---

ទោះបីជាយ៉ាងណាក៏ដោយ ស្តង់ដារស្ម័គ្រចិត្តទាំងនេះ អាស្រ័យលើការរាយការណ៍ដោយខ្លួនឯង ដោយ FIs រួមជាមួយលទ្ធភាពក្នុងការអនុវត្តរបស់ CMA បានដាក់កម្រិតលើលិខិតស្តីបន្ទោសមិនសាធារណៈមួយ។ នៅក្នុងឯកសារពាក់ព័ន្ធនឹងការវិនិយោគចំនួន ១៣ ដែលគ្របដណ្តប់នៅក្នុងសំណុំរឿងនេះ IFC បានបញ្ជាក់យ៉ាងខ្ជាប់ខ្ជួនថា ប្រទេសកម្ពុជាមានក្របខណ្ឌនិយ័តកម្មរឹងមាំ ដោយផ្អែកលើប្រព័ន្ធបទប្បញ្ញត្តិនៃការការពារជាច្រើន (ដែលមានបំណងការពារប្រព័ន្ធហិរញ្ញវត្ថុទាំងមូល) ក្នុងការរឹតបន្តឹងការកំណត់តម្លៃ និងហិរញ្ញប្បទានដែលមានហានិភ័យខ្ពស់ បង្កើនភាពគ្រប់គ្រាន់នៃដើមទុន និងបង្កើនសាច់ប្រាក់ងាយស្រួល។ វាមិនបានរួមបញ្ចូលគ្នា នៅក្នុងការវិភាគ ESDD និងការសម្រេចចិត្តដោយមិនមានបទប្បញ្ញត្តិដែលគ្មានការការពារ (ដែលផ្តោតលើការត្រួតពិនិត្យ និងការប្រព្រឹត្តរបស់គ្រឹះស្ថានហិរញ្ញវត្ថុ) រួមទាំងការការពារអតិថិជន ដើម្បីទប់ស្កាត់ ឬកាត់បន្ថយផលប៉ះពាល់សង្គមអវិជ្ជមានលើប្រជាជនដែលងាយរងគ្រោះ ដែលជាគោលដៅនៃមីក្រូហិរញ្ញវត្ថុ។ គណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ បញ្ហាច្បាប់ និងនិយ័តកម្មជុំវិញមីក្រូហិរញ្ញវត្ថុ៖ កំណត់សម្គាល់ដោយលេខាធិការដ្ឋាន ថ្ងៃទី០១ ខែ មេសា ឆ្នាំ២០១១ A/CN ៩/៧២៧ នៅទំ. ៧ និងកថាខណ្ឌ ១៩។

[430] IFC ការលើកកម្ពស់ការការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ឆ្នាំ២០១៥ ទំ. ១០ និង ២៦ មាននៅ https://bit.ly/41LJkma។ របាយការណ៍ MIMOSA ស្តីពីប្រទេសកម្ពុជា ខែមីនា ឆ្នាំ២០២០ ទំ. ៧។

[431] គម្រោងចំនួនពីរ ដែលត្រូវបានអនុម័តនៅក្រោយឆ្នាំ២០១៣ មិននិយាយពីវិញ្ញាបនបត្រនៃយុទ្ធនាការឆ្លាតវៃនោះទេ៖ ការវិនិយោគភាគហ៊ុនរបស់អម្រឹត នៅឆ្នាំ២០១៤ និងប្រាក់កម្ចីរបស់អេស៊ីលីដា នៅឆ្នាំ២០១៩។

[432] ក្នុងករណីមួយចំនួន ដូចជា ការវិនិយោគរបស់ធនាគារហត្ថា លេខ ៤៤២១១ នៅឆ្នាំ២០២០ IFC បានបង្ហាញថា គ្រឹះស្ថានហិរញ្ញវត្ថុបានអនុវត្តតាមគោលការណ៍ណែនាំនៃយុទ្ធនាការឆ្លាតវៃ ស្របពេលជាមួយគ្នានោះ វាបានចង្អុលបង្ហាញថា ធនាគារហត្ថាបានបាត់បង់វិញ្ញាបនបត្រនៃយុទ្ធនាការឆ្លាតវៃដោយសារបុនហិរញ្ញប្បទានដែលមានហានិភ័យខ្ពស់របស់ធនាគានេះលើសកម្រិត ចំនួន ៥%។

ប្រសិទ្ធភាពនៃការបញ្ជាក់បែបនេះអាស្រ័យលើភាពរឹងមាំនៃវិធីសាស្ត្រ ឯករាជ្យភាពរបស់ស្ថាប័នដែលធ្វើការបញ្ជាក់ និងភាពញឹកញាប់ និងភាពស៊ីជម្រៅនៃការត្រួតពិនិត្យរបស់អ្នកផ្តល់ប្រាក់កម្ចី។ ប្រសិនបើគ្មានការការពារទាំងនេះទេ ការបញ្ជាក់អាចផ្តល់ជូនតែរូបភាពមួយផ្នែក ឬហួសសម័យ នៃការអនុវត្តជាក់ស្តែងប៉ុណ្ណោះ។[433]

ស៊ីអេអូកត់សម្គាល់ថា គ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាទាំងបី ដែល IFC មានការវិនិយោគដោយផ្ទាល់ មាន ឬធ្លាប់មានវិញ្ញាបនប័ត្រពីភាគីទីបី។ ទោះបីជាការរាយការណ៍ដោយខ្លួនឯងរបស់អតិថិជន ការប្តេជ្ញាចិត្តដោយមានការបញ្ជាក់នៅក្នុងកិច្ចសន្យាផ្លូវច្បាប់ និងការបញ្ជាក់ពីភាគីទីបីក៏ដោយ ក៏ស៊ីអេអូបានសង្កេតឃើញចន្លោះប្រហោងក្នុងការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់ពួកគេ ស្របតាមស្តង់ដារ GIIP និងលក្ខខណ្ឌតម្រូវនៃច្បាប់ជាតិដែលពាក់ព័ន្ធ ដើម្បីការពារ និងកាត់បន្ថយផលប៉ះពាល់សង្គមអវិជ្ជមានលើប្រជាជនដែលងាយរងគ្រោះ (សូមមើលផ្នែក ៤.២.១)។ សម្រាប់ការវិនិយោគចំនួនពីរនៅធនាគារហត្ថា នៅឆ្នាំ២០២១[434] IFC បានតម្រូវឲ្យអតិថិជនអនុវត្តការវាយតម្លៃហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ តាមរយៈសេវាទីប្រឹក្សារបស់ IFC បន្ទាប់ពីវាបានបាត់បង់វិញ្ញាបនបត្រនៃយុទ្ធនាការឆ្លាតវៃ នៅឆ្នាំ២០១៨។ ការវាយតម្លៃដែលបានធ្វើឡើងនៅចន្លោះខែធ្នូ ឆ្នាំ២០២១ និង ខែកក្កដា ឆ្នាំ២០២២ បានកំណត់ពីការកែលម្អគោលនយោបាយ និងនីតិវិធីរបស់ធនាគារហត្ថា ដែលត្រូវបានដោះស្រាយជាបន្តបន្ទាប់។ មុនពេលត្រួតពិនិត្យនេះ ធនាគារហត្ថាបានទទួលប្រាក់កម្ចីចំនួនប្រាំមួយពី IFC នៅចន្លោះឆ្នាំ២០១៤ និង ឆ្នាំ២០២០[435] ដោយមិនបានកំណត់ចន្លោះប្រហោងទាំងនេះដោយពឹងផ្អែកលើការរាយការណ៍ដោយខ្លួនឯងរបស់អតិថិជន និងវិញ្ញាបនបត្រនៃយុទ្ធនាការឆ្លាតវៃ ដែលបានផ្តល់ជូនក្នុងឆ្នាំ២០១៦។[436]

ការត្រួតពិនិត្យគ្រប់ជ្រុងជ្រោយលើគោលនយោបាយផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន ដែលមានសង្គតិភាពនឹងលក្ខខណ្ឌតម្រូវរបស់ IFC ក្នុងការកំណត់ វាយតម្លៃ និងកាត់បន្ថយផលប៉ះពាល់សង្គមលើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុដែលងាយរងគ្រោះ អាចអនុញ្ញាតឱ្យ IFC កំណត់ចន្លោះប្រហោងនៅក្នុងគោលនយោបាយ និងការអនុវត្តធៀបនឹង PS ដែលពាក់ព័ន្ធ និងផ្តល់ការណែនាំដល់អតិថិជនលើ៖

- **ការកែលម្អការអនុវត្តការវាយតម្លៃបំណុល** តាមរយៈ CBC ដែលត្រូវបានរចនាឡើង និងអនុវត្តដោយការផ្តល់ហិរញ្ញប្បទានរបស់ IFC ដូច្នេះរបាយការណ៍អ្នកខ្ចីត្រូវបានធ្វើឡើងជាភាសាក្នុងស្រុក ហើយមន្ត្រីឥណទានទទួលបានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវអំពីរបៀបបកស្រាយរបាយការណ៍ទាំងនោះ ដើម្បីវាយតម្លៃសមត្ថភាពសងបំណុលរបស់អ្នកខ្ចីឱ្យបានត្រឹមត្រូវ
- **ដាក់កម្រិតការអនុវត្តវត្ថុបញ្ចាំដែលមានគ្រោះថ្នាក់** តាមរយៈការមិនទទួលយកវត្ថុបញ្ចាំជាដីធ្លីជំនួសឲ្យការវាយតម្លៃសមត្ថភាពសងបំណុលរបស់អ្នកខ្ចី និងរួមបញ្ចូលប្រភេទអចលនទ្រព្យមួយចំនួន ដែល

---

[433] A.Ball, D.Owen, R. Gray, តម្លាភាពខាងក្រៅ ឬការចាប់យកផ្ទៃក្នុង? តួនាទីនៃសេចក្តីថ្លែងការណ៍របស់ភាគីទីបី ក្នុងការបន្ថែមគុណតម្លៃដល់របាយការណ៍បរិស្ថាននៃសាជីវកម្ម *យុទ្ធសាស្ត្រអាជីវកម្ម និងបរិស្ថាន* ៩ ១-២៣ ២០០០, https://bit.ly/46S1WSy V. Desai, វិញ្ញាបនបត្រភាគីទីបីជាការទទួលខុសត្រូវលើការអនុវត្តរបស់អង្គការ *ទិនានុប្បវត្តិនៃការគ្រប់គ្រង* ៤៤-៨ ខែវិច្ឆិកា ឆ្នាំ២០១៨ https://bit.ly/46ABXjJ។

[434] IFC គម្រោងលេខ ៤៤៧៤២ និង ៤៥៥៣៥ ដែលត្រូវបានដំណើរការរួមគ្នា។

[435] IFC គម្រោងលេខ ៣៦២៤២ ៣៨២៣៩ ៣៩១៦៧ ៤១២២៣ ៤០៨៩៨ ៤៤២១១ និង ៤៥៩៩៦ និង ៤៥៥៣៥។

[436] ក្នុងចំណោមប្រាក់កម្ចីចំនួនប្រាំពីរ សំណុំរឿងនេះបានរួមបញ្ចូលប្រាក់កម្ចីចំនួនពីរគឺ គម្រោងរបស់ធនាគារហត្ថា លេខ ៣៩១៦៧ និង ៤៤២១១ ដែលត្រូវបានអនុម័តនៅឆ្នាំ២០១៧ និង ឆ្នាំ២០២០ ដាច់ដោយឡែកពីគ្នា។

មិនអាចទទួលយកបាន ដោយសារភាពលំបាក វាអាចបណ្ដាលឱ្យអ្នកខ្ចីងាយរងគ្រោះ (ឧទាហរណ៍ លំនៅឋាន និងដីធ្លីដែលបង្កើតប្រាក់ចំណូល)

- **ពង្រឹងការការពារប្រឆាំងនឹងការប្រមូលប្រាក់ដែលឈ្លានពាន** តាមរយៈការរួមបញ្ចូលការការពារឱ្យបានគ្រប់គ្រាន់ និងពង្រឹងដំណើរការត្រួតពិនិត្យ ដើម្បីទប់ស្កាត់ និងដោះស្រាយឥរិយាបថឈ្លានពានរបស់បុគ្គលិក FI ចំពោះអ្នកខ្ចី។

### *៤.៣.១.៣ សេចក្តីសន្និដ្ឋានអំពីភាពអនុលោមរបស់ IFC ចំពោះលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាព ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ ទាក់ទងនឹងក្រុមងាយរងគ្រោះ*

ផ្អែកតាមព័ត៌មានខាងលើ ស៊ីអេអូរកឃើញថា IFC មិនបានអនុវត្តការត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគរបស់ខ្លួន យោងតាមលក្ខណៈ វិសាលភាព និងភាពជាក់លាក់នៃគម្រោង FI ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាពនោះទេ (គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ១៩ ២១ ៣២ និង ៣៣)។[437] ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC មិនបានកំណត់ភាពងាយរងគ្រោះរបស់អ្នកខ្ចីជាហានិភ័យនោះទេ និងមិនបានកំណត់លក្ខខណ្ឌតម្រូវសមស្រប ដើម្បីគ្រប់គ្រងហានិភ័យទាំងនោះទេ (គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣៤)។[438] ដូច្នេះ តាមរយៈការមិនពិចារណាលើផលប៉ះពាល់សង្គមដែលអាចកើតឡើង ដែលបានដឹង និងមានសារៈសំខាន់ លើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ការចាត់ថ្នាក់ការវិនិយោគរបស់ IFC មិនបានគិតគូរដល់វិសាលភាពពេញលេញនៃហានិភ័យ និងផលប៉ះពាល់ E&S នៃការវិនិយោគមីក្រូហិរញ្ញវត្ថុ នៅក្នុងបរិបទនៃសកម្មភាពអាជីវកម្មនៅកម្ពុជានោះទេ (គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣២ ៣៤ ៤០ និង ៤២)។[439] លើសពីនេះទៀត IFC មិនបានអនុលោមតាមកាតព្វកិច្ចនៃគោលនយោបាយនិរន្តរភាព ទាក់ទងនឹងប្រព័ន្ធគ្រប់គ្រង E&S របស់អតិថិជន FI និងសមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងហានិភ័យ E&S នៃមីក្រូហិរញ្ញវត្ថុ រួមទាំងការកំណត់ ទប់ស្កាត់ និងកាត់បន្ថយហានិភ័យចំពោះអ្នកខ្ចីមីក្រូហិរញ្ញវត្ថុដែលងាយរងគ្រោះ ស្របតាមស្តង់ដារ GIIP និងអនុលោមតាមច្បាប់ជាតិដែលពាក់ព័ន្ធ អនុវត្តតាមលក្ខខណ្ឌតម្រូវនៃ PS1 នោះទេ (គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ២២ ៣១-៣៥)។[440]

ជាលទ្ធផលនៃចន្លោះប្រហោងសំខាន់ៗទាំងនេះ ស៊ីអេអូសន្និដ្ឋានថា ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC មិនស្របតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាពនោះទេ ពីព្រោះវាមិនបានរួមបញ្ចូលការត្រួតពិនិត្យ E&S ឱ្យបានគ្រប់គ្រាន់ និងខកខានឱកាសក្នុងការកំណត់ចន្លោះប្រហោងនៃការវិនិយោគរបស់ខ្លួន ធៀបនឹង PS1 តម្រូវឲ្យមាននីតិវិធានការកែតម្រូវរបស់អតិថិជន និងធានាថា សកម្មភាពដែលទទួលបានហិរញ្ញប្បទានបាន

---

[437] សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ៨ ១៣ ២៧ ២៩។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

[438] សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

[439] សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៣ ១៨ ២៧-២៩។ សម្រាប់ការវិនិយោគនៅ Advans សូមមើល IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

[440] សម្រាប់ការវិនិយោគនៅ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៧ ២៧-២៩។

ជៀសវាង ឬកាត់បន្ថយផលប៉ះពាល់សង្គមអវិជ្ជមានលើអ្នកខ្ចីដែលងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ។

### ៤.៣.២ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា អម្រ៉ឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA

#### *៤.៣.២.១ ការត្រួតពិនិត្យការវិនិយោគដោយផ្ទាល់របស់ IFC (អេស៊ីលីដា អម្រ៉ឹត និងធនាគារហត្ថា)*

IFC បានត្រួតពិនិត្យការវិនិយោគដែលត្រូវបានគ្របដណ្តប់នៅក្នុងសំណុំរឿងនេះ ចាប់ពីឆ្នាំ២០០៥ មកទល់បច្ចុប្បន្ន។ ក្នុងអំឡុងពេលនេះ ដោយសារការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC មិនបានកំណត់ផលប៉ះពាល់ និងហានិភ័យសង្គមអវិជ្ជមាននៃការផ្តល់ប្រាក់កម្ចីរបស់ខ្លួនដល់ប្រជាជនដែលងាយរងគ្រោះ រួមទាំងអ្នកខ្ចីមីក្រូហិរញ្ញវត្ថុផងដែរនោះ IFC មិនបានត្រួតពិនិត្យការគ្រប់គ្រងរបស់អតិថិជន ចំពោះហានិភ័យ និងផលប៉ះពាល់ទាំងនោះ ក្រោយពេលអនុម័តគម្រោងនោះទេ។ កង្វះខាតការត្រួតពិនិត្យនៅក្នុងផ្នែកនេះមានន័យថា IFC មិនបានតម្រូវឲ្យមានការរាយការណ៍ពីអតិថិជនរបស់ខ្លួន ទាក់ទងនឹងវិធានការកាត់បន្ថយផលប៉ះពាល់ និងហានិភ័យសង្គមអវិជ្ជមាន ពីការផ្តល់ប្រាក់កម្ចី ឬការអនុវត្តការប្រមូលរបស់អតិថិជនរបស់ពួកគេនោះទេ។ នៅក្នុងការវិនិយោគចំនួន ៦ ក្នុងចំណោមការវិនិយោគទាំង ១៣ កិច្ចព្រមព្រៀងតាមផ្លូវច្បាប់ បានរួមបញ្ចូលការព្រមព្រៀងមានការបញ្ជាក់ ដែលអតិថិជនបានប្តេជ្ញាចិត្តអនុវត្តស្តង់ដារ GIIP ទាក់ទងនឹងមីក្រូហិរញ្ញវត្ថុ (សូមមើលផ្នែក ៤.៣.១ ខាងលើ)។ ស្តង់ដារទាំងនេះរួមបញ្ចូលបទដ្ឋានដែលបានពិភាក្សាខាងលើ ដើម្បីទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់សង្គមលើប្រជាជនដែលងាយរងគ្រោះ (សូមមើលផ្នែក ៤.២.១)។ ទោះបីជាយ៉ាងណាក៏ដោយ ការព្រមព្រៀងមានការបញ្ជាក់ទាំងនេះមិនកំណត់កាតព្វកិច្ចរាយការណ៍លើអតិថិជននោះទេ ហើយ IFC មានអានុភាព ឬដំណោះស្រាយតិចតួចក្នុងការអនុវត្ត ឬទាមទារឲ្យពួកគេអនុវត្តតាម ដោយខ្វះខាតការលើកឡើងអំពីការមិនបំពេញកាតព្វកិច្ចនៅក្នុងកិច្ចសន្យា។ ស្របពេលជាមួយគ្នានោះ IFC មិនបានប្រើ GIIP ដែលត្រូវបានបង្កើតក្នុងអំឡុងពេលនៃការវិនិយោគរបស់ខ្លួន ក្នុងការធ្វើការជាមួយអតិថិជន ដើម្បីទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់សង្គមអវិជ្ជមាន ព្រមទាំងកែលម្អលទ្ធផលនៃការអភិវឌ្ឍ ដែលជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវទូទៅនៃការមាន ESMS ស្របតាម PS1 នោះទេ។

ជារួម ការត្រួតពិនិត្យការវិនិយោគដោយផ្ទាល់របស់ IFC នៅមានកម្រិត។ ចំពោះការវិនិយោគចំនួនពីរ ក្នុងចំណោមការវិនិយោគទាំងបី ដែលត្រូវបានចាត់ថ្នាក់ជា FI-03 រួមមាន ធនាគារហត្ថា (គម្រោងលេខ ៤៤២១១) និងអម្រ៉ឹត (គម្រោងលេខ ៤៤២៣១) IFC បានសម្រេចចិត្តមិនធ្វើការត្រួតពិនិត្យយ៉ាងសកម្មលើគម្រោងទាំងនេះទេ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃរបស់ខ្លួនថា គម្រោងទាំងនេះបានបង្ហាញថាគ្មាន ឬមានហានិភ័យ E&S កម្រិតទាប។[441]

នៅក្នុងការពិនិត្យតាមដានការវិនិយោគនៅអេស៊ីលីដា (គម្រោងលេខ ៤២៤៨០ និង ៤៤៨៨២) និងធនាគារហត្ថា (គម្រោងលេខ ៤៤៥៣៥ និង ៤៤៧៤២) ដែលត្រូវបានចាត់ថ្នាក់ជា FI-02 នៅចន្លោះឆ្នាំ២០២០ ដល់ឆ្នាំ២០២២ IFC បានកត់សម្គាល់លើរបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយអំពី

[441] គេបានរំពឹងថា អតិថិជនរាយការណ៍អំពីសកម្មភាពហិរញ្ញប្បទានរបស់ខ្លួនទៅកាន់ IFC ដើម្បីឱ្យ IFC បញ្ជាក់ថា វិសាលភាពនៃផលបត្ររបស់អតិថិជនមិនមានការផ្លាស់ប្តូរយ៉ាងខ្លាំងក្លានោះទេ។ ការសម្រេចចិត្តនេះមិនត្រូវបានធ្វើឡើងទាក់ទងនឹងគម្រោង FI-3 ទីបី ដែលត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿងនេះទេ៖ គម្រោងធនាគារ ហត្ថា លេខ ៣៩១៦៧។

ការរំលោភសិទ្ធិមនុស្ស ទាក់ទងនឹងការផ្ដល់ប្រាក់កម្ចីគ្មានទំនួលខុសត្រូវ និងការជំពាក់បំណុលវ័ណ្ឌក ដែលទាក់ទងនឹងអេស៊ីលីដា និងធនាគារហត្ថា។ នៅខណៈពេលដែលរបាយការណ៍ត្រួតពិនិត្យ E&S របស់ IFC បានពិពណ៌នាអំពីបញ្ហាទាំងនេះថាជាបញ្ហាដ៏សំខាន់នោះ ពួកគេមិនបានរួមបញ្ចូលការត្រួតពិនិត្យបន្ថែម ការវិភាគ ឬការពិភាក្សាជាមួយអតិថិជននោះទេ ដោយផ្អែកលើមូលដ្ឋានដែលថា បញ្ហាដែលបានលើកឡើងត្រូវបានចាត់ទុកថាស្ថិតនៅក្រៅវិសាលភាពនៃគោលនយោបាយ E&S របស់ IFC ដូច្នេះវាមិនមែនជាផ្នែកមួយនៃការត្រួតពិនិត្យ E&S នោះទេ។ IFC បានបន្តវាយតម្លៃការអនុវត្ត E&S នៅកម្រិតគម្រោងរបស់ FIs ថាជាការពេញចិត្ត ដោយមិនមានការពិចារណាបន្ថែមលើរបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយនោះទេ។ ចំណុចនេះមិនបានការប្រែប្រួលនោះទេ នៅក្រោយឆ្នាំ២០២១ នៅពេលដែលអង្គភាពនានានៃអង្គការសហប្រជាជាតិបានចាប់ផ្ដើមរាយការណ៍យ៉ាងហោចណាស់មួយឆ្នាំម្ដង អំពីគ្រោះថ្នាក់សង្គមសំខាន់ៗ ដែលបណ្ដាលមកពីការផ្ដល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា (សូមមើលខ្សែបន្ទាត់ពេលវេលានៅផ្នែក ៣.៧.២)។

### *៤.៣.២.២ ការត្រួតពិនិត្យការវិនិយោគដោយផ្ទាល់របស់ IFC នៅ North Haven Thai, Advans, MEF និង MIFA*

អនុវត្តតាមគោលនយោបាយនិរន្តរភាព កាតព្វកិច្ចត្រួតពិនិត្យរបស់ IFC គឺពិនិត្យតាមដានភាពអនុលោមរបស់អតិថិជន តាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្ម តម្រូវឲ្យមានការរាយការណ៍ជាទៀងទាត់អំពីការអនុវត្តលក្ខខណ្ឌតម្រូវ E&S និងត្រួតពិនិត្យព័ត៌មានទាំងនោះ (គោលនយោបាយនិរន្តរភាព កថាខណ្ឌ ៧ ២៤ និង ៤៥)។

ដូចបានពន្យល់ខាងលើ IFC ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ បានតម្រូវឲ្យ មូលនិធិដែលខ្លួនផ្ដល់ហិរញ្ញប្បទាន ដែលជាលទ្ធផល បានផ្ដល់ហិរញ្ញប្បទានដល់ BFIs កម្ពុជា បង្កើត និងអនុវត្ត ESMS។ ចំពោះ MEF MIFA និង North Haven Thai, IFC បានកំណត់លក្ខខណ្ឌតម្រូវថា ESMS មានឧត្តមានុវត្តន៍សម្រាប់មីក្រូហិរញ្ញវត្ថុ ឬឧត្តមានុវត្តន៍សម្រាប់ឧស្សាហកម្ម (សូមមើលផ្នែក ៤.៣.១)។ ជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងរបស់ពួកគេ មូលនិធិទាំងនេះបានរួមបញ្ចូលដំណើរការវាយតម្លៃការអនុវត្តការផ្ដល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជនបន្ត (វិនិយោគិន) ស្របតាម GIIP ជាផ្នែកមួយនៃការត្រួតពិនិត្យភាពត្រឹមត្រូវ និងការពិនិត្យតាមដាន E&S របស់ពួកគេ។ នៅខាងក្រោម ស៊ីអេអូបង្ហាញការវិភាគរបស់ខ្លួនចំពោះការត្រួតពិនិត្យភាពត្រឹមត្រូវរបស់មូលនិធិទាំងនេះ និងការពិនិត្យតាមដានអតិថិជនបន្តរបស់ពួកគេ ស្របតាមលក្ខខណ្ឌតម្រូវ ESMS និងលក្ខខណ្ឌតម្រូវ E&S របស់ IFC។

ចាប់ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៨ MEF មិនបានកំណត់ ត្រួតពិនិត្យ ឬពិនិត្យតាមដានផលប៉ះពាល់លើក្រុមងាយរងគ្រោះ ដូចបានតម្រូវដោយ ESMS ដែលអនុវត្តតាម PS1 នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ វាបានរាយការណ៍អំពីភាពអនុលោមរបស់វិនិយោគិនរបស់ខ្លួន តាម GIIP សម្រាប់មីក្រូហិរញ្ញវត្ថុ ហៅថា គោលការណ៍ការពារអតិថិជន (CPP)[442] ដែល MEF បានរួមបញ្ចូលនៅក្នុងប្រព័ន្ធ E&S និងគំរូរបាយការណ៍ E&S ទៅ

[442] ជាពិសេស វាបានចាប់ផ្ដើមរាយការណ៍អំពីវិនិយោគិន ដែលប្រកាន់ខ្ជាប់នូវគោលការណ៍ការពារអតិថិជន។

IFC។[443] នៅឆ្នាំ២០១០ MEF បានចាប់ផ្តើមរាយការណ៍ទៅកាន់ IFC អំពីការប្រកាន់ខ្ជាប់នៃផលបត្ររបស់ខ្លួនចំពោះ GIIP រួមទាំងឥរិយាបថរបស់បុគ្គលិកប្រកបដោយសីលធម៌ ការអនុវត្តការប្រមូលប្រាក់ដែលសមរម្យ និងការជៀសវាងបំណុលវ័ណ្ឌក។ របាយការណ៍នេះបានប្រមូលផ្តុំចូលគ្នា ដោយមិនបានបញ្ជាក់ពី MFI នីមួយៗនោះទេ ពឹងផ្អែកលើការរាយការណ៍ដោយខ្លួនឯងដោយអតិថិជនបន្តទាំងនេះ និងខ្វះខាតភស្តុតាងនៃការប្រកាន់ខ្ជាប់របស់ MFI ទៅនឹង GIIP។ ដោយសារ MEF មិនបានរាយការណ៍អំពីការប្រកាន់ខ្ជាប់របស់ MFI នីមួយៗ ចំពោះស្តង់ដារទាំងនេះទេ ស៊ីអេអូមិនមានព័ត៌មានថាតើអតិថិជនបន្តរបស់ MEF (ធនាគារហត្ថា ប្រាសាក់ អម្រឹត និងអិលអូអិលស៊ី) បានអនុវត្ត GIIP ដើម្បីកំណត់ ទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់សង្គមលើក្រុមងាយរងគ្រោះ រួមទាំងអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ តាមរយៈការអនុវត្ត CPP ដែរឬអត់នោះទេ។ ចាប់ពីឆ្នាំ២០១៦ មក MEF បានផ្តល់របាយការណ៍លម្អិតអំពី MFI នីមួយៗបន្ថែមទៀត ដល់ IFC ស្តីពីការអនុវត្តការងារសង្គម និងសូចនាករ CPP ដូចជា គុណភាពនៃផលបត្រ (សូចនាករការជៀសវាងបំណុលវ័ណ្ឌករបស់អតិថិជន) សោហ៊ុយនៃប្រាក់កម្ចីជាមធ្យម និងការប្រព្រឹត្តិចំពោះអតិថិជនដោយការគោរព។ ជាថ្មីម្តងទៀត របាយការណ៍ទាំងនេះផ្អែកលើការរាយការណ៍ដោយខ្លួនឯងដោយវិនិយោគិន និងមិនបានរៀបរាប់លម្អិតអំពីរបៀបដែល MEF វាយតម្លៃភាពអនុលោមរបស់ខ្លួនចំពោះសូចនាករការអនុវត្តការងារសង្គមនោះទេ។

ការត្រួតពិនិត្យរបស់ IFC លើរបាយការណ៍ E&S របស់ MEF ម្តងម្កាល បានកត់សម្គាល់ព័ត៌មានរបស់ MEF ស្តីពីការអនុវត្តការងារសង្គមរបស់វិនិយោគិន និងភាពអនុលោមតាម GIIP ប៉ុន្តែភាគច្រើនផ្តោតលើការពិនិត្យ និងការត្រួតពិនិត្យរបស់អ្នកគ្រប់គ្រងមូលនិធិរបស់ធនាគារ និងវិនិយោគិន MFI។ ការត្រួតពិនិត្យរបស់ IFC នៅចន្លោះឆ្នាំ២០១០ និង ឆ្នាំ២០១៨ បានកត់សម្គាល់ថា ទីប្រឹក្សាផ្នែកវិនិយោគចំនួនបីរបស់ MEF គឺ Cyrano, BlueOrchard និង responsAbility (សូមមើលផ្នែក ២.១.៤) មិនមានប្រព័ន្ធគ្រប់គ្រង E&S ដូចបានតម្រូវដោយគោលនយោបាយ E&S របស់ IFC នោះទេ ប៉ុន្តែបានប្រើប្រាស់ប្រព័ន្ធវាយតម្លៃ ESG ផ្ទៃក្នុង នៅក្នុងការសម្រេចចិត្តលើការវិនិយោគរបស់ពួកគេ។ IFC មិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវនៃចំណាត់ការបន្ថែម ឬស្នើឱ្យមានការចុះសម្រុងគ្នានៃនីតិវិធី E&S ដើម្បីអនុញ្ញាតឱ្យមានការត្រួតពិនិត្យកាន់តែមានប្រសិទ្ធភាព និងដូចគ្នានោះទេ។[444]

ចាប់ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១៨ របាយការណ៍របស់ MEF បានយោងដល់យុទ្ធនាការឆ្លាតវៃ និងសូចនាករដែលពាក់ព័ន្ធ ទោះបីជាមិនតម្រូវឲ្យមានការបញ្ជាក់នៅក្នុងមូលនិធិទាំងមូលក៏ដោយ។[445] នៅឆ្នាំ២០១៩ Incofin

[443] ស៊ីអេអូមិនមានកំណត់ត្រានៃរបាយការណ៍ E&S របស់ MEF ក្រោយឆ្នាំ២០១៨ និងការពិនិត្យតាមដានរបស់ IFC នៅឆ្នាំ២០២២ និង ឆ្នាំ២០២៣ នោះទេ។

[444] BlueOrchard និង responsAbility មានប្រព័ន្ធដាក់ពិន្ទុ/វាយតម្លៃ/ពិនិត្យតាមដាន ESG ផ្ទៃក្នុងជាផ្លូវការ (BlueOrchard ប្រើ SPIRIT (ឧបករណ៍ឆ្លាតវៃក្នុងការរាយការណ៍អំពីការអនុវត្តការងារ និងផលប៉ះពាល់សង្គម) នៅខណៈពេលដែល Cyrano មិនមានប្រព័ន្ធផ្លូវការនោះទេ។

[445] ពួកគេមិនតម្រូវឲ្យមានការបញ្ជាក់ CPP ទេ ប៉ុន្តែ MEF បានរាយការណ៍ថា BlueOrchard បានលើកទឹកចិត្តឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់ខ្លួនទទួលបានការបញ្ជាក់នេះ ដែលត្រូវបានពិចារណានៅក្នុងការវាយតម្លៃរបស់ពួកគេ។ Incofin បានចូលរួមនៅឆ្នាំ ២០១៩ និងបានរួមបញ្ចូលលក្ខខណ្ឌតម្រូវនៃការបញ្ជាក់នេះ នៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចីរបស់ពួកគេ ប៉ុន្តែមិនបានអនុវត្តនៅក្នុងមូលនិធិទាំងមូលនោះទេ។

បានចូលមកធ្វើជាទីប្រឹក្សាវិនិយោគថ្មី[446] និងបានបន្តគ្រប់គ្រងការវិនិយោគរបស់ MEF នៅក្នុងអម្រឹត និង អិលអូអិលស៊ី។ នៅឆ្នាំដដែលនោះ MEF បានអនុម័តការប្រើប្រាស់ ALINUS នៅក្នុងមូលនិធិទាំងមូល ជាឧបករណ៍ដែលបង្កើតឡើងដោយ CERISE មិនស្វែងរកប្រាក់ចំណេញ និងប្រើប្រាស់ដោយ Incofin សម្រាប់សម្របសម្រួលការវិភាគការអនុវត្តការងារសង្គម។ នៅឆ្នាំ២០២១ ក្រុមការងារ E&S របស់ IFC បានគូសបញ្ជាក់អំពីការប្រើប្រាស់ឧបករណ៍នេះរបស់ MEF និងបានកត់សម្គាល់ថា វិនិយោគិនរបស់ MEF បានបង្ហាញថាមានការអនុវត្តការងារសង្គមខ្លាំងជាងមូលនិធិដែលជាមិត្តរបស់ពួកគេ ដូចបានបញ្ជាក់អះអាងដោយពិន្ទុ ALINUS ខ្ពស់ជាង។ នៅឆ្នាំ២០២០ IFC បានកត់សម្គាល់នៅក្នុងការត្រួតពិនិត្យ E&S របស់ MEF ថា កិច្ចព្រមព្រៀងប្រាក់កម្ចី Incofin ដែលបានរួមបញ្ចូលការព្រមព្រៀងផ្នែកសង្គម ដូចជា ការយល់ព្រម និងការអនុវត្ត CPPs និងខចែងអំពីការកំណត់តម្លៃប្រកបដោយទំនួលខុសត្រូវ។ ទោះបីជាយ៉ាងណាក៏ដោយ IFC មិនបានតាមដាន ឬវាយតម្លៃបន្ថែមលើការអនុវត្ត GIIP ដោយមូលនិធិ ឬវិនិយោគិនដោយផ្ទាល់នោះទេ។

MIFA ដែលគ្រប់គ្រងដោយ BlueOrchard ក៏បានរាយការណ៍ទៅ IFC អំពី CPP ប៉ុន្តែមិនបានលើកឡើងយ៉ាងជាក់លាក់អំពីផលប៉ះពាល់ និងវិធានការដែលអាចមាន សម្រាប់ប្រជាជនដែលងាយរងគ្រោះនោះទេ។ BlueOrchard ជូនដំណឹងទៅកាន់ថា វាបានត្រួតពិនិត្យភាពត្រឹមត្រូវនៅនឹងកន្លែង និងពិនិត្យតាមដានអតិថិជនបន្ត រៀងរាល់បីឆ្នាំម្តង។ អ្នកគ្រប់គ្រងមូលនិធិមិនតម្រូវឱ្យមានការបញ្ជាក់លើព័ត៌មាន E&S របស់វិនិយោគិនពីភាគីទីបីនោះទេ ប៉ុន្តែបានប្រើឧបករណ៍ដែលហៅថា SPIRIT[447] ជាតារាងពិន្ទុសម្រាប់ផលប៉ះពាល់ ESG ដោយផ្អែកលើការរាយការណ៍របស់វិនិយោគិន។[448]

---

[446] របាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ MEF ទំ. ១ https://bit.ly/4lcFoT6។ Incofin ធ្វើការត្រួតពិនិត្យភាពត្រឹមត្រូវនៅនឹងកន្លែង និងចុះពិនិត្យតាមដានជារៀងរាល់ឆ្នាំ ក្នុងអំឡុងពេលដែលពួកគេត្រួតពិនិត្យគោលនយោបាយ និងឯកសារកម្ចី និងការគ្រប់គ្រងការសម្ភាស បុគ្គលិកសាខា និងអតិថិជន។ ការត្រួតពិនិត្យរបស់ Inconfin ក៏គ្របដណ្តប់លើយន្តការតវ៉ា កម្រិតនៃការរឹបអូសវត្ថុបញ្ចាំ ការត្រួតពិនិត្យកម្រិតទីផ្សារ ការវាយតម្លៃការអនុវត្តសង្គមរបស់ ALINUS និងការវាយតម្លៃរបស់ភាគីទីបីដូចជា Decibels ពួកគេតាមដានគោលដៅសង្គមផ្សេងទៀត ដូចជាការប្តេជ្ញាចិត្តចំពោះគោលដៅសង្គម ការបំពេញតម្រូវការផលិតផលរបស់អតិថិជន ការប្រព្រឹត្តិចំពោះអតិថិជនប្រកបដោយទំនួលខុសត្រូវ និងការរក្សាតុល្យភាពនៃការអនុវត្តការងារសង្គម និងហិរញ្ញវត្ថុ។ Incofin បានរួមបញ្ចូលផងដែរនូវតម្រូវការសម្រាប់ការបញ្ជាក់ CPP នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ខ្លួន។ ចាប់ពីឆ្នាំ២០២២ មក Incofin បានបង្កើនស្តង់ដារដល់វិញ្ញាបនបត្រ GOLD SPTF/Cerise សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ដោយសារស្ថានភាពជំពាក់បំណុលច្រើនលើសកម្រិតស្តង់ដារទីផ្សារ។

[447] ឧបករណ៍ SPIRIT វាយតម្លៃគោលនយោបាយនានា។ កាតពិន្ទុផលប៉ះពាល់ ESG វាយតម្លៃសក្តានុពលនៃផលប៉ះពាល់ ដោយផ្តល់ពិន្ទុរួម ដែលត្រូវតែលើសពី ៥០ ដើម្បីទទួលបានការអនុម័ត។ ទិន្នន័យបានមកពីវិនិយោគិនជាចម្បង រួមជាមួយកត្តាមួយចំនួនដែលត្រូវបានវាយតម្លៃដោយប្រើទិន្នន័យខាងក្រៅ (ដូចជាព័ត៌មានកម្រិតប្រទេស) និងទិន្នន័យដទៃទៀតបានមកពីពិន្ទុឥណទានរបស់ BlueOrchard។ ក្នុងអំឡុងពេលត្រួតពិនិត្យការពិត និងផ្តល់មតិយោបល់ MIFA បានលើកឡើងថា SPIRIT បានវិវត្តទៅជា B.Impact នៅឆ្នាំ២០២៣ ដោយមានកាតពិន្ទុចំនួនពីរ កាតទីមួយសម្រាប់វាយតម្លៃផលប៉ះពាល់ និងកាតទីពីរសម្រាប់វាយតម្លៃហានិភ័យ។ កាតពិន្ទុទាំងពីរផ្តល់ពិន្ទុជារួម ដែលត្រូវតែលើសពី ៥០ ដើម្បីទទួលបានការអនុម័ត។

[448] ការត្រួតពិនិត្យភាពត្រឹមត្រូវនៅនឹងកន្លែង រួមមាន នីតិវិធី និងការត្រួតពិនិត្យប្រាក់កម្ចី ការចុះទៅកាន់សាខា និងការសម្ភាសអ្នកខ្ចីក្នុងករណីមានកង្វល់។ BlueOrchard បានចែករំលែកជាមួយស៊ីអេអូថា ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ពួកគេធ្វើឡើងនៅកម្រិតដំណើរការ មិនមែនកម្រិតប្រតិបត្តិការទេ។ ការត្រួតពិនិត្យត្រូវបានធ្វើឡើងប្រចាំត្រីមាស ដោយរួមបញ្ចូលព័ត៌មានទាក់ទងនឹងផលប៉ះពាល់ ការវិភាគផលបត្រតាមភូមិសាស្ត្រ និងយេនឌ័រ និងផលជះនៃទិន្នន័យដែលទាក់ទងនឹង KPI។ រៀងរាល់ពីរទៅបីឆ្នាំម្តង ការចុះត្រួតពិនិត្យនៅទីវាលត្រូវបានធ្វើឡើង ដែលរួមបញ្ចូលការគ្រប់គ្រង និងការត្រួតពិនិត្យសាខា ដោយការចុះសួរសុខទុក្ខអ្នកខ្ចីត្រូវធ្វើឡើងតែក្នុងករណីពិសេសប៉ុណ្ណោះ។ លើសពីនេះទៀត ការត្រួតពិនិត្យភាពត្រឹមត្រូវដោយផ្តោតលើហានិភ័យចំពោះមុខអាចកើតឡើង និងអាចតម្រូវឲ្យមានការផ្តោតលើហានិភ័យពិសេសណាមួយ ដែលស្ថាប័នអាចប្រឈមមុខ។

ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៧[449] របាយការណ៍ផ្ទាល់ខ្លួនរបស់ MIFA បានរួមបញ្ចូលកម្រងសំណួរដែលបំពេញដោយ MFIs នៅក្នុងផលបត្ររបស់ខ្លួន ដោយបង្ហាញថាតើពួកគេបានអនុម័តគោលការណ៍ដើម្បីធានាបាននូវការប្រព្រឹត្តិដោយយុត្តិធម៌ចំពោះអ្នកខ្ចី ដូចជា យុទ្ធនាការឆ្លាតវៃ CPPs ដែរឬទេ។ នៅឆ្នាំ២០១៤ អម្រឹត និងធនាគារហត្ថា បានបង្ហាញថា ពួកគេបានចារអនុម័តលើ CPP ហើយនៅឆ្នាំបន្តបន្ទាប់ទៀត អិលអូអិលស៊ី ស្ថាបនា និងប្រាសាក់ក៏បានបញ្ជាក់ពីការចារអនុម័តរបស់ពួកគេដែរ។ ទោះបីជាយ៉ាងណាក៏ដោយ នៅឆ្នាំ២០២០ MIFA បានរាយការណ៍ថា ស្ថាបនាបានឆ្លើយថា "ទេ" ចំពោះការចារអនុម័តលើ CPP ដែលជាសញ្ញានៃការជូនដំណឹងប្រកបដោយសក្តានុពលថា IFC មិនបានតាមដានការងារនេះទេ។ ការត្រួតពិនិត្យរបស់ IFC លើរបាយការណ៍ E&S របស់ MIFA បានផ្តោតលើដំណើរការរបស់ BlueOrchard ហើយចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០២២ IFC មិនបានតាមដានការអនុវត្ត CPP ដោយវិនិយោគិន MIFA នោះទេ។[450]

North Haven Thai ដែលជាម្ចាស់ភាគហ៊ុន ៣,៥% នៅអេស៊ីលីដា មិនបានរាយការណ៍ច្បាស់លាស់អំពីសមិទ្ធកម្មរបស់អេស៊ីលីដា ទាក់ទងនឹងផលប៉ះពាល់នៃសកម្មភាពរបស់ខ្លួនលើអ្នកខ្ចីដែលងាយរងគ្រោះ ឬផ្តល់ព័ត៌មានអំពីរបៀបដែលខ្លួនកំពុងត្រួតពិនិត្យការអនុវត្តរបស់វិនិយោគិនរបស់ខ្លួននោះទេ។ នៅក្នុងរបាយការណ៍ E&S ប្រចាំឆ្នាំ២០២៣ របស់ខ្លួន North Haven Thai បានជូនដំណឹងដល់ IFC ថា ESAP បានយល់ព្រមជាមួយអេស៊ីលីដា រួមបញ្ចូលលក្ខខណ្ឌតម្រូវមួយដែលថា វិនិយោគិនអនុវត្តយុទ្ធនាការឆ្លាតវៃនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន ដោយកត់សម្គាល់ថា ដំណើរការនេះកំពុងតែបន្ត។ IFC មិនបានតាមដាន ESAP រវាង North Haven Thai និងអេស៊ីលីដា ទាក់ទងនឹងភាពអនុលោមតាម GIIP នោះទេ ប៉ុន្តែវាបានផ្តល់អនុសាសន៍ឲ្យអ្នកគ្រប់គ្រងមូលនិធិបង្កើតអភិក្រមដែលមានរចនាសម្ព័ន្ធសម្រាប់ពិនិត្យតាមដានការអនុវត្ត ESAP នៅទូទាំងការវិនិយោគរបស់ខ្លួន និងតាមដានឱ្យបានដិតដល់បន្ថែមទៀតលើការបិទរបស់ពួកគេ។

ជាចុងក្រោយ Advans បានចាប់ផ្តើមរាយការណ៍ទៅកាន់ IFC អំពីការប្តេជ្ញាចិត្តក្នុងការអនុវត្តរបស់ខ្លួន រួមទាំងការអនុវត្តអាជីវកម្មប្រកបដោយនិរន្តរភាព និងទំនួលខុសត្រូវ ចាប់ពីឆ្នាំ២០០៩ មក។ ចាប់ពីឆ្នាំ២០១១ មក វាបានរួមបញ្ចូលបច្ចុប្បន្នភាពអំពីការប្តេជ្ញាចិត្តរបស់សាខារបស់ខ្លួនក្នុងការទប់ស្កាត់ការជំពាក់បំណុលវ័ណ្ឌ និងធានាបាននូវការប្រព្រឹត្តិដោយយុត្តិធម៌ និងការគោរពចំពោះអតិថិជន រួមទាំងតាមរយៈការអនុម័តគោលការណ៍ការពារអតិថិជនផងដែរ។ នៅចន្លោះឆ្នាំ២០១១ និង ឆ្នាំ២០១៤ Advans បានជូនដំណឹងដល់ IFC ថាសាខារបស់ខ្លួនបានប្រើវិធីសាស្រ្តផ្តល់ប្រាក់កម្ចីផ្អែកលើលំហូរសាច់ប្រាក់ដើម្បីវិភាគសមត្ថភាពសងប្រាក់របស់អតិថិជន[451] ពិនិត្យតាមដានគុណភាពសេវាកម្មដែលបានផ្តល់ និងអនុវត្តក្របខណ្ឌដែលបានកំណត់ សម្រាប់ការទារបំណុល ដើម្បីជៀសវាងវិធីសាស្រ្តដោយបង្ខិតបង្ខំ។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានព័ត៌មានជាក់លាក់ស្តីពីការអនុវត្តដោយសាខាខុសៗគ្នា រួមទាំង អម្រឹត ត្រូវបានផ្តល់ជូននោះទេ។ នៅឆ្នាំ២០១៤ Advans បានជូនដំណឹងទៅកាន់ IFC ថា អម្រឹតកំពុងទទួលបានវិញ្ញាបនបត្របញ្ជាក់ពីភាពអនុលោមតាម

[449] ស៊ីអេអូមិនមានកំណត់ត្រានៃរបាយការណ៍ E&S របស់ MEF ចាប់ពីឆ្នាំ២០២២ និង ឆ្នាំ២០២៣ និងការពិនិត្យតាមដានរបស់ IFC នៅឆ្នាំ២០២៣ នោះទេ។

[450] នៅឆ្នាំ២០២១ BlueOrchard បានធ្វើការស្ទង់មតិអតិថិជនចុងក្រោយ និងបានបង្ហាញថា អតិថិជន ៣២១ នាក់ ត្រូវបានជ្រើសរើសដោយចៃដន្យ សម្រាប់ MFI នីមួយៗនៅកម្ពុជា ដែលក្នុងនោះ អ្នកខ្ចីដែលត្រូវបានស្ទង់មតិ ៩៩% បាននិយាយថា បុគ្គលិក MFI មិនធ្លាប់ណែនាំឱ្យពួកគេលក់ដីរបស់ពួកគេដើម្បីសងប្រាក់កម្ចី ឬបង្ខំពួកគេឱ្យចុះហត្ថលេខាលើឯកសារដោយគ្មានសីលធម៌នោះទេ។

[451] Advans បានផ្តល់ព័ត៌មានលម្អិតបន្ថែមទៀត ដែលបង្ហាញថា សាខារបស់ Advans បានចុះមើលផ្ទះ និងអាជីវកម្ម អនុវត្តការត្រួតពិនិត្យជាប្រព័ន្ធលើប្រវត្តិហិរញ្ញវត្ថុរបស់អតិថិជន ធ្វើការជាមួយក្រេឌីតប៊្យូរ៉ូ តាមដែលអាចធ្វើបាន។

គោលការណ៍នៃយុទ្ធនាការឆ្លាតវៃ។ នៅឆ្នាំ២០១៥ កំណត់ត្រាការត្រួតពិនិត្យ E&S របស់ IFC បានកត់សម្គាល់ថា សាខានានាត្រូវបានតម្រូវឱ្យដាក់ជូននូវការវាយតម្លៃដោយខ្លួនឯងលើយុទ្ធនាការឆ្លាតវៃប្រចាំឆ្នាំ ដោយមិនមានការពិភាក្សាបន្ថែមនោះទេ។ ដូចគ្នានឹងមូលនិធិដទៃទៀតដែរ ឯកសារត្រួតពិនិត្យរបស់ IFC លើការវិនិយោគរបស់ Advans មិនបានពិពណ៌នាអំពីការពិចារណាជាក់លាក់លើប្រជាជនដែលងាយរងគ្រោះ ឬវិធានការដើម្បីការពារពួកគេនោះទេ។

#### *៤.៣.២.៣ សេចក្តីសន្និដ្ឋានអំពីភាពអនុលោមតាមគោលនយោបាយនិរន្តរភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យ ទាក់ទងនឹងក្រុមងាយរងគ្រោះ*

ស៊ីអេអូរកឃើញថា IFC មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ស្របតាមគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២[452] ដើម្បីធានាថា តាមរយៈការពិនិត្យតាមដាន និងការត្រួតពិនិត្យ ការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ត្រូវបានអនុវត្តតាមរបៀបដែលស្របតាមស្តង់ដារសមិទ្ធកម្មទី១ ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ និងបទប្បញ្ញត្តិជាតិដែលពាក់ព័ន្ធ។ IFC មិនបានបង្កើតលក្ខខណ្ឌតម្រូវចំពោះការវាយការណ៍ ឬការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលបំណុលដែលអាចប៉ះពាល់ជាអវិជ្ជមានដល់អ្នកខ្ចីដែលងាយរងគ្រោះនោះទេ។

មួយផ្នែក បញ្ហានេះបណ្តាលមកពី IFC មិនបានទទួលស្គាល់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ និងគ្រួសាររបស់ពួកគេ ជាក្រុមងាយរងគ្រោះក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ ដែលមានន័យថា ហានិភ័យ និងផលប៉ះពាល់សង្គមដែលពាក់ព័ន្ធមិនត្រូវបានរួមបញ្ចូលនៅក្នុងការត្រួតពិនិត្យរបស់ IFC លើការវិនិយោគ នៅក្នុងសំណុំរឿងនេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ IFC ក៏មិនបានគិតគូរពីការកើនឡើងនៃកង្វល់អំពីហានិភ័យនៃការជំពាក់បំណុលវ័ណ្ឌក ដែលទាក់ទងនឹងមីក្រូហិរញ្ញវត្ថុ និងគ្រោះថ្នាក់សង្គមធ្ងន់ធ្ងរដែលពាក់ព័ន្ធ នៅកម្ពុជា ដែលបានលើកឡើងពីឆ្នាំ២០០៩ មក។ ទោះបីជាមានភស្តុតាងកាន់តែច្រើនពីធនាគារពិភពលោក ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងស្ថាប័នដទៃទៀតក៏ដោយ ក៏ IFC មិនបានកែសម្រួលការត្រួតពិនិត្យលើការវិនិយោគទាំង១៣ ដើម្បីធានាថាសកម្មភាពអាជីវកម្មរបស់អតិថិជនអនុលោមតាម PS1 រួមទាំងការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ដែលបានបង្កើតឡើង ដើម្បីកំណត់ ជៀសវាង និងកាត់បន្ថយផលប៉ះពាល់សង្គមអវិជ្ជមានដល់អ្នកខ្ចីដែលងាយរងគ្រោះ និងគ្រួសាររបស់ពួកគេនោះទេ។

### ៤.៣.៣ សេចក្តីសន្និដ្ឋានអំពីភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគរបស់ខ្លួន

ស៊ីអេអូរកឃើញថា IFC មិនបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការធានា៖

- តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ ការពិនិត្យតាមដាន និងការត្រួតពិនិត្យរបស់ខ្លួន ដើម្បីធានាថាសកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ហិរញ្ញប្បទានបំពេញតាមលក្ខខណ្ឌតម្រូវនៃ PS1 ក្នុងរយៈពេលសមហេតុផល ឬដើម្បីការពារក្រុមងាយរងគ្រោះដោយការរចនា និងការអនុវត្តការវិនិយោគរបស់ខ្លួន ដោយមានបំណង "មិនបង្កគ្រោះថ្នាក់" ដល់ប្រជាជន "ដើម្បីពង្រឹងនិរន្តរភាពនៃប្រតិបត្តិការរបស់វិស័យឯកជន" និងដើម្បីធានាថាសោហ៊ុយនៃការអភិវឌ្ឍសេដ្ឋកិច្ច

[452] គោលនយោបាយនិរន្តរភាព ឆ្នាំ ២០១២ កថាខណ្ឌ ៤៥

មិនធ្លាក់លើជនក្រីក្រ ឬងាយរងគ្រោះដោយមិនសមាមាត្រនោះទេ (គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៧ ៩ និង ២២)។

- អតិថិជន និងអតិថិជនបន្តរបស់ខ្លួន បានបង្កើត និងអនុវត្ត ESMS ស្របតាម PS1 ដោយមានសមត្ថភាពកំណត់អត្តសញ្ញាណបុគ្គល និងក្រុមដែលអាចរងផលប៉ះពាល់ដោយផ្ទាល់ និងខុសៗគ្នា ឬមិនសមាមាត្រ ដោយសារស្ថានភាពលំបាក ឬស្ថានភាពងាយរងគ្រោះរបស់ពួកគេ និងស្នើ និងអនុវត្តវិធានការខុសៗគ្នា ដើម្បីកុំឱ្យផលប៉ះពាល់អវិជ្ជមានធ្លាក់លើពួកគេដោយមិនសមាមាត្រ ឬកំណត់ ទប់ស្កាត់ និងកាត់បន្ថយហានិភ័យ និងផលប៉ះពាល់សង្គម ដោយអនុវត្តតាម GIIP (គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៣ និង ៣៥ និង PS1 កថាខណ្ឌ ៧ និង ១២)។[453]
- ថាអតិថិជន និងអតិថិជនបន្តរបស់ខ្លួនបានអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែលពាក់ព័ន្ធ ប្រឆាំងនឹងការគំរាមកំហែង និងការបំភិតបំភ័យ និងការចូលរួមរបស់អាជ្ញាធរមូលដ្ឋានក្នុងសកម្មភាពរបស់ BFIs ដែលអាចបង្កើតការយល់ច្រឡំរវាងសកម្មភាពរបស់រដ្ឋ និងវិស័យឯកជន ដូចបានតម្រូវដោយគោលនយោបាយ E&S របស់ខ្លួន (គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៥ ទិដ្ឋភាពទូទៅនៃ PS កថាខណ្ឌ ៥)។[454]

## ៤.៤ អនុលោមភាពរបស់ IFC ចំពោះកាតព្វកិច្ចនៃក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច

អតិថិជនមីក្រូហិរញ្ញវត្ថុរបស់ IFC នៅកម្ពុជា ធ្វើប្រតិបត្តិការនៅតំបន់ដែលមានជនជាតិដើមភាគតិច (IPs) រស់នៅ និងកំពុងខ្ចីប្រាក់ពី BFIs។ ដូចបានពិពណ៌នានៅក្នុងផ្នែក ៣.៧ និង ៤.២.២ គោលនយោបាយ E&S របស់ IFC មានលក្ខខណ្ឌតម្រូវជាក់លាក់ សម្រាប់អតិថិជន ដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានចំពោះជនជាតិដើមភាគតិច តាមរយៈការបង្កើត ESMS ដែលប្រកាន់ខ្ជាប់នូវ៖

- គោលការណ៍នៃ PS1 ដើម្បីកំណត់ផលប៉ះពាល់ និងអនុវត្តវិធានការកាត់បន្ថយ ស្របតាម GIIP
- លក្ខខណ្ឌតម្រូវនៃ PS7 ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច និងកែសម្រួលដំណើរការតាមវប្បធម៌ និងការអនុវត្តរបស់ពួកគេ
- បញ្ជីផាត់ចេញ របស់ IFC ដែលហាមឃាត់សកម្មភាពមីក្រូហិរញ្ញវត្ថុ ដែលប៉ះពាល់ដល់ដីសហគមន៍ជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីសហគមន៍[455]
- ច្បាប់ជាតិដែលពាក់ព័ន្ធ ដែលនៅប្រទេសកម្ពុជា ហាមឃាត់អ្នកផ្តល់ប្រាក់កម្ចីមិនឲ្យទទួលយកដីជនជាតិដើមភាគតិចជាវត្ថុបញ្ចាំនោះទេ។

---

[453] សម្រាប់ការវិនិយោគរបស់ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៧-២៩ និង PS1 ឆ្នាំ២០០៦ កថាខណ្ឌ ៤ ៨ និង ១២។ សម្រាប់ការវិនិយោគរបស់ Advans សូមមើល ESRP ឆ្នាំ១៩៩៨ កថាខណ្ឌ ២២ ជើងទំព័រទី ៧។

[454] សម្រាប់ការវិនិយោគរបស់ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨ ទិដ្ឋភាពទូទៅនៃ PS កថាខណ្ឌ ៣ និង សម្រាប់ការវិនិយោគរបស់ Advans សូមមើល IFC OP ៤.០១ កថាខណ្ឌ ៩។

[455] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៥, PS1 ឆ្នាំ២០១២ កថាខណ្ឌ ៧ និង PS7 ឆ្នាំ២០១២ កថាខណ្ឌ ១ ៨ និង ៩ និងបញ្ជីផាត់ចេញរបស់ IFC។ សម្រាប់ការវិនិយោគនៅ MEF សូមមើលគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨, PS1 ឆ្នាំ២០០៦ កថាខណ្ឌ ៤, PS7 ឆ្នាំ២០០៦ កថាខណ្ឌ ១ ៧ និង ៨។

### ៤.៤.១ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវលើការវិនិយោគរបស់ខ្លួននៅ អេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA

គោលនយោបាយនិរន្តរភាពតម្រូវថា ក្នុងដំណាក់កាលមុនពេលវិនិយោគ IFC ត្រូវ៖

- ត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់អតិថិជន FI ដើម្បីកំណត់ហានិភ័យដែលអាចកើតឡើងចំពោះជនជាតិដើមភាគតិច[456]
- ត្រួតពិនិត្យសមត្ថភាព E&S និង ESMS របស់អតិថិជន និងសមត្ថភាពរបស់វាក្នុងការកំណត់ ទប់ស្កាត់ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច ស្របតាម PS1 PS7 GIIP ដែលពាក់ព័ន្ធ ច្បាប់ជាតិដែលពាក់ព័ន្ធ និងបញ្ជីផាត់ចេញរបស់ IFC
- តម្រូវឱ្យអតិថិជនបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះក្នុងអំឡុងពេលវិនិយោគ។

#### *៤.៤.១.១ ការកំណត់ និងត្រួតពិនិត្យផលប៉ះពាល់ដែលអាចកើតចេញពីសកម្មភាពរបស់ FI លើជនជាតិដើមភាគតិច និងសមត្ថភាពរបស់អតិថិជន និង ESMS*

ការស៊ើបអង្កេតរបស់ស៊ីអេអូរកមិនឃើញភស្តុតាងដែលថា IFC បានត្រួតពិនិត្យហានិភ័យ និងផលប៉ះពាល់ដែលអាចកើតឡើងចំពោះអ្នកខ្ចីជា IP ដោយសារការវិនិយោគដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគនោះទេ។ ស៊ីអេអូក៏រកមិនឃើញភស្តុតាងដែលថា IFC បានត្រួតពិនិត្យសមត្ថភាពរបស់អតិថិជនរបស់ខ្លួន រួមទាំងតាមរយៈប្រព័ន្ធគ្រប់គ្រង E&S របស់ពួកគេ ដើម្បីកំណត់ផលប៉ះពាល់លើជនជាតិដើមភាគតិច ឬអនុវត្តវិធានការកាត់បន្ថយដែលពាក់ព័ន្ធនោះដែរ។ លើសពីនេះទៀត ដូចបានពន្យល់ខាងលើ នៅខណៈពេលដែល IFC បានតម្រូវឱ្យអតិថិជនអនុវត្ត ESMS នោះ ស៊ីអេអូបានរកឃើញថា មិនមានការចង្អុលបង្ហាញថា IFC បានត្រួតពិនិត្យថាតើប្រព័ន្ធទាំងនេះអាចកំណត់ និងដោះស្រាយផលប៉ះពាល់លើជនជាតិដើមភាគតិចបានដែរឬអត់នោះទេ ឬថា IFC បានតម្រូវឱ្យអតិថិជនអនុវត្តវិធានការដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានលើអ្នកខ្ចីជាជនជាតិដើមភាគតិចនោះទេ។

សម្រាប់ការវិនិយោគដោយផ្ទាល់ចំនួនប្រាំបួន នៅអេស៊ីលីដា អម្រឹត និងធនាគារហត្ថា IFC បានសន្និដ្ឋានថា មានលទ្ធភាពទាបដែលសកម្មភាពរបស់អ្នកខ្ចីបន្តនឹងបង្កើតហានិភ័យ និងផលប៉ះពាល់ E&S សំខាន់ៗ ទាក់ទងនឹងជនជាតិដើមភាគតិច ឬបេតិកភណ្ឌវប្បធម៌ ឬបានចែងថា គម្រោងនេះនឹងមិនគាំទ្រសកម្មភាពអាជីវកម្មដែលមានហានិភ័យខ្ពស់ ដែលអាចរួមបញ្ចូលហានិភ័យទាំងនោះដែរ។[457] ទោះបីជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC មិនបានរួមបញ្ចូលការវាយតម្លៃលើហានិភ័យ និងផលប៉ះពាល់ដ៏ទូលំទូលាយ នៃសកម្មភាពផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុលើអ្នកខ្ចីដែលជាជនជាតិដើមភាគតិចនោះទេ។

---

[456] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៤។ សម្រាប់ការវិនិយោគនៅ MEF សូមមើល គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨ និង សម្រាប់ការវិនិយោគនៅ Advans សូមមើលកាតព្វកិច្ចទូទៅនៃការវាយតម្លៃហានិភ័យសង្គម នៅក្នុង IFC OP ៤.០១ និង ESRP ឆ្នាំ១៩៩៨។

[457] សេចក្តីសង្ខេប E&S និងការបង្ហាញព័ត៌មាន សម្រាប់គម្រោងអេស៊ីលីដា លេខ ៤២៤៨០៖ https://bit.ly/4hMGUIz; គម្រោងលេខ ៤៤៨៨២ https://bit.ly/4j1vEJj; អម្រឹត គម្រោងលេខ ៣៤៧៤៨ https://bit.ly/៣XyuZXz; គម្រោងលេខ ៤១២៩៤ https://bit.ly/3QNFd2E; គម្រោងលេខ ៤៤២៣១ https://bit.ly/42fxkt3; ធនាគារហត្ថា គម្រោងលេខ ៣៩១៦៧ https://bit.ly/3FDYn8B លេខ ៤៤២១១ https://bit.ly/3Xz7PjY លេខ ៤៤៧៤២ https://bit.ly/4c3Tlyt លេខ ៤៥៥៣៥ https://bit.ly/4j0IqHU។

IFC បានប្រើវិធីសាស្ត្រស្រដៀងគ្នាចំពោះមូលនិធិទាំងបួន ដែលរួមមាន MEF MIFA Advans និង North Haven Thai។ ស៊ីអេអូបានរកឃើញថា មិនមានភស្តុតាងបង្ហាញថា IFC បានវាយតម្លៃ ឬតម្រូវឲ្យមូលនិធិធ្វើការវាយតម្លៃថាតើសកម្មភាពរបស់វិនិយោគិនរបស់ពួកគេអាចមានផលប៉ះពាល់យ៉ាងទូលំទូលាយលើជនជាតិដើមភាគតិចនៅក្នុងតំបន់ដែលពួកគេធ្វើប្រតិបត្តិការដែរឬអត់នោះទេ។[458]

ស៊ីអេអូក៏បានរកឃើញផងដែរថា មិនមានភស្តុតាងបង្ហាញថា IFC បានត្រួតពិនិត្យថាតើគោលនយោបាយផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ និងការអនុវត្តន៍របស់ស្ថាប័នហិរញ្ញវត្ថុទាំងនេះស្របតាមស្តង់ដារ GIIP ដែលពាក់ព័ន្ធដែរឬអត់នោះទេ។[459]

ផលប៉ះពាល់នៃបំណុលមីក្រូហិរញ្ញវត្ថុលើដីធ្លី និងទំនាក់ទំនងរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានចងក្រងជាឯកសារនៅដើមឆ្នាំ២០១៣[460] និងត្រូវបានរាយការណ៍ចាប់ពីឆ្នាំ២០១៨ មក។[461] នៅឆ្នាំ២០១៨ OHCHR បានបោះពុម្ពការវាយតម្លៃអំពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ដោយកត់សម្គាល់ឃើញការកើនឡើងនៃបំណុលក្នុងចំណោមជនជាតិដើមភាគតិច និងសហគមន៍មួយចំនួនបញ្ហាប្រឈមក្នុងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ដោយសារកង្វល់ថា សមាជិកសហគមន៍ម្នាក់ៗអាចបាត់បង់ឱកាសទទួលបានឥណទាន។ របាយការណ៍នេះក៏បានគូសបញ្ជាក់អំពីតម្រូវការប្រាក់កម្ចីជាក្រុមកាន់តែធំរបស់សហគមន៍ជនជាតិដើមភាគតិច និងកម្មវិធីអក្ខរកម្មហិរញ្ញវត្ថុផងដែរ។[462] នៅឆ្នាំ២០២០ គម្រោងបែងចែកដីធ្លីរបស់ធនាគារពិភពលោកសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច (LASED) ដែលសំដៅ

---

[458] MEF គម្រោងលេខ ២៧៨២៧ https://bit.ly/3FHjOG4; MIFA គម្រោងលេខ ៣១៤៦៧ https://bit.ly/3DJCC6P; Advans គម្រោងលេខ ២១៨៥៦ https://bit.ly/4hB9v3o និង North Haven Thai គម្រោងលេខ ៣៨៦០៩ https://bit.ly/4iHCvbi។

[459] GIIP សម្រាប់ការវិនិយោគលើមីក្រូហិរញ្ញវត្ថុអំពាវនាវឱ្យផលិតផលហិរញ្ញវត្ថុត្រូវបានរចនាឡើងតាមរបៀបដែលជៀសវាងគ្រោះថ្នាក់ដល់អតិថិជន BFI និងផ្តល់អត្ថប្រយោជន៍ដល់ពួកគេ។ ចំណុចនេះរួមបញ្ចូលទាំងការកែសម្រួលផលិតផលតាមតម្រូវការ និងកាលៈទេសៈជាក់លាក់របស់សហគមន៍ដែលបានទទួលសេវាផងដែរ។ ស្តង់ដារ GIIP ទាក់ទងនឹងតម្លាភាព ទាមទារបន្ថែមទៀតថា អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុត្រូវផ្តល់ព័ត៌មានច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលា ទៅកាន់អ្នកខ្ចី តាមរបៀប និងភាសាដែលពួកគេអាចយល់បានដើម្បីឱ្យអ្នកខ្ចីអាចធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់។ សូមមើល Cerise+ SPTF មគ្គុទ្ទេសក៍ណែនាំសម្រាប់ការវាយតម្លៃ និងការអនុវត្តស្តង់ដារជាសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម និងបរិស្ថាន ស្តង់ដារ ៣B ៤B https://bit.ly/4mlrsRz; មជ្ឈមណ្ឌលបរិយាប័ន្នហិរញ្ញវត្ថុ Accion ការដាក់ឲ្យគោលការណ៍ដំណើរការ៖ ការណែនាំលម្អិតអំពីគោលការណ៍ការពារអតិថិជនការការពារ និងការផ្តល់ភាពអង់អាចដល់អ្នកប្រើប្រាស់ហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩ ទំ. ៨ https://bit.ly/4kw6Dao។

[460] ឯកសារនេះមានទំនាក់ទំនងនឹងភាពតានតឹងរបស់សមាជិកសហគមន៍ ដែលចង់ចាកចេញពីដំណើរការ និងការចេញវិញ្ញាបនបត្រ ICLT ដោយសារតម្រូវការប័ណ្ណកម្មសិទ្ធិផ្ទាល់ខ្លួន ដើម្បីទទួលបានជម្រើសឥណទាន។ Milne, Sarah នៅក្រោមស្បែកខ្លារខិន៖ ការធ្វើអាជីវកម្មដីធ្លី និងបញ្ហានៃប័ណ្ណកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា។ *ទស្សនៈអាស៊ីប៉ាស៊ីហ្វិក* ៥៤(៣) ឆ្នាំ២០១៣។

[461] UN OHCHR ការវាយតម្លៃពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ការកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ ខែតុលា ឆ្នាំ២០១៨ ទំ. ២៥ ២៧ https://bit.ly/4bShl1P; Brook, Jack "ការបាត់បង់ដីធ្លី និងបំណុល៖ ខ្សែបន្ទាត់ខាងក្រោមនៃការយល់ខុសអំពីមីក្រូឥណទាន" *South East Asia Globe* ខែឧសភា ឆ្នាំ២០២២ មាននៅ https://bit.ly/44C6L0s, De Lange, Emiel, Raj, Sushil Raj, និង Yun Mane, សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច គឺជាគន្លឹះសម្រាប់ការអភិរក្សនៅកម្ពុជា (សេចក្តីអធិប្បាយ), *Mongabay*, ខែធ្នូ ឆ្នាំ២០២៣, https://bit.ly/4kRGaob; Baird, Ian G., ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច ឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ និងការប្រែប្រួលនៃវិស័យកសិកម្មនៅខេត្តរតនគីរី ភាគឦសាននៃប្រទេសកម្ពុជា *ទិនានុប្បវត្តិការសិក្សាអំពីកសិករ* ឆ្នាំ២០២៤។

[462] UN OHCHR ការវាយតម្លៃពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ការកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ ខែតុលា ឆ្នាំ២០១៨ ទំ. ២៥ ២៧ https://bit.ly/4bShl1P។

ពង្រឹងសន្តិសុខនៃការកាន់កាប់ដីធ្លី និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្នសម្រាប់សហគមន៍ជនជាតិដើមភាគតិច និងជនបទនៅកម្ពុជា ក៏បានកំណត់បញ្ហាប្រឈមចំពោះដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិសហគមន៍ផងដែរ។ LASED បានរកឃើញថា បញ្ហាប្រឈមទាំងនេះត្រូវបានជម្រុញដោយផលប្រយោជន៍ ឬការលើកទឹកចិត្តរបស់សមាជិកសហគមន៍ម្នាក់ៗ ក្នុងការស្នើសុំប័ណ្ណកម្មសិទ្ធិជាលក្ខណៈបុគ្គល ដែលអាចប្រើជាវត្ថុបញ្ចាំដើម្បីទទួលបានប្រាក់កម្ចី ជាជាងការជ្រើសរើសភាពជាកម្មសិទ្ធិដីធ្លីសហគមន៍ នៅក្រោម ICLT។[463]

ទោះបីជាមានបរិបទបែបនេះក៏ដោយ ក៏ស៊ីអេអូរកមិនឃើញភស្តុតាងថា IFC បានត្រួតពិនិត្យ ឬពិចារណាលើផលប៉ះពាល់ដែលអាចកើតឡើងចំពោះជនជាតិដើមភាគតិច ឬសមត្ថភាពរបស់អតិថិជនដែលពាក់ព័ន្ធ នៅក្នុងការវិនិយោគដែលទាក់ទងនឹងសំណុំរឿងនេះទេ រួមទាំងការវិនិយោគចំនួនប្រាំដែលធ្វើឡើងនៅក្រោយឆ្នាំ ២០១៨ ផងដែរ។[464]

### *៤.៤.១.២ ការហាមឃាត់នៃបញ្ជីផាត់ចេញចំពោះការប៉ះពាល់ដីធ្លីរបស់ជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមពីពួកគេ*

លក្ខណ្ឌតម្រូវការទាក់ទងនឹងជនជាតិដើមភាគតិចតែមួយគត់ ដែលត្រូវបានកំណត់នៅក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC សម្រាប់ការវិនិយោគទាំងនេះ ទាក់ទងនឹងការហាមឃាត់នៃបញ្ជីផាត់ចេញចំពោះការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពមីក្រូហិរញ្ញវត្ថុ "ដែលប៉ះពាល់ដល់ដីដែលជាកម្មសិទ្ធិ ឬត្រូវបានទាមទារតាមការវិនិច្ឆ័យក្តី ដោយជនជាតិដើមភាគតិច ដោយពុំមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះ"។ [465] ចំពោះការវិនិយោគទាំង ១៣ IFC បានកំណត់ថា សកម្មភាពរបស់ FIs មិនបានប្រឈមនឹងបញ្ជីផាត់ចេញនោះទេ។ ចំពោះធនាគារហត្ថា គម្រោងលេខ ៣៩១៦៧ ៤៧៤២ និង ៤៥៣៥ និងអេស៊ីលីដា គម្រោងលេខ ៤២៤៨០ IFC ធ្វើការកំណត់បែបនេះ ដោយផ្អែកលើការរាយការណ៍របស់អតិថិជនដោយខ្លួនឯង។ នៅក្នុងការវិនិយោគដទៃទៀត ស៊ីអេអូមិនបានរកឃើញភស្តុតាង ឬកំណត់ត្រាអំពីប្រភពសម្រាប់ការវាយតម្លៃ និងការកំណត់របស់ IFC នោះទេ។

ក្នុងករណីមួយចំនួន ព័ត៌មានមានកម្រិត ដែលប្រមូលបានដោយ IFC បង្ហាញថា ការវាយតម្លៃកាន់តែលម្អិតត្រូវបានធានា។ ឧទាហរណ៍ ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC ចំពោះគម្រោង អេស៊ីលីដា ទាំងពីរ (លេខ ៤២៤៨០ និង ៤៤៨៨២) ត្រូវបានបញ្ចប់ដោយគ្មានភស្តុតាងថា គម្រោងនេះមិនប្រឈមនឹងសកម្មភាពនៃបញ្ជីផាត់ចេញនោះទេ ប៉ុន្តែ IFC ក៏បានកត់ត្រាផងដែរថា អេស៊ីលីដា មានការប្រឈមនឹងចម្ការកៅស៊ូ។ ដោយសារចម្ការកៅស៊ូនៅកម្ពុជា ជាញឹកញាប់ ត្រូវបានបង្កើតឡើងនៅលើដីដែលទាមទារដោយជនជាតិដើមភាគតិចនោះ

---

463 សូមមើល៖ ក្រុមធនាគារពិភពលោក ការបែងចែកដីធ្លីសម្រាប់គម្រោងអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច III គម្រោងលេខ P១៧១៣៣១ ទំ.៩ https://bit.ly/43CGnoC។

464 គោលនយោបាយនិរន្តរភាព កថាខណ្ឌ ៧ ចែងថា៖ "នៅខណៈពេលដែលការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម ស្របតាមស្តង់ដារសមិទ្ធកម្ម គឺជាទំនួលខុសត្រូវរបស់អតិថិជននោះ IFC ព្យាយាមធានាថា តាមរយៈកិច្ចខិតខំប្រឹងប្រែងត្រួតពិនិត្យភាពត្រឹមត្រូវ ពិនិត្យតាមដាន និងការត្រួតពិនិត្យរបស់ខ្លួន សកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ហិរញ្ញប្បទានត្រូវបានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធកម្មទាំងនោះ"។

465 បញ្ជីផាត់ចេញរបស់ IFC ពីឆ្នាំ២០០៧ និងមុននោះ https://bit.ly/3HJiGT8។

ស៊ីអេអូយល់ថា ការវាយតម្លៃកាន់តែហ្មត់ចត់ជាងនេះនឹងអាចកំណត់ហានិភ័យនៃការអនុវត្តនៅលើដី IP។[466] ជាលទ្ធផល ចំណុចនេះបានតម្រូវឱ្យមានការតាមដាន ដើម្បីកំណត់ថា ប្រតិបត្តិការរបស់ពួកគេរៀងៗខ្លួនមិនបានធ្វើឡើងនៅលើដីជនជាតិដើមភាគតិច ឬមានយល់ព្រមជាឯកសារពេញលេញពីជនជាតិដើមភាគតិច ដើម្បីកំណត់ភាពអនុលោមតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC រួមទាំងបញ្ជីផាត់ចេញផងដែរ។[467]

IFC បានតម្រូវឱ្យមានការអនុវត្តបញ្ជីផាត់ចេញនៅក្នុងការវិនិយោគដោយផ្ទាល់ចំនួនប្រាំបួននៅអេស៊ីលីដា អម្រឹត និងធនាគារហត្ថា[468] និងការវិនិយោគនៅក្នុងមូលនិធិចំនួនបួន ដែលរួមមាន MEF MIFA Advans និង North Haven Thai។ មូលនិធិទាំងនេះត្រូវបានតម្រូវឱ្យអនុវត្តបញ្ជីផាត់ចេញចំពោះសកម្មភាពអាជីវកម្មរបស់ពួកគេ និងតម្រូវឱ្យវិនិយោគិនរបស់ពួកគេធ្វើដូចគ្នា។[469] នៅក្នុងការវិនិយោគទាំងអស់ដែលបានធ្វើឡើង នៅក្រោយឆ្នាំ២០១២[470] លើកលែងចំពោះ North Haven Thai[471] បញ្ជីផាត់ចេញត្រូវបានភ្ជាប់ជាមួយជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ រវាង IFC និងអតិថិជនទាំងនេះ ដោយបានរួមបញ្ចូលការហាមឃាត់មិនឱ្យប៉ះពាល់ដីជនជាតិដើមភាគតិច។

ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូរកមិនឃើញភស្តុតាងនៅក្នុងកំណត់ត្រាការវាយតម្លៃដែលថា IFC បានផ្តល់ការណែនាំដល់អតិថិជន FI អំពីអត្ថន័យ និងវិសាលភាពនៃបញ្ជីផាត់ចេញ ទាក់ទងនឹងដីជនជាតិដើមភាគតិច សម្រាប់ការវិនិយោគណាមួយក្នុងចំណោមការវិនិយោគទាំង ១៣ នោះទេ។[472] ជាពិសេស មិនមានភស្តុតាង

---

466 សូមមើលឯកសារយោង៖ Global Atlas of Environmental Justice, ដីជនជាតិដើមភាគតិចសម្រាប់ចំការកៅស៊ូ ប្រទេសកម្ពុជា https://bit.ly/424vqKQ; Gerald Flynn, Vutha Srey ពុំមានយុត្តិធម៌សម្រាប់សហគមន៍ជនជាតិដើមភាគតិច ដោយសារអំណាចនៃកៅស៊ូនៅកម្ពុជា សារព័ត៌មាន Mongabay ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ https://bit.ly/3DOkPLV; ចលនាព្រៃទឹកភ្លៀងពិភពលោក ប្រទេសកម្ពុជា. ចំការកៅស៊ូ តំបន់ការពារ រេដបូក និងការគំរាមកំហែងផ្សេងទៀត៖ ការបាត់បង់អ្នករស់នៅក្នុងព្រៃឈើយ៉ាងខ្លាំង ព្រឹត្តិបត្រ WRM ២៦៥ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ https://bit.ly/41IiivR; Nehru Pry ជនជាតិដើមភាគតិចនៅកម្ពុជាត្រូវបានដកហូតយកទឹកដីដូនតា Mekong Eye ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២២, https://bit.ly/4c195lM, និង Malcolm j. Foster និង Denis D. Gray ភាពខ្ទះខ្ទែងរបស់កម្ពុជាចំពោះកៅស៊ូជម្រុញឲ្យក្រុមជនជាតិភាគតិចចាកចេញពីដីធ្លី The Seattle Times ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ https://bit.ly/4c196WS។

467 លើសពីនេះទៀត នៅក្នុងកម្ចីអេស៊ីលីដា លេខ ៤៨៨២ IFC មិនតម្រូវឲ្យមានការត្រួតពិនិត្យគម្រោងហានិភ័យខ្ពស់ នៅក្នុងចម្ការកៅស៊ូ ក្នុងចំណោមសកម្មភាពដែលមានហានិភ័យខ្ពស់ផ្សេងទៀត សម្រាប់ការផ្តល់ហិរញ្ញប្បទាននៅក្រោមគម្រោងនេះទេ https://bit.ly/4j4vEJj។

468 សេចក្តីសង្ខេប E&S និងការបង្ហាញព័ត៌មាន សម្រាប់អេស៊ីលីដា គម្រោងលេខ ៤២៤៨០៖ https://bit.ly/4hMGUIz; គម្រោងលេខ ៤៤៨៨២ https://bit.ly/4j1vEJj; អម្រឹត គម្រោងលេខ ៣៤៧៤៨ https://bit.ly/៣XyuZXz; គម្រោងលេខ ៤១២៩៤ https://bit.ly/3QNFd2E; គម្រោងលេខ ៤៤២៣១ https://bit.ly/42fxkt3; ធនាគារហត្ថា គម្រោងលេខ ៣៩១៦៧ https://bit.ly/3FDYn8B លេខ ៤៤២១១ https://bit.ly/3Xz7PjY លេខ ៤៤៧៤២ https://bit.ly/4c3Tlyt លេខ ៤៥៥៣៥ https://bit.ly/4j0IqHU។

469 MEF គម្រោងលេខ ២៧៨២៧ https://bit.ly/3FHjOG4; MIFA គម្រោងលេខ ៣១៤៦៧ https://bit.ly/3DJCC6P; Advans គម្រោងលេខ ២១៨៥៦ https://bit.ly/4hB9v3o និង North Haven Thai គម្រោងលេខ ៣៨៦០៩ https://bit.ly/4iHCvbi។

470 ក្នុងករណី Advans និង MEF ការវិនិយោគចំនួនពីរត្រូវបានធ្វើឡើងនៅមុនឆ្នាំ២០១២ វិសោធនកម្មត្រូវបានធ្វើឡើងនៅឆ្នាំ២០២០ និង ២០២១ ដាច់ដោយឡែកពីគ្នា ដើម្បីរួមបញ្ចូលលក្ខខណ្ឌតម្រូវ ទាក់ទងនឹងគោលការណ៍ការពារអតិថិជន និងបញ្ជីផាត់ចេញ។

471 បញ្ជីផាត់ចេញ ដែលភ្ជាប់មកជាមួយកិច្ចព្រមព្រៀងតាមផ្លូវច្បាប់របស់ North Haven Thai និងដែល FI ប្តេជ្ញាចិត្តអនុវត្ត មិនមានចំណុចដែលទាក់ទងនឹងមីក្រូហិរញ្ញវត្ថុ និងការហាមឃាត់មិនឲ្យប៉ះពាល់ដីជនជាតិដើមភាគតិចនោះទេ។

472 ក្នុងករណីការវិនិយោគភាគហ៊ុននៅអម្រឹត លេខ ៣៤៧៤៨ (ឆ្នាំ២០១៤) មានភស្តុតាងដែលមានការផ្តល់ដំបូន្មានទាក់ទងនឹងថ្នាំជក់ និងគ្រឿងស្រវឹងនៅក្នុងបញ្ជីផាត់ចេញ។ លក្ខខណ្ឌតម្រូវមួយ ត្រូវបានបន្ថែមនៅក្នុងការវិនិយោគនោះ ដើម្បីឲ្យអម្រឹតកែប្រែបញ្ជីផាត់ចេញ នៅក្នុងគោលនយោបាយ E&S របស់ខ្លួន ដើម្បីរួមបញ្ចូលបញ្ជីផាត់ចេញរបស់ IFC យ៉ាងពេញលេញ ពីព្រោះវត្ថុដែលទាក់ទងនឹងថ្នាំជក់ និងគ្រឿងស្រវឹងមិនត្រូវបានរួមបញ្ចូលនៅចំណុចនោះទេ https://bit.ly/3XyuZXz។

ដែលថា IFC បានពន្យល់ពីតម្រូវការក្នុងការជៀសវាងផលប៉ះពាល់អវិជ្ជមានលើដីបែបនេះទេ សូម្បីតែនៅពេលដែលមិនមានការទទួលស្គាល់ជាផ្លូវការក៏ដោយ ឬតម្រូវការក្នុងការកែសម្រួលដទៃទៀត ដូចជា ការបកប្រែឯកសារ និងការផ្តល់ការបកស្រាយជាភាសាក្នុងស្រុកនៅពេលប្រតិបត្តិការនៅក្នុងតំបន់ដែលមានប្រជាជនជនជាតិដើមភាគតិចភាគច្រើន។ ជាក់ស្តែង ស៊ីអេអូបានសង្កេតឃើញ ក្នុងអំឡុងពេលចុះត្រួតពិនិត្យនៅទីវាល និងការសម្ភាសជាមួយបុគ្គលិកសាខាក្នុងស្រុក ជាពិសេសនៅក្នុងតំបន់ដែលមានប្រជាជន IP ភាគច្រើន ថា BFIs មានការយល់ដឹងតែស្រពិចស្រពិលអំពីលក្ខខណ្ឌតម្រូវនៃបញ្ជីផាត់ចេញ ដែលហាមឃាត់សកម្មភាពរបស់ពួកគេមិនឲ្យប៉ះពាល់ដី IP។

ស៊ីអេអូក៏រកមិនឃើញភស្តុតាងដែលថា IFC បានត្រួតពិនិត្យភាពអនុលោមរបស់អតិថិជន និងអតិថិជនបន្តចំពោះលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែលទាក់ទងនឹងជនជាតិដើមភាគតិច និងការហាមឃាត់មិនឲ្យទទួលយកដីនៅក្នុង ICLTs ជាវត្ថុបញ្ចាំនោះទេ។

### *៤.៤.១.៣ សេចក្តីសន្និដ្ឋានទាក់ទងនឹងភាពអនុលោមរបស់ IFC ចំពោះលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តភាព ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ ទាក់ទងនឹងជនជាតិដើមភាគតិច*

ស៊ីអេអូរកឃើញថា IFC មិនបានត្រួតពិនិត្យផលប៉ះពាល់របស់អតិថិជន និងអតិថិជនបន្ត ដែលអាចកើតឡើងចំពោះជនជាតិដើមភាគតិច និងវិធានការកាត់បន្ថយដែលពាក់ព័ន្ធនោះទេ ទោះបីជាអតិថិជន FI ភាគច្រើនធ្វើប្រតិបត្តិការនៅក្នុងតំបន់ដែលមាន IP ភាគច្រើនក៏ដោយ។ នៅខណៈពេលដែលការវិនិយោគទាំងអស់តម្រូវឱ្យអតិថិជនអនុវត្តបញ្ជីផាត់ចេញនោះ ស៊ីអេអូបានរកឃើញថា ការត្រួតពិនិត្យរបស់ IFC លើការអនុវត្តរបស់អតិថិជនរបស់ខ្លួនមានចំនួនតិចតួចបំផុត។ នៅគ្រប់ករណីទាំងអស់ IFC បានដាក់កម្រិតលើការអនុវត្តបញ្ជីផាត់ចេញចំពោះផលប៉ះពាល់នៃអនុគម្រោងដែលអាចកើតឡើង (ពោលគឺ សកម្មភាពបរបស់អ្នកខ្ចី) ប៉ុន្តែមិនមែនចំពោះសកម្មភាពរបស់ FIs ដោយផ្ទាល់នោះទេ។[473] ស៊ីអេអូរកមិនឃើញភស្តុតាងដែលថា IFC បានផ្តល់ព័ត៌មានដល់អតិថិជនអំពីវិធីដោះស្រាយដី IP ដែលមិនមានការទទួលស្គាល់ជាផ្លូវការ ឬថា អតិថិជនយល់ពីរបៀបដោះស្រាយនោះទេ។ IFC បានទទួលយកការរាយការណ៍ដោយខ្លួនឯងពីអតិថិជនរបស់ខ្លួនដោយមិនមានភស្តុតាងថា គម្រោងរបស់ពួកគេនឹងមិនប៉ះពាល់ជាអវិជ្ជមានលើជនជាតិដើមភាគតិច ឬមានហានិភ័យ ឬផលប៉ះពាល់សំខាន់ៗចំពោះបរិស្ថាន និងបេតិកភណ្ឌវប្បធម៌របស់ពួកគេនោះទេ។

ស៊ីអេអូក៏រកឃើញផងដែរថា ទោះបីជាអតិថិជនមីក្រូហិរញ្ញវត្ថុរបស់ IFC នៅកម្ពុជា កំពុងធ្វើប្រតិបត្តិការនៅក្នុងតំបន់មួយចំនួនដែលមាន IP ភាគច្រើន និងមានភស្តុតាងកាន់តែច្រើនចាប់តាំងពីឆ្នាំ ២០១៨ មក ស្តីពី

[473] មិនមានចំណុចណាមួយនៅក្នុងពាក្យពេចន៍នៃបញ្ជីផាត់ចេញរបស់ IFC ដែលដាក់កម្រិតលើការអនុវត្តសកម្មភាពនៃអនុគម្រោង និងមិនរួមបញ្ចូលសកម្មភាពរបស់ FI ដោយផ្ទាល់នោះទេ។ បញ្ជីផាត់ចេញ MFI របស់ IFC អនុវត្តចំពោះតួអង្គទាំងអស់ ដែលពាក់ព័ន្ធនឹង៖ ក) អតិថិជនរបស់ IFC ឧទាហរណ៍ នៅពេលទិញដី ដើម្បីបង្កើតការិយាល័យ ខ) អតិថិជនបន្តរបស់ IFC នៅពេលប្រើប្រាស់ដីជនជាតិដើមភាគតិចសម្រាប់ផលិតកម្ម សកម្មភាព ឬជាវត្ថុបញ្ចាំ និង គ) ប្រជាជនដែលរងផលប៉ះពាល់ដោយសកម្មភាពរបស់អតិថិជនបន្តរបស់ IFC ដូចជា ការកាប់ឈើ សម្បទានកសិកម្ម ការធ្វើចម្ការ ទេសចរណ៍ជាដើម។

ហានិភ័យមីក្រូហិរញ្ញវត្ថុ និងផលប៉ះពាល់អវិជ្ជមានលើសហគមន៍ IP នៅកម្ពុជាក៏ដោយ[474] ក៏ IFC បានបន្តអនុម័តការវិនិយោគថ្មីៗដោយមិនបានកែសម្រួលការត្រួតពិនិត្យភាពត្រឹមត្រូវ E&S របស់ខ្លួន ដើម្បីរួមបញ្ចូលហានិភ័យទាំងនេះ ស្របតាមគោលនយោបាយនិរន្តរភាព និងបញ្ជីផាត់ចេញរបស់ IFC នោះទេ។ គម្រោង LASED របស់ធនាគារពិភពលោកផ្ទាល់ បានកំណត់ហានិភ័យនៃប្រតិបត្តិការមីក្រូហិរញ្ញវត្ថុចំពោះដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ IP ដែលគោលបំណងពង្រឹងសិទ្ធិកាន់កាប់ដី IP។[475] ទោះបីជាយ៉ាងណាក៏ដោយ IFC មិនបានតម្រូវឱ្យអតិថិជនរបស់ខ្លួនតម្រឹម ESMS និងការអនុវត្តរបស់ពួកគេជាមួយ GIIP និងច្បាប់ជាតិដែលពាក់ព័ន្ធ ដើម្បីដោះស្រាយហានិភ័យទាំងនេះ ឬបង្កើតលក្ខខណ្ឌតម្រូវក្នុងការពិនិត្យតាមដានដែលពាក់ព័ន្ធនោះទេ។

### ៤.៤.២ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យការវិនិយោគរបស់ខ្លួន នៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA

នៅពេលត្រួតពិនិត្យការវិនិយោគទាំងនេះ IFC បានទទួលព័ត៌មានជាទៀងទាត់ ទាក់ទងនឹងភាពអនុលោមរបស់អតិថិជន និងអតិថិជនបន្ត តាមបញ្ជីផាត់ចេញ។

#### *៤.៤.២.១ ការត្រួតពិនិត្យអតិថិជនរបស់ IFC ទាក់ទងនឹងផលប៉ះពាល់លើជនជាតិដើមភាគតិច*

ដូចបានពិពណ៌នាខាងលើ ស្ថាប័នហិរញ្ញវត្ថុនៅកម្ពុជា រួមទាំងអតិថិជន និងអតិថិជនបន្តរបស់ IFC ផងដែរ តែងតែទទួលយកប័ណ្ណកម្មសិទ្ធិដីទន់ ដែលត្រួតស៊ីគ្នានឹងដីសហគមន៍ IP ដោយគ្មានការយល់ព្រមពីសហគមន៍។ ដើមបណ្តឹង IP ទាំងអស់របស់ស៊ីអេអូ នៅក្នុងសំណុំរឿងនេះ ដែលបានប្រើដីជាវត្ថុបញ្ចាំ គឺមកពីសហគមន៍ជនជាតិដើមភាគតិចដែលមាន ICLT ដែលត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់។ ពួកគេបានប្រើប័ណ្ណកម្មសិទ្ធិដីទន់របស់ពួកគេជាវត្ថុបញ្ចាំ ដែលអ្នកផ្តល់ប្រាក់កម្ចីរបស់អតិថិជន IFC បានទទួលយកដោយគ្មានការយល់ព្រមពីសហគមន៍នោះទេ។ ការអនុវត្តនេះមានហានិភ័យបង្កផលប៉ះពាល់ដល់បូរណភាពដីសហគមន៍ និងបង្កើតជម្លោះក្នុងសហគមន៍ ហើយត្រូវបានហាមឃាត់ស្របតាមលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ការពឹងផ្អែកយ៉ាងខ្លាំងលើដីធ្លីជាវត្ថុបញ្ចាំនៅក្នុងមីក្រូហិរញ្ញវត្ថុកម្ពុជា រួមផ្សំជាមួយកង្វះផលិតផលហិរញ្ញវត្ថុជំនួស អាចលើកទឹកចិត្តអ្នកខ្ចីជាជនជាតិដើមភាគតិចឱ្យប្រើប្រាស់ដីសហគមន៍ជាវត្ថុបញ្ចាំ ដើម្បីបន្តទទួលបានឥណទាន (សូមមើលផ្នែក ៤.២.២)។

ទោះបីជាមានកាលៈទេសៈទាំងនេះក៏ដោយ ក៏ស៊ីអេអូរកមិនឃើញភស្តុតាងដែលថា IFC បានផ្តល់ដំបូន្មាន ឬបានពិនិត្យតាមដានកិច្ចខិតខំប្រឹងប្រែងរបស់អតិថិជន BFI របស់ខ្លួននៅក្នុងតំបន់ដែលមានប្រជាជនភាគច្រើន

---

[474] UN OHCHR ការវាយតម្លៃពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ការកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ ខែតុលា ឆ្នាំ២០១៨ ទំ. ២៥ ២៧ https://bit.ly/4bShl1P; Brook, Jack "ការបាត់បង់ដីធ្លី និងបំណុល៖ ខ្សែបន្ទាត់ខាងក្រោមនៃការយល់ខុសអំពីមីក្រូឥណទាន" *South East Asia Globe* ខែឧសភា ឆ្នាំ២០២២ មាននៅ https://bit.ly/44C6L0s, De Lange, Emiel, Raj, Sushil Raj, និង Yun Mane, សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច គឺជាគន្លឹះសម្រាប់ការអភិរក្សនៅកម្ពុជា (សេចក្តីអធិប្បាយ), *Mongabay*, ខែធ្នូ ឆ្នាំ២០២៣, https://bit.ly/4kRGaob; Baird, Ian G., ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច ឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ និងការប្រែប្រួលនៃវិស័យកសិកម្មនៅខេត្តរតនគីរី ភាគឦសាននៃប្រទេសកម្ពុជា *ទិនានុប្បវត្តិការសិក្សាអំពីកសិករ* ឆ្នាំ២០២៤។

[475] សូមមើល៖ ក្រុមធនាគារពិភពលោក, គម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច III, គម្រោងលេខ P១៧១៣៣១ https://bit.ly/43CGnoC។

ជា IP ដើម្បីកែសម្រួលសេវាកម្ម និងផលិតផល ដើម្បីជៀសវាងគ្រោះថ្នាក់នោះទេ។ ក្នុងអំឡុងពេលចុះទៅទីតាំង និងការសម្ភាសជាមួយបុគ្គលិកសាខានៅក្នុងមូលដ្ឋាន ជាពិសេសនៅតំបន់ដែលមានប្រជាជនភាគច្រើនជា IP មិនមានអតិថិជន និងអតិថិជនបន្តរបស់ IFC ណាមួយបានផ្តល់ព័ត៌មាន ឬឯកសារជាភាសា IP ដល់ស៊ីអេអូឡើយ។ នៅខណៈពេលដែលបុគ្គលិក BFI មួយចំនួននៅក្នុងតំបន់ទាំងនេះគឺជា IP និងនិយាយភាសាក្នុងមូលដ្ឋាននោះ ចំណុចនេះមិនធានាថាអាចដោះស្រាយឧបសគ្គនៃការប្រាស្រ័យទាក់ទងបានគ្រប់ពេលនោះទេ។ ក្នុងអំឡុងពេលសម្ភាសជាមួយអ្នកខ្ចី ស៊ីអេអូបានដឹងថា មានដើមបណ្តឹងយ៉ាងតិចបីនាក់ ដែលមានការលំបាកក្នុងការយល់អំពីលក្ខខណ្ឌ និងគោលនយោបាយប្រាក់កម្ចីរបស់ពួកគេ ដោយសារពួកគេមិននិយាយភាសាខ្មែរ។ កង្វះខាតឯកសារបកប្រែអាចរារាំងដល់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ជាមួយអ្នកខ្ចីជា IP ដែលធ្វើឱ្យពួកគេមិនមានព័ត៌មានចាំបាច់ ដើម្បីធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់។

លើសពីនេះទៀត ស្ថាប័នហិរញ្ញវត្ថុដែលធ្វើការនៅក្នុងតំបន់ដែលមានប្រជាជនភាគច្រើនជា IP មិនស្នើផ្តល់ផលិតផលដែលគិតគូរពីវប្បធម៌របស់ IP និងអាចផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ជនជាតិដើមភាគតិច ដូចជា ប្រាក់កម្ចីគ្មានប្រាតិភោគ ឬផលិតផលប្រាក់កម្ចីដែលមិនតម្រូវឱ្យមានវត្ថុបញ្ចាំ ប៉ុន្តែប្រើទម្រង់ផ្សេងទៀតនៃការធានារួមគ្នា។[476] លើសពីនេះទៀត ស៊ីអេអូរកមិនឃើញការចង្អុលបង្ហាញថា IFC បានពិនិត្យតាមដានថាតើអតិថិជនរបស់ខ្លួននៅក្នុងតំបន់ទាំងនេះបានស្នើផ្តល់ផលិតផលដែលត្រូវបានកែសម្រួលតាមវប្បធម៌របស់ IP ដូចជា ប្រាក់កម្ចីគ្មានប្រាតិភោគ ឬយន្តការធានារួមគ្នានោះទេ។

ចំពោះការត្រួតពិនិត្យការវិនិយោគផ្ទាល់របស់ IFC នៅក្នុងសំណុំរឿងនេះ ទាក់ទងនឹងជនជាតិដើមភាគតិច៖

- នៅចន្លោះឆ្នាំ២០១៩ និង ឆ្នាំ២០២៣ ការពិនិត្យតាមដានរបស់ IFC លើអេស៊ីលីដា គឺផ្អែកលើការត្រួតពិនិត្យរបាយការណ៍ E&S ប្រចាំឆ្នាំរបស់វា ដោយមានការចុះត្រួតពិនិត្យទីតាំងមួយលើក នៅខែវិច្ឆិកា ឆ្នាំ២០២២។[477] IFC តែងតែបានចាត់ទុកសមិទ្ធកម្ម E&S របស់អ្នកផ្តល់ប្រាក់កម្ចី ថាគួរជាទីពេញចិត្ត ដោយមួយផ្នែក ផ្អែកលើរបាយការណ៍របស់អេស៊ីលីដា ដែលថាមន្ត្រីឥណទានរបស់ខ្លួនបានធានាថា មិនមានប្រាក់កម្ចីណាមួយប្រឈមនឹងបញ្ជីផាត់ចេញនោះទេ។ នៅឆ្នាំ២០១៩ និង ឆ្នាំ២០២០ អេស៊ីលីដាបានរាយការណ៍ថា មូលហេតុទូទៅបំផុតសម្រាប់ការបដិសេធប្រាក់កម្ចីគឺ ដោយសារសកម្មភាពអាជីវកម្មរបស់អតិថិជន ពាក់ព័ន្ធនឹងដីជនជាតិដើមភាគតិច និងថា នេះគឺជាបញ្ហាដែលតែងតែបានពិភាក្សាជាមួយអ្នកខ្ចីបន្ត។ ស៊ីអេអូរកមិនឃើញភស្តុតាងនៅក្នុងកំណត់ត្រារបស់ IFC ដែលថា វាបានពិចារណា ឬតាមដានព័ត៌មាននេះជាមួយអតិថិជននោះទេ។
- នៅចន្លោះឆ្នាំ២០១៤ និង ឆ្នាំ២០២៣ IFC បានពិនិត្យតាមដានការអនុវត្តរបស់អម្រឹត តាមរយៈការត្រួតពិនិត្យរបាយការណ៍ E&S ប្រចាំឆ្នាំរបស់វា និងការចុះត្រួតពិនិត្យទីតាំង ក្នុងខែមីនា ឆ្នាំ២០១៧។

---

[476] របាយការណ៍នាពេលថ្មីៗនេះរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានគូសបញ្ជាក់ពីគំរូហិរញ្ញវត្ថុជំនួស ដែលធ្វើឱ្យជនជាតិដើមភាគតិចអាចទទួលបានឥណទានដោយមិនចាំបាច់ប្រើដីធ្លីជាវត្ថុបញ្ចាំ។ ឧទាហរណ៍រួមមាន ស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍សហគមន៍ និងយន្តការដែលផ្អែកលើបរធនបាលកិច្ច ដូចជា សមាគមប្រាក់សន្សំ និងឥណទានបង្វិល និងក្រុមផ្តល់ប្រាក់កម្ចីសាមគ្គីភាព។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស អន្ទាក់បំណុល៖ ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុដ៏ឃោរឃៅ និងការកេងប្រវ័ញ្ចលើជនជាតិដើមភាគតិចនៅកម្ពុជា ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៥ https://bit.ly/4gSi2QZ។

[477] នៅខែវិច្ឆិកា ឆ្នាំ២០២២ IFC បានចុះពិនិត្យតាមដានជាលើកដំបូង ចាប់តាំងពីឆ្នាំ ២០១១ មក។ ក្នុងអំឡុងពេលចុះត្រួតពិនិត្យនេះ IFC បានផ្តោតលើការត្រួតពិនិត្យការវាយតម្លៃលើកម្ចីធំៗចំនួនប្រាំមួយ។ IFC មិនបានត្រួតពិនិត្យ ឬប៉ះដំណើរការរបស់អេស៊ីលីដាសម្រាប់កម្ចីខ្នាតតូច ក្នុងការអនុវត្តបញ្ជីផាត់ចេញនោះទេ។

IFC បានកត់សម្គាល់លើការរាយការណ៍ដោយខ្លួនឯងរបស់ FI ថា មិនមានសកម្មភាពណាមួយដែលប្រឈមនឹងបញ្ជីផាត់ចេញនោះទេ និងបានចាត់ទុកសមិទ្ធកម្ម E&S របស់អម្រឹត ជារៀងរាល់ឆ្នាំ ថាជាទីពេញចិត្ត។ របាយការណ៍ E&S ប្រចាំឆ្នាំដំបូងរបស់អម្រឹត នៅឆ្នាំ២០១៤ បានរាយការណ៍ធៀបនឹងបញ្ជីផាត់ចេញថា មិនបានរួមបញ្ចូលការហាមឃាត់ចំពោះសកម្មភាពហិរញ្ញវត្ថុដែលប៉ះពាល់ដល់ដីជនជាតិដើមភាគតិចនោះទេ។ IFC បានកត់សម្គាល់ឃើញថា ការផាត់ចេញទាក់ទងនឹងគ្រឿងស្រវឹងមិនត្រូវបានរួមបញ្ចូលនោះទេ ប៉ុន្តែវាមិនទាក់ទងនឹងជនជាតិដើមភាគតិចនោះទេ។ នីតិវិធី E&S របស់អម្រឹត ត្រូវបានចេញនៅឆ្នាំបន្ទាប់ ឆ្នាំ២០១៥ និងបានរួមបញ្ចូលការហាមឃាត់សកម្មភាពហិរញ្ញវត្ថុដែលប៉ះពាល់ដល់ដីជនជាតិដើមភាគតិច។ ទោះបីជាយ៉ាងណាក៏ដោយ គំរូរបាយការណ៍ E&S ប្រចាំឆ្នាំ ដែលអម្រឹតបានអនុវត្តតាម ក្នុងការរាយការណ៍ទៅកាន់ IFC ចាប់តាំងពីឆ្នាំ២០២២ មក ជាថ្មីម្តងទៀត មិនបានរួមបញ្ចូលចំណុចនេះទេ។ ស៊ីអេអូរកមិនឃើញភស្តុតាងដែលថា IFC បានតាមដានការមិនរួមបញ្ចូលនេះ ជាមួយអតិថិជននោះទេ។ ក្នុងអំឡុងពេលប្រាំបួនឆ្នាំនៃការពិនិត្យតាមដានរបស់ IFC ស៊ីអេអូរកមិនឃើញកំណត់ត្រានៅក្នុងឯកសារគម្រោងស្តីពីការរាយការណ៍របស់អម្រឹត ឬការស្នើសុំដំបូន្មានលើបញ្ហាណាមួយទាក់ទងនឹងជនជាតិដើមភាគតិច ឬថា IFC បានតាមដានការអនុវត្តគោលនយោបាយ E&S របស់អម្រឹតនៅក្នុងតំបន់នេះទេ។

- នៅចន្លោះឆ្នាំ២០១៧ និង ឆ្នាំ២០២៣ IFC បានពិនិត្យតាមដានធនាគារ ហត្ថា តាមរយៈការត្រួតពិនិត្យរបាយការណ៍ E&S ប្រចាំឆ្នាំរបស់វា ដែលអ្នកផ្តល់ប្រាក់កម្ចីបានរាយការណ៍ថា មិនមានការប្រឈមនឹងសកម្មភាពនៃបញ្ជីផាត់ចេញ ក្នុងអំឡុងពេលពិនិត្យតាមដាននោះទេ។ ការត្រួតពិនិត្យរបស់ IFC បានកត់សម្គាល់លើសេចក្តីថ្លែងការណ៍ទាំងនេះ ដោយមិនស្នើសុំការបញ្ជាក់បន្ថែមណាមួយឡើយ និងបានសន្និដ្ឋានថា សមិទ្ធកម្ម E&S របស់ធនាគារហត្ថាគឺ គួរជាទីពេញចិត្ត។ ស៊ីអេអូរកមិនឃើញភស្តុតាងនៅក្នុងឯកសារពិនិត្យតាមដានរបស់ IFC ដែលថា IFC និងធនាគារហត្ថា ធ្លាប់ពិភាក្សាអំពីបញ្ហាជនជាតិដើមភាគតិចនោះទេ។

ទាក់ទងនឹងការវិនិយោគលើមូលនិធិរបស់ IFC នៅក្នុងសំណុំរឿងនេះ៖

- ការរាយការណ៍របស់ MEF ទៅកាន់ IFC នៅចន្លោះឆ្នាំ២០០៩ និង ឆ្នាំ២០១៨ បានសង្កត់ធ្ងន់លើការប្រកាន់ខ្ជាប់របស់វិនិយោគិនរបស់ខ្លួន ចំពោះបញ្ជីផាត់ចេញ ដែលត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយវិនិយោគិន ដែលរួមមាន ប្រាសាក់ ធនាគារហត្ថា និងស្ថាបនា។ MEF ក៏បានរាយការណ៍អំពីការប្រឈមរបស់ខ្លួនផ្ទាល់ ចំពោះសកម្មភាពនៅក្នុងបញ្ជីផាត់ចេញផងដែរ។ ស៊ីអេអូកត់សម្គាល់ថា ទោះបីជា MEF បានវិនិយោគលើ MFIs មួយចំនួនធំក៏ដោយ ក៏វាបានរាយការណ៍ជាបន្តបន្ទាប់ថា មិនមានការរំលោភបំពានធ្ងន់ធ្ងរលើបញ្ជីផាត់ចេញនោះទេ។ នៅឆ្នាំ២០១៣ IFC បានកត់សម្គាល់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៦៦ ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំង ៨២ ដែល MEF បានធ្វើការវិនិយោគ បានបញ្ជាក់ថា ពួកគេមិនបានផ្តល់ប្រាក់កម្ចីសម្រាប់សកម្មភាពនៅក្នុងបញ្ជីផាត់ចេញនោះទេ។ IFC បានផ្តល់អនុសាសន៍ឲ្យអ្នកគ្រប់គ្រងមូលនិធិបន្តធ្វើការជាមួយវិនិយោគិនដើម្បីធានាបាននូវភាពអនុលោមតាមបញ្ជីផាត់ចេញ និងធ្វើការតាមដាន ដើម្បីកំណត់ថាតើ MFI ជាក់លាក់មួយនឹងត្រួតពិនិត្យបញ្ជីផាត់ចេញរបស់ពួកគេដែរឬទេ។ IFC ក៏បានស្នើឱ្យអ្នកគ្រប់គ្រងមូលនិធិត្រួតពិនិត្យរបាយការណ៍/ការឆ្លើយតបផ្នែក E&S ពីវិនិយោគិនរបស់ពួកគេ និងតាមដាន

ចំណុចខ្វះខាតណាមួយនៅក្នុងការត្រួតពិនិត្យរបស់ MFI ចំពោះសកម្មភាពរបស់អ្នកខ្ចី ធៀបនឹងបញ្ជីផាត់ចេញផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាជនជាតិដើមភាគតិច ដែលទាក់ទងនឹងបញ្ជីផាត់ចេញនោះ មិនត្រូវបានលើកឡើងយ៉ាងច្បាស់លាស់នៅក្នុងកំណត់ត្រាការពិនិត្យតាមដានរបស់ IFC នោះទេ។

នៅឆ្នាំ២០១៤ MEF បានរាយការណ៍ទៅកាន់ IFC ថា BlueOrchard បានផ្ទៀងផ្ទាត់ភាពអនុលោមតាមបញ្ជីផាត់ចេញ ដោយប្រើឧបករណ៍ចំនួនពីរ៖ ការត្រួតពិនិត្យឯកសារប្រាក់កម្ចីដោយមន្ត្រីវិនិយោគ ជាផ្នែកមួយនៃការត្រួតពិនិត្យប្រចាំឆ្នាំរបស់ពួកគេ និងឧបករណ៍ SPIRIT ដែលសួរថាតើ MFI មាន "បញ្ជីផាត់ចេញសម្រាប់ការផ្តល់ប្រាក់កម្ចីដែរឬទេ" កំណត់ត្រាពិនិត្យតាមដានរបស់ IFC ក្នុងឆ្នាំនោះ បានកត់សម្គាល់ថា មានកំណត់ត្រាតិចតួច ឬគ្មានកំណត់ត្រាអំពីភាពអនុលោមរបស់ MFIs តាមបញ្ជីផាត់ចេញ និងបញ្ហា E&S ជាទូទៅនោះទេ ដោយអាស្រ័យលើទីប្រឹក្សាវិនិយោគ ដែលគ្រប់គ្រងវិនិយោគិននីមួយៗ។ ក្នុងឆ្នាំបន្តបន្ទាប់ កំណត់ត្រារបស់ IFC បានបញ្ជាក់ថា មិនមានរបាយការណ៍ ESDD ត្រូវបានចែករំលែកដោយ MEF ដោយមិនមានលក្ខខណ្ឌតម្រូវក្នុងការតាមដានជាផ្លូវការពី IFC នោះទេ។ ជាទូទៅ IFC មានការពេញចិត្ត ដែល MEF បានផ្ទៀងផ្ទាត់ភាពអនុលោមតាមបញ្ជីផាត់ចេញតាមរយៈការរាយការណ៍ដោយខ្លួនឯង និងការផ្ទៀងផ្ទាត់នៅនឹងកន្លែង ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងថាអ្នកគ្រប់គ្រងមូលនិធិទាំងអស់ធានាថាមានភាពអនុលោម ដោយរួមបញ្ចូលបញ្ជីផាត់ចេញនៅក្នុងកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់វិនិយោគិន។

- ក្នុងការរាយការណ៍ទៅកាន់ IFC នៅចន្លោះឆ្នាំ២០១៤ និង ឆ្នាំ២០២០ MIFA បានប្រើអភិក្រមស្រដៀងគ្នានឹងការរាយការណ៍របស់ខ្លួនអំពីគោលការណ៍ការពារអតិថិជនរបស់ឧស្សាហកម្មនេះដែរ (សូមមើលផ្នែក ៤.៣.២) រួមទាំងព័ត៌មានជាក់លាក់របស់វិនិយោគិន ថាតើពួកគេមានបញ្ជីផាត់ចេញ និងថាតើវាត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចីដែរឬទេ។ វិនិយោគិនទាំងនេះ រួមមាន អម្រឹត ធនាគារហត្ថា អិលអូអិលស៊ី និងស្ថាបនា ដែលបានបញ្ជាក់យ៉ាងខ្ជាប់ខ្ជួននូវការប្តេជ្ញាចិត្តទាំងពីរនេះ។ ករណីលើកលែងគឺ របាយការណ៍របស់អម្រឹត ទៅកាន់ MIFA នៅឆ្នាំ២០១៧ ដែលបង្ហាញថា លក្ខខណ្ឌតម្រូវ E&S ត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចីរបស់ពួកគេ ប៉ុន្តែមិនបានភ្ជាប់មកជាមួយនូវបញ្ជីផាត់ចេញនោះទេ។ បញ្ជីផាត់ចេញរបស់ MIFA រួមបញ្ចូលសកម្មភាពដែលប៉ះពាល់ដល់ដីដែលជាកម្មសិទ្ធិ ឬត្រូវបានទាមទារ ស្របតាមការវិនិច្ឆ័យក្តី ដោយជនជាតិដើមភាគតិច ដោយពុំមានការយល់ព្រមជាឯកសារពេញលេញពីប្រជាជនទាំងនោះ។
- នៅឆ្នាំ២០១៤ IFC បានកត់សម្គាល់ថា MFIs ចំនួនប្រាំពីរនៅក្នុងផលបត្ររបស់ MIFA ខ្វះខាតបញ្ជីផាត់ចេញ ហើយ MFIs ចំនួន ១៥ មិនបានរួមបញ្ចូលបញ្ជីផាត់ចេញនៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចីរបស់ពួកគេនោះទេ។ IFC បានផ្តល់អនុសាសន៍ឲ្យ MIFA តាមដានវិនិយោគិន ហើយនៅឆ្នាំ២០១៥ ចំនួនក្រុមហ៊ុនវិនិយោគដែលមិនមានបញ្ជីផាត់ចេញដែលត្រូវបានអនុម័តជាផ្លូវការ បានធ្លាក់ចុះមកត្រឹមបី។ ការពិនិត្យតាមដានរបស់ IFC នៅឆ្នាំ២០១៥ បានសន្និដ្ឋានថា BlueOrchard អនុលោមតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC និងបានចាត់ថ្នាក់សមិទ្ធកម្មរបស់ខ្លួនថា គួរជាទីពេញចិត្ត។ នៅឆ្នាំដដែលនោះ បន្ទាប់ពីបានចុះត្រួតពិនិត្យទីតាំង IFC បានផ្តល់អនុសាសន៍ឲ្យ MIFA ធានាថា បញ្ជីផាត់ចេញរបស់វិនិយោគិនរបស់ខ្លួនបានរួមបញ្ចូលធាតុនានានៃបញ្ជីផាត់ចេញរបស់ IFC។ ចាប់ពីឆ្នាំ២០១៧

មក MIFA បានរាយការណ៍អំពីភាគរយនៃប្រាក់កម្ចីរបស់វិនិយោគិនរបស់ខ្លួន ដែលជាប់ពាក់ព័ន្ធយ៉ាងខ្លាំងក្លា នៅក្នុងសកម្មភាពហាមឃាត់ ដោយ MFIs ជាប់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះ ដោយបានរាយការណ៍ជាបន្តបន្ទាប់អំពីការប្រឈម 0% រហូតដល់ឆ្នាំ២០២០។ កំណត់ត្រានេះត្រូវបានកត់សម្គាល់នៅក្នុងការពិនិត្យតាមដាន E&S របស់ IFC ដោយមិនមានការតាមដានទាក់ទងនឹងការប្រឈមកម្រិតទាបនេះទេ។ ការពិនិត្យតាមដាន E&S របស់ IFC នៅឆ្នាំ២០១៧ ក៏បានកត់សម្គាល់ផងដែរថា វិនិយោគិន MFI របស់ MIFA ប្រហែល ៧០% មិនបានរួមបញ្ចូលបញ្ជីផាត់ចេញនៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចីរបស់ពួកគេនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ IFC មិនបានដោះស្រាយបញ្ហានេះ នៅក្នុងការពិនិត្យតាមដាន ឆ្នាំ២០១៨-២០២០ របស់ខ្លួនជាបន្តបន្ទាប់ឡើយ។ នៅឆ្នាំ២០២១ និង ២០២២ IFC បានកត់សម្គាល់ថា កិច្ចព្រមព្រៀងប្រាក់កម្ចីរបស់វិនិយោគិន MIFA មានបញ្ជីផាត់ចេញ ស្របតាមវិស័យ និងសកម្មភាពដែលត្រូវបានរឹតបន្តឹងរបស់ IFC ដោយមិនមានព័ត៌មានលម្អិតបន្ថែមទៀតទេ។

- នៅចន្លោះឆ្នាំ២០១៨ និង ឆ្នាំ២០២៣ North Haven Thai បានរាយការណ៍យ៉ាងជាប់លាប់ថា មិនមានការប្រឈមនឹងបញ្ជីផាត់ចេញនោះទេ។[478] ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូកត់សម្គាល់ថា បញ្ជីផាត់ចេញ ដែលបានរួមបញ្ចូលនៅក្នុង ESMS ឆ្នាំ២០១៨ របស់ North Haven Thai មិនមានបញ្ញត្តិស្តីពីជនជាតិដើមភាគតិចនោះទេ។ នៅខណៈពេលដែលតម្រូវឱ្យមានកំណែ ESMS ថ្មីបំផុតនោះ របាយការណ៍ត្រួតពិនិត្យ E&S របស់ IFC ឆ្នាំ២០១៨ មិនបានសម្គាល់ឃើញភាពខុសគ្នានោះទេ។ ការត្រួតពិនិត្យ E&S របស់ IFC ជាបន្តបន្ទាប់ បានរាយការណ៍យ៉ាងខ្ជាប់ខ្ជួនអំពីការមិនប្រឈមនឹងបញ្ជីផាត់ចេញនេះ ដោយមិនបានលើកឡើងអំពីភាពខុសគ្នារវាងបញ្ជីផាត់ចេញរបស់ North Haven Thai និងបញ្ជីផាត់ចេញរបស់ IFC នោះទេ។
- នៅចន្លោះឆ្នាំ២០០៩ និង ឆ្នាំ២០២១ Advans បានរាយការណ៍យ៉ាងជាប់លាប់ថា មិនមានការប្រឈមនឹងបញ្ជីផាត់ចេញ ដែលបានរួមបញ្ចូលសកម្មភាពដែលរំលោភលើដីជាកម្មសិទ្ធិ ឬទាមទារដោយជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមជាឯកសារពេញលេញរបស់ពួកគេនោះទេ។ បញ្ជីផាត់ចេញរបស់ Advans បានផ្តល់ការណែនាំដល់មន្ត្រីឥណទាននៅតាមសាខារបស់ខ្លួន ប៉ុន្តែមិនបានរួមបញ្ចូលចំណុចស្តីពីជនជាតិដើមភាគតិច នៅក្នុងការណែនាំនោះទេ។[479] Advans មិនតម្រូវឱ្យការព្រមព្រៀងតាមផ្លូវច្បាប់នៅសាខារបស់ខ្លួនរួមបញ្ចូលភាពអនុលោមតាមបញ្ជីផាត់ចេញនោះទេ ប៉ុន្តែចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០២១ FI បានរាយការណ៍ថា ប្រាក់កម្ចីទាំងអស់ត្រូវបានត្រួតពិនិត្យធៀបនឹងបញ្ជីផាត់ចេញ ដែលជាផ្នែកមួយនៃ ESMS របស់វា។ ទោះបីជាយ៉ាងណាក៏ដោយ មានអសង្គតិភាពមួយចំនួននៅក្នុងរបាយការណ៍របស់ Advans។ ឧទាហរណ៍ នៅឆ្នាំ២០១០ អតិថិជនបន្តរបស់ IFC ទាំងពីរ បានរាយការណ៍ថា មិនមានការប្រឈមនឹងបញ្ជីផាត់ចេញនោះទេ និងបានជូនដំណឹងទៅកាន់ IFC ថា មីក្រូអាជីវកម្មមួយចំនួនដែលផ្តល់ហិរញ្ញប្បទានដោយសាខារបស់ Advans

[478] ស៊ីអេអូមិនមានកំណត់ត្រានៃរបាយការណ៍ E&S របស់ North Haven Thai ចាប់ពីឆ្នាំ២០២១ និង ឆ្នាំ២០២២ និងការពិនិត្យតាមដានរបស់ IFC នៅឆ្នាំ២០១៩ នោះទេ។

[479] នៅក្រោយឆ្នាំ២០១៤ ទម្រង់របាយការណ៍របស់ Advans មានការកែប្រែ ហើយវាបានឈប់ភ្ជាប់បញ្ជីផាត់ចេញរបស់ពួកគេនៅក្នុងរបាយការណ៍ដែលពួកគេដាក់ជូន IFC។

ពេលខ្លះ បានចូលរួមក្នុងសកម្មភាព ដែលរួមបញ្ចូលពាណិជ្ជកម្មភេសជ្ជៈមានជាតិអាល់កុល និងថ្នាំជក់ ដែលមាននៅក្នុងបញ្ជីការហាមឃាត់។ ការត្រួតពិនិត្យ E&S របស់ IFC នៅឆ្នាំ២០១០ មិនបានកត់ត្រាពីអសង្គតិភាពនេះនៅក្នុងរបាយការណ៍របស់អតិថិជនរបស់ខ្លួនទេ ប៉ុន្តែបានកត់សម្គាល់ថា សាខាបានបដិសេធប្រាក់កម្ចីជាញឹកញាប់ ដោយសារធាតុនៃបញ្ជីផាត់ចេញនេះ ឬផលប៉ះពាល់អវិជ្ជមានចំពោះសង្គម ឬបរិស្ថាន ជាមូលហេតុដែលមន្ត្រីឥណទានបានទៅជួបអតិថិជនជាទៀងទាត់ ដើម្បីវាយតម្លៃភាពអនុលោមតាមបញ្ជីផាត់ចេញ។ ចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២១ Advans បានរាយការណ៍ទៅកាន់ IFC ថា មន្ត្រីឥណទានរបស់ខ្លួនបានអនុវត្តបញ្ជីផាត់ចេញ បានចុះត្រួតពិនិត្យ បន្ទាប់ពីបានបញ្ចេញប្រាក់ ដើម្បីធានាចំពោះភាពអនុលោម និងបានបញ្ឈប់ការពិចារណាបន្ថែមលើការផ្តល់ហិរញ្ញប្បទាន ប្រសិនបើគម្រោងពាក់ព័ន្ធនឹងសកម្មភាពដែលត្រូវបានផាត់ចេញ។ Advans ក៏បានជូនដំណឹងទៅកាន់ IFC ផងដែរថា ខ្លួនបានផ្តល់ការបណ្តុះបណ្តាលស្តីពីការពិនិត្យមើលបញ្ជីផាត់ចេញដល់អ្នកគ្រប់គ្រងសាខា និងមន្ត្រីឥណទាន។ ការពិនិត្យតាមដាន E&S របស់ IFC ក្នុងអំឡុងពេលប៉ុន្មានឆ្នាំនេះ បានកត់សម្គាល់យ៉ាងជាប់លាប់ថា ប្រាក់កម្ចីទាំងអស់ត្រូវបានត្រួតពិនិត្យធៀបនឹងបញ្ជីផាត់ចេញ និងថាសាខារបស់ Advans មិនប្រឈមនឹងសកម្មភាពដែលត្រូវបានផាត់ចេញ ដោយមិនមានការពិចារណា ឬព័ត៌មានលម្អិតបន្ថែមទៀតនោះទេ។[480] ផលប៉ះពាល់ដែលអាចកើតឡើងចំពោះជនជាតិដើមភាគតិច មកពី Advans ឬប្រតិបត្តិការរបស់សាខា មិនត្រូវបានលើកឡើងនៅក្នុងការរាយការណ៍របស់ Advans ឬការត្រួតពិនិត្យ E&S របស់ IFC នោះទេ។

ស៊ីអេអូរកមិនឃើញភស្តុតាងដែលថា IFC បានស្នើសុំព័ត៌មាន ឬបានត្រួតពិនិត្យ ថាតើគ្រឹះស្ថានហិរញ្ញវត្ថុបានអនុលោមតាមច្បាប់ជាតិដែលពាក់ព័ន្ធ ស្តីពីជនជាតិដើមភាគតិច ក្នុងអំឡុងពេលត្រួតពិនិត្យរបស់ IFC លើការវិនិយោគទាំង ១៣ នោះទេ។ ស៊ីអេអូក៏រកមិនឃើញភស្តុតាងដែលថា IFC បានត្រួតពិនិត្យ ឬពិនិត្យតាមដានគោលនយោបាយ និងការអនុវត្តរបស់គ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះដែរ។

### *៤.៤.២.២ សេចក្តីសន្និដ្ឋានអំពីភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចក្នុងការត្រួតពិនិត្យនៃគោលនយោបាយនិរន្តរភាព ពាក់ព័ន្ធនឹងផលប៉ះពាល់លើជនជាតិដើមភាគតិច*

ការត្រួតពិនិត្យរបស់ IFC លើការវិនិយោគនៅក្នុងសំណុំរឿងនេះ បានរួមបញ្ចូលការអនុវត្តបញ្ជីផាត់ចេញដោយអតិថិជនទាំងប្រាំពីររបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូបានរកឃើញភស្តុតាងតិចតួចដែលថា IFC បានផ្តល់ដំបូន្មាន ឬការណែនាំដល់អតិថិជនរបស់ខ្លួនអំពីបញ្ញត្តិស្តីពីការផាត់ចេញនៅក្នុងបញ្ជីនោះ ទាក់ទងនឹងជនជាតិដើមភាគតិច។ ទោះបីជាក្នុងករណីដែលអតិថិជនបានរាយការណ៍ថា ធាតុនៃការផាត់ចេញនៃ IP គឺជាមូលហេតុទូទៅនៃការបដិសេធប្រាក់កម្ចីក៏ដោយ ក៏ IFC មិនបានស្នើសុំធ្វើការផ្ទៀងផ្ទាត់ពីរបៀបដែលវាត្រូវបានអនុវត្តនោះទេ។

[480] បន្ទាប់ពីមានការចុះត្រួតពិនិត្យអម្រឹតនៅខែមីនា ឆ្នាំ២០១៧ IFC បានកត់សម្គាល់នៅក្នុងការពិនិត្យតាមដាន Advans ថា ការពិនិត្យមើលបញ្ជីផាត់ចេញនៅក្នុងអម្រឹត ត្រូវបានធ្វើឡើងដោយមន្ត្រីឥណទានសម្រាប់ប្រាក់កម្ចី ឬអតិថិជនដោយមិនគិតពីចំនួនប្រាក់កម្ចីនោះទេ និងបានវិនិច្ឆ័យថា Advans Group មិនតម្រូវឱ្យសាខារួមបញ្ចូលការព្រមព្រៀងតាមផ្លូវច្បាប់នៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចីរបស់ពួកគេជាមួយអតិថិជន ទាក់ទងនឹងភាពអនុលោមតាមការផាត់ចេញ និងច្បាប់ជាតិនោះទេ ពីព្រោះការត្រួតពិនិត្យ E&S ត្រូវបានធ្វើឡើងមុនពេលបង្កើតកិច្ចសន្យាប្រាក់កម្ចី ដូច្នេះជាទូទៅ សកម្មភាពនៅក្នុងបញ្ជីផាត់ចេញមិនត្រូវបានផ្តល់ហិរញ្ញប្បទានជូនទេ។

លើសពីនេះទៀត ទោះបីជាអតិថិជនបានរាយការណ៍ដោយខ្លួនឯងទៅកាន់ IFC ថា មូលហេតុដែលទាក់ទងនឹង IP បាននាំឲ្យមានការបដិសេធការស្នើសុំប្រាក់កម្ចីក៏ដោយ ក៏ស៊ីអេអូរកមិនឃើញភស្តុតាងដែលថា IFC បានតាមដានព័ត៌មាននេះ ឬបានត្រួតពិនិត្យអតិថិជនរបស់ខ្លួន ដើម្បីធានាថា សកម្មភាពរបស់ពួកគេអនុលោមតាម PS7 និងបញ្ញត្តិដែលពាក់ព័ន្ធនៃបញ្ជីផាត់ចេញនោះទេ។ នេះជាចំណុចដែលគួរឱ្យកត់សម្គាល់ជាពិសេស ដោយសារការអនុវត្តនៃការទទួលយកប័ណ្ណកម្មសិទ្ធិដីទន់ ដែលត្រួតស៊ីគ្នានឹងដីសហគមន៍ IP ជាវត្ថុបញ្ចាំ ដោយគ្មានការយល់ព្រមពីសហគមន៍ (សូមមើលផ្នែក ៤.២.២)។[481]

CAO ក៏រកមិនឃើញភស្តុតាងដែលថា IFC បានផ្តល់ដំបូន្មាន ឬបានពិនិត្យតាមដានកិច្ចប្រឹងប្រែងរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលធ្វើការនៅក្នុងតំបន់ដែលប្រជាជនភាគច្រើនជា IP ធ្វើការកែសម្រួលសេវាកម្ម និងផលិតផលរបស់ពួកគេ ដើម្បីជៀសវាងគ្រោះថ្នាក់នោះទេ។

ផ្អែកតាមចំណុចខាងលើ ស៊ីអេអូរកឃើញថា IFC មិនបានអនុលោមតាមកាតព្វកិច្ចរបស់ខ្លួននៅក្រោមគោលនយោបាយនិរន្តរភាព ដើម្បីធានាថា តាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគរបស់ខ្លួន អតិថិជនរបស់ខ្លួនបានជៀសវាង និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច។ ជាពិសេស IFC មិនបានធានាថា សកម្មភាពមីក្រូហិរញ្ញវត្ថុដែលអតិថិជនរបស់ខ្លួនផ្តល់ហិរញ្ញប្បទានមិនប៉ះពាល់ដល់ដី IP ដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីសហគមន៍នោះទេ (PS7 ឆ្នាំ២០១២ កថាខណ្ឌ ៨ និង ៩[482] និងបញ្ជីផាត់ចេញរបស់ IFC)។ IFC ក៏មិនបានធានាថា អតិថិជនរបស់ខ្លួនបានអនុវត្តតាមច្បាប់ជាតិស្តីពីកិច្ចការពារដីជនជាតិដើមភាគតិចនោះទេ (គោលនយោបាយនិរន្តរភាពឆ្នាំ២០១២ កថាខណ្ឌ ៣៥ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌ ៥)[483] និងលក្ខខណ្ឌតម្រូវ GIIP ទាក់ទងនឹងតម្លាភាព និងការកែសម្រួលសេវាកម្ម និងផលិតផលហិរញ្ញវត្ថុ ដើម្បីជៀសវាងគ្រោះថ្នាក់ (គោលនយោបាយនិរន្តរភាពឆ្នាំ២០១២ កថាខណ្ឌ ៣៥ PS1 កថាខណ្ឌ ៧)។

## ៤.៥ ភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចនៃក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ទាក់ទងនឹងលទ្ធភាពទទួលបានដំណោះស្រាយបណ្តឹងសារទុក្ខ

ដូចបានពន្យល់នៅក្នុងផ្នែក ៣.៧ និង ៤.២.៣ គោលនយោបាយ E&S របស់ IFC តម្រូវឱ្យអតិថិជន FI មានយន្តការទំនាក់ទំនងខាងក្រៅ ឬយន្តការបណ្តឹងសារទុក្ខ។ យន្តការនេះត្រូវបានតម្រូវ ដើម្បីទទួលយក ចុះឈ្មោះ ពិនិត្យ វាយតម្លៃ តាមដាន ឆ្លើយតប និងធ្វើសកម្មភាពចំពោះការសាកសួរ និងការតវ៉ាពីសាធារណជនអំពីប្រតិបត្តិការរបស់ពួកគេ ដោយមិនមានការសងសឹកចំពោះការលើកឡើងនូវបណ្តឹងសារទុក្ខនោះទេ។ [484]

---

[481] UN OHCHR ការវាយតម្លៃពីឱកាសឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ការកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ ខែតុលា ឆ្នាំ២០១៨ ទំ. ២៧ https://bit.ly/4bShl1P និង Brook, Jack "ការបាត់បង់ដីធ្លី និងចំណុលៈ ខ្សែបន្ទាត់ខាងក្រោមនៃការយល់ខុសអំពីមីក្រូឥណទាន" *South East Asia Globe* ខែឧសភា ឆ្នាំ២០២២ មាននៅ https://bit.ly/44C6L0s និងសេចក្តីប្រកាសព័ត៌មានរួមគ្នារបស់ ABC និង CMA ស្តីពីបញ្ជីវត្ថុបញ្ចាំដែលត្រូវបានហាមឃាត់ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ https://bit.ly/45flCkh។

[482] សម្រាប់ការវិនិយោគនៅ MEF PS7 ឆ្នាំ២០០៦ កថាខណ្ឌ ៧ និង ៨។

[483] សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌ ៣ និង សម្រាប់ការវិនិយោគនៅ Advans IFC OP ៤.០១ កថាខណ្ឌ ៩។

[484] គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៥, PS1 ឆ្នាំ២០១២ កថាខណ្ឌ ៣៤ និង ៣៥។ សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨ និង ២៩ PS1 ឆ្នាំ២០០៦ កថាខណ្ឌ ២៣។

លក្ខខណ្ឌតម្រូវរបស់ IFC ត្រូវបានបំពេញបន្ថែមដោយលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិ និង GIIP ដែលតម្រូវឱ្យអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ធានាបាននូវភាពអាចស្វែងរកបាននៃយន្តការបណ្តឹងឆ្លើយតប និងដំណើរការដោះស្រាយបញ្ហា។ គោលនយោបាយនិរន្តរភាពរបស់ IFCក៏ចែងផងដែរថា IFC រំពឹងឲ្យអតិថិជនរបស់ខ្លួនកាត់បន្ថយជាអប្បបរមានូវហានិភ័យទាក់ទងនឹងយេនឌ័រពីសកម្មភាពអាជីវកម្ម និងផលប៉ះពាល់ខុសគ្នាតាមយេនឌ័រដោយអចេតនា។[485]

### ៤.៥.១ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវនៃការវិនិយោគរបស់ខ្លួន នៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA

ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគ IFC បានត្រួតពិនិត្យបណ្តឹងសារទុក្ខរបស់អតិថិជនឬយន្តការទំនាក់ទំនងខាងក្រៅ នៅក្នុងការវិនិយោគចំនួនប្រាំបីក្នុងចំណោមការវិនិយោគទាំង ១៣ ដែលបានគ្របដណ្តប់ដោយពាក្យបណ្តឹងនេះ។ IFC មិនបានពង្រីកវិសាលភាពនៃការត្រួតពិនិត្យលើការវិនិយោគទាំងនេះ ទៅកាន់ការវាយតម្លៃយ៉ាងហ្មត់ចត់លើសមត្ថភាពរបស់អតិថិជនក្នុងការដោះស្រាយពាក្យបណ្តឹង ឬប្រសិទ្ធភាពនៃយន្តការទាំងនេះទេ។ ផ្ទុយទៅវិញ IFC ជាទូទៅ បានដាក់កម្រិតលើការត្រួតពិនិត្យរបស់ខ្លួនដើម្បីផ្ទៀងផ្ទាត់អត្ថិភាពនៃយន្តការ ឬប្រព័ន្ធទំនាក់ទំនងខាងក្រៅ។[486] ករណីលើកលែងរួមមាន (i) ការវិនិយោគរបស់ IFC នៅ North Haven Thai នៅឆ្នាំ២០១៨ ដែល IFC ទាមទារឱ្យមានការបង្កើតយន្តការសាមញ្ញមួយនៅក្នុង ESAP របស់អតិថិជន (ii) ESDD របស់ IFC នៅអេស៊ីលីដា ដែលផ្តល់ព័ត៌មានលម្អិតមួយចំនួនអំពីដំណើរការដែលបានអនុវត្តសម្រាប់ដោះស្រាយពាក្យបណ្តឹងជាផ្លូវការ (លេខ ៤៤៨៨២) និង (iii) ការវិនិយោគរបស់ IFC ឆ្នាំ២០២១ នៅធនាគារ ហត្ថា (លេខ ៤៥៥៣៥ និង ៤៤៧៤២) ដែល IFC បានតម្រូវឲ្យបង្កើតយន្តការទំនាក់ទំនង E&S ខាងក្រៅ ដែលជាផ្នែកមួយនៃការកែលម្អ ESMS របស់គម្រោង។

នៅក្នុងការវិនិយោគដែលនៅសល់ចំនួនប្រាំទៀត IFC មិនបានស្នើសុំ ត្រួតពិនិត្យ ឬផ្ទៀងផ្ទាត់អត្ថិភាពនៃយន្តការបណ្តឹងសារទុក្ខនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះទេ។ ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC នៅលើ MEF MIFA និង Advans ត្រូវបានធ្វើឡើងនៅចន្លោះឆ្នាំ២០០៤ និង ឆ្នាំ២០១២ (លេខ ២៧៨២៧ ៣១៤៦៧ និង ២១៨៥៦) មិនបានរួមបញ្ចូលការត្រួតពិនិត្យ ឬស្នើសុំឲ្យបង្កើតយន្តការបណ្តឹងសារទុក្ខ ឬយន្តការទំនាក់ទំនងខាងក្រៅនៅតាម FI ឬនៅកម្រិតអតិថិជនបន្តនោះទេ។ ដូចគ្នាដែរ ទាំងការវិនិយោគភាគហ៊ុនរបស់ IFC នៅឆ្នាំ២០១៤ និងការវិនិយោគប្រាក់កម្ចីនៅឆ្នាំ២០១៨ នៅអម្រឹត (លេខ ៣៤៧៤៨ និង ៤១២៩៤) បានរួមបញ្ចូល ESDD នៃយន្តការសារទុក្ខ ឬយន្តការទំនាក់ទំនងខាងក្រៅ។ ជាចុងក្រោយ ក្នុងការវិនិយោគនៅឆ្នាំ២០១៧ នៅធនាគារហត្ថា (លេខ ៣៩១៦៧) IFC បានពិចារណាលើទំនាក់ទំនងខាងក្រៅ ក្នុងអំឡុងពេល ESDD ប៉ុន្តែបានកំណត់ថា វាជាបញ្ហា E&S មិនសំខាន់ ដោយសារលក្ខណៈមីក្រូហិរញ្ញវត្ថុនៃអាជីវកម្មរបស់

---

485 គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ១៣។ គោលនយោបាយ E&S របស់ IFC មុនៗ (អនុវត្តចំពោះការវិនិយោគរបស់ IFC នៅក្នុង MEF និង Advans) មិនមានលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់គ្រប់គ្រងហានិភ័យដែលទាក់ទងនឹងយេនឌ័រនោះទេ។

486 ចំពោះការវិនិយោគនៅឆ្នាំ២០១៩ និង ២០២០ នៅធនាគារហត្ថា អេស៊ីលីដា និងអម្រឹត នៅខណៈពេលដែលមានភស្តុតាងដែលថា ការគ្រប់គ្រងបណ្តឹងសារទុក្ខគឺជាផ្នែកមួយនៃរបៀបវារៈ ក្នុងអំឡុងពេលធ្វើបេសកកម្មវាយតម្លៃនៅអេស៊ីលីដានោះ លទ្ធផល ESDD បង្ហាញតែបណ្តាញទំនាក់ទំនង ដែលមានតំណភ្ជាប់ទៅកាន់គេហទំព័ររបស់អតិថិជន សម្រាប់ភាគីពាក់ព័ន្ធខាងក្រៅតែប៉ុណ្ណោះ។ IFC មិនបានផ្តល់ព័ត៌មានលម្អិត ឬភស្តុតាងបន្ថែមដែលថា ខ្លួនបានត្រួតពិនិត្យលើភាពគ្រប់គ្រាន់នៃដំណើរការរបស់អតិថិជន ដាច់ដោយឡែកពីគ្នានោះទេ (អេស៊ីលីដាលេខ ៤២៤៨០ អម្រឹតលេខ ៤៤២៣១ និងធនាគារ ហត្ថា លេខ ៤៤២១១)។

ក្រុមហ៊ុន។ នៅក្នុងការត្រួតពិនិត្យនោះ IFC មិនបានពិចារណាថា ESMS របស់អតិថិជនគួរតែអនុវត្តតាម GIIP នៅក្រោម PS1 និងអនុលោមតាមស្តង់ដារ GIIP សម្រាប់មីក្រូហិរញ្ញវត្ថុ ដែលទាមទារឱ្យមានយន្តការដែលអាចប្រើប្រាស់បាន អាចកែសម្រួលបាន និងមានប្រសិទ្ធភាព ទាន់ពេលវេលា និងមានការឆ្លើយតបនឹងពាក្យបណ្តឹង និងការដោះស្រាយបញ្ហា។ ក្រោយមក នៅឆ្នាំនោះ ធនាគារជាតិនៃកម្ពុជាបានចេញបទប្បញ្ញត្តិដែលតម្រូវឱ្យ FIs ទាំងអស់នៅកម្ពុជាត្រូវតែមានយន្តការដោះស្រាយពាក្យបណ្តឹង។ IFC បានដឹងអំពីបទប្បញ្ញត្តិនេះ ដោយសារខ្លួនបានគាំទ្រ និងណែនាំ NBC អំពីការអភិវឌ្ឍ (សូមមើលផ្នែកទី ៤.១ ខាងលើ)។

ជាទូទៅ IFC បានធ្វើការត្រួតពិនិត្យភាពត្រឹមត្រូវតិចតួចលើយន្តការបណ្តឹងសារទុក្ខ ដែលផ្តល់ដោយអតិថិជន និងអតិថិជនបន្ត FI របស់ខ្លួន ដើម្បីធានាចំពោះលទ្ធភាពទទួលបានសំណងសម្រាប់អ្នកខ្ចី។ នៅក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន IFC មិនបានត្រួតពិនិត្យភាពគ្រប់គ្រាន់នៃយន្តការដែលអនុវត្តដោយធនាគារ MFIs និងមូលនិធិទាំងនោះទេ។ មានការត្រួតពិនិត្យតិចតួចអំពីរបៀបដំណើរការយន្តការ របៀបអនុវត្ត ឬប្រសិទ្ធភាពរបស់យន្តការទាំងនោះក្នុងការគ្រប់គ្រងពាក្យបណ្តឹងពីអ្នកខ្ចី។

### ៤.៥.២ សកម្មភាពរបស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា អម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA

ការត្រួតពិនិត្យរបស់ IFC លើយន្តការបណ្តឹងសារទុក្ខ និងយន្តការទំនាក់ទំនង ដែលដំណើរការដោយអតិថិជន FI ទាំងប្រាំពីរ ក្នុងរយៈពេលជាង ២០ ឆ្នាំ នៃការវិនិយោគ ត្រូវបានរៀបរាប់លម្អិតនៅខាងក្រោម។

នៅឆ្នាំ២០១៩ និង ឆ្នាំ២០២០ អេស៊ីលីដាបានរាយការណ៍អំពីយន្តការបណ្តឹងសារទុក្ខរបស់ខ្លួនតាមរយៈរបាយការណ៍ E&S ប្រចាំឆ្នាំរបស់ខ្លួន ដោយបញ្ជាក់ថា យន្តការទំនាក់ទំនងខាងក្រៅរបស់ខ្លួនបានផ្តល់លទ្ធភាពប្រើប្រាស់ និងកន្លែងទំនាក់ទំនងសម្រាប់ពាក្យបណ្តឹង និងការសាកសួររបស់អតិថិជន។ ក្នុងអំឡុងពេលនេះ អេស៊ីលីដាបានទទួលពាក្យបណ្តឹង និងសំណួររាប់ពាន់ ដែលត្រូវបានចាត់ថ្នាក់ជាបញ្ហាយ៉ាងទូលំទូលាយ ដែលភាគច្រើនទាក់ទងនឹងប្រព័ន្ធធនាគារ និងការលើកឡើងទូទៅមួយចំនួនអំពីសេវាអតិថិជន ឯកជនភាពនៃទិន្នន័យ និងការពន្យល់អំពីថ្លៃសេវា។ ការត្រួតពិនិត្យរបស់ IFC លើរបាយការណ៍ទាំងនោះបានកត់សម្គាល់ថា យន្តការទំនាក់ទំនងខាងក្រៅមានភាពគួរជាទីពេញចិត្ត និងបានរក្សាទុកឲ្យនៅដដែលអស់រយៈពេលជាច្រើនឆ្នាំ។ នៅឆ្នាំ២០២១ របាយការណ៍ E&S របស់អេស៊ីលីដាមិនរួមបញ្ចូលព័ត៌មានទាក់ទងនឹងយន្តការទំនាក់ទំនងខាងក្រៅរបស់ខ្លួនទេ ប៉ុន្តែការត្រួតពិនិត្យរបស់ IFC បានកត់សម្គាល់ថា បណ្តាញទំនាក់ទំនងដែលគួរជាទីពេញចិត្ត ត្រូវបានបង្កើតឡើង និងថែរក្សា សម្រាប់ការទទួលមតិយោបល់ពីខាងក្រៅ។ បណ្តាញទាំងនេះ រួមមាន មជ្ឈមណ្ឌលហៅទូរសព្ទ ២៤/៧ អ៊ីមែលដែលបានកំណត់ និងគេហទំព័រក្រុមហ៊ុន។ ការត្រួតពិនិត្យរបស់ IFC នៅឆ្នាំ២០២២ និង ២០២៣ បានរកឃើញសារជាថ្មីថា យន្តការនោះគួរជាទីពេញចិត្ត ដោយមិនមានការវាយតម្លៃបន្ថែមលើដំណើរការ ឬប្រសិទ្ធភាពរបស់វានោះទេ។[487]

នៅចន្លោះឆ្នាំ២០១៤ និង ឆ្នាំ២០២២ IFC បានទទួលរបាយការណ៍អំពីយន្តការបណ្តឹងសារទុក្ខរបស់អម្រឹតទាំងពីអម្រឹត និងតាមរយៈរបាយការណ៍ស្តីពីសមិទ្ធកម្មបរិស្ថាន (AEPRs) របស់ Advans (នៅចន្លោះឆ្នាំ២០០៩ និង ឆ្នាំ២០២១) និង AEPRs របស់ MIFA (នៅចន្លោះឆ្នាំ២០១៤ និង ឆ្នាំ២០២១)។

---

[487] ស៊ីអេអូមិនមានកំណត់ត្រានៃរបាយការណ៍ E&S របស់អេស៊ីលីដា ចាប់ពីឆ្នាំ២០២២ ដល់ ឆ្នាំ២០២៣ នោះទេ។

- ចាប់ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៤ Advans មិនបានរាយការណ៍អំពីយន្តការបណ្តឹងសារទុក្ខរបស់ខ្លួនផ្ទាល់ ឬយន្តការបណ្តឹងសារទុក្ខរបស់អម្រ៉ឹតនោះទេ[488] ហើយ IFC មិនបានវាយតម្លៃ ឬយោងដល់ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធខាងក្រៅ របស់ Advans ឬសាខារបស់វាគឺ អម្រ៉ឹត ក្នុងអំឡុងពេលពិនិត្យតាមដាន E&S នោះទេ។[489]
- ក្នុងឆ្នាំ២០២៤ អម្រ៉ឹតបានចាប់ផ្តើមរាយការណ៍ទៅកាន់ IFC ដោយផ្ទាល់ ហើយចាប់ពីឆ្នាំ២០១៤ ដល់ ២០១៨ បានរាយការណ៍ថា មិនបានទទួលបណ្តឹងសារទុក្ខនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការពិនិត្យតាមដានរបស់ IFC លើការវិនិយោគរបស់ Advans និង MIFA បានបង្ហាញថា អម្រ៉ឹត បានទទួលពាក្យបណ្តឹងមួយចំនួន ២៣ ក្នុងឆ្នាំ២០១៤ ដែលភាគច្រើន ទាក់ទងនឹងសេវាអតិថិជន និងការប្រព្រឹត្តិរបស់បុគ្គលិកចំពោះអតិថិជន (បានរាយការណ៍ទៅកាន់ MIFA)។[490] នៅឆ្នាំ២០១៥ អម្រ៉ឹតបានទទួលពាក្យបណ្តឹង និងសំណួររាប់ពាន់ ហើយនៅឆ្នាំ២០១៦ និង ឆ្នាំ២០១៧ មានពាក្យបណ្តឹងចំនួន ១០០ (បានរាយការណ៍ទៅកាន់ Advans) លើកឡើងពីបញ្ហាដែលទាក់ទងនឹងផលប៉ះពាល់អវិជ្ជមាននៃការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ដែលអាចកើតឡើង ដូចជា ការប្រព្រឹត្តិរបស់បុគ្គលិក និងសំណើសុំព័ត៌មានឥណទាន។[491] ទោះបីជាមានពាក្យបណ្តឹងដែលពាក់ព័ន្ធទាំងនេះក៏ដោយ ក៏ IFC មិនបានវាយតម្លៃលើទំនាក់ទំនងភាគីពាក់ព័ន្ធរបស់អម្រ៉ឹតដែរ រហូតដល់ឆ្នាំ២០១៨ វាបានពិចារណាថា ទំនាក់ទំនងទាំងនេះគួរជាទីពេញចិត្ត និងបានបញ្ជាក់ថា មិនមានកង្វល់អំពីលក្ខណៈរបស់អតិថិជននោះទេ។[492]
- នៅចន្លោះឆ្នាំ២០១៨ និង ឆ្នាំ២០២១ Advans បានរាយការណ៍ថា អម្រ៉ឹតបានទទួលសំណួរ និងពាក្យបណ្តឹងរាប់ពាន់ ដែលពាក់ព័ន្ធជាចម្បងនឹងវត្ថុបញ្ចាំ អត្រាការប្រាក់ ថ្លៃផាកពិន័យ អាកប្បកិរិយារបស់នយោជិត ការពន្យាពេលសងប្រាក់កម្ចី សេវាអតិថិជន និងការសងប្រាក់កម្ចីមុនកាលកំណត់។ អម្រ៉ឹតបានរាយការណ៍ទៅកាន់ IFC ដោយផ្ទាល់ អំពីពាក្យបណ្តឹងនៅឆ្នាំ២០២០ និង ឆ្នាំ២០២១ អំពីបញ្ហានានា ដូចជា ភាពយឺតយ៉ាវក្នុងការសងប្រាក់កម្ចី សេវាមិនល្អ និងការពន្យារពេលដកវត្ថុបញ្ចាំ។

---

[488] នៅខណៈពេលដែលការវិនិយោគនៅ Advans ត្រូវបានអនុម័តនៅឆ្នាំ២០០៤ នោះ ស៊ីអេអូមិនមានកំណត់ត្រាអំពីការត្រួតពិនិត្យរបស់ IFC មុនឆ្នាំ២០០៩ នោះទេ។

[489] ចាប់ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១១ Advans មិនបានរាយការណ៍ថាមានយន្តការបណ្តឹងសារទុក្ខនោះទេ។ នៅចន្លោះឆ្នាំ២០១២ និង ២០១៤ Advans បានរាយការណ៍អំពីកិច្ចខិតខំប្រឹងប្រែងជាបន្ត ដើម្បីពង្រឹង ឬកសាងយន្តការនានានៅតាមសាខាជាច្រើន ប៉ុន្តែមិនបាននិយាយអំពីកិច្ចខិតខំប្រឹងប្រែងនៅក្នុងប្រទេសកម្ពុជានោះទេ។ នៅក្នុង AEPR លើកទីមួយរបស់ Advans នៅឆ្នាំ២០១៧ បានរាយការណ៍ថា វាមានអ៊ីមែលសាធារណៈ និងទម្រង់សំណួរនៅលើគេហទំព័ររបស់ខ្លួន និងមិនបានទទួលពាក្យបណ្តឹងនៅឆ្នាំនោះទេ។

[490] ព័ត៌មាននេះបានរួមបញ្ចូលនៅក្នុងរបាយការណ៍ E&S ប្រចាំឆ្នាំ២០១៤ របស់ MIFA មិនបានបង្កឱ្យមានការតាមដានណាមួយរបស់ IFC ទាក់ទងនឹងអម្រ៉ឹតនោះទេ។ ទោះបីជាយ៉ាងនេះក្តី ស៊ីអេអូកត់សម្គាល់ថា នៅក្នុងការត្រួតពិនិត្យរបស់ខ្លួន IFC បានកត់សម្គាល់ឃើញមានពាក្យបណ្តឹងជាច្រើន នៅក្នុង MFIs ដែលជាវិនិយោគិនរបស់ MIFA និងបានធ្វើការតាមដាន ជាមួយ MIFA។

[491] នៅចន្លោះឆ្នាំ២០១៤ និង ២០១៦ MIFA បានរាយការណ៍ថា អម្រ៉ឹតមាននីតិវិធីដោះស្រាយបណ្តឹង មន្ត្រីដោះស្រាយបណ្តឹង និងបណ្តាញបណ្តឹងជាច្រើន (ប្រអប់ផ្តល់យោបល់នៅកម្រិតសាខា មជ្ឈមណ្ឌលហៅទូរសព្ទ ទំនាក់ទំនងផ្ទាល់មាត់ ហ្វេសប៊ុក និងអ៊ីមែល) សម្រាប់អ្នកខ្ចីដើម្បីលើកបណ្តឹងរបស់ពួកគេ។ ការវាយតម្លៃរបស់ IFC លើ AEPRs របស់ MIFA ក្នុងអំឡុងពេលនោះ ដែលរួមបញ្ចូលព័ត៌មានអំពីអម្រ៉ឹតបានវាយតម្លៃយន្តការទាំងនេះថា "ជាទីពេញចិត្ត" ដោយមិនមានមតិបន្ថែមទាក់ទងនឹងអម្រ៉ឹត ឬអតិថិជនបន្តផ្សេងទៀត ដែល MIFA បានរាយការណ៍នោះទេ។

[492] នៅឆ្នាំ២០១៧ MIFA មិនបានរាយការណ៍អំពីចំនួនពាក្យបណ្តឹង ដែលអម្រ៉ឹតបានទទួលនោះទេ។ ការពិនិត្យតាមដានរបស់ IFC នៅចន្លោះឆ្នាំ២០១៧ និង ២០១៩ ទាំងអស់ បានវាយតម្លៃយន្តការទាំងនេះថា "ជាទីពេញចិត្ត"។

កំណត់ត្រាការពិនិត្យតាមដានរបស់ IFC លើ Advans MIFA និង អម្រឹត មិនបានរួមបញ្ចូលមតិយោបល់លើការដោះស្រាយបណ្តឹងសារទុក្ខរបស់អម្រឹត ឬភាពខុសគ្នានៃពាក្យបណ្តឹងដែលបានទទួល រវាងរបាយការណ៍របស់អម្រឹត Advans និង MIFA នោះទេ។[493] IFC បានចាត់ទុកយន្តការនេះថាគួរឱ្យពេញចិត្ត តាមរយៈការពិនិត្យតាមដានលើ MIFA ប៉ុន្តែមិនមានភស្តុតាងនៃរបៀបដែលវាបានធ្វើការសន្និដ្ឋាន ឬស្នើសុំព័ត៌មានបន្ថែមនោះទេ។ ផ្ទុយទៅវិញ IFC បានបញ្ចេញយោបល់តែលើដំណើរការទំនាក់ទំនងផ្ទៃក្នុងរវាងវិនិយោគិន និងមូលនិធិប៉ុណ្ណោះ។[494]

- នៅចន្លោះឆ្នាំ២០២២ និង ឆ្នាំ២០២៣ អម្រឹតបានរួមបញ្ចូលការពិពណ៌នាអំពីយន្តការទំនាក់ទំនងខាងក្រៅរបស់ខ្លួនជាលើកដំបូង និងដំណើរការវានៅក្នុងរបាយការណ៍ E&S របស់ខ្លួន ដែលដាក់ជូន IFC ដោយរាយការណ៍អំពីពាក្យបណ្តឹងនៅឆ្នាំ២០២២ និង ឆ្នាំ២០២៣ ដែលភាគច្រើន ទាក់ទងនឹងបញ្ហាធនាគារ។ កំណត់ត្រាពិនិត្យតាមដាន E&S របស់ IFC ចំពោះអម្រឹត ក្នុងអំឡុងពេលពីរឆ្នាំនេះ មិនបានរួមបញ្ចូលព័ត៌មានអំពីយន្តការបណ្តឹងសារទុក្ខរបស់ FI ឬការពិចារណាលើចំនួនពាក្យបណ្តឹងដែលបានរាយការណ៍នោះទេ។

នៅចន្លោះឆ្នាំ២០១៧ និង ឆ្នាំ២០២១ ធនាគារហត្ថា បានរាយការណ៍អំពីយន្តការបណ្តឹងសារទុក្ខរបស់ខ្លួនតាមរយៈរបាយការណ៍ E&S ប្រចាំឆ្នាំ ទៅកាន់ IFC និងបានបង្ហាញថា មិនមានពាក្យបណ្តឹងជាផ្លូវការ ឬមិនផ្លូវការនោះទេ ប៉ុន្តែពេលខ្លះវាបានទទួលពាក្យបណ្តឹងផ្ទាល់មាត់។[495] កំណត់ត្រាការពិនិត្យតាមដានរបស់ IFC បានបញ្ជាក់ថា យន្តការបណ្តឹងសារទុក្ខរបស់ធនាគារមានភាពគួរជាទីពេញចិត្ត ហើយរហូតដល់ឆ្នាំ២០២០ IFC បានចាត់ទុកទំនាក់ទំនងខាងក្រៅ ជាបញ្ហា E&S ដែលមិនសំខាន់សម្រាប់អតិថិជននោះទេ ដោយសារលក្ខណៈនៃអាជីវកម្មរបស់ខ្លួនផ្តោតលើមីក្រូហិរញ្ញវត្ថុ។[496] បន្ទាប់ពី ESAP ត្រូវបានភ្ជាប់មកជាមួយប្រាក់កម្ចីរបស់ IFC នៅឆ្នាំ២០២១ វាបានតម្រូវឱ្យធនាគារហត្ថា អនុវត្តយន្តការទំនាក់ទំនងខាងក្រៅ (សូមមើលផ្នែក ESSD ខាងលើ) កំណត់ត្រាការពិនិត្យតាមដានរបស់ IFC នៅឆ្នាំ២០២២ និង ២០២៣ បានបន្តបញ្ជាក់ថា ទំនាក់ទំនងភាគីពាក់ព័ន្ធខាងក្រៅរបស់ធនាគារគឺ គួរជាទីពេញចិត្ត។ ស្របពេលជាមួយគ្នានោះ IFC បានកត់សម្គាល់ថា ធនាគារហត្ថា មិនបានរាយការណ៍អំពីទំនាក់ទំនងភាគីពាក់ព័ន្ធខាងក្រៅនៅក្នុងរបាយការណ៍ E&S

---

[493] ក្នុងអំឡុងពេលដូចគ្នានេះ MIFA បានរាយការណ៍ថា៖ នៅឆ្នាំ២០២០ អម្រឹតបានទទួលពាក្យបណ្តឹងចំនួន ២០៣ ទាក់ទងនឹងសមតុល្យគណនី ភាពងាយស្រួលរបស់សាខា ដំណើរការបញ្ចេញប្រាក់ ព័ត៌មានអំពីផលិតផល អាកប្បកិរិយារបស់បុគ្គលិក រួមទាំងពាក្យបណ្តឹងចំនួន ១២ ទាក់ទងនឹងការអនុវត្តការប្រមូលប្រាក់ ហើយនៅឆ្នាំ២០២១ ការដោះស្រាយពាក្យបណ្តឹងរបស់អម្រឹត បានអនុវត្តតាមឧត្តមានុវត្ត ដោយមិនមានព័ត៌មានលម្អិតបន្ថែមទៀតនោះទេ។

[494] ការពិនិត្យតាមដានរបស់ IFC លើ Advans ក្នុងអំឡុងពេលនោះ បានពិពណ៌នាតែអំពីយន្តការទូទៅ និងប្រធានបទសំខាន់ៗនៃពាក្យបណ្តឹងសម្រាប់ក្រុម និងសាខារបស់ខ្លួននៅទូទាំងពិភពលោកប៉ុណ្ណោះ ដោយមិនផ្តល់យោបល់ជាក់លាក់លើយន្តការរបស់អម្រឹត ឬចំនួនបណ្តឹង ដែលអម្រឹតបានទទួលនោះទេ។ ស៊ីអេអូមិនមានកំណត់ត្រាអំពីការពិនិត្យតាមដានរបស់ IFC លើ Advans នៅឆ្នាំ ២០២២ នោះទេ។

[495] CAO កត់សម្គាល់ថា នៅចន្លោះឆ្នាំ២០១៧ និង ឆ្នាំ២០២០ នៅខណៈពេលដែលវាមិនមែនជាផ្នែកមួយនៃការស៊ើបអង្កេតនេះ MIFA មានការវិនិយោគនៅធនាគារ ហត្ថា។ ជាលទ្ធផល AEPRs របស់ MIFA ទៅកាន់ IFC រួមបញ្ចូលព័ត៌មានទាក់ទងនឹងយន្តការបណ្តឹងសារទុក្ខរបស់ធនាគារ ហត្ថា។ របាយការណ៍ទាំងនេះបង្ហាញពីអសង្គតិភាពជាមួយការរាយការណ៍របស់ធនាគារហត្ថា ទៅកាន់ IFC ក្នុងអំឡុងពេលនោះ ដោយមិនមានភស្តុតាងដែល IFC បានសម្គាល់ឃើញភាពខុសគ្នាទាំងនេះទេ។ នៅឆ្នាំ២៩១៧ MIFA បានរាយការណ៍ថា ធនាគារ ហត្ថាបានទទួលពាក្យបណ្តឹងចំនួន ២០ ពាក់ព័ន្ធនឹងប្រាក់កម្ចី ការសន្សំប្រាក់ និងសេវាធនាគារតាមទូរសព្ទដៃ។ នៅឆ្នាំ ២០២០ MIFA បានរាយការណ៍ថា ធនាគារ ហត្ថា បានទទួលពាក្យបណ្តឹងចំនួន ៣៦ ទាក់ទងនឹងការអនុវត្តការប្រមូលប្រាក់។

[496] នៅឆ្នាំ២០២១ ការពិនិត្យតាមដានរបស់ IFC មិនបានលើកឡើងពីទំនាក់ទំនងខាងក្រៅជាបញ្ហា E&S មិនសំខាន់នោះទេ។

របស់ខ្លួននោះទេ។ ក្រោយមក IFC មិនបានចងក្រងជាឯកសារ ថាតើយន្តការបណ្ដឹងសារទុក្ខថ្មី ត្រូវបានអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់ ESAP ដែរឬអត់នោះទេ។[497]

ការពិនិត្យតាមដានរបស់ IFC លើមូលនិធិ MEF និង MIFA ផ្ដល់ព័ត៌មានបន្ថែមអំពីការអនុវត្តយន្តការបណ្ដឹងសារទុក្ខដោយអតិថិជនបន្ត អិលអូអិលស៊ី ស្ថាបនា និងប្រាសាក់។

MIFA បានរាយការណ៍ទៅកាន់ IFC អំពីយន្តការបណ្ដឹងសារទុក្ខរបស់អតិថិជនបន្តរបស់ខ្លួន (អម្រឹត អិលអូអិលស៊ី និងស្ថាបនា) ដោយផ្ដល់ព័ត៌មានលម្អិតមួយចំនួនអំពីដំណើរការដោះស្រាយពាក្យបណ្ដឹងរបស់វិនិយោគិនរបស់ខ្លួន ព្រមទាំងចំនួនពាក្យបណ្ដឹងដែលបានទទួលក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ដូចបានសង្ខេបនៅខាងក្រោម៖

- ចាប់ផ្ដើមពីឆ្នាំ២០១៥ មក MIFA បានរាយការណ៍អំពីយន្តការបណ្ដឹងសារទុក្ខរបស់អិលអូអិលស៊ី ដែលមានអង្គភាពទទួលខុសត្រូវក្នុងការដោះស្រាយពាក្យបណ្ដឹងដែលបានដាក់ជូនតាមរយៈមជ្ឈមណ្ឌលហៅទូរសព្ទ និងការផ្សព្វផ្សាយ និងបង្កើនដំណោះស្រាយ។ MIFA បានរាយការណ៍ថា អិលអូអិលស៊ីបានទទួលពាក្យបណ្ដឹងមួយចំនួនតូច (៥០ ឬតិចជាងនេះ) នៅឆ្នាំ២០១៧ និង ឆ្នាំ២០២០ ដែលទាក់ទងនឹងការបដិសេធប្រាក់កម្ចី និងបញ្ហាដទៃទៀត។[498]
- នៅឆ្នាំ២០២០ MIFA បានរាយការណ៍អំពីធនាគារស្ថាបនាជាលើកដំបូង ដែលវាមានប្រអប់ទទួលយោបល់របស់អតិថិជននៅគ្រប់សាខា និងមជ្ឈមណ្ឌលហៅទូរសព្ទ ដើម្បីទទួលពាក្យបណ្ដឹង។ ក្នុងអំឡុងឆ្នាំនោះ ស្ថាបនាបានទទួលពាក្យបណ្ដឹងរាប់ពាន់ ទាក់ទងនឹងប្រាក់កម្ចី ការគ្រប់គ្រងសាច់ប្រាក់ សេវាប័ណ្ណឥណទាន អេធីអឹម ធនាគារឌីជីថល និងសេវាអតិថិជន។
- ការពិនិត្យតាមដានរបស់ IFC លើ MIFA នៅចន្លោះឆ្នាំ២០១៥ និង ឆ្នាំ២០២២ បានវាយតម្លៃយន្តការទាំងនេះថា ជាការពេញចិត្ត ដោយមិនមានមតិយោបល់បន្ថែម ទាក់ទងនឹងអិលអូអិលស៊ី ឬស្ថាបនា ឬអតិថិជនបន្តដទៃទៀតនោះទេ។ កំណត់ត្រារបស់ IFC មិនផ្ដល់ភស្តុតាងថា វាបានពិចារណាលើព័ត៌មានលម្អិតដែលផ្ដល់ដោយ MIFA រួមជាមួយមតិយោបល់ ដែលដាក់កម្រិតលើដំណើរការទំនាក់ទំនងផ្ទៃក្នុងរវាងវិនិយោគិន និងមូលនិធិនោះទេ។

មិនដូចគ្នានឹង MIFA នោះទេ MEF មិនបានផ្ដល់របាយការណ៍លម្អិតស្ដីពីការដោះស្រាយបណ្ដឹងសារទុក្ខដោយអតិថិជនបន្តរបស់ IFC (អម្រឹត ធនាគារហត្ថា អិលអូអិលស៊ី និងប្រាសាក់) និងចំនួនពាក្យបណ្ដឹងដែលពួកគេបានទទួលនោះទេ។ នៅចន្លោះឆ្នាំ២០១០ និង ២០១៥ MEF បានរាយការណ៍ពីការប្រកាន់ខ្ជាប់នូវផលបត្ររបស់ខ្លួនចំពោះគោលការណ៍ការពារអតិថិជន ដែលរួមមាន ការអនុវត្តយន្តការសម្រាប់ដោះស្រាយបណ្ដឹងសារទុក្ខ ដោយផ្អែកលើការរាយការណ៍ដោយខ្លួនឯងរបស់អតិថិជនបន្ត។ ចាប់ពីឆ្នាំ២០០៦ មក MEF បានផ្ដល់ការវាយតម្លៃជាក់លាក់របស់ MFI ចាប់ពី ១-៥ សម្រាប់ដំណោះស្រាយពាក្យបណ្ដឹង ប៉ុន្តែមិនមានព័ត៌មានលម្អិតបន្ថែម អំពីដំណើរការ ចំនួនពាក្យបណ្ដឹងដែលបានទទួល បញ្ហាដែលបានលើកឡើង ឬរបៀបដោះស្រាយនោះទេ។[499] របាយការណ៍ពិនិត្យតាមដានរបស់ IFC នៅចន្លោះឆ្នាំ២០០៩ និង ឆ្នាំ២០១៣ មិនបានផ្ដល់ការ

497 ស៊ីអេអូ មិនមានកំណត់ត្រារបាយកាណ៍ E&S របស់ធនាគារហត្ថា ចាប់ពីឆ្នាំ២០២២ និង ឆ្នាំ២០២៣ នោះទេ។
498 ស៊ីអេអូ មិនមានកំណត់ត្រារបាយកាណ៍ E&S របស់ MIFA ចាប់ពីឆ្នាំ២០២២ និង ឆ្នាំ២០២៣ និងការពិនិត្យតាមដានរបស់ IFC នៅឆ្នាំ២០២៣ នោះទេ។
499 នៅឆ្នាំ២០១៦ និង ឆ្នាំ២០១៧ អម្រឹត អិលអូអិលស៊ី ប្រាសាក់ ស្ថាបនា និងធនាគារហត្ថា តែងតែកត់ត្រា ៥ ជាពិន្ទុខ្ពស់បំផុត។

វាយតម្លៃណាមួយលើការវាយតម្លៃទាំងនេះទេ ហើយនៅចន្លោះឆ្នាំ២០១៤ និង ២០២១ IFC បានវាយតម្លៃលើយន្តការបណ្តឹងសារទុក្ខថា ជាទីពេញចិត្ត។[500] ដោយសារ MEF មិនបានផ្តល់របាយការណ៍លម្អិតអំពីវិនិយោគិនរបស់ខ្លួននោះ វាមិនបានផ្តល់ព័ត៌មានអំពីប្រាសាក់ ដល់ IFC នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ MIFA បានបញ្ជាក់ប្រាប់ IFC ថា ប្រាសាក់មានយន្តការដោះស្រាយពាក្យបណ្តឹងរបស់អតិថិជន និងបានបណ្តុះបណ្តាលបុគ្គលិកឱ្យដោះស្រាយវា ចាប់តាំងពីឆ្នាំ២០១៥ មក និងបានទទួលពាក្យបណ្តឹងរាប់រយនៅឆ្នាំ២០២០។

ជាចុងក្រោយ ទាក់ទងនឹង North Haven Thai, IFC តម្រូវឱ្យអតិថិជនបង្កើតយន្តការទំនាក់ទំនងភាគីពាក់ព័ន្ធខាងក្រៅនៅកម្រិតមូលនិធិ ជាផ្នែកមួយនៃផែនការសកម្មភាព E&S សម្រាប់គម្រោង។ របាយការណ៍ប្រចាំឆ្នាំ E&S លើកដំបូងរបស់អតិថិជន នៅឆ្នាំ២០១៨ បានបញ្ជាក់ថា វាមានយន្តការសម្រាប់ទទួល និងឆ្លើយតបទៅនឹងពាក្យបណ្តឹងជាសាធារណៈ។ កំណត់ត្រាការត្រួតពិនិត្យ E&S របស់ IFC បានចាត់ទុកព័ត៌មាននេះថាពេញលេញ និងគ្រប់គ្រាន់ ស្របពេលជាមួយគ្នានោះ មានការកត់សម្គាល់ថា មានកង្វះខាតព័ត៌មានលម្អិតបន្ថែមទៀត។ បួនឆ្នាំក្រោយ នៅឆ្នាំ២០២០ IFC បានបង្ហាញថា យន្តការទំនាក់ទំនងខាងក្រៅកំពុងរង់ចាំសេចក្តីសម្រេច ហើយនៅឆ្នាំ២០២៣ IFC បានពិចារណាលើការអនុវត្តយន្តការពាក្យបណ្តឹងដែលនឹងត្រូវបញ្ចប់។[501] នៅឆ្នាំ២០២០ និង ឆ្នាំ២០២៣ សកម្មភាពត្រួតពិនិត្យ E&S របស់ IFC បានរាយការណ៍ថា North Haven Thai មិនបានទទួលពាក្យបណ្តឹង ទាក់ទងនឹង E&S នោះទេ ដោយមិនមានព័ត៌មានបន្ថែមអំពីយន្តការបណ្តឹងសារទុក្ខរបស់មូលនិធិនោះទេ។ របាយការណ៍ ឆ្នាំ២០២៣ បានរួមបញ្ចូលព័ត៌មានអំពីអេស៊ីលីដា ប៉ុន្តែមិនបានលើកឡើងអំពីយន្តការបណ្តឹងសារទុក្ខ ឬពាក្យបណ្តឹងដែលបានទទួលនោះទេ។

ជាការឆ្លើយតបនឹងការចោទប្រកាន់អំពីការគំរាមកំហែង និងការសងសឹក ដែលធ្វើឡើងដោយអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ នៅក្នុងពាក្យបណ្តឹងរបស់ពួកគេ ដែលដាក់ជូនស៊ីអេអូនៅឆ្នាំ២០២២ នោះ IFC បានចាប់ផ្តើមចូលរួមជាមួយ និងបណ្តុះបណ្តាលអតិថិជន និងអតិថិជនបន្តមួយចំនួនអំពីការទប់ស្កាត់ ការគ្រប់គ្រង និងការដោះស្រាយហានិភ័យនៃការសងសឹក។ នៅខែវិច្ឆិកា ឆ្នាំ២០២២ IFC បានរៀបចំវគ្គបណ្តុះបណ្តាលតាមបែបនិម្មិតរយៈពេល ៧២ នាទី ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ និងថ្នាក់កណ្តាល មកពីអម្រឹត ធនាគារហត្ថា និងប្រាសាក់។ IFC ក៏បានបង្កើតឯកសារណែនាំសម្រាប់អតិថិជនដែលផ្តល់សេវាមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ស្តីពីការដោះស្រាយកង្វល់នៃការសងសឹក ដែលផ្តោតលើការបង្កើតសេចក្តីថ្លែងការណ៍មិនអត់ឱនចំពោះការសងសឹក និងរួមបញ្ចូលការប្រឆាំងនឹងការសងសឹកនៅក្នុងក្រមសីលធម៌របស់ក្រុមហ៊ុន។[502] លើសពីនេះទៀត IFC បានសហការជាមួយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជា ដើម្បីដាក់បញ្ចូលមេរៀនស្តីពីការគ្រប់គ្រងហានិភ័យ

---

[500] ស៊ីអេអូ មិនមានកំណត់ត្រារបាយកាណ៍ E&S របស់ MEF នៅក្រោយឆ្នាំ២០១៨ និងការពិនិត្យតាមដានរបស់ IFC នៅឆ្នាំ២០២២ និង ឆ្នាំ២០២៣ នោះទេ។

[501] បន្ទាប់ពីមានការស្នើសុំ ក្រុមហ៊ុន North Haven Thai បានផ្តល់ជូនស៊ីអេអូនូវតំណភ្ជាប់ទៅកាន់យន្តការទំនាក់ទំនងខាងក្រៅរបស់ខ្លួន៖ ប្រព័ន្ធទូរសព្ទទាន់ហេតុការណ៍ដើម្បីសុចរិតភាព នៅលើគេហទំព័រ Morgan Stanley ទូទៅ ដែលមិននិយាយអំពី North Haven Thai នោះទេ៖ https://bit.ly/4l7hSa4។ ស៊ីអេអូមិនមានកំណត់ត្រានៃរបាយការណ៍ E&S របស់ North Haven Thai ចាប់ពីឆ្នាំ២០២១ និង ឆ្នាំ២០២២ និងការពិនិត្យតាមដានរបស់ IFC នៅឆ្នាំ២០១៩ នោះទេ។

[502] ក្នុងអំឡុងពេលបណ្តុះបណ្តាល IFC បានចែករំលែកឯកសារណែនាំ ព្រមទាំងកំណត់សម្គាល់ការណែនាំរបស់ IFC ជាមួយអតិថិជន និងអតិថិជនបន្តរបស់ខ្លួន។ សូមមើល៖ IFC ការវិនិយោគ IDB កំណត់សម្គាល់អំពីការអនុវត្តល្អសម្រាប់វិស័យឯកជន៖ ការដោះស្រាយហានិភ័យនៃការសងសឹកនឹងភាគីពាក់ព័ន្ធនឹងគម្រោង ឆ្នាំ២០២១ https://bit.ly/42gGzt2។

នៃការសងសឹកនៅក្នុងវគ្គសិក្សាអំពីការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ ដែលត្រូវបានបង្កើតឡើងដោយមានការគាំទ្រពី IFC នៅឆ្នាំ២០២៣។

ទោះបីជាវាមានភាពវិជ្ជមានក្តី គំនិតផ្តួចផ្តើមទាំងនេះត្រូវបានដាក់កម្រិតចំពោះភាពស៊ីជម្រៅ ហើយស៊ីអេអូរកមិនឃើញភស្តុតាងដែលថា IFC បានរួមបញ្ចូលធាតុនៃការបណ្តុះបណ្តាលទាំងនេះទៅក្នុងការពិនិត្យតាមដាន E&S របស់អតិថិជន និងអតិថិជនបន្តរបស់ខ្លួន រួមទាំង សម្រាប់អម្រឹត និងធនាគារហត្ថា ដែលបានទទួលការបណ្តុះបណ្តាលនោះទេ។ សម្រាប់អតិថិជនដទៃទៀតនៅក្នុងសំណុំរឿងនេះ អេស៊ីលីដា MEF MIFA Advans និង North Haven Thai ស៊ីអេអូបានរកឃើញថា មិនមានភស្តុតាងដែលថា IFC បានផ្តល់ដំបូន្មាន ការណែនាំ ឬការបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ការគំរាមកំហែង និងការសងសឹក នៅក្នុងបរិបទនៃការដោះស្រាយបណ្តឹងសារទុក្ខនោះទេ។

### ៤.៥.៣ សេចក្តីសន្និដ្ឋានអំពីភាពអនុលោមរបស់ IFC ចំពោះគោលនយោបាយនិរន្តរភាពរបស់ខ្លួនទាក់ទងនឹងលទ្ធភាពទទួលបានឧបាស្រ័យ

FIs ដែលជាប់ពាក់ព័ន្ធនឹងគម្រោងទាំង១៣ បានដំណើរការយន្តការបណ្តឹងសារទុក្ខ និងរាយការណ៍អំពីចំនួនបណ្តឹងសារទុក្ខ និងបញ្ហានានាដែលត្រូវបានលើកឡើង ទៅកាន់ IFC។ ទោះបីជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យរបស់ស៊ីអេអូ រកមិនឃើញភស្តុតាងដែលថា ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ IFC បានវាយតម្លៃភាពគ្រប់គ្រាន់ ការបំពេញមុខងារ និងស័ក្តិសិទ្ធភាពនៃយន្តការទាំងនេះទេ។ ដូចគ្នានេះដែរ ក្នុងអំឡុងពេលត្រួតពិនិត្យការវិនិយោគ ការពិនិត្យតាមដានរបស់ IFC លើយន្តការបណ្តឹងសារទុក្ខ ទំនងជាដាក់កម្រិតយ៉ាងខ្លាំងលើការផ្ទៀងផ្ទាត់អត្ថិភាពនៃយន្តការទាំងនេះ ដោយមិនបានត្រួតពិនិត្យការបំពេញមុខងារ ឬភាពគ្រប់គ្រាន់នៃយន្តការទាំងនេះទេ។

IFC មិនបានតាមដានបន្តឡើយ នៅពេលដែលអតិថិជនបានរាយការណ៍អំពីចំនួនបណ្តឹងទាបគួរឱ្យភ្ញាក់ផ្អើលចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ ឬនៅពេលដែលមានអសង្គតភាពនៅក្នុងរបាយការណ៍ដែល IFC បានទទួល។ ឧទាហរណ៍ កំណត់ត្រាត្រួតពិនិត្យរបស់ IFC មិនឆ្លើយតបនឹងអវត្តមាននៃការរាយការណ៍អំពីពាក្យបណ្តឹងពីអម្រឹតក្នុងរយៈពេលជាងប្រាំឆ្នាំឡើយ (នៅចន្លោះឆ្នាំ២០១៤-២០២០) ហើយពួកគេក៏មិនបានធ្វើឲ្យស៊ីគ្នារវាងតួលេខចំនួនពាក្យបណ្តឹងខុសគ្នា ដែលរាយការណ៍ដោយ Advans, MIFA និងអម្រឹត ក្នុងឆ្នាំតែមួយដែរ។ IFC បានវាយតម្លៃយន្តការទំនាក់ទំនងខាងក្រៅរបស់ធនាគារហត្ថាថា ជាទីពេញចិត្ត សម្រាប់រយៈពេលបីឆ្នាំ (ឆ្នាំ២០១៧-២០២០) ប៉ុន្តែក្រោយមក តម្រូវឱ្យធនាគារហត្ថាអនុវត្តយន្តការបែបនេះជាផ្នែកមួយនៃ ESAP ដែលភ្ជាប់ជាមួយនឹងប្រាក់កម្ចីឆ្នាំ២០២១ របស់ខ្លួន ដោយបានលើកឡើងនូវចម្ងល់ថាតើយន្តការនេះមានអត្ថិភាពមុនប្រាក់កម្ចីឆ្នាំ២០២១ មែនដែរឬទេ។ ទោះបីជាការរាយការណ៍របស់ MIFA មានភាពលម្អិត ដោយរួមបញ្ចូលព័ត៌មានអំពីដំណើរការ និងចំនួនពាក្យបណ្តឹងក្តី ការពិនិត្យតាមដានរបស់ IFC លើមូលនិធិរបស់ MIFA មានការផ្តោតតិចតួចទៅលើការផ្ទៀតផ្ទាត់ថា MIFA បានរាយការណ៍អំពីយន្តការរបស់ពួកគេ ដោយគ្មានការតាមដានសំខាន់ៗ ចំពោះព័ត៌មានដែលផ្តល់ជូន ឬការបញ្ជាក់ថាតើវាមានប្រសិទ្ធភាពដែរឬទេ។

ស៊ីអេអូរកមិនឃើញភស្តុតាងដែលថា ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ ឬការត្រួតពិនិត្យជាបន្តបន្ទាប់ IFC បានបញ្ជាក់ថា យន្តការបណ្តឹងសារទុក្ខរបស់ FIs មានភាពឆាប់រហ័ស ងាយស្រួលប្រើប្រាស់ មានភាពសមស្របតាមវប្បធម៌ និងតម្លាភាព ព្រមទាំងមានកិច្ចការពារសុវត្ថិភាពសមស្រប ដើម្បីទប់ស្កាត់ទណ្ឌកម្ម

ស្របតាម PS1 នោះទេ។[503] ស៊ីអេអូក៏រកមិនឃើញភស្តុតាងដែលថា IFC បានធានថា អតិថិជនបានអនុវត្ត គោលនយោបាយ ដើម្បីដោះស្រាយហានិភ័យចំពោះយេនឌ័រជាក់លាក់ នៅក្នុងការគ្រប់គ្រងយន្តការបណ្តឹងសារទុក្ខ ឬការទប់ស្កាត់ការសងសឹកនោះដែរ។[504] ចាប់ពីឆ្នាំ២០២២មក IFC បានផ្តល់ការណែនាំ និងការបណ្តុះបណ្តាលដល់អតិថិជនរបស់ខ្លួន ស្តីពីការទប់ស្កាត់ការគំរាមកំហែង និងការសងសឹក។ ទោះបីជាយ៉ាងណាក៏ដោយ ស៊ីអេអូរកមិនឃើញភស្តុតាងថា IFC បានតម្រូវឱ្យអតិថិជន និងអតិថិជនបន្តរបស់ខ្លួន អនុវត្តតាមការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ចំពោះយន្តការបណ្តឹងសារទុក្ខនៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុនោះទេ។ កាន់តែជាក់លាក់ IFC មិនបានតម្រូវឱ្យអតិថិជនរបស់ខ្លួនធានាថា អ្នកខ្ចីប្រាក់អាចប្រើប្រាស់យន្តការបណ្តឹងសារទុក្ខ ស្របតាមលក្ខខណ្ឌតម្រូវនៃ GIIP នោះទេ។[505]

ជាចុងក្រោយ ស៊ីអេអូរកមិនឃើញភស្តុតាងថា IFC បានព្យាយាមធានាថា អតិថិជនរបស់ខ្លួនបានអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ជាតិស្តីពីការដោះស្រាយពាក្យបណ្តឹងនៅគ្រឹះស្ថានហិរញ្ញវត្ថុ[506] ដូចបានតម្រូវដោយគោលនយោបាយ E&S របស់ IFC នោះទេ។[507]

ហេតុនេះ ស៊ីអេអូរកឃើញថា IFC មិនបានអនុលោមតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាថា មានការបង្កើតយន្តការបណ្តឹងសារទុក្ខគ្រប់គ្រាន់នៅគ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីទទួល ឆ្លើយតប និងសម្របសម្រួលការដោះស្រាយពាក្យបណ្តឹង ឬកង្វល់នានាឱ្យបានទាន់ពេលវេលា ពាក់ព័ន្ធនឹងសមិទ្ធិកម្ម E&S របស់ពួកគេនោះទេ (គោលនយោបាយស្តីពីនិរន្តរភាពឆ្នាំ២០១២, កថាខណ្ឌ ៣៥, PS1 កថាខណ្ឌ ៣៤-៣៥)។[508] IFC ក៏មិនបានព្យាយាមធានាថា អតិថិជនរបស់ខ្លួនបានអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិពាក់ព័ន្ធនឹងការដោះស្រាយពាក្យបណ្តឹងនៅគ្រឹះស្ថានហិរញ្ញវត្ថុដែរ (គោលនយោបាយស្តីពីនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៥, ទិដ្ឋភាពទូទៅនៃ PS កថាខណ្ឌ ៥)[509]

---

503 IFC, PS1 កថាខណ្ឌ ៣៥

504 គោលនយោបាយនិរន្តរភាពចែងថា IFC រំពឹងឲ្យអតិថិជនរបស់ខ្លួនកាត់បន្ថយជាអប្បបរមានូវហានិភ័យទាក់ទងនឹងយេនឌ័រពីសកម្មភាពអាជីវកម្ម និងផលប៉ះពាល់ខុសគ្នាតាមយេនឌ័រដោយអចេតនា។ គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ១៣។ ដូចបានបង្ហាញនៅក្នុងផ្នែក ៤.២.១ (២.ii) ខាងលើ និងផ្នែក ៥.៤ ខាងក្រោម អ្នកខ្ចីជាស្ត្រីប្រឈមនឹងហានិភ័យ និងផលប៉ះពាល់ខុសៗគ្នា ពីការអនុវត្តការប្រមូលប្រាក់ដែលមានលក្ខណៈឈ្លានពាន ក៏ដូចជាទាក់ទងនឹងទម្រង់នៃការគំរាមកំហែង ឬការបំភិតបំភ័យដែលពួកគេអាចប្រឈមមុខ ជាការសងសឹកចំពោះការដាក់ពាក្យបណ្តឹងផងដែរ។

505 ស្តង់ដារ GIIP ផ្តល់អនុសាសន៍ថា ពាក្យបណ្តឹងត្រូវតែដាក់ជូនបុគ្គលដែលមិនមែនជាមន្ត្រីឥណទាន ឬមន្ត្រីផលិតផលរបស់អ្នកខ្ចី និងអ្នកគ្រប់គ្រងរបស់ពួកគេ ជាពិសេសអង្គភាពដែលផ្តោតលើការដោះស្រាយពាក្យបណ្តឹង ដាច់ដោយឡែកពីអង្គភាពអាជីវកម្ម ដែលធ្វើប្រតិបត្តិការ។ ពួកគេក៏អំពាវនាវឱ្យមានបណ្តាញពាក្យបណ្តឹងឥតគិតថ្លៃ និងងាយស្រួលប្រើប្រាស់ យ៉ាងតិចពីរ សម្រាប់ដាក់ពាក្យបណ្តឹង រួមជាមួយនីតិវិធីបញ្ជូនបន្តទៅកាន់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ សម្រាប់ពាក្យបណ្តឹងធ្ងន់ធ្ងរ។ សូមមើល Cerise+ SPTF, បទដ្ឋានសកលសម្រាប់ការគ្រប់គ្រងសមិទ្ធិកម្មបរិស្ថាន និងសង្គម, ២០២២, 4.E.1.2, និងក្រុមធនាគារពិភពលោក, កំណត់ត្រាបច្ចេកទេស៖ ការដោះស្រាយបណ្តឹងនៅក្នុងគោលការណ៍ ការអនុវត្ត និងអភិក្រមនិយ័តកម្មរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ខែមិថុនា ឆ្នាំ២០១៩, ទំព័រ ២-៥ https://bit.ly/3DscZre។

506 ប្រកាស B៧-០១៧-២៩៩ ស្តីពី "ដំណោះស្រាយពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់"" https://bit.ly/3FGuxAB។

507 គោលនយោបាយស្តីពីនិរន្តរភាព ឆ្នាំ២០១២, កថាខណ្ឌ ៣៥, ទិដ្ឋភាពទូទៅនៃ PS, កថាខណ្ឌ ៥។

508 សម្រាប់ការវិនិយោគនៅ MEF គោលនយោបាយស្តីពីនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨ និង ២៩, PS1 ឆ្នាំ២០០៦ កថាខណ្ឌ ២៣។

509 សម្រាប់ការវិនិយោគលើ MEF៖ គោលនយោបាយស្តីពីនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨, ទិដ្ឋភាពទូទៅនៃ PS កថាខណ្ឌ ៣, និងសម្រាប់វិនិយោគលើ Advans, IFC OP 4.01, កថាខណ្ឌ៩។

# ៥. ការវាយតម្លៃរបស់ស៊ីអេអូទៅលើគ្រោះថ្នាក់ដែលពាក់ព័ន្ធ

ផ្នែកនេះត្រួតពិនិត្យគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងគំហើញអំពីបដិលោមភាព ដែលត្រូវបានពន្យល់នៅក្នុងផ្នែកមុន។

ពាក់ព័ន្ធនឹងការចោទប្រកាន់របស់ដើមបណ្ដឹង ចាំបាច់ត្រូវកត់សម្គាល់ថា ការអនុវត្តការផ្ដល់ប្រាក់កម្ចី និងការប្រមូលប្រាក់ដែលមានគ្រោះថ្នាក់ មិននាំឱ្យមានគ្រោះថ្នាក់ដល់គ្រប់គ្រួសារនោះទេ។ មិនមែនអ្នកខ្ចីដែលមិនបំពេញកាតព្វកិច្ចគ្រប់រូបសុទ្ធតែប្រឈមមុខនឹងលក្ខខណ្ឌសេដ្ឋកិច្ចដូចគ្នា ស្ថិតក្រោមការគំរាមកំហែង ឬបានទទួលរងសម្ពាធ និងបានទទួលយកការទាមទារ និងយោបល់មិនសមស្របពីបុគ្គលិក FI នៅទីវាលនោះទេ។ អ្នកខ្ចីមួយចំនួនងាយរងគ្រោះជាង ដោយសារស្ថានភាពសេដ្ឋកិច្ច កម្រិតអក្ខរកម្ម រួមទាំងអក្ខរកម្មផ្នែកច្បាប់ និងហិរញ្ញវត្ថុ ដែនកំណត់ផ្នែកភាសា និងការយល់ដឹងរបស់ពួកគេអំពីសិទ្ធិជាកូនបំណុលរបស់ពួកគេ។ កត្តាទាំងនេះអាចជះឥទ្ធិពលលើផលសម្រេចចុងក្រោយ និងកម្រិតគ្រោះថ្នាក់ដែលបង្កឡើងដោយការអនុវត្តការផ្ដល់ប្រាក់កម្ចី និងការប្រមូលប្រាក់ដែលមានគ្រោះថ្នាក់លើអ្នកខ្ចី។

ដើមបណ្ដឹងចំនួន ១៨ នាក់ និងគ្រួសាររបស់ពួកគេ នៅក្នុងសំណុំរឿងនេះ ពឹងផ្អែកជាចម្បងលើវិស័យកសិកម្មខ្នាតតូច ដើម្បីស្វែងរកប្រាក់ចំណូល ឬចិញ្ចឹមជីវិត។ សម្រាប់អ្នកដែលបានរាយការណ៍អំពីប្រាក់ចំណូលរបស់ពួកគេទៅកាន់ស៊ីអេអូ ពួកគេទទួលបានប្រាក់ចំណូលប្រចាំខែពីការធ្វើកសិកម្ម ចំនួនពី ១៧ ដុល្លារអាមេរិកទៅ ៧០ ដុល្លារអាមេរិកក្នុងមួយខែ នៅខណៈពេលដែលគ្រួសារបន្ថែមប្រាក់ចំណូលរបស់ពួកគេតាមរយៈសាច់ញាតិដែលធ្វើការនៅក្នុងរោងចក្រកាត់ដេរ ដែលទទួលបានប្រាក់ចំណូលរហូតដល់ ២០០ ដុល្លារក្នុងមួយខែ។ ដើមបណ្ដឹងចំនួនប្រាំពីរនាក់ជាសមាជិកសហគមន៍ជនជាតិដើមភាគតិច ដែលមុខរបរចិញ្ចឹមជីវិត និងប្រភពប្រាក់ចំណូលចម្បងរបស់ពួកគេនៅមុនពេលមានកម្ចីមីក្រូហិរញ្ញវត្ថុ បានមកពីការធ្វើស្រែចម្ការនៅលើដីរបស់ពួកគេ។ [510] គ្រួសារមួយចំនួនបានបំពេញបន្ថែមប្រាក់ចំណូលរបស់ពួកគេដោយការងារស៊ីឈ្នួលគេប្រចាំថ្ងៃ ដូចជា ការកាត់ស្មៅនៅក្នុងសហគមន៍ ជាដើម។ ដើមបណ្ដឹងដប់មួយនាក់ដទៃទៀតក៏បានពឹងផ្អែកជាចម្បងលើការធ្វើស្រែចម្ការនៅលើដីរបស់ពួកគេ ដើម្បីចិញ្ចឹមជីវិត ឬបំពេញបន្ថែមលើការស៊ីឈ្នួលគេប្រចាំថ្ងៃ[511] ឬធ្វើការនៅក្នុងចម្ការសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។ ដើមបណ្ដឹងបានរាយការណ៍ពីសមត្ថភាពនៅមានកម្រិតក្នុងការអាន និងសរសេរជាភាសាខ្មែរ ដោយដើមបណ្ដឹងយ៉ាងតិចដប់ពីរនាក់មិនអាចនិយាយ និង/ឬសរសេរភាសានេះបានទេ។[512]

---

[510] ដើមបណ្ដឹងបានរាយការណ៍អំពីការរកបានប្រាក់ចំណូលពីសកម្មភាពកសិកម្ម ចាប់ពី ៧០.០០០ - ២៥០.០០០ រៀលក្នុងមួយខែ (១៧,៥ ដុល្លារអាមេរិក ទៅ ៦២,៥ ដុល្លារអាមេរិក) អាស្រ័យលើការប្រមូលផល។

[511] ដើមបណ្ដឹងបានរាយការណ៍ពីប្រាក់ឈ្នួលប្រចាំថ្ងៃសម្រាប់ការស៊ីឈ្នួលធ្វើស្រែចម្ការ ចាប់ពី ១២.០០០ ទៅ ៣០.០០០ រៀលក្នុងមួយថ្ងៃ (ប្រហែល ៦,៥ ទៅ ៧,៥ ដុល្លារអាមេរិកក្នុងមួយថ្ងៃ) ហើយចំពោះការងារនៅក្នុងរោងចក្រកាត់ដេរ ពួកគេទទួលបាន ២០០ ដុល្លារអាមេរិកក្នុងមួយខែ។ ប្ដីរបស់ដើមបណ្ដឹងម្នាក់ធ្លាប់រកប្រាក់ចំណូលបាន ១.០០០ ដុល្លារអាមេរិកក្នុងមួយខែពីការងារជាចុងភៅមុនពេលមានការរាតត្បាតជំងឺកូវីដ ១៩ ប៉ុន្តែគាត់បានចាកចេញពីគ្រួសារនៅឆ្នាំ២០២០។

[512] ដើមបណ្ដឹងម្នាក់មិនអាចនិយាយ អាន ឬសរសេរភាសាខ្មែរបានទេ ដើមបណ្ដឹងប្រាំពីរនាក់មិនបានទទួលការអប់រំក្នុងប្រព័ន្ធនោះទេ ហើយដើមបណ្ដឹងប្រាំបួននាក់បានទទួលការអប់រំក្នុងប្រព័ន្ធមួយចំនួន (ត្រឹមថ្នាក់ទី៣)។

ការវាយតម្លៃរបស់ស៊ីអេអូទៅលើគ្រោះថ្នាក់ដែលពាក់ព័ន្ធ នៅក្នុងសំណុំរឿងនេះ គឺផ្អែកលើកិច្ចសម្ភាសជាមួយដើមបណ្តឹង [513] បន្ថែមពីលើព័ត៌មានដែលមានជាសាធារណៈ ព្រមទាំងកិច្ចពិភាក្សាជាមួយអ្នកជំនាញនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សា និងឧស្សាហកម្មហិរញ្ញវត្ថុ (សូមមើលផ្នែក ៣.៦ ស្តីពីវិធីសាស្ត្រស៊ើបអង្កេត)។ សក្ខីកម្មផ្ទាល់ខ្លួនរបស់ដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ មានសង្គតិភាពនឹងបទពិសោធន៍ដ៏ទូលំទូលាយ ដែលបានចងក្រងឯកសារដោយការស្រាវជ្រាវរបស់អង្គការសហប្រជាជាតិ និងអង្គការដទៃទៀត និងរបាយការណ៍ដែលបានបោះពុម្ពផ្សាយស្តីពីផលប៉ះពាល់សង្គមនៃការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ និងការជំពាក់បំណុលវណ្ឌកនៅកម្ពុជា។ ឈរលើមូលដ្ឋាននេះ ស៊ីអេអូរកឃើញថា ដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ បានជួបប្រទះនឹងគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងបដិលោមភាពរបស់ IFC។

**រូបភាពទី៤៖ គ្រោះថ្នាក់ដែលដើមបណ្តឹងបានជួបប្រទះនៅក្នុងសំណុំរឿងនេះ**




## ៥.១ ការបាត់បង់មុខរបរចិញ្ចឹមជីវិត និងទ្រព្យសម្បត្តិដែលមានផលិតភាព

ដើមបណ្តឹងចោទប្រកាន់ថា បុគ្គលិកគ្រឹះស្ថានហិរញ្ញវត្ថុដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹង ដែលបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពី IFC បានបង្ខំពួកគេឱ្យប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីជាវត្ថុបញ្ចាំ ហើយបន្ទាប់មក បានបង្ខំពួកគេឱ្យលក់ដីមុនកាលកំណត់ ដើម្បីឆ្លើយតបទៅនឹងសម្ពាធនៃការប្រមូលប្រាក់។ ក្នុងករណីជាច្រើន ដីនេះជាប្រភពប្រាក់ចំណូលចម្បងរបស់ពួកគេ ហើយនៅគ្រប់ករណីទាំងអស់ ដីនេះគឺជាទ្រព្យសម្បត្តិដ៏សំខាន់ ដែលរួមចំណែកដល់ការទ្រទ្រង់ជីវិត និងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ដើមបណ្តឹងដប់ប្រាំនាក់បានរាយការណ៍ពី

---

[513] ដោយសារកង្វល់អំពីការគំរាមកំហែង និងការសងសឹក គ្រោះថ្នាក់របស់ដើមបណ្តឹងម្នាក់ៗនឹងមិនផ្សារភ្ជាប់ទៅនឹងដើមបណ្តឹងជាក់លាក់នៅក្នុងផ្នែកខាងក្រោមឡើយ។ ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធ ដែលរក្សាការសម្ងាត់ ដែលត្រូវបានចែករំលែកជាមួយ IFC និងអតិថិជន តាមភាពសមស្រប និងអនុវត្តតាមវិសាលភាពនៃការយល់ព្រមពីគ្រួសារដើមបណ្តឹងនីមួយៗ។

ការលក់ដីមួយចំណែក ឬស្ទើរតែទាំងអស់ ដើម្បីសងបំណុលរបស់ពួកគេ។[514] ការលក់ទាំងនេះត្រូវបានធ្វើឡើងដោយអ្នកខ្ចីដោយផ្ទាល់ នៅខាងក្រៅការអនុវត្តច្បាប់លើវត្ថុបញ្ចាំជាផ្លូវការ ឬនីតិវិធីតុលាការ (សូមមើលការអនុវត្តរបស់ BFI នៅក្នុងផ្នែក ៤.២.១) [515] ហើយដើមបណ្តឹងដប់បួននាក់ ក្នុងចំណោមពួកគេ បានរាយការណ៍អំពីការលក់ដីបែបនេះ ដើម្បីឆ្លើយតបទៅនឹងកលយុទ្ធនៃការដាក់សម្ពាធក្នុងការប្រមូលប្រាក់ ដូចបានពិពណ៌នានៅក្នុងផ្នែក ៤.២.១ ដែលផ្ទុយពីស្តង់ដារ GIIP ស្របតាមលក្ខខណ្ឌតម្រូវនៃ PS1 សម្រាប់ជនងាយរងគ្រោះ។ កលយុទ្ធនៃការដាក់សម្ពាធ ដែលបានរាយការណ៍ទៅកាន់ស៊ីអេអូ រួមមាន សំណើរបស់មន្ត្រី BFI ឱ្យលក់ដីរបស់ពួកគេ ការគំរាមរឹបអូសដី ឬផ្ទះ រួមជាមួយការនិយាយបញ្ឆិតបញ្ឆៀងថា ធនាគារ ឬ MFI នឹងលក់វត្ថុបញ្ចាំ (ដី/ផ្ទះ) ក្រោមតម្លៃទីផ្សារ តាមរយៈការដាក់ដេញថ្លៃ ឬការគំរាមបញ្ជូនទៅអាជ្ញាធរមូលដ្ឋាន (មេភូមិ ឬមេឃុំ) នគរបាល ឬតុលាការ ដោយមិនពន្យល់អំពីដំណើរការ ឬផលវិបាកដែលអាចកើតឡើង ដូចជា ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬការជាប់ពន្ធនាគារនោះទេ។ ក្នុងករណីដើមបណ្តឹងទីដប់ប្រាំ ទោះបីជាការលក់ដីរបស់គាត់មិនពាក់ព័ន្ធដោយផ្ទាល់នឹងការសងប្រាក់កម្ចីដែលផ្តល់ដោយអតិថិជនរបស់ IFC ក៏ដោយ ក៏គាត់បានលក់ដីដើម្បីសងប្រាក់កម្ចីមួយ ដែលគាត់បានខ្ចីពីអ្នកដែលមិនមែនជាអតិថិជនរបស់ IFC ដើម្បីសងប្រាក់កម្ចីដំបូងពីអតិថិជនរបស់ IFC[516] ដែលបង្ហាញពីការលំបាកក្នុងការគណនាទំហំពេញលេញនៃផលប៉ះពាល់ពីការបាត់បង់ដីធ្លីដោយសារបំណុល។

ដូចបានពន្យល់ខាងលើ ការផ្តល់យោបល់ដែលមានគ្រោះថ្នាក់ដោយមន្ត្រី BFI បានកំណត់គោលដៅលើបុគ្គលដែលគេមិនអើពើ ដែលខ្វះខាតអក្ខរកម្មផ្នែកច្បាប់ និងហិរញ្ញវត្ថុ និងចំណេះដឹងអំពីសិទ្ធិ និងជម្រើសរបស់ពួកគេ ដែលជាញឹកញាប់ ធ្វើឱ្យមានគ្រោះថ្នាក់។ ក្នុងការធ្វើសេចក្តីសម្រេចនេះ ស៊ីអេអូគិតគូរពីបាតុភូតដែលបានចងក្រងជាឯកសារយ៉ាងល្អ អំពីរបៀបដែលអវត្តមាននៃដំណើរការរឹបអូសជាផ្លូវការអាចបិទបាំងសម្ពាធនៃការប្រមូលបំណុលដោយបង្ខំ និងការអនុវត្តដែលបង្កភាពអាម៉ាស់ជាសាធារណៈ រួមផ្សំជាមួយកង្វះចំណេះដឹងរបស់អ្នកខ្ចីអំពីសិទ្ធិរបស់ពួកគេ ជាញឹកញាប់ នាំឱ្យមានការលក់ដីដោយសារភាពតានតឹងផ្លូវចិត្ត

---

514 ក្រៅពីដើមបណ្តឹងពីរនាក់ដែលបានផ្តល់លិខិតផ្ទេរកម្មសិទ្ធិឲ្យស៊ីអេអូត្រួតពិនិត្យក្នុងអំឡុងពេលសម្ភាស ភស្តុតាងចម្បងនៃការលក់ដី រួមមាន សក្ខីកម្មរបស់ដើមបណ្តឹង។ ដោយសារអវត្តមាននៃសុរិយោដីកណ្តាល និង ប្រតិបត្តិការដីធ្លីក្រៅប្រព័ន្ធនៅតាមជនបទនៃប្រទេសកម្ពុជា ដើមបណ្តឹងភាគច្រើនមិនបានផ្តល់ឯកសារផ្លូវការនៃការផ្ទេរកម្មសិទ្ធិដីធ្លីនោះទេ។ ដើមបណ្តឹងបានផ្តល់ជូនស៊ីអេអូនូវភស្តុតាងនៃកម្មសិទ្ធិដីធ្លីដំបូង នៅពេលដែលពួកគេបានខ្ចីកម្ចីមីក្រូហិរញ្ញវត្ថុ។

515 ច្បាប់កម្ពុជាស្តីពីសិទ្ធិប្រាតិភោគមិនផ្តល់ជូនម្ចាស់បំណុលនូវអំណាចក្នុងការរឹបអូសវត្ថុបញ្ចាំដោយផ្ទាល់នោះទេ ដោយចំណាត់ការបែបនេះត្រូវអនុវត្តដោយតុលាការតែប៉ុណ្ណោះ។ មាត្រា ៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៦។

516 ដើមបណ្តឹងបានខ្ចីប្រាក់ពីអ្នកដែលមិនមែនជាអតិថិជនរបស់ IFC ដើម្បីសងកម្ចីពីអតិថិជនរបស់ IFC និងបានលក់ផ្ទះដើម្បីសងប្រាក់កម្ចីដំបូងពីអតិថិជន IFC។ គាត់មិនបានរាយការណ៍ពីសម្ពាធនៃការប្រមូលប្រាក់ពីអតិថិជនរបស់ IFC នោះទេ ប៉ុន្តែនៅបំផុតគាត់បានលក់ដីរបស់គាត់ក្រោមការគំរាមរឹបអូសពីអ្នកដែលមិនមែនជាអតិថិជនរបស់ IFC ដែលប្រាក់កម្ចីពីអ្នកទាំងនោះ គឺដើម្បីសងប្រាក់កម្ចីរបស់គាត់ដែលមាននៅជាមួយអតិថិជនរបស់ IFC ។

(សូមមើលផ្នែក ៤.២)។ ដំណើរការនេះបង្វែរទំនួលខុសត្រូវចំពោះការដកហូតកម្មសិទ្ធិ ពីការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ ដែលមិនស្របតាម GIIP ទៅអ្នកខ្ចីដោយផ្ទាល់។[517]

នៅខណៈពេលដែលមិនត្រូវបានតម្រូវដោយច្បាប់នោះទេ ការអនុវត្តជាទូទៅរបស់ធនាគារ និង MFIs ចំពោះការរក្សាទុកឯកសារកម្មសិទ្ធិដីផ្លូវរបវ័ន្ត[518] បង្កើនភាពភ័យខ្លាច និងលើកទឹកចិត្តអ្នកខ្ចីបន្ថែមទៀតឱ្យលក់ដីស្រែចម្ការរបស់ពួកគេ មុនពេលធនាគារលក់វា។ ស៊ីអេអូបានសង្កេតឃើញថា រួមជាមួយការលក់ក្នុងតម្លៃទាបជាងតម្លៃទីផ្សារដែលអាចកើតឡើង ការគំរាមរឹបអូសដី និងផ្ទះ ត្រូវបានគេយល់ឃើញថាជាហានិភ័យពិតប្រាកដនៅក្នុងចំណោមអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ ជាពិសេសជនដែលខ្វះការយល់ដឹងអំពីផ្លូវច្បាប់ពាក់ព័ន្ធនឹងនីតិវិធីរឹបអូសវត្ថុបញ្ចាំ និងសិទ្ធិនានា។[519] ការយល់ឃើញបែបនេះមានកាន់តែខ្លាំងក្លាឡើង នៅពេលដែលអាជ្ញាធរមូលដ្ឋានចូលរួមក្នុងការទារបំណុល តាមការពិពណ៌នានៅក្នុងផ្នែក ៤.២ ជាសកម្មភាពដែលត្រូវបានរាយការណ៍សម្រាប់អតិថិជន និងអតិថិជនបន្តរបស់ IFC នៅក្នុងសំណុំរឿងនេះទាំងអស់។

ការលក់ដីមិនមែនជាគ្រោះថ្នាក់ដែលជាប់មកជាមួយទេ ដោយសារកម្រិតគ្រោះថ្នាក់អាស្រ័យលើស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងចំណោមដើមបណ្តឹង ១៥ នាក់ ដែលបានលក់ដីដើម្បីសងបំណុល ដើមបណ្តឹង ១១ នាក់ បានពឹងផ្អែកលើការធ្វើស្រែចម្ការជាប្រភពប្រាក់ចំណូលបឋមរបស់ពួកគេ។ ដើមបណ្តឹងបួននាក់ក្នុងចំណោមដើមបណ្តឹងទាំង ១១ នាក់លក់ដីកសិកម្មភាគច្រើន ឬទាំងអស់ ដែលបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរលើជីវភាពរស់នៅរបស់ពួកគេ។[520] ដើមបណ្តឹង ៤ នាក់ទៀត ដែលបានលក់ដី មិនបានពឹងផ្អែកលើដីនោះជាប្រភពចំណូលចម្បងរបស់ពួកគេឡើយ ប៉ុន្តែពួកគេធ្វើស្រែចម្ការសម្រាប់ការប្រើប្រាស់

[517] Green, Bylander ឆ្នាំ២០២១ ទំ. ២០៣ អ្នកនិពន្ធពន្យល់ថា "បំណុលមីក្រូហិរញ្ញវត្ថុទំនងជាធ្វើឲ្យបញ្ហាសង្គមជាប្រព័ន្ធនៃការជំពាក់បំណុលវ័ណ្ឌក មានលក្ខណៈបុគ្គល ដូច្នេះ វាបង្កភាពមិនច្បាស់លាស់ចំពោះទំហំ និងលំនាំនៃការដកហូតកម្មសិទ្ធិដីធ្លី។ ការដកហូតកម្មសិទ្ធិដោយសារបំណុល ជាញឹកញាប់ មិនមានការកត់សម្គាល់ដោយអាជ្ញាធរមូលដ្ឋាន មន្ត្រីឥណទាន និងអ្នកខ្ចីប្រាក់ដោយផ្ទាល់នោះទេ ដែលធ្វើឱ្យការលក់ដីដោយភាពតានតឹងផ្លូវចិត្តមានភាពត្រឹមត្រូវ តាមរយៈកិច្ចសន្ទនាប្រកបដោយសីលធម៌អំពីភាពស្របច្បាប់ និងជម្រើសផ្ទាល់ខ្លួន។ នៅពេលមានការគាំទ្រពីសកម្មភាពនៃការបង្ខិតបង្ខំ ដែលបង្កភាពអាម៉ាសជាសាធារណៈ កិច្ចសន្ទនានេះបានបង្វែរទំនួលខុសត្រូវចំពោះការដកហូតកម្មសិទ្ធិនេះពីប្រព័ន្ធហិរញ្ញវត្ថុដ៏ឃោរឃៅ ទៅអ្នកខ្ចីដោយផ្ទាល់" (Bylander, Maryann, Phasy Res, Lacey Jacoby, Peter Bradley និង Andrea Blobel Perez. ឆ្នាំ២០១៨ "ការជំពាក់បំណុលវ័ណ្ឌក និងមីក្រូឥណទាននៅកម្ពុជា៖ ការបោះជំហានលើសពីរង្វង់ដែលផ្តោតលើអ្នកខ្ចី។" *ការត្រួតពិនិត្យគោលនយោបាយអភិវឌ្ឍន៍*; Federici, Silvia. ឆ្នាំ២០១៤ "ពីការប្រើប្រាស់សិទ្ធិរួមគ្នាចំពោះបំណុល៖ ហិរញ្ញវត្ថុ មីក្រូឥណទាន និងស្ថាបត្យកម្មកំពុងប្រែប្រួលនៃសមាច័យទុន" *South Atlantic Quarterly* ១១៣(២):២៣១–៤៤.; Fernando, Jude L., ed. ឆ្នាំ២០០៦ មីក្រូហិរញ្ញវត្ថុ៖ គ្រោះថ្នាក់ និងសេចក្តីរំពឹងទុក។ ញូវយ៉ក៖ Routledge.; Young, Stephen ឆ្នាំ២០១០ "'គ្រោះថ្នាក់ផ្នែកសីលធម៌' នៃមីក្រូហិរញ្ញវត្ថុ៖ ការរៀបចំឥណទានជនបទឡើងវិញនៅប្រទេសឥណ្ឌា" *Antipode* ៤២(១):២០១–២៣.)។

[518] ទោះបីជាការរក្សាទុកឯកសារកម្មសិទ្ធិរូបវ័ន្តមិនផ្ទុយនឹងស្តង់ដារឧស្សាហកម្មក៏ដោយ (សូមមើល Cerise + SPTF ស្តង់ដារសកលសម្រាប់ការគ្រប់គ្រងសមិទ្ធិកម្មសង្គម និងបរិស្ថាន ១.៤.២.៤៖ "ប្រសិនបើអ្នកផ្តល់សេវាប្រមូលឯកសារកម្មសិទ្ធិ អ្នកផ្តល់សេវានឹងប្រគល់ឯកសារទាំងនោះជូនអតិថិជនវិញ ក្រោយពីសងកម្ចី") ស៊ីអេអូកត់សម្គាល់ឃើញការរាយការណ៍អំពីភាពយឺតយ៉ាវក្នុងការប្រគល់ឯកសារកម្មសិទ្ធិជូនអ្នកខ្ចីវិញ ទោះបីជាមានបទប្បញ្ញត្តិនៃកិច្ចសន្យាស្តង់ដារ និងលក្ខខណ្ឌនៃកិច្ចសន្យាស្តង់ដារ ឆ្នាំ២០២៣ ដែលកំណត់ឱ្យប្រគល់ជូនវិញក្នុងរយៈពេល ៧ ថ្ងៃ ក្រោយពីសងកម្ចីក៏ដោយ។ កិច្ចសម្ភាសរបស់ស៊ីអេអូជាមួយ ABC ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤។

[519] ការសង្កេតរបស់ស៊ីអេអូ គឺផ្អែកលើការសម្ភាសជាមួយអ្នកខ្ចីដែលជាដើមបណ្តឹង និងមិនមែនជាដើមបណ្តឹង ព្រមទាំងការពិភាក្សាជាមួយអង្គការសង្គមស៊ីវិល (CSOs) និងតំណាងសហគមន៍។

[520] ដើមបណ្តឹងពីរនាក់ក្នុងចំណោមដើមបណ្តឹងទាំងនេះបានបោះបង់ចោលការធ្វើកសិកម្ម ក្រោយពេលលក់ដីស្រែចម្ការរបស់ពួកគេ នៅខណៈពេលដែលដើមបណ្តឹងពីរនាក់ទៀតបានរាយការណ៍ពីការលំបាកក្នុងការបំពេញតម្រូវការមូលដ្ឋាន និងងាកទៅស្វែងរកអាហារសម្រាប់ចិញ្ចឹមជីវិត និងកាត់បន្ថយការទទួលទានអាហារ។

ផ្ទាល់ខ្លួន។ ដើមបណ្ដឹងម្នាក់បានលក់ដីភាគច្រើនរបស់គាត់ ដែលគាត់បានពឹងផ្អែកដីនោះសម្រាប់ចិញ្ចឹមជីវិត។ គ្រួសារនានាដែលបានលក់ដីរបស់ពួកគេភាគច្រើន ឬទាំងអស់ បានរាយការណ៍អំពីអារម្មណ៍ដែលត្រូវគេបង្ខំឱ្យលក់ដីរបស់ពួកគេមុនពេលកំណត់ និងការជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុដោយសារការបាត់បង់ប្រាក់ចំណូល ឬប្រភពមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ដែលនាំឱ្យមានយន្តការទប់ទល់ដែលមានគ្រោះថ្នាក់ (សូមមើលព័ត៌មានលម្អិតបន្ថែមទៀតនៅក្នុងផ្នែក ៤.២)។[521]

បន្ថែមពីលើការលក់ដីនេះទៀត ដើមបណ្ដឹងប្រាំមួយនាក់បានរាយការណ៍ពីការលក់ ការបង្កើតអ៊ីប៉ូតែក ឬការបញ្ចាំទ្រព្យសកម្មសម្រាប់បង្កើតប្រាក់ចំណូលសំខាន់ៗ ដែលរួមមាន គោក្របី ត្រាក់ទ័រ និងយានជំនិះដទៃទៀត ដើម្បីសងបំណុល ឬទប់ទល់នឹងការថយចុះនៃមុខរបរចិញ្ចឹមជីវិត និងទូទាត់ចំណាយមូលដ្ឋាននៅក្នុងគ្រួសារ។ សកម្មភាពទាំងនេះត្រូវបានជម្រុញដោយសម្ពាធនៃប្រមូលប្រាក់មិនត្រឹមត្រូវ ដូចបានពិពណ៌នានៅផ្នែក ៤.១។

ដើមបណ្ដឹង ១៥ នាក់ ដែលបានបាត់បង់ដី ឬទ្រព្យសកម្មដែលមានផលិតភាពដទៃទៀត ដែលបណ្ដាលឲ្យមានការថយចុះនៃមុខរបរចិញ្ចឹមជីវិតរបស់ពួកគេនោះ បួននាក់បានបោះបង់ចោលការធ្វើស្រែចម្ការ និងបានបង្វែរទៅប្រើទម្រង់ដទៃទៀតនៃការបង្កើតប្រាក់ចំណូល។ ពួកគេបានពិពណ៌នាការប្រែប្រួលនេះថា មានផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅរបស់ពួកគេ។ ដើម្បីបង្ហាញបន្ថែមទៀតអំពីគ្រោះថ្នាក់ពីការការបាត់បង់ដី ឬទ្រព្យសកម្មចំពោះប្រជាជនងាយរងគ្រោះនោះ ឧទាហរណ៍នៃផលប៉ះពាល់លើមុខរបរចិញ្ចឹមជីវិតរបស់ដើមបណ្ដឹង ដែលបានរាយការណ៍ទៅកាន់ស៊ីអេអូ រួមមាន៖

- ដើមបណ្ដឹងម្នាក់ ដែលជាកសិករ បានលក់ដី ១២ ហិចតា ដើម្បីសងបំណុលសរុបចំនួន ២០.៦២៥ ដុល្លារអាមេរិក ទៅអតិថិជន និងអតិថិជនបន្តរបស់ IFC នៅចន្លោះឆ្នាំ២០១៥ និង ឆ្នាំ២០២១ ដែលនៅទីបំផុត គាត់ត្រូវបោះបង់ការធ្វើស្រែចម្ការ ហើយទទួលយកការងារសំណង់ ជាមួយកូនអាយុ ១៣ ឆ្នាំរបស់គាត់ ដែលត្រូវឈប់រៀន។ ករណីនេះបង្ហាញពី របៀបដែលការលក់ដីដោយសារបំណុលបានកែប្រែមុខរបរចិញ្ចឹមជីវិតរបស់ដើមបណ្ដឹង ដោយបង្ខំឱ្យគាត់បោះបង់ចោលការងារកសិកម្ម និងទទួលយកការងារសំណង់ ដើម្បីសងបំណុល ហើយកូនរបស់គាត់ត្រូវឈប់រៀន ដែលធ្វើឲ្យបាត់បង់សិទ្ធិទទួលបានការអប់រំ (សូមមើលព័ត៌មានលម្អិតបន្ថែមទៀតនៅក្នុងផ្នែក ៤.២)។
- ដើម្បីបណ្ដឹងម្នាក់បានលក់ដីកសិកម្មរបស់គាត់ដើម្បីសងបំណុលរបស់កូនស្រីគាត់ ចំនួន ១៣.០០០ ដុល្លារអាមេរិក គាត់បានបាត់បង់ប្រភពចំណូលចម្បងសម្រាប់ទិញចំណីអាហារ ហើយជ្រើសរើសយកការរកបន្លែព្រៃ ត្រី និងកង្កែបពីស្ទឹងមួយនៅក្បែរនោះ សម្រាប់ផ្គត់ផ្គង់អាហាររបស់គាត់។
- ដើមបណ្ដឹងមួយ ជាកសិករ បានលក់ដីមួយផ្នែកដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ និងត្រូវទៅស៊ីឈ្នួលគេប្រចាំថ្ងៃ ដើម្បីរ៉ាប់រងប្រាក់កម្ចីសរុបចំនួន ៩.០០០ ដុល្លារអាមេរិក[522] ដែលបានកាត់បន្ថយពេលវេលាសម្រាប់ធ្វើស្រែចម្ការ និងបង្កឱ្យគាត់ត្រូវទិញអង្ករពីទីផ្សារ ជំនួសឲ្យការផលិតវា។

---

[521] ដើមបណ្ដឹងដែលបានលក់ដីកសិកម្ម បានរាយការណ៍ថា ការប្រមូលផល និងប្រាក់ចំណូលដែលពាក់ព័ន្ធ បានថយចុះដោយសារការបាត់បង់ដីធ្លី។ ដើម្បីធ្វើស្រែចម្ការបន្តទៀត ដើមបណ្ដឹងពីរនាក់បានងាកទៅរកការជួលដី ដែលនាំឱ្យមានបន្ទុកហិរញ្ញវត្ថុ ដែលធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេបន្ថែមទៀត។ ដើមបណ្ដឹងប្រាំបួននាក់បានងាកទៅរកការស៊ីឈ្នួលគេប្រចាំថ្ងៃ និងបួននាក់ទៀតបានបោះបង់ចោលការធ្វើកសិកម្ម។

[522] ដើមបណ្ដឹងមានប្រាក់កម្ចីសរុបចំនួន ៥.០០០ ដុល្លារអាមេរិក ពីអតិថិជន/អតិថិជនបន្តរបស់ IFC និងប្រាក់កម្ចីចំនួន ៤.០០០ ដុល្លារអាមេរិកពី BFIs ដទៃទៀត។

ដើម្បីបណ្តឹងដប់មួយនាក់ទៀត ដែលបានបាត់បង់ដី ឬទ្រព្យសកម្មសម្រាប់បង្កើតប្រាក់ចំណូលដទៃទៀត បានជួបប្រទះនឹងការថយចុះ ឬការផ្លាស់ប្តូរមុខរបរចិញ្ចឹមជីវិតស្រដៀងគ្នា។ ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធដែលរក្សាការសម្ងាត់។

គ្រោះថ្នាក់ដែលត្រូវបានរាយការណ៍ដោយដើមបណ្តឹងមានសង្គតិភាពនឹងការសិក្សា និងរបាយការណ៍កាន់តែទូលំទូលាយ អំពីការលក់ដីដោយសារបំណុលនៅកម្ពុជា ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅ។ ឧទាហរណ៍នៅឆ្នាំ២០១៦ គោលការណ៍ណែនាំអំពីការផ្តល់ប្រាក់កម្ចីរបស់ CMA បានទទួលស្គាល់ថា "ការបាត់បង់ដីដោយសារការជំពាក់បំណុលវ័ណ្ឌក មានភាពធ្ងន់ធ្ងរ និងគួរតែមានការពិនិត្យតាមដាន និងត្រូវបានជៀសវាងតាមដែលអាចធ្វើបាន"។ [523] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានធ្វើសេចក្តីសន្និដ្ឋាននៅឆ្នាំ២០២៣ ថា "កម្ចីខ្នាតមីក្រូ ត្រឹម ៥.០០០ ដុល្លារ ឬតិចជាងនេះ បានក្លាយជាភាពទាក់ទាញមួយ ដែលនាំឱ្យមានបំណុល និងការដកហូត ជាពិសេស ប្រាក់កម្ចីទាំងនេះមានទំនាក់ទំនងនឹងការបាត់បង់ដីជាច្រើន ដែលត្រូវបានប្រើជាវត្ថុបញ្ចាំ"។[524] ការសិក្សានានាបានកំណត់បន្ថែមទៀតនូវទំនាក់ទំនងរវាងការលក់ដី និងបំណុលមីក្រូហិរញ្ញវត្ថុ ព្រមទាំងបានគូសបញ្ជាក់អំពីទំហំ និងផលប៉ះពាល់នៃបាតុភាពនេះទៅលើគ្រួសារនានា ជាពិសេស គ្រួសារដែលមានមុខរបរចិញ្ចឹមជីវិតពឹងផ្អែកលើដីធ្លី។[525]

ការសិក្សាបែបបរិមាណវិស័យចំនួនពីរ នៅចន្លោះឆ្នាំ២០២២ និង ឆ្នាំ២០២៣ ដែលរៀបចំដោយ CMA និង BMZ (ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍) បានស្ទង់មតិប្រជាជនសរុប ៤.៦៥០គ្រួសារ ហើយការស្ទង់មតិទាំងពីរបានរកឃើញថា អ្នកខ្ចីប្រហែល ៦% បានលក់ដីដើម្បីសងបំណុលនៃប្រាក់កម្ចីខ្នាតមីក្រូ ដែលបង្ហាញពីអត្រាការលក់ថ្នាក់ជាតិលើសពី ៣០.០០០ ប្រតិបត្តិការក្នុងមួយ

[523] របាយការណ៍បណ្តោះអាសន្នស្តីពីគោលការណ៍ណែនាំអំពីការផ្តល់ប្រាក់របស់ CMA ខែឧសភា ឆ្នាំ២០២១ ទំ. ២៦

[524] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា Vitit Muntarbhorn ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (ឆ្នាំ២០២៣), A/HRC/54/75, កថាខណ្ឌ ៦០ មាននៅ៖ https://bit.ly/3Fr4FbH។

[525] Green, Bylander ឆ្នាំ២០២១ ទំ. ២០៤; Marks, Simon, Reaksmey, Hul, "វិធីចាកចេញសម្រាប់មនុស្សមួយចំនួន ប៉ុន្តែជាអន្ទាក់បំណុលសម្រាប់អ្នកដទៃទៀត", *ខេបូឌា ដេលី* ខែឧសភា ឆ្នាំ២០១១ មាននៅ https://bit.ly/3IN7Glj; Ovesen, Jan និង Ing-Britt Trankell "ទំនាក់ទំនងរវាងមីក្រូឥណទាន និងការផ្តល់ប្រាក់កម្ចីឯកជននៅកម្ពុជា" ទិន្នានុប្បវត្តិនវិទ្យាអាស៊ីប៉ាហ្វិក ១៥(២) ឆ្នាំ២០១៤ ទំ. ១៧៨-៩៦., Surrusco, Matt, និង Buth Kimsay "កម្ចីខ្នាតមីក្រូល្អសម្រាប់មនុស្សមួយចំនួន ប៉ុន្តែធ្វើឱ្យមនុស្សជាច្រើនស្ថិតក្នុងបំណុល" *ខេបូឌា ដេលី* ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ បន្ថែមលើការសិក្សា និងឯកសារនានាដែលបានទាញអាគត្តដ្ឋានខាងក្រោមរួមមាន៖ Bateman ផ្តល់ទឡ្ហីករណ៍ថា វិស័យមីក្រូហិរញ្ញវត្ថុកំពុងជម្រុញជនក្រីក្រឱ្យធ្លាក់ទៅក្នុងភាពគ្មានដីធ្លី រួមជាមួយ "ការបាត់បង់ដីបន្តិចម្តងៗដោយសារអសមត្ថភាពក្នុងការសងប្រាក់កម្ចីខ្នាតមីក្រូ" ដែលជាលទ្ធផលមួយនៃ "លទ្ធផលដែលមានមហន្តរាយបំផុតទាក់ទងនឹងកំណើនគំរូមីក្រូហិរញ្ញវត្ថុនៅកម្ពុជា"។ Bateman, Milford "កំណើនវិស័យមីក្រូឥណទាននៅកម្ពុជា៖ គ្រោះមហន្តរាយដែលកំពុងលាតត្រដាង" សកលភាវូបនីយកម្មនៅផ្លូវប្រសព្វ ការគិតឡើងវិញអំពីវិសមភាព និងព្រំដែន EADI NORDIC ឆ្នាំ២០១៧ (តទៅហៅថា Bateman ឆ្នាំ២០១៧) ទំ. ១៤ ១៦។ ក្នុងចំណោមឯកសារជាច្រើនទៀត សូមមើល Rido, Thath, "មីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ ការអភិវឌ្ឍ បញ្ហាប្រឈម និងសេចក្តីរំពឹងទុក" *ឯកសារ MPRA* ឆ្នាំ២០១៨ ទំ. ១០-១១; Surrusco, Matt, Kimsay, Buth, "កម្ចីខ្នាតមីក្រូល្អសម្រាប់មនុស្សមួយចំនួន ប៉ុន្តែធ្វើឱ្យមនុស្សជាច្រើនស្ថិតក្នុងបំណុល" *ខេបូឌា ដេលី* ខែមីនា ឆ្នាំ២០១៧ មាននៅ https://bit.ly/42gN8J9; លីកាដូ ឆ្នាំ២០២៣, ការស្ទង់មតិប្រជាជន ៧៧ គ្រួសារ ដែលខ្ចីប្រាក់ពី MFI/ធនាគារក្នុងប្រព័ន្ធ នៅគ្រប់ស្រុកនៃខេត្តកំពង់ស្ពឺ។

ឆ្នាំ។[526] [527]

ដូចបានពន្យល់នៅក្នុងផ្នែក ៤.៣ ខាងលើ តាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគរបស់ខ្លួន IFC មិនបានធានាថា ការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន និងអតិថិជនបន្តរបស់ខ្លួន មានការការពារសុវត្ថិភាពសមស្រប ដើម្បីការពារប្រជាជនងាយរងគ្រោះពីការបាត់បង់ទ្រព្យសកម្មសំខាន់ៗ ឬទ្រព្យសកម្មសម្រាប់បង្កើតប្រាក់ចំណូល ដូចជា ដីរបស់គ្រួសារដែលមានមុខរបរចិញ្ចឹមពឹងផ្អែកលើដីនោះ។

ជាការសន្និដ្ឋាន ស៊ីអេអូរកឃើញថា ដើមបណ្តឹង ១៥ នាក់ ដែលមានមុខរបរចិញ្ចឹមពឹងផ្អែកលើដី បានទទួលរងគ្រោះថ្នាក់តាមរយៈការបាត់បង់ដីរបស់ពួកគេមួយផ្នែក ឬទាំងស្រុង ឬទ្រព្យសកម្មសម្រាប់បង្កើតប្រាក់ចំណូលដទៃទៀត។

## ៥.២ អសន្តិសុខស្បៀង និងផលប៉ះពាល់លើសុខភាព ការអប់រំ និងទំនាក់ទំនងគ្រួសារ

ដោយសារការធ្លាក់ចុះនៃប្រាក់ចំណូល និងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ដើមបណ្តឹងបានរាយការណ៍ពីការជ្រើសរើសយកយន្តការទប់ទល់ផ្សេងៗ៖ (១) ការទទួលទានអាហារតិចជាងមុន ឬមិនសូវមានគុណភាព (២) ការពន្យារពេលទៅទទួលការព្យាបាលដើម្បីកាត់បន្ថយចំណាយ និងផលប៉ះពាល់ដទៃទៀតលើសុខភាពផ្លូវកាយ និងផ្លូវចិត្ត (៣) ការឱ្យកូនឈប់រៀនដើម្បីជួយសងបំណុល និង (៤) ការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ ដែលបង្កផលប៉ះពាល់ដល់គ្រួសាររបស់ពួកគេ។ ផលប៉ះពាល់សង្គមទាំងនេះបានកើតចេញពីការបាត់បង់ដី ឬទ្រព្យសកម្ម ដែលប៉ះពាល់ដល់មុខរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែក្នុង

---

[526] MCRIL *ការវាយតម្លៃផលប៉ះពាល់នៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជា* ឆ្នាំ២០២៣ (តទៅនេះហៅថា របាយការណ៍ MCRIL-CMA)។ របាយការណ៍ដែលរៀបចំដោយ CMA បានធ្វើការស្ទង់មតិប្រជាជន ៣.២៦២ គ្រួសារនៅជាងដប់ខេត្ត p.viii; របាយការណ៍ Bliss ទំ. ៨២ ដែលស្ទង់មតិប្រជាជន ១.៣៨៨ គ្រួសារ។ ការស្ទង់មតិបន្ថែមទៀតសម្រាប់របាយការណ៍សិក្សាឆ្នាំ២០២២ បានរកឃើញថា គ្រួសារ ១៥% បានលក់ដីកសិកម្មក្នុងរយៈពេលដប់ឆ្នាំចុងក្រោយ ដែលក្នុងនោះ ៣១% បានលក់ដីដើម្បីសងប្រាក់កម្ចី។ Guermond, V, Parsons, L., Ly Vouch, L., Brickell, K., Michiels, S., Fay, G., Bateman, M., Zanello, G., Natarajan, N., Iskander, D., និង Picchioni, F. (ឆ្នាំ២០២២). មីក្រូហិរញ្ញវត្ថុ ការជំពាក់បំណុលវ័ណ្ឌក និងការបន្សុាំនឹងអាកាសធាតុ៖ ភស្តុតាងថ្មីៗពីជនបទនៅកម្ពុជា។ Royal Holloway, សាកលវិទ្យាល័យទីក្រុងឡុងដ៍ (តទៅហៅថា Guermond et al., ឆ្នាំ២០២២) ទំ. ៥៣ ដែលស្ទង់មតិប្រជាជន ៦២១ គ្រួសារ បន្ថែមពីលើកម្រងសំណួរជាលក្ខណៈបុគ្គល ចំនួន ១.២២០ កម្រងសំណួរ។

[527] ការសិក្សាយ៉ាងទូលំទូលាយបញ្ជាក់ថា ការលក់ដីដោយសារបំណុលមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការធ្វើស្រែចម្ការនៅក្នុងគ្រួសារ និងមុខរបរចិញ្ចឹមជីវិតនៅតាមជនបទនៃប្រទេសកម្ពុជា។ វិទ្យាស្ថានជាតិស្ថិតិបានរាយការណ៍ថា ប្រជាជនមួយលានគ្រួសារបានឈប់ធ្វើស្រែចម្ការ ឬកាត់បន្ថយដីស្រែចម្ការរបស់ពួកគេ នៅចន្លោះឆ្នាំ២០១៧ និង ឆ្នាំ២០១៩/២០២០ ដោយស្ត្រីជាម្ចាស់ដីរងផលប៉ះពាល់មិនសមាមាត្រ។ សម្ព័ន្ធសហគមន៍កសិករកម្ពុជាបានសន្មតថា បញ្ហានេះភាគច្រើនបណ្តាលមកពីកសិករលក់ដីដើម្បីយកប្រាក់បន្ទាន់ នៅពេលដែលមានវិបត្តិបំណុលកាន់តែខ្លាំង។ ការស្រាវជ្រាវក៏បង្ហាញផងដែរថា សម្ពាធបំណុលកំពុងជម្រុញឱ្យមានការផ្លាស់ប្តូរការធ្វើកសិកម្ម ដែលរួមមាន ផលិតកម្មបែបប្រពលវប្បកម្ម ដែលនាំឱ្យមានឱនភាពដីធ្ងន់ធ្ងរ ការថយចុះនៃទឹកក្រោមដី និងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលមានគ្រោះថ្នាក់កាន់តែច្រើន។ ក្នុងករណីមួយចំនួន អ្នកខ្ចីនៅតាមជនបទបានងាកទៅរកការកាប់ឆ្ការព្រៃ និងការពង្រីកការកាន់កាប់ដីធ្លី ដើម្បីទទួលបានដីដែលមានជីជាតិកាន់តែច្រើន។ សូមមើល៖ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១៧ មាននៅ៖ https://bit.ly/3LXJIod; វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១៩/២០ មាននៅ៖ https://bit.ly/3NMoYIS; Techseng, Tran, Dickison, Michael, "ការបាត់បង់ដីធ្លី កំណត់ត្រាការកើនឡើងនៃបំណុលនៅក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចចុងក្រោយបង្អស់" VOD ខែកុម្ភៈ ឆ្នាំ២០២១ មាននៅ https://bit.ly/41alrAZ; Phoeurk Raksmey et al., បំណុលផ្ទាល់ខ្លួន និងបំណុលគ្រួសារនៅដែនជម្រកសត្វព្រៃឆែប គូលែនព្រហ្មទេព ព្រៃព្រះរកា ខេត្តព្រះវិហារ ឆ្នាំ២០២២ ទំ. ៥; Emiel de Lange, ការយល់ដឹងពីការគ្រប់គ្រងតំបន់សហគមន៍នៅវាលទំនាបភាគខាងជើង ឆ្នាំ២០២២។

ករណីដែលមិនបាត់បង់ដី ដើមបណ្ដឹងបានរាយការណ៍ពីការជួបប្រទះនឹងផលប៉ះពាល់ទាំងនេះ ដោយសារបំណុលច្រើនពេក និងសម្ពាធពីការប្រមូលប្រាក់ពីសំណាក់ BFIs ដូចបានពិពណ៌នាខាងលើ ដែលផ្ទុយពីស្តង់ដារ GIIP ដែលត្រូវបានតម្រូវ ស្របតាម PS1។

*ក) អសន្តិសុខស្បៀង*

ដើមបណ្ដឹងប្រាំមួយនាក់បានរាយការណ៍អំពីការកាត់បន្ថយការទទួលទានអាហារនៅក្នុងគ្រួសាររបស់ពួកគេ ជាពិសេស សាច់ ជាមធ្យោបាយដើម្បីឆ្លើយតប និងទប់ទល់ជាមួយនឹងភាពជំពាក់បំណុលវ័ណ្ឌក ឬការបង្ខំឲ្យលក់ដីបង្កបង្កើនរបស់ពួកគេមុនកាលកំណត់ ដើម្បីសងប្រាក់កម្ចី។ ទំនាក់ទំនងរវាងកង្វះអាហារូបត្ថម្ភ ការទទួលបានអាហារូបត្ថម្ភមិនគ្រប់គ្រាន់ និងបញ្ហាសុខភាព ត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់ ហើយវាសារៈសំខាន់ជាពិសេសសម្រាប់កុមារ ដែលភាពយឺតយ៉ាវនៃការអភិវឌ្ឍផ្លូវចិត្ត និងផ្លូវកាយរបស់ពួកគេ គឺជាកង្វល់ដ៏គួរឱ្យកត់សម្គាល់នៅកម្ពុជា។[528] ដោយឈរលើមូលដ្ឋាននេះ ការផ្លាស់ប្តូររបបអាហារដែលមានហានិភ័យ ឬបង្កឱ្យមានអាហារូបត្ថម្ភមិនល្អ ឬកង្វះអាហារូបត្ថម្ភ គឺជាផលប៉ះពាល់អវិជ្ជមាន និងបង្កជាគ្រោះថ្នាក់។

*ខ) ផលប៉ះពាល់លើការអប់រំរបស់កុមារ*

ដើមបណ្ដឹងដប់នាក់បានរាយការណ៍អំពីការបញ្ឈប់ការសិក្សារបស់កូនៗពួកគេ ដែលមានអាយុពី ១៣ ទៅ ១៧ ឆ្នាំ ដោយសារមិនមានលទ្ធភាពបង់ថ្លៃសាលារៀន ឬត្រូវការឱ្យកូនៗរបស់ពួកគេទៅធ្វើការដើម្បីសងប្រាក់កម្ចី។ កុមារបានទៅធ្វើការនៅចម្ការកៅស៊ូ ចម្ការអំពៅ ចម្ការពោត រោងចក្រសម្លូតស្វាយ ឬធ្វើការងារនៅរោងចក្រកែច្នៃ និងការដ្ឋានសំណង់។ កុមារប្រាំនាក់ក្នុងចំណោមពួកគេ មិនបានត្រលប់ទៅសាលារៀនវិញទេ រួមទាំងកុមារអាយុ ១៤ ឆ្នាំពីរនាក់ ដែលត្រូវឈប់រៀនដើម្បីទៅធ្វើការងារនៅចម្ការអំពៅ និងការដ្ឋានសំណង់ ដើម្បីជួយសងបំណុលមីក្រូហិរញ្ញវត្ថុរបស់ឪពុកម្តាយពួកគេ។ កូនរបស់ដើមបណ្ដឹងម្នាក់ទៀតបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ទាប់ពីបានឈប់រៀននៅអាយុ ១៣ ឆ្នាំ និងធ្វើការងារនៅចម្ការអំពៅអស់រយៈពេលបីឆ្នាំ។ កូនៗរបស់ដើមបណ្ដឹងម្នាក់ទៀត ដែលមានអាយុ ១៣ និង ១៥ ឆ្នាំ បានវិលត្រលប់ទៅសាលារៀនវិញ បន្ទាប់ពីបានធ្វើការងារបេះពោតអស់រយៈពេលពីរសប្តាហ៍ ដើម្បីឆ្លើយតបនឹងសំណើ និងសម្ពាធឱ្យសងបំណុលពីបុគ្គលិករបស់អតិថិជនបន្តរបស់ IFC ប៉ុន្តែដើមបណ្ដឹងនៅតែបន្តជួបប្រទះនឹងការលំបាកចំពោះចំណាយលើការអប់រំ។

អង្គការអន្តរជាតិខាងការងារ (ILO) និងប្រភពដទៃទៀតបានព្រមានអំពីទំនាក់ទំនងទៅវិញទៅមករវាងពលកម្ម

[528] Kimty Seng, ការពិនិត្យឡើងវិញលើសក្តានុពលរបស់មីក្រូឥណទានក្នុងការកាត់បន្ថយភាពក្រីក្រ៖ ភស្តុតាងពីកម្ពុជា, *ទិន្នានុប្បវត្តិនៃការអភិវឌ្ឍអន្តរជាតិ* ឆ្នាំ២០១៨; Res, ឆ្នាំ២០២១; Phasy Res, មីក្រូហិរញ្ញវត្ថុនៅក្នុងព្រំដែនព្រៃឈើ៖ ដី និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាជនពូណងនៅតំបន់ការពារនៃប្រទេសកម្ពុជា, *WCS កម្ពុជា, KSWS REDD+,* ឆ្នាំ២០២៤ (តទៅហៅថា Res, ២០២៤); Iskander, D. et al., ភាពធុញទ្រាន់នឹងបំណុល៖ របៀបដែលការជំពាក់បំណុលវ័ណ្ឌក កំពុងប៉ះពាល់ដល់សុខភាពនៅទីជនបទនៃប្រទេសកម្ពុជា, ឆ្នាំ២០២២ (តទៅហៅថា Iksander et al., ២០២២); របាយការណ៍ Bliss, ទំ. ២១-២២ ដែលទាញអាគតដ្ឋានក្នុងចំណោម UNICEF et al. (ឆ្នាំ២០២១)៖ ជំងឺកូវីដ ១៩. ការវាយតម្លៃផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គម។ ភ្នំពេញ, ៥៥f, ៧១; ព្រះរាជាណាចក្រកម្ពុជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ការបែងចែកដីសម្រាប់គម្រោងអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច III (LASED III), ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម, ឆ្នាំ២០២៥, p.ix, ៣២ https://bit.ly/4k9d2aS។

កុមារ និងតម្រូវការរបស់គ្រួសារក្រីក្រក្នុងការសងបំណុល។[529] ច្បាប់ការងារកម្ពុជាកំណត់អាយុអប្បបរមាសម្រាប់ការចូលធ្វើការ ត្រឹម ១៥ ឆ្នាំ និងអាយុអប្បបរមាសម្រាប់ការធ្វើការងារដែលមានគ្រោះថ្នាក់ ត្រឹម ១៨ឆ្នាំ[530] ប៉ុន្តែកុមារដែលឈប់រៀន និងហេតុការណ៍នៃពលកម្មកុមារដែលអាចកើតឡើង នៅតែជាកង្វល់ចម្បងនៅក្នុងប្រទេសនេះ ដោយកុមារអាយុ ៥-១៤ ឆ្នាំ ចំនួន ៩% ធ្វើការងារពេញម៉ោង ហើយកុមារអាយុ ១៥-១៧ ឆ្នាំ ចំនួន ៤៣% ធ្វើការងារដែលមានគ្រោះថ្នាក់។[531]

តាមទស្សនវិស័យនៃការអភិវឌ្ឍសង្គម ការបាត់បង់ការអប់រំមានផលវិបាករយៈពេលវែងជាខ្លាំង។ នៅកម្រិតផ្ទាល់ខ្លួន វាដាក់កម្រិតលើឱកាសការងាររបស់កុមារនាពេលអនាគត សក្តានុពលក្នុងការរកប្រាក់ចំណូល និងសមត្ថភាពក្នុងការបំបែកវដ្តនៃភាពក្រីក្រ។ វាក៏កាត់បន្ថយសមត្ថភាពរបស់ពួកគេក្នុងការចូលរួមយ៉ាងពេញលេញក្នុងជីវិតជាពលរដ្ឋ និងធ្វើការសម្រេចចិត្តអំពីសុខភាព គ្រួសារ និងហិរញ្ញវត្ថុ ដោយមានព័ត៌មានគ្រប់គ្រាន់។ ការរំខានដល់ការអប់រំក្នុងវ័យជំទង់បង្កការខូចខាតជាពិសេស ពីព្រោះវាស្របគ្នានឹងដំណាក់កាលសំខាន់ៗនៃការអភិវឌ្ឍខួរក្បាល សង្គម និងអារម្មណ៍។[532]

### *គ) ផលប៉ះពាល់លើសុខភាព*

បន្ថែមលើផលប៉ះពាល់ជាទូទៅរបស់អសន្តិសុខស្បៀងទៅលើសុខភាពរបស់ប្រជាជនទៀតនោះ ដើមបណ្តឹងម្នាក់បានរាយការណ៍អំពីការពន្យារពេលទទួលការព្យាបាល ដើម្បីសន្សំប្រាក់សម្រាប់សងបំណុល។ មានការបោះពុម្ពផ្សាយការសិក្សាបែបវិទ្យាសាស្ត្រកាន់តែច្រើនអំពីទំនាក់ទំនងដោយប្រយោល និងដោយផ្ទាល់រវាងការ

---

529 ILO, កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC), ការអនុវត្តល្អសម្រាប់ការដោះស្រាយពលកម្មកុមារនៅកម្ពុជា ឆ្នាំ ២០១៤ ទំ. ២២, https://bit.ly/429drl4។ ក្រសួងការបរទេសសហរដ្ឋអាមេរិក, ក្រុមប្រឹក្សាធុរកិច្ចកម្ពុជាស្តីពីការវិនិយោគ និងអន្តរកម្មដែលមានហានិភ័យខ្ពស់, សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១, https://bit.ly/41cQmfV។ បំណុលហិរញ្ញវត្ថុក៏បានជម្រុញកុមារឱ្យធ្វើការងារគ្រោះថ្នាក់នៅក្នុងឡឥដ្ឋ ឬនៅក្នុងវិស័យកសិកម្ម ដូចជា ការបាញ់ថ្នាំសម្លាប់សត្វល្អិតនៅចម្ការចេក ឬការប្រឈមនឹងសារធាតុគីមីគ្រោះថ្នាក់។ Muyhong, Chan, Narin, Sun, Sarath, Sorn, Nachemson, Andrew, "កម្មករ រួមទាំងកុមារមិនគ្រប់អាយុ ពុះពារនឹងសារធាតុគីមីគ្រោះថ្នាក់ដើម្បីចិញ្ចឹមជីវិត នៅក្នុងចម្ការចេកនៃប្រទេសកម្ពុជា" *CamboJA* News, ខែវិច្ឆិកា ឆ្នាំ ២០២១ https://bit.ly/41ds4m4។ ក្រសួងការងារសហរដ្ឋអាមេរិក, គំហើញឆ្នាំ២០២៣ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ ២០២៣ ទំ. ១; ក្រសួងការងារសហរដ្ឋអាមេរិក, គំហើញឆ្នាំ២០២២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ២០២២ ទំ. ១; Brickell K., Parsons, L., Natarajan, N., Chann, S. Blood Bircks៖ សាច់រឿងដែលគ្មានអ្នកនិយាយ ទាសភាពសម័យទំនើប និងការប្រែប្រួលអាកាសធាតុពីប្រទេសកម្ពុជា ឆ្នាំ២០១៨។ Blomberg, M., សេចក្តីថ្លែងការផ្លូវការបង្ហាញពីពលកម្មកុមារនៅក្នុងឡឥដ្ឋនៃប្រទេសកម្ពុជា ទោះបីជាមានការបង្ក្រាបក៏ដោយ, Reuters ខែកុម្ភៈ ឆ្នាំ២០២០ https://bit.ly/422OkCO។

530 មាត្រា១៧៧ នៃច្បាប់ការងារ រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ១៩៩៧)។ ច្បាប់ការងារ (VS/VKM/0397/01) រាជធានីភ្នំពេញ។

531 ក្រសួងការងារសហរដ្ឋអាមេរិក, គំហើញឆ្នាំ២០២៣ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ២០២៣ ទំ. ១។ នៅឆ្នាំ២០២០ ប្រទេសកម្ពុជា គឺជារដ្ឋនៅតំបន់អាស៊ីអាគ្នេយ៍ ដែលទទួលបានការវាយតម្លៃធ្ងន់ធ្ងរបំផុត ទាក់ទងនឹងពលកម្មកុមារ។ GLOBE, សន្ទស្សន៍ពលកម្មកុមារ៖ ប្រទេសកម្ពុជាមានហានិភ័យខ្ពស់បំផុតនៅក្នុងតំបន់ចំពោះកម្មករមិនគ្រប់អាយុ ខែមិថុនា ឆ្នាំ២០២០ https://bit.ly/43K4Mco។ ក្រសួងការងារសហរដ្ឋអាមេរិក, គំហើញឆ្នាំ២០២២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ២០២២ ទំ. ១; Brickell K., Parsons, L., Natarajan, N., Chann, S. Blood Bircks៖ សាច់រឿងដែលគ្មានអ្នកនិយាយ ទាសភាពសម័យទំនើប និងការប្រែប្រួលអាកាសធាតុពីប្រទេសកម្ពុជា ឆ្នាំ២០១៨។ Blomberg, M., សេចក្តីថ្លែងការផ្លូវការបង្ហាញពីពលកម្មកុមារនៅក្នុងឡឥដ្ឋនៃប្រទេសកម្ពុជា ទោះបីជាមានការបង្ក្រាបក៏ដោយ, Reuters ខែកុម្ភៈ ឆ្នាំ២០២០ https://bit.ly/422OkCO។ នៅកម្រិតសង្គម ការបោះបង់ចោលការសិក្សាយ៉ាងទូលំទូលាយធ្វើឱ្យប៉ះពាល់ដល់ការបង្កើតមូលធនមនុស្ស ធ្វើឱ្យកម្លាំងពលកម្មជំនាញចុះខ្សោយ និងរារាំងកំណើនសេដ្ឋកិច្ច។

532 សូមមើល៖ UNESCO ឆ្នាំ២០២៤/២០២៥ របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល ភាពជាអ្នកដឹកនាំផ្នែកអប់រំ៖ ការជម្រុញការសិក្សា https://bit.ly/4o2OiTx; WBG, របាយការណ៍ថ្មីលើកឡើងថា ការបាត់បង់ការសិក្សាត្រូវបានតែបានស្តារឡើងវិញ ដើម្បីជៀសវាងការខូចខាតរយៈពេលវែងចំពោះសុខុមាលភាព និងផលិតភាពរបស់កុមារ ឆ្នាំ២០២២ https://bit.ly/4gVdRUu។

ជំពាក់បំណុលវ័ណ្ឌក និងសុខភាព [533] ព្រមទាំងរបៀបដែលអ្នកជំពាក់បំណុលនៅកម្ពុជាតែងតែពន្យារពេលទទួលព្យាបាលផ្នែកវេជ្ជសាស្ត្រដែលចាំបាច់ ដើម្បីជៀសវាងការជំពាក់បំណុលកាន់តែច្រើន ដោយការជាប់បំណុលវ័ណ្ឌក "មានទំនាក់ទំនងនឹងការលះបង់សុខភាពរយៈពេលខ្លីកាន់តែច្រើន ដើម្បីសងបំណុល និងភាពអត់ទ្រាំជាមួយការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត និងសង្គមរយៈពេលវែង"។[534]

ដើមបណ្តឹងដប់ពីរនាក់បានរាយការណ៍បន្ថែមទៀតអំពីផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត ដែលរួមមាន ការគេងមិនលក់ ភាពថប់បារម្ភ ការធ្លាក់ទឹកចិត្ត និងការបាត់បង់ចំណង់អាហារ ដោយសារសម្ពាធពីការទារបំណុល ឬភាពតានតឹងផ្លូវចិត្តរយៈពេលវែង និងភាពល្ងីតល្ងៃ ដោយសារកង្វះការសម្រាកដោយសារប្រាក់កម្ចី។ ជាទូទៅការសិក្សាបានបង្ហាញថា អ្នកដែលមានភាពតានតឹងផ្នែកហិរញ្ញវត្ថុ និងអ្នកដែលមានការលំបាកក្នុងការសងបំណុល ទំនងជារាយការណ៍អំពីភាពថប់បារម្ភច្រើនជាង និងភាពពេញចិត្តចំពោះជីវិតតិចជាង ជាពិសេស អ្នកដែលមានផលធៀបខ្ពស់រវាងបំណុល និងទ្រព្យសកម្ម។[535] នៅប្រទេសកម្ពុជាជាពិសេស មានការរកឃើញថាបំណុល និងការលំបាកក្នុងការសងបំណុល ចូលរួមចំណែកដល់ភាពតានតឹងផ្លូវចិត្ត ភាពថប់បារម្ភ និងបញ្ហាដំណេកកម្រិតខ្ពស់ នៅក្នុងចំណោមសហគមន៍ជនបទ[536] ដូចជា ដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ជាដើម។ ការសិក្សាឆ្នាំ២០២២ បានរកឃើញថា កសិករនៅតាមជនបទនៃប្រទេសកម្ពុជាតែងតែផ្សារភ្ជាប់ភាពតានតឹងផ្លូវកាយ និងផ្លូវចិត្តរបស់ខ្លួនទៅនឹងការបង់រំលោះប្រាក់កម្ចីបន្ទាប់ ស្របពេលជាមួយគ្នានោះ សង្កត់ធ្ងន់ថាទោះបីជាក្នុងតម្លៃណាក៏ដោយ ត្រូវជៀសវាងការបង្កភាពអាម៉ាស និងការខូចកេរ្តិ៍ឈ្មោះពីការមានមន្ត្រីឥណទានចុះមកដល់ផ្ទះ ឬកន្លែងធ្វើអាជីវកម្មរបស់ពួកគេ ដើម្បីទារបំណុលដែលបង់យឺត។[537]

ដើមបណ្តឹងនៅក្នុងសំណុំរឿងនេះបានរាយការណ៍ពីផលប៉ះពាល់ដល់សុខភាពផ្លូវចិត្តខុសៗគ្នា។ ទោះបីជាមិនមានហេតុការណ៍នៃការធ្វើអត្តឃាតដោយសារបំណុល ក្នុងចំណោមដើមបណ្តឹងទាំង ១៨ នាក់ ឬគ្រួសាររបស់ពួកគេក៏ដោយ ក៏ដើមបណ្តឹងម្នាក់ និងសមាជិកគ្រួសាររបស់ដើមបណ្តឹងម្នាក់ទៀត ពិតជាបានបង្ហាញទៅកាន់ស៊ីអេអូថា ពួកគេធ្លាប់មានគំនិតធ្វើអត្តឃាតដោយសារស្ថានភាពបំណុល និងសម្ពាធពីការអនុវត្តការប្រមូលប្រាក់ ដែលចាំបាច់ត្រូវមានអន្តរាគមន៍ពីគ្រួសារ។ ព័ត៌មានទាំងនេះស្របគ្នានឹងការសិក្សានានា ដែលបានរកឃើញថា បន្ទុកបំណុល និងភាពមាក់ងាយពីសង្គម គឺជាកត្តាកំណត់សង្គមដ៏ខ្លាំងក្លា ដែលមានទំនាក់ទំនងនឹងការកើនឡើងនៃលទ្ធភាពក្នុងការប៉ុនប៉ងធ្វើអត្តឃាត។[538] បន្ថែមលើបទពិសោធន៍ដែលបានដឹងពីប្រទេស

---

[533] Östergren PO, Bodin T, Canivet C, Moghaddassi M, Vilhelmsson A. ការលក់អនាគតរបស់នរណាម្នាក់៖ ការជំពាក់បំណុលវ័ណ្ឌក និងហានិភ័យនៃសុខភាពផ្លូវចិត្តចុះខ្សោយ និងតួនាទីការងារដែលមានគ្រោះថ្នាក់ - លទ្ធផលពីក្រុមសុខភាពសាធារណៈ Scania ប្រទេសស៊ុយអែត. BMJ Open. ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២; ១២(១១)។

[534] Iskander et al., ឆ្នាំ២០២២ ទំ. ២។

[535] កម្មវិធីសុវត្ថិភាពហិរញ្ញវត្ថុ និង Dyvonne Body, បន្ទុកបំណុលលើសុខភាពផ្លូវចិត្ត និងផ្លូវកាយ, ខែសីហា ឆ្នាំ២០១៨, https://bit.ly/3R78TYv។ Meltzer H, Bebbington P, Brugha T, Farrell M, Jenkins R. ទំនាក់ទំនងរវាងបំណុលផ្ទាល់ខ្លួន និងវិបត្តិផ្លូវចិត្តទូទៅជាក់លាក់. *Eur J Public Health.* ខែកុម្ភៈ ឆ្នាំ២០១៣; ២៣(១):១០៨-១៣។

[536] Guermond et al., ឆ្នាំ២០២២ ទំព័រ ៣៤-៣៥

[537] Guermond et al., ឆ្នាំ២០២២ ទំព័រ ៣៤-៣៥

[538] Naranjo DE, Glass JE, Williams EC. អ្នកដែលមានបន្ទុកបំណុលទំនងជារាយការណ៍អំពីការប៉ុនប៉ងធ្វើអត្តឃាតច្រើនជាងអ្នកដែលមិនមានបន្ទុកបំណុល៖ ការសិក្សាថ្នាក់ជាតិជាមួយមនុស្សពេញវ័យនៅសហរដ្ឋអាមេរិក។ J Clin Psychiatry. ថ្ងៃទី៦ ខែមេសា ឆ្នាំ ២០២១;៨២(៣), https://bit.ly/4itPLQu; Rojas Y. ការជំពាក់បំណុលហិរញ្ញវត្ថុ និងអត្តឃាត៖ ការសិក្សាតាមដានរយៈពេលមួយឆ្នាំលើប្រជាជនដែលបានចុះបញ្ជីនៅអាជ្ញាធរអនុវត្តច្បាប់ស៊ុយអែត។ Int J Soc Psychiatry. ខែវិច្ឆិកា ឆ្នាំ២០២២;៦៨(៧):១៤៤៥-១៤៥៣។

ដទៃទៀត ដែលបំណុលមីក្រូឥណទានបានបង្កឱ្យមានផលប៉ះពាល់សង្គមប្រភេទនេះ [539] (សូមមើលផ្នែក ១.១) ប្រព័ន្ធផ្សព្វផ្សាយក៏បានរាយការណ៍អំពី ករណីអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាតចំនួនបួននៅកម្ពុជា ដោយមានការរាយការណ៍ថា បំណុលគឺជាកត្តារួមចំណែក។[540]

*ឃ) ចំណាកស្រុកដោយសារបំណុល និងផលប៉ះពាល់លើគ្រួសារជាបន្តបន្ទាប់*

ដើមបណ្តឹងប្រាំពីរនាក់បានធ្វើចំណាកស្រុកដោយខ្លួនឯង ឬមានសាច់ញាតិធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារបន្ថែម ដើម្បីសងប្រាក់កម្ចីរបស់ពួកគេ ដែលមានផលប៉ះពាល់អវិជ្ជមានជាបន្តបន្ទាប់លើជីវិតគ្រួសាររបស់ពួកគេ ការអប់រំរបស់កូនៗពួកគេ និងក្នុងករណីមួយចំនួន ការលំបាកផ្នែកហិរញ្ញវត្ថុបន្ថែមទៀត និងហានិភ័យទាក់ទងនឹងលក្ខខណ្ឌការងាររបស់ជនចំណាកស្រុក និងផលប៉ះពាល់ខុសៗគ្នាតាមយេនឌ័រ។ ក្នុងចំណោមដើមបណ្តឹងដែលបានរាយការណ៍ពីការធ្វើចំណាកស្រុក ដើមបណ្តឹងពីរនាក់បានធ្វើចំណាកស្រុកតាមរដូវកាលទៅកាន់ស្រុក ឬខេត្តជិតខាង ដើម្បីស៊ីឈ្នួលប្រចាំថ្ងៃ ដើមបណ្តឹងពីរនាក់ទៀតបានធ្វើចំណាកស្រុកទៅកាន់ខេត្តជិតខាងរយៈពេលមួយឆ្នាំ ឬយូរជាងនេះ ហើយដើមបណ្តឹងបីនាក់ទៀតបានធ្វើចំណាកស្រុក ឬមានសាច់ញាតិធ្វើចំណាកស្រុកទៅបរទេស (ទៅប្រទេសថៃ និងប្រទេសកូរ៉េខាងត្បូង) ដើម្បីជួយសងបំណុលពួកគេ។ ទោះបីជាចំណាកស្រុកចេញពីទីជនបទមានបុព្វហេតុជាច្រើនក្តី ក៏អង្គការអន្តរជាតិទេសន្តរប្រវេសន៍បានរាយការណ៍ថា នៅត្រឹមឆ្នាំ២០១៦ ជនចំណាកស្រុកកម្ពុជាចំនួន ៤០,៦% បានចាកចេញពីប្រទេស ដោយសារបំណុលហិរញ្ញវត្ថុ។[541] ចំណាកស្រុកផ្ទាល់មិនមានគ្រោះថ្នាក់ជាប់មកជាមួយឡើយ ប៉ុន្តែអាចបង្កឱ្យមានផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គម។ ពលករចំណាកស្រុកអាចប្រឈមមុខនឹងចំណាយថ្មីៗ ដូចជា ការទិញអាហារ

---

539 សូមមើល៖ Biswas, Soutik "ការរីករាលដាលនៃអត្តឃាតដោយសារមីក្រូហិរញ្ញវត្ថុនៅប្រទេសឥណ្ឌា", BBC News, ខែធ្នូ ឆ្នាំ ២០១០, https://bit.ly/41GDWza, និងរបាយការណ៍របស់អ្នកជំនាញឯករាជ្យនៃអង្គការសហប្រជាជាតិស្តីពីបំណុលឯកជន និងសិទ្ធិមនុស្ស របាយការណ៍របស់អ្នកជំនាញឯករាជ្យស្តីពីឥទ្ធិពលនៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធដទៃទៀតរបស់រដ្ឋ លើការសម្រេចបានសិទ្ធិមនុស្សពេញលេញ ជាពិសេស សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឆ្នាំ២០២០ A/HRC/43/45, https://bit.ly/4huZHYJ នៅទំព័រ១ និងកថាខណ្ឌ ៣៣។

540 Jack Brook, 'ខ្ញុំខ្លាចថា ខ្ញុំនឹងសម្លាប់ខ្លួន ដូចប្តីខ្ញុំដែរ'៖ ការឆ្លុះបញ្ចាំងលើក្រុមហ៊ុនផ្តល់ប្រាក់កម្ចីនៅកម្ពុជា បន្ទាប់ពីអត្តឃាតរបស់ជនជាតិដើមភាគតិច, *The Guardian*, ខែតុលា ឆ្នាំ២០២៣, https://bit.ly/43HKT5J។ ស៊ីអេអូកត់សម្គាល់ថា បន្ទាប់ពីការចោទប្រកាន់ទាំងនេះពីប្រព័ន្ធផ្សព្វផ្សាយ CMA បានរៀបចំការស៊ើបអង្កេតលើករណីអត្តឃាត និងបានសន្និដ្ឋានថា មិនមានភស្តុតាងអំពីទំនាក់ទំនងរវាងហេតុការណ៍នេះជាមួយកម្ចីមីក្រូហិរញ្ញវត្ថុនោះទេ និងថា "សោកនាដកម្មនេះបណ្តាលមកពីកត្តាជាច្រើនរួមបញ្ចូលគ្នា ដែលរួមមាន អ្នកផ្តល់ប្រាក់កម្ចីឯកជន បញ្ហាគ្រួសារ និងបញ្ហាដទៃទៀត។" សូមមើល៖ Thang Sinorn, CMA មានជំហររឹងមាំប្រឆាំងនឹងការចោទប្រកាន់អំពីអត្តឃាត, *Kiripost*, ខែវិច្ឆិកា ឆ្នាំ២០២៣, https://bit.ly/3XTeGoj។ ស៊ីអេអូបានស្នើសុំមើលរបាយការណ៍នេះ ប៉ុន្តែមិនបានទទួលការអនុញ្ញាតនោះទេ។ តាមការស្នើសុំរបស់ពួកគេ ស៊ីអេអូបានធ្វើកិច្ចសម្ភាសជាលក្ខណៈបុគ្គលដោយឯករាជ្យជាមួយសាច់ញាតិរបស់អ្នកខ្ចី ដែលបានគូសបញ្ជាក់ឡើងវិញថា បំណុល គឺជាកត្តាមួយនៃអត្តឃាត ឬការប៉ុនប៉ងធ្វើអត្តឃាត។ ប្រព័ន្ធផ្សព្វផ្សាយដទៃទៀតបានចង្អុលបង្ហាញផងដែរថា បំណុលមានតួនាទីក្នុងការធ្វើអត្តឃាតនៅក្នុងប្រទេសកម្ពុជា សូមមើល៖ *The Nation* ខែធ្នូ ឆ្នាំ២០២២ https://officecao.org/45ve9fg; និង *Kiripost* ខែកញ្ញា ឆ្នាំ២០២៣ https://officecao.org/4lpuB70។

541 IOM (ឆ្នាំ២០២២) ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមនៃជំងឺកូវីដ ១៩ ទៅលើពលករចំណាកស្រុកនៅប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ប្រទេសមីយ៉ាន់ម៉ា និងប្រទេសថៃ https://bit.ly/41RDqyq, ទំ. xix, ២៦,៣៣; IOM, (ឆ្នាំ២០១៩). បំណុល និងបទពិសោធន៍របស់ជនចំណាកស្រុក៖ ការយល់ដឹងស៊ីជម្រៅពីតំបន់អាស៊ីអាគ្នេយ៍. ទីក្រុងបាងកក៖ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ https://bit.ly/4255NdR។ Dickson, Brett, Koenig, Andrea, "របាយការណ៍វាយតម្លៃ៖ ព័ត៌មានអំពីពលករចំណាកស្រុកកម្ពុជាដែលបានវិលត្រលប់មកវិញ", អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ប្រចាំកម្ពុជា, ឆ្នាំ២០១៦, ទំ. ១៤. https://bit.ly/3nGFLw សូមមើល៖ Bylander, Maryann. ឆ្នាំ២០១៤. "កម្ចីឆ្លងដែន៖ ចំណាកស្រុក និងមីក្រូឥណទាននៅទីជនបទនៃប្រទេសកម្ពុជា" ការអភិវឌ្ឍ និងការផ្លាស់ប្តូរ ៤៥ (២): ២៨៤–៣០៧។

ជំនួសឱ្យការផលិតអាហារ ដែលនាំឱ្យមានការផ្លាស់ប្តូររបៀបរបប និងជីវភាពរស់នៅគួរឱ្យកត់សម្គាល់ ព្រមទាំងលក្ខខណ្ឌការងារដែលអសុវត្ថិភាពផងដែរ។

ឧទាហរណ៍ ពាក់ព័ន្ធនឹងដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ដើមបណ្តឹងជាជនជាតិដើមភាគតិចម្នាក់ បានធ្វើចំណាកស្រុកទៅប្រទេសថៃជាមួយគ្រួសាររបស់គាត់ ដើម្បីឱ្យគាត់ និងប្រពន្ធរបស់គាត់អាចធ្វើការងារ ដើម្បីសងបំណុលជាង ២០ លានរៀល (ប្រហែល ៥.០០០ដុល្លារអាមេរិក)។ កាលពីមុន ពួកគេមានដីកសិកម្មនៅក្នុង ICLTs របស់សហគមន៍ពួកគេ ដោយពួកគេបានលក់ដីមួយផ្នែកដើម្បីសងបំណុល ហើយពួកគេទទួលបានប្រាក់ចំណូលពីរបរអារឈើ ការប្រមូលផលគ្រាប់ស្វាយចន្ទី និងសកម្មភាពកសិកម្មដទៃទៀត។ ពួកគេបានរាយការណ៍ថា នៅក្នុងចម្ការទុរេន និងមង្ឃុតនៅប្រទេសថៃដែលប្តីប្រពន្ធនេះធ្វើការ កម្មករភាគច្រើនក៏មកពីប្រទេសកម្ពុជាដែរ ដោយក្នុងនោះ កម្មករ ១០ នាក់ក្នុងចំណោមកម្មករ ៣០ នាក់ មកពីភូមិរបស់ពួកគេ។ បន្ទាប់ពីទៅដល់ទីនោះ ប្តីប្រពន្ធនេះបានរកឃើញថា ចំណាយផ្លូវច្បាប់ពាក់ព័ន្ធនឹងការចូល និងការធ្វើការងារដោយស្របច្បាប់នៅប្រទេសថៃ ព្រមទាំងចំណាយលើការរស់នៅ ខ្ពស់ជាងការរំពឹងទុករបស់ពួកគេ។ បញ្ហានេះបានបង្ខំឱ្យពួកគេកាត់បន្ថយបរិមាណ និងគុណភាពអាហារដែលពួកគេទទួលទាន ដើម្បីសន្សំលុយ ហើយកូនៗរបស់ពួកគេដែលមានអាយុ ១២ និងប្រាំពីរឆ្នាំ មិនអាចទៅរៀនបានទេ ដែលបង្កឲ្យមានភាពថប់បារម្ភបន្ថែមទៀត។ ក្នុងរយៈពេលប្រហែលមួយឆ្នាំនៃការធ្វើការងារនៅប្រទេសថៃ ដើមបណ្តឹងនេះអាចសងបំណុលបានប្រមាណ ២.១៥០.០០០រៀល (ប្រហែល ៥៣០ ដុល្លារអាមេរិក) នៃបំណុលរបស់គាត់។[542] គ្រួសារនេះមានបំណងត្រលប់មកកម្ពុជាវិញ នៅឆ្នាំ២០២៥ ដើម្បីចុះឈ្មោះកូនៗឱ្យចូលរៀនឡើងវិញ បន្ទាប់ពីមិនបានទៅសាលារៀនអស់រយៈពេលពីរឆ្នាំ ព្រមទាំងធ្វើដំណើរតាមរដូវកាល ទៅកាន់ប្រទេសថៃនៅរដូវប្រមូលផល។

គ្រួសាររបស់ដើមបណ្តឹងបួននាក់បានរាយការណ៍ថា សាច់ញាតិជាស្ត្រីបានធ្វើចំណាកស្រុកទៅធ្វើការងារនៅរោងចក្រកាត់ដេរ ដែលធ្វើឱ្យពួកគេបែកពីគ្រួសារ និងបណ្តាញគាំទ្ររបស់ពួកគេ ដើម្បីផ្ញើប្រាក់ខែមួយផ្នែករបស់ពួកគេ ដើម្បីជួយសងបំណុលគ្រួសារ។ នៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា ដែលកម្មករ ៨០% ជាស្ត្រីអាយុក្រោម ៣០ ឆ្នាំនោះ លក្ខខណ្ឌការងារមានគ្រោះថ្នាក់ និងបញ្ហាតាមយេនឌ័រជាក់លាក់ ដូចជា ការរើសអើង

---

[542] របាយការណ៍ជាច្រើន រួមទាំងការសិក្សារបស់ IOM ពីឆ្នាំ២០១៩ គូសបញ្ជាក់អំពីបញ្ហាប្រឈមរបស់ពលករចំណាកស្រុកកម្ពុជានៅប្រទេសថៃ ដូចជា ការរកចំណូលបានតិចជាងប្រាក់ឈ្នួលអប្បបរមា ជាពិសេស ការធ្វើការនៅក្នុងវិស័យដែលមានការកេងប្រវ័ញ្ច ដូចជា វិស័យសំណង់ កម្មសាល នេសាទ និងកសិកម្ម។ ការប៉ាន់ស្មាននានាបង្ហាញថា ជនចំណាកស្រុកប្រហែល ២០% ទៅ ៣៣% មិនមានឯកសារនោះទេ ដែលធ្វើឱ្យពួកគេងាយរងគ្រោះចំពោះការរំលោភសិទ្ធិមនុស្សជាពិសេស និងទំនងជាជួបប្រទះនឹងពលកម្មដោយបង្ខំច្រើនជាងពលករក្នុងស្រុកចំនួនបីដង។ IOM, ការវាយតម្លៃការផ្លាស់ប្តូរដែលអាចកើតឡើងនៅក្នុងលំនាំនៃចំណាកស្រុករបស់ជនចំណាកស្រុកកម្ពុជា និងផលប៉ះពាល់លើប្រទេសថៃ និងប្រទេសកម្ពុជា, ឆ្នាំ២០១៩ ទំ. v. ILO, លក្ខខណ្ឌការងារនៅក្នុងវិស័យកសិកម្មនៅប្រទេសថៃ, ការស្ទង់មតិជាមួយជនចំណាកស្រុក ដែលធ្វើការងារនៅចម្ការអំពៅ កៅស៊ូ ដូងប្រេង និងពោតនៅប្រទេសថៃ, ឆ្នាំ២០២១; IOM, ពីចំណាកស្រុកទៅនវានុវត្តន៍៖ ការធ្វើដំណើររបស់ពលករស្ត្រីចំណាកស្រុកកម្ពុជាដែលវិលត្រលប់មកវិញ, ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ https://bit.ly/3FEHLNX។ Ry Sochan, IOM៖ ជនចំណាកស្រុកកម្ពុជានៅប្រទេសថៃមានជីវភាពក្រីក្រ, ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ https://bit.ly/3DJKWn5; មជ្ឈមណ្ឌលចំណាកស្រុកចម្រុះ, ការឆ្លុះបញ្ចាំង 4Mi នៃ MMC អាស៊ីប៉ាស៊ីហ្វិក-ខែវិច្ឆិកា ឆ្នាំ២០២៣, ការប្រើប្រាស់ជនរត់ពន្ធដើម្បីធ្វើដំណើរទៅប្រទេសថៃ ក្នុងចំណោមប្រជាជនកម្ពុជា និងប្រជាជនឡាវ, https://bit.ly/4bSfvDz; Winrock, RCG, Winrock International៖ STIP នៅប្រទេសកម្ពុជា និង CTIP នៅប្រទេសថៃ, ការវាយតម្លៃស្ថានភាពពលករចំណាកស្រុកកម្ពុជា, ឆ្នាំ២០២៤, https://bit.ly/4bNvtPm, ទំ. ៤។

ពាក់ព័ន្ធនឹងការមានផ្ទៃពោះ និងការបៀតបៀនផ្លូវភេទ កើតឡើងជាទូទៅ។[543]

នៅក្នុងកិច្ចសម្ភាស និងការពិនិត្យឯកសារ ស៊ីអេអូបានសង្កេតឃើញថា ប្រាក់កម្ចី ជាញឹកញាប់ ត្រូវបានចុះហត្ថលេខារួមគ្នាពីសំណាក់ឪពុកម្ដាយ កូនៗដែលពេញវ័យ បងប្អូនបង្កើត និងសមាជិកសហគមន៍ ក្នុងនាមជាអ្នកធានា។ ការអនុវត្តរបស់ BFIs ក្នុងការរាប់បញ្ចូលប្រាក់ចំណូលរបស់សមាជិកគ្រួសារ នៅក្នុងការវាយតម្លៃសមត្ថភាពសងប្រាក់ (សូមមើលផ្នែក ៤.២.១) រួមផ្សំជាមួយការធ្វើចំណាកស្រុកដោយសារបំណុល បានផ្សារភ្ជាប់គ្រួសារជនបទទៅនឹងទីផ្សារការងារទីក្រុង និងបរទេសកាន់តែខ្លាំង ដែលជាញឹកញាប់ មានភាពមិនស្ថិតស្ថេរ។[544] ការពឹងពាក់គ្នាទៅវិញទៅមកផ្នែកហិរញ្ញវត្ថុនេះមានន័យថា នៅពេលដែលហត្ថលេខីរួមធ្វើចំណាកស្រុកដើម្បីទៅធ្វើការ ប្រាក់បញ្ញើរបស់ពួកគេក្លាយជាប្រភពនៃការសងប្រាក់ដ៏សំខាន់។ នៅក្នុងគ្រួសាររបស់ដើមបណ្ដឹងបីនាក់ ការលំបាកក្នុងការសងប្រាក់បានកើតឡើង នៅពេលសាច់ញាតិដែលធ្វើចំណាកស្រុកជួបប្រទះនឹងការបាត់បង់ការងារ ឬការកាត់បន្ថយប្រាក់ខែ ដែលនាំឱ្យមានការថយចុះនៃប្រាក់បញ្ញើ។ ថាមវន្តនេះមិនត្រឹមតែធ្វើឱ្យគ្រួសារប្រឈមនឹងទីផ្សារការងារខាងក្រៅដែលអាចមានភាពប្រែប្រួលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងសង្គម និងគ្រួសារផងដែរ។[545]

*ង) ផលប៉ះពាល់លើទំនាក់ទំនងគ្រួសារ*

នៅក្នុងគ្រួសាររបស់ដើមបណ្ដឹងជាច្រើន ការបាត់បង់ដី និងការធ្លាក់ចុះ ឬការផ្លាស់ប្ដូរមុខរបរចិញ្ចឹមជីវិតដោយសារប្រាក់កម្ចីដែលមិនមានការការពារសមស្របសម្រាប់ជនងាយរងគ្រោះ នាំឲ្យមានភាពតានតឹងនៅក្នុងគ្រួសារ។ ឧទាហរណ៍៖

[543] ទីភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ, មជ្ឈមណ្ឌលព័ត៌មានពលករកម្ពុជាផ្ដល់ការបំពាក់បំប៉នជូនកម្មករកាត់ដេរ ដើម្បីទាមទារឱ្យមានលក្ខខណ្ឌល្អប្រសើរ, ខែមិថុនា ឆ្នាំ២០២៤, https://bit.ly/4mLNMJV សូមមើល៖ Green, ស្ថានភាពបំណុលមិនស្មោះត្រង់, ឆ្នាំ ២០២៣, ទំ. ៥៩៤, Brickell, Katherine, Maryann Bylander, Nithya Natarajan, Laurie Parsons និង Brenda S. A. Yeoh. ឆ្នាំ២០២២. "បំណុល (គ្មាន)សេរីភាព និងការអភិវឌ្ឍ៖ មេរៀនពីអាស៊ីទំនើប" Geoforum ១៣៧:១៥១–១៥៣.; CATU et al., ការកាត់ដេរនៅក្រោមសម្ពាធ, ការបាត់បង់ប្រាក់ឈ្នួលរយៈពេលវែងនៅទូទាំងឧស្សាហកម្មកាត់ដេរកម្ពុជា, ឆ្នាំ២០២០, ទំ. ១២; អង្គការឃ្លាំមើលសិទ្ធិមនុស្ស 'ធ្វើការងារកាន់តែលឿន ឬចាកចេញ' ការរំលោភបំពានសិទ្ធិការងារនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា, ខែមីនា ឆ្នាំ២០១៥, https://bit.ly/3TmAG8t។

[544] W.Nathan Green, ស្ថានភាពបំណុលមិនស្មោះត្រង់៖ ការបង្ហាញពីការវិនិយោគលើផលប៉ះពាល់សង្គមសម្រាប់មីក្រូហិរញ្ញវត្ថុ, EPA: សេដ្ឋកិច្ច និងលំហ, ៥៥(៣), ឆ្នាំ២០២៣, ទំ. ៥៩៤ (តទៅហៅថា Green, ស្ថានភាពបំណុលមិនស្មោះត្រង់, ឆ្នាំ២០២៣); ការស្ទង់មតិរបស់ IOM ឆ្នាំ២០១៩ លើជនចំណាកស្រុកកម្ពុជាចំនួន ៩០០ នាក់នៅប្រទេសថៃ បានរកឃើញថា អ្នកឆ្លើយតបជាង ៩០ ភាគរយបាននិយាយថា ការប្រាក់ផ្ញើរបស់ពួកគេមានសារៈសំខាន់ក្នុងការកែលម្អស្ថានភាពរស់នៅរបស់គ្រួសារពួកគេ ឬជាប្រាក់ចំណូលចម្បងរបស់គ្រួសារពួកគេ, IOM, ការវាយតម្លៃការផ្លាស់ប្ដូរដែលអាចកើតឡើងនៅក្នុងលំនាំនៃចំណាកស្រុករបស់ជនចំណាកស្រុកកម្ពុជា និងផលប៉ះពាល់លើប្រទេសថៃ និងប្រទេសកម្ពុជា, ឆ្នាំ២០១៩ ទំ. ៤២, សូមមើល ទំ. ៤ ផងដែរ។

[545] Abby Seiff និង Sokummono Khan, កម្ចីខ្នាតតូចនៅកម្ពុជាបានបង្កភាពលិចលង់ចំពោះជនក្រីក្រ និងគាំទ្រអ្នកមាន, *The Dial*, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣, https://bit.ly/4hwQizR។ របាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយនាពេលថ្មីៗនេះបានគូសបញ្ជាក់ថា ពលករចំណាកស្រុកកម្ពុជាដែលត្រឡប់មកពីប្រទេសថៃវិញ កំពុងប្រឈមមុខនឹងហានិភ័យបំណុលកាន់តែខ្ពស់ ដោយសារការបាត់បង់ការងារដែលផ្សារភ្ជាប់ទៅនឹងសម្ពាធសេដ្ឋកិច្ចនៅក្នុងតំបន់ រួមទាំងភាពតានតឹងនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃផងដែរ។ សូមមើល៖ កាសែតខ្មែរថាមស៍ តើកម្ពុជាអាចឆ្លងកាត់ពន្ធគយ ភាពតានតឹងនៅតាមព្រំដែន និងការកើនឡើងនៃបំណុលបានដែរឬទេ ខែកញ្ញា ឆ្នាំ ២០២៥ https://bit.ly/4nxa0PJ; The Guardian, 'ពេលនេះ មិនមានការងារធ្វើទេ មានតែបំណុល'៖ កម្មករកាត់ដេរកម្ពុជាប្រឈមមុខនឹងអនាគតមិនប្រាកដប្រជា នៅខណៈដែលពន្ធគយរបស់សហរដ្ឋអាមេរិកជិតមកដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ https://bit.ly/46JUEQN; កាសែតខ្មែរថាមស៍ នាយករដ្ឋមន្ត្រីជម្រុញឱ្យធនាគារ និង MFIs បន្ធូរបន្ថយបន្ទុកបំណុលរបស់កម្មករដែលវិលត្រឡប់មកវិញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ https://bit.ly/46JUEQN; https://bit.ly/3IqeFUE។

- ដើមបណ្តឹងម្នាក់ ដែលបានទទួលយកប្រាក់កម្ចីប្រមាណ ៨.៥០០ ដុល្លារអាមេរិក នៅចន្លោះឆ្នាំ ២០១៦ និង ឆ្នាំ២០២៤ បានរាយការណ៍ថា ប្រាក់កម្ចីបន្តបន្ទាប់គ្នាទាំងនេះ និងការជំពាក់បំណុល របស់គាត់បាននាំឱ្យមានការលក់ដី សម្ភារៈធ្វើកសិកម្ម និងផ្ទះរបស់គាត់ ហើយវាក៏បានរួមចំណែក ដល់ការលែងលះគ្នារបស់គាត់ និងការឈប់រៀនរបស់កូនអាយុ ១៥ ឆ្នាំរបស់គាត់ ដើម្បីធ្វើចំណាក ស្រុក និងធ្វើការនៅក្នុងរោងចក្រសម្លូតស្វាយនៅជិតព្រំដែនថៃ ដើម្បីសងបំណុលផងដែរ។
- ដើមបណ្តឹងម្នាក់ទៀត ដែលប្រាក់កម្ចីរបស់គាត់ពីអតិថិជន និងអតិថិជនបន្តរបស់ IFC បានកើនដល់ ២៧.១៧០ ដុល្លារអាមេរិក នៅចន្លោះឆ្នាំ២០១៦ និង ឆ្នាំ២០២៤ និងបានពឹងផ្អែកលើការធ្វើស្រែចម្ការ ជាប្រភពប្រាក់ចំណូលចម្បងរបស់គាត់ បានលក់ដីរបស់គាត់ដើម្បីសងបំណុលអ្នកផ្តល់ប្រាក់កម្ចីក្រៅ ប្រព័ន្ធ ដែលគាត់បានខ្ចីដើម្បីសងប្រាក់កម្ចីមួយក្នុងចំណោមប្រាក់កម្ចីនានារបស់គាត់។ ដើម្បីជួយសង បំណុល ប្តីរបស់គាត់បានធ្វើចំណាកស្រុកទៅធ្វើការជាកម្មករសំណង់ ក្រោយមក កូនស្រីអាយុ ១៤ ឆ្នាំ របស់គាត់បានឈប់រៀនត្រឹមថ្នាក់ទីប្រាំមួយ។ បន្ទាប់ពីប្តីរបស់គាត់បានបាត់បង់ការងារនៅដើមឆ្នាំ ២០២៤ ប្រាក់ចំណូលគ្រួសាររបស់ពួកគេបានធ្លាក់ចុះបន្ថែមទៀត ហើយប្រាក់កម្ចីក្រៅប្រព័ន្ធរបស់ គាត់ (ដែលគាត់បានខ្ចីដើម្បីសងប្រាក់កម្ចីក្នុងប្រព័ន្ធប្រចាំខែ) បានកើនឡើង នាំឱ្យមានទំនាស់ក្នុង គ្រួសារជាញឹកញាប់។ នៅត្រឹមបំណាច់ឆ្នាំ២០២៤ គាត់ និងប្តីរបស់គាត់បានបែកបាក់គ្នា។
- ឧទាហរណ៍បន្ថែមទៀតអំពីផលប៉ះពាល់បែបនេះមាននៅក្នុងឧបសម្ព័ន្ធ ដែលរក្សាការសម្ងាត់។

គ្រោះថ្នាក់ដែលដើមបណ្តឹងបានជួបប្រទះពីយន្តការទប់ទល់ ដែលពួកគេបានប្រើប្រាស់ដើម្បីដោះស្រាយបំណុល ច្រើនហួស មានសង្គតិភាពនឹងហានិភ័យសង្គមដែលត្រូវបានទទួលស្គាល់ ពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុនៅ កម្ពុជា។ គិតត្រឹមដើមឆ្នាំ២០១៣ ការសិក្សាមួយដែលរៀបចំដោយ BlueOrchard, Incofin និង OikoCredit បានសម្គាល់ឃើញយន្តការទប់ទល់ទូទៅបំផុត ដែលអ្នកខ្ចីមីក្រូហិរញ្ញវត្ថុបានប្រើប្រាស់។ ការសិក្សានេះបាន រកឃើញថា ការលះបង់ទូទៅបំផុត គឺការកាត់បន្ថយគុណភាព (៤៨%) ឬបរិមាណ (៤៤%) អាហារ និងថា ពួកគេចំនួនជាងមួយភាគបួន (២៧%) បានគ្រប់គ្រងសម្ពាធនៃការសងបំណុលតាមរយៈការបញ្ជូនសមាជិក គ្រួសារទៅស្វែងរកការងារធ្វើនៅក្រៅភូមិ ២៥% បានប្រើប្រាស់លុយសន្សំក្នុងរយៈពេល ១២ ខែ ដើម្បីសង ប្រាក់កម្ចី និង ២៣% បានទទួលយកប្រាក់កម្ចីថ្មី ដើម្បីសងប្រាក់កម្ចីដែលមានស្រាប់។ ការលះបង់ដទៃទៀត របស់អ្នកខ្ចីប្រាក់មួយចំនួនតូច រួមមាន ការធ្វើការលើសពី ១០ ម៉ោងក្នុងមួយថ្ងៃ ការពន្យារពេលចំណាយប្រាក់ លើការព្យាបាលសុខភាព ការលក់ ឬការបញ្ចាំទ្រព្យសកម្ម និងការបញ្ឈប់កូនពីសាលារៀន។[546] វិធានការបែប នេះមានបញ្ជាក់អះអាងពីការសិក្សាក្រោយៗទៀតជាច្រើន[547] និងការស្ទង់មតិ ៦០ ដេស៊ីប៊ែល នាពេលថ្មីៗនេះ

[546] Dannet Liv. ការសិក្សាអំពីកត្តាជម្រុញនៃការជំពាក់បំណុលវ័ណ្ឌក របស់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ ការស៊ើបអង្កេតស៊ីជម្រៅ នៅតំបន់ឆ្អែត, វិទ្យាស្ថានសិក្សាការអភិវឌ្ឍកម្ពុជា, ខែមីនា ឆ្នាំ២០១៣, ទំ. ៥២ (រៀបចំដោយ BlueOrchard, Incofin និង OikoCredit)។ របាយការណ៍នេះក៏លើកឡើងផងដែរថា ក្នុងចំណោមអ្នកខ្ចីទាំងអស់ មានអ្នកខ្ចីតែ ៦% ប៉ុណ្ណោះ ដែលត្រូវបានស្ទង់មតិ ដោយចាត់ទុក ថាការលះបង់របស់ពួកគេមិនអាចទទួលយកបានទេ ពីព្រោះវាប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ។

[547] យោងតាមការសិក្សារបស់មជ្ឈមណ្ឌលមីក្រូហិរញ្ញវត្ថុ (MFC) ឆ្នាំ២០១៧ អ្នកខ្ចី ៤៨ ភាគរយ បានកាត់បន្ថយគុណភាពអាហារនៅ ឆ្នាំ២០១២ ៣៥ ភាគរយនៅឆ្នាំ២០១៧ នៅខណៈពេលដែល ៤៤ ភាគរយបានកាត់បន្ថយបរិមាណអាហារនៅឆ្នាំ២០១២ និង ២៩

នៅឆ្នាំ២០២៤ ដែលអ្នកខ្ចីចំនួន ២៤% ក្នុងចំណោមអ្នកខ្ចីដែលបានចូលរួមនៅក្នុងការស្ទង់មតិនេះ បានកាត់បន្ថយការទទួលទានអាហារដើម្បីសងបំណុល។

ជាសេចក្តីសន្និដ្ឋាន ស៊ីអេអូរកឃើញថា គ្រោះថ្នាក់ដែលដើមបណ្តឹងបានជួបប្រទះតាមរយៈយន្តការទប់ទល់ដែលពួកគេប្រើប្រាស់ ដោយសារការបាត់បង់ ការធ្លាក់ចុះ ឬការផ្លាស់ប្តូរមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ដែលបណ្តាលមកពីបំណុលច្រើនពេក និងសម្ពាធពីការប្រមូលប្រាក់ដោយ BFIs រួមមាន អសន្តិសុខស្បៀង ផលប៉ះពាល់លើសុខភាពផ្លូវកាយ និងផ្លូវចិត្ត ផលប៉ះពាល់លើការអប់រំរបស់កុមារ ដែលទាំងអស់នេះសុទ្ធតែជះឥទ្ធិពលលើគ្រួសារ និងទំនាក់ទំនងគ្រួសារ។ ជាពិសេស ដើមបណ្តឹងប្រាំមួយនាក់បានទទួលរងអសន្តិសុខស្បៀង ដើមបណ្តឹងដប់ពីនាក់ ឬគ្រួសាររបស់ពួកគេបានជួបប្រទះផលប៉ះពាល់លើសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដើមបណ្តឹងដប់នាក់បានបញ្ឈប់កូនៗរបស់ពួកគេពីសាលារៀន ដើម្បីឲ្យពួកគេអាចធ្វើការជួយសងបំណុលបាន ដើមបណ្តឹងពីរគ្រួសារបានលែងលះគ្នា ឬបែកបាក់ស្វាមីភរិយា ដោយសារភាពតានតឹងដែលទាក់ទងនឹងបំណុល ហើយដើមបណ្តឹងប្រាំពីរនាក់បានធ្វើចំណាកស្រុកក្នុងប្រទេស ឬទៅបរទេស ដើម្បីសងបំណុល ដែលបង្កបញ្ហាបន្ថែមទៀតទៅលើគ្រួសាររបស់ពួកគេ ដោយសារការបែកចេញពីគ្រួសារ ចំណាយបន្ថែម និងក្នុងករណីមួយចំនួន លក្ខខណ្ឌការងារគ្មានសុវត្ថិភាព និងអស្ថិរភាព។

## ៥.៣ ផលប៉ះពាល់លើជនជាតិដើមភាគតិច

ដើមបណ្តឹងប្រាំពីរនាក់នៅក្នុងសំណុំរឿងនេះ បានកំណត់អត្តសញ្ញាណជាជនជាតិគ្រឹង ជាជនជាតិដើមភាគតិចដែលត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលនៅកម្ពុជា។ ពួកគេចោទប្រកាន់ថា បន្ថែមលើគ្រោះថ្នាក់នៅក្នុងផ្នែក ៥.២ ខាងលើទៀតនោះ គ្រឹះស្ថានហិរញ្ញវត្ថុដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះបានទទួលយក*ប្លង់ទន់*នៃដីជនជាតិដើមភាគតិច (IP) ជាវត្ថុបញ្ចាំ ហើយក្រោយមក បានបង្ខំពួកគេឱ្យលក់ដីផ្ទាល់ខ្លួនរបស់ពួកគេដែលស្ថិតនៅក្នុងដីសហគមន៍នេះ។ ពេលខ្លះ ដីត្រូវបានលក់ទៅឱ្យអ្នកដែលមិនមែនជាសមាជិកសហគមន៍ ដែលរំលោភលើសិទ្ធិ វប្បធម៌ ប្រពៃណី និងជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច។

ដើមបណ្តឹងជា IP ទាំងប្រាំពីរនាក់ នៅក្នុងសំណុំរឿងនេះ បានលក់ដីមួយកន្លែង ដែលត្រួតស៊ីគ្នានឹង ICLTs ដើម្បីសងបំណុលដោយផ្ទាល់ ឬដោយប្រយោល ទៅអតិថិជន និងអតិថិជនបន្តរបស់ IFC។ ពួកគេពីរនាក់

---

ភាគរយនៅឆ្នាំ២០១៧។ របាយការណ៍ Bliss ឆ្នាំ២០២២ បានរកឃើញថា ៣៦,៦ ភាគរយបានរិតត្បឹតការប្រើប្រាស់របស់ពួកគេ (ជាពិសេស ការទិញចំណីអាហារ) ដើម្បីសងបំណុល។ មជ្ឈមណ្ឌលមីក្រូហិរញ្ញវត្ថុ (MFC), ផលរបរល្អ, CBC, ការសិក្សាអំពីការជំពាក់បំណុលវ័ណ្ឌក នៅកម្ពុជា II៖ របាយការណ៍ចុងក្រោយ ខែតុលា ឆ្នាំ២០១៧, ទំ. ៤៩-៥០។ របាយការណ៍ Bliss, ទំ. ៤៥ និង ៧៦។ សូមមើល Green, Nathan W., Bylander, Maryann, "អំណាចរបស់មីក្រូហិរញ្ញវត្ថុក្នុងការផាត់ចេញ៖ ការជំពាក់បំណុលវ័ណ្ឌក និងការដកហូតកម្មសិទ្ធិដីធ្លីនៅកម្ពុជា", *សង្គមវិទ្យានៃការអភិវឌ្ឍ*, លេខ ៧.២, ឆ្នាំ២០២១, ទំ. ២០២ និង ២១១ (ទៅហៅថា Green, Bylander, ២០២១); នៅឆ្នាំ២០២៣ អង្គការលីកាដូ និងអង្គការសមធម៌កម្ពុជាបានបញ្ចេញរបាយការណ៍មួយ ដែលផ្អែកលើការស្ទង់មតិប្រជាជន ៧១៧ គ្រួសារនៅខេត្តកំពង់ស្ពឺ ដែលមានចម្ងាយប្រហែល ៥០ គីឡូម៉ែត្រពីរាជធានីភ្នំពេញ ការស្ទង់មតិនេះបានរកឃើញថា "ការរីករាលដាលនៃការជំពាក់បំណុលវ័ណ្ឌក បាននាំឱ្យមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរជាច្រើន" ការសិក្សានេះបង្ហាញថា គ្រួសារ ៦,១% បានលក់ដីដើម្បីសងបំណុល នៅខណៈពេលដែលគ្រួសារ ប្រហែល ៣% បានឱ្យកូនឈប់រៀនដោយសារប្រាក់កម្ចីជាពិសេសដែលជាញឹកញាប់ ដើម្បីឱ្យពួកគេចាប់ផ្តើមធ្វើការដើម្បីសងបំណុល" អង្គការលីកាដូ អង្គការសមធម៌កម្ពុជា, ការគំរាមកំហែងពីបំណុល, ការសិក្សាបែបបរិមាណវិស័យអំពីអ្នកខ្ចីប្រាក់កម្ចីខ្នាតមីក្រូនៅខេត្តកំពង់ស្ពឺ ប្រទេសកម្ពុជា, ឆ្នាំ២០២៣, https://bit.ly/41MHhgb (តទៅហៅថា អង្គការលីកាដូ, ឆ្នាំ២០២៣); Phasy Res, មីក្រូហិរញ្ញវត្ថុនៅពេលមានជំងឺកូវីដ ១៩, កិច្ចការពារអ្នកប្រើប្រាស់ និងដំណើរការរៀបចំកម្ចីឡើងវិញនៅកម្ពុជា, ឆ្នាំ២០២១ (តទៅហៅថា Res, ២០២១), https://bit.ly/4iLFoap, បានកត់សម្គាល់ថា "ការកាត់បន្ថយការទទួលទានអាហាររបស់គ្រួសារ" គឺជាយុទ្ធសាស្រ្តចម្បង ដែលគ្រួសារមានវិបត្តិបំណុលប្រើប្រាស់ ដើម្បីសងប្រាក់កម្ចីរបស់ពួកគេ។

បានលក់ដីនោះទៅឱ្យអ្នកដែលមិនមែនជាសមាជិកសហគមន៍ ដោយមិនមានការយល់ព្រមពីសហគមន៍នោះទេ។ ដូចបានពិពណ៌នាខាងលើ (ផ្នែក ៤.២.២) ការពឹងផ្អែកខ្លាំងរបស់អ្នកផ្តល់ប្រាក់កម្ចីលើវត្ថុបញ្ចាំជាដី និងកង្វះផលិតផលដែលមិនត្រូវការវត្ថុបញ្ចាំនោះ អាចនាំឱ្យមានការបាត់បង់ដីរបស់ជនជាតិដើមភាគតិច ប៉ះពាល់ដល់ដំណើរការ ICLTs និងកម្មសិទ្ធិដីសមូហភាពតាមបែបប្រពៃណីរបស់សហគមន៍ IP ដែលរួមចំណែកដល់ជម្លោះនៅក្នុងសហគមន៍ និងផលប៉ះពាល់អវិជ្ជមានលើការអនុវត្តផ្នែកវប្បធម៌ ដោយមានសារៈសំខាន់ចំពោះសហគមន៍ជនជាតិដើមភាគតិច។ ជនជាតិដើមភាគតិចនៅកម្ពុជាងាយរងគ្រោះជាពិសេស ចំពោះការបាត់បង់កម្មសិទ្ធិដីធ្លី ដោយសារមុខរបរចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើដី។[548] បន្ថែមពីលើផលប៉ះពាល់លើមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ (សូមមើលផ្នែក ៥.១) ទៀតនោះ ការបាត់បង់ដីរបស់ជនជាតិដើមភាគតិចមិនត្រឹមតែមានគ្រោះថ្នាក់ចំពោះដើមបណ្តឹងដែលជា IP ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះសហគមន៍ទាំងមូលផងដែរ ដោយពួកគេបាត់បង់ដីសមូហភាពមួយផ្នែក ដែលផ្សារភ្ជាប់ទៅនឹងអត្តសញ្ញាណ វប្បធម៌ និងការទទួលបានធនធានធម្មជាតិ (សូមមើលផ្នែក ៤.២.២)។[549]

លើសពីនេះទៀត ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍នៅប៉ែកឦសាននៃប្រទេសជាទីកន្លែងដែលដើមបណ្តឹងជាជនជាតិដើមភាគតិចរស់នៅ ការបាត់បង់ដីអាចផ្លាស់ប្តូរការប្រតិបត្តិវប្បធម៌ប្រពៃណី ដែលម្តាយផ្ទេរទ្រព្យសម្បត្តិទៅកូនស្រី និងការដែលកូនស្រីបន្តរស់នៅក្នុងភូមិជាមួយម្តាយពួកគេ ដែលតាមរយៈការប្រតិបត្តិបែបនេះ ទ្រព្យសំខាន់ៗ ដូចជា ដី ត្រូវបានផ្ទេរពីម្តាយទៅឱ្យកូនស្រី ហើយកូនស្រីនៅតែបន្តរស់នៅក្នុងភូមិជាមួយម្តាយពួកគេ ដោយទង្វើបែបនេះផ្តល់ជូននូវទម្រង់មួយនៃការការពារផ្នែកសេដ្ឋកិច្ច និងសុវត្ថិភាពផ្ទាល់ខ្លួនសម្រាប់ស្ត្រី។[550] ស៊ីអេអូកត់សម្គាល់បន្ថែមទៀតថា ចំពោះសហគមន៍ជនជាតិដើមភាគតិចមួយចំនួននៅកម្ពុជា រួមទាំងសហគមន៍តំណាងនៅក្នុងសំណុំរឿងនេះដែរ ដី និងទេសភាព គឺជាវិធីនៃការចងចាំរួមគ្នា ដែលបង្កើតជាអត្តសញ្ញាណ ប្រវត្តិសាស្ត្រ និងបេតិកភណ្ឌវប្បធម៌របស់ពួកគេ។[551] ចំពោះសហគមន៍ទាំងនោះ បន្ថែមពីលើការរំលោភលើសិទ្ធិជនជាតិដើមភាគតិចទៀតនោះ ការលក់ដីទៅឱ្យអ្នកដែលមិនមែនជាសមាជិកសហគមន៍ក៏អាចនាំឱ្យបាត់បង់អនុស្សាវរីយ៍ អត្តសញ្ញាណ និងបេតិកភណ្ឌវប្បធម៌រួមផងដែរ។

---

548 របាយការណ៍ Bliss ឆ្នាំ២០២២

549 នៅឆ្នាំ២០១៨ UN OHCHR បានគូសបញ្ជាក់ថា ការការពារសិទ្ធិទទួលបានដី និងធនធាន គឺជាមូលដ្ឋានគ្រឹះនៃសុខុមាលភាពរយៈពេលវែងរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា និងចាំបាច់ចំពោះការមានវត្តមានរបស់ពួកគេក្នុងនាមជាប្រជាជនដែលមានអត្តសញ្ញាណដោយឡែក។ សូមមើល៖ UN OHCHR, ការវាយតម្លៃលើឱកាសទទួលបានឥណទានសម្រាប់សហគមន៍ជនជាតិដើមនៅកម្ពុជា ដែលកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ, ខែតុលា ឆ្នាំ២០១៨, ទំ. https://bit.ly/4bShl1P។ ស្របជាមួយគោលការណ៍ទាំងនេះ ក្រុមធនាគារពិភពលោកគាំទ្រដល់គម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច (LASED) ដែលមានបំណងពង្រឹងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្នសម្រាប់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ជនបទនៅកម្ពុជា។ សូមមើល៖ ក្រុមធនាគារពិភពលោក, គម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច III, គម្រោងលេខ P១៧១៣៣១ https://bit.ly/43CGnoC។

550 Res, មីក្រូហិរញ្ញវត្ថុនៅក្នុងព្រំដែនព្រៃឈើ, ឆ្នាំ២០២៤, ទំ. ៣៩, ៥៣។ Salemink, Oscar. ឆ្នាំ១៩៩៩. 'លើសពីការសមគំនិត និងកង្វះបទពិសោធន៍៖ ការកំណត់បរិបទជាតិពន្ធុសាស្ត្រនៃប្រជាជននៅតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម ឆ្នាំ១៨៥០-១៩៩០'. និក្ខេបបទថ្នាក់បណ្ឌិត ផ្នែកប្រវត្តិសាស្ត្រ. សាកលវិទ្យាល័យ Vrijdag ប្រទេសហូឡង់, ទំ. ១៣៦-១៣៨; Salemink, Oscar. ឆ្នាំ១៩៩៩. 'លើសពីការសមគំនិត និងកង្វះបទពិសោធន៍៖ ការកំណត់បរិបទជាតិពន្ធុសាស្ត្រនៃប្រជាជននៅតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម ឆ្នាំ១៨៥០-១៩៩០'. និក្ខេបបទថ្នាក់បណ្ឌិត. សាកលវិទ្យាល័យ Vrijdag. ប្រទេសហូឡង់, ទំ. ១៣៩

551 J. Padwe, *ព្រៃឈើដែលរងការរំខាន, ការចងចាំដែលស្ថិតនៅរាយប៉ាយ, ជនជាតិចារ៉ាយ និងជនជាតិដទៃទៀតដែលរស់នៅតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា* សារព័ត៌មាននៃសាកលវិទ្យាល័យវ៉ាស៊ីងតោន ឆ្នាំ២០២០

ផលប៉ះពាល់ទាំងនេះទៅលើដីជនជាតិដើមភាគតិចក៏បង្កឱ្យមានជម្លោះផ្ទៃក្នុង និងការបែងចែកនៅក្នុងសហគមន៍ផងដែរ។

ដើមបណ្តឹងម្នាក់ ដែលបានលក់ដីនៅក្នុង ICLTs របស់សហគមន៍គាត់ ដើម្បីសងបំណុលទៅអតិថិជនបន្តរបស់ IFC ចំនួនពីរ បានបង្ហាញថា មូលហេតុមួយក្នុងចំណោមមូលហេតុនានា ដែលគ្រួសាររបស់គាត់បានចាកចេញពីសហគមន៍របស់ពួកគេគឺ ដើម្បីជៀសវាងជម្លោះជាមួយប្រធាន ICLTs ដែលចាត់ទុកថា ការលក់នេះខុសច្បាប់។ ដើមបណ្តឹងជាជនជាតិដើមភាគតិចម្នាក់ទៀតបានចែករំលែកថា ចំណាកស្រុកដោយសារបំណុលបានរារាំងគាត់ពីការនិយាយភាសារបស់គាត់ និងការចូលរួមនៅក្នុងការសែនថ្វាយ និងពិធីតាមបែបប្រពៃណីដែលបំបែកគាត់ចេញពីសហគមន៍របស់គាត់ និងធ្វើឱ្យគាត់មានអារម្មណ៍ឯកោ និងដាច់ទំនាក់ទំនងជាមួយដូនតារបស់គាត់។

ស្របជាមួយគ្រោះថ្នាក់ទាំងនេះដែលដើមបណ្តឹងបានជួបប្រទះ អង្គការសង្គមស៊ីវិលមួយបានរាយការណ៍ថា សហគមន៍ជនជាតិដើមភាគតិចចំនួន ១៩ ក្នុងចំណោម ៤៩ សហគមន៍ ដែលបានដាក់ពាក្យស្នើសុំ ICLTs បានស្នើសុំដកខ្លួនពីដំណើរការនេះ ដោយសារសមាជិករបស់សហគមន៍ទាំងនេះមានបំណងចង់កាន់កាប់ដីជាលក្ខណៈបុគ្គល ដើម្បីអាចលក់ និងប្រើប្រាស់ជាវត្ថុបញ្ចាំសម្រាប់កម្ចី។[552] របាយការណ៍មួយ នៅឆ្នាំ ២០២៤ បានរកឃើញថា ប្រជាជន ២០ គ្រួសារ ក្នុងចំណោម ៩៣ គ្រួសារនៅតំបន់ ICLT មួយ បានលក់ដីទៅឱ្យសមាជិកសហគមន៍ដទៃទៀត ដើម្បីបំពេញកាតព្វកិច្ចបំណុល។[553] ប្រាក់កម្ចីដោយមានវត្ថុបញ្ចាំ បានធ្វើឱ្យសហគមន៍ជនជាតិដើមភាគតិចជាច្រើននៅក្នុងតំបន់ដែលទទួលស្គាល់ ICLT ងាកទៅកាប់ព្រៃឈើដើម្បីទទួលបានដីកាន់តែច្រើន ដើម្បីសងប្រាក់កម្ចី ដែលបង្កើតផលប៉ះពាល់ដល់បរិស្ថានបន្ថែមទៀត និងមិនអាចព្យាករណ៍ទុកមុនបាន។[554]

ដោយសារប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច (ICLTs) ត្រូវបានបង្កើតឡើង ដើម្បី "ការពារកម្មសិទ្ធិជាសមូហភាព" និង "ថែរក្សាអត្តសញ្ញាណ វប្បធម៌ [...] ទំនៀមទម្លាប់ និងប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗ" ស៊ីអេអូយល់ថា ការលក់ដីសហគមន៍ទៅឱ្យអ្នកដែលមិនមែនជាសមាជិកសហគមន៍ដោយគ្មានការយល់ព្រមពីសហគមន៍ធ្វើឱ្យខូចគោលបំណងទាំងនេះ និងប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិចកាន់តែទូលំទូលាយ។[555]

---

552 កិច្ចប្រជុំពិគ្រោះយោបល់ជាមួយ CSOs នៅខេត្តរតនគីរី នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤

553 Res, ឆ្នាំ២០២៤, ទំ. ៤៣, ៤៤, ៤៨

554 De Lange, Emiel, Raj, Sushil Raj និង Yun Mane, សិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច គឺជាគន្លឹះនៃការអភិរក្សនៅកម្ពុជា (សេចក្តីអធិប្បាយ), *Mongabay*, ខែធ្នូ ឆ្នាំ២០២៣, https://bit.ly/4kRGaob។

555 អនុក្រឹត្យស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច លេខ ៨៣ អនក្រ.បក. ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ https://bit.ly/3IrHZK9 មាត្រា ២។ នៅឆ្នាំ២០១៨ UN OHCHR បានគូសបញ្ជាក់ថា ការការពារសិទ្ធិទទួលបានដី និងធនធាន គឺជាមូលដ្ឋានគ្រឹះនៃសុខុមាលភាពរយៈពេលវែងរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា និងចាំបាច់ចំពោះការមានវត្តមានរបស់ពួកគេក្នុងនាមជាប្រជាជនដែលមានអត្តសញ្ញាណដោយឡែក។ សូមមើល៖ UN OHCHR, ការវាយតម្លៃលើឱកាសទទួលបានឥណទានសម្រាប់សហគមន៍ជនជាតិដើមនៅកម្ពុជា ដែលកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាព សហគមន៍ជនជាតិដើមភាគតិចនៅ

ជាការសន្និដ្ឋាន ស៊ីអេអូរកឃើញថា ដើមបណ្តឹងជាជនជាតិដើមភាគតិចទាំងប្រាំពីរនាក់ បានទទួលរងគ្រោះថ្នាក់តាមរយៈការបាត់បង់ដីសហគមន៍របស់ពួកគេ។ នៅពីរករណី ការលក់ដីសហគមន៍ទៅឲ្យអ្នកដែលមិនមែនជាសមាជិកសហគមន៍ ដោយគ្មានការយល់ព្រមពីសហគមន៍ បានប៉ះពាល់ដល់សហគមន៍របស់ពួកគេ រួមជាមួយការចង្អុលបង្ហាញពីគ្រោះថ្នាក់ជាបន្តបន្ទាប់ និងគ្រោះថ្នាក់ដែលអាចកើតឡើងចំពោះអត្តសញ្ញាណ និងវប្បធម៌របស់ពួកគេ។

## ៥.៤ ភាពភ័យខ្លាច និងហេតុការណ៍នៃការគំរាមកំហែង និងការសងសឹក

ផ្អែកលើការស៊ើបអង្កេតរបស់ខ្លួន ស៊ីអេអូកត់សម្គាល់អំពីវត្តមាននៃភាពភ័យខ្លាចគួរឱ្យកត់សម្គាល់ ដែលប៉ះពាល់ដល់អាកប្បកិរិយារបស់អ្នកខ្ចី ពាក់ព័ន្ធនឹងការសងបំណុលនៅកម្ពុជា។ ភាពភ័យខ្លាចនេះគឺជាភស្តុតាងនៅក្នុងរបាយការណ៍ដែលផ្តល់ជូនស៊ីអេអូដោយដើមបណ្តឹងបីនាក់ ដែលមានភាពស្ទាក់ស្ទើរក្នុងការស្នើសុំការរៀបចំកម្ចីឡើងវិញ ឬបង្ហាញការលំបាកផ្នែកហិរញ្ញវត្ថុរបស់ពួកគេជាមួយ BFIs ឬប្រើយន្តការទប់ទល់ដែលមានគ្រោះថ្នាក់ ដូចបានពិពណ៌នាខាងលើ។ ភាពភ័យខ្លាចនេះត្រូវតែបានយកមកពិចារណានៅក្នុងបរិបទនៃភាពងាយរងគ្រោះជាក់លាក់របស់ប្រជាជនគោលដៅ ដែលពួកគេភាគច្រើនមានចំណេះដឹងតិចតួចអំពីសិទ្ធិរបស់ពួកគេ និងមានការយល់ដឹងតិចតួចអំពីប្រព័ន្ធច្បាប់ និងហិរញ្ញវត្ថុ។ ដើមបណ្តឹងភាគច្រើនមានភាពភ័យខ្លាចខ្លាំងចំពោះវិធានការជាសក្តានុពល ដែលអ្នកផ្តល់ប្រាក់កម្ចី រួមទាំងអតិថិជន និងអតិថិជនបន្តរបស់ IFC អាចអនុវត្តក្នុងករណីដែលពួកគេមិនបំពេញកាតព្វកិច្ច។ ភាពភ័យខ្លាចនេះមួយផ្នែកកើតចេញពីអន្តរកម្មជាមួយមន្ត្រីឥណទានដោយផ្ទាល់ និងសម្ពាធដែលពួកគេរាយការណ៍ថា បានទទួលពីមន្ត្រីឥណទានទាំងនោះ។ ភាពភ័យខ្លាចនេះមួយផ្នែកទៀតកើតចេញពីការសង្កេតរបស់ដើមបណ្តឹងអំពីរបៀបដែលគ្រួសារដទៃទៀតបានបង្ហាញពីការលំបាកក្នុងការសងប្រាក់កម្ចីទៅកាន់អ្នកផ្តល់ប្រាក់កម្ចី បានទទួលរងសម្ពាធ និងការបៀតបៀន។

លើកលែងតែដើមបណ្តឹងម្នាក់ ដើមបណ្តឹងគ្រប់រូបបានរាយការណ៍ពីការទទួលរងការគំរាមកំហែងពីអតិថិជន និងអតិថិជនបន្តរបស់ IFC រួមជាមួយវិធានការនានា ដូចជា ការនាំទៅជួបអាជ្ញាធរមូលដ្ឋាន នគរបាល ឬតុលាការ ដោយមិនពន្យល់ថាតើការធ្វើបែបនេះមានអត្ថន័យយ៉ាងដូចម្តេចនោះទេ ឬការគំរាមរឹបអូសដី ឬផ្ទះ និងការលក់ក្រោមតម្លៃទីផ្សារ។ ទោះបីជាយ៉ាងណាក៏ដោយ ដើមបណ្តឹងតែម្នាក់ ដែលមិនបានរាយការណ៍ពីការគំរាមកំហែងពីអតិថិជន ឬអតិថិជនបន្តរបស់ IFC បានបង្ហាញភាពភ័យខ្លាចថា ទ្រព្យសម្បត្តិរបស់គាត់អាចត្រូវគេរឹបអូស ដោយសារគាត់បានសង្កេតឃើញអ្នកជិតខាងរបស់គាត់លក់ដីដើម្បីសងបំណុល និងបានឃើញមន្ត្រីទាមទារឱ្យអ្នកខ្ចីលក់ទ្រព្យសម្បត្តិរបស់ពួកគេ ដើម្បីសងប្រាក់កម្ចី។ ដើម្បីជៀសវាងបញ្ហានេះ គាត់បានជ្រើសរើសខ្ចីប្រាក់កម្ចីបន្ថែម ដើម្បីសងបំណុលរបស់គាត់ឱ្យបានទាន់ពេលវេលា ដោយគាត់ពឹងផ្អែកលើប្រាក់ចំណូលរបស់កូនៗគាត់។ ថ្វីបើបែបនេះក្តី គាត់មានការលំបាកខ្លាំងក្នុងការសងបំណុលចំនួន ៦៣.៧៥០ ដុល្លារអាមេរិក ដែលបានបង្គរក្នុងរយៈពេលជាច្រើនឆ្នាំ តាមរយៈបុនហិរញ្ញប្បទាន និងប្រាក់កម្ចីកាន់តែធំឡើងជាបន្តបន្ទាប់។ ស៊ីអេអូក៏កត់សម្គាល់ផលប៉ះពាលខុសៗគ្នាតាមយេនឌ័រផងដែរ ដោយដើមបណ្តឹងជាស្ត្រីបីនាក់

ខេត្តរតនគីរី មណ្ឌលគីរី និងក្រចេះ, ខែតុលា ឆ្នាំ២០១៨, ទំ. https://bit.ly/4bShl1P។ ស្របជាមួយគោលការណ៍ទាំងនេះ ក្រុមធនាគារពិភពលោកគាំទ្រដល់គម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច (LASED) ដែលមានបំណងពង្រឹងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន តាមរយៈ ICLT សម្រាប់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ជនបទនៅកម្ពុជា។ សូមមើល៖ ក្រុមធនាគារពិភពលោក, គម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច III, គម្រោងលេខ P១៧១៣៣១ https://bit.ly/43CGnoC។

បានរាយការណ៍ពីវត្តមានរបស់មន្ត្រី BFI នៅផ្ទះរបស់ពួកគេក្នុងរយៈពេលវែង នៅពេលដែលពួកគេនៅម្នាក់ឯង។ ទោះបីជាការចុះជួបបែបនេះមិនកំណត់គោលដៅលើស្ត្រីក៏ដោយ ក៏ការដែលមានតែស្ត្រីរាយការណ៍អំពីការអនុវត្តបែបនេះបង្ហាញថា វាអាចមានផលប៉ះពាល់លើពួកគេខុសៗគ្នា ហើយពួកគេយល់ថា ការអនុវត្តបែបនេះគឺជាការគំរាមកំហែងបន្ថែមទៀត។ បញ្ហានេះគូសបញ្ជាក់ពីចន្លោះប្រហោងនៃការត្រួតពិនិត្យរបស់ IFC លើការអនុវត្តការប្រមូលប្រាក់របស់អតិថិជនរបស់ខ្លួន ជាពិសេសកង្វះការការពារ ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងយេនឌ័រ ព្រមទាំងថាមវន្តយេនឌ័ររវាងមន្ត្រីជាបុរស និងអ្នកខ្ចីជាស្ត្រី ដែលអាចបង្កើនភាពភ័យខ្លាច និងសម្ពាធលើអ្នកខ្ចីជាស្ត្រី ឬសមាជិកគ្រួសារអ្នកខ្ចីជាស្ត្រី។

ស៊ីអេអូបានទទួលព័ត៌មានពីដើមបណ្តឹង អង្គការសង្គមស៊ីវិល និងស្ថាប័នសិក្សាសង្គមថា ក្នុងករណីជាច្រើន ភាពភ័យខ្លាចនេះធ្វើឱ្យអ្នកខ្ចីជ្រើសរើសជម្រើសដែលពោរពេញដោយគ្រោះថ្នាក់ ជំនួសឱ្យការទៅជួបអ្នកផ្តល់ប្រាក់កម្ចីរបស់ពួកគេ នៅពេលដែលពួកគេប្រឈមមុខនឹងបញ្ហាប្រឈមក្នុងការសងប្រាក់។ អ្នកខ្ចីមីក្រូហិរញ្ញវត្ថុជាច្រើននៅកម្ពុជា ក៏មិនបានដឹងពីយន្តការបណ្តឹងសារទុក្ខរបស់អ្នកផ្តល់ប្រាក់កម្ចីដែរ។[556] ដើមបណ្តឹងដែលបានព្យាយាមប្រើប្រាស់យន្តការទាំងនេះ បានប្រាប់ស៊ីអេអូថា បទពិសោធន៍នេះ ជាញឹកញាប់ បានក្លាយជាប្រភពនៃការគំរាមកំហែង និងការបៀតបៀនបន្ថែមទៀត ពាក់ព័ន្ធនឹងការលំបាកផ្នែកហិរញ្ញវត្ថុរបស់ពួកគេ។

មានដើមបណ្តឹងតែបីនាក់ប៉ុណ្ណោះ ដែលបានប្រើយន្តការបណ្តឹងសារទុក្ខដែលមាន ហើយពួកគេទាំងអស់គ្នាបានប្រើវាដោយផ្ទាល់ តាមរយៈយន្តការរបស់ NBC ដោយសារកង្វះខាតទំនុកចិត្តចំពោះយន្តការរបស់អតិថិជន និងអតិថិជនបន្តរបស់ IFC ដោយមានការគាំទ្រ និងការណែនាំពីអង្គការមិនមែនរដ្ឋាភិបាល។ ថ្វីបើបែបនេះក្តី ដើមបណ្តឹងពីរនាក់ក្នុងចំណោមពួកគេបានជួបប្រទះការគំរាមកំហែង ឬការស្តីបន្ទោសពីបុគ្គលិក BFI បន្ទាប់ពីពួកគេបានដាក់ពាក្យបណ្តឹង។ ដូចបានពន្យល់នៅក្នុងផ្នែក ៤.២.៣ ក្នុងករណីជាច្រើន ដំណើរការដោះស្រាយបណ្តឹងសារទុក្ខត្រូវបានប្រើប្រាស់ដើម្បីបំភិតបំភ័យ ដាក់សម្ពាធ និងបង្ខូចកេរ្តិ៍ឈ្មោះដើមបណ្តឹង ជំនួសឱ្យការដើរតួជាគន្លងដ៏គួរឲ្យទុកចិត្តសម្រាប់ការដោះស្រាយជម្លោះ។ ឧទាហរណ៍៖

- ដើមបណ្តឹងរបស់ស៊ីអេអូម្នាក់បានដាក់បណ្តឹងតាមរយៈយន្តការបណ្តឹងសារទុក្ខរបស់ធនាគារជាតិនៃកម្ពុជា ដែលគាត់បានអះអាងថា មិនមានការឆ្លើយតបនោះទេ។ ភ្លាមៗបន្ទាប់ពីនោះ មន្ត្រីឥណទានមកពីគ្រឹះស្ថានផ្តល់ប្រាក់កម្ចីមួយ ក្នុងចំណោមគ្រឹះស្ថានផ្តល់ប្រាក់កម្ចីដែលពាក់ព័ន្ធ បានចាប់ផ្តើមចុះទៅជួបគ្រួសាររបស់គាត់ជារៀងរាល់ថ្ងៃ ហើយក្នុងករណីមួយចំនួន នៅផ្ទះគាត់ជាច្រើនម៉ោង ដើម្បីដាក់សម្ពាធលើគាត់ឱ្យដាក់ស្លាកលក់នៅមុខផ្ទះរបស់ពួកគេ។ បន្ទាប់ពីដើមបណ្តឹងបានអនុវត្តតាមដោយដាក់ស្លាក "ផ្ទះសម្រាប់លក់" ហើយនោះ ការចុះទៅជួបនេះនៅតែបន្តកើតឡើង ដោយមន្ត្រីឥណទានបានដាក់សម្ពាធបន្ថែមទៀតឱ្យដើមបណ្តឹងបញ្ឈប់ការសិក្សារបស់កូនគាត់ លក់ដី ព្រមទាំងណែនាំអំពី អ្នកដែលពួកគេគួរតែលក់ដីទៅឲ្យ និងដោយរបៀបណា ដើម្បីសងប្រាក់កម្ចី។ អ្នកខ្ចីបានបង្ហាញថា គាត់បានប្រាប់ពួកគេថា គាត់ចង់រង់ចាំការឆ្លើយតបពី NBC មុនពេលធ្វើសកម្មភាពបន្ថែមទៀត មន្ត្រីឥណទានបានគំរាមគាត់ដោយប្រើនីតិវិធីតុលាការ។
- ភ្លាមៗបន្ទាប់ពីពាក្យបណ្តឹងត្រូវបានដាក់ជូនស៊ីអេអូ មានការរាយការណ៍ទៅកាន់ស៊ីអេអូថា បុគ្គលិក

[556] របាយការណ៍ Bliss បានរកឃើញថា ២៧,៥% នៃអ្នកខ្ចី ៨៦២ នាក់ បានរាយការណ៍ថា ពួកគេមិនទទួលបានព័ត៌មានអំពីយន្តការពាក្យបណ្តឹងឡើយ។ របាយការណ៍ Bliss ទំ. ៦៩។

> ឥណទានមកពីអតិថិជន និងអតិថិជនបន្តមួយចំនួនរបស់ IFC បានចុះទៅកាន់សហគមន៍ ព្យាយាមកំណត់អត្តសញ្ញាណអ្នកដាក់ពាក្យបណ្តឹង។ នៅចុងខែឧសភា ឆ្នាំ២០២២ ដើមបណ្តឹងម្នាក់ នៅក្នុងសំណុំរឿងរបស់ស៊ីអេអូ ដែលគេបានស្គាល់អត្តសញ្ញាណ បានប្រឈមមុខនឹងការចោទប្រកាន់ពីសហគមន៍របស់ពួកគេថា សកម្មភាពរបស់ពួកគេនឹងធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់ភូមិនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ភាពភ័យខ្លាចរបស់អ្នកខ្ចីចំពោះការគំរាមកំហែង និងការសងសឹក មានកាន់តែខ្លាំង ដោយសារបរិបទប្រទេសនៅតាមព្រំដែន ដែលមានការរាយការណ៍អំពីការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌប្រឆាំងនឹងជនដែលបញ្ចេញមតិប្រឆាំងនឹងសកម្មភាពសេដ្ឋកិច្ច ដែលត្រូវបានមើលឃើញថា បង្កគ្រោះថ្នាក់ ឬរំលោភបំពានលើសិទ្ធិសហគមន៍។ មានការរាយការណ៍ថា គោលដៅទាំងនេះ រួមមាន អ្នកការពារសិទ្ធិមនុស្ស អ្នកការពារបរិស្ថាន អ្នកសារព័ត៌មាន អ្នកប្រឆាំងផ្នែកនយោបាយ និងអ្នកដទៃទៀតដែលគេយល់ថាជាគូបដិបក្ខរបស់អាជ្ញាធរ ឬអ្នកមានអំណាច (សូមមើលផ្នែក ៤.២.៣)។ នៅក្នុងបរិបទនេះ នាយកប្រតិបត្តិរបស់ CSO មួយ ដែលតំណាងឱ្យដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ បច្ចុប្បន្ន កំពុងប្រឈមនឹងរឿងក្តីព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទញុះញង់ ទាក់ទងនឹងសកម្មភាពសង្គមរបស់គាត់។[557] រឿងក្តីព្រហ្មទណ្ឌនេះបានដំណើរការទៅមុខ នៅខណៈពេលដែលក្រុមការងារភាពអនុលោមរបស់ស៊ីអេអូកំពុងអនុវត្តការចុះពិនិត្យទីតាំងសម្រាប់ការស៊ើបអង្កេតរបស់ខ្លួន កាលពីនៅខែមីនា ឆ្នាំ២០២៤។

ស៊ីអេអូសន្និដ្ឋានថា ភាពភ័យខ្លាច និងហេតុការណ៍នៃការគំរាមកំហែង និងការសងសឹកពីអ្នកផ្តល់ប្រាក់កម្ចីដែលត្រូវបានរាយការណ៍ដោយដើមបណ្តឹង បង្កើតបានជាគ្រោះថ្នាក់។

### គំហើញទូទៅនៃគ្រោះថ្នាក់

ជាការសន្និដ្ឋាន ស៊ីអេអូរកឃើញថា គ្រោះថ្នាក់ដែលបានពិពណ៌នានៅក្នុងផ្នែកនេះ មានភាពកាន់តែធ្ងន់ធ្ងរឡើង ដោយសារភាពងាយរងគ្រោះជាក់លាក់របស់ដើមបណ្តឹងទាំង ១៨ នាក់ និងគ្រួសាររបស់ពួកគេ ដែលការពឹងផ្អែកលើកសិកម្មខ្នាតតូចសម្រាប់ប្រាក់ចំណូល ឬការចិញ្ចឹមជីវិត អក្ខរកម្មតិចតួច (រួមទាំងផ្នែកច្បាប់ និងហិរញ្ញវត្ថុ) ឧបសគ្គផ្នែកភាសា និងការយល់ដឹងមានកម្រិតអំពីសិទ្ធិរបស់កូនបំណុល បានបង្កើនការប្រឈមនឹងផលប៉ះពាល់អវិជ្ជមាននៃការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់ដែលមានគ្រោះថ្នាក់។ នៅខណៈពេលដែលព័ត៌មានលម្អិតជាក់លាក់អំពីគ្រោះថ្នាក់នីមួយៗ ដែលដើមបណ្តឹងបានរាយការណ៍ទៅកាន់ស៊ីអេអូដោយផ្ទាល់ មិនអាចផ្ទៀងផ្ទាត់ដោយឯករាជ្យនៅគ្រប់ករណីទាំងអស់បាននោះ លក្ខណៈនៃគ្រោះថ្នាក់ទាំងនេះ រួមទាំងការបាត់បង់ដីធ្លី និងទ្រព្យសកម្មដែលមានផលិតភាព អសន្តិសុខស្បៀង ផលប៉ះពាល់អវិជ្ជមានចំពោះសុខភាព ការរំខានដល់ការអប់រំរបស់កុមារ ភាពតានតឹងនៅក្នុងគ្រួសារទាក់ទងនឹងការធ្វើចំណាកស្រុក ការគំរាមកំហែង និងការសងសឹក និងផលប៉ះពាល់លើអត្តសញ្ញាណ និងវប្បធម៌របស់ជនជាតិដើមភាគតិច មានសង្គតិភាពនឹងលំនាំដែលបានចងក្រងជាឯកសារនៅក្នុងការសិក្សាថ្នាក់ជាតិ និងអន្តរជាតិ ក៏ដូចជារបាយការណ៍របស់សង្គមស៊ីវិល ស្ថាប័នអង្គការសហប្រជាជាតិ និងការស្រាវជ្រាវរបស់ស្ថាប័នសិក្សាលើការជំពាក់បំណុលវ័ណ្ឌក នៅកម្ពុជា។

[557] សេចក្តីថ្លែងការណ៍របស់ CSO ដែលទាមទារឱ្យមានវិធានការពីធនាគារពិភពលោកចំពោះការសងសឹកនៅកម្ពុជា, ឆ្នាំ២០២៤, https://bit.ly/4iLONPO; មជ្ឈមណ្ឌលធនធានធុរកិច្ច និងសិទ្ធិមនុស្ស, អៀង វុទ្ធី – អង្គការសមធម៌កម្ពុជា, https://bit.ly/4hNUU4K

## គ្រោះថ្នាក់ទាក់ទងនឹងបដិលោមភាពរបស់ IFC តាមគោលនយោបាយនិរន្តរភាពរបស់ខ្លួន

គ្រោះថ្នាក់ដែលបានចងក្រងជាឯកសារ នៅក្នុងសំណុំរឿងនេះ ទាក់ទងនឹងបដិលោមភាពរបស់ IFC តាមគោលនយោបាយនិរន្តរភាពរបស់ខ្លួន ជាពិសេសកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាថា អតិថិជនកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម (E&S) ស្របតាមស្តង់ដារសមិទ្ធកម្ម ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) និងច្បាប់ជាតិ។ កាតព្វកិច្ចទាំងនេះ រួមមាន ការពិចារណាជាពិសេសចំពោះកាលៈទេសៈ និងតម្រូវការរបស់ជនងាយរងគ្រោះ រួមទាំងកាលៈទេសៈ និងតម្រូវការរបស់ដើមបណ្តឹង ដែលមានប្រាក់ចំណូលទាប មានអក្ខរកម្មតិចតួច (រួមទាំងផ្នែកច្បាប់ និងហិរញ្ញវត្ថុ) ឧបសគ្គផ្នែកភាសា ឬការយល់ដឹងមានកម្រិតអំពីសិទ្ធិរបស់ពួកគេ។ [558] កាតព្វកិច្ចទាំងនេះក៏រួមបញ្ចូលការធានាថា ក្រុមប្រជាជនទាំងនេះមិនរងផលប៉ះពាល់មិនសមាមាត្រពីគម្រោងនោះទេ។

គ្រោះថ្នាក់ដែលដើមបណ្តឹងបានជួបប្រទះ រួមមាន ការបាត់បង់មុខរបរចិញ្ចឹមជីវិត ភាពក្រីក្រ អសន្តិសុខស្បៀង ផលប៉ះពាល់អវិជ្ជមានចំពោះសុខភាព ការរំខានដល់ការអប់រំរបស់កុមារ ការធ្វើចំណាកស្រុកដោយសារបំណុល ការគំរាមកំហែង និងការសងសឹក និងគ្រោះថ្នាក់ផ្នែកវប្បធម៌ និងសង្គមចំពោះជនជាតិដើមភាគតិច គឺជាប្រភេទផលប៉ះពាល់អវិជ្ជមានដែលគោលនយោបាយនិរន្តរភាព និងស្តង់ដារសមិទ្ធកម្មរបស់ IFC មានបំណងទប់ស្កាត់ ឬគ្រប់គ្រង។ ស្របតាមគោលនយោបាយនិរន្តរភាព IFC ត្រូវបានតម្រូវឱ្យធានា តាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគ និងការត្រួតពិនិត្យជាបន្តបន្ទាប់ ថា អតិថិជនរបស់ខ្លួនមានប្រព័ន្ធដើម្បីជៀសវាង កាត់បន្ថយជាអប្បបរមា ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើជនដែលងាយរងគ្រោះ។

នៅក្នុងសំណុំរឿងនេះ ស៊ីអេអូបានរកឃើញថា IFC មិនបាន៖

- វាយតម្លៃឱ្យបានគ្រប់គ្រាន់ ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ ឬពិនិត្យតាមដាន ក្នុងអំឡុងពេលត្រួតពិនិត្យការវិនិយោគ ថាតើការអនុវត្តការផ្តល់ប្រាក់កម្ចី និងការប្រមូលប្រាក់របស់អតិថិជន FI និងអតិថិជនបន្ត ស្របតាមលក្ខខណ្ឌតម្រូវនៃ PS1 រួមទាំងស្តង់ដារ GIIP និងច្បាប់ជាតិ[559] សម្រាប់ការគ្រប់គ្រងហានិភ័យចំពោះអ្នកខ្ចីដែលងាយរងគ្រោះ រួមទាំងអ្នកដែលមានអក្ខរកម្មទាប ជំនាញផ្នែកភាសាមានកម្រិត និងការយល់ដឹងមានកម្រិតអំពីសិទ្ធិរបស់ពួកគេ និងស្របតាមលក្ខខណ្ឌតម្រូវនៃ

---

[558] ស្តង់ដារសមិទ្ធកម្មទី១ របស់ IFC (ឆ្នាំ២០១២) កថាខណ្ឌ ៩ ចែងថា៖ ចំណុចស្នូលនៃបេសកកម្មអភិវឌ្ឍន៍របស់ IFC គឺ កិច្ចខិតខំប្រឹងប្រែងអនុវត្តសកម្មភាពវិនិយោគ និងការផ្តល់ប្រឹក្សា ដោយមានបំណង "មិនបង្កគ្រោះថ្នាក់" ដល់មនុស្ស និងបរិស្ថាន និង "ពង្រឹងនិរន្តរភាពនៃប្រតិបត្តិការរបស់វិស័យឯកជន និងទីផ្សារដែលពួកគេធ្វើការ និងសម្រេចបានផលសម្រេចនៃការអភិវឌ្ឍជាវិជ្ជមាន។ IFC ប្តេជ្ញាចិត្តធានាថា សោហ៊ុយលើការអភិវឌ្ឍសេដ្ឋកិច្ចមិនធ្លាក់លើជនក្រីក្រ ឬងាយរងគ្រោះដោយមិនសមាមាត្រនោះទេ ថាបរិស្ថានមិនវិចវិលនៅក្នុងដំណើរការនោះ និងថាធនធានធម្មជាតិកកើតឡើងវិញត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព។

[559] ស្តង់ដារសមិទ្ធកម្មទី១ របស់ IFC (ឆ្នាំ២០១២) *ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម* កថាខណ្ឌ ៤៖ "អតិថិជន ដោយមានការសម្របសម្រួលជាមួយភ្នាក់ងាររដ្ឋាភិបាល និងអាជ្ញាធរដែលទទួលខុសត្រូវដទៃទៀត នឹងអនុវត្តលោមតាមច្បាប់ជាធរមាន រួមទាំងច្បាប់ដែលអនុវត្តកាតព្វកិច្ចរបស់ប្រទេសម្ចាស់ផ្ទះ នៅក្រោមច្បាប់អន្តរជាតិផងដែរ"; កថាខណ្ឌ ៦៖ "ផែនការសកម្មភាពនឹងពិពណ៌នាអំពីសកម្មភាពដែលចាំបាច់ ដើម្បីអនុវត្តសំណុំវិធានការកាត់បន្ថយផ្សេងៗ ឬវិធានការកែតម្រូវ ដែលចាំបាច់ដើម្បីអនុលោមតាមស្តង់ដារសមិទ្ធកម្ម ដូចបានវាស់ស្ទង់ធៀបនឹងលក្ខខណ្ឌតម្រូវនៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP)"; កថាខណ្ឌ ២៤៖ "អតិថិជននឹងបង្កើត និងបន្តដំណើរការកំណត់ហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោង។ ដំណើរការនេះនឹង… ធានាបាននូវភាពអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ទាក់ទងនឹងបញ្ហាបរិស្ថាន និងសង្គម"។

PS7 ដើម្បីជៀសវាង និងគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ដល់ជនជាតិដើមភាគតិចដែរឬទេ។[560]

- ធានាថាអតិថិជន FI មានយន្តការបណ្ដឹងសារទុក្ខដែលមានប្រសិទ្ធភាព មានលក្ខណៈងាយស្រួល និងគួរឱ្យទុកចិត្ត ដែលមិនមានហានិភ័យនៃការសងសឹកនោះទេ។[561]

សរុបមក ភស្តុតាងគាំទ្រដល់ការសម្រេចចិត្តរបស់ស៊ីអេអូថា គ្រោះថ្នាក់ដែលដើមបណ្ដឹងទាំងនេះបានជួបប្រទះរួមជាមួយផលវិបាកដែលលាតសន្ធឹងលើសពីអ្នកខ្ចីម្នាក់ៗ ទៅដល់គ្រួសារ និងសហគមន៍របស់ពួកគេ និងក្នុងករណីជនជាតិដើមភាគតិច ទៅដល់បេតិកភណ្ឌវប្បធម៌ និងសិទ្ធិសមូហភាពរបស់ពួកគេផងដែរ គឺទាក់ទងនឹងបដិលោមភាពរបស់ IFC នៅក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគរបស់ខ្លួន។

[560] ស្តង់ដារសមិទ្ធកម្មទី១ របស់ IFC (ឆ្នាំ២០១២) *ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម* កថាខណ្ឌ ១២៖ "ដំណើរការកំណត់អត្តសញ្ញាណនឹងពិចារណា... បុគ្គល ឬក្រុមដែលអាចរងផលប៉ះពាល់ដោយផ្ទាល់ និងខុសៗគ្នា ឬមិនសមាមាត្រ ដោយគម្រោង ដោយសារស្ថានភាពលំបាក ឬងាយរងគ្រោះរបស់ពួកគេ"។ ស្តង់ដារសមិទ្ធកម្មទី៧ របស់ IFC – *ជនជាតិដើមភាគតិច* កថាខណ្ឌ ១៖ "ជនជាតិដើមភាគតិចងាយរងគ្រោះជាពិសេស ប្រសិនបើដីធ្លី និងធនធានរបស់ពួកគេត្រូវបានផ្លាស់ប្តូរ ទន្ទ្រាន ឬចរិលយ៉ាងខ្លាំង"; កថាខណ្ឌ ១៣៖ "អតិថិជននឹងកំណត់ និងវាយតម្លៃផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលនៃគម្រោង លើស្ថានភាពសង្គម វប្បធម៌ និងសេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច"។

[561] ស្តង់ដារសមិទ្ធកម្មទី១ របស់ IFC (ឆ្នាំ២០១២) កថាខណ្ឌ ២៩៖ "យន្តការបណ្តឹងសារទុក្ខគួរតែត្រូវបានពង្រីកវិសាលភាពទៅកាន់ហានិភ័យ និងផលប៉ះពាល់អវិជ្ជមាននៃគម្រោង និងអាចប្រើប្រាស់បានសម្រាប់គ្រប់ផ្នែកទាំងអស់នៃសហគមន៍ដែលរងផលប៉ះពាល់ រួមទាំងក្រុមងាយរងគ្រោះ និងដោយគ្មានការសងសឹក"។

# ៦. មូលហេតុឫសគល់នៃបដិលោមភាព

## ការប្រើអភិក្រមដែលមិនបានពិចារណាពីហានិភ័យ និងផលប៉ះពាល់សង្គមលើអ្នកទទួលផលគម្រោង

គោលនយោបាយនិរន្តរភាពរបស់ IFC ធ្វើឲ្យស្ថាប័ននេះប្ដេជ្ញាចិត្តសម្រេចឲ្យបាននូវផលសម្រេចនៃការអភិវឌ្ឍជាវិជ្ជមាន ដោយតាមរយៈការត្រួតពិនិត្យភាពត្រឹមត្រូវ ការពិនិត្យតាមដាន និងការត្រួតពិនិត្យការវិនិយោគធានាថា សកម្មភាពដែលខ្លួនគាំទ្រមាននិរន្តរភាពបរិស្ថាន និងសង្គម និងអនុវត្តស្របតាមស្តង់ដារសមិទ្ធកម្ម។ គោលនយោបាយនេះក៏តម្រូវផងដែរថា សោហ៊ុយលើការអភិវឌ្ឍសេដ្ឋកិច្ចមិនធ្លាក់លើជនក្រីក្រ ឬជនងាយរងគ្រោះដោយមិនសមាមាត្រនោះទេ និងអនុវត្តស្តង់ដារសមិទ្ធកម្ម ក្នុងការអនុវត្តតាមការប្ដេជ្ញាចិត្តនេះ។

អភិក្រមរបស់ IFC ក្នុងការកំណត់ហានិភ័យ និងផលប៉ះពាល់ មានចំណុចងងឹងដ៏ធំមួយ៖ ភាពងាយរងគ្រោះរបស់ក្រុមគន្លឹះនៃប្រជាជនដែលរងផលប៉ះពាល់ ដែលជាអ្នកទទួលផល។ នៅក្នុងសំណុំរឿងនេះ បដិលោមភាពរបស់ IFC កើតចេញពីការមិនទទួលស្គាល់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ គ្រួសារ និងសហគមន៍របស់ពួកគេ ដែលរួមមានកសិករ ជនជាតិដើមភាគតិច និងអ្នកដទៃទៀត ដែលភាពងាយរងគ្រោះរបស់ពួកគេត្រូវបានផ្សារភ្ជាប់ទៅនឹងអក្ខរកម្មកម្រិតទាប (រួមទាំង អក្ខរកម្មផ្នែកហិរញ្ញវត្ថុ ផងដែរ) ប្រាក់ចំណូលទាប និងការពឹងផ្អែកលើមុខរបរចិញ្ចឹមជីវិតនៅលើដីធ្លី ជាប្រជាជនរងផលប៉ះពាល់ដែលងាយរងគ្រោះ។

## ការដាច់ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំនៅកម្រិតវិស័យ និងការអនុវត្តនៅកម្រិតគម្រោង

មូលហេតុឫសគល់នៃបដិលោមភាពរបស់ IFC នៅក្នុងសំណុំរឿងនេះ គឺចន្លោះប្រហោងរវាងការចូលរួមយ៉ាងទូលំទូលាយនៅកម្រិតវិស័យ ដើម្បីលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវនៅកម្ពុជា និងការប្រើចំណេះដឹង ស្តង់ដារ និងការអនុវត្ត ដែលមានកម្រិត ចំពោះការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ខ្លួនផ្ទាល់។ នៅម្ខាង IFC បានដើរតួនាទីយ៉ាងសកម្មនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា អស់រយៈពេលជាងពីរទសវត្សរ៍មកហើយ ដោយគាំទ្រគំនិតផ្តួចផ្តើមដោះស្រាយហានិភ័យនៃបំណុលវ័ណ្ឌក និងពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ ឧទាហរណ៍ រួមមាន ការធ្វើការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើតក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា (CBC) កិច្ចសហការរបស់វាជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និង CBC ដើម្បីបង្កើត និងលើកកម្ពស់គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី និងសេវាទីប្រឹក្សា ដើម្បីពង្រឹងក្របខណ្ឌការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុផងដែរ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះឆ្លុះបញ្ចាំងពីការទទួលស្គាល់យ៉ាងច្បាស់អំពីផលប៉ះពាល់អវិជ្ជមាននៃមីក្រូហិរញ្ញវត្ថុដែលអាចកើតឡើង និងការប្តេជ្ញាចិត្តលើកកម្ពស់ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) នៅកម្រិតវិស័យ។ នៅម្ខាងទៀត IFC មិនបានអនុវត្តការយល់ដឹង និងស្តង់ដារ GIIP ទាំងនេះជាប្រព័ន្ធ ចំពោះការត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ខ្លួនផ្ទាល់នោះទេ។ ជាលទ្ធផល ហានិភ័យដែល IFC កំពុងខិតខំកាត់បន្ថយនៅក្នុងវិស័យនេះ ដូចជាបំណុលវ័ណ្ឌក ការបាត់បង់ទ្រព្យសកម្មដែលមានផលិតភាព និងការអនុវត្តការប្រមូលបំណុលដែលមានគ្រោះថ្នាក់ មិនត្រូវបានកំណត់ វាយតម្លៃ ឬដោះស្រាយយ៉ាងជាប់លាប់ នៅក្នុងគម្រោងដែលខ្លួនបានផ្តល់ហិរញ្ញប្បទាននោះទេ។ ចន្លោះប្រហោងរវាងភាពជាអ្នកដឹកនាំនៅកម្រិតវិស័យរបស់ IFC និងការអនុវត្តនៅកម្រិតគម្រោងរបស់ខ្លួន ចង្អុលបង្ហាញពីកង្វះខាតទំនាក់ទំនង និងបានរួមចំណែកដល់ការកើតឡើងជាបន្តបន្ទាប់នៃគ្រោះថ្នាក់សង្គម ក្នុងចំណោមអ្នកខ្ចី នៅក្នុងការវិនិយោគដែលគ្របដណ្តប់ដោយសំណុំរឿងនេះ។

ទោះបីជាកង្វះខាងការតម្រឹមយ៉ាងជាក់ស្តែងនេះបាននាំឱ្យមានបដិលោមភាព ដែលត្រូវបានចងក្រងជាឯកសារនៅក្នុងរបាយការណ៍នេះក្តី វាក៏បង្ហាញបញ្ហាកាន់តែធំមួយទៀតគឺ បញ្ហាប្រឈមជាក់ស្តែងក្នុងការឆ្លើយតប និងកែសម្រួលតាមការប្រែប្រួលនៃព័ត៌មាន និងការយល់ដឹងអំពីផលប៉ះពាល់សង្គមអវិជ្ជមានពីសកម្មភាពមីក្រូហិរញ្ញវត្ថុនៅកម្រិតគម្រោង និងនៅកម្រិតផលបត្រ។ IFC មិនអាចពិចារណា និងឆ្លើយតបជាប្រព័ន្ធចំពោះព័ត៌មានដែលកំពុងលេចឡើង ដែលចង្អុលបង្ហាញពីហានិភ័យសង្គមដ៏គួរឱ្យកត់សម្គាល់ ចំពោះផ្នែកដែលងាយរងគ្រោះរបស់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ និងវិធានការប្រកបដោយប្រសិទ្ធភាពដើម្បីការពារពួកគេ នៅក្នុងគម្រោងរបស់ខ្លួនផ្ទាល់នោះទេ។

លទ្ធផលគឺ ភាពមិនស្របគ្នាជាបន្តបន្ទាប់រវាងចំណេះដឹងដែលកំពុងវិវត្តអំពីផលប៉ះពាល់ និងហានិភ័យសង្គមនៃមីក្រូហិរញ្ញវត្ថុ និង GIIP ដែលពាក់ព័ន្ធ និងវិធីដែល IFC បានអនុវត្តការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែក E&S និងការត្រួតពិនិត្យការវិនិយោគរបស់ខ្លួននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។

# ៧. អនុសាសន៍សម្រាប់ផែនការសកម្មភាពរបស់គណៈគ្រប់គ្រង IFC

គោលនយោបាយស៊ីអេអូចែងថា៖

> *ប្រសិនបើស៊ីអេអូរកឃើញបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ ស៊ីអេអូផ្តល់អនុសាសន៍ដល់ IFC/MIGA ដើម្បីធ្វើការពិចារណា នៅពេលរៀបចំផែនការសកម្មភាពរបស់គណៈគ្រប់គ្រង (MAP)។ អនុសាសន៍នានាអាចពាក់ព័ន្ធនឹងការដោះស្រាយបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធនៅកម្រិតគម្រោង [...] និង/ឬជំហាននានាដែលចាំបាច់ ដើម្បីទប់ស្កាត់បដិលោមភាពនាពេលអនាគត ដែលពាក់ព័ន្ធទៅតាមកាលៈទេសៈនានា។*[562]

អនុវត្តតាមបទប្បញ្ញត្តិនេះ ស៊ីអេអូផ្តល់អនុសាសន៍ដូចខាងក្រោម ដើម្បី៖ (ក) ដោះស្រាយបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ នៅកម្រិតគម្រោង (អនុសាសន៍កម្រិតគម្រោង) និង (ខ) ទប់ស្កាត់បដិលោមភាពរបស់ IFC នាពេលអនាគត (អនុសាសន៍ជាប្រព័ន្ធ)។

*កំណត់សម្គាល់ជាក់លាក់អំពីគំនិតផ្តួចផ្តើមបន្តបន្ទាប់*

ដើម្បីកំណត់បរិបទនៃអនុសាសន៍របស់ខ្លួន ស៊ីអេអូទទួលស្គាល់ថា ចាប់តាំងពីឆ្នាំ២០២៣ មក រដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារនិយ័តកម្ម ធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ សង្គមស៊ីវិល គ្រឹះស្ថានហិរញ្ញវត្ថុពហុភាគី រួមទាំង IFC និងដៃគូអនុវត្តន៍ បានរួមគ្នាស្វែងរកដំណោះស្រាយ ដើម្បីដោះស្រាយកង្វល់កាន់តែច្រើន ពាក់ព័ន្ធនឹងផលប៉ះពាល់សង្គមនៃបំណុលវ័ណ្ឌក។ ក្នុងការផ្តល់អនុសាសន៍កម្រិតគម្រោង ស៊ីអេអូបានពិចារណាលើគំនិតផ្តួចផ្តើមដែលមានស្រាប់ ដូចខាងក្រោម៖

1. នៅខែវិច្ឆិកា ឆ្នាំ២០២៣ ការិយាល័យអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងធនាគារជាតិនៃកម្ពុជា (NBC) បានចាប់ផ្តើមដំណើរការកិច្ចសន្ទនាពហុភាគីពាក់ព័ន្ធ។ ជាផ្នែកមួយនៃកិច្ចសន្ទនានេះ មានការចាត់វិធានការជាច្រើន (សូមមើលព័ត៌មានលម្អិតនៅក្នុង**ឧបសម្ព័ន្ធ ក**)។ ភាពពាក់ព័ន្ធជាពិសេសចំពោះអនុសាសន៍ដែលបានផ្តល់ជូនមានដូចខាងក្រោម គឺថា (i) សមាគមធនាគារនៅកម្ពុជា (ABC) និង CMA បានបង្កើតមជ្ឈមណ្ឌលអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCC) ដែលបានដំណើរការមជ្ឈមណ្ឌលទំនាក់ទំនងតាមទូរសព្ទសម្រាប់អ្នកខ្ចី នៅខែកញ្ញា ឆ្នាំ២០២៤ ដោយមានការគាំទ្រពី IFC និង (ii) IFC និងដៃគូអភិវឌ្ឍន៍ដទៃទៀត[563] គឺជាកិច្ចខិតខំប្រឹងប្រែងឈានមុខគេ ក្នុងការវាយតម្លៃសមិទ្ធលទ្ធភាព

---

[562] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ១១៣. ស្រដៀងគ្នានេះដែរ កថាខណ្ឌ១២០ នៃគោលនយោបាយស៊ីអេអូចែងថា របាយការណ៍ស៊ើបអង្កេតភាពអនុលោមនឹងផ្តល់ "អនុសាសន៍ដល់ IFC/MIGA សម្រាប់ពិចារណា ក្នុងការរៀបចំ MAP ដែលពាក់ព័ន្ធនឹងការដោះស្រាយបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ នៅកម្រិតគម្រោង ឬអនុគម្រោង និង/ឬជំហាននានា ដែលចាំបាច់ ដើម្បីទប់ស្កាត់បដិលោមភាពនាពេលអនាគត ដែលពាក់ព័ន្ធទៅតាមកាលៈទេសៈនានា។"

[563] FMO, គំនិតផ្តួចផ្តើមវិស័យដែលអាចមាន – ប្រទេសកម្ពុជា, https://bit.ly/3R7beCL។ នៅខែធ្នូ ឆ្នាំ២០២២ មានការដាក់ពាក្យបណ្តឹងមួយជាមួយនឹងការិយាល័យទំនាក់ទំនងជាតិប្រទេសហូឡង់ (NCP) ដើម្បីឱ្យមានការអនុវត្តគោលការណ៍ណែនាំរបស់ OECD សម្រាប់សហគ្រាសពហុជាតិសាសន៍ស្តីពី ការអនុវត្តធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ដែលពាក់ព័ន្ធនឹង Oikocredit – ដែលជា

និងការរចនាយន្តការឯករាជ្យសម្រាប់ការប្រឹក្សាយោបល់ និងសន្ទានកម្មបំណុល ដូចជា អ្នកដោះស្រាយវិវាទហិរញ្ញវត្ថុ នៅក្រោម FCC ជាដើម។[564]

2. នៅឆ្នាំ២០២៤ SPTF បានដាក់ឲ្យដំណើរការគម្រោងសាកល្បងមួយ នៅក្នុងភូមិចំនួនបី នៅខេត្តរតនគិរី ដើម្បីពង្រឹងភាពអង់អាចរបស់អ្នកប្រើប្រាស់ សម្រាប់អតិថិជនដែលមានភាពតានតឹងផ្លូវចិត្តដោយសារបំណុល។ គំនិតផ្តួចផ្តើមនេះពាក់ព័ន្ធនឹងការអនុវត្តសេវាប្រឹក្សាយោបល់អំពីបំណុល ក្រោមការដឹកនាំរបស់ "អ្នកប្រឹក្សាយោបល់អំពីបំណុលនៅថ្នាក់ភូមិ" ដែលបានទទួលការបណ្តុះបណ្តាលមកពីសហគមន៍។[565]

3. CMA និង ABC បានដឹកនាំការបណ្តុះបណ្តាលសម្រាប់ CEOs និងម្ចាស់ភាគហ៊ុន FI អំពីតួនាទីនៃអភិបាលកិច្ច និងកិច្ចការពារអតិថិជន។[566] ដោយមានការគាំទ្រពី NBC ពួកគេបានអនុវត្តកម្មវិធីផ្តល់វិញ្ញាបនបត្រសម្រាប់ការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវនៅឆ្នាំ២០២២ សម្រាប់មន្ត្រីឥណទាន និងបុគ្គលិកដទៃទៀតដែលពាក់ព័ន្ធនឹងឥណទាន ដែលផ្តល់ជូនដោយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ។ វិញ្ញាបនបត្រនេះបានក្លាយជាកាតព្វកិច្ចរបស់មន្ត្រីឥណទានដែលជាសមាជិក ABC ចាប់តាំងពីឆ្នាំ២០២៣[567] មក ហើយ CMA បានប្រកាសថា ខ្លួនមានផែនការធ្វើដូចគ្នានេះ ក្នុងឆ្នាំ២០២៥។[568]

---

វិនិយោគិនសកលលើផលជះផ្នែកសង្គម ដែលមានទីស្នាក់ការកណ្តាលទៅប្រទេសហូឡង់ – ពាក់ព័ន្ធនឹងការវិនិយោគរបស់ពួកគេលើវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា។ ដំណើរការដោះស្រាយត្រូវបានបិទបញ្ចប់នៅខែមករា ឆ្នាំ២០២៥ ហើយជាលទ្ធផល Oikocredit បានប្តេជ្ញាចិត្តរៀបចំក្របខណ្ឌមួយសម្រាប់យន្តការសន្ទានកម្មឯករាជ្យមួយ និងមជ្ឈមណ្ឌលសាមគ្គីភាព និងជំនួយ ដែលស្របជាមួយនឹងបទដ្ឋានអន្តរជាតិ រួមទាំងគោលការណ៍មគ្គុទ្ទេសក៍របស់អង្គការសហប្រជាជាតិស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស. សូមមើល៖ OECD Watch, សម្ព័ន្ធកម្ពុជាសម្រាប់ការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្ស et al. vs. Oikocredit, https://bit.ly/3FvjBFR និង Oikocredit, ការបិទកិច្ចសន្ទនា OECD, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥ https://bit.ly/3XPwDnK។

564 UN, បច្ចុប្បន្នភាពស្តីពីវឌ្ឍនភាពនៃសេចក្តីថ្លែងការណ៍រួម, https://bit.ly/423yxDI. FMO, គំនិតផ្តួចផ្តើមនៃវិស័យដែលអាចមាន - ប្រទេសកម្ពុជា, https://bit.ly/3R7beCL.

565 ស៊ីអេអូកត់សម្គាល់ថា មានការរាយការណ៍ពីបញ្ហាប្រឈមសំខាន់ៗក្នុងការអនុវត្តកម្មវិធីអក្ខរកម្មផ្នែកហិរញ្ញវត្ថុទាំងនេះ។ P. Res, មីក្រូហិរញ្ញវត្ថុនៅពេលមានជំងឺកូវីដ១៩, កិច្ចការពារអ្នកប្រើប្រាស់ និងដំណើរការរៀបចំកម្ចីឡើងវិញ, នៅកម្ពុជា, ឆ្នាំ២០២១; P. Res, ការបណ្តុះបណ្តាលអក្ខរកម្មផ្នែកហិរញ្ញវត្ថុនៅកម្ពុជា ជាឧបករណ៍មួយដើម្បីបង្កើតភាពអត្តនោម័តរបស់អ្នកខ្ចី, ឆ្នាំ២០២៣, M. Bylander, P. Res, 'ប្រសិនបើអ្នកដួល សូមក្រោកឈរឡើងវិញម្តងទៀត'៖ លក្ខណៈផ្នែកសីលធម៌នៃអក្ខរកម្មផ្នែកហិរញ្ញវត្ថុនៅក្នុងលោកខាងត្បូង, *ការអភិវឌ្ឍ និងការផ្លាស់ប្តូរ*, ឆ្នាំ២០២១។ អ្នករិះគន់បានចង្អុលបង្ហាញថា កម្មវិធីទាំងនេះតែងតែដើរតួនាទីធ្វើយុត្តិកម្មឧស្សាហកម្មធនាគារ – នៅពេលខ្លះ កម្មវិធីទាំងនេះស្ថិតក្រោមការដឹកនាំរបស់មន្ត្រីឥណទានដែលមកពីឧស្សាហកម្មធនាគារ - នៅខណៈដែលមានការស្តីបន្ទោសអំពីបំណុលវណ្ណក ទៅលើកង្វះខាតអក្ខរកម្មផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចីតែមួយមុខ។ ការយល់ឃើញបែបនេះមើលរំលងកត្តារួមចំណែកដទៃទៀត ដូចជា ការអនុវត្តការផ្តល់ប្រាក់កម្ចីបែបឃោរឃៅ និងក្របខណ្ឌនិយ័តកម្មមិនគ្រប់គ្រាន់ ដែលត្រូវបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះ។ N.Green, ការបន្តមានវត្តមានអ្នកផ្តល់ប្រាក់កម្ចី៖ របៀបដែលបំណុលក្រៅប្រព័ន្ធធ្វើឱ្យហិរញ្ញវត្ថុនីយកម្មធ្លាក់ចូលកាន់តែជ្រៅនៅតំបន់ជនបទនៃប្រទេសកម្ពុជា *ទិនានុប្បវត្តិការសិក្សាអំពីកសិករ* ឆ្នាំ២០២៥។

566 សមាគមធនាគារនៅកម្ពុជាលើកកម្ពស់ការអនុវត្តទីផ្សារ ដើម្បីបង្កើនទំនុកចិត្ត និងសុចរិតភាពនៅក្នុងវិស័យធនាគារ *កាសែតខ្មែរថាមស៍* ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤, https://bit.ly/3DvX774។

567 ស៊ីអេអូសម្ភាស ABC; ប្រធាន ABC មានប្រសាសន៍ថា ខ្លួនគឺជាសមាគមដែលជឿជាក់ថា និយ័តករនឹងដោះស្រាយបញ្ហា និងគិតដល់ពេលអនាគត នៅក្នុងការសម្រេចចិត្តរបស់ពួកគេ, កាសែតខ្មែរថាមស៍ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ https://bit.ly/3ReLHYh។

568 CMA, បុគ្គលិកមីក្រូហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងឥណទាន ៧៦% បានប្រលងជាប់កម្មវិធីផ្តល់វិញ្ញាបនបត្រសម្រាប់ "ការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ" ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤, https://bit.ly/43HK4Kb។

ស៊ីអេអូបានពិចារណាលើគំនិតផ្តួចផ្តើម និងកម្មវិធីទាំងនេះនៅក្នុងការផ្តល់អនុសាសន៍ខាងក្រោម (សូមមើលព័ត៌មានលម្អិតបន្ថែមទៀតអំពីគំនិតផ្តួចផ្តើមទាំងនេះនៅក្នុងឧបសម្ព័ន្ធ ក)។

លើសពីនេះទៀត តាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយស៊ីអេអូ ក្នុងករណីដែល IFC បានដកខ្លួនចេញពីការវិនិយោគរបស់ខ្លួន "អនុសាសន៍នឹងពិចារណាលើភាពពាក់ព័ន្ធនៃការដកខ្លួនចេញរបស់ IFC/MIGA។"[569] នៅក្នុងសំណុំរឿងនេះ IFC បានដកការវិនិយោគចំនួនប្រាំក្នុងចំណោមការវិនិយោគដែលពាក់ព័ន្ធទាំង១៣ បន្ទាប់ពីមានការដាក់ពាក្យបណ្តឹងនៅខែកុម្ភៈ ឆ្នាំ២០២២ ដោយសារតណៈប្រតិទាន និងការសងប្រាក់កម្ចី។[570]

ទោះបីជាយ៉ាងណាក៏ដោយ IFC នៅតែមានទំនាក់ទំនងហិរញ្ញវត្ថុជាមួយគ្រឹះស្ថានទាំងអស់នេះ លើកលែង BFI មួយក្នុងចំណោម BFI ទាំង ៦ នៅកម្ពុជា តាមរយៈការវិនិយោគដែលនៅសកម្មដទៃទៀត។[571] ស៊ីអេអូក៏កត់សម្គាល់ផងដែរថា ប្រាក់កម្ចី MEF ដែលបានផ្តល់ដល់ FIs ចំនួនបួន ក្នុងចំណោម FIs នៅក្នុងសំណុំរឿងនេះ បានដល់តណៈប្រតិទាន និងត្រូវបានសងវិញ តាំងពីពេលចាប់ផ្តើមការស៊ើបអង្កេតភាពអនុលោមនេះ (សូមមើលផ្នែក ២ ខាងលើ)។ ជាលទ្ធផល នៅពេលបញ្ចប់របាយការណ៍នេះ IFC មិនមានទំនាក់ទំនងហិរញ្ញវត្ថុសកម្មជាមួយប្រាសាក់នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រាសាក់ គឺជាដៃគូធុរកិច្ចរបស់ IFC ដោយមានកិច្ចសហការជាច្រើនតាំងពីឆ្នាំ២០១២[572] មក និងជាសមាជិករបស់ ABC ដែល IFC សហការជាមួយនៅក្នុងគំនិតផ្តួចផ្តើមកម្រិតវិស័យរបស់ខ្លួន។ ស៊ីអេអូលើកទឹកចិត្ត IFC ឱ្យពិចារណាលើទំនាក់ទំនងដ៏ទូលំទូលាយជាមួយប្រាសាក់ នៅពេលសម្រេចចិត្តអំពីសកម្មភាពកម្រិតគម្រោងរបស់ខ្លួន នៅក្នុងសំណុំរឿងនេះ ព្រមទាំងពិចារណាលើគំហើញ និងអនុសាសន៍របស់ស៊ីអេអូនៅក្នុងសកម្មភាពធុរកិច្ចនាពេលអនាគតជាមួយនឹងប្រាសាក់។

ដោយគិតគូរដល់ការពិចារណា និងគំហើញខាងលើ ស៊ីអេអូផ្តល់អនុសាសន៍ឲ្យ IFC ធ្វើសកម្មភាពដូចខាងក្រោម នៅកម្រិតគម្រោង និងកម្រិតស្ថាប័ន៖

### អនុសាសន៍នៅកម្រិតគម្រោង

1. **IFC គួរតែធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីរចនា និងអនុវត្តកម្មវិធីដែលមានប្រសិទ្ធភាពមួយ ដើម្បីវាយតម្លៃ ពង្រឹង និងដោះស្រាយអសាធនភាព និងការជំពាក់បំណុលរបស់ដើមបណ្តឹងម្នាក់ៗ រួមទាំងដើមបណ្តឹងទាំង ១៨ នាក់ ដែលដាក់ពាក្យបណ្តឹងនេះផងដែរ។** ជម្រើសគួរតែរួមមាន ការផ្អាក

---

569 គោលនយោបាយស៊ីអេអូ កថាខណ្ឌ ១២០(គ)។

570 ការវិនិយោគចំនួនបីក្នុងចំណោមការវិនិយោគទាំងនេះត្រូវបានសងរួចរាល់ បន្ទាប់ពីមានការដាក់ពាក្យបណ្តឹង និងមានការដកខ្លួនចេញនៅពេលវាយតម្លៃភាពអនុលោម៖ គម្រោងរបស់ធនាគារហត្ថាលេខ ៣៩១៦៧ និង ៤៤២១១, និងគម្រោងរបស់អម្រ៊ីត លេខ ៤១២៩៤, ដែលសុទ្ធតែបានដកចេញនៅឆ្នាំ២០២២។ គម្រោងពីរផ្សេងទៀតត្រូវបានដកចេញនៅចន្លោះពេលរវាងការវាយតម្លៃភាពអនុលោម និងកាលបរិច្ឆេទនៃរបាយការណ៍នេះ៖ អម្រ៊ីត គម្រោងលេខ ៤៤២៣១ ត្រូវបានដកចេញនៅខែមិថុនា ឆ្នាំ២០២៣ និង ធនាគារហត្ថា គម្រោងលេខ ៤៥៥៣៥ ត្រូវបានដកចេញនៅខែកក្កដា ឆ្នាំ២០២៤។

571 ទំនាក់ទំនងផ្នែកហិរញ្ញវត្ថុសកម្មរបស់ IFC ជាមួយអម្រ៊ីតគឺ តាមរយៈការវិនិយោគភាគហ៊ុននៅឆ្នាំ២០២៤ (គម្រោង IFC លេខ ៣៨៧៤៨) និងទំនាក់ទំនងផ្នែកហិរញ្ញវត្ថុសកម្មរបស់ IFC ជាមួយធនាគារហត្ថាគឺ ប្រាក់កម្ចីបន្ទាប់បន្សំសកម្ម (គម្រោង IFC លេខ ៤៤៧៤២)។

572 គម្រោង IFC លេខ ៣២១៤១ ៣៣២០៦ ៣៤៥៩៣ ៣៧១៨០ ៣៦២៨០ ៣៨២៣៥

សងប្រាក់ ការលើកលែងការប្រាក់ ឬបំណុលដែលជំពាក់ ការរៀបចំឥណទានឡើងវិញ បុនហិរញ្ញប្បទានដោយមិនបង្កើនបំណុល ការគាំទ្រចំពោះមុខរបរចិញ្ចឹមជីវិត ឬការងារ ឬវិធានការសមស្របដទៃទៀត អាស្រ័យលើស្ថានភាពរបស់អ្នកខ្ចីម្នាក់ៗ។ កម្មវិធីទាំងនេះក៏គួរតែពិចារណាលើ៖

a. **ការប្រមូលទិន្នន័យមូលដ្ឋាន និងបណ្តុំព័ត៌មានសេដ្ឋកិច្ចសង្គមរបស់អ្នកខ្ចីបន្ត** រួមទាំងការប្រឈមនឹងប្រាក់កម្ចី អត្រាការប្រាក់ សមត្ថភាពសងប្រាក់ និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គម តាមរយៈទីភ្នាក់ងារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីធានាបាននូវទំនុកចិត្ត និងការចូលរួមរបស់សហគមន៍។

b. ការស្វែងយល់ពីវាល់**ជម្រើសក្នុងការរៀបចំឥណទានឡើងវិញ បុនហិរញ្ញប្បទាន ឬការលើកលែង** សម្រាប់អ្នកខ្ចីដែលរងផលប៉ះពាល់ ដែលមានការលំបាកផ្នែកហិរញ្ញវត្ថុដែលអាចផ្ទៀងផ្ទាត់បាន និងការ**ពិចារណាលើផ្លូវចេញសម្រាប់អ្នកជំពាក់បំណុល**។ ផ្លូវចេញសម្រាប់អ្នកជំពាក់បំណុលអាចរួមមាន ការធ្វើផែនការគ្រប់គ្រងបំណុលបុគ្គល ការសំដៅលើគំនិតផ្តួចផ្តើមបង្កើតប្រាក់ចំណូល ការប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុ និងការជួយអ្នកខ្ចីដោយយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីកាត់បន្ថយការពឹងផ្អែកលើឥណទាន។

c. **ចាប់ដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលនៅតាមសហគមន៍**ដើម្បីបង្កើតបណ្តាញទំនាក់ទំនងជាមួយអ្នកខ្ចី ពិនិត្យតាមដានការអនុវត្តការផ្តល់ប្រាក់កម្ចី និងលើកកម្ពស់ការចូលរួមដ៏មានអត្ថន័យរបស់ភាគីពាក់ព័ន្ធនៅគ្រប់ពេលនៃការវិនិយោគរបស់ IFC។ ភាពជាដៃគូក៏អាចផ្តល់នូវ**ការគាំទ្រដល់មុខរបរចិញ្ចឹមជីវិត និងការងារ** និងភ្ជាប់ទំនាក់ទំនងរវាងអ្នកខ្ចី និងទីផ្សារការងារដែលពាក់ព័ន្ធបានដែរ (ឧទាហរណ៍ តាមរយៈការរៀបចំពិព័រណ៍ការងារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសកម្មភាពចូលរួមរបស់និយោជក ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន)។

IFC អាចទាញយកអត្ថប្រយោជន៍ពីការព្រមព្រៀងនៃកិច្ចសន្យា និងឥទ្ធិពលនៃកេរ្តិ៍ឈ្មោះរបស់ខ្លួន ដើម្បីធានាថាមានការចូលរួមពីអតិថិជន និងការសហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលគួរឱ្យទុកចិត្ត ដើម្បីធ្វើការវាយតម្លៃអ្នកខ្ចី និងផ្តល់ការគាំទ្រដល់មុខរបរចិញ្ចឹមជីវិត។ IFC ក៏អាចប្រមូលផ្តុំបរធនរបស់ម្ចាស់ជំនួយ ឬធនធាននៃសេវាទីប្រឹក្សារបស់ខ្លួន ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការប្រឹក្សាអំពីបំណុល ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការពិនិត្យតាមដាន។

2. **IFC គួរតែបន្តកិច្ចខិតខំប្រឹងប្រែងផ្តល់ការគាំទ្រដល់ការបង្កើតយន្តការពាក្យបណ្តឹងឯករាជ្យ**[573] **សម្រាប់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជា** ដែលអនុវត្តតាមការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ស្របតាមលក្ខខណ្ឌតម្រូវនៃ PS1។ យន្តការគួរតែឯករាជ្យពីគ្រឹះស្ថានហិរញ្ញវត្ថុ និងបុត្រសម្ព័ន្ធរបស់ពួកគេ ក្នុងការធ្វើអភិបាលកិច្ច និងការធ្វើប្រតិបត្តិការ ហើយ FIs គួរតែប្តេជ្ញាចិត្តអនុលោមតាម និងអនុវត្ត

---

[573] យន្តការបណ្តឹងដែលដំណើរការដោយឯករាជ្យ គួរតែដំណើរការដោយគ្មានការជះឥទ្ធិពល ឬការគ្រប់គ្រងពីភាគីដែលមានសក្តានុពល ចំពោះពាក្យបណ្តឹងដែលវាអាចទទួលបាន។

ដំណោះស្រាយរបស់ខ្លួន។[574] IFC បានចាប់ផ្តើមធ្វើការជាមួយសមាគមធនាគារកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងដៃគូអភិវឌ្ឍន៍ដទៃទៀតនៅឆ្នាំ២០២៤ ដើម្បីបង្កើតយន្តការសម្រាប់វិស័យនេះ។ IFC អាចកោះប្រជុំដៃគូទាំងនេះរួមជាមួយធនាគារជាតិនៃកម្ពុជា (NBC) DFIs ដទៃទៀត និងសង្គមស៊ីវិល ដើម្បីរួមគ្នារចនាគំរូដែលមានប្រសិទ្ធភាព។[575]

3. **IFC គួរតែធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយលើគោលនយោបាយ និងការអនុវត្តរបស់គ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ** ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ ដើម្បី៖

    a. កំណត់ និងដោះស្រាយចន្លោះប្រហោងនៃ PS1 និង PS7 រួមទាំង GIIP ដែលពាក់ព័ន្ធ និងពង្រឹងសមត្ថភាពរបស់អតិថិជន និងអតិថិជនបន្តផងដែរ

    b. តម្រូវឱ្យអតិថិជនរួមបញ្ចូលលក្ខណៈវិនិច្ឆ័យនៃសមិទ្ធកម្មសង្គម លើសពីប្រាក់កម្ចីដែលបានអនុម័ត ឬបំណុលដែលបានប្រមូល នៅក្នុងគម្រោងលើកទឹកចិត្តសម្រាប់មន្ត្រីឥណទាន/មន្ត្រីប្រមូលប្រាក់ និងអ្នកគ្រប់គ្រង។

4. **IFC គួរតែបង្កើតកម្មវិធីបណ្តុះបណ្តាលអតិថិជន** ដើម្បីពង្រឹងយន្តការបណ្តឹងសារទុក្ខជាប្រព័ន្ធ នៅកម្រិតអតិថិជន និងអតិថិជនបន្ត ដោយផ្តោតលើការបង្កើតឧបករណ៍ និងអភិវឌ្ឍសមត្ថភាពក្នុងការដោះស្រាយវិវាទ ដោយទប់ស្កាត់ការគំរាមកំហែង ការបៀតបៀន ឬការសងសឹកចំពោះអ្នកខ្ចី។ ស្របពេលជាមួយគ្នានេះ ផ្តល់ការបណ្តុះបណ្តាលឯកទេស ស្របតាម GIIP ដល់មន្ត្រីឥណទាន និងមន្ត្រីប្រមូលប្រាក់ ដោយគ្របដណ្តប់ការវាយតម្លៃយ៉ាងត្រឹមត្រូវលើសមត្ថភាពសងប្រាក់ និងការយល់ដឹងអំពីលក្ខខណ្ឌតម្រូវរបស់ IFC ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច និងរបៀបបញ្ចៀសការខូចខាត ក្នុងការអនុវត្តការផ្តល់កម្ចី និងការប្រមូលប្រាក់របស់ពួកគេ។ IFC គួរតែតម្រូវឲ្យរបាយការណ៍តាមដានការអនុវត្ត។

5. **IFC គួរតែធ្វើការជាមួយអតិថិជនដើម្បីបង្កើត និងអនុវត្តកម្មវិធីផ្តល់ភាពអង់អាចផ្នែកហិរញ្ញវត្ថុ** សំដៅលើ (i) កសាងការយល់ដឹង និងសមត្ថភាពរបស់អ្នកខ្ចីដែលងាយរងគ្រោះ ក្នុងការចូលរួមជាមួយ BFIs និង (ii) អភិវឌ្ឍការប្រាស្រ័យទាក់ទង និងឯកសារព័ត៌មានអំពីប្រាក់កម្ចីដែលអាចប្រើប្រាស់បាន សម្រាប់អ្នកខ្ចី។ ការបណ្តុះបណ្តាលគួរតែត្រូវបានកែសម្រួលតាមកម្រិតភាសា និងអក្ខរកម្មនៅក្នុងមូលដ្ឋាន និងផ្តល់ជូនដោយទីភ្នាក់ងារ ឬអង្គការមិនមែនរដ្ឋាភិបាល ដោយមានវត្តមានសហគមន៍ ដែលត្រូវបានបង្កើតឡើង។ ខ្លឹមសារគួរតែរួមបញ្ចូលការខ្ចីប្រាក់ដោយមានព័ត៌មានគ្រប់គ្រាន់ ហានិភ័យនៃបំណុលវ័ណ្ឌក លក្ខខណ្ឌនៃប្រាក់កម្ចី យន្តការបណ្តឹងសារទុក្ខ និងសិទ្ធិរបស់អ្នកខ្ចី ក្នុងគោលបំណងធ្វើឲ្យអ្នកខ្ចី

---

[574] WBG បានពន្យល់ថា GIIP ចង្អុលបង្ហាញថា អ្នកប្រើប្រាស់គួរតែទទួលបានយន្តការដោះស្រាយវិវាទជំនួស ដែលពួកគេអាចប្តឹងជំទាស់នឹងសេចក្តីសម្រេចចិត្តណាមួយ ដែលកើតចេញពីការដោះស្រាយពាក្យបណ្តឹងផ្ទៃក្នុងនៅទីតាំងរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ដែលក្នុងចំណោមលក្ខខណ្ឌផ្សេងទៀត យន្តការជំនួសនេះមានឯករាជ្យភាពពីភាគីទាំងពីរ អនុវត្តមុខងាររបស់ខ្លួនដោយឥតលម្អៀង និងមានអំណាចក្នុងការចេញសេចក្តីសម្រេចដែលចងកាតព្វកិច្ចលើអ្នកផ្តល់សេវាហិរញ្ញវត្ថុ។ WBG, ការអនុវត្តល្អៗចំពោះកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ, ឆ្នាំ២០១៧, ទំ. ៥១-៥២, https://bit.ly/41PWcWT។

[575] ជម្រើសនៃការផ្តល់មូលនិធិអាចរួមមាន គំរូចម្រុះនៃការរួមចំណែករបស់ម្ចាស់ជំនួយ ពន្ធ MFI និងការគាំទ្រពីដៃគូអភិវឌ្ឍន៍។

អាចធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ និងចូលរួមប្រកបដោយការស្ថាបនា ជាមួយ BFIs។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ IFC គួរតែគាំទ្រឲ្យអតិថិជន និងអតិថិជនបន្តបង្កើតសំណុំឯកសារប្រាក់កម្ចី និងការប្រាស្រ័យទាក់ទងរបស់អ្នកខ្ចី ដែលអាចប្រើប្រាស់បាន មានភាពសមស្របផ្នែកវប្បធម៌ និងត្រូវបានបង្ហាញជាភាសាក្នុងស្រុក ដើម្បីធានាបាននូវការយល់ព្រមដោយមានព័ត៌មានគ្រប់គ្រាន់ និងការយល់ដឹងរបស់អ្នកខ្ចីអំពីសិទ្ធិ និងកាតព្វកិច្ច។

នៅក្នុងការអនុវត្តសកម្មភាពកម្រិតគម្រោង ស៊ីអេអូរំឭកអំពីគោលការណ៍ស្នូលរបស់ខ្លួនថា "ប្រជាជនមិនគួរទទួលរងគ្រោះថ្នាក់ដោយសារកិច្ចសហប្រតិបត្តិការនៅក្នុងដំណើរការស៊ីអេអូឡើយ"[227] រួមទាំងក្រោយពេលបញ្ចប់ និងបោះពុម្ពផ្សាយរបាយការណ៍ស៊ើបអង្កេតភាពអនុលោមនេះ និងការអនុវត្ត MAP ជាបន្តបន្ទាប់។ ដូចមានចែងនៅក្នុងសេចក្តីថ្លែងការណ៍របស់ IFC ស្តីពីការសងសឹកនឹងសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនឹងគម្រោង "IFC មិនអត់ឱនចំពោះសកម្មភាពណាមួយរបស់អតិថិជនរបស់ IFC ដែលស្មើនឹងការសងសឹក រួមទាំងការគំរាមកំហែង ការបំភិតបំភ័យ ការបៀតបៀន ឬអំពើហិង្សាទៅលើអ្នកទាំងឡាយ ដែលបញ្ចេញគំនិតរបស់ខ្លួនពាក់ព័ន្ធនឹងសកម្មភាពរបស់ IFC ឬអតិថិជន [របស់ខ្លួន] ឡើយ។"[228] ស៊ីអេអូជម្រុញឱ្យគ្រប់ភាគី និងភាគីពាក់ព័ន្ធអនុវត្តរាល់កិច្ចខិតខំប្រឹងប្រែងដើម្បីការពារសុវត្ថិភាពរបស់ដើមបណ្តឹង និងតំណាងរបស់ពួកគេពីការគំរាមកំហែង និងការសងសឹក ដោយសារការពាក់ព័ន្ធ និងការចូលរួមរបស់ពួកគេនៅក្នុងសំណុំរឿងនេះ។ ការប្រឹក្សាយោបល់ និងការចូលរួមជាមួយដើមបណ្តឹង និងតំណាងរបស់ពួកគេគប្បីមានយន្តការនានាដើម្បីទប់ស្កាត់ និងកាត់បន្ថយហានិភ័យនៃការសងសឹក នៅពេលដែល IFC រៀបចំ និងអនុវត្តផែនការសកម្មភាពគ្រប់គ្រងរបស់ខ្លួន។

## អនុសាសន៍កម្រិតស្ថាប័ន

ដើម្បីដោះស្រាយមូលហេតុឫសគល់នៃគំហើញអំពីបដិលោមភាព នៅក្នុងសំណុំរឿងនេះ ស៊ីអេអូផ្តល់អនុសាសន៍ថា IFC គួរតែពង្រឹងការធ្វើសមាហរណកម្មកាតព្វកិច្ចនៃគោលនយោបាយនិរន្តរភាពរបស់ខ្លួន រួមមាន កាតព្វកិច្ចដែលទាក់ទងនឹងការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការការពារក្រុងងាយរងគ្រោះ និងជនជាតិដើមភាគតិច ទៅក្នុងការរៀបចំរចនាសម្ព័ន្ធ ការត្រួតពិនិត្យភាពត្រឹមត្រូវ និងការគ្រប់គ្រងសកម្មភាពមីក្រូហិរញ្ញវត្ថុរបស់ខ្លួន។

ដោយទទួលស្គាល់អំពីតួនាទី និងការងារគន្លឹះរបស់ IFC នៅក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុពិភពលោក និងកម្ពុជា IFC គួរតែអភិវឌ្ឍការងាររបស់ខ្លួនដែលមានស្រាប់នៅក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ និងកំណែទម្រង់វិស័យនេះ នៅក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុពិភពលោក និងកម្ពុជា ដើម្បី៖

1. **អភិវឌ្ឍសមត្ថភាព និងឧបករណ៍ ព្រមទាំងបង្កើនជំនាញផ្ទៃក្នុង ដើម្បីរៀបចំ និងអនុវត្តដំណើរការសម្រាប់ប្រើប្រាស់ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងគ្រប់គ្រងគម្រោង ដើម្បីកំណត់ក្រុមងាយរងគ្រោះ និងវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនៃការវិនិយោគពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុ។** ដំណើរការនេះគួរតែវាយតម្លៃសមត្ថភាព និងបទពិសោធន៍របស់អតិថិជនក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនៃ GIIP ទាក់ទងនឹងអ្នកខ្ចីដែលងាយរងគ្រោះ និងជនជាតិដើមភាគតិចផងដែរ។ ក្នុងអំឡុងពេលគ្រប់គ្រង IFC គួរតែតម្រូវឲ្យ FIs រួមបញ្ចូលបណ្តុំព័ត៌មានអំពីសំណាកតំណាងឲ្យអ្នកខ្ចីឥណទានខ្នាត

តូច (ឧ. រួមជាមួយចំនួនប្រាក់កម្ចី និងរយៈពេល អត្រាការប្រាក់ ការទូទាត់សង ភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុ និងកម្រិតទុក្ខព្រួយ និងរបៀបដែលបុគ្គលិក FI ធ្វើអន្តរកម្មជាមួយសហគមន៍) នៅក្នុងរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំរបស់ពួកគេ។ ការរួមបញ្ចូលបែបនេះនឹងជួយ IFC តាមដានលទ្ធផលរបស់អ្នកខ្ចី និងធានាថាអតិថិជនអនុវត្តស្របតាមស្តង់ដារសមិទ្ធកម្ម GIIP និងច្បាប់ជាតិដែលពាក់ព័ន្ធ។

2. **រួមបញ្ចូលកិច្ចព្រមព្រៀងស្តង់ដារ រួមជាមួយលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ លើការបំពេញតាម GIIP ទាក់ទងនឹងអ្នកខ្ចីដែលងាយរងគ្រោះ នៅក្នុងកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ សម្រាប់ការវិនិយោគលើបរិយាប័ន្នហិរញ្ញវត្ថុ។** ស្តង់ដារ GIIP ទាំងនេះគួរតែចងកាតព្វកិច្ចលើលក្ខខណ្ឌតម្រូវ ដែលអតិថិជនត្រូវបំពេញ និងរាយការណ៍នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ពួកគេ ហើយ IFC នឹងពិនិត្យតាមដានដើម្បីផ្ទៀងផ្ទាត់ការអនុវត្តរបស់ពួកគេ។

# ឧបសម្ព័ន្ធ ក. គំនិតផ្ដួចផ្ដើមបន្តបន្ទាប់នៅកម្ពុជា

ខាងក្រោមគឺជាគំនិតផ្ដួចផ្ដើម ដែលស៊ីអេអូដឹងថាបានចាប់ផ្ដើមឡើងនៅកម្ពុជា ចាប់តាំងពីឆ្នាំ២០២៣ មក ដោយរដ្ឋាភិបាលកម្ពុជា ទីភ្នាក់ងារនិយ័តកម្ម គ្រឹះស្ថានហិរញ្ញវត្ថុ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដើម្បីឆ្លើយតបនឹងកង្វល់ដែលកំពុងកើនឡើងអំពីផលប៉ះពាល់នៃបំណុលវណ្ឌកែ លើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុ។

## 1. កិច្ចសន្ទនាពហុភាគីពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ

នៅខែវិច្ឆិកា ឆ្នាំ២០២៣ ការិយាល័យអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងធនាគារជាតិនៃកម្ពុជា (NBC) បានដាក់ឲ្យដំណើរការគំនិតផ្ដួចផ្ដើមកិច្ចសន្ទនាពហុភាគីពាក់ព័ន្ធ ដោយគ្របដណ្ដប់លើក្រុម និងគ្រឹះស្ថានចំនួន ១០០ ដើម្បីកំណត់ និងពិនិត្យតាមដានជំហាន និងការប្ដេជ្ញាចិត្តដែលអាចធ្វើសកម្មភាពបាន។[576] គិតត្រឹមខែមករា ឆ្នាំ២០២៥ កិច្ចសន្ទនានេះបានធ្វើឱ្យមានការវាយតម្លៃភាពអនុលោមរបស់ FIs ធំបំផុតចំនួន ៣០ នៅក្នុងប្រទេសនេះស្របតាមក្រមប្រតិបត្តិសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ និងស្តង់ដារសកលសម្រាប់កិច្ចការពារអតិថិជនរបស់ Cerise+SPTF ។[577] គំនិតផ្ដួចផ្ដើមដទៃទៀតបានផ្ដល់ដល់ FIs នូវលទ្ធភាពទទួលបានព័ត៌មានតាមអនឡាញ ស្ដីពីប្លង់រឹង ICLTs និងដីរបស់រដ្ឋ ដើម្បីលើកកម្ពស់ភាពអនុលោមតាមច្បាប់ ដែលហាមឃាត់ការប្រើប្រាស់ប្លង់រឹងទាំងនេះជាវត្ថុបញ្ចាំ [578] និងបានត្រួតពិនិត្យសូចនាករសមិទ្ធកម្មគន្លឹះរបស់ FIs ដើម្បីតម្រឹមសូចនាករទាំងនោះជាមួយក្រមប្រតិបត្តិមីក្រូហិរញ្ញវត្ថុជាតិ និងស្តង់ដារសកល។ សមាគមធនាគារនៅកម្ពុជា (ABC) និង CMA ក៏បានបង្កើតមជ្ឈមណ្ឌលអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCC) ដែលបានដាក់ឲ្យដំណើរការមជ្ឈមណ្ឌលទំនាក់ទំនងតាមទូរសព្ទសម្រាប់អ្នកខ្ចីនៅខែកញ្ញា ឆ្នាំ២០២៤ផងដែរ។[579]

IFC ចូលរួមនៅក្នុងកិច្ចសន្ទនានេះ [580] និងតាមរយៈគម្រោងផ្ដល់ទីប្រឹក្សា FIG ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ

[576] ស៊ីអេអូបានទទួលព័ត៌មានថា ទោះបីជា CSOs មួយចំនួន ត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំពហុភាគីពាក់ព័ន្ធក្ដី ក៏ពួកគេបានសម្រេចចិត្តមិនចូលរួមដោយសារមិនបានរួមបញ្ចូលអ្នកខ្ចីនៅក្នុងដំណើរការនេះទេ។ CSOs បានជូនដំណឹងទៅកាន់ស៊ីអេអូថា ពួកគេយល់ថា អ្នកខ្ចីគួរតែអាចចូលរួមក្នុងដំណើរការនេះ ដោយមានការការពារយ៉ាងសមស្របពីការសងសឹកដែលអាចកើតឡើង ពីព្រោះពួកគេគឺជាប្រជាជនដែលរងផលប៉ះពាល់ដោយផ្ទាល់ https://bit.ly/423yxDI។

[577] ឧបករណ៍វាយតម្លៃសុខដុមនីយកម្មនៃកិច្ចការពារអ្នកប្រើប្រាស់ ត្រូវបានរៀបចំឡើងដោយ Cerise+SPTF។ Hin Pisei, ប្រទេសកម្ពុជាជម្រុញឱ្យមានការអនុវត្តផ្នែកធនាគារប្រកបដោយក្រមសីលធម៌ រួមជាមួយឧបករណ៍វាយតម្លៃកិច្ចការពារអតិថិជនថ្មី, ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤, https://bit.ly/4hwUHmn។

[578] S. Manet, កិច្ចប្រជុំ NBC-UN ត្រួតពិនិត្យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា, *ការសែតខ្មែរថាមស៍*, ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥ https://bit.ly/423yxDI។

[579] ព្រឹត្តិការណ៍សំខាន់ៗដទៃទៀត រួមមាន កិច្ចខិតខំប្រឹងប្រែងបង្កើតការចែករំលែកទិន្នន័យសម្រាប់ BFI និងសេវាហិរញ្ញប្បទានមិនមែនធនាគារ ការអនុវត្តវិធានការរៀបចំឥណទានឡើងវិញ និងការដាក់ឲ្យដំណើរការសាកល្បងកម្មវិធីហានិភ័យអាកាសធាតុ និងការធានារ៉ាប់រងលើដំណាំនៅក្រោមសហករណ៍កសិកម្មបែបទំនើប។ សូមមើល៖ អង្គការសហប្រជាជាតិប្រចាំកម្ពុជា, សេចក្ដីថ្លែងការណ៍រួមអំពីបច្ចុប្បន្នភាពនៃវឌ្ឍនភាព៖ NBC-UN រៀបចំកិច្ចពិគ្រោះយោបល់ពហុភាគីពាក់ព័ន្ធស្ដីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៥, https://bit.ly/423yxDI។

[580] S. Manet, កិច្ចប្រជុំ NBC-UN ត្រួតពិនិត្យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា, *ការសែតខ្មែរថាមស៍*, ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥ https://bit.ly/423yxDI។

(លេខ ៦០៧៥២៨) របស់ខ្លួន បានគាំទ្រដល់ការបង្កើត FCC។ នៅពេលនេះ IFC និងដៃគូអភិវឌ្ឍន៍ដទៃទៀត[581] កំពុងដឹកនាំកិច្ចខិតខំប្រឹងប្រែងក្នុងការវាយតម្លៃសមិទ្ធលទ្ធភាព និងការរចនាយន្តការឯករាជ្យសម្រាប់ការប្រឹក្សាយោបល់ និងសន្ទានកម្មបំណុល ដូចជា អ្នកដោះស្រាយវិវាទហិរញ្ញវត្ថុ នៅក្រោម FCC ជាដើម។[582]

## 2. អគ្គនាយកដ្ឋានបទប្បញ្ញត្តិ និងបរិយាបន្នហិរញ្ញវត្ថុ

តាមរយៈគម្រោងផ្តល់ទីប្រឹក្សា FIG ស្តីពីគម្រោងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (លេខ ៦០៧៥២៨) របស់ខ្លួន IFC ក៏បានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ NBC ក្នុងការបង្កើនការត្រួតពិនិត្យលើកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ តាមរយៈការបង្កើតអគ្គនាយកដ្ឋានបទប្បញ្ញត្តិ និងបរិយាបន្នហិរញ្ញវត្ថុ ផងដែរ។[583]

## 3. កម្មវិធីអក្ខរកម្មផ្នែកហិរញ្ញវត្ថុ

ចាប់ពីឆ្នាំ២០១៦មក NBC បានដាក់ឲ្យដំណើរការកម្មវិធីអក្ខរកម្មផ្នែកហិរញ្ញវត្ថុមួយចំនួន ដោយសហការជាមួយ CMA ABC CBC និងក្រសួងពាក់ព័ន្ធ។ កម្មវិធីទាំងនេះរួមមាន សិក្ខាសាលានៅថ្នាក់ខេត្ត និងថ្នាក់ស្រុក យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គម និងសមាហរណកម្មអក្ខរកម្មផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀន។ [584] ចាប់តាំងពីឆ្នាំ២០២៣មក ចំណុចផ្តោតនេះត្រូវបានពង្រីក ដើម្បីរួមបញ្ចូលបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ស្ត្រី និងសហគមន៍ជនបទ។[585]

---

581 FMO, គំនិតផ្តួចផ្តើមវិស័យដែលអាចមាន – ប្រទេសកម្ពុជា, https://bit.ly/3R7beCL។ នៅខែធ្នូ ឆ្នាំ២០២២ មានការដាក់ពាក្យបណ្តឹងមួយជាមួយនឹងការិយាល័យទំនាក់ទំនងជាតិប្រទេសហូឡង់ (NCP) ដើម្បីឱ្យមានការអនុវត្តគោលការណ៍ណែនាំរបស់ OECD សម្រាប់សហគ្រាសពហុជាតិសាសន៍ស្តីពី ការអនុវត្តធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ដែលពាក់ព័ន្ធនឹង Oikocredit – ដែលជាវិនិយោគិនសកលលើផលជះផ្នែកសង្គម ដែលមានទីស្នាក់ការកណ្តាលទៅប្រទេសហូឡង់ – ពាក់ព័ន្ធនឹងការវិនិយោគរបស់ពួកគេលើវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា។ ដំណើរការដោះស្រាយត្រូវបានបិទបញ្ចប់នៅខែមករា ឆ្នាំ២០២៥ ហើយជាលទ្ធផល Oikocredit បានប្តេជ្ញាចិត្តរៀបចំក្របខណ្ឌមួយសម្រាប់យន្តការសន្ទានកម្មឯករាជ្យមួយ និងមជ្ឈមណ្ឌលសាមគ្គីភាព និងជំនួយ ដែលស្របជាមួយនឹងបទដ្ឋានអន្តរជាតិ រួមទាំងគោលការណ៍មគ្គុទ្ទេសក៍របស់អង្គការសហប្រជាជាតិស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស។ សូមមើល៖ OECD Watch, សម្ព័ន្ធកម្ពុជាសម្រាប់ការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្ស et al. vs. Oikocredit, https://bit.ly/3FvjBFR និង Oikocredit, ការបិទកិច្ចសន្ទនា OECD, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥ https://bit.ly/3XPwDnK។

582 អង្គការសហប្រជាជាតិ, សេចក្តីថ្លែងការណ៍រួមអំពីបច្ចុប្បន្នភាពនៃវឌ្ឍនភាព, https://bit.ly/423yxDI។ FMO, គំនិតផ្តួចផ្តើមវិស័យដែលអាចមាន – ប្រទេសកម្ពុជា, https://bit.ly/3R7beCL។

583 NBC, របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ២០២៣, ទំ. ២៣, https://bit.ly/4iskMnQ

584 តាំងពីឆ្នាំ២០១៦ មក យុទ្ធនាការ "តោះ! និយាយពីលុយ" កំណត់គោលដៅលើយុវជន ដោយសហការជាមួយយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងសៀវភៅរឿងកំប្លែង, សូមមើល៖ NBC, យុទ្ធនាការ តោះ! និយាយពីលុយ, https://bit.ly/43KCWwF ២០១៩ យុទ្ធនាការ "តក់ៗពេញបំពង់" អក្ខរកម្មផ្នែកហិរញ្ញវត្ថុ អាជីវកម្មខ្នាតតូច ការធានារ៉ាប់រង។ នៅឆ្នាំ២០១៧ ការបង្កប់អក្ខរកម្មផ្នែកហិរញ្ញវត្ថុនៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀនត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា។ សូមមើល៖ https://bit.ly/4l9un4K។

585 គួរឱ្យកត់សម្គាល់ គម្រោងហិរញ្ញវត្ថុសហគមន៍ប្រកបដោយសុវត្ថិភាព ដែលត្រូវរចនាឡើងសម្រាប់សហគមន៍ ត្រូវបានអនុវត្តនៅបួនខេត្ត ដោយមានផែនការពង្រីកទៅកាន់ខេត្តដទៃទៀត។ សូមមើល៖ CMA, ការផ្តល់ភាពអង់អាចដល់សហគមន៍៖ "គម្រោងហិរញ្ញវត្ថុសហគមន៍

តួអង្គទីផ្សារ ដែលរួមមាន SPTF, CMA និងអ្នកផ្ដល់ប្រាក់កម្ចី និងវិនិយោគិននីមួយៗ ក៏បានអនុវត្តកម្មវិធីអក្ខរកម្មផ្នែកហិរញ្ញវត្ថុ និងបានព្យាយាមកែលម្អរចនាសម្ព័ន្ធអភិបាលកិច្ច FI ផងដែរ។ នៅឆ្នាំ២០១៤ SPTF បានចូលរួមជាមួយតួអង្គទីផ្សារដើម្បីរចនាយន្តការឯករាជ្យសម្រាប់ដោះស្រាយបណ្ដឹងសារទុក្ខ និងការប្រឹក្សាយោបល់អំពីបំណុល សម្រាប់គ្រួសារក្រីក្រ និងមានប្រាក់ចំណូលទាប ដែលជាអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងប្រព័ន្ធ។[586] ជាលទ្ធផល នៅឆ្នាំ២០១៤ SPTF បានដាក់ឲ្យដំណើរការគម្រោងអនុវត្តសាកល្បងមួយនៅភូមិចំនួនបី នៅខេត្តរតនគីរី ដើម្បីពង្រឹងភាពអង់អាចរបស់អ្នកប្រើប្រាស់ សម្រាប់អតិថិជនដែលមានភាពតានតឹងផ្លូវចិត្តដោយសារបំណុល។ គំនិតផ្ដួចផ្ដើមនេះរួមបញ្ចូលការអនុវត្តសេវាប្រឹក្សាយោបល់អំពីបំណុលនៅតាមភូមិ ក្រោមការដឹកនាំរបស់ "អ្នកប្រឹក្សាយោបល់អំពីបំណុលនៅថ្នាក់ភូមិ" ដែលបានទទួលការបណ្ដុះបណ្ដាល មកពីសហគមន៍។ អតិថិជននឹងរៀនពិនិត្យតាមដានលំហូរសាច់ប្រាក់នៅក្នុងគ្រួសាររបស់ពួកគេ ទទួលបានរបាយការណ៍ផ្ទាល់ខ្លួនពីក្រេឌីតប៊្យូរ៉ូ ដាក់ពាក្យបណ្ដឹងផ្លូវការ ចរចាជាមួយអ្នកផ្ដល់សេវាហិរញ្ញវត្ថុ (FSPs) អំពីសុខភាព និងបំណុលហិរញ្ញវត្ថុរបស់ពួកគេ ព្រមទាំងស្វែងយល់អំពីតារាងម៉ាទ្រិចស្ដីពីការកើនឡើងនៃបណ្ដឹងសារទុក្ខ (ABC CMA និងបណ្ដាញផ្លូវការដទៃទៀត)។[587]

## 4. កម្មវិធីផ្ដល់វិញ្ញាបនបត្រសម្រាប់ការផ្ដល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវសម្រាប់មន្ត្រីឥណទាន

CMA និង ABC បានដឹកនាំការបណ្ដុះបណ្ដាលសម្រាប់ CEOs និងម្ចាស់ភាគហ៊ុន FI អំពីតួនាទីនៃអភិបាលកិច្ច និងកិច្ចការពារអតិថិជន។[588] ដោយមានការគាំទ្រពី NBC ពួកគេបានអនុវត្តកម្មវិធីផ្ដល់វិញ្ញាបនបត្រសម្រាប់ការផ្ដល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវនៅឆ្នាំ២០២២ សម្រាប់មន្ត្រីឥណទាន និងបុគ្គលិកដទៃទៀតដែលពាក់ព័ន្ធនឹងឥណទាន។ កម្មវិធីនេះ និងវិញ្ញាបនបត្រ ដែលផ្ដល់ជូនដោយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ បានក្លាយជាកាតព្វកិច្ចរបស់មន្ត្រីឥណទានដែលជាសមាជិក ABC យ៉ាងហោចណាស់ចាប់តាំងពីឆ្នាំ២០២៣[589] មក ហើយ CMA ក៏មានផែនការធ្វើដូចគ្នានេះដែរ សម្រាប់បុគ្គលិកដែលពាក់ព័ន្ធនឹងឥណទានរបស់សមាជិក នៅឆ្នាំ២០២៥។[590]

---

ប្រកបដោយសុវត្ថិភាព" បង្កើតការចាប់ផ្ដើមដ៏ខ្លាំងក្លា និងត្រៀមខ្លួនសម្រាប់ឆ្នាំ២០២៤, https://bit.ly/4bSkHHz; អង្គការសហប្រជាជាតិ, សេចក្ដីថ្លែងការណ៍រួមអំពីបច្ចុប្បន្នភាពនៃវឌ្ឍនភាព៖ NBC-UN រៀបចំកិច្ចពិគ្រោះយោបល់ពហុភាគីពាក់ព័ន្ធស្ដីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៥, https://bit.ly/423yxDI; C.Vanyuth, ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុ ដែលផ្ដល់ភាពអង់អាចដល់ប្រជាជនមូលដ្ឋាន, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤, https://bit.ly/425qrKW។ នៅថ្នាក់ភូមិ អក្ខរកម្មផ្នែកហិរញ្ញវត្ថុ ផលិតផលធនាគារ កិច្ចការពារអ្នកប្រើប្រាស់ ហិរញ្ញវត្ថុផ្ទាល់ខ្លួន និងការឆបោក។

586 Cerise+SPTF, ការពង្រឹងការអនុវត្តកិច្ចការពារអតិថិជននៅកម្ពុជា, សំណើសម្រាប់គម្រោងអនុវត្តសាកល្បងការផ្ដល់ភាពអង់អាចដល់អតិថិជននៅខេត្តរតនគីរី, ដែលដាក់ជូនដោយក្រុមការងារអនុវត្តការងារសង្គម, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤, ទំ. ២។

587 Cerise+SPTF, ការពង្រឹងការអនុវត្តកិច្ចការពារអតិថិជននៅកម្ពុជា, សំណើសម្រាប់គម្រោងអនុវត្តសាកល្បងការផ្ដល់ភាពអង់អាចដល់អតិថិជននៅខេត្តរតនគីរី, ដែលដាក់ជូនដោយក្រុមការងារអនុវត្តការងារសង្គម, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤។

588 សមាគមធនាគារនៅកម្ពុជាលើកកម្ពស់ការអនុវត្តទីផ្សារ ដើម្បីបង្កើនទំនុកចិត្ត និងសុចរិតភាពនៅក្នុងវិស័យធនាគារ *កាសែតខ្មែរថាមស៍* ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤, https://bit.ly/3DvX774។

589 ស៊ីអេអូសម្ភាស ABC; ប្រធាន ABC មានប្រសាសន៍ថា ខ្លួនគឺជាសមាគមដែលជឿជាក់ថា និយ័តករនឹងដោះស្រាយបញ្ហា និងគិតដល់ពេលអនាគត នៅក្នុងការសម្រេចចិត្តរបស់ពួកគេ, កាសែតខ្មែរថាមស៍ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ https://bit.ly/3ReLHYh។

590 CMA, បុគ្គលិកមីក្រូហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងឥណទាន ៧៦% បានប្រលងជាប់កម្មវិធីផ្ដល់វិញ្ញាបនបត្រសម្រាប់ "ការផ្ដល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ" ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤, https://bit.ly/43HK4Kb។

# ឧបសម្ព័ន្ធ ខ. ខ្សែបន្ទាត់ពេលវេលាលម្អិតនៃ GIIP ដែលពាក់ព័ន្ធនៅក្នុងបរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា និងការវិនិយោគរបស់ IFC

**ឧបសម្ព័ន្ធខ. ខ្សែបន្ទាត់ពេលវេលាលម្អិតនៃGIIPដែលពាក់ព័ន្ធនៅក្នុងបរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា និងការវិនិយោគរបស់IFC**

**ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ(GIIP)ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គមមីក្រូហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគរបស់IFC នៅក្នុងសំណុំរឿងនេះ។**

- ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ដែលពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា
- ការវិនិយោគរបស់IFCដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ស៊ីអេអូ

2002

**ឆ្នាំ២០០២**
ក្រុមប្រឹក្សាយោបល់ដើម្បីជួយជនក្រីក្រ (CGAP) ដែល IFC និង WB ជាសមាជិក បានអនុម័តគោលការណ៍ណែនាំស្តីពីបទប្បញ្ញត្តិ និងការត្រួតពិនិត្យមីក្រូហិរញ្ញវត្ថុ

2003

**ឆ្នាំ២០០៣**
បណ្តាញ SEEP នៃសមាគមមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសជាច្រើន បោះពុម្ពផ្សាយបណ្តុំគោលការណ៍លើកដំបូងស្តីពីការធ្វើនិយ័តកម្មដោយខ្លួនឯង។

2004

**ឆ្នាំ២០០៤**
Accion អន្តរជាតិ អង្គការមិនស្វែងរកប្រាក់ចំណេញពិភពលោក ផ្តោតលើបរិយាប័ន្នហិរញ្ញវត្ថុ អនុម័តគោលការណ៍ធ្វើនិយ័តកម្មដោយខ្លួនឯងស្រដៀងគ្នា។

2005

**ឆ្នាំ២០០៥**
លេខ ២១៨៥៦៖ IFC ធ្វើការវិនិយោគភាគហ៊ុនចំនួន ២,១៨ MM (ភាគហ៊ុន ១៥,៩៩%) នៅ Advans B.A។ ត្រូវបានចាត់ថ្នាក់ជា FI។

2006

**ឆ្នាំ២០០៦**
FMO (ធនាគារអភិវឌ្ឍន៍សហគ្រិនភាពនៃប្រទេសហូឡង់) បង្កើតគោលការណ៍ណែនាំផ្ទៃក្នុងដើម្បីវាយតម្លៃអតិថិជនរបស់អ្នកផ្តល់សេវាហិរញ្ញវត្ថុ ដែលគ្របដណ្តប់លើការទប់ស្កាត់បំណុលវិណ្ណក ការធានាបាននូវការប្រមូលប្រាក់ប្រកបដោយទំនួលខុសត្រូវ និងការវាយតម្លៃ ការប្រកាន់ខ្ជាប់របស់ FI ចំពោះគោលការណ៍ណែនាំស្តីពីហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់ និង ឧត្តមានុវត្តន៍របស់ FMO។

2007

**ឆ្នាំ២០០៧**
CGAP និងអ្នកដឹកនាំឧស្សាហកម្មដទៃទៀត បង្កើតក្រុមការងារអនុវត្តការងារសង្គម (SPTF) ដើម្បីកសាង "ក្របខណ្ឌកំណត់ និងវាស់ស្ទង់ការអនុវត្តការងារសង្គមនៅក្នុងមីក្រូហិរញ្ញវត្ថុ"។

2008

**ឆ្នាំ២០០៨**
អ្នកដឹកនាំមីក្រូហិរញ្ញវត្ថុ រួមទាំង ធនាគារ Deutsch និង CGAP ចេញសេចក្តីប្រកាស Pocantico ស្តីពីតម្រូវការស្របសម្រាប់ក្រុមសួលធម៌ទូទាំងឧស្សាហកម្ម ដែលបែងចែកមីក្រូហិរញ្ញវត្ថុពីអ្នកផ្តល់សេវាហិរញ្ញវត្ថុដទៃទៀត។ សេចក្តីប្រកាស Pocantico គឺជាមូលដ្ឋានសម្រាប់គំនិតផ្តួចផ្តើមរបស់វិនិយោគិនកាន់តែទូលំទូលាយ ដើម្បីការពារអតិថិជនដែលមានប្រាក់ចំណូលទាប ពីការអនុវត្ត និងផលិតផលហិរញ្ញវត្ថុដែលអាចមានគ្រោះថ្នាក់។

ត

## ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិ (ចិញ្ចP) ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គមរបស់មីក្រូហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងសំណុំរឿងនេះ។

- ការវិវត្តនៃការអនុវត្តឧស្សាហកម្មល្អជាតិល្អ ដែលពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា
- ការវិនិយោគរបស់ IFC ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ស៊ីអេអូ

**2009**

**ឆ្នាំ២០០៩–២០១៩**

គោលការណ៍ការពារអតិថិជននៃយុទ្ធនាការឆ្លាតវៃ ត្រូវបានបោះពុម្ពផ្សាយ។

ចាប់ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០២០ យុទ្ធនាការឆ្លាតវៃសកល ដែលដឹកនាំដោយមជ្ឈមណ្ឌលបរិយាប័ន្នហិរញ្ញវត្ថុ (CFI) និងមានទីតាំងនៅក្នុងអង្គការ Accion អន្តរជាតិ International ត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងទំនួលខុសត្រូវ ដល់អ្នកប្រើប្រាស់ដែលទទួលបានសេវាមិនគ្រប់គ្រាន់។ យុទ្ធនាការនេះ ដែលបានដំណើរការរហូតដល់ឆ្នាំ២០២០ បានបង្កើតស្តង់ដារការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុសកលដំបូងគេ ក្នុងទម្រង់ជាគោលការណ៍ការពារអតិថិជន (CPPs) និងបានបង្កើតកម្មវិធីផ្តល់វិញ្ញាបនបត្រដ៏រឹងមាំមួយ សម្រាប់អ្នកផ្តល់សេវាហិរញ្ញវត្ថុ។ គោលការណ៍ទាំងនោះរួមមាន៖

1. **ការរចនាផលិតផល និងការផ្តល់សេវាសមស្រប ដើម្បីទប់ស្កាត់គ្រោះថ្នាក់**
2. **ការទប់ស្កាត់បំណុលវ័ណ្ឌ** (ការថែទាំគ្រប់គ្រាន់ ទាក់ទងនឹងសមត្ថភាពសងប្រាក់)
3. **តម្លាភាព** ដើម្បីអនុញ្ញាតឱ្យមានការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់
4. **ការកំណត់តម្លៃប្រកបដោយទំនួលខុសត្រូវ**
5. **ការប្រព្រឹត្តចំពោះអតិថិជនដោយយុត្តិធម៌ និងគោរព**
6. **ភាពឯកជននៃទិន្នន័យអតិថិជន**
7. **យន្តការសម្រាប់ដោះស្រាយពាក្យបណ្តឹង**

គោលការណ៍ទាំងនេះត្រូវបានអមមកជាមួយដោយឧបករណ៍ និងទម្រង់គំរូ ដើម្បីជួយស្ថាប័នហិរញ្ញវត្ថុក្នុងការអនុវត្ត ព្រមទាំងឧបករណ៍សម្រាប់អ្នកវាយតម្លៃឯករាជ្យ ដើម្បីពិនិត្យមើលការអនុវត្តរបស់ពួកគេ ការណែនាំអំពីឧត្តមានុវត្តន៍លើប្រធានបទជាក់លាក់ និងវគ្គបណ្តុះបណ្តាល ដើម្បីជួយសម្រួលដល់ការអនុម័ត។

**ឆ្នាំ ២០០៩**

ស្រេខ ២៧៨២៧៖ ការវិនិយោគភាគហ៊ុនរបស់ IFC នៅក្នុងឥណទានពង្រឹងមក្រូហិរញ្ញវត្ថុ (MEF) ចំនួន ១៥០ MM ដុល្លារអាមេរិក (ភាគហ៊ុន ២១,៦%)។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI។

**ឆ្នាំ ២០០៩**

ការវាយតម្លៃអំពីវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលផ្តល់មូលនិធិដោយធនាគារពិភពលោកនៅកម្ពុជា បានចងក្រងឯកសារថា "អសមត្ថភាពក្នុងការសងប្រាក់កម្ចី នៅពេលនេះ គឺជាកង្វល់ដ៏ធ្ងន់ធ្ងរមួយសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ [នៅកម្ពុជា] អ្នកឆ្លើយតបគ្រប់រូបបានរាយការណ៍ពីបំណុលមិនទាន់សងខ្នាតធំពីប្រភពជាច្រើន ដែលរួមមាន អ្នកផ្តល់ប្រាក់កម្ចីឯកជន សាច់ញាតិ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs)"។

**ឆ្នាំ ២០០៩**

បើកដំណើរការ វេទិកាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ដែលគ្រប់គ្រងដោយ IFC និងរួមបញ្ចូល DFIs ម្ចាស់ជំនួយសាធារណៈ រដ្ឋាភិបាល និយតករ និងអ្នកដទៃទៀត។ វេទិកាបានរួមបញ្ចូលគោលការណ៍ការពារអតិថិជននៃយុទ្ធនាការឆ្លាតវៃនៅក្នុងការងាររបស់ខ្លួន។

**2010**

**ឆ្នាំ ២០១០**

CGAP ធ្វើបច្ចុប្បន្នភាព និងបោះពុម្ពផ្សាយ "ការអនុវត្តគោលការណ៍ការពារអតិថិជន៖ មគ្គុទ្ទេសក៍ណែនាំផ្នែកបច្ចេកទេសសម្រាប់វិនិយោគិន" ដែលបានរួមបញ្ចូលបញ្ជីត្រួតពិនិត្យភាពត្រឹមត្រូវរបស់អតិថិជន សម្រាប់វិនិយោគិន។

**ឆ្នាំ ២០១០**

ប្រាក់កម្ចីលើកដំបូង ដែល MEF ផ្តល់ជូនធនាគារហត្ថា រហូតដល់ឆ្នាំ២០២២ ដោយប្រាក់កម្ចីចុងក្រោយត្រូវបានសងវិញនៅខែឧសភា ឆ្នាំ២០២២។

**ឆ្នាំ ២០១០**

ប្រាក់កម្ចីលើកដំបូង ដែល MEF ផ្តល់ជូនប្រាសាក់ តាមរយៈប្រាក់កម្ចីជាច្រើន រហូតដល់ឆ្នាំ២០២២ ដោយប្រាក់កម្ចីចុងក្រោយត្រូវបានសងនៅខែកក្កដា ឆ្នាំ ២០២៤។

**2011**

**ឆ្នាំ ២០១១**

IFC បញ្ជូនអនុស្សរណៈស្តីពីហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវទៅកាន់គណៈកម្មាធិការប្រតិបត្តិការសាជីវកម្ម (COC)

**ឆ្នាំ ២០១១**

CGAP បានបោះពុម្ពផ្សាយឯកសារមួយ ដែលគូសបញ្ជាក់ថា ឧស្សាហកម្ម MFI នៅកម្ពុជា មានហានិភ័យខ្ពស់ចំពោះការជំពាក់បំណុលវ័ណ្ឌក

**ឆ្នាំ ២០១១**

ចាប់ផ្តើមដំណើរការ គោលការណ៍សម្រាប់វិនិយោគិននៅក្នុងបរិយាប័ន្នហិរញ្ញវត្ថុ (PIIF) ក្នុងអំឡុងពេលនៃវេទិកាហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវលើកទី ២ នៅទីក្រុងឡាអេ (សហការរៀបចំដោយ IFC)។ PIFF ចាត់ទុកថា គោលការណ៍ការពារអតិថិជនមានសារៈសំខាន់ណាស់ និងជម្រុញឱ្យវិនិយោគិនធ្វើសមាហរណកម្មការការពារអតិថិជននៅក្នុងគោលនយោបាយ និងការអនុវត្តរបស់ពួកគេ។

ត

## ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិ(GIIP)ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គមមីក្រូហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងសំណុំរឿងនេះ។

- ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ដែលពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា
- ការវិនិយោគរបស់IFCដែលពាក់ព័ន្ធ និងការស៊ើបអង្កេតរបស់ស៊ីអេអូ

**2012**

**ឆ្នាំ២០១២**
SPTF បោះពុម្ពផ្សាយស្តង់ដារសកលសម្រាប់ការគ្រប់គ្រងការអនុវត្តការងារសង្គម (USSPM) ជាលើកដំបូង ដែលរួមបញ្ចូលគោលការណ៍ការពារអតិថិជននៃយុទ្ធនាការឆ្លាតវៃ។

**ឆ្នាំ ២០១២**
MEF ផ្តល់ប្រាក់កម្ចីលើកដំបូងដល់អម្រឹត បន្តដោយប្រាក់កម្ចីជាច្រើនទៀត ដោយប្រាក់កម្ចីចុងក្រោយត្រូវបានសងនៅខែមិថុនា ឆ្នាំ២០២៤។

**ឆ្នាំ២០១២**
ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ ខេមបូឌា (CBC) ជាគ្រឹះស្ថានឯកជនមួយ ត្រូវបានបង្កើតឡើងដោយមានការគាំទ្រពី IFC។

**ឆ្នាំ ២០១២**
លេខ ៣១៤៦៧៖ ការវិនិយោគភាគហ៊ុនរបស់ IFC នៅមូលនិធិគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុដើម្បីបំណុលអាស៊ី(MIFA) ចំនួន ២០ MM ដុល្លារ (ភាគហ៊ុន ១៥,២៦%)។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI។

**2013**

**ឆ្នាំ២០១៣**
វិទ្យាស្ថានអភិវឌ្ឍន៍កម្ពុជាបោះពុម្ពផ្សាយការសិក្សាមួយដែលគូសបញ្ជាក់ពីហានិភ័យនៃការជំពាក់បំណុលលើសលុប ក្នុងចំណោមអតិថិជនមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

**ឆ្នាំ ២០១៣**
MIFA ផ្តល់ប្រាក់កម្ចីលើកដំបូងដល់អម្រឹត បន្តដោយប្រាក់កម្ចីជាច្រើនទៀត រហូតដល់ឆ្នាំ២០២១ (គ្មានប្រាក់កម្ចីរបស់ MIFA នៅអម្រឹត ដែលមិនទាន់សងនោះទេ)។

**ឆ្នាំ២០១៣**
បានធ្វើការបញ្ជាក់ក្នុងរយៈពេលបីឆ្នាំ ហើយជាង ១២០ យុទ្ធនាការត្រូវបានបញ្ចប់នៅឆ្នាំ២០២០។

**ឆ្នាំ ២០១៣**
MIFA ផ្តល់ប្រាក់កម្ចីលើកដំបូងដល់អិលអូអិលស៊ី បន្តដោយប្រាក់កម្ចីជាច្រើនទៀត រហូតដល់ឆ្នាំ២០២១។ ប្រាក់កម្ចីចំនួន៥ នៅមិនទាន់បានសង។

**2014**

**ឆ្នាំ ២០១៤**
លេខ ៣៤៧៤៨៖ IFC ធ្វើការវិនិយោគភាគហ៊ុននៅអម្រឹតចំនួន ១៧,៥ MM ដុល្លារអាមេរិក (ភាគហ៊ុន ១៩,៩៩% - ថយចុះត្រឹម ១០% នៅឆ្នាំ ២០២៤) និងប្រាក់កម្ចីចំនួន ១០ MM ដុល្លារអាមេរិក។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-២។

**2015**

**ឆ្នាំ២០១៥**
TPK (ក្រោយមកជា អិលអូអិលស៊ី) ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាដំបូងគេ ដែលទទួលបានវិញ្ញាបនបត្រពីយុទ្ធនាការឆ្លាតវៃនៅខែមិថុនា ឆ្នាំ២០១៥។ នៅទីបំផុត MFIs កម្ពុជាដែលឈានមុខគេភាគច្រើន បានទទួលវិញ្ញាបនបត្រ។

**ឆ្នាំ ២០១៥**
MEF ផ្តល់ប្រាក់កម្ចីលើកដំបូងដល់អិលអូអិលស៊ី បន្តដោយប្រាក់កម្ចីជាច្រើនទៀត រហូតដល់ឆ្នាំ២០២០ ដោយប្រាក់កម្ចីចុងក្រោយត្រូវបានសងនៅខែតុលា ឆ្នាំ២០២៤។

**ឆ្នាំ២០១៥២០១៦**
ក្រុមការងារវិនិយោគិន SPTF បានបង្រួបបង្រួមកិច្ចខិតខំប្រឹងប្រែងរបស់វិនិយោគិនផ្សេងៗ ដើម្បីបង្កើតការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសង្គមតែមួយ - ការតម្រឹមការត្រួតពិនិត្យភាពត្រឹមត្រូវ និងការពិនិត្យតាមដានវិនិយោគិន ទៅនឹងស្តង់ដារសកល (ALINUS)។ ដោយបានបញ្ចប់នៅឆ្នាំ២០១៦ ឧបករណ៍នេះរួមបញ្ចូលសូចនាករចំនួន ៦៨ ដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់សម្រាប់ការវាយតម្លៃការអនុវត្តការងារសង្គមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

**ឆ្នាំ២០១៥**
IFC បោះពុម្ពសៀវភៅគោលនយោបាយស្តីពីការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា ដែលបង្ហាញថា ការជំពាក់បំណុលលើសលុប រួមជាមួយក្របខណ្ឌការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុទន់ខ្សោយ កើតឡើងទាំងចំពោះសេដ្ឋកិច្ចកម្ពុជា និងអ្នកប្រើប្រាស់ម្នាក់ៗ។

**2016**

**ឆ្នាំ ២០១៦**
CMAរៀបចំសិក្ខាសាលារយៈពេលមួយថ្ងៃ ជាលើកដំបូងនៃសិក្ខាសាលាប្រភេទនេះហៅថា "តោះ! និយាយអំពីបំណុលលើសលុប នៅពេលនេះ!"។ សិក្ខាសាលានេះរួមបញ្ចូលបទបង្ហាញដោយ M-CRIL, IMF, MIMOSA និងបទបង្ហាញដទៃទៀត។

ត

## ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិ (GIIP) ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គមនៃមីក្រូហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងសំណុំរឿងនេះ។

- ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ដែលពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា
- ការវិនិយោគរបស់ IFC ដែលពាក់ព័ន្ធ និងការស៊ើបអង្កេតរបស់ស៊ីអេអូ

**ឆ្នាំ ២០១៦**

CMA ដោយមានការគាំទ្រពីវិនិយោគិនសង្គម និង DFIs (ADA BIO FMO Incofin និង Proparco) ចាប់ផ្តើមដំណើរការគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី ដែលត្រូវបានអនុម័តដោយ CMA និងសមាជិកភាគច្រើន នៅខែធ្នូ ឆ្នាំ២០១៦។ អនុស្សរណៈនៃការយោគយល់គ្នានៃគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវ ត្រូវបានចុះហត្ថលេខា ដោយមានការត្រួតពិនិត្យពីក្រុមហ៊ុន ក្រេឌីត ប៊ុយរ៉ូ ខេមបូឌា (CBC)។ វិនិយោគិនជាង ២០ នាក់ រួមទាំង IFC បានចុះអនុម័តលើ MoU នេះ។

គោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីនេះ មានវិធានចំនួនបួន៖

1. ការពង្រឹងលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ទៅកាន់ CBC
2. ដែនកំណត់នៃពហុប្រាក់កម្ចី ដោយមានប្រាក់កម្ចីលក្ខណៈបុគ្គលចំនួន ២ ឬប្រាក់កម្ចីជាក្រុមចំនួន ៣ ជាអតិបរមា
3. ការទទួលស្គាល់ហានិភ័យនៃបុរេហិរញ្ញប្បទានប្រាក់កម្ចីដោយឈ្លានពាន (ចំណុចនេះត្រូវបានធ្វើបច្ចុប្បន្នភាព ដោយមានដែនកំណត់ជាក់លាក់ នៅឆ្នាំ២០១៨)
4. ការលើកកម្ពស់កិច្ចការពារអតិថិជន តាមរយៈ (i) ការទទួលស្គាល់សារៈសំខាន់នៃទ្រព្យសម្បត្តិដែលមានផលិតភាពចំពោះអតិថិជនដែលមានប្រាក់ចំណូលទាប និងគួរតែមានការផ្តល់ព័ត៌មានអំពីកត្តាខិតខំប្រឹងប្រែងដែលអាចធ្វើបានទាំងអស់ ដើម្បីបញ្ចៀសការលក់ទ្រព្យសម្បត្តិទាំងនោះ ជាពិសេសដីធ្លី ដើម្បីសងប្រាក់កម្ចី (ii) ការប្តេជ្ញាចិត្តត្រួតពិនិត្យគ្រោងការណ៍លើកទឹកចិត្ត ដើម្បីបង្កើនកិច្ចការពារអតិថិជនជាអតិបរមា នៅក្នុងដំណើរការផ្តល់ប្រាក់កម្ចី និងប្រមូលប្រាក់ (iii) ការប្តេជ្ញាចិត្តអភិវឌ្ឍ និងអនុវត្ត គោលនយោបាយច្បាស់លាស់សម្រាប់ការរៀបចំឥណទានឡើងវិញ និងការរៀបចំកាលវិភាគនៃការផ្តល់ប្រាក់កម្ចីឡើងវិញ សម្រាប់អតិថិជនដែលមិនអាចបំពេញតាមការសន្យាសងប្រាក់របស់ពួកគេបាន ស្របតាមគោលការណ៍ណែនាំនៃយុទ្ធនាការឆ្លាតវៃ និង (iv) កាត់បន្ថយបន្តិចម្តងៗនូវការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន ជាភ្នាក់ងារនៅក្នុងធនាគារនៃភូមិគ្រប់គ្រង ជាពិសេសសម្រាប់ការប្រមូលប្រាក់ដើម្បីបង់រំលោះ។ វិធានទាំងបួននេះមិនមានលក្ខខណ្ឌតម្រូវនៃរបាយការណ៍ជាក់លាក់ ឬគ្រោងការណ៍ត្រួតពិនិត្យនោះទេ។

**2017**

**ឆ្នាំ ២០១៧**

លេខ ៣៩១៦៧៖ IFC ផ្តល់ប្រាក់កម្ចី MSME ជាន់ខ្ពស់ ដល់ហត្ថាកសិករ លីមីតធីត បច្ចុប្បន្នជា ធនាគារហត្ថា ចំនួន ៥ MM ដុល្លារអាមេរិក ដែលត្រូវបានសង នៅខែមិថុនា ឆ្នាំ២០២២។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-3។

**2018**

**ឆ្នាំ ២០១៨**

លេខ ៤១២៩៤៖ IFC ផ្តល់ប្រាក់កម្ចី MSME ដល់អម្រឹត ចំនួន ១០ MM ដុល្លារអាមេរិក ដែលត្រូវបានសងនៅខែកក្កដា ឆ្នាំ២០២២។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-2។

**ឆ្នាំ២០១៨**

CMA បានធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី ដើម្បីរួមបញ្ចូលលក្ខខណ្ឌតម្រូវភាពអនុលោមជាភាតព្វកិច្ច សម្រាប់សូចនាករជាក់លាក់ សម្រាប់សមាជិក CMA ទាំងអស់ ដោយផ្អែកលើទិន្នន័យពិនិត្យតាមដាន ដែលផ្តល់ជូនដោយ CBC និងបន្ថែមការដាក់កម្រិតជាក់លាក់លើបុរេហិរញ្ញប្បទាន តាមរយៈការបង្កើតលក្ខខណ្ឌពេលវេលា ភាពញឹកញាប់ និងទំហំប្រាក់កម្ចី សម្រាប់បុរេហិរញ្ញប្បទាន។

**ឆ្នាំ ២០១៨**

លេខ ៣៨៦០៩៖ IFC ធ្វើការវិនិយោគភាគហ៊ុនឯកជននៅ North Haven Thai ចំនួន ១៥ MM ដុល្លារអាមេរិក (ភាគ ហ៊ុន ៣,៣៨%។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-2។

**ឆ្នាំ២០១៨**

យុទ្ធនាការឆ្លាតវៃគាំទ្រគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីរបស់ CMA និងការផ្ទៀងផ្ទាត់ភាពអនុលោម និងជាកាតព្វកិច្ចរបស់គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ដែលកំពុងព្យាយាមថែរក្សា (ឬទទួលបាន) វិញ្ញាបនបត្រឆ្លាតវៃនៅកម្ពុជា។

**ឆ្នាំ២០១៨**

MIFA ផ្តល់ប្រាក់កម្ចីដល់ស្ថាបនា ដែលមិនទាន់បានសង គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ។

**2019**

**ឆ្នាំ២០១៩**

ធនាគារពិភពលោកបានចេញ [កំណត់សម្គាល់គោលនយោបាយស្តីពីការដោះស្រាយពាក្យបណ្តឹង នៅក្នុងគោលការណ៍អ្នកផ្តល់សេវាហិរញ្ញវត្ថុ។]

**ឆ្នាំ២០១៩**

លេខ ៤២៤៨០៖ IFC ផ្តល់ប្រាក់កម្ចីគាំទ្រសម្រាប់សហគ្រាស ធុនតូច និងមធ្យម ដល់អេស៊ីលីដា ចំនួន ១១០ MM ដុល្លារ អាមេរិក ដោយផ្តោតលើផលបត្រការប្រាក់បន្ទាប់ពីកម្ចីភ្ជាប់អចលនទ្រព្យ និងសហគ្រាស ធុនតូច និងមធ្យមដែលគ្រប់គ្រងដោយស្ត្រី។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-2។

**ឆ្នាំ២០១៩**

ធនាគារពិភពលោកបានចេញ[កំណត់សម្គាល់គោលនយោបាយរបស់ប្រទេសកម្ពុជាស្តីពីមីក្រូហិរញ្ញវត្ថុ និងសុខមាលភាពគ្រួសារ] ដែលបានព្រមានអំពី "ការកើនឡើងយ៉ាងឆាប់រហ័សនូវផលធៀបបំណុលលើដោយសារការប្រើប្រាស់បំណុល [ដែល] បានលើកឡើងនូវកង្វល់កាន់តែច្រើនអំពីសមត្ថភាពសងបំណុលរបស់អ្នកខ្ចីជាច្រើននាក់។

**ឆ្នាំ២០១៩**

របាយការណ៍ការខូចខាតវត្ថុបញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានបោះពុម្ពផ្សាយដោយសមាគមធាងត្នោត និងលីកាដូ

**ត**

## ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ(GIIP)ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គមមីក្រូហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងសំណុំរឿងនេះ។

- ការវិវត្តនៃការអនុវត្តឧស្សាហកម្មល្អជាតិល្អ ដែលពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា
- ការវិនិយោគរបស់ IFC ដែលពាក់ព័ន្ធ និងការស៊ើបអង្កេតរបស់ស៊ីអេអូ

**2020**

**ឆ្នាំ២០២០**
លេខ ៤៤២៣១៖ IFC ផ្តល់ប្រាក់កម្ចីក្ស័យដែសម្រាប់ MSME ដល់អម្រឹត ចំនួន ២៥ MM ដុល្លារអាមេរិក ដោយផ្តោតលើ MSME ដែលគ្រប់គ្រងដោយស្ត្រី ដែលត្រូវបានសងវិញនៅឆ្នាំ ២០២៤។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-3។

**ឆ្នាំ ២០២០**
IFC រៀបចំរបាយការណ៍សន្ទស្សន៍មីក្រូហិរញ្ញវត្ថុនៃការផ្សព្វផ្សាយ និងតិត្ថិភាពទីផ្សារ (MIMOSA)។ របាយការណ៍នេះសន្និដ្ឋានថា ប្រទេសកម្ពុជាបានឈានដល់កម្រិតតិត្ថិភាពទីផ្សារអតិបរមា ដែលបានវាស់ស្ទង់ដោយសន្ទស្សន៍នេះ និងកត់សម្គាល់អំពី ទំហំប្រាក់កម្ចីកាន់តែធំ ការកើនឡើងនៃរយៈពេលសងប្រាក់កម្ចី ការចូលក្នុងទីផ្សារកម្រិតខ្ពស់ និងកង្វះខាតកិច្ចការពារអ្នកប្រើប្រាស់ និងលំនៅដ្ឋានគតយុត្ត។

**ឆ្នាំ២០២០**
លេខ ៤៤២១១៖ IFC ផ្តល់ប្រាក់កម្ចីក្ស័យដែសម្រាប់ MSME ជាន់ខ្ពស់ ដល់ធនាគារហត្ថា ចំនួន ២៥ MM ដុល្លារអាមេរិក ដោយផ្តោតលើ MSMEs ដែលគ្រប់គ្រងដោយស្ត្រី ដែលត្រូវបានសងនៅខែមិថុនាឆ្នាំ ២០២២។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-3។

**ឆ្នាំ ២០២០**
យុទ្ធនាការឆ្លាតវៃប្រកាសពីការបញ្ចប់របស់ខ្លួន រួមជាមួយការត្រួតពិនិត្យលើវិញ្ញាបនបត្រដែលមានស្រាប់ ដែលត្រូវបានផ្ទេរទៅឲ្យទីភ្នាក់ងារវាយតម្លៃដែលពាក់ព័ន្ធ។ គម្រោង និងសមាសធាតុទាំងអស់ត្រូវបានផ្ទេរទៅកាន់ CERISE+SPTF។

**2021**

**ឆ្នាំ២០២១**
CERISE+SPTF ចាប់ផ្តើមដំណើរការ គន្លងការពារអតិថិជន។ គន្លងនេះរួមបញ្ចូល វិញ្ញាបនបត្រ ដែលនឹងធ្វើឡើងនិងចេញដោយភ្នាក់ងារវាយតម្លៃដែលបានអនុម័ត។ គន្លងការពារអតិថិជនរួមបញ្ចប់ស្តង់ដារចំនួនប្រាំបី ដែលស្តង់ដារនីមួយៗមានវិសាលភាព និងគោលការណ៍ណែនាំផ្ទាល់ខ្លួនរបស់វា៖ ស្តង់ដារចំនួនប្រាំពីរ បានរួមបញ្ចូលនៅក្នុងយុទ្ធនាការឆ្លាតវៃ ហើយស្តង់ដារទន្ទ្រានបែងចែកថា អភិបាលកិច្ច និង ការគ្រប់គ្រងអ្នកផ្តល់សេវាហិរញ្ញវត្ថុបានប្តេជ្ញាចិត្តការពារអតិថិជន ដោយមានសវនកម្មផ្ទៃក្នុង និងប្រព័ន្ធធនធានមនុស្ស ដើម្បីគាំទ្រដល់ការអនុវត្តរបស់ខ្លួន។

**ឆ្នាំ ២០២១**
លេខ ៤៤៨៨២៖ IFC ផ្តល់ប្រាក់កម្ចី SME ដល់អេស៊ីលីដាចំនួន ១៦៩ MM ដុល្លារអាមេរិក ផ្តោតលើ SME ដែល គ្រប់គ្រងដោយស្ត្រី។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-2។

**ឆ្នាំ ២០២១**
លេខ ៤៥៥៣៥៖ IFC ផ្តល់ប្រាក់កម្ចីក្ស័យដែសម្រាប់ MSME ជាន់ ខ្ពស់ដល់ធនាគារ ហត្ថា ចំនួន ៧០ MM ដុល្លារអាមេរិក ដែលត្រូវ បានសងវិញនៅឆ្នាំ២០២៤។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-2។

**ឆ្នាំ២០២១**
អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផលប៉ះពាល់នៃបំណុលបរទេស និងកាតព្វកិច្ចហិរញ្ញវត្ថុអន្តរជាតិដែលពាក់ព័ន្ធដទៃទៀតរបស់រដ្ឋ លើការទទួលបានសិទ្ធិមនុស្សពេញលេញ អគ្គលេខាធិការអង្គការសហប្រជាជាតិ និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ក្នុងឆ្នាំ២០២០ ២០២១ និង ២០២២ សម្តែងការព្រួយបារម្ភអំពីផលវិបាកសង្គមអវិជ្ជមាននៃបំណុលវិណ្ឌក នៅកម្ពុជា។

**ឆ្នាំ២០២១**
លេខ ៤៤៧៤២៖ IFC ផ្តល់ប្រាក់កម្ចីក្ស័យដែសម្រាប់ MSME បន្ទាប់បន្សំដល់ធនាគារ ហត្ថា ចំនួន ៤០ MM ដុល្លារអាមេរិក។ គម្រោងត្រូវបានចាត់ថ្នាក់ជា FI-2។

**ឆ្នាំ២០២១**
សិទ្ធិទទួលបានជំនួយសង្គ្រោះ៖ របាយការណ៍បញ្ចេញមតិរបស់សហគមន៍ដីធ្លីដែលជំពាក់បំណុលត្រូវបានបោះពុម្ពផ្សាយដោយអង្គការសមធម៌កម្ពុជា និង លីកាដូ។

**ឆ្នាំ២០២១**
របាយការណ៍ផលប៉ះពាល់ និងការផ្សព្វផ្សាយរបស់ MIFA បានរកឃើញថា អ្នកឆ្លើយតបក្បាលស្ទង់មតិចំនួន ៧២% ឡើងទៅ នៅប្រទេសកម្ពុជា អះអាងថា គុណភាពជីវិតជារួម មានភាពប្រសើរឡើង បន្ទាប់ពីមានការផ្តល់ប្រាក់កម្ចីដោយ MFIs

**2022**

**ឆ្នាំ២០២២**
ABC CMA និងសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជាអនុម័តក្រមប្រតិបត្តិនៃវិស័យធនាគារ និងហិរញ្ញវត្ថុ ដែលតម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ ផ្លូវការទាំងអស់នៅក្នុងប្រទេស អនុលោមតាមគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី និងពិន័យតាមដានដោយ CBC។

**ឆ្នាំ២០២២**
ការវិនិយោគដោយ North Haven Thai នៅអេស៊ីលីដា។

**ឆ្នាំ២០២២**
នៅក្នុងរបាយការណ៍ស្តីពីប្រទេសកម្ពុជា ឆ្នាំ២០២២ អគ្គលេខាធិការអង្គការសហប្រជាជាតិបញ្ជាក់ថា ការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុបានបង្កើនភាពងាយរងគ្រោះរបស់ប្រជាជនដែលងាយរងគ្រោះរួចហើយ និងថា បំណុលសរុបដែលខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់ជាតិ មានចំនួនខ្ពស់បំផុតនៅលើពិភពលោក។

ការសិក្សាដែលធ្វើឡើងដោយក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច បានសម្គាល់ឃើញការកាត់បន្ថយអាហារដោយសារបំណុល ការលក់ដីធ្លី និងកុមារ ដែលបោះបង់ការសិក្សាដើម្បីទៅធ្វើការ និងជួយសងបំណុល ជាយន្តការទប់ទល់។

ត

## ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ (GIIP) ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់សង្គមរបស់មីក្រូហិរញ្ញវត្ថុ ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងសំណុំរឿងនេះ។

- ការវិវត្តនៃការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ដែលពាក់ព័ន្ធនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បរិបទមីក្រូហិរញ្ញវត្ថុកម្ពុជា
- ការវិនិយោគរបស់ IFC ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ ស៊ីអេអូ

**2022**

**ឆ្នាំ២០២២**
ABC CMA និងសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជាអនុម័តក្រមប្រតិបត្តិនៃវិស័យធនាគារ និងហិរញ្ញវត្ថុ ដែលតម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ ផ្តល់ការទាំងអស់នៅក្នុងប្រទេស អនុលោមតាមគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចី និងពិន័យតាមដានដោយ CBC។

**ឆ្នាំ២០២២**
ការវិនិយោគដោយ North Haven Thai នៅអេស៊ីលីដា។

**ឆ្នាំ២០២២**
នៅក្នុងរបាយការណ៍ស្តីពីប្រទេសកម្ពុជា ឆ្នាំ២០២២ អគ្គលេខាធិការអង្គការសហប្រជាជាតិបញ្ជាក់ថា ការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុបានបង្កើនភាពងាយរងគ្រោះរបស់ប្រជាជនដែលងាយរងគ្រោះរួចហើយ និងថា បំណុលសរុបដែលនៅជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់ជាតិ មានចំនួនខ្ពស់បំផុតនៅលើពិភពលោក។

ការសិក្សាដែលធ្វើឡើងដោយក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច បានសម្គាល់ឃើញការកាត់បន្ថយអាហារដោយសារបំណុល ការលក់ដីធ្លី និងកុមារ ដែលបោះបង់ការសិក្សាដើម្បីទៅធ្វើការ និងជួយសងបំណុល ជាយន្តការទប់ទល់។

**2023**

**ឆ្នាំ២០២៣**
CMA និង NBC រួមជាមួយ CERISE+SPIF ចាប់ផ្តើមដំណើរការគម្រោង "ហិរញ្ញវត្ថុមានសុវត្ថិភាព" នៅកម្ពុជា ដោយសង្កត់ធ្ងន់លើអត្ថកម្មផ្នែកហិរញ្ញវត្ថុ ការបណ្តុះបណ្តាលបុគ្គលិក និងប្រព័ន្ធដោះស្រាយពាក្យបណ្តឹងកាន់តែរឹងមាំ។

ក្នុងខែសីហា វិញ្ញាបនប័ត្រ CPP សម្រាប់ អេអឹមខេ អម្រឹត អិលអូអិលស៊ី និងស្ថាបនាត្រូវបានដាក់ឱ្យនៅក្រោមការត្រួតពិនិត្យ ដោយស្ថាប័នផ្តល់វិញ្ញាបនបត្ររបស់ពួកគេដាច់ដោយឡែកពីគ្នា។

ក្នុងខែវិច្ឆិកា ការសិក្សាមួយ ដែលរៀបចំដោយ CMA បានរកឃើញផលប៉ះពាល់សង្គមស្រដៀងគ្នានឹងការសិក្សាឆ្នាំ ២០២២ របស់រដ្ឋាភិបាលអាល្លឺម៉ង់។

CMA បានបង្កើតកិច្ចសន្យាស្តង់ដារ និងលក្ខខណ្ឌកិច្ចសន្យាស្តង់ដារសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ជាការប៉ុនប៉ងលើកកម្ពស់តម្លាភាព ប្រសិទ្ធភាព និងកិច្ចការពារអ្នកប្រើប្រាស់។

**ឆ្នាំ២០២៣**
របាយការណ៍ស្តីពីការគំរាមកំហែងបំណុល៖ ការសិក្សាបែបបរិមាណវិស័យលើអ្នកខ្ចីប្រាក់កម្ចីខ្នាតមីក្រូនៅកម្ពុជា ត្រូវបានបោះពុម្ពផ្សាយដោយអង្គការសមធម៌កម្ពុជា និង លីកាដូ។

**ឆ្នាំ២០២៣**
អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសានភាពសិទ្ធិមនុស្សនៅកម្ពុជា និងគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សម្តែងការព្រួយបារម្ភអំពីផលប៉ះពាល់សង្គមអវិជ្ជមាននៃការជំពាក់បំណុលវណ្ណក។

**2024**

**ឆ្នាំ២០២៤**
ក្រុមហ៊ុនទិន្នន័យផលប៉ះពាល់ ៦០ ដេស៊ីបែល ចេញផ្សាយការស្ទង់មតិលើអតិថិជន MFI ចំនួន ២.៩៣៩ នាក់នៅកម្ពុជា ដែលគ្របដណ្តប់លើក្រុមហ៊ុនផ្តល់សេវាហិរញ្ញវត្ថុធំជាងគេចំនួនដប់។ លទ្ធផលបានបញ្ជាក់ថាភាពតានតឹងក្នុងការសងប្រាក់មានកម្រិតខ្ពស់ក្នុងចំណោមអ្នកខ្ចីដែលនាំឲ្យមានការលះបង់និងផលប៉ះពាល់សង្គមអវិជ្ជមាន ដូចជាការលក់ដីនិងកុមារបោះបង់ការសិក្សា។

# ឧបសម្ព័ន្ធ គ. ទិដ្ឋភាពទូទៅនៃដំណើរការស៊ើបអង្កេតរបស់ស៊ីអេអូ

"*គោលបំណងនៃមុខងារភាពអនុលោមរបស់ស៊ីអេអូគឺ អនុវត្តការត្រួតពិនិត្យភាពអនុលោមរបស់ IFC/MIGA ចំពោះគោលនយោបាយ E&S [បរិស្ថាន និងសង្គម] វាយតម្លៃគ្រោះថ្នាក់ដែលពាក់ព័ន្ធ និងផ្តល់អនុសាសន៍អំពីវិធានការដោះស្រាយ តាមភាពសមស្រប*"។[591] មុខងារភាពអនុលោមមិនវាយតម្លៃភាពគ្រប់គ្រាន់ ឬភាពសមស្របនៃគោលនយោបាយ E&S ហើយក៏មិនបង្កើតគំហើញពាក់ព័ន្ធនឹងភាពអនុលោមរបស់គម្រោង អនុគម្រោង អតិថិជន ឬអតិថិជនបន្ត ចំពោះស្តង់ដារសមិទ្ធកម្មរបស់ IFC ដែរ។[592] ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងបំពេញតួនាទីរបស់ខ្លួន មុខងារភាពអនុលោមតាមរបស់ស៊ីអេអូនឹងវាយតម្លៃលើការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ IFC/MIGA លើលក្ខខណ្ឌតម្រូវ E&S របស់ខ្លួននៅកម្រិតគម្រោង ឬអនុគម្រោង និងពិចារណាលើសមិទ្ធកម្ម E&S កម្រិតគម្រោង ឬអនុគម្រោង។[593]

គួរឱ្យកត់សម្គាល់ថា ស៊ីអេអូមិនមានសិទ្ធិអំណាចពាក់ព័ន្ធនឹងដំណើរការតុលាការទេ។ ស៊ីអេអូមិនមែនជាសាលាឧទ្ធរណ៍ យន្តការអនុវត្តច្បាប់ ឬជំនួសប្រព័ន្ធតុលាការអន្តរជាតិ ឬប្រព័ន្ធតុលាការនៅក្នុងប្រទេសម្ចាស់ផ្ទះឡើយ។

ចាប់ពីការវាយតម្លៃរហូតដល់របាយការណ៍ស៊ើបអង្កេត ករណីភាពអនុលោមនេះសុទ្ធតែត្រូវបានរៀបចំឡើងស្របតាមគោលនយោបាយរបស់ស៊ីអេអូ។

## ការស៊ើបអង្កេត

ការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូផ្តោតលើ IFC/MIGA និងរបៀបដែលពួកគេធានាចំពោះសមិទ្ធកម្ម E&S របស់គម្រោង។ គោលបំណងនៃការស៊ើបអង្កេតភាពភាពអនុលោម គឺដើម្បីកំណត់៖

(១) ថាតើ IFC/MIGA បានអនុលោមតាមគោលនយោបាយ E&S របស់ខ្លួនដែរឬទេ និង

(២) ថាតើមានគ្រោះថ្នាក់ ឬគ្រោះថ្នាក់ដែលអាចកើតឡើង ពាក់ព័ន្ធនឹងបដិលោមភាពណាមួយរបស់ IFC/MIGA ដែរឬទេ។[594]

នៅក្នុងការវាយតម្លៃសមិទ្ធិកម្ម E&S របស់ IFC/MIGA ស៊ីអេអូតែងតែចាំបាច់ត្រូវត្រួតពិនិត្យលើសកម្មភាពរបស់អតិថិជនរបស់ IFC/MIGA និងផ្ទៀងផ្ទាត់ផលសម្រេចផ្នែក E&S នៅទីវាល។

## វិសាលភាព និងអភិក្រមវិធីសាស្ត្រ[595]

វិសាលភាពនៃការស៊ើបអង្កេតភាពអនុលោម ត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌយោង (TOR) នៃការស៊ើបអង្កេត

---

[591] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ៧៦

[592] Ibid., កថាខណ្ឌ ៧៧

[593] Ibid.

[594] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ១១២

[595] Ibid., កថាខណ្ឌ ១១៥ ១១៧ និង ១១៨។

ដែលត្រូវបោះពុម្ពផ្សាយរួមគ្នាជាមួយនឹងរបាយការណ៍វាយតម្លៃរបស់ស៊ីអេអូ។ ការស៊ើបអង្កេតភាពអនុលោមគឺផ្អែកលើព័ត៌មានដែលស៊ីអេអូទទួលបានពីឯកសារ កិច្ចសម្ភាស សេចក្តីថ្លែងការណ៍ របាយការណ៍ សារឆ្លើយឆ្លងគ្នា ការសង្កេតរបស់ស៊ីអេអូទៅលើសកម្មភាព និងលក្ខខណ្ឌនានា និងប្រភពដទៃទៀត ដែលស៊ីអេអូចាត់ទុកថាពាក់ព័ន្ធ។ របាយការណ៍ស៊ើបអង្កេតរបស់ស៊ីអេអូនឹងរួមបញ្ចូលគំហើញពីការស៊ើបអង្កេតពាក់ព័ន្ធនឹងភាពអនុលោម បដិលោមភាព និងគ្រោះថ្នាក់ណាមួយដែលពាក់ព័ន្ធ។ របាយការណ៍នេះក៏នឹងរួមបញ្ចូលបរិបទ ភស្តុតាង និងការលើកហេតុផល ដើម្បីគាំទ្រដល់គំហើញ និងសេចក្តីសន្និដ្ឋានរបស់ស៊ីអេអូ ពាក់ព័ន្ធនឹងមូលហេតុឫសគល់នៃបដិលោមភាពដែលបានកំណត់ផងដែរ។[596]

ភស្តុតាងពាក់ព័ន្ធគ្រប់គ្រាន់ គឺចាំបាច់ដើម្បីផ្តល់មូលដ្ឋានសមស្របសម្រាប់គំហើញ និងសេចក្តីសន្និដ្ឋានរបស់ស៊ីអេអូ។[597] ស៊ីអេអូនឹងមិនបង្កើតគំហើញ និងទាញសេចក្តីសន្និដ្ឋាន ដោយផ្អែកលើអត្ថប្រយោជន៍នៃហេតុការណ៍ដែលបានកើតឡើងរួចហើយនោះទេ។[598] ផ្ទុយទៅវិញ ស៊ីអេអូនឹងវាយតម្លៃថាតើមានភស្តុតាងថា IFC/MIGA បានអនុវត្តលក្ខខណ្ឌតម្រូវ E&S ដែលពាក់ព័ន្ធដែរឬទេ ដោយពិចារណាលើប្រភពព័ត៌មានដែលមាន នៅពេលដែលពួកគេធ្វើការសម្រេចចិត្ត។[599] លើសពីនេះទៀត ទោះបីជាស៊ីអេអូអាចស្វែងរកការបញ្ជាក់ ក្នុងអំឡុងពេលស៊ើបអង្កេតក៏ដោយ ក៏ស៊ីអេអូនឹងមិនទទួលយកការពង្រីកបន្ថែម លើសពីវិសាលភាពដែលបានកំណត់នៅក្នុង TOR នោះទេ។ ប្រសិនបើមានបញ្ហា ឬកង្វល់បន្ថែមលេចឡើង ក្នុងអំឡុងពេលស៊ើបអង្កេតនោះ បញ្ហា ឬកង្វល់ទាំងនេះអាចស្ថិតក្រោមការវាយតម្លៃដាច់ដោយឡែក ស្របតាមឆន្ទានុសិទ្ធិរបស់អគ្គនាយកស៊ីអេអូ។

ការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូមិនមែនជាដំណើរការតុលាការ ឬដំណើរការផ្លូវច្បាប់ឡើយ។[600] ស៊ីអេអូអនុវត្តតាមគំរូមិនមែនជាគូបដិបក្ខ ដោយខ្លួនធ្វើការ "ពិចារណាជាប្រព័ន្ធ និងដោយមិនលម្អៀង លើការពិតកាលៈទេសៈ ព័ត៌មាន និងភស្តុតាង ដែលពួកគេ*អាចទទួលបាន*ពីឯកសារ កិច្ចសម្ភាស សេចក្តីថ្លែងការណ៍ របាយការណ៍ សារឆ្លើយឆ្លង និងប្រភពដទៃទៀត ដែលស៊ីអេអូកំណត់ថាពាក់ព័ន្ធ" [បន្ថែមការសង្កត់ធ្ងន់]។[601] គំហើញ និងសេចក្តីសន្និដ្ឋានអំពីភាពអនុលោមរបស់ស៊ីអេអូ គឺផ្អែកលើភស្តុតាង "ពាក់ព័ន្ធគ្រប់គ្រាន់" ដែលអាចមាន។[602] លើសពីនេះទៀត នៅក្នុងដំណើរការមិនមែនគូបដិបក្ខ ស៊ីអេអូទទួលបានព័ត៌មានពីប្រភពជាច្រើន ហើយដើមបណ្តឹងមិនចាំបាច់ដាក់ភស្តុតាង ឬឯកសារគាំទ្រសម្រាប់ការចោទប្រកាន់របស់ពួកគេនោះទេ។ ទោះបីជាដើមបណ្តឹងអាចជ្រើសរើសផ្តល់ភស្តុតាងក៏ដោយ[603] ក៏នៅក្រោមគោលនយោបាយស៊ីអេអូ ការធ្វើបែបនេះមិន

---

[596] Ibid., កថាខណ្ឌ ១២០(ខ)

[597] Ibid., កថាខណ្ឌ ១១៧

[598] Ibid., កថាខណ្ឌ ១១៦

[599] Ibid.

[600] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ៩

[601] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ១១៥ និង ១១៧

[602] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ១១៧

[603] គោលនយោបាយរបស់ស៊ីអេអូ, កថាខណ្ឌ ៣២ និង ៣៤(ឃ)។

មែនជាលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យបណ្ដឹង ឬដើម្បីឱ្យស៊ីអេអូឈានដល់គំហើញអំពីបដិលោមភាព និង គ្រោះថ្នាក់ដែលពាក់ព័ន្ធនោះទេ។

គោលនយោបាយ E&S របស់ IFC កំណត់ទំនួលខុសត្រូវរបស់ IFC និងអតិថិជនរបស់ខ្លួនក្នុងការប្រមូលព័ត៌មាន ឬចងក្រងឯកសារអំពីសមិទ្ធកម្ម E&S របស់គម្រោង។[604] នៅក្នុងការវាយតម្លៃថាតើមានគ្រោះថ្នាក់ពាក់ព័ន្ធនឹង គំហើញអំពីបដិលោមភាពដែរឬអត់នោះ ស៊ីអេអូនឹងពិចារណាលើថាតើបដិលោមភាពរបស់ IFC បានរួមចំណែក ចំពោះភាពគ្មានទិន្នន័យ ឬព័ត៌មានដែលចាំបាច់ ដើម្បីផ្ទៀងផ្ទាត់ការចោទប្រកាន់របស់ដើមបណ្ដឹងអំពីគ្រោះថ្នាក់ ដែរឬទេ។ នៅក្នុងកាលៈទេសៈបែបនេះ ស៊ីអេអូអាចរកឃើញថា មាន "ការចង្អុលបង្ហាញអំពីគ្រោះថ្នាក់ដែល ពាក់ព័ន្ធ" នៅពេលដែលគ្រោះថ្នាក់តាមការចោទប្រកាន់របស់ដើមបណ្ដឹងបានកើតឡើង ឬអាចនឹងកើតឡើងនា ពេលអនាគត។

ពាក់ព័ន្ធនឹងគំហើញអំពីបដិលោមភាពរបស់ IFC/MIGA និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ ស៊ីអេអូនឹងផ្ដល់អនុសាសន៍ ឱ្យ IFC/MIGA ពិចារណា នៅក្នុងការរៀបចំផែនការសកម្មភាពរបស់គណៈគ្រប់គ្រង (MAP) ពាក់ព័ន្ធនឹងដំណោះ ស្រាយចំពោះបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ នៅកម្រិតគម្រោង ឬអនុគម្រោង និង/ឬជំហានដែល ចាំបាច់ ដើម្បីទប់ស្កាត់បដិលោមភាពនាពេលអនាគត តាមភាពពាក់ព័ន្ធ នៅក្នុងកាលៈទេសៈនានា។[605] អនុ សាសន៍នានានឹងពិចារណាលើភាពពាក់ព័ន្ធនៃការចាកចេញណាមួយរបស់ IFC/MIGA។[606]

## គំហើញអំពីគ្រោះថ្នាក់

ស្តង់ដារដែលត្រូវបានអនុវត្តនៅក្នុងការស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូ សម្រាប់ការវាយតម្លៃ "គ្រោះថ្នាក់" ដែលពាក់ព័ន្ធ មានចែងនៅក្នុងគោលនយោបាយស៊ីអេអូ។ គោលនយោបាយនេះកំណត់និយមន័យថា "គ្រោះ ថ្នាក់" ថាជា ផលប៉ះពាល់បរិស្ថាន និងសង្គមអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ ទៅលើមនុស្ស ឬបរិស្ថាន ដែលបណ្ដាលមកពី គម្រោង ឬអនុគម្រោងដោយផ្ទាល់ ឬដោយប្រយោល។ គ្រោះថ្នាក់អាចមានភាពជាក់ស្ដែង ឬទំនងជានឹងកើត ឡើងយ៉ាងសមហេតុផល នាពេលអនាគត។" ការយោងដល់ "គ្រោះថ្នាក់" ដែលមិនបានសរសេរជាអក្សរធំ គួរតែ ត្រូវបានអាន ស្របតាមអត្ថន័យធម្មតា និងតាមការប្រើប្រាស់ទូទៅនៃពាក្យនោះ។[607]

---

[604] ឧទាហរណ៍ សូមមើល គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០០៦, កថាខណ្ឌ ១៥ និង ២៦; PS1 ឆ្នាំ២០០៦ ៩, ១៤, ១៦, ២១, ២២, ២៤, ២៥, ២៦; គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០១២, កថាខណ្ឌ ២៨, ៤៥; PS1 ឆ្នាំ២០១២, កថាខណ្ឌ ៧, ១៤, ២៣, ២៤, ៣០ និង ៣៤។ សូមមើល គោលនយោបាយស៊ីអេអូ កថាខណ្ឌ ១១៤ ស្ដីពីតម្រូវការរបស់ស៊ីអេអូក្នុងការវាយតម្លៃការត្រួត ពិនិត្យ និងការគ្រប់គ្រងរបស់ IFC ចំពោះលក្ខខណ្ឌតម្រូវ E&S របស់ខ្លួន នៅកម្រិតគម្រោង និងអនុគម្រោង នៅពេលពិចារណាលើគំហើញ អំពីគ្រោះថ្នាក់។

[605] Ibid., កថាខណ្ឌ ១២០(គ)។

[606] Ibid.

[607] គោលនយោបាយស៊ីអេអូ, សន្ទានុក្រម និងជើងទំព័រទី២ នៅក្នុងគោលនយោបាយស៊ីអេអូ។

បន្ទាប់ពីមានគំហើញអំពីបដិលោមភាពរបស់ IFC/MIGA របាយការណ៍ស៊ើបអង្កេតភាពអនុលោមរបស់ស៊ីអេអូ នឹងធ្វើការវាយតម្លៃមួយក្នុងចំណោមការវាយតម្លៃគ្រោះថ្នាក់ដែលពាក់ព័ន្ធដូចខាងក្រោម៖

- មានគ្រោះថ្នាក់ចំពោះដើមបណ្តឹង។ សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើឡើង នៅពេលដែលមានភស្តុតាងពាក់ព័ន្ធគ្រប់គ្រាន់ដើម្បីផ្តល់មូលដ្ឋានសមហេតុផលសម្រាប់ការសន្និដ្ឋានអំពីភាពអនុលោមរបស់ស៊ីអេអូ។
- មានការចង្អុលបង្ហាញអំពីគ្រោះថ្នាក់ចំពោះដើមបណ្តឹង។ សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើឡើង ដោយផ្អែកលើភស្តុតាងដែលមាន ដែលនឹងចង្អុលបង្ហាញលទ្ធភាពដែលថា គ្រោះថ្នាក់មានភាពជាក់ស្តែង ឬទំនងជាបានកើតឡើងយ៉ាងសមហេតុផល ឬអាចកើតឡើងនាពេលអនាគត។ នៅពេលដែលបដិលោមភាពរបស់ IFC/MIGA បានរួមចំណែកដល់ភាពគ្មានទិន្នន័យ ឬព័ត៌មានដែលចាំបាច់សម្រាប់ផ្ទៀងផ្ទាត់ការចោទប្រកាន់របស់ដើមបណ្តឹងអំពីគ្រោះថ្នាក់នោះ ស៊ីអេអូអាចរកឃើញថា មាន "ការចង្អុលបង្ហាញអំពីគ្រោះថ្នាក់ដែលពាក់ព័ន្ធ" នៅពេលដែលគ្រោះថ្នាក់ដែលដើមបណ្តឹងបានលើកឡើង បានកើតឡើង ឬអាចកើតឡើងនាពេលអនាគត។
- មានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីឈានដល់សេចក្តីសន្និដ្ឋានអំពីគ្រោះថ្នាក់ចំពោះដើមបណ្តឹង។

## ការបញ្ចប់របាយការណ៍ស៊ើបអង្កេត

បន្ទាប់ទទួលបានមតិយោបល់ពី IFC/MIGA ទៅលើសេចក្តីព្រាងរបាយការណ៍ស៊ើបអង្កេតពី IFC/MIGA និងដើមបណ្តឹង ស៊ីអេអូនឹងបញ្ចប់របាយការណ៍ស៊ើបអង្កេតរបស់ខ្លួន។ នៅពេលដាក់របាយការស៊ើបអង្កេតជូនគណៈគ្រប់គ្រង IFC/MIGA ជាផ្លូវការហើយ និងបានផ្តល់ជូនដល់ក្រុមប្រឹក្សាភិបាលហើយ គេហ៍ទំព័ររបស់ស៊ីអេអូនឹងជូនដំណឹងដល់សាធារណជនអំពីការបញ្ចប់ការស៊ើបអង្កេត។[608]

បន្ទាប់ពីស៊ីអេអូដាក់របាយការណ៍ស៊ើបអង្កេតភាពអនុលោមជាផ្លូវការជូន IFC/MIGA រួចហើយ គណៈគ្រប់គ្រង IFC/MIGA មានពេល ៥០ថ្ងៃការងារ ដើម្បីដាក់របាយការណ៍របស់គណៈគ្រប់គ្រង ជូនក្រុមប្រឹក្សាភិបាលដើម្បីធ្វើការពិចារណា។ របាយការណ៍របស់គណៈគ្រប់គ្រងត្រូវតែរួមបញ្ចូល MAP ដើម្បីទទួលបានការអនុម័តរបស់ក្រុមប្រឹក្សាភិបាល។ MAP ពង្រាងសកម្មភាព ដែល IFC/MIGA ស្នើឡើង ដើម្បីឆ្លើយតបនឹងគំហើញពីការស៊ើបអង្កេតរបស់ស៊ីអេអូ។ IFC/MIGA ត្រូវតែពិគ្រោះយោបល់ជាមួយដើមបណ្តឹង និងអតិថិជន ក្នុងអំឡុងពេលដំណើរការរៀបចំ MAP របស់ខ្លួន។[609]

ក្នុងពេលជាមួយគ្នាដែល IFC/MIGA បង្ហាញ MAP ទៅកាន់ក្រុមប្រឹក្សាភិបាលដើម្បីទទួលបានការអនុម័ត ស៊ីអេអូនឹងផ្តល់មតិយោបល់ទៅលើ MAP ដែលបានស្នើ។ បន្ទាប់ពីក្រុមប្រឹក្សាភិបាលអនុម័តលើ MAP របាយការណ៍ស៊ើបអង្កេតភាពអនុលោម របាយការណ៍របស់គណៈគ្រប់គ្រង និង MAP នឹងត្រូវចុះផ្សាយនៅលើគេហទំព័ររបស់ស៊ីអេអូ។[610]

---

608 Ibid., កថាខណ្ឌ ១២៨

609 Ibid., កថាខណ្ឌ ១៣០-១៣១ និង ១៣៤

610 Ibid., កថាខណ្ឌ ១៣៥ និង ១៣៨

## ឧបសម្ព័ន្ធ ឃ៖ គំហើញរបស់ស៊ីអេអូអំពីបដិលោមភាព គ្រោះថ្នាក់ដែលពាក់ព័ន្ធ និងអនុសាសន៍

យោងតាមគោលនយោបាយស៊ីអេអូ ជាការឆ្លើយតបនឹងការស៊ើបអង្កេតភាពអនុលោមនេះ គណៈគ្រប់គ្រង IFC ត្រូវបានតម្រូវឲ្យរៀបចំរបាយការណ៍គណៈគ្រប់គ្រងមួយ។[611] ក្នុងគោលបំណងឆ្លើយតបនឹងគំហើញរបស់ស៊ីអេអូអំពីបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ បើមាន របាយការណ៍គណៈគ្រប់គ្រងនឹងរួមបញ្ចូលផែនការសកម្មភាពរបស់គណៈគ្រប់គ្រង (MAP) ដែលមានវិធានការដោះស្រាយមានពេលវេលាកំណត់ ដែលស្នើដោយគណៈគ្រប់គ្រង។[612] ម្យ៉ាងវិញទៀត របាយការណ៍គណៈគ្រប់គ្រងគួរតែរួមបញ្ចូលការឆ្លើយតបសមស្របចំពោះគំហើញ ឬអនុសាសន៍របស់ស៊ីអេអូអំពីបដិលោមភាព ឬគ្រោះថ្នាក់ដែលពាក់ព័ន្ធ ដែល IFC មិនអាចលើកឡើងនៅក្នុង MAP បាន។[613] ប្រសិនបើក្រុមប្រឹក្សាភិបាលអនុម័តលើ MAP ការពិនិត្យតាមដានរបស់ស៊ីអេអូនឹងផ្ទៀងផ្ទាត់ការអនុវត្តវិធានការដែលមានចែងនៅក្នុង MAP ប្រកបដោយប្រសិទ្ធភាព។[614] ការពិនិត្យតាមដានភាពអនុលោមរបស់ស៊ីអេអូនឹងមិនពិចារណាលើគំហើញអំពីបដិលោមភាព ដែលមិនមានវិធានការកែតម្រូវដែលពាក់ព័ន្ធ នៅក្នុង MAP នោះទេ។[615]

នៅក្នុងតារាង ឃ.១ គូឡោនដំបូងបង្ហាញពីគំហើញរបស់ស៊ីអេអូអំពីភាពអនុលោម និងការវាយតម្លៃលើគ្រោះថ្នាក់ដែលពាក់ព័ន្ធ។ គូឡោនទីពីរនឹងត្រូវបំពេញដោយស៊ីអេអូក្នុងអំឡុងពេលពិនិត្យតាមដានភាពអនុលោមនៃសំណុំរឿងនេះ ដោយឈរលើមូលដ្ឋាននៃផែនការសកម្មភាពរបស់គណៈគ្រប់គ្រង ដែលទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាលរបស់ IFC។

នៅក្នុងតារាង ឃ.២ ស្របតាមគោលនយោបាយស៊ីអេអូ[616] ដើម្បីឆ្លើយតបនឹងគំហើញរបស់ស៊ីអេអូអំពីបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ ស៊ីអេអូ

[611] គោលនយោបាយស៊ីអេអូ កថាខណ្ឌ ១៣០

[612] Ibid., កថាខណ្ឌ ១៣១

[613] Ibid., កថាខណ្ឌ ១៣២

[614] Ibid., កថាខណ្ឌ ១៤០

[615] Ibid., កថាខណ្ឌ ១៤១

[616] Ibid., កថាខណ្ឌ ១១៣។

ផ្តល់អនុសាសន៍ជាបន្តបន្ទាប់ ដើម្បីឲ្យ IFC ពិចារណា នៅពេលរៀបចំផែនការសកម្មភាពរបស់គណៈគ្រប់គ្រង។ អនុសាសន៍ទាំងនេះពាក់ព័ន្ធនឹងការកែតម្រូវបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធនៅកម្រិតគម្រោង ព្រមទាំងជំហានដែលចាំបាច់ ដើម្បីទប់ស្កាត់បដិលោមភាពនាពេលអនាគត។

## តារាង ឃ.១. គំហើញរបស់ស៊ីអេអូអំពីបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ ព្រមទាំងវិធានការដោះស្រាយរបស់ IFC ដែលពាក់ព័ន្ធ ឬយុត្តិកម្មការមិនអនុវត្តវិធានការដោះស្រាយ

ស៊ីអេអូរកឃើញថា ការត្រួតពិនិត្យមុនពេលវិនិយោគរបស់ IFC និងការត្រួតពិនិត្យការវិនិយោគទាំង ១៣ របស់ខ្លួន នៅក្នុងសំណុំរឿងនេះ មានបដិលោមភាពធ្ងន់ធ្ងរចំពោះទំនួលខុសត្រូវរបស់ខ្លួន នៅក្រោមក្របខណ្ឌនិរន្តរភាពដែលពាក់ព័ន្ធ។

ពាក់ព័ន្ធនឹងពាក្យបណ្ដឹង ដែលបានដាក់ជូនស៊ីអេអូ ការត្រួតពិនិត្យរបស់ IFC និងការត្រួតពិនិត្យការវិនិយោគទាំង ១៣ នៅក្នុងសំណុំរឿងនេះ មានភាពបរាជ័យនៅក្នុងផ្នែកនានា ដែលបានសង្ខេបនៅខាងក្រោម។ តារាងខាងក្រោមនេះសង្ខេបអំពីគំហើញរបស់ស៊ីអេអូពាក់ព័ន្ធនឹងភាពអនុលោមរបស់ IFC ចំពោះគោលនយោបាយ E&S របស់ខ្លួន និងការចោទប្រកាន់របស់ដើមបណ្ដឹងអំពីគ្រោះថ្នាក់ដោយសារបដិលោមភាពរបស់ IFC។

| គំហើញរបស់ស៊ីអេអូអំពីបដិលោមភាព និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ | វិធានការដោះស្រាយរបស់ IFC ឬយុត្តិកម្មការមិនអនុវត្តវិធានការដោះស្រាយរបស់ IFC |
| --- | --- |
| **ភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចនៅក្នុងក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ពាក់ព័ន្ធនឹងប្រជាជនងាយរងគ្រោះ** | |
| ស៊ីអេអូរកឃើញថា IFC មិនបានអនុវត្តទាំងការត្រួតពិនិត្យភាពត្រឹមត្រូវមុនពេលវិនិយោគ និងការត្រួតពិនិត្យការវិនិយោគ ដើម្បីតម្រូវឲ្យអតិថិជនរបស់ខ្លួនចាត់វិធានការកំណត់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុជាជនងាយរងគ្រោះ ដូចបានតម្រូវដោយ PS1 និងអនុវត្តការការពារដែលត្រូវបានកែសម្រួល តាមរយៈប្រព័ន្ធគ្រប់គ្រង E&S របស់ពួកគេ។ ស្របតាមគោលជំហររបស់ខ្លួនដែលថា អ្នកខ្ចីមីក្រូហិរញ្ញវត្ថុមិនមែនជាជនដែលរងផលប៉ះពាល់ ដែលវិធានការកាត់បន្ថយហានិភ័យ E&S ត្រូវអនុវត្តចំពោះ | |

ពួកគេនោះ IFC មិនបានតម្រូវឱ្យអតិថិជនរបស់ខ្លួនកំណត់ និងវាយតម្លៃភាពងាយរងគ្រោះរបស់អ្នកខ្ចីមីក្រូហិរញ្ញវត្ថុ និងគ្រួសាររបស់ពួកគេ ឬអនុម័តវិធានការកាត់បន្ថយដែលសមស្រប សម្រាប់ការវិនិយោគទាំងនេះទេ។

ស៊ីអេអូកត់សម្គាល់ថា ផលិតផលមីក្រូហិរញ្ញវត្ថុត្រូវបានរចនាសម្រាប់ប្រជាជនមួយផ្នែកបានទទួលសេវាមិនគ្រប់គ្រាន់ និងថា អ្នកខ្ចី និងគ្រួសាររបស់ពួកគេភាគច្រើនមានអក្ខរកម្មក្នុងការអាន ការសរសេរ ផ្នែកហិរញ្ញវត្ថុ និងច្បាប់នៅកម្រិតទាប ជាកត្តាដែលជះឥទ្ធិពលលើភាពងាយរងគ្រោះរបស់ប្រជាជន ឬគ្រួសារ។ ទោះបីជាយ៉ាងណាក៏ដោយ IFC បានចាត់ថ្នាក់គម្រោងទាំង ១៣ ថាមានហានិភ័យផ្នែកបរិស្ថាន និងសង្គមពីកម្រិតមធ្យមទៅទាប ដោយមិនគិតពីហានិភ័យ និងផលប៉ះពាល់សង្គមដែលបានចងក្រងជាឯកសារ លើអ្នកខ្ចីមីក្រូហិរញ្ញវត្ថុដែលងាយរងគ្រោះនៅកម្ពុជា រួមទាំងការបាត់បង់ដីធ្លី ការធ្លាក់ចុះនៃជីវភាពរស់នៅ និងការបាត់បង់លទ្ធភាពទទួលបានការអប់រំនោះទេ។ ហានិភ័យ និងផលប៉ះពាល់ទាំងនេះត្រូវបានចងក្រងជាឯកសារយ៉ាងទូលំទូលាយ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០ មក និងត្រូវបានទទួលស្គាល់ដោយក្រុមធនាគារពិភពលោក រួមទាំង IFC ផងដែរ។

ការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ IFC មិនបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់គោលនយោបាយនិរន្តរភាពនោះទេ (កថាខណ្ឌទី២២ ៣១-៣៥) ពីព្រោះវាមិនបានរួមបញ្ចូលការត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គមនៃសមត្ថភាពរបស់អតិថិជនក្នុងការគ្រប់គ្រងហានិភ័យសង្គមនៃមីក្រូហិរញ្ញវត្ថុលើជនងាយរងគ្រោះឲ្យបានគ្រប់គ្រាន់ ឬសមត្ថភាពរបស់ពួកគេក្នុងការធានាថា អនុគម្រោងរបស់ពួកគេមិនមានហានិភ័យសង្គមលើជនងាយរងគ្រោះតាមដែលអាចធ្វើបាននោះទេ។[617] ស៊ីអេអូយល់ឃើញថា កិច្ចខិតខំប្រឹងប្រែងរបស់ IFC នៅក្រោម*យុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ និងការការពារអ្នកប្រើប្រាស់*របស់ខ្លួន ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងការត្រួតពិនិត្យការវិនិយោគគឺមិនគ្រប់គ្រាន់ ដើម្បីធានាថា អតិថិជន និងអតិថិជនបន្តរបស់ខ្លួនបានបង្កើត និងអនុវត្តប្រព័ន្ធគ្រប់គ្រង ស្របតាម GIIP និងលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែល

[617] សម្រាប់ការវិនិយោគរបស់ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ១៧ និង ២៧-២៩។

ពាក់ព័ន្ធនោះទេ។ ជាពិសេស IFC មិនបានធានាថា អ្នកផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ បានបង្កើត និងអនុវត្ត ESMS ដែលមានសមត្ថភាពកំណត់អត្តសញ្ញាណបុគ្គល និងក្រុមដែលជួបការលំបាក ឬងាយរងគ្រោះ និងបានអនុវត្តវិធានការផ្សេងៗ ដើម្បីកុំឱ្យផលប៉ះពាល់អវិជ្ជមានធ្លាក់ទៅលើពួកគេដោយមិនសមាមាត្រនោះទេ។ [618] លើសពីនេះទៀត IFC មិនបានធានាថាអតិថិជនរបស់ខ្លួនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃ PS1 ដែលត្រូវអនុវត្តតាម និងធានាថា អតិថិជនបន្តបានអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែលហាមឃាត់អាជ្ញាធរមូលដ្ឋានមិនឲ្យផ្សព្វផ្សាយផលិតផលប្រាក់កម្ចី ការផ្តល់សេវាជាភ្នាក់ងារលក់ ឬការទាមទារឲ្យអ្នកខ្ចីសងប្រាក់នោះទេ។[619]

ដោយផ្អែកលើចំណុចខាងលើ ស៊ីអេអូយល់ឃើញថា IFC មិនបានបំពេញកាតព្វកិច្ចនៃគោលនយោបាយនិរន្តរភាពរបស់ខ្លួន ក្នុងការរៀបចំ និងអនុវត្តការវិនិយោគរបស់ខ្លួន ក្នុងគោលបំណង "មិនបង្កគ្រោះថ្នាក់" និងធានាថាសកម្មភាពអាជីវកម្មដែលខ្លួនផ្តល់ហិរញ្ញប្បទានបំពេញតាមលក្ខខណ្ឌតម្រូវនៃ PS1 ដែលពាក់ព័ន្ធ ជាពិសេស ការការពារក្រុមងាយរងគ្រោះ (កថាខណ្ឌ ៧ ៩ និង ២២) នោះទេ។

## ភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចនៅក្នុងក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច

ការស៊ើបអង្កេតរបស់ស៊ីអេអូបង្ហាញថា មុនពេលវិនិយោគ IFC មិនបានអនុវត្តក្របខណ្ឌនិរន្តរភាព ដើម្បីត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតឡើងលើជនជាតិដើមភាគតិច ឬកំណត់វិធានការកាត់បន្ថយដែលពាក់ព័ន្ធ នៅក្នុងការវិនិយោគដែលគ្របដណ្តប់ដោយសំណុំរឿងនេះទេ ដែលរួមបញ្ចូលអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការ

[618] ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌទី៣៣ និង ៣៥ និង PS1 កថាខណ្ឌទី៧ និង ១២។ សម្រាប់ការវិនិយោគរបស់ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌទី២៧-២៩ និង PS1 ឆ្នាំ២០០៦ កថាខណ្ឌទី៤ ៨ និង ១២។ សម្រាប់ការវិនិយោគរបស់ Advans សូមមើល ESRP ឆ្នាំ១៩៩៨ កថាខណ្ឌទី២២ ជើងទំព័រទី៧។

[619] ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៥ និងទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌ ៥។ សម្រាប់ការវិនិយោគរបស់ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ ២០០៦ កថាខណ្ឌទី២៨ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌទី៣ និងសម្រាប់ការវិនិយោគរបស់ Advans IFC OP ៤.០១ កថាខណ្ឌទី៩។

នៅក្នុងតំបន់ IP ភាគច្រើនផងដែរ។ ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ IFC បានពឹងផ្អែកលើការរាយការណ៍របស់អតិថិជនដោយផ្ទាល់ ដោយមិនមានចងក្រងឯកសារអំពីការផ្ទៀងផ្ទាត់ថា គម្រោងរបស់ពួកគេនឹងមិននាំមកនូវហានិភ័យនៃផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច ឬដីធ្លី និងបេតិកភណ្ឌវប្បធម៌របស់ពួកគេនោះទេ។

នៅខណៈពេលដែលគម្រោងទាំង ១៣ បានតម្រូវឱ្យមានការអនុវត្តបញ្ជីផាត់ចេញរបស់ IFC ដែលបញ្ជាក់ពីប្រភេទគម្រោងដែលស្ថាប័ននឹងមិនផ្តល់ហិរញ្ញប្បទាននោះ IFC បានធ្វើការត្រួតពិនិត្យមុនពេលវិនិយោគតិចតួច ចំពោះអតិថិជនដែលមានស្រាប់តែប៉ុណ្ណោះ។ នៅគ្រប់ករណីដែលស៊ីអេអូបានត្រួតពិនិត្យ IFC បានអនុវត្តបញ្ជីផាត់ចេញចំពោះផលប៉ះពាល់ដែលអាចកើតឡើងនៃអនុគម្រោង ប៉ុន្តែមិនមែនចំពោះសកម្មភាពរបស់អតិថិជន FI ដោយផ្ទាល់នោះទេ និងមិនមានភស្តុតាងដែលថា IFC បានផ្តល់ព័ត៌មានដល់អតិថិជនអំពីរបៀបដោះស្រាយដីធ្លី IP ដែលមិនមានការទទួលស្គាល់ជាផ្លូវការ ឬថាអតិថិជនយល់ពីរបៀបដោះស្រាយវានោះទេ។ ក្នុងអំឡុងពេលត្រួតពិនិត្យទីតាំង និងសម្ភាសជាមួយបុគ្គលិកសាខាងក្នុងមូលដ្ឋាន ជាពិសេសក្នុងតំបន់ដែលប្រជាជនភាគច្រើនជា IP នោះ ស៊ីអេអូបានសង្កេតឃើញថា បុគ្គលិក BFIs ដែលបានសម្ភាស ភាគច្រើន មានការយល់ដឹងស្រពិចស្រពិលអំពីលក្ខខណ្ឌតម្រូវនៃបញ្ជីផាត់ចេញ ដែលហាមឃាត់ពួកគេមិនឲ្យធ្វើសកម្មភាពដែលប៉ះពាល់ដល់ដីធ្លីរបស់ IP។

ក្នុងអំឡុងពេលត្រួតពិនិត្យ E&S, IFC បានពិនិត្យតាមដានរបៀបដែលអតិថិជនរបស់ខ្លួនបានអនុវត្តលក្ខខណ្ឌតម្រូវនៃបញ្ជីផាត់ចេញ ប៉ុន្តែបានផ្តល់ការប្រឹក្សា ឬការណែនាំជាឯកសារតិចតួចណាស់ អំពីបទប្បញ្ញត្តិនៃបញ្ជីនោះ ទាក់ទងនឹងជនជាតិដើមភាគតិច ដែលហាមឃាត់សកម្មភាពមីក្រូហិរញ្ញវត្ថុដែលប៉ះពាល់ដល់ដីសហគមន៍ជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីពួកគេនោះទេ។ ទោះបីជាក្នុងករណីដែលអតិថិជនបានរាយការណ៍ថា ចំណុចផាត់ចេញនៃ IP ជាមូលហេតុទូទៅមួយនៃការបដិសេធប្រាក់កម្ចីក៏ដោយ ក៏ IFC មិនបានស្នើសុំធ្វើការផ្ទៀងផ្ទាត់ពីរបៀបអនុវត្តបទប្បញ្ញត្តិទាំងនោះដែរ។ ការត្រួតពិនិត្យរបស់ស៊ីអេអូ លើគោលនយោបាយ និងការអនុវត្តរបស់អតិថិជន និង

| | |
|---|---|
| អតិថិជនបន្ត ក៏បានបង្ហាញពីករណីដែលប្លង់ដីទន់ពីអ្នកខ្ចីជាជនជាតិដើមភាគតិច ដែលត្រួតលើដីសហគមន៍ IP ត្រូវបានទទួលយកជាវត្ថុបញ្ចាំដោយមិនមានការយល់ព្រមពីសហគមន៍នោះទេ។ ការពឹងផ្អែកលើដីជាវត្ថុបញ្ចាំនេះបង្កើតហានិភ័យដែលអ្នកខ្ចីជាជនជាតិដើមភាគតិចនឹងប្រើប្រាស់ចំណែកផ្ទាល់ខ្លួននៃដីសហគមន៍ជាវត្ថុបញ្ចាំ ដើម្បីថែរក្សាលទ្ធភាពទទួលបានឥណទាន ដែលប៉ះពាល់ដល់ការការពារ ដែលបទប្បញ្ញត្តិនៃបញ្ជីផាត់ចេញមានបំណងផ្តល់ជូន។<br><br>ស៊ីអេអូយល់ឃើញថា IFC មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច និងធានាថា សកម្មភាពមីក្រូហិរញ្ញវត្ថុដែលខ្លួនផ្តល់ហិរញ្ញប្បទានមិនប៉ះពាល់ដល់ដីរបស់ពួកគេ ដោយមិនមានការយល់ព្រមជាឯកសារពេញលេញពីពួកគេ ស្របតាម PS7 (កថាខណ្ឌ ៨ និង ៩)[620] និងបញ្ជីផាត់ចេញរបស់ IFC នោះទេ។ ស៊ីអេអូក៏យល់ឃើញផងដែរថា IFC មិនបានធានាថា អតិថិជន និងអតិថិជនបន្តរបស់ខ្លួន បានអនុវត្តតាមច្បាប់ជាតិដែលពាក់ព័ន្ធស្តីពីការការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច (គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ៣៥ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌ ៥) នោះទេ។[621] | |
| **ភាពអនុលោមរបស់ IFC ចំពោះកាតព្វកិច្ចនៅក្នុងក្របខណ្ឌនិរន្តរភាពរបស់ខ្លួន ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានឧបាស្រ័យក្នុងការដោះស្រាយបណ្តឹងសារទុក្ខ** | |
| ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្នុងសំណុំរឿងនេះ ដំណើរការយន្តការបណ្តឹងសារទុក្ខ ដែលមានបំណងផ្តល់លទ្ធភាពទទួលបានសំណងដល់អ្នកខ្ចី និងរាយការណ៍ទៅកាន់ IFC អំពីយន្តការទាំងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកលើ | |

[620] សម្រាប់ការវិនិយោគរបស់ MEF, PS7 ឆ្នាំ២០០៦ កថាខណ្ឌ ៧ និង ៨។

[621] សម្រាប់ការវិនិយោគរបស់ MEF៖ គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌ ៣ និងសម្រាប់ការវិនិយោគរបស់ Advans IFC OP ៤.០១ កថាខណ្ឌ ៩។ ច្បាប់ជាតិដែលពាក់ព័ន្ធ រួមមាន មាត្រា ៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា (ឆ្នាំ២០០៦) បទបញ្ញាក្រសួង (ប្រកាស) លេខ ៥៥៦ សជណ. ស្តីពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ (ឆ្នាំ២០១៧) មាត្រា ១៩ នៃច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ (ឆ្នាំ២០១៩)។ ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ (នស/រកម/១១១៩/០១៦) និងអនុក្រឹត្យ (ប្រកាស) លេខ ធ៧-០១៧-២៩៩ ស្តីពីដំណោះស្រាយពាក្យបណ្តឹងរបស់អតិថិជន។

កំណត់ត្រាការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកបរិស្ថាន និងសង្គម និងការត្រួតពិនិត្យការវិនិយោគរបស់ IFC ស៊ីអេអូយល់ឃើញថា ជាទូទៅ IFC បានបញ្ជាក់យល់ព្រមលើអត្ថិភាពនៃយន្តការទាំងនេះដោយមិនមានការត្រួតពិនិត្យមុខងារ ឬភាពគ្រប់គ្រាន់របស់យន្តការទាំងនេះទេ។ ជាពិសេស ស៊ីអេអូយល់ថា មិនមានភស្តុតាងដែលថា IFC បានវាយតម្លៃថាតើបណ្តាញពាក្យបណ្តឹងរបស់ BFIs បានបំពេញតាមលក្ខខណ្ឌតម្រូវនៃ PS1 ដែរឬទេ រួមទាំងថាតើវាបានដំណើរការយ៉ាងឆាប់រហ័ស អាចប្រើប្រាស់បាន សមស្របតាមវប្បធម៌ មានតម្លាភាព និងមានសុវត្ថិភាព ក្នុងការទប់ស្កាត់ការសងសឹកបានដែរឬទេ។[622] ចាប់ពីឆ្នាំ២០២២ មក IFC បានផ្តល់ប្រឹក្សា និងការបណ្តុះបណ្តាលដល់អតិថិជនមួយចំនួនអំពីការទប់ស្កាត់ការគំរាមកំហែង និងការសងសឹកចំពោះអ្នកខ្ចី ដែលបានលើកឡើងនូវកង្វល់នានាតាមរយៈយន្តការទាំងនេះ។ នៅខណៈពេលដែលមានការអភិវឌ្ឍជាវិជ្ជមាននោះ ភាពស៊ីជម្រៅនៃយន្តការទាំងនេះនៅមានកម្រិត និងមិនត្រូវបានតាមដានដោយការគ្រប់គ្រងរបស់ IFC នោះទេ។

ដោយផ្អែកលើចំណុចខាងលើ ស៊ីអេអូយល់ឃើញថា IFC មិនបានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាថា អតិថិជន និងអតិថិជនបន្តបានបង្កើតយន្តការបណ្តឹងសារទុក្ខបានគ្រប់គ្រាន់ ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ឆ្នាំ ២០១២ (កថាខណ្ឌ ៣៥) និងមិនស្របតាម PS1 (កថាខណ្ឌ ៣៤ និង ៣៥) នោះទេ។[623] IFC ក៏មិនបានព្យាយាមធានាថា អតិថិជនរបស់ខ្លួនបានអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិថ្នាក់ជាតិ ទាក់ទងនឹងការដោះស្រាយពាក្យបណ្តឹងនៅស្ថាប័នហិរញ្ញវត្ថុ ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ (កថាខណ្ឌទី៣៥) PS (ទិដ្ឋភាពទូទៅ កថាខណ្ឌ៥) នោះដែរ។[624]

---

[622] PS1 ឆ្នាំ២០១២ កថាខណ្ឌ ៣៥, PS1 ឆ្នាំ២០០៦ កថាខណ្ឌ ២៣។

[623] សម្រាប់ការវិនិយោគរបស់ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨ និង ២៩, PS1 កថាខណ្ឌ ២៣។

[624] សម្រាប់ការវិនិយោគរបស់ MEF គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៨ ទិដ្ឋភាពទូទៅអំពី PS កថាខណ្ឌ ៣ និងសម្រាប់ការវិនិយោគរបស់ Advans IFC OP ៤.០១ កថាខណ្ឌ ៩។

| គ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងបដិលោមភាពរបស់ IFC | |
|---|---|
| ស៊ីអេអូរកឃើញគ្រោះថ្នាក់ចំពោះដើមបណ្ដឹងពាក់ព័ន្ធនឹងបដិលោមភាពខាងលើរបស់ IFC នៅក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងត្រួតពិនិត្យការវិនិយោគរបស់ខ្លួននៅអេស៊ីលីដា អេម្រឹត ធនាគារហត្ថា North Haven Thai, Advans, MEF និង MIFA។ ស៊ីអេអូយល់ថា IFC មិនបានរួមចំណែកដល់ការជៀសវាង ការកាត់បន្ថយ និង/ឬការដោះស្រាយគ្រោះថ្នាក់ដែលដើមបណ្ដឹងបានជួបប្រទះ ដោយសារការរៀបចំគម្រោង និងអនុគម្រោង ដោយគ្មានការកំណត់ និងកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ E&S ចំពោះប្រជាជនដែលរងផលប៉ះពាល់ពីគម្រោងឲ្យបានសមស្របនោះទេ។<br><br>ស៊ីអេអូរកឃើញគ្រោះថ្នាក់ដូចខាងក្រោម៖<br><br>a) ដើមបណ្ដឹងដប់ប្រាំនាក់ ដោយពួកគេភាគច្រើនមានភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចរួចហើយ បានរាយការណ៍ពីការធ្លាក់ចុះនៃជីវភាពរស់នៅ ក្រោយពេលលក់ដីកសិកម្ម ឬទ្រព្យសកម្មសម្រាប់បង្កើតប្រាក់ចំណូលដទៃទៀត ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ។ ពួកគេបានរៀបរាប់ថា ពួកគេលក់ទ្រព្យទាំងនេះដើម្បីឆ្លើយតបនឹងសម្ពាធពីការទារបំណុល ឬការភ័យខ្លាចថា អ្នកផ្ដល់ប្រាក់កម្ចីនឹងលក់ដេញថ្លៃដីដែលជាវត្ថុបញ្ចាំរបស់ពួកគេ ក្រោមតម្លៃទីផ្សារ។ ដើមបណ្ដឹងដប់មួយនាក់បានទាញអាគតដ្ឋានអំពី ការពឹងផ្អែកលើការធ្វើស្រែចម្ការជាប្រភពចំណូលចម្បងរបស់ពួកគេ ដែលក្នុងចំណោមពួកគេ ដើមបណ្ដឹងបួននាក់បានលក់ដីកសិកម្មរបស់ពួកគេទាំងអស់ ឬស្ទើរតែទាំងអស់ ដែលបង្ខំឱ្យពួកគេបោះបង់ចោលការធ្វើស្រែចម្ការ ហើយទៅស៊ីឈ្នួលប្រចាំថ្ងៃ ឬងាកទៅរកយន្តការទប់ទល់ប្រកបដោយគ្រោះថ្នាក់។ ដើមបណ្ដឹងបានរាយការណ៍ថា ការបាត់បង់ដី ឬទ្រព្យសកម្មដែលមានផលិតភាពបានកាត់បន្ថយសមត្ថភាពក្នុងការបង្កើតប្រាក់ចំណូលយ៉ាងខ្លាំង បង្កើនហានិភ័យក្នុងការធ្លាក់ចូលក្នុងភាពក្រីក្រ ឬធ្លាក់ចូលក្នុងភាពក្រីក្រកាន់តែជ្រៅ។<br><br>b) ក្នុងចំណោមដើមបណ្ដឹងទាំង ១៨ នាក់ ដើមបណ្ដឹងប្រាំមួយនាក់បានរាយការណ៍អំពីការកាត់បន្ថយគុណភាព និង | |

បរិមាណអាហារនៅក្នុងគ្រួសារដើម្បីសងបំណុល។ នៅក្នុង ១២ ករណី ដើមបណ្តឹងបានរាយការណ៍អំពី ការពន្យារពេលទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ ឬផលប៉ះពាល់ចំពោះសុខភាពផ្លូវចិត្ត រួមមាន ការគេងមិនលក់ ភាពថប់បារម្ភ ភាពបាក់ទឹកចិត្ត ការបាត់បង់ចំណង់អាហារ និងក្នុងករណីមួយចំនួន ការគិត ឬប៉ុនប៉ងធ្វើអត្តឃាត។ ដើមបណ្តឹងដប់នាក់បានបញ្ឈប់កូនៗរបស់ពួកគេពីសាលារៀនដើម្បីជួយសងបំណុល ហើយកុមារបានចូលធ្វើការនៅគ្រប់ករណី។ នៅក្នុងប្រាំពីរករណី ដើមបណ្តឹង ឬសមាជិកគ្រួសាររបស់ពួកគេបានធ្វើចំណាកស្រុកទៅកាន់ប្រទេស ឬតំបន់ដទៃទៀត ដើម្បីស្វែងរកការងារធ្វើ ដើម្បីសងប្រាក់កម្ចីរបស់ពួកគេ ដោយដើមបណ្តឹងបាននិយាយថា វានាំឲ្យមានការបែកពីគ្រួសារ ការរំខានដល់ការអប់រំរបស់កុមារ ការប្រឈមនឹងលក្ខខណ្ឌការងារមិនល្អ និងភាពងាយរងគ្រោះតាមយេនឌ័រជាក់លាក់។ នៅក្នុងករណីមួយចំនួន វាក៏បានបង្កើតភាពតានតឹងផ្នែកហិរញ្ញវត្ថុបន្ថែមទៀតដែរ។

c) ដើមបណ្តឹងដែលជាជនជាតិដើមភាគតិចបានរាយការណ៍ពីផលប៉ះពាល់អវិជ្ជមានបន្ថែមទៀត។ ដើមបណ្តឹងប្រាំពីរនាក់មកពីសហគមន៍ជនជាតិដើមភាគតិចដែលមានការទទួលស្គាល់ពីរដ្ឋាភិបាល បានរាយការណ៍ពីការលក់ដីដែលត្រូវគ្នានឹងដីសហគមន៍ដើម្បីសងបំណុលមីក្រូហិរញ្ញវត្ថុ ដែលបានកាត់បន្ថយមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ហើយក្នុងករណីមួយចំនួន បានប៉ះពាល់ដល់អត្តសញ្ញាណរបស់ពួកគេក្នុងនាមជាជនជាតិដើមភាគតិច។ ដីពីរចំណែក ក្នុងចំណោមដីដែលបានលក់ទាំងនេះ ត្រូវបានលក់ទៅឲ្យអ្នកដែលមិនមែនជាសមាជិកសហគមន៍។ ដោយហេតុថា ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច (ICLTs) ត្រូវបានបង្កើតឡើងដើម្បី "ការពារកម្មសិទ្ធិសមូហភាព" និង "ថែរក្សាអត្តសញ្ញាណ វប្បធម៌ [...] ទំនៀមទម្លាប់ និងប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចនីមួយៗនោះ" ស៊ីអេអូចាត់ទុកថា ការលក់ដីសហគមន៍ទៅឱ្យអ្នកដែលមិនមែនជាសមាជិកសហគមន៍ប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិចកាន់តែទូលំទូលាយ។ ស៊ីអេអូ សន្និដ្ឋានថា ចំណុចខ្វះខាតរបស់ IFC ទាក់ទងនឹងការពឹងផ្អែករបស់អ្នកផ្តល់ខ្ចីប្រាក់លើការប្រើប្រាស់ដីធ្លីជាវត្ថុបញ្ចាំ និងការទទួលយកវត្ថុបញ្ចាំដែលត្រូវគ្នានឹងដីរបស់ជនជាតិដើមភាគតិច ដែលស្ថិតក្រោមការការពារ បានធ្វើឱ្យខូចដំណើរការ ICLT ប៉ះពាល់

| | |
|---|---|
| ដល់សុចរិតភាពនៃដីសហគមន៍ជនជាតិដើមភាគតិច បានរួមចំណែកដល់ជម្លោះក្នុងសហគមន៍ និងមានផលប៉ះពាល់អវិជ្ជមានដល់អត្តសញ្ញាណ និងវប្បធម៌របស់ជនជាតិដើមភាគតិច។<br>d) ដើមបណ្ដឹងគ្រប់រូប លើកលែងតែដើមបណ្ដឹងម្នាក់ បានរាយការណ៍ថា មន្ត្រីដែលមកពីអតិថិជន និងអតិថិជនបន្តរបស់ IFC បានគំរាមកំហែងពួកគេដោយសកម្មភាពសងសឹកនានា ដូចជា ការនាំទៅជួបអាជ្ញាធរមូលដ្ឋាន នគរបាល ឬតុលាការ ឬមានការរឹបអូសយកដីធ្លី ឬផ្ទះសម្បែងរបស់ពួកគេ ហើយលក់វាក្រោមតម្លៃទីផ្សារ។ កលយុទ្ធទាំងនេះត្រូវបានរាយការណ៍ថា បានបង្កឱ្យមានបរិយាកាសនៃភាពភ័យខ្លាច ធ្វើឲ្យអ្នកខ្ចីស្ទាក់ស្ទើរក្នុងការចូលទៅជួបអ្នកផ្ដល់ប្រាក់កម្ចីដើម្បីស្វែងរកជម្រើសដំណោះស្រាយ និងនាំឲ្យពួកគេប្រើយន្តការទប់ទល់ដែលមានគ្រោះថ្នាក់។ លើសពីនេះទៀត ដើមបណ្ដឹងដែលបានព្យាយាមប្រើយន្តការបណ្ដឹងសារទុក្ខ បានរាយការណ៍ថា ដំណើរការនៃយន្តការនេះបានក្លាយជាប្រភពនៃការគំរាមកំហែង និងការបៀតបៀន។ ស៊ីអេអូក៏បានកត់សម្គាល់ផងដែរថា ស្ត្រីជាដើមបណ្ដឹងបីនាក់បានរាយការណ៍ពីវត្តមានរបស់បុរសជាមន្ត្រី BFI នៅក្នុងផ្ទះរបស់ពួកគេយ៉ាងយូរ នៅខណៈពេលដែលពួកគេនៅម្នាក់ឯង ដែលពួកគេយល់ឃើញថា វាជាទម្រង់មួយនៃការបំភិតបំភ័យបន្ថែមទៀត។ | |

## តារាង ឃ.២. អនុសាសន៍កម្រិតគម្រោង និងជាប្រព័ន្ធរបស់ស៊ីអេអូ

| អនុសាសន៍កម្រិតគម្រោង |
| --- |
| 1. IFC **គួរតែធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីរៀបចំ និងអនុវត្តកម្មវិធីដែលមានប្រសិទ្ធភាពមួយ ដើម្បីវាយតម្លៃ ពង្រឹង និងដោះស្រាយអសាធនភាព និងការជំពាក់បំណុលរបស់ដើមបណ្តឹងម្នាក់ៗ រួមទាំងដើមបណ្តឹងទាំង ១៨ នាក់ ដែលដាក់ពាក្យបណ្តឹងនេះផងដែរ។** ជម្រើសក្នុងការដោះស្រាយគួរតែរួមមាន ការផ្អាកសងប្រាក់ ការលើកលែងការប្រាក់ ឬបំណុលដែលជំពាក់ ការរៀបចំឥណទានឡើងវិញ បុនហិរញ្ញប្បទានដោយមិនបង្កើនបំណុល ការគាំទ្រចំពោះមុខរបរចិញ្ចឹមជីវិត ឬការងារ ឬវិធានការសមស្របដទៃទៀត អាស្រ័យលើស្ថានភាពរបស់អ្នកខ្ចីម្នាក់ៗ។ កម្មវិធីទាំងនេះក៏គួរតែពិចារណាលើ៖<br>a. **ការប្រមូលទិន្នន័យមូលដ្ឋាន និងបណ្តុំព័ត៌មានសេដ្ឋកិច្ចសង្គមរបស់អ្នកខ្ចីបន្ត** រួមទាំងការប្រឈមនឹងប្រាក់កម្ចី អត្រាការប្រាក់ សមត្ថភាពសងប្រាក់ និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គម តាមរយៈទីភ្នាក់ងារដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីធានាបាននូវទំនុកចិត្ត និងការចូលរួមរបស់សហគមន៍។<br>b. ការស្វែងយល់ពីរាល់**ជម្រើសក្នុងការរៀបចំឥណទានឡើងវិញ បុនហិរញ្ញប្បទាន ឬការលើកលែង** សម្រាប់អ្នកខ្ចីដែលរងផលប៉ះពាល់ដែលមានការលំបាកផ្នែកហិរញ្ញវត្ថុដែលអាចផ្ទៀងផ្ទាត់បាន និងការ**ពិចារណាលើផ្លូវចេញសម្រាប់អ្នកជំពាក់បំណុល។** ផ្លូវចេញសម្រាប់អ្នកជំពាក់បំណុលអាចរួមមាន ការធ្វើផែនការគ្រប់គ្រងបំណុលបុគ្គល ការសំដៅលើគំនិតផ្តួចផ្តើមបង្កើតប្រាក់ចំណូល ការប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុ និងការជួយអ្នកខ្ចីដោយយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីកាត់បន្ថយការពឹងផ្អែកលើឥណទាន។<br>c. **ចាប់ដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលនៅតាមសហគមន៍**ដើម្បីបង្កើតបណ្តាញទំនាក់ទំនងជាមួយអ្នកខ្ចី ពិនិត្យតាមដានការអនុវត្តការផ្តល់ប្រាក់កម្ចី និងលើកកម្ពស់ការចូលរួមដ៏មានអត្ថន័យរបស់ភាគីពាក់ព័ន្ធនៅគ្រប់ពេលនៃការវិនិយោគរបស់ IFC។ ភាពជាដៃគូក៏អាចផ្តល់នូវ**ការគាំទ្រដល់មុខរបរចិញ្ចឹមជីវិត និងការងារ** និងភ្ជាប់ទំនាក់ទំនងរវាងអ្នកខ្ចី និងទីផ្សារការងារដែលពាក់ព័ន្ធបានដែរ (ឧទាហរណ៍ |

តាមរយៈការរៀបចំពិព័រណ៍ការងារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសកម្មភាពចូលរួមរបស់និយោជក ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន)។

IFC អាចទាញយកអត្ថប្រយោជន៍ពីការព្រមព្រៀងនៃកិច្ចសន្យា និងឥទ្ធិពលនៃកេរ្តិ៍ឈ្មោះរបស់ខ្លួន ដើម្បីធានាថាមានការចូលរួមពីអតិថិជន និងការសហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលគួរឱ្យទុកចិត្ត ដើម្បីធ្វើការវាយតម្លៃអ្នកខ្ចី និងផ្តល់ការគាំទ្រដល់មុខរបរចិញ្ចឹមជីវិត។ IFC ក៏អាចប្រមូលផ្តុំបរធនរបស់ម្ចាស់ជំនួយ ឬធនធាននៃសេវាទីប្រឹក្សារបស់ខ្លួន ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការប្រឹក្សាអំពីបំណុល ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការពិនិត្យតាមដាន។

2. IFC **គួរតែបន្តកិច្ចខិតខំប្រឹងប្រែងផ្តល់ការគាំទ្រដល់ការបង្កើតយន្តការពាក្យបណ្តឹងឯករាជ្យ[625] សម្រាប់អ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជា** ដែលអនុវត្តតាមការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ ស្របតាមលក្ខខណ្ឌតម្រូវនៃ PS1។ យន្តការគួរតែឯករាជ្យពីគ្រឹះស្ថានហិរញ្ញវត្ថុ និងបុគ្គលសម្ព័ន្ធរបស់ពួកគេ ក្នុងការធ្វើអភិបាលកិច្ច និងការធ្វើប្រតិបត្តិការ ហើយ FIs គួរតែប្តេជ្ញាចិត្តអនុលោមតាម និងអនុវត្តដំណោះស្រាយរបស់ខ្លួន។ IFC បានចាប់ផ្តើមធ្វើការជាមួយសមាគមធនាគារកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងដៃគូអភិវឌ្ឍន៍ដទៃទៀតនៅឆ្នាំ២០២៤ ដើម្បីបង្កើតយន្តការសម្រាប់វិស័យនេះ។ IFC អាចកោះប្រជុំដៃគូទាំងនេះរួមជាមួយធនាគារជាតិនៃកម្ពុជា (NBC) DFIs ដទៃទៀត និងសង្គមស៊ីវិល ដើម្បីរួមគ្នារចនាគំរូដែលមានប្រសិទ្ធភាព។[626]

3. IFC **គួរតែធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយលើគោលនយោបាយ និងការអនុវត្តរបស់គ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ** ដែលពាក់ព័ន្ធនឹងសំណុំរឿងនេះ ដើម្បី៖
   a. កំណត់ និងដោះស្រាយចន្លោះប្រហោងនៃ PS1 និង PS7 រួមទាំង GIIP ដែលពាក់ព័ន្ធ និងពង្រឹងសមត្ថភាពរបស់អតិថិជន និងអតិថិជនបន្តផងដែរ

[625] យន្តការបណ្តឹងដែលដំណើរការដោយឯករាជ្យ គួរតែដំណើរការដោយគ្មានការជះឥទ្ធិពល ឬការគ្រប់គ្រងពីភាគីដែលមានសក្តានុពល ចំពោះពាក្យបណ្តឹងដែលវាអាចទទួលបាន។
[626] ជម្រើសនៃការផ្តល់មូលនិធិអាចរួមមាន គំរូចម្រុះនៃការរួមចំណែករបស់ម្ចាស់ជំនួយ ពន្ធ MFI និងការគាំទ្រពីដៃគូអភិវឌ្ឍន៍។

b. តម្រូវឱ្យអតិថិជនរួមបញ្ចូលលក្ខណៈវិនិច្ឆ័យនៃសមិទ្ធកម្មសង្គម លើសពីប្រាក់កម្ចីដែលបានអនុម័ត ឬបំណុលដែលបានប្រមូល នៅក្នុងគម្រោងលើកទឹកចិត្តសម្រាប់មន្ត្រីឥណទាន/មន្ត្រីប្រមូលប្រាក់ និងអ្នកគ្រប់គ្រង។

4. IFC **គួរតែបង្កើតកម្មវិធីបណ្តុះបណ្តាលអតិថិជន** ដើម្បីពង្រឹងយន្តការបណ្តឹងសារទុក្ខជាប្រព័ន្ធ នៅកម្រិតអតិថិជន និងអតិថិជនបន្ត ដោយផ្តោតលើការបង្កើតឧបករណ៍ និងអភិវឌ្ឍសមត្ថភាពក្នុងការដោះស្រាយវិវាទ ដោយទប់ស្កាត់ការគំរាមកំហែង ការបៀតបៀន ឬការសងសឹកចំពោះអ្នកខ្ចី។ ស្របពេលជាមួយគ្នានេះ ផ្តល់ការបណ្តុះបណ្តាលឯកទេស ស្របតាម GIIP ដល់មន្ត្រីឥណទាន និងមន្ត្រីប្រមូលប្រាក់ ដោយគ្របដណ្តប់ការវាយតម្លៃយ៉ាងត្រឹមត្រូវលើសមត្ថភាពសងប្រាក់ និងការយល់ដឹងអំពីលក្ខខណ្ឌតម្រូវរបស់ IFC ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច និងរបៀបបញ្ចៀសការខូចខាត ក្នុងការអនុវត្តការផ្តល់កម្ចី និងការប្រមូលប្រាក់របស់ពួកគេ។ IFC គួរតែតម្រូវឲ្យរបាយការណ៍តាមដានការអនុវត្ត។

5. IFC **គួរតែធ្វើការជាមួយអតិថិជនដើម្បីបង្កើត និងអនុវត្តកម្មវិធីផ្តល់ភាពអង់អាចផ្នែកហិរញ្ញវត្ថុ** សំដៅលើ (i) កសាងការយល់ដឹង និងសមត្ថភាពរបស់អ្នកខ្ចីដែលងាយរងគ្រោះ ក្នុងការចូលរួមជាមួយ BFIs និង (ii) អភិវឌ្ឍការប្រាស្រ័យទាក់ទង និងឯកសារព័ត៌មានអំពីប្រាក់កម្ចីដែលអាចប្រើប្រាស់បាន សម្រាប់អ្នកខ្ចី។ ការបណ្តុះបណ្តាលគួរតែត្រូវបានកែសម្រួលតាមកម្រិតភាសា និងអក្ខរកម្មនៅក្នុងមូលដ្ឋាន និងផ្តល់ជូនដោយទីភ្នាក់ងារ ឬអង្គការមិនមែនរដ្ឋាភិបាល ដោយមានវត្តមានសហគមន៍ ដែលត្រូវបានបង្កើតឡើង។ ខ្លឹមសារគួរតែរួមបញ្ចូលការខ្ចីប្រាក់ដោយមានព័ត៌មានគ្រប់គ្រាន់ ហានិភ័យនៃបំណុលវណ្ណែក លក្ខខណ្ឌនៃប្រាក់កម្ចី យន្តការបណ្តឹងសារទុក្ខ និងសិទ្ធិរបស់អ្នកខ្ចី ក្នុងគោលបំណងធ្វើឲ្យអ្នកខ្ចីអាចធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ និងចូលរួមប្រកបដោយការស្ថាបនា ជាមួយ BFIs។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ IFC គួរតែគាំទ្រឲ្យអតិថិជន និងអតិថិជនបន្តបង្កើតសំណុំឯកសារប្រាក់កម្ចី និងការប្រាស្រ័យទាក់ទងរបស់អ្នកខ្ចី ដែលអាចប្រើប្រាស់បាន មានភាពសមស្របផ្នែកវប្បធម៌ និងត្រូវបានបង្ហាញជាភាសាក្នុងស្រុក ដើម្បីធានាបាននូវការយល់ព្រមដោយមានព័ត៌មានគ្រប់គ្រាន់ និងការយល់ដឹងរបស់អ្នកខ្ចីអំពីសិទ្ធិ និងកាតព្វកិច្ច។

## អនុសាសន៍ជាប្រព័ន្ធ

1. **អភិវឌ្ឍសមត្ថភាព និងឧបករណ៍ ព្រមទាំងបង្កើនជំនាញផ្ទៃក្នុង ដើម្បីរៀបចំ និងអនុវត្តដំណើរការ សម្រាប់ប្រើប្រាស់ក្នុងអំឡុងពេលត្រួតពិនិត្យភាពត្រឹមត្រូវ និងគ្រប់គ្រងគម្រោង ដើម្បីកំណត់ក្រុមងាយរងគ្រោះ និងវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនៃការវិនិយោគពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុ។** ដំណើរការនេះគួរតែវាយតម្លៃសមត្ថភាព និងបទពិសោធន៍របស់អតិថិជនក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនៃ GIIP ទាក់ទងនឹងអ្នកខ្ចីដែលងាយរងគ្រោះ និងជនជាតិដើមភាគតិចផងដែរ។ ក្នុងអំឡុងពេលគ្រប់គ្រង IFC គួរតែតម្រូវឲ្យ FIs រួមបញ្ចូលបណ្តុំព័ត៌មានអំពីសំណាកតំណាងឲ្យអ្នកខ្ចីឥណទានខ្នាតតូច (ឧ. រួមជាមួយចំនួនប្រាក់កម្ចី និងរយៈពេល អត្រាការប្រាក់ ការទូទាត់សង ភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុ និងកម្រិតទុក្ខព្រួយ និងរបៀបដែលបុគ្គលិក FI ធ្វើអន្តរកម្មជាមួយសហគមន៍) នៅក្នុងរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំរបស់ពួកគេ។ ការរួមបញ្ចូលបែបនេះនឹងជួយ IFC តាមដានលទ្ធផលរបស់អ្នកខ្ចី និងធានាថាអតិថិជនអនុវត្តស្របតាមស្តង់ដារសមិទ្ធកម្ម GIIP និងច្បាប់ជាតិដែលពាក់ព័ន្ធ។
2. **រួមបញ្ចូលកិច្ចព្រមព្រៀងស្តង់ដារ រួមជាមួយលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ លើការបំពេញតាម GIIP ទាក់ទងនឹងអ្នកខ្ចីដែលងាយរងគ្រោះ នៅក្នុងកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ សម្រាប់ការវិនិយោគលើបរិយាប័ន្នហិរញ្ញវត្ថុ។** ស្តង់ដារ GIIP ទាំងនេះគួរតែចងកាតព្វកិច្ចលើលក្ខខណ្ឌតម្រូវ ដែលអតិថិជនត្រូវបំពេញ និងរាយការណ៍នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ពួកគេ ហើយ IFC នឹងពិនិត្យតាមដាន ដើម្បីផ្ទៀងផ្ទាត់ការអនុវត្តរបស់ពួកគេ។